## កម្រងឯកសារស្តីពី

# ចរន្តអក្សរសិល្ប៍ខ្មែរ

## ចាប់ពីសម័យមុនគ្រិស្តសករាជ
## រហូតដល់សម័យបច្ចុប្បន្ន



អង្គរវត្តប្រាង្គប្រាសាទខ្មែរ


រៀបរៀងដោយ

លោក អៀង ពិសី



បោះពុម្ពលើកទី១

ការផ្សាយរបស់អ្នកនិពន្ធ

ព.ស ២៥៥៦ គ.ស ២០១២



រក្សាសិទ្ធិ

## ពាក្យផ្តើម

ចាប់តាំងពីខ្ញុំមានកំណើត ហើយត្រូវបានលោកឪពុកអ្នកម្ដាយ យកទៅឲ្យចូលរៀនសូត្រនៅសាលាចំណេះទូទៅមក អ្វីដែលខ្ញុំមានការចាប់អារម្មណ៍ជាងគេគឺការសិក្សានូវមុខវិជ្ជាអក្សរសាស្ត្រខ្មែរ។ ខ្ញុំស្រឡាញ់អក្សរសាស្ត្រ ហើយរិតតែស្រឡាញ់ទៀត នៅពេលដែលដឹងថា ខ្មែរជាជាតិមួយថ្លៃថ្នូរ ហើយមានវប្បធម៌ អរិយធម៌តាំងពីសម័យបុរាណនៃកំណើតជាតសាសន៍ខ្លួន។

អក្សរសាស្ត្រខ្មែរ មានការវិវត្តន៍ច្រើនណាស់ តែចំពោះអក្សរសិល្ប៍វិញ ក៏តែងផ្សារភ្ជាប់ជាមួយការរីកចម្រើននៃអក្សរសាស្ត្រដែរ។ ក្នុងគោលបំណងមួយដើម្បីលើកកម្ពស់ការសិក្សាអក្សរសិល្ប៍ខ្មែរបន្ថែមទៀត ទើបខ្ញុំត្រូវចងក្រងនូវសៀវភៅមួយក្បាលនេះឡើង។ សៀវភៅនេះ ទោះបីជាមានលោកអ្នកអក្សរសាស្ត្របានចងក្រងជាច្រើនមកហើយក៏ដោយ ក៏ប៉ុន្តែដោយសារមនសិការជាតិ ទើបខ្ញុំត្រូវតែចងក្រងបន្ថែមទៀត ដើម្បីទុកជាឯកសារសម្រាប់អ្នកសិក្សាយកមកត្រិះរិះពិចារណាទៅលើអក្សរសិល្ប៍ខ្មែរ។

សៀវភៅមួយក្បាលនេះ មិនសង្កត់ធ្ងន់ទៅលើអក្សរសាស្ត្រទេ តែអ្វីដែលជាវត្ថុបំណងដ៏ស្រួចស្រាវរបស់ខ្ញុំនោះ គឺការយកចិត្តទុកដាក់ទៅលើអក្សរសិល្ប៍តែប៉ុណ្ណោះ។

សៀវភៅមួយក្បាលនេះ បានឆ្លងកាត់ការស្រាវជ្រាវយ៉ាងយូរ ទើបសមិទ្ធផលដ៏ស្ដួចស្ដើងមួយនេះបានលេចចេញជារូបរាងឡើង។

ទោះបីជាយ៉ាងណា ក៏នៅមានកង្វះខាតជាច្រើនដែរ ដែលមាននៅក្នុងសៀវភៅមួយនេះ ទាំងសេចក្ដី ក៏ដូចជាផ្នែកអក្ខរាវិរុទ្ធដែរ សង្ឃឹមថា អស់លោកជាអ្នកសិក្សា ស្រាវជ្រាវមេត្តាអភ័យទោស ក៏ដូចជាជួយបញ្ចេញជាពាក្យរិះគន់សម្រាប់ការកែលម្អ នៅស្នាដៃលើកក្រោយឲ្យរិតតែជាមិត្តដ៏ល្អសម្រាប់មិត្តអ្នកសិក្សាគ្រប់ស្រទាប់ជាន់ថ្នាក់។

ព្រៃវែង ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១

អៀង ពិសី

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណចំពោះ

លោក **ផាន់ សុផល**

លោក **សួន ប៊ុនថា**

កញ្ញា **ជឹម ភារម្យ**

ដែលលោក នាងកញ្ញាបានជួយកែសម្រួលអក្ខរាវិរុទ្ធសៀវភៅនេះ តាំងពីដើមរហូតដល់ចប់។

គោរពជូនពរសុខភាពល្អ ជ័យជម្នះគ្រប់ភារកិច្ច!!...

# បញ្ជីអត្ថបទ


| ល រ | ចំណងជើង | ទំព័រ |
|---|---|---|
| ១ | អក្សរសិល្ប៍សម័យមុនគ្រិស្តសករាជ | ១ |
| ២ | បញ្ជីរាយនាមព្រះមហាក្សត្រខ្មែរ | ៣១ |
| ៣ | អក្សរសិល្ប៍សម័យមុនអង្គរ | ៣៥ |
| ៤ | អក្សរសិល្ប៍សម័យអង្គរ | ៤៣ |
| ៥ | អក្សរសិល្ប៍សម័យលង្វែក | ៩២ |
| ៦ | អក្សរសិល្ប៍សម័យឧដុង្គ | ១១៣ |
| ៧ | អក្សរសិល្ប៍សម័យអាណានិគមបារាំង | ២០៦ |
| ៨ | អក្សរសិល្ប៍សម័យសង្គមរាស្ត្រនិយម | ២៧៥ |
| ៩ | អក្សរសិល្ប៍សម័យសាធារណរដ្ឋខ្មែរ | ៣១៣ |
| ១០ | អក្សរសិល្ប៍សម័យកម្ពុជាប្រជាធិបតេយ្យ | ៣៤៤ |
| ១១ | អក្សរសិល្ប៍សម័យក្រោយថ្ងៃរំដោះ | ៣៧៦ |
| ១២ | អក្សរសិល្ប៍សម័យបច្ចុប្បន្ន | ៣៩៣ |

# អក្សរសិល្ប៍ខ្មែរសម័យមុនគ្រិស្តសករាជ

ខ្មែរមានកំណើតនៅលើផែនដីនេះ ដែលគេហៅថាស្រុកខ្មែរនៅទ្វីបអាស៊ីប៉ែកអគ្នេយ៍គឺតាំងពីឆ្នាំ៦០០០មុនគ្រិស្តសករាជមកម្ល េះៗ តាមការអះអាងរបស់លោក**ថាច់ ថ្វាន់** ក្នុងសៀវភៅ**ប្រវត្តិសាស្ត្រ ប្រជាជាតិខ្មែរ**" មុននោះខ្មែរជនជាតិមុណ្ឌៈ ដែលរស់នៅពាសពេញលើទ្វីបឥណ្ឌាតាំងពី៣០ ០០០ឆ្នាំមុនគ្រិស្តសករាជ គឺពី៣០០សតវត្សរ៍មុនព្រះយេស៊ូមកម្ល៉េះ ។ កាលឆ្នាំ១០ ០០០ មុនគ្រិស្តសករាជ ទ្វីបឥណ្ឌាត្រូវទទួលការលុកលុយពីពួកទ្រាវិឌ ឬតាមូល ដែលជាក្ងីផ្គខ្មៅសព្វថ្ងៃ ។ ដោយមិនព្រមទទួលការត្រួតពិនិត្យសង្កត់ពីពួកទ្រាវិឌ ជនជាតិមុណ្ឌៈបានគេចខ្លួន ចេញទៅគ្រប់ទិសទី ចូលព្រៃឡើងភ្នំ ឬក៏ចាកផុតពីទ្វីបឥណ្ឌាតែម្តងៗក្នុងចំណោមអ្នកខាងក្រោមនេះ មានមួយក្រុមបានមកដល់ស្រុកខ្មែរសព្វថ្ងៃកាលឆ្នាំ ៦០០០ មុនគ្រិស្តសករាជ ហើយពួកនេះបានគេហៅថា "ខ្មែរ" រហូតមកដល់ពេលបច្ចុប្បន្ន" ។

ការលើកឡើងខាងលើនេះមានសេចក្តីថា ទឹកដីខ្មែរសម័យនោះមិនទាន់មានមនុស្សរស់នៅទេៗ តាមពិតទឹកដីខ្មែរ ប្រហែលជាមានមនុស្សរស់នៅរួចទៅហើយ គ្រាន់តែថា មនុស្សមុណ្ឌៈគ្រាន់តែជាចំណូ

លថ្មីដែលមានអត្តចរិតប្រហាក់ប្រហែលគ្នាជា មួយអ្នកម្ចាស់ស្រុកតែប៉ុណ្ណោះ។ ការលើកឡើងខាងលើ ចង់បញ្ជាក់ថា ខ្មែរសម័យមុននោះគឺមិនមានទេ។ តាមរយៈ**រឿងព្រះថោងនាងនាគ** បានបញ្ជាក់ថា នាងនាគគឺជាម្ចាស់ស្រុកដែលបានរស់នៅលើទឹកដីនេះតាំងពីយូរយារណាស់មកហើយ។ នាងគឺជាម្ចាស់ស្រុក ដែលមាននគររបស់ខ្លួនដែរគ្រាន់តែសាច់រឿងបានបង្ហាញថា នគរនាង**នាគ**គឺស្ថិតនៅក្នុងស្ថានកុជង្គនាគនាបាតសមុទ្រឯណោះ។ ត្រង់ឃ្លាដែលថា នគរនាងនាគស្ថិតនៅបាតសមុទ្រមានសេចក្តីថា នគរនោះឯងមានកំណើតតាំងពីយូរយារណាស់មកហើយ។ ការករកើតនគរមួយៗមិនមែនចេះតែកើតបានភ្លាមៗទេ ទាល់តែមានការឯកភាពគ្នា ព្រមព្រៀងគ្នាទើបអាចបង្កបានជានគរពេញលក្ខណៈបាន។

នគរមួយនេះប្រជាជន ក៏ពិតជាមានកំណើតយូរបន្តទៅទៀត គ្រាន់តែថា នគរនោះមានការរីកចម្រើនឬយ៉ាងណាអាស្រ័យទៅលើការរស់នៅរបស់ក្រុម។ អ្នកនិពន្ធបានបង្ហាញតាមរយៈស្នាដៃរឿងថា នគរនេះជានគរនាគ។ ការបង្ហាញថា ជានគរសត្វ មានន័យថា នគរនេះប្រហែលជាមិនមានការដឹកនាំ ឬគ្រប់គ្រងបានត្រឹមត្រូវទេ ឬរបៀបរបបជាលក្ខណៈសភាវគតិជាទម្លាប់សត្វ តែសត្វនេះ ជាសត្វដែលមានអំណាចតេជៈខ្លាំងពូកែ ចេះដឹងខុសដឹងត្រូវមានសតិជាមនុស្សថ្លៃថ្នូរ។

ចំពោះរបៀបរបបនៃការរស់នៅ មនុស្សសម័យនោះក៏ពិតជាមិនអត់ទេអំពីសិល្បៈនៃការបំបាត់ទុក្ខ ឬសេចក្តីនឿយហត់។ គេប្រាកដជាមានសិល្បៈមួយសម្រាប់បម្រើការសប្បាយរីករាយជាមិនខាន។ ពួកគេក៏មានជំនឿទៅលើវត្ថុសក្តិសិទ្ធដែរ ដែលជំនឿនេះ ជួយឲ្យការរស់នៅមានលំអានផ្អែកអារម្មណ៍នឹងន មិនប្រាសចាកសេចក្តីភ័យខ្លាច មាន

ន័យថា មនុស្សមានកំណើតភ្លាម ក៏មានជួនភ្ជាប់ជាមួយនូវជំនឿភ្លាមដែរ ដូចជា ចេះស្រឡាញ់ ចេះគោរព ចេះខ្លាច ចេះស្ងើចសរសើរ ជាដើម។ បានជាថា ទាំងនេះជាជំនឿ ព្រោះអារម្មណ៍ជាអ្នកបង្កើតឲ្យមានភាពរំជួលនេះឡើងតាមរយៈផ្លូវចិត្ត។ មនុស្សខ្មែរកើតឡើងពីសម័យនោះ ទោះបីជាគំនិតខាងផ្នែកអក្សរសាស្ត្រខ្វះក៏ដោយ ក៏គេចេះដាក់នគរខ្លួនថា **នគរនាគ**ដែរ។

តាមន័យសម្រាយជាពាក្យទំនើប **នាគ** មានន័យថា ប្រសើរ, ចម្បង បរិសុទ្ធ។ តាមន័យនេះ ចង់បញ្ជាក់ថា ខ្មែរបានរៀបចំស្រុកទេសខ្លួនដោយប្រារព្ធជាពាក្យខ្ពង់ខ្ពស់ ថ្លៃថ្នូរណាស់ ជាជាតិដ៏ខ្ពង់ខ្ពស់បំផុតក្នុងប្រវត្តិសាស្ត្រជាតិខ្លួន ដែលមិនមានជាតិឯណាអាចមានអំណាចដូចខ្មែរបាន។ ទោះបីជាវិស័យអក្សរសាស្ត្រខ្លួនមិនទាន់មានលក្ខណៈស៊ីជម្រៅក្ដី ក៏ប៉ុន្តែខ្មែរចេះប្រារព្ធយកពាក្យថា នាគជាឈ្មោះនគរដ៏ពិសិដ្ឋរបស់ខ្លួនមកដាក់ដែរ។

ចំពោះពាក្យថា **ខ្មែរ**មានកំណើតនៅពេលណា មានការផ្លាស់ប្ដូរមកជាឈ្មោះនេះតាំងពីអង្កាល់? ហេតុដូចម្ដេចបានជាផ្លាស់ពីនគរនាគមកដាក់ជានគរខ្មែរនោះ ខ្ញុំស្រាវជ្រាវមិនទាន់ឃើញនៅឡើយ ហើយក៏មិនទាន់ពើបប្រទះឃើញមានឯកសារណាបានចារឹកច្បាស់លាស់ដែរ។ ដូច្នេះ ជាសំណូមពររបស់ខ្ញុំ សូមប្រិយមិត្តមេត្តាជួយគាស់រំលើងឲ្យឃើញពីកំណើតនៃពាក្យថា ខ្មែរនេះឲ្យបានដាក់ច្បាស់ដើម្បីទុកជាប្រយោជន៍រួមរបស់ជនជាតិយើងតទៅ។

ប្រសិនណាជាងាកមកមើល អំពីការកកើតទឹកដីប្រទេសខ្មែរយើងវិញ ឃើញថាប្រទេសខ្មែរមានកំណើតតាំងពីយូរយារណាស់មក

ហើយ។ ក្នុងសៀវភៅប្រវត្តិសាស្ត្រខ្មែររបស់លោកត្រឹង ងាលោកបានសរសេរបានគូសបញ្ជាក់យ៉ាងច្បាស់ថា "នៅសម័យស័កទី១ ភូមិភាគអាស៊ីអាគ្នេយ៍នេះបានប្រទះនឹងពំនើងផ្ទត់ពីរគឺ កាឡេដូន្យាង និងអ៊ែរស៊ីន្យាង ដែលបង្កើតឲ្យមានជួរភ្នំ និងខ្ពង់រាបនានានៅពាសពេញទឹកដីខ្មែរ។ ប៉ុន្តែពំនើងផ្ទត់ទាំងពីរនេះ ត្រូវលិចទៅវិញនៅចុងស័កទី៣ នៅដើមស័កទី២ ពំនើងផ្ទត់នេះ ក៏ងើបម្តងទៀតបង្កើតបានជាជួរភ្នំខ្ពង់រាបវាលទំនាប និងទន្លេ បឹងបួរដែលសណ្តូកពីជួរភ្នំហិមាល័យ រហូតដល់ភូមិភាគអាស៊ីអាគ្នេយ៍ទាំងមូល។ នៅស័កទី២នេះដែរ ដោយសារតែមានជំនោរនិងលំនាចទឹកនាំឲ្យទឹកដីខ្មែរខ្លះងើបឡើង ខ្លះទៀតលិចទៅក្នុងបាតសមុទ្រ។

នៅសតវត្សទី៣មុនគ្រិស្តសករាជ ទឹកសមុទ្របាននាចបន្តិចម្តងៗ រីឯទន្លេមេគង្គបានហូរនាំដីល្បាប់មកចាក់បង្កើតបានជាដីសណ្តរចុះទៅទិសខាងត្បូងៗ ទីតាំងនេះហើយគឺជាទឹកដីខ្មែរយើង"។

តាមការលើកឡើងខាងលើ ឃើញថា កំណកំណើតទឹកដីខ្មែរគឺមានតាំងពីយូរយារណាស់មកហើយ ចំណែកប្រជាជនវិញក៏មានកំណើតយូរយារណាស់មកហើយដែរ។ កាលណាមានទឹកដី ប្រជាជនក៏មុខតែមានរស់នៅមិនខានដែរ ព្រោះថា មនុស្សត្រូវរស់ជាមួយធម្មជាតិអាស្រ័យផលពីធម្មជាតិជានិច្ច។ តាមរយៈការស្រាវជ្រាវ ការរស់នៅរបស់មនុស្សខ្មែរ ឃើញថា ទីតាំងភូមិសាស្ត្រមួយចំនួននៅលើទឹកដីខ្មែរគឺមាននៅសេសសល់កម្ទេចកម្ទីជាច្រើនដែលជាសំណល់ប្រចាំជីវភាពរស់នៅប្រដាប់ប្រដាប្រើប្រាស់ប្រចាំថ្ងៃរបស់មនុស្សខ្មែរសម័យនោះ។ ករណីដូចជាមានការអះអាងក្នុងសៀវភៅប្រវត្តិសាស្ត្រខ្មែរថា ស្ថានីយជាច្រើនដែលមានសេសសល់ពីសម័យបុរេប្រវត្តិជាច្រើនកន្លែង នៅពាសពេញប្រទេសកម្ពុជាបានបញ្ជាក់យ៉ាងច្បាស់លាស់ណាស់ អំពីទឹកដីនិង

មនុស្សខ្មែរសម័យមុនប្រវត្តិសាស្ត្រ។ ក្នុងនោះរួមមានៈ

ស្ថានីយយុគថ្មបំបែករកឃើញដោយលោក សូវាំងនៅឆ្នាំ ១៩៦៣ មានស្ថានីយស្រែស្បូវ ផៃ ស្រែឫស្សី កន្ទួត ព្រែកទេរ ខ្សឹម ស្នួល ស្ថានីយទាំងនោះមានអាយុកាលប្រមាណពី៦០០ ពាន់ទៅ៦៨០ ពាន់ឆ្នាំមុនគ្រិស្តសករាជ ។

ស្ថានីយល្អាងស្ពាន (ខេត្តបាត់ដំបង) រកឃើញដោយលោក រ៉ូឡង់ ម៉ូរេ ឆ្នាំ១៩៦៥ ។ ស្ថានីយនេះមានអាយុកាលពី៦៨០០ - ៤៣០០ឆ្នាំ មុនគ្រិស្តសករាជ ។ ស្ថានីយភ្នំល្អាង(ខេត្តកំពត) រកឃើញដោយលោក កាបូណែល ឆ្នាំ១៩៦៧ ។ ស្ថានីយនេះមានអាយុកាលប្រមាណជា ៣៤២០ ឆ្នាំ មុនគ្រិស្តសករាជ ។

ស្ថានីយក្បាលរមាស(ខេត្តកំពត) រកឃើញដោយលោក បារី ឆ្នាំ ១៨៨១ ។ ស្ថានីយនេះមានអាយុកាលប្រមាណជា**៣៤២០ ឆ្នាំ** មុនគ្រិស្តសករាជ។ស្ថានីយសំរោងសែន(ខេត្តកំពង់ឆ្នាំង) រកឃើញដោយលោក រ៉ុក ឆ្នាំ១៨៧៦ លោកម៉ូរាឆ្នាំ ១៨៧៧ លោកដេម នៅឆ្នាំ១៨៨៨ និងលោក ហង់រីមង់ស៊ុយ នៅឆ្នាំ ១៩០២ - ១៩០៣ ។ ស្ថានីយនេះមានអាយុកាល**៣២៣០ - ១២៨០ឆ្នាំ**មុនគ្រិស្តសករាជ ។

ស្ថានីយតំបន់អង្គរ(ខេត្តសៀមរាប) រកឃើញដោយលោកប៉ែរណាត គីលីពគ្រោស្លីយេឆ្នាំ១៩៥៩។ ស្ថានីយភូមិមូល ស្រុកមេមត់ (ខេត្តកំពង់ចាម) រកឃើញដោយលោក ល្វីម៉ាល់ឡឺរ ឆ្នាំ១៩៥៩ និងលោក ប៉ែរណាតគីលីពគ្រោស្លីយេឆ្នាំ១៩៦២ ។ ស្ថានីយនេះមានអាយុកាលប្រមាណជាពី១៥០០ឆ្នាំ មុនគ្រិស្តសករាជ។

ស្ថានីយអង្គរបុរី (ខេត្តតាកែវ) រកឃើញដោយលោក មីរាមស្តាក ជនជាតិអាមេរិចនិងលោកជុចភឿន ជនជាតិខ្មែរនៅឆ្នាំ ១៩៩២។

ស្ថានីយនេះមានអាយុកាល៥០០-៤០០ឆ្នាំមុនគ្រិស្តសករាជ។

ស្ថានីយម្លូព្រៃ (ខេត្តព្រះវិហារ) រកឃើញដោយលោក បែលឡង់ ឆ្នាំ១៩៣៨។

ស្ថានីយអន្លង់ផ្តៅ(ខេត្តកំពង់ឆ្នាំង) រកឃើញដោយលោក ហង់រី-ម៉ង់ស៊ុយ ឆ្នាំ១៩០២។

ការអះអាងខាងលើបញ្ជាក់យ៉ាងច្បាស់លាស់ណាស់ថា ទឹកដីប្រទេសខ្មែរ និងជនជាតិខ្មែរមានកំណើតរាប់ពាន់ឆ្នាំមុនគ្រិស្តសករាជ គឺប្រមាណជា៦០០ ០០០ឆ្នាំមុនគ្រិស្តសករាជមកម្ល៉េះដែលទឹកដីក៏មានជួនភ្ជាប់ជាមួយនូវមនុស្សជាតិដែរ។ មនុស្សខ្មែរមានកំណើតយូរយារណាស់ចំណែកថា ការរស់នៅរបស់មនុស្សសម័យនោះមានលក្ខណៈបែបណាយើងបានដឹងខ្លះៗហើយថា ជីវភាពរស់នៅរបស់ពួកគាត់គឺពឹងផ្អែកទៅលើរបរបាញ់សត្វ ជាមូលដ្ឋានសម្រាប់ការរស់នៅ។ មនុស្សខ្មែរក៏ចេះប្រកបរបរកសិកម្ម មានដាំដំណាំជាលក្ខណៈចម្ការ ដូចជាចេះដាំដើមឈើហូបផ្លែ ចេះ ដាំបន្លែ ចេះចិញ្ចឹមសត្វសម្រាប់ជាកម្លាំងប្រើប្រាស់ ក៏ដូចជាសម្រាប់តម្រូវការក្នុងការហូបចុកប្រចាំថ្ងៃ។ ការរស់នៅត្រូវមានមេកើយជាអ្នកទទួលខុសត្រូវលើសុវត្ថិភាពរបស់ក្រុម។ អ្នកដែលក្លាយជាមេក្រុមលុះត្រាតែអ្នកនោះមានលទ្ធភាពអស្ចារ្យ ឬជាមនុស្សពូកែខាងសិល្បសាស្ត្រ មានកម្លាំងពលំមាំមួនអស្ចារ្យណាស់ និងមានបញ្ញាវាងវៃជាងអ្នកឯទៀតនៅក្នុងក្រុម។

មនុស្សចេញផុតពីជីវិតជាសត្វ។ គេចេះការពារខ្លួនពីសត្វសាហាវ ដោយប្រើមែកឈើ ឆ្អឹងសត្វ ដុំថ្មធ្វើជាអាវុធ។ ក្រោយមកគេរកឃើញភ្លើង រួចស៊ីសាច់ឆ្អិន រស់នៅក្នុងរូងភ្នំ ចេះដាំដំណាំនិងចិញ្ចឹមសត្វពួកគេចេះស្លៀកពាក់ស្បែកសត្វ ចេះត្រិះរិះពិចារណា គោរពបុព្វបុរស

ចេះសូនរូប គូររូបនៅជញ្ជាំងគុហា ចេះធ្វើឧបករណ៍ប្រើប្រាស់ពីថ្មបំបែកៗមនុស្សខ្មែរចេះយកថ្មទៅសំលៀងឲ្យមុតស្រួច ធ្វើឧបករណ៍ប្រើប្រាស់ដូចជា កាំបិត ព្រួញ រណារ។ គេចេះសង់ផ្ទះផុតពីដីនៅតាមមាត់ទឹក(ស្ទឹង ទន្លេ) ជាភូមិតូចឬធំ។ គេចេះចិញ្ចឹមសត្វឆ្កែ គោ សេះ ចៀម ជ្រូក មាន់ ទា ។ ក្រៅពីនោះគេចេះធ្វើក្អម ឆ្នាំង ចាន ភាជន៍ពីដីផុតៗបន្ថែមពីលើនេះទៅទៀត គេចេះត្បាញសរសៃរុក្ខជាតិធ្វើជាសម្លៀកបំពាក់ ដាំស្រូវ និងពោតយកមកប្រើប្រាស់ក្នុងការរស់នៅដែរ។មនុស្សចេះប្រើលោហៈដូចជា ស្ពាន់ លង្ហិន សំណប៉ាហាំង ទង់ដែង និងដែកធ្វើជាឧបករណ៍ប្រើប្រាស់ និងគ្រឿងអលង្ការផ្សេងៗ ។ មនុស្សចេះប្រើប្រាស់សត្វជំនួយកម្លាំង ចេះធ្វើកសិកម្មយ៉ាងស្ទាត់ជំនាញ ពិសេសចេះត្បាញកញ្ឆើ ល្អី សម្លៀកបំពាក់ពីសំឡី គ ធ្វើស្នាចៗជីវភាពរស់នៅនាសម័យនោះមានលក្ខណៈដូចយើងសព្វថ្ងៃដែរ(តំបន់ដាច់ស្រយាល)។

មនុស្សសម័យបុរេប្រវត្តិកម្ពុជា ឈប់រស់នៅជាចរកជនទៀតហើយ។ ពួកគេមានភូមិនិងមានផ្ទះតូចៗ សង់ខ្ពស់ផុតពីដី។ ចេះប្រកបរបរដាំស្រូវ ពោត និងប្រើកណ្តៀវច្រូតកាត់។

គេចេះផ្សាំងសត្វគោ ជ្រូក ឆ្កែ មាន់ជាដើម។ តែផលិតផលដាំដុះនិងការចិញ្ចឹមសត្វនេះពុំគ្រប់គ្រាន់សម្រាប់ចិញ្ចឹមជីវិតទេ។ ដូច្នេះគេដើរបរបាញ់សត្វ នេសាទត្រី ចាប់ត្រកួត អណ្តើក ពស់លៀស គ្រំ ខ្យងខ្ចៅយកមកធ្វើម្ហូបនិងបេះផ្លែឈើផងដែរ។

មនុស្សខ្មែរសម័យបុរាណមានជំនឿលើគុណ ទោស បាប បុណ្យស្គាល់អំពើល្អអាក្រក់ ចេះគោរពដូនតា អ្នកតាចាស់ស្រុក ដើមឈើធំៗព្រលឹងខ្មោចៗ ពួកគេបញ្ចុះសពឲ្យបញ្ឈរជង្គង់ ឬដេកផ្ងារ សាក់គ្រឿងអលង្ការ ប្រដាប់ប្រដាប្រើប្រាស់ ព្រោះគេមានជំនឿថាជីវិតមិនសាប

សូន្យទេ។ ពួកគេមានភាសារបស់ខ្លួនមុនឥណ្ឌាចូលស្រុកម្ល េះគឺភាសាខ្មែរ។

ប្រជាជនខ្មែរដែលរស់នៅលើទឹកដីនេះ ឬមានឈ្មោះថាជានាគនោះមិនមានអរិយធម៌រីកចម្រើនណាស់ទេ គឺមានត្រឹមតែអរិយធម៌ប្រចាំជាតិសាសន៍គេប៉ុណ្ណោះ។ ពួកគេមិនមានអក្សរសម្រាប់កត់ត្រាភាសាដែលនិយាយទាក់ទងប្រាស្រ័យគ្នាឡើយ។ ផ្នែកគ្រឿងបរិក្ខាប្រើប្រាស់ គឺខ្មែរយើងចេះសង់ផ្ទះអំពីឈើ និងមានភាជន៍សម្រាប់ចម្អិនម្ហូបអាហារប្រចាំថ្ងៃផងដែរ។

ទាក់ទងជាមួយសិល្បៈអក្សរសិល្ប៍ ដែលជាប្រធានបទដ៏ស្រួចស្រាវរបស់យើងនោះគឺថា ទោះបីជាការរស់នៅមិនទាន់ការរីកចម្រើនឧត្តមយ៉ាងណាក្តី ក៏ប៉ុន្តែផ្នែកវិស័យសិល្បៈ ខ្មែរមានប្រចាំជាតិសាសន៍ខ្លួនណាស់ទៅហើយ ដូចជាគេចេះច្រៀង ចេះរាំ ចេះប្រគំតន្ត្រី។

## ចម្រៀង:

ទោះបីជាមិនមានភស្តុតាងបញ្ជាក់យ៉ាងត្រចះត្រចង់ អំពីបញ្ហានេះ ក៏ប៉ុន្តែខ្ញុំអាចសន្និដ្ឋានបានថា ចម្រៀងដែលប្រើសម័យនោះគឺសម្រាប់តែការកំដរបរិយាកាសបំបាត់ទុក្ខកង្វល់ សេចក្តីឈឺចាប់បណ្តាលមកពីការរស់នៅជាមួយធម្មជាតិ ដែលធម្មជាតិបង្កការលំបាកផ្សេងៗក្នុងជីវភាពរស់នៅដូចជាទឹកជំនន់ រន្ទះបាញ់ រំពារ...។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ក៏នៅមានបទចម្រៀងខ្លះ សរសើរពីធម្មជាតិដ៏ស្រស់បំព្រងដែរ ឬសុំឲ្យធម្មជាតិជួយចម្រើនខ្លួន។ ដូចជាគេច្រៀងថា សុំឲ្យផលភោគផ្លែឈើនានាកើតយ៉ាងច្រើន ដើម្បីបានជាចំណីដ៏ប្រពៃសម្រាប់ក្រុមគេសម្រាប់គ្រួសារគេ។ ផ្នត់គំនិតនេះហើយ ជាហេតុនាំឲ្យខ្មែរនឹងអាច

បង្កើតសាសនាបានយ៉ាងឆាប់រហ័សមិនខាន តែត្រូវចំណាយពេលយូរណាស់ ព្រោះនាគឬខ្មែរសម័យនោះ មានការត្រិះរិះពិចារណាណាស់មុនពេលបានបង្កើតផលិតផលខ្លួន។ មានមតិមួយទៀតយល់ថា ខ្មែរមានគំនិតស៊ីកណាស់ មុនសម្រេចចិត្តធ្វើអ្វីមួយ ឬពេលធ្វើអ្វីមួយគឺនៅត្រាំត្រែងធ្វើដោយយកចិត្តទុកដាក់ ជាសាច់ការទៀតផង។ ការលើកឡើងនេះក៏សមហេតុផលដែរ ព្រោះថា ប្រសិនណាជាគេប្រឹងតែផលិតដោយយកចិត្តទុកដាក់ជាសមិទ្ធផលសម្រេចតែម្តងនោះ គឺមិនត្រឹមត្រូវទេប្រសិនណាជាមិនមានការសាកល្បងទេនោះ។ អ្វីដែលកើតឡើង ក៏នឹងងាយទទួលរងផលប៉ះពាល់ទៅវិញដែរ។

ទាក់ទងជាមួយជំនឿ ខ្មែរឬនាគ ហាក់ដូចជាមិនសូវមានបទចម្រៀងទេ តែខ្មែរបែរជាចេះគោរពដើមឈើធំៗ ដោយគិតថា នៅដើមឈើនោះមានវត្ថុអ្វីម្យ៉ាងដែលមានឫទ្ធិអស្ចារ្យមកតាំងសណ្ឋិតនៅ ដូចជាគេឃើញភ្លើងហោះនៅទីនោះ គេគិតថា មានអ្វីដែលអស្ចារ្យមកនៅទីនោះ ទើបគេប្រាយប្រាប់អ្នករស់នៅមិនឲ្យទៅប៉ះពាល់ទេ ដូចជាទៅបេះផល្លានុផលនោះ ឬទៅបៀតបៀនកាប់មែក ស្លឹកឡើយ។ ការពិចារណានេះ ក៏នាំឲ្យគេត្រូវយកអ្វីមួយមកតាំងទុកជាគ្រឿងសម្គាល់ថា ជាកន្លែងដ៏សក្តិសិទ្ធ ដូចជាគេដាក់តាំងថ្មភ្នំជាដើម។

ជាប់ទាក់ទងនឹងនេះ គេបានដឹងចរិតខ្មែរសព្វថ្ងៃនេះថា ទោះបីជាការរស់នៅសម័យបច្ចុប្បន្នមានការរីកចម្រើនយ៉ាងណា ក៏គេនៅតែមានជំនឿទៅលើដើមឈើធំៗថា មានវត្ថុសក្តិសិទ្ធិនៅទីនោះ ដែលគេយល់ថាវត្ថុសក្តិសិទ្ធិនោះ គឺមានដូចជាខ្មោច ព្រាយបិសាច ឬអារក្ខអារក្សទេវតាជាដើម។ ខ្មែរយើងក៏យកដុំថ្មដូចកាលពីរាប់ម៉ឺនឆ្នាំមុនមកដាក់តម្កល់ជាការសម្គាល់ថា ជាកន្លែងសក្តិសិទ្ធដែរ។ លើសពីនេះទៅទៀត ខ្មែរក៏

បានសាងខ្លួម ដែលសព្វថ្ងៃថា ជា**ពានទេវតា**មកដាក់តម្កល់អុជធូបបូជាទៅវិញ។ ការធ្វើនេះ ក៏ព្រោះតែយើងអនុវត្តន៍តាមដូនតា បុព្វបុរសខ្មែរយើងកាលពីពាប់រយសតវត្សមុនដែលវាជាជំនឿមួយបាននៅជាមួយផ្នត់គំនិតខ្មែរតាំងពីពាប់ម៉ឺនឆ្នាំ មិនមែនទើបនឹងកើតនៅពេលនេះទេ។

ទាក់ទងជាមួយសិល្បៈចម្រៀងនេះដែរ ឃើញថា ចម្រៀងបុរាណខ្មែរ ហើយដែលកូនខ្មែរចេះច្រៀងគ្រប់គ្នានោះ គឺតែងតែមានភ្ជាប់ជាមួយពាក្យថា **អើយ**ជានិច្ច។ ពាក្យថា **អើយ...អឺងអើយ... ហាអឺ។**...នេះគឺជាទំនុកចម្រៀងខ្មែរតាំងពីសម័យបុរាណ ដែលខ្មែរសម័យបុរេប្រវត្តិធ្លាប់បានច្រៀងនៅក្នុងសង្គមរស់នៅរបស់ខ្លួន ដែលមិនមានជាតិសាសន៍ឯណាដូចទេ។ ទំនុកចម្រៀងមួយនេះ មានអាយុកាលចំណាស់ណាស់។ ខ្ញុំសន្និដ្ឋានថា ខ្មែរសម័យបុរាណ ឬសម័យបុរេប្រវត្តិ គឺពិតជាមានទំនុកបទបុរាណជាឃ្លាជាប់ទាក់ទងជាមួយពាក្យខាងលើនេះមិនខាន។

នៅប្រទេសខ្មែរជនជាតិភាគតិចខ្មែរ ដូចជា ក្នុង ជង សម្រែជាដើម ទំនុកបទចម្រៀងរបស់គេតែងតែមានពាក្យថា **អ៊ើយ** ដែលពាក្យនេះហើយ ជាទំនុកបទចម្រៀងទំនុកខ្មែរសម័យបុរាណ ដែលបុព្វបុរសខ្មែរបានយកមកប្រើនៅក្នុងការរៀបបទទំនុកចម្រៀង ឬច្រៀងកម្សាន្តហើយដែលពេលបច្ចុប្បន្នបានហៅមកថា **អើយ... អឺងអើយ**...រហូតដល់សព្វថ្ងៃនេះ ក៏បានជាប់ជាទំនុកបទខ្មែរសម័យបច្ចុប្បន្នយកមកប្រើដែរ។

ចម្រៀងខ្មែរសម័យបុរាណ ប្រជាជនខ្មែរនិយមច្រៀងជាបទកំណាព្យកាព្យឃ្លោងប្រកបដោយការចាប់ចុងចួនគ្នា តែមិនមានក្បួនច្បាប់គ្រប់គ្រាន់នៅឡើយទេ។ ការចាប់ចុងចួននៅពេលនោះ គឺមានការចាប់ចុងចួនមិនមានសណ្តាប់ធ្នាប់ មានន័យថាគេច្រៀងតាមតែទម្លាប់នឹកឃើញប៉ុណ្ណោះរួចធ្វើការផ្តោះផ្តងគ្នា ចំពោះបទណាដែលមានការ

ចោទឆ្លើយឆ្លងគ្នា។ ការលើកឡើងនេះ គឺខ្ញុំសង្កេតឃើញថា ប្រជាជនខ្មែរសម័យបច្ចុប្បន្នក្តី ជំនាន់ជីតាទួតខ្ញុំក្តី គឺពេលដែលគាត់ច្រៀងចម្រៀងឲ្យចៅៗស្តាប់ ការច្រៀងនោះ គឺគាត់មិនបានរៀបគម្រោងទេ នឹកឃើញភ្លាមគាត់ច្រៀងតែម្តង ធ្វើយ៉ាងណាឲ្យតែមានការចាប់ចុងចួនគ្នាបានល្អប៉ុណ្ណោះគឺរួចរាល់ទៅហើយ។ ចំណែកម្តាយខ្ញុំ គាត់តែងច្រៀងចម្រៀងបំពេរប្អូនខ្ញុំ ខ្ញុំស្តាប់ឮគាត់បានរៀបចំណាប់ចួនគ្នាបានល្អណាស់។ ចម្រៀងនេះគាត់ក៏ធ្លាប់ច្រៀងបំពេរខ្ញុំដែរ។ ម្តាយខ្ញុំគាត់រៀនបានទាបណាស់ គឺថ្នាក់ទី១១ជំនាន់សង្គមរាស្ត្រនិយមប៉ុណ្ណោះ គឺប្រមាណជាថ្នាក់ទី២សម័យបច្ចុប្បន្នប៉ុណ្ណោះ។ ការច្រៀងរបស់គាត់ គឺមានចំណាប់ចួនគ្នាបានល្អណាស់ហើយពីរោះទៀតផង។ ខ្ញុំចូលចិត្តស្តាប់គាត់ច្រៀងបំផុត។ចម្រៀងនោះនៅតែជិតជាប់ក្នុងវិញ្ញាណខ្ញុំជានៅឡើយ។

ប្រសិនណាជាងាកមកសម្លឹង មើលពីកំណាកំណើតចម្រៀងចាប៉ីខ្សែដៀវរបស់ព្រះគិរម្យកាសាអ៊ូហៅង៉ុយវិញ ឃើញថា អ្នកព្រះគិរម្យបានច្រៀងចម្រៀងនេះ ប្រកបដោយការចាប់ចួនគ្នាបានល្អឥតខ្ចោះដែលសុទ្ធសឹងជាបទកំណាព្យដ៏ថ្លៃថ្លា នឹងពីរោះបំផុត។ ចំណែកចម្រៀងអាយ៉ៃវិញ ក៏ឃើញថា អ្នកច្រៀងក៏មិនមានការសរសេរព្រាងអ្វីទុកជាមុនដែរ គឺនឹកភ្លាមច្រៀងភ្លាមតែម្តង។ ការរពូកនេះ ប្រសិនណាជាស្តាប់ចាប់ចួនកំណាព្យឃើញថា មានលក្ខណៈល្អឥតខ្ចោះតែម្តង។ ខ្មែរសម័យប្រវត្តិសាស្ត្រ ក៏មានបទចម្រៀងកំណាព្យកាព្យឃ្លោងកើតចេញពីឧត្តមគតិអក្សរសាស្ត្រដ៏ថ្លៃថ្លាដែរ។ ការច្រៀង ទោះបីជានឹកភ្លាមច្រៀងភ្លាមក៏នៅតែរក្សាចំណាប់ចួនបានល្អដដែល។ ម្យ៉ាងវិញទៀត ប្រសិនជាផ្អែកទៅតាមការបង្ហាញរបស់លោក**លី សុមុនី** នៅក្នុងសៀវភៅ**កំណាព្យខ្មែរ**បានគូសបញ្ជាក់ថា កំណាព្យខ្មែរពិតជាមានប្រភពជាយូរលង់មក

ហើយ គឺតាំងពីមុនឥណ្ឌាចូលមកម្ល៉េះ ឆន្ទៈសំស្រ្កឹតគ្រាន់តែជាកត្តាសម្រាប់ពិគ្រោះ ក្នុងការរៀបចំកែលម្អក្បួនកំណាព្យខ្មែរឲ្យបានត្រឹមត្រូវប៉ុណ្ណោះ។ កំណាព្យខ្មែរយើងមានលក្ខណៈប្លែកស្រលះពីកំណាព្យសំស្រ្កឹតដែរ។ តាមការអះអាងនេះ សបញ្ជាក់ថា ទោះបីជាប្រភេទកំណាព្យខ្មែរមានលក្ខណៈគ្រាន់តែជាហេតុក៏ដោយ ក៏អាចឲ្យខ្ញុំសន្និដ្ឋានបានថា កេរតំណែលដែលបន្សល់ទុករហូតមកដល់សព្វថ្ងៃនេះគឺ កំណាព្យទាំងនោះបានប្រែរូបរាងមកជាកំណាព្យកម្រងកែវ នៅពេលបច្ចុប្បន្ននេះដែរ

នៅទីនេះបានជាខ្ញុំលើកយកតែប្រភពកំណាព្យមកនិយាយ ក៏ព្រោះតែកំណាព្យគឺជាប្រភពដំបូងនៃទំនុកបទចម្រៀង។ បទចម្រៀងខ្មែរ គឺមានចំណាប់ចូនរណ្តំណែងណងគ្នាណាស់ហេតុដូច្នេះហើយបានជាគេមានសង្កេតឃើញបទចម្រៀងខ្មែរ ចែកជាប្រភេទទៅតាមបរិយាកាសនៃបទចម្រៀងផ្សេងៗពីគ្នា។

ខ្ញុំមិនអាចដឹងបានថា តើខ្មែរសម័យបុរាណមានទំនុកបទចម្រៀងបុរាណមុនគ្រិស្តសករាជយ៉ាងណានោះទេ គ្រាន់តែមានទំនុកជាហេតុដែលអាចធ្វើជាទ្រឹស្តីបទតែប៉ុណ្ណោះ ហើយអ្វីដែលបានលើកឡើង ក៏ប្រាកដជាអាចនាំឲ្យយើងគិតបានថា ជនជាតិខ្មែរលើ កាលណាមានចម្រៀងមនោសញ្ចេតនា ឬជាបទអ្វីក៏ដោយទាក់ទងដល់ជីវភាពរស់នៅរបស់គេម្នាក់ៗ ទំនៀមទម្លាប់... ពួកគេតែងច្រៀងមានទំនុកពាក្យថា អើយ អឺងអើយ ហាអើយជានិច្ច។ យើងត្រូវទទួលស្គាល់ថា ខ្មែរសម័យមុនគ្រិស្តសករាជ ក៏តែងមានមនោសញ្ចេតនា ការសប្បាយ រំភើបញាប់ញ័រដែរ ដូច្នេះកម្រងមនោសញ្ចេតនាតាមរយៈបទចម្រៀងក៏ត្រូវមានសម្រាប់ញុំាងពិធីជានិច្ច ហើយសិល្បៈចម្រៀងនេះទៀតសោត ក៏ខ្មែរមានលំនាំសម្រាប់ការបង្កើតសិល្បៈតែងកាព្យមួយទៀត នៅពេលដែល

មានអរិយធម៌ឥណ្ឌាផ្សាយចូលមក នៅអំឡុងសតវត្សទី១នៃគ្រិស្តសក-ពជ។

ជារួមសេចក្តីមក ខ្ញុំអាចសន្និដ្ឋានបានថា ជីវភាពខ្មែរសម័យបុរាណ គឺមិនអាចផ្តាច់បានពីបញ្ហាមនោសញ្ចេតនាតាមរយៈបទចម្រៀងបានទេ ពីព្រោះ មនុស្សកើតមកនៅលើលោកនេះ តែងរុំជុំពាក់ដោយមនោសញ្ចេតនាណាស់ មនុស្សត្រូវការសប្បាយ ត្រូវការកម្សាន្ត ដូច្នេះបទចម្រៀងក៏គង់តែមានសម្រាប់លម្ហែអារម្មណ៍ជាពុំខាន ហើយទំនុកបទដែលបានយកប្រើនោះ គឺមានតែទំនុកចម្រៀងដែលមានប្រើពាក្យថា **អើយ អឺងអើយ**នេះជាមិនខាន ព្រោះមានតែពាក្យទាំងនេះហើយដែលជាមូលដ្ឋាន នៃការបង្កើតមនោសញ្ចេតនានៃបទចម្រៀងនៅក្នុងវិស័យសិល្បៈចម្រៀងរបស់ខ្មែរ ហើយមានតែជនជាតិខ្មែរទេមានទំនុកបទបែបនេះ។ ជនជាតិផ្សេងទៀតដែលជាជនជាតិក្បែរខាង ហើយបានទទួលឥទ្ធិពលពីខ្មែរស្ទើរតែទាំងស្រុងនោះ ក៏មានទំនុកបទនេះសម្រាប់ប្រើនៅក្នុងបទចម្រៀងរបស់គេដែរ។

### របាំ

របាំមានន័យថា ល្បែងច្រៀងរាំ ។ ជនជាតិខ្មែរសម័យមុនគ្រិស្តសករាជ ទោះបីជាស្ថិតក្នុងផ្នត់គំនិតជាលក្ខណៈបុរាណយ៉ាងណាក៏ដោយ ក៏ខ្មែរសម័យនោះនៅមានសិល្បៈរាំច្រៀងដែរ។ របាំកាលពីសម័យនោះអាចឲ្យខ្ញុំសន្និដ្ឋានថា មនុស្សខ្មែរសម័យបុរាណមានការចេះរាំជាលក្ខណៈវង់ ហើយការរាំគឺជាក្រុមៗ។ ការសម្តែងសិល្បៈរបាំនេះគឺច្រើនតែប្រព្រឹត្តទៅនៅពេលសម្រាកពីការងារ ជួបជុំគ្នាដែលយើងហៅថា **ជប់លៀង**។ និយាយដល់បញ្ហានេះ តើខ្មែរសម័យបុរេ មានពិធីជប់

លៀងដែរឬទេ? ខ្ញុំគិតថា ប្រាកដជាមាន ព្រោះនៅពេលគេបានសម្រេចកិច្ចការអ្វីមួយ គេតែងតែមានសេចក្តីសប្បាយរីករាយ ហើយការនេះ គេក៏ប្រាកដជាមានជួបជុំគ្នានៅក្នុងក្រុមសប្បាយរីករាយ មានការផឹកស៊ី រាំរែក ស្រែកអាឡេអាឡូ ដែលជារឿងធម្មតាសម្រាប់ជីវភាពរស់នៅដ៏សាមញ្ញសម្រាប់ខ្មែរសម័យបុរេប្រវត្តិ។

ខាងលើ ខ្ញុំនិយាយដល់ការផឹកស៊ី តើមនុស្សខ្មែរសម័យបុរេមានអ្វីសម្រាប់ផឹកស៊ី។ ការផឹក គឺផឹកស្រាដែលជាគ្រឿងស្រវឹងនាំឲ្យមនុស្សបាត់សតិ ហើយក៏នាំការសប្បាយសម្រាប់មនុស្សដែលមានតម្រូវការផឹកស៊ីនេះដែរ។ ខ្ញុំគិតថា មនុស្សខ្មែរសម័យនោះ ទាំងស្រីទាំងប្រុសគឺគេចេះផឹកស្រាទាំងអស់គ្នា។ ស្រាដែលគេផឹក គឺជាស្រាម្យ៉ាងដែលយកចេញពីដើមឈើ ស្ងួកឈើលាយផ្សំជាមួយទឹកដែលមានសារធាតុស្រវឹងដែរ រួចផឹកយ៉ាងសប្បាយរីករាយនៅពេលដែលគេជួបជុំគ្នា។

## តន្ត្រី

ខ្មែរមានចម្រៀង មានរបាំ ចុះអ្វីទាំងនេះ នៅពេលដែលចាប់ផ្តើមបានអ្វីមកកំដរបរិយាកាសទៅវិញ? គឺមានតែតន្ត្រីទេជាគ្រឿងដែលអាចទាញទាក់អ្នកសិល្បៈរបាំមករាំទៅតាមចង្វាក់បទបាន។

ខ្ញុំគិតថា តន្ត្រីខ្មែរសម័យបុរេមានតែឧបករណ៍ដំទេ ចំណែកខាងផ្លុំ កួត គឺមិនមានឡើយ។ ឧបករណ៍សម្រាប់ដំ គេបានអ្វីសម្រាប់ដំ? នេះជាសំណួរដែលយើងត្រូវតែមានការចាប់អារម្មណ៍។ ខ្មែរសម័យនោះ ទោះបីជាមានការរស់នៅជារបៀបសត្វក៏ដោយ ក៏គេចេះមានបញ្ញាយកឈើមូលមកដំគ្នាបង្កើតបានជាស្នូរសំឡេងមួយកើតឡើងដែរ។ ស្នូរនេះ ហើយនាំឲ្យពួកគេស្រែកអាឡេអាឡូទៅតាមការដំរង្វើល ញឹក ហើយ

សភាពអ្វីអរក៏ត្រូវបានកើតឡើងតំណាលគ្នានិងតន្ត្រីជារបៀបអ្នកភ្នំដែរ។

ខ្ញុំមិនមានអ្វីដែលត្រូវបានអធិប្បាយឲ្យវែងឆ្ងាយ អំពីតន្ត្រីនេះទេ ព្រោះមិនឯកសារណាមួយបញ្ជាក់ ពីការរស់នៅរបស់ខ្មែរសម័យបុរេប្រវត្តិឡើយ ពិសេសទាក់ទងជាមួយបញ្ហាអក្សរសិល្ប៍នេះតែម្តងរឹតតែមានការខ្វះខាតថែមទៀត។ បញ្ហាអសកម្មយ៉ាងណា។ ក៏អាស្រ័យទៅលើការស្រាវជ្រាវបន្តទៅទៀត ដើម្បីជាកិត្តិយសមួយរបស់ខ្មែរ បញ្ជាក់ថាខ្មែរ មានកំណើតតាំងពីយូរលង់ណាស់មកហើយ កុំបីច្រលំថា ខ្មែរគឺជាឥណ្ឌា ដូចអ្វីដែលអ្នកស្រាវជ្រាវបរទេសមួយចំនួនអះអាងនោះឡើយ ព្រោះគេមិនមែនមានចរិតជាខ្មែរ ហើយការរស់នៅរបស់ខ្មែរនៅតំបន់ឆ្ងាយដាច់ស្រយាលយ៉ាងណាក៏គេមិនបានដឹង មិនបានភ្លក្សរសជាតិដែរ គឺមានតែខ្មែរទេដែលដឹង ដែលស្គាល់។ ការរស់នៅដ៏សែនលំបាក និងការប្រកាន់របបរស់នៅជាលក្ខណៈបុរាណ គួបផ្សំជាមួយទំនៀមទម្លាប់របស់ជនជាតិខ្មែរភាគតិច ក៏ជាសន្ទស្សន៍មួយសម្រាប់ការគិតពិចារណាដល់ការរស់នៅរបស់បុព្វបុរសខ្មែររាប់លានឆ្នាំមុនគ្រិស្តសករាជដែរ។

ជាបន្តទៅទៀត ខ្ញុំនាំអារម្មណ៍មិត្តអ្នកអានទៅស្គាល់ជនជាតិមួយនៅប្រទេសឥណ្ឌា ដែលអ្នកស្រាវជ្រាវយើងយល់ថា គឺជាបុព្វបុរសរបស់ខ្មែរ នោះគឺជនជាតិ**មុណ្ឌៈ** ។ នៅក្នុងសៀវភៅ**ប្រវត្តិសាស្ត្រប្រជាជាតិខ្មែរ** រៀបរៀងដោយលោក **ថាច់ ត្នាន់** បានសរសេរថា " ជនជាតិមុណ្ឌៈជាជនជនជាតិដែលបានកើតមុនគេបង្អស់នៅលើទឹកដីស្រុកឥណ្ឌា ។ គេបានទទួលស្គាល់ថា ជនជាតិនេះមានជីវិតរស់នៅលើទ្វីបឥណ្ឌាយ៉ាងតិចណាស់ក៏៣០ ០០០ឆ្នាំមុនគ្រិស្តសករាជមកទៀត គឺមុនព្រះយេស៊ូ។ សព្វថ្ងៃគេឲ្យឈ្មោះជនជាតិនេះថា និស្ហាដា តែជនជាតិឥណ្ឌាច្រើនហៅថា **អធីវស៊ី** វិញដោយពាក្យនេះមានន័យថា ជនជាតិដើម ឬជនជាតិដំបូង។

នៅច្រើនពាន់ឆ្នាំមុនព្រះយេស៊ូ ជនជាតិមុណ្ឌៈ មានជីវភាពនិងវប្បធម៌ យ៉ាងខ្ពង់ខ្ពស់រួចទៅហើយ។ ជនជាតិឥតនេះមានជំនឿលើសាសនា ឬព្រះមួយអង្គណាទេ។ គេកាន់របបមាតានិយម គេគោរពម្ដាយនិងឪពុក គោរពដី គោរពទឹក ហើយមានជំនឿទៅលើអ្នកតា។

ជនជាតិមុណ្ឌៈ បានចាប់ផ្ដើមចេញពីទ្វីបឥណ្ឌារវាងឆ្នាំ១០ ០០០ មុនព្រះយេស៊ូ ក្រោយពេលដែលមានពួកតាមូលចូលមកលុកលុយ។ ក្រុមដែលបង្កើតបាននគរថ្មីដែលហៅថា នគរខ្មែរ និងជាតិមួយថ្មីហៅថា ជាតិខ្មែរនោះ បានមកដល់កន្លែងទឹកដីសព្វថ្ងៃរវាងឆ្នាំ ៦០០០មុនគ្រិស្តសករាជ។

ការអះអាងដូច្នេះ ខ្ញុំមិនឯកភាពទេ ព្រោះថាជនជាតិខ្មែរមានកំណើតយូរយារណាស់មកហើយ បានជានិយាយដូច្នេះពីព្រោះសម្អាងទៅលើប្រវត្តិទឹកដីខ្មែរ គឺមានអាយុកាលប្រមាណជា៦០០ ០០០ឆ្នាំមុនគ្រិស្តសករាជមកម្ល៉េះ។ ប្រសិនណាជាទឹកដីនេះមានកំណើតយូរយាមកហើយ យើងអាចសួរថា តើមានមនុស្សរស់នៅដែរឬទេ? អ្នកនោះមានវប្បធម៌យ៉ាងណាដែរ?

នេះជាបញ្ហាមួយដែលអ្នកសិក្សា ត្រូវចេះពិចារណាឲ្យបានវែងឆ្ងាយ។ ជនជាតិខ្មែរ ដូចអ្វីដែលខ្ញុំបានលើកឡើងខាងលើ គឺពីមុនតំបូង គេមានឈ្មោះថា ជានគរនាគ។ ពាក្យថា នគរនាគនេះ មិនមែនជាការដាក់ឈ្មោះដោយខ្លួនឯងទេ គឺអ្នកសិក្សាយើងជំនាន់ក្រោយមកទៀតជាអ្នកប្រសិទ្ធនាមដាក់ឲ្យ។ ពួកនាគមានវប្បធម៌ពិសេសមួយដែលជាការបង្កើតខ្លួនឯង មានអរិយធម៌ដ៏ត្រចះត្រចង់របស់ខ្លួនរួចជាស្រេច គឺការចេះគោរពអ្នកមានគុណ គោរពញាតិមិត្តជាចាស់ព្រឹទ្ធាចារ្យជាដើម។ អំឡុងឆ្នាំ៦០០០ មុនគ្រិស្តសករាជ ជនជាតិមុណ្ឌៈបានភៀសខ្លួនមកពី

ឥណ្ឌា ក៏បានមកប្រសប់ជាមួយនាគខ្មែរ រួចបានសម្រេចបង្កើតនគរថ្មីមួយមានឈ្មោះថា **នគរខ្មែរ** ។ ជនជាតិទាំងពីរមានវប្បធម៌អរិយធម៌ប្រហាក់ប្រហែលគ្នា ដូច្នេះបានជាពួកគេចាប់ដៃបង្កើតបានជានគរថ្មីមួយដែលមានលក្ខណៈពិសេស ដោយឡែកពីមុណ្ឌៈជាជនជាតិដើមតែមិនទាន់មានអក្សរប្រើនៅឡើយ។ អ្វីដែលគេបានរក្សាទុកនៅដូចដើមរួមមាន៖

-ការគោរពម្ដាយឪពុក ដែលត្រូវបានចាត់ទុកជាអ្នកមានគុណ។ ខ្មែរនាគ ក៏មានទំនៀមទម្លាប់យ៉ាងនេះដែរ លុះមកដល់ជនជាតិមុណ្ឌៈដែលមានវប្បធម៌ស្រដៀងគ្នាដែរ ទើបពួកគេរក្សាទុកដដែល។ បានជាខ្ញុំនិយាយដូច្នេះ ព្រោះសម្គាល់ថា ជនជាតិនាគគោរពមាតាបិតាណាស់ដូចជានាងនាគគោរពតាមបិតានៅឋាននាគ ស្រឡាញ់ជនជាតិខ្លួន ឲ្យតម្លៃទៅលើសីធម៌ប្រពៃណីខ្លួនជាធំ។ ចំណែកជនជាតិមុណ្ឌៈ តាមរយៈការអះអាងរបស់លោក**ឋាច់ ត្វាន់** នៅក្នុងសៀវភៅប្រវត្តិសាស្ត្រប្រជាជាតិខ្មែរក៏មានការអះអាងស្រដៀងគ្នានេះដែរ។ ជនជាតិមុណ្ឌៈគោរព នឹងឲ្យតម្លៃទៅលើបុព្វការីជនមានមាតាបិតាជាដើមដូចនាគដែរ។ អាស្រ័យដោយមានលក្ខណៈដូច្នេះហើយបាន ជាគេសម្រេចរក្សាទុកទំនៀមទម្លាប់នេះនៅដដែល។

-គោរពផែនដី និងទឹក ជនជាតិខ្មែរមានការគោរពទៅលើម្ចាស់ទឹកដីដូចជាគោរពទៅលើអ្នកតា ដោយគេសង្កេតឃើញថា ខ្មែរនាគចេះយកដុំថ្មមកតាំងជាអ្នកតាមានឫទ្ធិមួយ នៅកន្លែងច្បាស់លាស់រួចគេនាំគ្នាគោរពបូជាដូចជាមានតង្វាយ ព្រមទាំងរក្សាចិត្តគំនិតមិនទៅប៉ះពាល់នៅកន្លែងវត្ថុសក្ដិសិទ្ធនោះជាដាច់ខាត។ ចំណែកការគោរពបូជាទឹកវិញគឺខ្មែរនាគគិតថា ទឹកដ៏មានអំណាចនេះ ប្រាកដជាមានម្ចាស់គ្រប់គ្រង

ជាមិនខាន ហើយនោះគឺជាជាអ្នកដែលមានអំណាចបេស្កាណាស់ទៀតផង ដូចអ្វីដែលខ្មែរបានអះអាងនៅក្នុងរឿង **អ្នកតាទឹកអ្នកតាភ្នំ**ជាដើម។ ការនិយាយបែបនេះ មិនមែនមានន័យថា ខ្ញុំផ្តេកផ្តួលទៅលើជំនឿតាមរយៈរឿងព្រេងទេ តែប្រសិនណាជាគិតពីបញ្ហានេះ រឿងអ្នកតាទឹក អ្នកតាភ្នំមិនមានអ្នកអក្សរសាស្ត្រណាម្នាក់អះអាងថា កើតឡើងនៅអំឡុងឆ្នាំណាទេ គេគ្រាន់តែដឹងថា វាជារឿងព្រេងប៉ុណ្ណោះដែលមិនមានកាលបរិច្ឆេទសរសេរច្បាស់។ ខ្ញុំគិតថា រឿងនេះគឺកើតឡើងនៅគ្រាដែលខ្មែរនាគ មានការយល់ឃើញដំបូងពីបាតុភូតធម្មជាតិថាមានលក្ខណៈអស្ចារ្យជាងកម្លាំងមនុស្ស។ ពិធីបុណ្យបណ្តែតប្រទីបខ្មែរក៏មានជាប់ទាក់ទងជាមួយព្រះគង្គានេះដែរ។ ជនជាតិមុណ្ឌៈក៏មានការគោរពបូជាទៅលើទឹក ដីដែរដូចជាគេគិតថា ព្រះធរណីនិងគង្គា គឺមានអ្នកមានបុណ្យមានអំណាចបេស្កាគ្រប់គ្រង គឺព្រះនាងគង្គីង និងក្រពើជានិមិត្តរូប។ ពួកគេនិយាយថា ព្រះនាង**គង្គីង**គឺជាព្រះធរណី។ អាស្រ័យដោយជនជាតិទាំងពីនេះ មានលំនាំជំនឿប្រហាក់ប្រហែលគ្នាទើបបានជាគេត្រូវចាប់ដៃគ្នាបង្កើតនគរខ្មែរនេះឯង។

ទាក់ទងដល់បញ្ហាដែលនាគ និងមុណ្ឌៈចាប់ដៃគ្នាបង្កើតបានជានគរថ្មីមួយហៅថា **ខ្មែរ**នោះ ប្រព្រឹត្តទៅតាមរបៀបណា ខ្ញុំមិនអាចបកស្រាយបានទេ ។ ក៏ប៉ុន្តែ គួរគិតពិចារណាថា កាលពីជំនាន់នោះ មុនពេលឈានទៅដល់ការរួបរួមគ្នាបង្កើតជានគរមួយៗ ជាលើកដំបូង អ្នកចំណូល និងអ្នកម្ចាស់ស្រុកត្រូវមានសកម្មភាពប្រយុទ្ធគ្នានិងគ្នាសិនកាលណាដឹងចាញ់ឈ្នះរួចហើយ ទើបគេរិះរកផ្លូវសម្រាប់ដោះស្រាយជាក្រោយ។ មកពីបញ្ហានេះហើយ បានជាពួកគេត្រូវប្រែឈ្មោះជាតិសាសន៍ខ្លួនពីនាគ និងពីមុណ្ឌៈមកជា**ខ្មែរ**។

ពាក្យថា **ខ្មែរ**មានន័យយ៉ាងពីរោះ តាមការប្រែក្នុងវចនានុក្រមថា **មនុស្សមានសេចក្តីក្សេម។**

តើនរណាជាអ្នកដាក់ឈ្មោះថា ខ្មែរ? គឺអ្នកសិក្សា មិនមែនជានាគ ឬមុណ្ឌៈជាអ្នកដាក់ឈ្មោះទេ ព្រោះថា ខេមរៈ ឬខ្មែរនេះជាភាសាបាលី ដូច្នេះជនជាតិមុណ្ឌៈ ឬនាគសម័យនោះមិនទាន់ទទួលឥទ្ធិពលភាសាបាលីនៅឡើយ។ បានជាគេដាក់ឈ្មោះថា ជានគរខ្មែរ ពីព្រោះគេដឹងថា នគរមួយនេះ មនុស្សរស់នៅប្រកបដោយសេចក្តីសុខណាស់មិនមានបញ្ហាស្មុគស្មាញអ្វីកើតឡើងជាមួយជនជាតិខ្លួនឡើយ។ អាស្រ័យដោយការរស់នៅមានសេចក្តីសុខដូច្នេះ ទើបត្រូវនិងភាសាបាលីថា ខេមរៈ ក៏បណ្តាលឲ្យគេដាក់ឈ្មោះថា ខេមរៈ ឬខ្មែរហូតមក។

នៅសម័យមុនគ្រិស្តសករាជ នគរខ្មែរគឺមានការរៀបចំរចនាសម្ព័ន្ធជាលក្ខណៈស្រុកទេសរួចជាស្រេចទៅហើយ។ គេបានដឹងថា ខ្មែរសម័យនោះមានទឹកដីធំទូលាយណាស់ ខាងជើងទល់ជាមួយភ្នំយុន ណាន់ ខាងត្បូងទល់ជាមួយនគរម៉ាឡេស៊ី ខាងកើតទល់ជាមួយសមុទ្រចិន ខាងលិចទល់ជាមួយឈូងសមុទ្របឹងហ្គាល។ ខ្មែរសម័យមុនគ្រិស្តសករាជប្រកាន់របបមាតាធិបតេយ្យ ដូច្នេះទើបមាននៅសេសសល់ពាក្យមេរហូតប្រើប្រាស់រហូតមកដល់សព្វថ្ងៃនេះ។

នៅសម័យនោះហើយដែលនគរខ្មែរ ត្រូវបានដឹកនាំដោយក្សត្រីមួយព្រះអង្គព្រះនាមនាងសោម៉ា ដែលខ្មែរនិយមហៅថា នាងសក់ក្រអូប ឬហៅថា នាងនាគ។ ខ្ញុំគិតថា នាងនាគ គ្រាន់តែជាមេកន្ទ្រាញដ៏មានប្រាជ្ញាវាងវៃម្នាក់តែប៉ុណ្ណោះ ព្រោះនាងអាចរួបរួមនគរមករស់នៅក្រោមការគ្រប់គ្រងនៃអ្នកដឹកនាំតែម្នាក់។ ខ្មែរសម័យនោះ ខ្ញុំគិតថាមិនទាន់រីកចម្រើនទេ គ្រាន់តែយើងមានហេតុនៃសន្ទស្សការរីកចម្រើនតែ

ប៉ុណ្ណោះ ។ ភស្តុតាងដែលបញ្ជាក់ថាខ្មែរមានការរីកចម្រើនដូចជា៖

**វិស័យនយោបាយ:** ប្រទេសខ្មែរមានការរៀបចំរចនាសម្ព័ន្ធស្រុកខ្លួនក្រោមការគ្រប់គ្រង របស់អ្នកដឹកនាំស្រីដែលមានពូជពង្សជាវង្សត្រកូលខ្ពង់ខ្ពស់ថាជា**នាគ**។

**វិស័យកសិកម្ម:** ដើម្បីបំពេញតម្រូវការក្នុងរបរដាំស្រូវ ដំណាំរួមផ្សំនានា ខ្មែរចេះយកកម្លាំងសត្វព្រៃមកប្រើការជំនួសមនុស្ស ។ ទោះបីជាសត្វព្រៃកាចសាហាវយ៉ាងណា ឬលូងក្នុងការអូសទាញយ៉ាងណា ក៏ខ្មែរចេះផ្សាំងវា ឲ្យសម្របសម្រួលជាមួយមជ្ឈដ្ឋានមនុស្សបានដែរ។ មួយវិញទៀត មនុស្សខ្មែរចេះធ្វើស្រែបង្កបង្កើនផលដោយមិនរង់ចាំទឹកភ្លៀងជាអំណោយរបស់មេឃទេ មនុស្សខ្មែរចេះធ្វើស្នាចសម្រាប់បាចទឹកបញ្ចូលស្រែ ខ្មែរចេះយកពូជឈើហូបផ្លែនានាមកដាំនៅជិតផ្ទះដើម្បីងាយស្រួលប្រមូលផលមកបំពេញតម្រូវការរស់នៅ។

**វិស័យវប្បធម៌:** មនុស្សខ្មែរ ទោះបីជារកមិនទាន់ឃើញមាស ពេជ្រដែលកប់បាត់នៅក្នុងដីក្តី ក៏ប៉ុន្តែគេអាចយកសំបកខ្យង ខ្ចៅ អង្កាំមកច្នៃធ្វើជាអលង្ការសម្រាប់លម្អកាយដែរ។

**ជំនឿ:** ខ្មែរចេះកប់ខ្មោចដាក់ក្នុង**ក្រឡ** ព្រោះគេគិតថា ការកប់ខ្មោចដាក់ក្នុងក្រឡ គឺជាការគោរពចំពោះព្រលឹងអ្នកស្លាប់មិនឲ្យលំបាកនៅក្នុងធរណី ក៏ហាក់ដូចជាឲ្យអ្នកស្លាប់ទៅកាន់ភពថ្មីដោយសុខសាន្ត។ ក្រៅពីនេះ ខ្មែរនៅមានជំនឿលើដើមឈើណាធំៗដែលបានដុះតែឯងថានៅទីនោះមានអ្នកតាអ្វីម្យ៉ាង ដែលមានឫទ្ធិអំណាចអស្ចារ្យគ្រប់គ្រងថែរក្សា ដូច្នេះគេក៏ហាមប្រាមកូនចៅ ឬមនុស្សម្នាទាំងឡាយក្នុងគ្រួសារឬក្នុងភូមិមិនឲ្យទៅបំផ្លិចបំផ្លាញវាចោល ព្រមទាំងបានយកថ្មភ្នំទៅដាក់ជាការចំណាំកន្លែងនោះទៀតផង ។ ជំនឿនេះ ក៏នៅមានជាប់ក្នុងផ្នត់

គំនិតខ្មែរសម័យបច្ចុប្បន្ននេះដែរ ព្រោះគេតែងសង្កេតឃើញថា ទីណាដែលមានដើមឈើធំៗ ស៊ុបទ្រុបទីនោះភាគច្រើនត្រូវបានប្រជាជនខ្មែរសង់ពនទេវតាដាក់តម្កល់ មានពេលខ្លះនៅក្នុងពនទេវតានោះមានដាក់ថ្មភ្នំពីរបីដុំទៀតផងសម្រាប់បង្ហាញថា ទីនេះមានអ្នកតាម្ចាស់ស្រុកជាអ្នកថែរក្សាឲ្យសុខ ឲ្យលាភ។

**វិស័យអក្សរសាស្ត្រ:** ទោះបីជាខ្មែរមិនទាន់មានអក្សរសាស្ត្រសម្រាប់កត់ត្រាពីព្រឹត្តិការណ៍ជាតិក៏ដោយ ក៏វិស័យអក្សរសាស្ត្រយើងមិនមែនអត់សោះរង់ចាំការចម្លងពីឥណ្ឌាដែរ។ មនុស្សខ្មែរចេះចំណាំរឿងកាលបុរាណ ដូចជារឿងរនា រឿងផ្ការីក រឿងស្សោជាដើម។ ការចំណាំនេះ រហូតមកដល់ពេលបច្ចុប្បន្នខ្មែរនៅរក្សាទុកដូចដើមមិនបោះបង់ចោលទេ។

**វិស័យអក្សរសិល្ប៍:** ខ្មែរមិនទាន់មានអក្សរសាស្ត្រសម្រាប់កត់ត្រាតែខ្មែរនៅតែមានរឿងនិទាន សម្រាប់ជាតិសាសន៍ខ្លួនរួចជាស្រេចមានការរៀបចំជាតួអង្គ កាលអាកាសបុរាណសំខាន់ណាស់សម្រាប់ការសិក្សារបស់មនុស្សខ្មែរជំនាន់ក្រោយទៀតផង។ កស្តុតាងដែលបញ្ជាក់ថា ខ្មែរមានអក្សរសិល្ប៍ដ៏ផូរផង់របស់ខ្លួនគឺខ្ញុំរកឃើញរឿងមួយដែលស្វែងយល់ពីការយល់ដឹងដំបូងរបស់មនុស្សខ្មែរ។ រឿងនោះមានចំណងជើងថា **"រឿងអ្នកតាទឹក អ្នកតាភ្នំ"** ។

ជាបន្តទៅទៀត ខ្ញុំនឹងលើកយកអក្សរសិល្ប៍រឿងអ្នកតាទឹក អ្នកតាភ្នំមកសិក្សាដើម្បីឲ្យឃើញថា ការយល់ឃើញដំបូងរបស់មនុស្សខ្មែរសម័យបុរេមានលក្ខណៈអស្ចារ្យប៉ុណ្ណា ការរស់នៅមានជួបប្រទះការលំបាកយ៉ាងណា ហើយគេខំពុះពារជម្នះការលំបាកនោះដល់កម្រិតណា។

## រឿង អ្នកតាទឹក អ្នកតាភ្នំ

កាលពីព្រេងនាយ មានតាយាយពីរនាក់ប្ដីប្រពន្ធរស់នៅឯស្រុកជនបទឆ្ងាយមួយ គាត់មានកូនក្រមុំម្នាក់មានរូបសម្រស់ស្អាតជាង់គេនៅក្នុងភូមិៗ ថ្ងៃមួយ មានអ្នកតាពីរនាក់ ម្នាក់ជាអ្នកតាភ្នំ ម្នាក់ទៀតជាអ្នកតាទឹក បានចូលមកស្ដីដណ្ដឹងកូនក្រមុំតាយាយនោះ។

តាយាយបានបង្គាប់ថា អ្នកណានាំបណ្ណាការមកដល់មុនគេ គាត់នឹងលើកកូនក្រមុំឲ្យទៅអ្នកនោះជាប្រពន្ធភ្លាមៗ អ្នកតាទាំងពីរបានវិលមកដល់លំនៅវិញ ។ បន្ទាប់ពីនោះមក អ្នកតាភ្នំក៏បានពីងពាក់ចាស់ទុំនៅក្នុងភូមិនាំបណ្ណាការមកដល់ផ្ទះតាយាយមុនគេ។ តាយាយរក្សាពាក្យសច្ចៈ ក៏បានលើកកូនក្រមុំឲ្យទៅអ្នកតាភ្នំ ហើយក៏បានរៀបការកូនឲ្យទៅ។ប្ដីប្រពន្ធទាំងពីរក៏បានរួមរស់ជាមួយគ្នាមានសេចក្ដីសុខចាប់តាំងពីពេលនោះតទៅ។

ចំណែកអ្នកតាទឹក ដែលបាននាំបណ្ណាការមកដល់ក្រោយអ្នកតាភ្នំ គាត់មានសេចក្ដីក្ដៅក្រហាយ នឹងខឹងតាយាយណាស់ ត្រលប់ទៅដល់ផ្ទះវិញ ក៏បានបង្កើតជាទឹកជំនន់ ដើម្បីជន់ឲ្យលិចគូស្នេហ៍កិរិយាថ្មីថ្មោងនេះ ក៏ប៉ុន្តែអ្នកតាភ្នំ ក៏បានជប់ភ្នំបង្កើតបានជាដីខ្ពស់ទប់ទល់ជាមួយទឹកជំនន់វិញ ដោយមានការចូលរួមពីសំណាក់ប្រជាជននៅក្នុងភូមិផងដែរ ទើបដីក៏ចេះតែខ្ពស់មិនមានទឹកលិចបាន។ អ្នកតាទឹកប្រើងតម្ទើងទឹកឲ្យរឹតតែខ្លាំង អ្នកតាភ្នំក៏រឹតតែជញ្ជូនដីជាមួយអ្នកស្រុកទប់ទល់ទឹកជំនន់កាន់តែខ្ពស់មិនឲ្យទឹកលិចបាន។

នៅគ្រាបន្ទាប់មក អ្នកតាទឹកអស់អំណាច ក៏បានសុំចុះចាញ់អ្នកតាភ្នំ ហើយខ្លួនក៏បានដកទឹកចេញ លែងមករំខានការរស់នៅរបស់របស់អ្នកតាភ្នំជាមួយប្ដីប្រពន្ធទៀត។ ចាប់តាំងពីពេលនោះមក អ្នកតាភ្នំក៏បានរួមរស់ជាមួយប្រពន្ធបានសុខអន្លើផតទៅ។

## អត្ថន័យរឿង

នៅក្នុងរឿងអ្នកតាទឹកអ្នកតាភ្នំ ឃើញថា ផ្ទៃរឿងទាំងមូល ការប្រើប្រាស់ពាក្យពេចន៍មានលក្ខណៈងាយអាន ងាយយល់ព្រោះអ្នកនិពន្ធបានរើសយកតែពាក្យសម្ដីងាយអាន ងាយសិក្សាសម្រាប់មនុស្សគ្រប់វ័យ។ ពាក្យពេចន៍ដែលបានប្រើគឺមានលក្ខណៈសាមញ្ញឥតខ្ចោះតែមានការស៊ីជម្រៅទៅក្នុងស្រទាប់សង្គមយ៉ាងខ្លាំង។ នៅក្នុងសន្ដានចិត្តប្រជាជន អ្នកនិពន្ធខ្មែរដែលបាននិពន្ធរឿងនេះឡើង គឺលោកមានគោលបំណង ប្រៀបធៀបទៅក្នុងសង្គមយ៉ាងជ្រៅសម្រាប់ការត្រិះរិះពិចារណាសិក្សានៃអ្នកជំនាន់ក្រោយ។

## អ្នកតាទឹក

នៅក្នុងផ្នត់គំនិតអ្នកនិពន្ធខ្មែរសម័យនោះ ទោះបីជាការសិក្សារៀនសូត្រនៅមានកម្រិតក៏ដោយ ក៏ប៉ុន្តែឧត្តមគតិខាងការគិតពិចារណាមានទំហំវែងឆ្ងាយណាស់។ ការរស់នៅរបស់ប្រជាជនមានភាពភ័យខ្លាចគ្រប់ពេលវេលា មានន័យថា ការគម្រាមកំហែងពីធម្មជាតិបានធ្វើបាបប្រជាជន និងការរស់នៅរបស់គេឲ្យអសន្តិសុខ ឈឺចាប់ ទុក្ខព្រួយ នឹងជួបគ្រោះទុរភិក្សស្ទើរតែរៀងរាល់ឆ្នាំ។នៅក្នុងផ្នត់គំនិតខ្មែរសម័យបច្ចុប្បន្ន គេអាចគិតថា ភាពអន្តរាយទាំងនេះ គឺបណ្ដាលមកពីប្រជាជនបង្កបង្កើន

ផលខុសរដូវកាល។ ខែវស្សារដូវទឹកតម្លើង ប្រជាជនដែលរស់នៅតាមបណ្តោយមាត់ទន្លេចេះតែធ្វើស្រូវ ធ្វើចម្ការ ការធ្វើរបៀបនេះ នឹងមិនអាចឲ្យពួកគាត់ទទួលផលផ្លែមានទេ។

សម្រាប់ផ្នត់គំនិតខ្មែរសម័យបុរាណវិញ ឃើញថា ទោះបីជាមានបញ្ហាទឹកជំនន់ដ៏អាក្រក់ក្តី ក៏នៅក្នុងសេចក្តីសង្ឃឹមរបស់គាត់ នៅតែនឹកគិតថា គង់នៅមានថ្ងៃណាមួយ មនុស្សអាចទប់ស្កាត់មហន្តរាយនេះបានជាស្ថាពរពុំខាន។

ការស្រាវជ្រាវរបស់ពួកគាត់សម័យនោះ នៅមានកម្រិត ពួកគាត់មិនអាចចេញទៅតាមដានរកប្រភពទឹក ដែលនាំឲ្យមានអន្តរាយនេះបានឡើយ គាត់តែងចំណាំថា ឲ្យតែដល់រដូវមួយច្បាស់លាស់ គឺទឹកកំណាចនេះ តែងតែចេញមកអុកឡុករាតត្បាតដំណាំប្រជាជនជានិច្ច។ ប្រជាជនខ្មែរសម័យនោះ គិតថា ទឹកនេះប្រាកដជាមានម្ចាស់ដ៏មានអំណាចចេស្តាណាម្នាក់នៅពីក្រោយជាពុំខាន ហេតុដូច្នេះហើយបានជាគាត់ជឿថា **អ្នកតាទឹក**នេះឯងជាប្រភពនៃការបង្កើតទឹកជំនន់។

គេអាចមានចម្ងល់ដែរថា ចុះហេតុអ្វីបានជាប្រជាជនមិនព្រមដាក់ឈ្មោះអ្វីក្រៅពីពាក្យថា អ្នកតាទឹកនេះទៅ? មិនចាំបាច់មានចម្ងល់ទេ ពីព្រោះខ្មែរសម័យនោះ មិនទាន់ស្គាល់អ្វីក្រៅពីអ្នកតាទេ។ អ្នកតាគឺជាអ្នកដ៏អស្ចារ្យបំផុតនៅក្នុងសន្តានចិត្តមនុស្សជំនាន់នោះ។ អ្នកតា គឺជាអ្នកដែលមានឫទ្ធិអំណាចអស្ចារ្យគ្មាននរណាអាចរារាំងបាន។ តែអ្នកតានេះក៏មានអ្នកតាអាក្រក់ដូចជាអ្នកតាទឹកដែរ ហើយអ្នកតាទឹកក៏មិនប្រាកដថាអាក្រក់សម្រាប់ពួកគាត់ដែរ ពីព្រោះការរស់នៅប្រចាំថ្ងៃគឺគាត់ត្រូវការទឹកសម្រាប់ប្រើប្រាស់។ ហេតុដូច្នេះហើយ អ្នកតាទឹកអាចជាគំនិតសម្គាល់ពីភាពល្អប្រសើរសម្រាប់ការរស់នៅរបស់គាត់ដែរ តែអ្នកតាទឹក

នេះក៏ជាការសម្គាល់ថា ជាប្រភពនៃទុក្ខកាលណាអ្នកតាបញ្ចេញកំហឹងស្រោចស្រពមកលើប្រជាជនខ្លាំងក្លា ពេលនោះប្រជាជនទាំងមូលនឹងត្រូវទទួលនូវមហន្តរាយពុំខាន។

ន័យមួយទៀត អ្នកតាទឹកគឺតំណាងឲ្យគ្រោះមហន្តរាយដែលបង្កឡើងដោយទឹកជំនន់ ហើយជាសត្រូវរបស់ដំណាំផងទាំងឡាយរបស់ប្រជាជនសម័យបុរាណ។

## អ្នកតាគ្នំ

អ្នកតាគ្នំ គឺជាអ្នកតំណាងសេចក្តីសង្ឃឹមដ៏មុតស្រួច របស់ប្រជា-ជនសម័យបុរាណ។ ទោះបីជាការគម្រាមកំហែងពីសំណាក់ទឹកជំនន់ក៏ដោយ ក៏សេចក្តីសង្ឃឹមមួយត្រូវតែកើតមានចំពោះអ្នករស់គ្នាពុំខាន។ ការសង្ឃឹមនេះ ត្រូវបានអ្នកនិពន្ធខ្មែរសម័យនោះយកមកប្រាយប្រាប់អ្នកអានថា អ្នកតាគ្នំគឺជាសេចក្តីសង្ឃឹមដ៏មុតស្រួចរបស់អ្នកជំនាន់នោះ។ ខ្ញុំមិនបានដឹងថា អ្នកតាគ្នំ នៅក្នុងសន្តានចិត្តប្រជាជនខ្មែរគឺជាអ្វីទេ តែតាមការស្មានប្រមាណមក ឃើញថា អ្នកតាគ្នំគឺជាបង្អែកផ្នែករូបារម្មណ៍មួយរបស់ប្រជាជន ដែលគេជឿជាក់ថា មានទោះបីជាអ្នកតាទឹកប្រែមកជាផ្ញើបាបរូបគេយ៉ាងណាក៏ដោយ ក៏នៅមានអ្នកតាគ្នំជាអ្នកតានៃសេចក្តីសង្ឃឹមរង់ចាំជួយជានិច្ច។ ប្រជាជនត្រូវតែហ៊ានតស៊ូជាមួយការលំបាកនៅក្នុងជីវិត។ សេចក្តីលំបាក គឺជាហេតុដែលបណ្តាលមកពី អ្នកតាទឹកដែលខឹងសម្បារជាមួយពួកគេ ហើយបានព្យាយាមបំផ្លាញពួកគេក្នុងកលប្រើងតម្លើងទឹកជំនន់ឲ្យមកលិចភូមិឋានពួកគាត់។

អ្នកតាគ្នំ គឺជាសការៈល្អមួយនៅពីក្រោយនៃចលនាតស៊ូយកជ័យជម្នះរបស់ប្រជាជន។ កម្លាំងចិត្តនេះ បញ្ជាប្រជាជនក្នុងន័យមនសិការ

ជាតិ មនសិការគ្រួសារថា ត្រូវតែតស៊ូឡើង អ្នកតាទឹកមិនអាចបៀតបៀនសេចក្តីសុខបានទេ ព្រោះមានអ្នកតាភ្នំជាអ្នកនៅពីខាងក្រោយចាំជួយជាកម្លាំង។ ការតស៊ូនេះ យូរទៅគង់តែបានជ័យជម្នះដូចសេចក្តីប្រាថ្នាជាពុំខាន។ អ្នកតាភ្នំនេះ នាំឲ្យប្រជាជនក្នុងបុរាណសម័យ មានទំនុកចិត្ត គេនឹកថា អ្នកតាភ្នំគឺនៅក្នុងចិត្តគេជានិច្ច។ អ្នកតាភ្នំគឺជា អ្នកដឹកនាំដ៏ល្អប្រសើរម្នាក់ ហើយប្រជាជនមានទំនុកចិត្តលើ នឹងប្រគល់សេចក្តីស្រឡាញ់រាប់អានជូនគ្រប់ៗគ្នា។

ក្រៅពីជាអ្នកដឹកនាំដ៏ប្រពៃ អ្នកតាភ្នំគឺជាឋាមពលរបស់ប្រជាជនខ្មែរសម័យរឿងនេះ មានន័យថា ទោះបីជាការរស់នៅជួបប្រទះសេចក្តីភ័យខ្លាច ដោយសារតែទឹកជំនន់ដែលគេយល់ថាជាឫទ្ធិអំណាចរបស់អ្នកតាទឹកក៏ពិតមែន ក៏ប៉ុន្តែអ្នកនិពន្ធបានបញ្ជាក់ថា អ្នកតាភ្នំ ដែលតំណាងម្ចាស់ទឹកដីនោះ នៅចាំរក្សាការពារប្រជាជនគ្រប់ពេលវេលា។

កំហឹងអ្នកតាទឹកក្នុងការបញ្ចេញឫទ្ធិទឹកជំនន់នោះ គឺជាអំពើសង្សឹកនៃអ្នកដឹកនាំម្នាក់ដែលប្រជាជនធ្លាប់គិតថាល្អ ហើយបែរជាអាក្រក់វិញ ។ គេបានយកអំណាចមកបញ្ចេញគាបសង្កត់ប្រជាជន តែអ្នកតាភ្នំត្រូវបញ្ចេញភាពខ្លាំងក្លា ជាមួយប្រជាជនទប់ស្កាត់អំពើដ៏លាមកនេះ។ អ្នកតាភ្នំ គឺជាអ្នកដឹកនាំម្នាក់ ដ៏មានប្រជាប្រិយភាពសម្រាប់ផ្តល់ជាទឹកក់ក្តៅដល់ប្រជាជនដែលរស់នៅក្នុងសង្គមមួយ។

**តាយាយ**

តួអង្គតាយាយនៅក្នុងរឿងអ្នកតាទឹកអ្នកតាភ្នំ គេអាចនិយាយបានថា អ្នកទាំងពីរគឺជាតំណាងឲ្យប្រជាជនដែលរស់នៅក្នុងសង្គមនោះ។ កាលណាមានកូនក្រមុំរូបស្អាត គឺតែងមានអ្នកចោមរោមស្រ

ឡាញ់ ជាច្រើន។ ហេតុការណ៍មួយដែលបានកើតឡើង គឺទំនាស់រឿងបណ្ដាលមកពីពិធីមង្គលការតែម្ដង។

ភាពភ័យខ្លាចរបស់តាយាយក្នុងរឿង គឺជាភាពភ័យខ្លាចរបស់ប្រជាជនទូទៅដែលការរស់នៅត្រូវជួបបញ្ហាជាច្រើនក្នុងការរស់នៅ។ ក៏ប៉ុន្តែ តាយាយមានភាពក្លាហានហ៊ានប្រឈមជាមួយការពិត ខណៈដែលអ្នកតាទឹកនាំបណ្ដាការមកក្រោយអ្នកតាភ្នំ។

តាយាយគាត់ចេះប្រមើមើលមនុស្សម្នាក់ ដែលគាត់ត្រូវប្រគល់ការទុកចិត្តជាអ្នកដឹកនាំទៅឲ្យគេ។ កូនក្រមុំ គឺជាសេចក្ដីសង្ឃឹមតែមួយគត់របស់ជរាទាំងពីរ។ អ្នកនិពន្ធ ត្រូវតែឲ្យអ្នកតាភ្នំទទួលបាននាងជាភរិយារក្សាគ្នាលុះថ្ងៃអវសាន។

## កូនក្រមុំតាយាយ

នាងក្រមុំនេះគឺជានិមិត្តរូបដ៏ប្រពៃមួយដូចអ្វី ដែលបាននិយាយខាងលើរួចមកហើយថា នាងគឺជាសេចក្ដីសង្ឃឹមតែមួយគត់របស់ប្រជាជនបុរាណ។ នាងក្រមុំនេះគឺជាបេះដូងរបស់ប្រជាជន របស់គ្រួសារ។ ដោយមានឧត្ដមគតិយ៉ាងនេះហើយ បានជាអ្នកនិពន្ធត្រូវពិពណ៌នាថា នាងជានារីដ៏ស្រស់ស្អាតម្នាក់គ្មានក្រមុំឯណាមកប្រដូចបានទេ។ សេចក្ដីក្រមុំបរិសុទ្ធ គឺជាសុភមង្គលមួយនៃគ្រួសារសង្គមជាតិ។នាងបានជាទីពឹងដ៏កក់ក្ដៅរបស់ប្រជាជននៅទូទាំងប្រទេស។

## តួអង្គដទៃទៀត

តួអង្គដទៃទៀត គឺសម្ដៅដល់បណ្ដាអ្នកស្រុកទាំងឡាយដែលរស់នៅជាមួយតាយាយក្នុងសង្គមមួយដែលមានអ្នកដឹកនាំអំណាចមានទិស

ដោយបញ្ច្រាស់គ្នា។ ផ្នត់គំនិតរបស់ពួកគាត់សម័យនោះ គឺគោរពស្រឡាញ់អ្នកដឹកនាំដែលពោរពេញទៅដោយព្រហ្មវិហារធម៌ មានសេចក្ដីចេះអាណិតស្រឡាញ់ប្រជាជន យកចិត្តទុកដាក់ជាមួយសុខទុក្ខប្រជាជន។

អ្នកតាក្អំ គឺត្រូវបានអ្នកស្រុករៀបរាប់ថា គាត់គឺជាជនមួយរូបដែលប្រជាជនស្រឡាញ់រាប់អាន ។ អ្នកតាក្អំចេះអប់រំប្រជាជនឲ្យចេះរួមកម្លាំងសាមគ្គីគ្នា ព្រោះកម្លាំងសាមគ្គីគឺជាកត្តាលើករជំរុញចលនាតស៊ូឲ្យទទួលបានជោគជ័យគ្រប់ស្ថានភាពការងារស្រាលធ្ងន់។

ក្រៅរឿងនេះ នៅមានរឿងមួយទៀតដែលនិយាយពីកំណើតជាតិខ្មែរដែរ នោះគឺរឿង**ព្រះថោងនាងនាគ** ក៏ប៉ុន្តែដោយសាររឿងនេះ គ្រាន់តែសង្កត់ធ្ងន់ទៅលើកំណើតទឹកដី នៅទីនេះ ខ្ញុំមិនបានលើកមកបង្ហាញទេ។ នៅឱកាសនេះ ខ្ញុំលើកយកតែរឿងដែលជាចន្លោះអក្សរសិល្ប៍មុនសម័យឥណ្ឌាចូលស្រុកតែប៉ុណ្ណោះ។ រឿងអ្នកតាទឹកអ្នកតាក្អំ គឺជាពិតជាអក្សរសិល្ប៍ ដ៏សែនចំណាស់មួយដែលអ្នកសិក្សាអក្សរសិល្ប៍មិនគិតថាវាស្ថិតនៅក្នុងសម័យកាលណាមួយច្បាស់លាស់បានទេ។

មានលក្ខខណ្ឌតែមួយគត់ដែលខ្ញុំសន្និដ្ឋានថា វាជាអក្សរសិល្ប៍សម័យមុនគ្រិស្តសករាជនោះគឺ សម្អាងទៅលើពាក្យពេចន៍ដែលបានប្រើនៅក្នុងសាច់រឿង គឺមានភាពសាមញ្ញមិនពិបាកយល់ទេ។ ខ្មែរសម័យនោះជឿថា មានតែ**អ្នកតា**ទេដែលមានឫទ្ធិអំណាចចេស្ដាអស្ចារ្យ ខ្មែរមិនទាន់ស្គាល់ពាក្យថា **ព្រះ**ទេ។ នៅក្នុងសង្គមរស់នៅ ខ្មែរគោរពបូជាអ្នកតាអ្នកតាគឺជាដួងព្រលឹងពួកគាត់ តែអ្នកដឹកនាំទំនុកចិត្តនេះ ក៏មានអាក្រក់ល្អជាពុំខាន បានជាអ្នកនិពន្ធបានសរសេរថា អ្នកតាទឹកបានបង្កើតតែភាពភ័យខ្លាច ហើយអ្នកតាក្អំគឺតំណាងសេចក្ដីសង្ឃឹមជូនប្រជាជនវិញ។

ការប្រយុទ្ធយុទ្ធសិល្ប៍ដាក់គ្នារវាងអ្នកតាទាំងពីរ គឺហាក់ដូចជាគូប្រកួតពីរនាក់កំពុងដណ្តើមប្រជាប្រិយភាពគ្នាពីប្រជាជនដែរ។

អក្សរសិល្ប៍ខ្មែរសម័យមុនប្រវត្តិសាស្ត្រ មិនមែនមានតែប៉ុណ្ណឹងទេ គឺនៅមានច្រើនជាងនេះទៅទៀត ក៏ប៉ុន្តែខ្ញុំពុំអាចស្រាវជ្រាវឲ្យអស់សេចក្តីបាន។ និទានការអក្សរសិល្ប៍នេះ នៅមានផ្សារភ្ជាប់ជាមួយបទចម្រៀងពាក្យសម្តី ដែលទាំងអស់នេះត្រូវកប់បាត់ក្នុងស្រមោលអន្ធការមួយមិនមាននរណាអាចគាស់រំលើងបាន។ ប្រជាជាតិខ្មែរ ជាជាតិចំណាស់មួយវិស័យសិល្បៈ អក្សរសិល្ប៍ ចម្ងាក់ក៏មានច្រើនឥតគណនាដែលពេលនេះកំពុងតែត្រូវការកូនខ្មែរជួយស្វែងយល់ និងស្រាវជ្រាវរកឲ្យឃើញនូវមហាកំណប់ ដ៏មហាសាលនេះទុកជាប្រយោជន៍ជាតិបន្តឲ្យកូនចៅជំនាន់ក្រោយមានមោទនភាពតទៅទៀត។

យើងសព្វថ្ងៃ បានត្រឹមតែដឹងថា ជាតិខ្មែរមានកំណើតយូរណាស់តែអាថ៌កំបាំងនៃវប្បធម៌ ខ្មែររកឃើញបានតែមួយភាគតូចប៉ុណ្ណោះ។ ចូរកូនខ្មែរសម័យក្រោយទៀត ត្រូវស្វែងយល់ និងស្រាវជ្រាវបន្ថែមទៀតព្រោះថា ជាតិចំណាស់មួយដែលមានកំណើតរាប់សែនឆ្នាំមុនគ្រិស្តសករាជមិនមែនបន្សល់ទុកត្រឹមតែកងដៃ កងជើងតិចតួចទេ។ ជាតិគេដែលមានអាយុកាលចាស់ដូចជាយើង គេនៅឃើញស្នាដៃអក្សរសិល្ប៍គេជាច្រើនសម្រាប់យើងយកមកសិក្សាដែរ។

មកដល់ឆ្នាំទី៥០នៃគ្រិស្តសករាជ ខ្មែរក៏បានប្រទះសង្គ្រាមសារជាថ្មីជាមួយពួកឥណ្ឌាដែលដឹកនាំដោយព្រះបាទកៅណ្ឌិន្យ។ នៅក្នុងចម្បាំងដ៏ខ្លាំងក្លានេះ ទ័ពទាំងពីរក្រុមបានប្រយុទ្ធគ្នានៅកណ្តាលសមុទ្រដោយសារ តែទ័ពខ្មែរមានសព្វាវុទ្ធមិនគ្រប់គ្រាន់ដូចខាងទ័ពព្រះកៅណ្ឌិន្យ នឹងដោយសារតែខ្មែរនៅប្រើឧបករណ៍ជាលក្ខណៈបុរាណពីបុព្វ

បុរសខ្លួនបានបន្សល់ទុកនោះមានដូចជា លំពែងធ្វើពីថ្មសំលៀង ដំបង ហើយមិនមានក្បាច់គុណពិសេសទេ ទើបត្រូវបរាជ័យ។ ការបរាជ័យក៏មិនបានបណ្តាលឲ្យខ្មែរមានការខាតបង់ដែរ ។ ព្រះបាទកៅណ្ឌិន្យ ព្រះអង្គ ក៏បានយកព្រះនាងស្តេចខ្មែរព្រះនាមនាង**សោម៉ា**ធ្វើជាអគ្គមហេសីក្នុងគ្រានោះទៅ។ ក្នុងខណៈជាស្តេចផែនដី ព្រះបាទកៅណ្ឌិន្យ ក៏បាន រៀបចំស្រុកទេសខ្មែរ តាមរបៀបឥណ្ឌា ហើយគ្រានោះដែរ ដែលអក្សរ សំស្រ្កឹត ក៏ត្រូវបានចូលខ្លួនមកផ្សព្វផ្សាយលើទឹកដីខ្មែរ។

ប្រទេសខ្មែរ ក៏បានដូរសាសនាមកការគោរពបូជាព្រហ្មញ្ញសាសនាដែរ។ ព្រះបាទកៅណ្ឌិន្យ ក៏បានរៀបចំប្រជាជនខ្មែរឲ្យបេះស្លៀកសម្លៀកបំពាក់ជាលក្ខណៈឥណ្ឌាដែរ។ ក៏ប៉ុន្តែ ទោះបីជាសាសានាព្រហ្មញ្ញ មានឥទ្ធិពលនៅក្នុងសង្គមខ្មែរយ៉ាងក្តី ក៏ផ្នត់គំនិតប្រជាជនខ្មែរនៅតែមិន បោះបង់ចោលជំនឿដើមនៃសាសនាខ្លួនដែរ ពោលគឺពួកគាត់នៅតែថែរក្សាជំនឿដែលមានពីខាងដើមរបស់ខ្លួនដដែល ដូចជាជឿទៅលើអ្នកតា ទេវតា ដើមឈើធំៗជាដើម។

ប្រទេសខ្មែរ ចាប់តាំងពីពេលនោះដែរ ដែលចរន្តអក្សរសិល្ប៍ខ្មែរ ក៏មានការផ្លាស់ប្តូរដោយមានលំនាំទៅតាមសាសនាព្រហ្មញ្ញដែរ ព្រោះតែសាសនានេះ មានលក្ខណៈធំ លូតលាស់ជាង ម្យ៉ាងទៀត ព្រះមហាក្សត្រ ទ្រង់គ៏បានប្រតិបត្តិតាមឱវាទសាសនានេះដែរ។

# បញ្ជីរាយព្រះនាមព្រះមហាក្សត្រខ្មែរ

មុននឹងសិក្សា ទៅលើចរន្តអក្សរសិល្ប៍ខ្មែរឲ្យបានជាក់លាក់ទៅតាមសម័យកាលនៃប្រវត្តិសាស្ត្រ ជាដំបូងខ្ញុំសូមមិត្តអ្នកអានធ្វើការសិក្សាជាមួយគ្នាអំពីព្រះនាមនៃព្រះមហាក្សត្រខ្មែរដែលបានសោយរាជ្យតាមសម័យកាលនីមួយៗជាមុនសិន។ ខាងក្រោមនេះខ្ញុំស្រង់យកព្រះនាម ព្រះមហាក្សត្រខ្មែរដែលបានសោយរាជ្យនៅនគរព្រះរាជាណាចក្រកម្ពុជា តាំងពីសម័យសម័យសតវត្សទី១នៃគ្រិស្តសករាជរហូតដល់សម័យបច្ចុប្បន្ន។

| លរ | ព្រះនាម | រជ្ជកាល | រាជធានី | រាជវង្ស |
|---|---|---|---|---|
| ១ | ព្រះបាទហ៊ុនទៀន | ៦៨ គ ស | គោកធ្លក | ឥណ្ឌា |
| ២ | ព្រះបាទហ៊ុន ប៉ាន់ហួង | ស វ ទី២ | គោកធ្លក | បុត្តហ៊ុន ទៀន |
| ៣ | ព្រះបាទហ៊ុន ប៉ាន់ប៉ាន់ | ស វទី២ | គោកធ្លក | បុត្តប៉ាន់ ហួង |
| ៤ | ព្រះបាទហ្វាន់ ម៉ាន់ | ២៣០គស | គោកធ្លក | បុត្តហ៊ុន ទៀន |
| ៥ | ព្រះបាទគីន ចេង | ស វទី៣ | គោកធ្លក | បុត្តបុត្តចេម៉ាន់ |
| ៦ | ព្រះបាទហ្វាន់ឆាន | ២៥០គស | គោកធ្លក | ក្មួយចេម៉ាន់ |
| ៧ | ព្រះបាទហ្វាន់ស៊ីយុន | ២៥០-២៨៩ | គោកធ្លក | បុត្តប៉ាន់ប៉ាន់ |
| ៨ | ព្រះបាទឆៀនឈូតាន់ | ៣៥៧ ? | វ្យាធបុរៈ | បុត្តប៉ាន់ប៉ាន់ |
| ៩ | ព្រះបាទកៅណ្ឌិន្យ | ៤៣៥-៥១៥ | វ្យាធបុរៈ | មកពីឥណ្ឌា |
| ១០ | ព្រះបាទស្រីឥន្ទ្រវរ្ម័ន | ៤៣៨...? | វ្យាធបុរៈ | រាជវង្សកៅណ្ឌិន្យ |
| ១១ | ព្រះបាទជ័យវរ្ម័ន | ៤៨៤...? | វ្យាធបុរៈ | រាជវង្សកៅណ្ឌិន្យ |
| ១២ | ព្រះបាទកៅណ្ឌិន្យវរ្ម័ន | ៥០៣...? | វ្យាធបុរៈ | រាជវង្សកៅណ្ឌិន្យ |
| ១៣ | ព្រះបាទគុណវរ្ម័ន | ៥១៤...? | វ្យាធបុរៈ | បុត្តកៅណ្ឌិន្យ |
| ១៤ | ព្រះបាទរុទ្រវរ្ម័ន | ៥១៧-៥៣៩ | វ្យាធបុរៈ | មកពីឥណ្ឌា |
| ១៥ | ព្រះបាទភវវរ្ម័នទី១ | ៥៩៨-៦០០ | ភវបុរៈ | ចៅស្តេចរុទ្រវរ្ម័ន |

| | | | | |
|---|---|---|---|---|
| ១៦ | ព្រះបាទមហេន្ទ្រវរ្ម័ន | ៦០០-៦១៥ | ភវបុរៈ | ជីដូនមួយភវវរ្ម័ន |
| ១៧ | ព្រះបាទឥសានវរ្ម័ន | ៦១៦-៦៣៥ | ឥសានបុរៈ | បុត្តមហេន្ទ្រវរ្ម័ន |
| ១៨ | ព្រះបាទភវវរ្ម័នទី២ | ៦៣៩...? | ឥសានបុរៈ | បុត្តមហេន្ទ្រវរ្ម័ន |
| ១៩ | ព្រះបាទជ័យវរ្ម័នទី១ | ៦៥៧-៦៨១ | ឥសានបុរៈ | បុត្តភវវរ្ម័នទី២ |
| ២០ | ព្រះបាទជ័យវរ្ម័នទេវី | ៧១៣...? | ឥសានបុរៈ | បុត្តជ័យទី១ |
| ២១ | ព្រះបាទបុស្ករាក្ស | ៧២៣...? | ឥសានបុរៈ | ចៅកៅណ្ឌិន្យ |
| ២២ | ព្រះបាទជ័យសិង្ហវរ្ម័ន | ៧៥៣...? | ឥសានបុរៈ | បុត្តជេន្ទ្រវរ្ម័ន |
| ២៣ | ព្រះបាទបហឹបតីវរ្ម័ន | ៧៧៤-៧៨៤ | ឥសានបុរៈ | បុត្តជេន្ទ្រវរ្ម័ន |
| ២៤ | ព្រះបាទជ័យវរ្ម័នទី២ | ៨០២-៨៦៩ | ភ្នំគូលេន | ចៅស្តេចបុស្ករាក្ស |
| ២៥ | ព្រះបាទជ័យវរ្ម័នទី៣ | ៨៦៩-៨៧៧ | ភ្នំគូលេន | ចៅស្តេចជ័យវរ្ម័នទី២ |
| ២៦ | ព្រះបាទឥន្ទ្រាវរ្ម័នទី១ | ៨៧៧-៨៨៩ | ភ្នំគូលេន | ចៅស្តេចជ័យវរ្ម័នទី៣ |
| ២៧ | ព្រះបាទយសោវរ្ម័នទី១ | ៨៨៩-៩០៨ | អង្គរធំ | ចៅស្តេចឥន្ទ្រាវរ្ម័នទី១ |
| ២៨ | ព្រះបាទហ៌សវរ្ម័នទី១ | ៩០៨-៩២២ | អង្គរធំ | ចៅស្តេចយសោវរ្ម័នទី១ |
| ២៩ | ព្រះបាទឥសានវរ្ម័នទី២ | ៩២២-៩២៨ | អង្គរធំ | អនុជស្តេចយសោវរ្ម័នទី១ |
| ៣០ | ព្រះបាទជ័យវរ្ម័នទី៤ | ៩២៨-៩៤២ | កោះកេរ្តិ៍ | ប្អូនថ្លៃស្តេចយសោវរ្ម័នទី១ |
| ៣១ | ព្រះបាទហ៌សវរ្ម័នទី២ | ៩៤២-៩៤៤ | កោះកេរ្តិ៍ | បុត្តស្តេចជ័យវរ្ម័នទី៤ |
| ៣២ | ព្រះបាទរាជិន្ទ្រវរ្ម័នទី២ | ៩៤៤-៩៦៨ | អង្គរធំ | ចៅស្តេចយសោវរ្ម័នទី១ |
| ៣៣ | ព្រះបាទជ័យវរ្ម័នទី៥ | ៩៦៨-១០០១ | ភ្នំតាកែវ | បុត្តស្តេចរាជិន្ទ្រវរ្ម័នទី២ |
| ៣៤ | ព្រះបាទឧទ្យិទិត្យវរ្ម័នទី១ | ១០០១-១០០២ | អង្គរធំ | ក្មួយជ័យវរ្ម័នទី៥ |
| ៣៥ | ព្រះបាទសុរ្យវរ្ម័នទី១ | ១០០២-១០៤៩ | អង្គរធំ | រាជវង្សយសោវរ្ម័នទី១ |
| ៣៦ | ព្រះបាទឧទ្យិទិត្យវរ្ម័នទី២ | ១០៤៩-១០៧៩ | អង្គរធំ | បុត្តសុរ្យវរ្ម័នទី១ |
| ៣៧ | ព្រះបាទហ៌សទី៣ | ១០៧៩-១០៩០ | អង្គរធំ | ប្អូនសុរ្យវរ្ម័នទី១ |
| ៣៨ | ព្រះបាទជ័យវរ្ម័នទី៦ | ១០៩០-១១០៩ | អង្គរធំ | រាជវង្សរុន្ទ្រវរ្ម័ន |
| ៣៩ | ព្រះបាទធរណិន្ទ្រវរ្ម័ន | ១១០៩-១១១២ | អង្គរធំ | បងជ័យវរ្ម័នទី៦ |
| ៤០ | ព្រះបាទសុរិយ្យវរ្ម័នទី២ | ១១១២-១១៦២ | អង្គរធំ | បុត្តធរណិន្ទ្រ |
| ៤១ | ព្រះបាទធរណិន្ទ្រវរ្ម័នទី២ | ១១៥០-១១៦០ | អង្គរធំ | ជីដូនមួយសុរិយ្យវរ្ម័នទី២ |
| ៤២ | ព្រះបាទយសោវរ្ម័នទី២ | ១១៦០-១១៦៥ | **អង្គរធំ** | **បុត្ត៤២?** |
| ៤៣ | ព្រះបាទជ័យឥន្ទ្រវរ្ម័នទី៤ | ១១៧៧-១១៨១ | អង្គរធំ | ស្តេចចាម |
| ៤៤ | ព្រះបាទជ័យវរ្ម័នទី៧ | ១១៨១-១២៨១ | អង្គរធំ | បុត្តធរណិន្ទ្រវរ្ម័នទី២ |
| ៤៥ | ព្រះបាទឥន្ទ្រវរ្ម័នទី២ | ១២១៨-១២៤៣ | អង្គរធំ | បុត្តស្តេច? |
| ៤៦ | ព្រះបាទជ័យវរ្ម័នទី៨ | ១២៤៣-១២៩៥ | អង្គរធំ | បុត្តស្តច? |
| ៤៧ | ព្រះបាទជ័យវរ្ម័នទី៩ | ១៣២៧-១៣៣៥ | អង្គរធំ | បុត្តស្តេច? |
| ៤៨ | ព្រះបាទត្រសក់ផ្អែម | ១៣៣៥-១៣៤០ | អង្គរធំ | បុត្តស្តេច? |
| ៤៩ | ព្រះបាទសុរិយោពណ៌ | ១៣៤០-១៣៤០ | អង្គរធំ | រាជវង្សត្រសក់ផ្អែម |
| ៥០ | ព្រះបាទនិព្វានបទ | ១៣៤០-១៣៤៥ | អង្គរធំ | បុត្តសុរិយោពណ៌ |

| | | | | |
|---|---|---|---|---|
| ៥១ | ព្រះបាទសទ្ធានរាជ | ១៣៤៥-១៣៤៧ | អង្គរធំ | បុត្តសុរិយោពណ៌ |
| ៥២ | ព្រះបាទស្រីលំពង់រាជា | ១៣៤៦-១៣៥១ | អង្គរធំ | បុត្តត្រសក់ផ្អែម |
| ៥៣ | ព្រះបាទស្រីសុរិយោទ័យ | ១៣៥២-១៣៥៣ | អង្គរធំ | បុត្តស្រីលំពង់រាជា |
| ៥៤ | ព្រះចៅបាអាត | ១៣៥៣-១៣៥៥ | មហានគរ | ស្តេចសៀម |
| ៥៥ | ព្រះចៅបាសាទ | ១៣៥៥-១៣៥៨ | មហានគរ | ស្តេចសៀម |
| ៥៦ | ព្រះចៅកំបង់ពិសី | ១៣៥៨-១៣៥៩ | មហានគរ | ស្តេចសៀម |
| ៥៧ | ព្រះបាទស្រីសុរិយោវង្ស | ១៣៥៩-១៣៦៩ | អង្គរធំ | បុត្តស្រីសុរិយោទ័យ |
| ៥៨ | ព្រះបាទបរមរាមា | ១៣៦៩-១៣៧២ | អង្គរធំ | បុត្តស្រីលំពង់រាជា |
| ៥៩ | ព្រះបាទធម្មាសោក | ១៣៧៣-១៣៨៣ | អង្គរធំ | បុត្តបរមរាមា |
| ៦០ | ព្រះចៅពញ្ញាក្រែក | ១៣៨០...? | អង្គរធំ | ស្តេចសៀម |
| ៦១ | ព្រះបាទពញាយ៉ាត | ១៣៩៣-១៤៦៣ | ទួលបាសាន | បុត្តស្រីសុរិយោវង្ស |
| ៦២ | ព្រះបាទសុរ្យវង្សទី២ | ១៤០១-១៤១៧ | អង្គរធំ | ក្មួយស្រីសុរិយោទ័យ |
| ៦៣ | ព្រះបាទបរមសុខា | ១៤១៧-១៤២០ | អង្គរធំ | បុត្តស្រីសុរិយោទ័យ |
| ៦៤ | ព្រះបាទនារាយរាជាទី១ | ១៤៦៣-១៤៦៩ | ចតុមុខ | បុត្តពញាយ៉ាត |
| ៦៥ | ព្រះបាទស្រីរាជា | ១៤៦៩-១៤៨៤ | ចតុមុខ | បុត្តពញាយ៉ាត |
| ៦៦ | ព្រះបាទស្រីសុរិយោទ័យ | ១៤៧៥-១៤៨៥ | ស្រីសន្ធរ | បុត្តនារាយរាជាទី១ |
| ៦៧ | ព្រះបាទធម្មរាជាទី១ | ១៤៨៦-១៥០៤ | ចតុមុខ | បុត្តពញាយ៉ាត |
| ៦៨ | ព្រះបាទស្រីសុគន្ធបទ | ១៥០៤-១៥១២ | ទួលបាសាន | បុត្តធម្មរាជាទី១ |
| ៦៩ | ព្រះបាទជេដ្ឋាធិរាជ(ស្តេចកន) | ១៥១២-១៥២៥ | ទួលបាសាន | ជ្រែករាជ |
| ៧០ | ព្រះបាទចន្ទរាជា | ១៥២៧-១៥៦៦ | លង្វែក | បុត្តធម្មរាជាទី១ |
| ៧១ | ព្រះបាទបរមរាជាទី៤ | ១៥៦៦-១៥៧៦ | លង្វែក | បុត្តចន្ទរាជា |
| ៧២ | ព្រះបាទសត្ថាទី១ | ១៥៧៦-១៥៩៥ | លង្វែក | បុត្តបរមរាជាទី៤ |
| ៧៣ | ព្រះបាទជ័យជេដ្ឋាទី១ | ១៥៨៦-១៥៩៥ | លង្វែក | បុត្តសត្ថាទី១ |
| ៧៤ | ព្រះបាទរាមាជើងព្រៃ | ១៥៩៤-១៥៩៦ | ស្រីសន្ធរ | ជ្រែករាជ |
| ៧៥ | ព្រះបាទបរមរាជាទី៦(អង្គតន់) | ១៥៩៦-១៥៩៩ | ស្រីសន្ធរ | បុត្តសត្ថាទី១ |
| ៧៦ | ព្រះបាទបរមរាជាទី៧(ពញាអន) | ១៥៩៩-១៦០០ | ស្រីសន្ធរ | បុត្តបរមរាជាទី៤ |
| ៧៧ | ព្រះបាទកែវហ្វាទី១(ពញាញោម) | ១៦០០-១៦០៣ | ស្រីសន្ធរ | បុត្តសត្ថាទី១ |
| ៧៨ | ព្រះបាទស្រីសុរិយោពណ៌ | ១៦០៣-១៦១៨ | ល្វាឯម | បុត្តបរមរាជាទី៤ |
| ៧៩ | ព្រះបាទជ័យជេដ្ឋាទី២ | ១៦១៨-១៦២៨ | ឧដុង្គ | បុត្តស្រីសុរិយោពណ៌ |
| ៨០ | ព្រះបាទស្រីធម្មរាជា | ១៦២៩-១៦៣៤ | កោះឃ្លោក | បុត្តជ័យជេដ្ឋាទី២ |
| ៨១ | ព្រះបាទចៅពញានូ | ១៦៣៥-១៦៣៩ | ឧដុង្គ | បុត្តជ័យជេដ្ឋាទី២ |
| ៨២ | ព្រះបាទបទុមរាជាទី១ | ១៦៣៩-១៦៤១ | ឧដុង្គ | បុត្តព្រះឧទ័យ |
| ៨៣ | ព្រះបាទពញាច័ន្ទ | ១៦៤១-១៦៥៩ | ឧដុង្គ | បុត្តជ័យជេដ្ឋាទី២ |
| ៨៤ | ព្រះបាទបរមរាជាទី៩ | ១៦៥៩-១៦៧២ | ឧដុង្គ | បុត្តព្រះឧទ័យ |
| ៨៥ | ព្រះបាទស្រីជ័យជេដ្ឋា | ១៦៧២-១៦៧៣ | ឧដុង្គ | បុត្តបរមរាជាទី៩ |

| | | | | |
|---|---|---|---|---|
| ៨៦ | ព្រះបាទកែវហ្វាទី២ | ១៦៧៣-១៦៧៥ | ឧដុង្គ | បុត្តបរមរាជាទី៩ |
| ៨៧ | ព្រះបាទជ័យជេដ្ឋាទី៣ | ១៦៧៥-១៦៨៨ | ឧដុង្គ | បុត្តបរមរាជាទី៩ |
| ៨៨ | អ្នកម្នាងទៃ | ១៦៨៨-១៦៨៨ | ឧដុង្គ | បុត្តជ័យជេដ្ឋាទី៣ |
| ៨៩ | ព្រះបាទជ័យជេដ្ឋាទី៣ | ១៦៨៨-១៦៩៥ | ឧដុង្គ | បុត្តបរមរាជាទី៩ |
| ៩០ | ព្រះបាទឧទ័យរាជា | ១៦៩៥-១៦៩៦ | ឧដុង្គ | បុត្តកែវហ្វាទី២ |
| ៩១ | ព្រះបាទជ័យជេដ្ឋាទី៣ | ១៦៩៦-១៦៩៩ | ឧដុង្គ | បុត្តបរមរាជាទី៩ |
| ៩២ | ព្រះបាទកែវហ្វាទី៣(អង្គរឹម) | ១៧០០-១៧០២ | ពោធិសត្វ | បុត្តអង្គនន់ |
| ៩៣ | ព្រះបាទជ័យជេដ្ឋាទី៣ | ១៧០០-១៧០២ | ឧដុង្គ | បុត្តបរមរាជាទី៩ |
| ៩៤ | ព្រះបាទធម្មរាជាទី៣ | ១៧០២-១៧០៣ | ឧដុង្គ | បុត្តជ័យជេដ្ឋាទី៣ |
| ៩៥ | ព្រះបាទកែវហ្វាទី៣ | ១៧០៣-១៧០៦ | ពោធិសត្វ | បុត្តអង្គនន់ |
| ៩៦ | ព្រះបាទសត្ថាទី២ | ១៧០៦-១៧០៩ | ឧដុង្គ | បុត្តកែវហ្វាទី៣ |
| ៩៧ | ព្រះបាទកែវហ្វាទី៣ | ១៧១០-១៧២២ | ឧដុង្គ | បុត្តអង្គនន់ |
| ៩៨ | ព្រះបាទសត្ថាទី២ | ១៧២២-១៧២៩ | ឧដុង្គ | បុត្តកែវហ្វាទី៣ |
| ៩៩ | ព្រះបាទធម្មរាជាទី៣ | ១៧៣៧-១៧៤៩ | ឧដុង្គ | បុត្តអង្គសូរ |
| ១០០ | ព្រះបាទធម្មរាជាទី៤ | ១៤៩(១ឆ្នាំ) | ឧដុង្គ | បុត្តធម្មរាជាទី៣ |
| ១០១ | ព្រះបាទរាមាធិបតីទី៣ | ១៧៤៧-១៧៤៨ | ឧដុង្គ | បុត្តឧទ័យរាជា |
| ១០២ | ព្រះបាទសត្ថាទី២ | ១៧៤៩ | ឧដុង្គ | បុត្តកែវហ្វាទី៣ |
| ១០៣ | ព្រះបាទស្រីជ័យជេដ្ឋា | ១៧៤៩-១៧៥៥ | ឧដុង្គ | បុត្តធម្មរាជាទី៣ |
| ១០៤ | ព្រះបាទរាមាធិបតីទី៣ | ១៧៥៦-១៧៥៧ | ឧដុង្គ | បុត្តឧទ័យរាជា |
| ១០៥ | ព្រះបាទនារាយរាជាទី២ | ១៧៥៨-១៧៧៥ | ឧដុង្គ | ចៅរាមាធិបតីទី៣ |
| ១០៦ | ព្រះបាទរាមរាជា | ១៧៧៥-១៧៧៩ | ឧដុង្គ | បុត្តស្រីជេដ្ឋា |
| ១០៧ | ព្រះបាទនារាយរាជាទី៣ | ១៧៧៩-១៧៩៦ | ឧដុង្គ | បុត្តនារាយរាជាទី២ |
| ១០៨ | ព្រះបាទចៅហ្វាប៉ុក | ១៧៦៩-១៨០៥ | ឧដុង្គ | បុត្តស្តេច? |
| ១០៩ | ព្រះបាទឧទ័យរាជា | ១៨០៦-១៨៣៤ | ឧដុង្គ | បុត្តនារាយរាជាទី៣ |
| ១១០ | ម្ចាស់ក្សត្រីអង្គម៉ី | ១៨៣៤-១៨៤០ | ឧដុង្គ | បុត្តនារាយរាជាទី៣ |
| ១១១ | ព្រះបាទអង្គឌួង | ១៨៤០-១៨៥៩ | ឧដុង្គ | បុត្តនារាយរាជាទី៣ |
| ១១២ | ព្រះបាទនរោត្តម | ១៨៥៩-១៩០៤ | ឧដុង្គ-ភ្នំពេញ | បុត្តអង្គឌួង |
| ១១៣ | ព្រះបាទស៊ីសុវត្ថិ | ១៩០៤-១៩២៧ | ភ្នំពេញ | បុត្តអង្គឌួង |
| ១១៤ | ព្រះបាទស៊ីសុវត្ថិមុនីវង្ស | ១៩២៧-១៩៤១ | ភ្នំពេញ | បុត្តស៊ីសុវត្ថិ |
| ១១៥ | ព្រះបាទនរោត្តមសីហនុ | ១៩៤១-១៩៥៥ | ភ្នំពេញ | បុត្តសុរាម្រឹត |
| ១១៦ | ព្រះបាទសុរាម្រឹត | ១៩៥៥-១៩៦០ | ភ្នំពេញ | បិតាសីហនុ |
| ១១៧ | ម្ចាស់ក្សត្រីកុសុមនារីរត្ន | ១៩៦០-១៩៧០ | ភ្នំពេញ | មាតាសីហនុ |
| ១១៨ | ព្រះបាទនរោត្តមសីហនុ | ១៩៩៣-២០០៤ | ភ្នំពេញ | បុត្តសុរាម្រឹត |
| ១១៩ | ព្រះបាទនរោត្តមសីហមុនី | ២០០៤... | ភ្នំពេញ | បុត្តសីហនុ |

# អក្សរសិល្ប៍សម័យមុនអង្គរ

សម័យមុនអង្គរគឺជាសម័យមួយ ដែលអ្នកសិក្សាបានចាត់ទុកថា ជាសម័យដំបូងបំផុតដែលប្រទេសខ្មែរចាប់ផ្ដើមកសាង វប្បធម៌ អរិយធម៌ ដែលជាឥស្សរភាពដ៏អស្ចារ្យរបស់ខ្លួននៅលើទឹកដីជាកេរតំណែល ដែលបានបន្សល់ទុកកាលពីរាប់សតវត្សមកហើយ។ ឯកសារខ្លះថា ខ្មែរចាប់កសាងរាជធានីរបស់ខ្លួននៅកោះគោកធ្លក។ អក្សរសាស្ត្រខ្មែរក៏ចាប់មានរូបរាងឡើងតាំងពីពេលនោះមក តែមានរូបរាងដូចជាអក្សរឥណ្ឌានៅភាគខាងត្បូង។

នៅក្នុងសៀវភៅ ប្រវត្តិអក្សរសាស្ត្រខ្មែររបស់លោកលាង ហាប់អាន បានសរសេរថា តាមរយៈការសិក្សារបស់លោក ហ្វ្រ៊ិក ម៉ាស់ប៉េរ៉ូ នៅក្នុងសៀវភៅលោកឈ្មោះវេយ្យាករណ៍នៃភាសាខ្មែរ លោកបានបែងចែកភាសាខ្មែរតាំងពីដើមកំណើត មកទល់និងបច្ចុប្បន្នកាលនេះមានការផ្លាស់ប្ដូររូបចំនួន១០លើកមកហើយដែលមានរូបរាងផ្សេងគ្នាះ

លក្ខណៈទី១ ជាអក្សរបែបសិលាចារឹកហាន់ជ័យ ប្រមាណសតវត្សទី៦នៃគ្រិស្តសករាជ

លក្ខណៈទី២ ជាអក្សរបែបសិលាចារឹក វាលកន្តែល នៅអំឡុងចុងសតវត្សទី៦ ឬដើមសតវត្សទី៧នៃគ្រិស្តករាជ។

លក្ខណៈទី៣ អក្សរបែបសិលាចារឹក អង្គជំនីក នៅអំឡុងឆ្នាំ ៦៦៧នៃគ្រិស្តកាជ។

លក្ខណៈទី៤ អក្សរបែបសិលាចារឹកព្រះឥន្ទកោសីយ គឺនៅអំឡុងឆ្នាំ៩៧០នៃគ្រិស្តកាជ។

លក្ខនៈទី៥ អក្សរបែបសិលាចារឹកព្រះកែវ គឺនៅអំឡុងឆ្នាំ ១០០២ នៃគ្រិស្តកាជ។

លក្ខណៈទី៦ អក្សរបែបសិលាចារឹក ព្រះនក ក្នុងអំឡុងឆ្នាំ ១០៦៦ នៃគ្រិស្តកាជ។

លក្ខណៈទី៧ អក្សរបែបសិលាចារឹកបន្ទាយឆ្មា អំឡុងសតវត្ស ទី១២ឬដើមសតវត្សទី១៣ នៃគ្រិស្តកាជ។

លក្ខណៈទី៨ អក្សរបែបសិលាចារឹកអង្គរវត្ត នៅក្នុងសតវត្សទី១៣ នៃគ្រិស្តកាជ។

លក្ខណៈទី៩ អក្សរបែបមហាសិលាចារឹកអង្គរនៅឆ្នាំ១៧០២ នៃគ្រិស្តកាជ។

លក្ខណៈទី១០ អក្សរបែបសម័យបច្ចុប្បន្ន។

ទោះបីជាអក្សរសាស្ត្រខ្មែរសម័យបុរាណមានទម្រង់ ដូចជាអក្សរឥណ្ឌាក្តី ក៏ប៉ុន្តែបុព្វបុរសខ្មែរ លោកបានកែប្រែកាឡែបន្តិចម្តងៗ និងច្រើនសម័យកាលរហូតមានរូបរាងដោយឡែកពីឥណ្ឌា និងមានសូរលក្ខណៈពិសេសពីឥណ្ឌាទៀតផង។

យោងតាមឯកសាររបស់លោកត្រឹង ង៉ា នៅក្នុងសៀវភៅប្រវត្តិសាស្ត្រខ្មែរ បានអះអាងថា មនុស្សខ្មែរនៅសម័យអាណាចក្រភ្នំ គឺមានសម្បុរខ្មៅ សក់រួញអង្កាជី រូបច្រើនមិនសូវបាន។ មានន័យថា មិនសូវស្អាត ល្អដូចជាជនជាតិចិនសម័យបុរាណទេ តែម៉ឺងម៉ាត់ការងារណាស់។

គេច្រើនស្លៀកសារ៉ុងអំបោះ ដើរជើងទទេសម្រាប់មនុស្សសាមញ្ញ តែសម្រាប់នាម៉ឺន គឺគេមានពាក់ស្បែកជើង។

ចំពោះអក្សរសិល្ប៍ដែលគេយកមកនិទាន នៅក្នុងជីវភាពរស់នៅវិញ គឺភាគច្រើននៃរឿងនោះត្រូវបានប្រឌិតតាមទេវកថាឥណ្ឌា ទាំងនេះគឺអាស្រ័យដោយសារតែខ្មែរទទួលឥទ្ធិពលពីឥណ្ឌាទើបបានជាអ្វីៗដែលទ្រទ្រង់វិស័យព្រលឹងនិយមនេះ ត្រូវបានប្រឌិតចេញពីឥណ្ឌាដែរ។ មនុស្សសម័យនគរភ្នំចូលចិត្តស្តាប់រឿង ដែលមានជាប់ទាក់ទងជាមួយព្រះទេវៈណាស់ដែរ។

មកដល់សម័យចេនឡា មនុស្សប្រុសខ្មែរច្រើនមានសម្បុរខ្មៅដូចជាមនុស្សសម័យអាណាចក្រភ្នំដែរ ប៉ុន្តែស្រីៗច្រើនមានសម្បុរសទាំងនេះប្រហែលមកពីទម្លាប់ស្រីខ្មែរចូលម្លប់ ហើយប្រុសៗច្រើនចេញទៅធ្វើការនៅក្រៅផ្ទះ។ មនុស្សខ្មែរទាំងប្រុសទាំងស្រីនៅសម័យនោះ ច្រើនតែបួងសក់ ហើយពាក់រយ៉ាថៃមទៀត។

នៅសម័យមុនអង្គរ អក្សរសាស្ត្រ អក្សរសិល្ប៍ខ្មែរច្រើនតែផ្តោតសំខាន់ទៅលើការកត់ត្រានៅលើផ្ទាំងថ្ម ហេតុដូច្នេះហើយបានជា មានសិលាចារឹកជាច្រើនមាននៅរាយប៉ាយពេញប្រទេស។ វណ្ណកម្មដ៏ល្អឯកនេះ មនុស្សខ្មែរជំនាន់នោះ គឺជាកស្តុតាងដ៏វិសេសវិសាលមួយ សម្រាប់ជាការបញ្ជាក់ពីអត្តសញ្ញាណជាតិខ្មែរ ថាជាជាតិមួយថ្លៃថ្នូរមានវប្បធម៌របស់ខ្លួនតាំងពីបុរាណ និងនៅសេសសល់រហូតដល់បច្ចុប្បន្នទៀត។ ខាងក្រោមនេះ គឺជាអត្ថបទសិលាចារឹកខ្លះដែលខ្ញុំលើកមកបង្ហាញមិត្តអ្នកអាន ដើម្បីបានជ្រាបពីអក្សរសិល្ប៍បុរាណខ្មែរសម័យមុនអង្គរថាមានលក្ខណៈយ៉ាងណា?

ដោយហេតុតែសម័យមុនអង្គរ បានលាតសន្ធឹងវែងឆ្ងាយ គឺប្រមាណពីសតវត្សទី១ រហូតដល់សតវត្សទី៨គ្រាដែលព្រះមហាក្សត្រខ្មែរព្រះបាទជ័យវរ្ម័នទី២បានលើករាជធានីមកតាំងនៅអង្គរ ទើបត្រូវបញ្ចប់

ដូច្នេះ ខ្ញុំលើកតែអត្ថបទមួយចំនួនដែលជាអត្ថបទសិលាចារឹកកើតឡើង មុនសម័យអង្គរមកបង្ហាញខ្លះដូចខាងក្រោម៖

## អត្ថបទសិលាចារឹកនៅ វ៉ូកាញ់

ជាសិលាចារឹកដែលមានអាយុកាលចាស់ជាងគេបំផុត នៅអាស៊ីអគ្នេយ៍ដែលបានកើតឡើងនៅអំឡុងសតវត្សទី២ ឬទី៣ប៉ុណ្ណោះ។

អត្ថន័យជាសង្ខេបនៃអត្ថបទនេះមានដូចតទៅ៖

...សេចក្តីករុណាចំពោះសព្វសត្វទាំងឡាយ... ប្រថមជ័យ... ថ្ងៃពេញបុណ្ណមី (?) ព្រះរាជាទ្រង់បានប្រកាសក្នុងរាជសភាថា "ចូរប្រជាជនគ្រប់ផឹកនូវទឹកអម្រឹត ពោលគឺព្រះរាជបន្ទូល ព្រះបាទ...ជាវង្សនៃព្រះបាទស្រីមារៈ ទ្រង់បានជាកិត្តិយសនៃរាជវង្សស្រីមារៈ ទ្រង់បានប្រកាសក្នុងកណ្តាលជំនុំជន នូវព្រះរាជបន្ទូល សូរសីហនាទជាប្រយោជន៍ដល់ប្រជាជនទាំងឡាយ ទ្រង់ជាករុណា ទាំងពីរដេប្រសើរទ្រង់ប្រថាប់លើសិង្ហាសនៈ (ព្រះរាជបល្លង្កស្វេតច័ត្រ?) ហើយទ្រង់ឈ្វេងយល់នូវគតាកតិ គឺការអន្ទោលស្លាប់កើតនៃមនុស្សលោក ទើបត្រាស់ថា "កាលបើកូនខ្ញុំក្តី បងប្អូនខ្ញុំក្តីមិនមែនអ្នកកន្សៀតទេ បានសម្រេចបំណងខ្លួនហើយ(បានសោយរាជ្យតទៅ?) (ខ្ញុំសូមឲ្យយក) សម្បត្តិខ្ញុំទាំងអស់ ប្រាក់ សង្ហារិមក្តី អសង្ហារិមក្តី ទៅប្រើជាវត្ថុសម្រាប់ជាទីរីករាយ និងជាប្រយោជន៍ដល់សត្វលោកទាំងឡាយ នេះជាសេចក្តីបញ្ជារបស់ខ្ញុំ។ សូមព្រះរាជាទាំងឡាយនៅក្នុងអនាគត ប្រតិបត្តិតាមព្រះរាជបញ្ជាខ្ញុំនេះកុំបីខាន។ ហើយចូរប្រើក្សាជាមួយសេវកាមាត្រឈ្មោះវីរ...របស់ខ្ញុំ។

សេចក្តីដកស្រង់នៃអត្ថបទខាងលើនេះ សបញ្ជាក់ពីស្នាព្រះហស្ត របស់ព្រះរាជាខ្មែរមួយព្រះអង្គ គឺព្រះបាទស្រីមារៈ ឬហ្វាន់ ម័ន ដែលឯកសារចិនប្រសិទ្ធនាមថា ហ្វាន់ ចេម័ន ព្រះអង្គបានចារឹកឡើងនៅគ្រាដែលព្រះអង្គឡើងគ្រងរាជសម្បត្តិ។ ព្រះអង្គបានចាត់ចែងរៀបសិលាចារឹកនេះឡើង ដើម្បីទុកជាតំណាងឧត្តមគតិរបស់ព្រះអង្គទុកតទៅព្រះរាជាខាងក្រោយទៀត។ ព្រះអង្គមានព្រះទ័យជ្រះថ្លា ទ្រង់តែងសន្តោសដល់ប្រជាពលរដ្ឋទូទៅ ពិសេសគឺព្រះអង្គបានយល់ច្បាស់អំពីដំណើរ**គតាគតិ** ការវិលកើត វិលស្លាប់របស់មនុស្សនៅក្នុងវដ្តសង្សារ។

គោលបំណងនៃអ្នកតាក់តែងអត្ថបទនេះ គឺបង្ហាញពីការសព្វព្រះទ័យចំពោះជំនឿក្នុងព្រះពុទ្ធសាសនា ដូចមានចែងនៅក្នុងសេចក្តីប្រកាសរបស់ព្រះបាទស្រីមារៈអំពីការអន្ទោលកើតស្លាប់នៃមនុស្សលោក។

តាមរយៈគំនិត និងពាក្យសម្តីដែលជាព្រះរាជបណ្តាំនៅក្នុងអត្ថបទនេះ គេអាចសិក្សាបានថា ប្រទេសនគរភ្នំជាប្រទេសដែលកាន់លទ្ធិព្រះពុទ្ធសាសនា ។ តាមរយៈអត្ថបទនេះ បញ្ជាក់ថា ប្រទេសខ្មែរបានប្រ-តិបត្តិ តាមព្រះពុទ្ធសាសនាចាប់តាំងពីសសវត្សទី២ជាគ្រាដែលព្រះពុទ្ធសាសនាមានឫសគល់ និងបានការយកចិត្តទុកដាក់ពីសំណាក់ព្រះរាជានៅក្នុងប្រទេសទៀតផង។

## អត្ថបទសិលាចារឹក នៅព្រៃវៀរ

អត្ថបទនេះមានទីតាំងនៅវត្តព្រៃវៀរ ស្ថិតនៅក្នុងឃុំព្រៃវៀរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។ អត្ថបទនេះ ត្រូវបានចារនៅពុទ្ធសករាជ ១២០៦ គ្រិស្តករាជ៦៦៤ ដែលមាន១០បន្ទាត់ ចារនៅលើផ្ទាំងថ្មភក់។ អត្ថន័យសម្រាយនៅក្នុងអត្ថបទនេះមានដូចតទៅៈ

១ ព្រះបាទស្រីជយវរ្ម័ន ដ៏មានជោគ មានវិរិយភាព យ៉ាងមហិមា ទ្រង់ឋិតនៅជិតព្រះលក្ស្មី ទ្រង់គង់នៅគ្មានកម្រើក។

២ ទ្រង់មានព្រះនេត្រទតវែងឆ្ងាយ ...មានព្រះបញ្ញា វាងវៃក្នុងកិច្ចការពារលោក ហើយទ្រង់ត្រូវបានអ្នកប្រាជ្ញសហស្រាស្ត្រលើកដំកើងឡើង។

៣ ក្នុងពេលដែលទ្រង់គ្រប់គ្រងទឹកដី បានមកពីការវាតទីដ៏វែងឆ្ងាយ ក្នុងខណៈនោះមានព្រះភិក្ខុដ៏ជំនាញ២អង្គគង់នៅក្នុងព្រះរាណាចក្រព្រះអង្គ។ ភិក្ខុនេះមានព្រះមាតារួមឧទរ ម៉ុងម៉ាត់ក្នុង...។

៤ ទាំងពីរអង្គប្រកបដោយគុណធម៌ទ្រង់សីល មានចំណេះវិជ្ជាសភាពស្ងប់ស្ងៀម សេចក្ដីអំណត់អត់ធន់ មានខ្លួនទូន្មានហើយ មានករុណា សម្មាធិប្រុងប្រយ័ត្នជានិច្ច ហើយព្រះអង្គមានព្រះគោតជាវត្ត ដែលនាមចុងប្រាកដទាំងពីរ គឺមួយអង្គនាម ភានុ ហើយមួយអង្គទៀតនាម សិង្ហ។

៥ បុត្រនៃកូនស្រីដែលជាបងនៃ ភិក្ខុទាំងពីររូបនេះមានព្រះកិត្តិនាមខ្ពស់ គឺព្រះវិសុទ្ធ សុភកីរ្តិ ដែលមានព្រះសកម្មភាពយ៉ាងបរិសុទ្ធ។

៦ តាមការគ្រប់គ្រងជាហូរហែ នៃព្រះញាតិវង្សរាមកហើយ តាមព្រះបញ្ញារបស់ព្រះមហាក្សត្រ ព្រះរាជបុត្រនេះត្រូវបានទទួលពេញបន្ទុកនូវអ្វីទាំងអស់ ដែលព្រះអង្គមានបុព្វសិទ្ធនឹងទទួលពេញសមត្ថភាព។

៧ មានសត្វទ្វេបាទ ចតុបាទ សួនឧទ្យាន ដីធ្លី ព្រៃព្រឹក្សា ចំការភ្លឺ ហើយនិងទាំងអ្វីដែលឋិតនៅក្នុងព្រះរាជាណាចក្រ ត្រូវបានមកទ្រង់

ហើយគ្មាននរណាជទៃម្នាក់អាចមកទាមទារបានទេ។ នេះគឺជាព្រះរាជបណ្តាំ និងជាព្រះរាជបញ្ជារបស់ព្រះមហាក្សត្រ។

៨ សេចក្តីសំរេចបិត នៅក្នុងសម័យព្រះចៅនៃសកៈ ដែលទ្រង់បានទទួលហើយនូវ រសៈ នូវវសុ និងវត្ថុ របស់អាយតនៈ ជាថ្ងៃទី២កើតខែមាឃ។ ព្រះរាជបញ្ជានេះ ប្រគល់ទៅព្រះសង្ឃដែលគង់នៅក្នុងជានីរបស់ព្រះមហាក្សត្រ ។ គឺសេចក្តីនេះរាប់បានថាជា ព្រះរាជតម្រិះរបស់ព្រះមហាក្សត្រ ព្រះអង្គឯងប្រកបដោយព្រះវិចារណត្រូវ...។

តាមរយៈអត្ថបទសិលាចារឹកនេះ បង្ហាញថា នៅសម័យនោះមានព្រះសង្ឃចំនួនពីរអង្គជាបងប្អូនបង្កើតនិងគ្នា ដែលមានជាតិជាព្រះមហាក្សត្រ ហើយទ្រង់បានយាងមកបំពេញបព្វជានៅវត្តនេះ។

នៅសម័យនោះ ព្រះពុទ្ធសាសនាមានការរីកចម្រើនខ្លាំង ហើយខ្មែរនិយមកាន់ព្រះពុទ្ធបែបហីនយានទៀតផង។ ព្រះភិក្ខុសង្ឃបានកាន់ក្រិត្យវិន័យ មានសមត្ថភាពបរិបូណ៌។ ទាំងព្រះរាជបុត្រព្រះមហាក្សត្រក៏បានចូលមកបួសនៅក្នុងសាសនា ចំណែកព្រះរាជាក៏ទ្រង់មានសទ្ធាជ្រះថ្លាណាស់ដែរនៅក្នុងកិច្ចទំនុកបម្រុងវត្តអារាមសាមណព្រាហ្មណ៌។

សរុបសេចក្តីមក អក្សរសិល្ប៍ខ្មែរសម័យមុនអង្គរ គឺបានផ្តេកទាំងស្រុងទៅអត្ថបទជាសិលាចារឹក ដែលត្រូវបានព្រះមហាក្សត្រកសាងឡើងដើម្បីរៀបរាប់អំពីដំណើររឿងរ៉ាវ ទាក់ទងជាមួយស្ថានការណ៍ស្រុកទេស ដោយមានរាយពីហេតុនៃព្រឹត្តិការណ៍នោះជាប់ជាមួយផងដែរ។ បើទោះបីជាគេមិនទាន់រកឃើញអត្ថបទ ដែលនិយាយអំពីរឿងរ៉ាវអ្វីមួយមានជាប់ទាក់ទងទៅនឹងសិល្បៈក្តី ឬជាប់ទាក់ទងទៅនឹងផ្នត់គំនិតក្តី ក៏យ៉ាងហោចណាស់ គេអាចសន្និដ្ឋានបានថា មនុស្សជំនាន់មុនអង្គរ

គឺមានចំណូលចិត្តស្តាប់រឿងរ៉ាវបែបនិទានកថា ហើយមានជាប់ទាក់ទង ជាមួយព្រះទេវៈដ៏មានឫទ្ធានុភាព ឬនិយាយពីកំណត់កំណើតមនុស្សនៅ លើទឹកដីនេះ ឬទេវកថាឥណ្ឌា ដែលនិយាយពីកំណើតព្រះអាទិត្យ ព្រះចន្ទ ព្រះពាយជាដើម។

សេចក្តីយ៉ាងណា ក៏ខ្ញុំពុំអាចហ៊ានសន្និដ្ឋានបានត្រឹមត្រូវនោះទេ តែអ្វីដែលបានលើកឡើង ក៏ព្រោះតែផ្អែកទៅលើផ្នត់គំនិតមនុស្សខ្មែរ មានជំនឿទៅលើសាសនាមកពីឥណ្ឌា ។ដូច្នេះ ឥទ្ធិពលនៃវប្បធម៌នោះក៏ មុខតែអាចសាយភាយមកដល់បណ្តាចិត្តមនុស្សខ្មែរសម័យនោះពុំខាន។

អក្សរសិល្ប៍នៅសម័យមុនអង្គរ មិនមែនត្រឹមតែផ្សារភ្ជាប់តែជា មួយអត្ថបទសិលាចារឹកទាំងស្រុងទេ ការនិទានពីរឿងរ៉ាវណាមួយនៃ ផ្នែកទេវកថា ក៏មុខជាជ្រាបចូលសន្តានចិត្តប្រជាជនយើងសម័យនោះជា ពុំខាន។ ទោះបីជាមិនមានភស្តុតាងបញ្ជាក់ជាសត្យានុម័តក្តី ក៏យ៉ាង ហោចណាស់យើងត្រូវដឹងថា ជីវិតមនុស្សកើតមកគឺតែងផ្សារភ្ជាប់ជា មួយភាពសប្បាយរីករាយជានិច្ច។

ការរាំរែក ក៏ត្រូវតែមានជានិច្ចដែរ តែភស្តុតាងដែលយើងឃើញ មានតាមរយៈអត្ថបទសិលាចារឹក គឺមានតែព្រះមហាក្សត្រប៉ុណ្ណោះដែល មានអ្នកតន្ត្រីប្រចាំព្រះអង្គ។ មិនមែនមានតែព្រះរាជា ឬនៅព្រះរាជវាំង ទេដែលមានតន្ត្រី មានអ្នកអ្នករបាំ នៅស្រុកស្រែជនបទឆ្ងាយៗពីទីក្រុងក៏ មានអ្នកតន្ត្រី អ្នកសិល្បៈដែរសម្រាប់ប្រារព្ធពិធីបុណ្យទាននានានៅក្នុង ភូមិស្រុករបស់គេ។

សរុបសេចក្តីនិយាយជារួមដោយខ្លីមកមានន័យថា មនុស្សខ្មែរ បានបង្កើតទម្រង់សិល្បៈសម្រាប់ជាតិខ្លួនយ៉ាងមាំមួនណាស់ គឺតាំងពី សម័យមុនសម័យនេះទៅទៀត ។យ៉ាងណាមិញ ចំពោះរឿងរ៉ាវផ្សេងៗ

ទៀតដែលជាវណ្ណកម្មអក្សរសិល្ប៍ ក៏ខ្មែរមានជានិច្ចដែរសម្រាប់ញ៉ាំង ការរស់នៅរបស់ផង់ខ្លួនឲ្យមានភាពសប្បាយរីករាយ បំបាត់ភាពភ័យខ្លាចបណ្ដាលមកពីសត្វសាហាវ បំបាត់ភាពរង៉ោបណ្ដាលមកពីអាកាសធាតុដ៏សែនត្រជាក់នៅបុរាណសម័យ។

## អក្សរសិល្ប៍សម័យអង្គរ

### ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍សម័យអង្គរ

*សម័យអង្គរគិតចាប់ពីគ្រិស្តសករាជទី៨០២រហូតដល់ គ្រិស្តសករាជ* **១២១២**(*លាង ហាប់អាន* *ប្រវត្តិ អក្សរសាស្ត្រខ្មែរសម័យនគរភ្នំ ដល់សម័យឧដុង្គថា សម័យមហានគរចាប់ពីគ្រិស្តសតវត្សទី៩ ដល់សតវត្ស ១២*)។ នៅក្នុងសម័យអង្គរ ប្រទេសកម្ពុជាប្រកាន់ខ្ជាប់លើព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនាមហាយាន។ មានពេលខ្លះយើងបានលើកតម្កើងវីរបុរស ខ្លះជាអ្នកមានបុណ្យជាមនុស្សអស្ចារ្យ សម្រាប់ប្រារព្ធក្នុងពិធី សាសនាទៀតផង (*ពិធីទេវរាជ*)។ នៅក្នុងសម័យអង្គរត្រូវបានអ្នកសិក្សាស្រាវជ្រាវ ចាត់ទុកថាជាសម័យដ៏រុងរឿងបំផុតក្នុងប្រវត្តិសាស្ត្រខ្មែរ ពោលគឺជាសម័យដែលមានការរីកចម្រើនលើគ្រប់វិស័យរួមទាំងវិស័យអក្សរសាស្ត្រផងដែរ។ ហេតុនេះឯង ទើបបានជាភាសា និងអក្សរសំស្ក្រឹតក្លាយជាមូលដ្ឋាននៃលទ្ធិទាំងពីរគឺលទ្ធិព្រហ្មញ្ញសាសនា និងលទ្ធិពុទ្ធសាសនាមហាយាន ហើយបានទទួលកិត្តិយសជាភាសា ផ្លូវ

ការសម្រាប់កិច្ចការជាន់ខ្ពស់ផ្សេងៗ នៅក្នុងអាណាចក្រទាំងមូល។ ចំពោះការប្រើប្រាស់ខាងសិលាចារឹកក្ដី ខាងផ្នែកវណ្ណកម្មក្ដី ភាសានិយាយ ធម្មតាក្ដី នៅក្នុងសម័យនោះគឺមានសុទ្ធតែលាយដោយភាសាសំស្ក្រឹតទាំងអស់។ ប្រហែលមកពីសម័យអង្គរ មានការរីកចម្រើនខាងផ្នែកអក្សរសាស្ត្រជាតិដូច្នេះហើយ បានជាភាសាដែលប្រើប្រាស់របស់ប្រជាជន មានលាយច្របូកច្របល់ ដោយភាសាសំស្ក្រឹត យ៉ាងសម្បូរហូរហៀរ រហូតដល់បច្ចុប្បន្នដោយឥតដឹងខ្លួន ដូចជាមិត្រ សួស្ដី ពណ៌ អារម្មណ៍ ប្រព្រឹត្ត រក្សា...ជាដើម។ ពាក្យទាំងនេះ ខ្មែរយើងបានប្រើរត់មាត់តាំងពីមនុស្សចាស់ រហូតដល់កូនក្មេង ហាក់ដូចជាមិនចាប់អារម្មណ៍ទៅលើពាក្យទាំងនេះថាខ្មែរបានខ្ចីពីភាសាសំស្ក្រឹត តាំងពីយូរយារណាស់មកហើយទេ ហើយបែរជាយល់ច្រឡំថាជាភាសាខ្មែរទៅវិញ

គេសង្កេតឃើញថាវិស័យអក្សរសាស្ត្រនៅ សម័យអង្គរបានផ្ដិតជាប់នៅនឹងថ្មហៅថា**សិលាចារឹក** ដែលការចារគឺគេប្រើអក្សរសំស្ក្រឹត និងអក្សរខ្មែរបុរាណហើយអត្ថន័យ នៅក្នុងសេចក្ដីនោះគឺច្រើនអួតសរសើរពីឧត្ដមភាពនៃវីរជន ដោយលើកតម្កើងជនទាំងនោះឡើងខ្ពស់ដូចជាទេវៈនៅក្នុងសាសនាព្រាហ្មណ៍។

ចំពោះអក្សរសាស្ត្រ ដែលចារជាភាសាខ្មែរបុរាណវិញភាគច្រើនគេឃើញមានការសរសេរពីការធ្វើទាន ការបរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួនឲ្យដល់សាធារណៈ។ និយាយរួមមកបញ្ហាអក្សរសាស្ត្រនៅក្នុងសម័យអង្គរមានការ បែងចែកជា៖

**-អក្សរសំស្ក្រឹត:** សម្រាប់ប្រើជាមួយពួកវណ្ណៈថ្នាក់លើមានព្រះរាជា នាម៉ឺន...ឬសម្រាប់អាទិទេព។

***-អក្សរខ្មែរ ឬភាសាខ្មែរៈ*** សម្រាប់ប្រើជាមួយពួកវណ្ណៈថ្នាក់ក្រោម មានដូចជា ប្រជារាស្ត្រសាមញ្ញឬសម្រាប់ប្រើជាមួយទាសាទាសីជាដើម។

និយាយរួមមកអក្សរសិល្ប៍សម័យអង្គរ ត្រូវបានកត់ត្រានឹងចារលើសិលា ដែលអាចឲ្យអ្នកសិក្សាធ្វើការបែងចែកចេញជាបីដំណាក់កាលរួមមានៈ

***-ដំណាក់កាលទីមួយ*** ចាប់ពីសតវត្សទី៩ ដល់សតវត្សទី១០ជារយៈពេលដែលអក្សរសាស្ត្រជាតិ មានទំនោរប្រើអក្សរសំស្ក្រឹតសម្រាប់កត់ត្រា។ គេសង្កេតឃើញអត្ថបទដែលចារ នៅក្នុងអំឡុងនេះច្រើនតែសរសេរអួតសរសើរពីតេជៈបារមីព្រះអាទិទេព ចម្រៀងអង្វរករដល់វត្ថុសក្តិសិទ្ធនានា។ ចំពោះការកត់ត្រាជាភាសាខ្មែរគឺពុំសូវមានការនិយមប្រើទេ បានន័យថា គឺមានការកត់ត្រាតិចតួចបំផុត។

***-ដំណាក់កាលទីពីរ*** ចាប់ពីសតវត្សទី១១ដល់សតវត្សទី១២ គឺជាសម័យកាលដែលអក្សរសាស្ត្រ អក្សរសិល្ប៍ខ្មែរមានការរីកចម្រើនលូតលាស់ខ្ពស់បំផុត ស្ថិតក្នុងស្ថានភាពដែលប្រទេសខ្មែរកំពុងមានការរីកចម្រើនយ៉ាងខ្លាំងលើគ្រប់វិស័យ។ នៅក្នុងសម័យនោះអត្ថបទភាគច្រើនត្រូវបានសរសេរលើស្បែកសត្វ បន្ទាប់មកទើបមានចម្លាក់រូបភាព។និន្នាការអក្សរសិល្ប៍នេះច្រើននិទានទាក់ទងនឹងលទ្ធិព្រាហ្មណ៍។ ការចារបៀបនេះពុំអាចរក្សាទុកបានយូរទេ ព្រោះទទួលរងការបំផ្លាញពីសត្វល្អិត និងបម្រែបម្រួលអាកាសធាតុ។ បច្ចុប្បន្ននេះ កេរដំណែលទាំងអស់នេះពុំមាននៅសេសសល់បន្តិចបន្តួចសោះឡើយ។

***-ដំណាក់កាលទីបី*** ចាប់ពីសតវត្សទី១៣ដល់សតវត្សទី១៤ នៅក្នុងដំណាក់កាលនេះ ប្រទេសជាតិបានថមថយអំណាចបន្តិចម្តងហេតុមកពីមានសង្គ្រាមជាមួយប្រទេសជិតខាង ដូចជាប្រទេសសៀម ប្រទេស

យួនជាដើម។ បញ្ហាផ្ទៃក្នុងប្រទេសក៏មានភាពរកាំរកូសណាស់ដែរ ហេតុដូចនេះហើយបញ្ហាអក្សរសាស្ត្រ អក្សរសិល្ប៍ក៏ថមថយទៅតាមនោះដែរ

នៅសម័យអង្គរបញ្ហាអក្សរសាស្ត្រ អក្សរសិល្ប៍មានការរីកចម្រើនលូតលាស់ណាស់ រហូតបានផ្សាយទៅរដ្ឋនានាដែលស្ថិតក្នុងចំណុះទៀតផង។ ខាងក្រោមនេះយើងនឹងលើកយកអ្នកនិពន្ធសំខាន់ៗនៅក្នុងសម័យអង្គរមកធ្វើការបង្ហាញជូនអ្នកសិក្សាដើម្បីស្វែងយល់ដូចតទៅ៖

## ១ បណ្ឌិត សិវសោម

លោកជាអ្នកប្រាជ្ញមួយរូប នៅក្នុងរជ្ជកាលព្រះបាទ**ឥន្ទ្រវរ្ម័នទី១** (៨៧៧-៨៨៩)។បណ្ឌិតរូបនេះមានចំណេះជ្រៅជ្រះខាងក្បួនច្បាប់ផ្សេងៗដែលទាក់ទងនឹងវិស័យអក្សរសាស្ត្រជាតិ ហើយលោកក៏បានរៀនចេះចប់ខាងគម្ពីរត្រៃវេទទៀតផង។ ឯកសារខ្លះបានសរសេរថា លោកបានសរសេររឿង **មហាភាតរយុទ្ធ** និងក្បួនខ្នាតវេយ្យាករណ៍ថែមទៀត។ ខាងក្រោមនេះ ខ្ញុំនឹងលើកយកស្នាដៃរបស់លោកមកធ្វើការបង្ហាញដើម្បីឲ្យអ្នកសិក្សាបានជ្រាប៖

### -សិលាចារឹកប្រាសាទកណ្ដាលដើម

ស្នាដៃសិលាចារឹករបស់លោក សរសេរជាអត្ថបទពាក្យកាព្យដែលអួតសរសើរពីបារមីព្រះបាទឥន្ទ្រវរ្ម័នទី១ថា ព្រះអង្គជាស្ដេចដែលមានឫទ្ធិខ្លាំងពូកែ ដែលមានឈ្មោះល្បីល្បាញធ្វើឲ្យសត្រូវបាក់បបខ្វបខ្វាចព្រះចេស្ដារបស់ព្រះអង្គឥតហ៊ានកម្រើកឡើយ។ ស្នាដៃបានបន្ថែមទៀតថា ព្រះបាទឥន្ទ្រវរ្ម័នទី១នេះហើយជាអ្នកកសាងប្រាសាទព្រះគោ និងប្រាសាទបាគង ដែលជាបុរាណដ្ឋានដ៏មានតម្លៃរបស់ខ្មែរនាពេលបច្ចុប្បន្ន។

ខាងក្រោមនេះ ជាអត្ថបទប្រែសម្រួលមកបង្ហាញជូនអ្នកសិក្សា ដើម្បីស្វែងយល់៖ [...]សូម្បីលោកកំពូលពួនអាត្មាក្នុងព្រៃស្ងាត់ក៏ដោយ រាជសត្រូវក្តីស្ទាងដោយប្រទីបជ័យជម្នះរបស់ព្រះអង្គ រត់ចូលមកជ្រកក្រោម ព្រះចាន ហាក់ដូចជាខ្លាចក្រែងព្រះអង្គចាប់ចានសារជាថ្មីទៀត[...]

ប្រយោគខាងលើនេះអ្នកបណ្ឌិតសិវសោម បានសរសេរអួតសរសើរពីបារមីនៃព្រះបាទឥន្ទ្រវរ្ម័នថាជាព្រះរាជា ដែលមានឫទ្ធានុភាពអស្ចារ្យដែលអាច ធ្វើឲ្យរាជសត្រូវនៅគ្រប់ទិសទីសុខចិត្តនាំគ្នាចុះញ៉មក្រោមព្រះចេស្តារបស់ព្រះអង្គជានិច្ច។

## ២ **បណ្ឌិតយតិអមរភាវៈ**

លោកបណ្ឌិតជាអ្នកប្រាជ្ញឯកដ៏សំខាន់មួយរូបនៅក្នុង រជ្ជកាលព្រះបាទយសោវរ្ម័នទី១(គ.ស៨៨៩ដល់៩០៨) ដែលត្រូវបានព្រះរាជាទ្រង់សព្វព្រះហរទ័យប្រោសព្រះរាជទានឋានន្តរសក្តិ ជាអធិបតីលើបណ្ឌិតទាំងឡាយ នៅក្នុងសម័យនោះទៀតផង។ ដោយគុណសម្បត្តិដ៏លើសលប់របស់លោកព្រះរាជាក៏ព្រះរាជទានលោកជា សង្ឃរាជនៅវត្ត **ឥន្ទ្រាស្រម** ដែលជាមជ្ឈមណ្ឌលដ៏ធំមួយនៅក្នុងសាសនាព្រាហ្មណ៍។ គេបានរកឃើញស្នាដៃរបស់លោកបន្សល់ទុកជាសិលាចារឹក ឈ្មោះថា សិលាចារឹក**ភ្នំបាយ័ង្គ** ដែលយើងលើកយកសេចក្តីសម្រង់ដែលមានសេចក្តីថា៖ [...]
សូមព្រះសិវៈដ៏មានជតាធំ ហើយដែលមានព្រះចានដូងជាដរាវណាធសមុខ ស្រែកថ្ងូរទ្រហឹងពេញអាកាសដោយសេចក្តី ឈឺចាប់, ថែរក្សាសម្បត្តិរបស់អ្នក[...]

តាមការបង្ហាញខាងលើនេះ លោកបណ្ឌិតយតិអមរភាវៈបាន អង្វរសុំឲ្យព្រះឥសូរ ដែលមានឫទ្ធិអំណាចអស្ចារ្យដែលអាចជាន់លើពួកយក្សមុខជប់ឲ្យស្រែកថ្ងូរទ្រហឹងពេញព្រៃនោះ សូមឲ្យព្រះអង្គតាមជួយថែរក្សាប្រជារាស្ត្រឲ្យបានសេចក្តីសុខចម្រើនកុំបីខានឡើយ។

តាមការលើកបង្ហាញខាងលើនេះដែរ ព្រះរាជូបត្ថម្ភបានបង្ហាញពីទឹកចិត្តស្នេហាជាតិពិតៗ និងពីវីរភាពដ៏អង់អាច របស់ព្រះបាទ យសោវរ្ម័នទី១ ដែលជាវីរក្សត្រមួយអង្គក្នុងសម័យសតវត្សទី៩ហើយដែលបានកសាងប្រាសាទអង្គរធំ ក្នុងគ្រិស្តសករាជទី៩០០ បន្ថែមពីលើនោះព្រះអង្គបានកសាងបន្ទាយការពារយ៉ាងរឹងមាំឈ្មោះថា **យសោធបុរៈ** ឬ**ឥន្ទ្របត្ថមហានគរ** ដើម្បីការពាររាជសត្រូវពីគ្រប់ទិសទី។

## ៣ បណ្ឌិតទិវាករ

លោកបណ្ឌិតទិវាករគឺជាអ្នកកវីនិពន្ធឯក ក្នុងរជ្ជកាលព្រះបាទរាជិន្ទ្រវរ្ម័នទី១ អំឡុងគ្រិស្តសករាជ៩៤៤ដល់៩៦៨ ដែលបណ្ឌិតរូបនេះបានចេះចាំស្ទាត់ខាងវិជ្ជាត្រៃវេទ ដែលលោកអាចសែកមន្តគាថាធ្វើឲ្យទ័ពសត្រូវវិនាសខ្ចាត់ខ្ចាយ មិនហ៊ានឈ្លានពាននគរឡើយ។ លោកបណ្ឌិតរូបនេះ បានសាងគុណសម្បត្តិជាច្រើនជូនប្រទេសជាតិរហូតព្រះរាជាសព្វព្រះរាជហរទ័យ ប្រទានព្រះរាជបុត្រីព្រះនាម**ឥន្ទ្រលក្ស្មី**ឲ្យធ្វើជាភរិយា។ ក្រៅពីសាងគុណសម្បត្តិដ៏មហាសាលជូនប្រទេសជាតិ លោកបណ្ឌិតទិវាករ នៅបាននិពន្ធសិលាចារឹកនៅប្រាសាទ**កំភីស**ដូចមានសេចក្តីថា៖

[...] ឆេះពេលរាលដោយព្រួញទិព្វរបស់ព្រះអង្គ មហាព្រៃនៃពួកសត្រូវលែងលូតលាស់ឡើងវិញ សូម្បីបើស្រោចស្រពដោយទឹក

ក្មេកពួកជីប្រឹក្សាក៏ដោយ[...]។ តាមន័យសេចក្ដីយ៉ាងខ្ចីខាងលើនេះ លោកបណ្ឌិតទិវាករបានសរសេរអួតសរសើរពីបារមី របស់ព្រះបាទ ជ័យវរ្ម័នទី៥ (៩៦៨ដល់១០០១)ដែលត្រូវជាបុត្រព្រះបាទ រាជិន្ទ្រវរ្ម័នទី១ថាជាក្សត្រប្រកបដោយបារមីក្លៀវក្លា អស្ចារ្យដែលបង្ក្រាបអស់ពួកសត្រូវឈ្លានពាននៅគ្រប់ទិសទី ឲ្យវិនាសសាបសូន្យប្រៀបប្រដូចនឹងមហាព្រៃស្ងប់ស្ងាត់ឈឹង ទោះបីមានពួកទីប្រឹក្សា មកដាស់តឿនយ៉ាងណាក៏លែងហ៊ានមកបៀតបៀនមហានគរទៀតដែរ។

## ៤ បណ្ឌិតកវិន្ទ្រៈ

លោកបណ្ឌិតកវិន្ទ្រៈ គឺជាអ្នកនិពន្ធយ៉ាងឆើតមួយរូបក្នុងរជ្ជកាលព្រះបាទសុរ្យវរ្ម័នទី១(គ.ស១០០២ដល់១០៤៩)។ លោកបានរៀនចាំចេះស្ទាត់នូវក្បួនច្បាប់គម្ពីរផ្សេងៗ ហើយក៏ជាអ្នកប្រាជ្ញយ៉ាងវាងវៃបំផុតដែលអាច ដោះស្រាយបញ្ហាផ្សេងៗបានយ៉ាងឆាប់រហ័សដោយ មិនចាំបាច់ចំណាយ ពេលគិតយូរឡើយ។ ដោយសារបញ្ញាដ៏វាងវៃរបស់លោកនេះហើយ ទើបបានជាព្រះបាទសុរ្យវរ្ម័នទី១បានតែងតាំងលោកជាទីប្រឹក្សាផ្ទាល់របស់ព្រះអង្គ។

លោកបណ្ឌិតកវិន្ទ្រៈ បានបន្សល់ទុកស្នាដៃរបស់លោកនៅ

ក្នុងសិលាចារឹកប្រាសាទខ្នាស្ថិតក្នុងខេត្តម្លូព្រៃ ដែលមានសេចក្ដីថា:

[...] ក្នុងសង្គ្រាម គ្រឿងអាវុធដែលពួកបច្ចាមិត្ត វាត់មកយ៉ាងជូន់លើព្រះអង្គដោយពេញកំហឹង ហាក់ដូចជាសត្វតូចមួយពិច ប្រស្រីក្រពៅប៉ុណ្ណោះ...។ ក្នុង

ប្រយោគខាងលើនេះ លោកបណ្ឌិតកវិន្ទ្រៈ បានបង្ហាញនូវព្រះបេស្តា ព្រះបាទសុរ្យវរ្ម័នទី១ ក្នុងគ្រាដែលព្រះអង្គយាងចេញទៅធ្វើសឹកសង្គ្រាម ជាមួយសត្រូវៗ លោកបណ្ឌិតបានបន្តទៀតថា កាលដែលសត្រូវបាន វាយប្រហារដោយអាវុធមកលើព្រះអង្គមានដាវ លំពែងជាដើមនោះ គឺ ពុំបានធ្វើឲ្យព្រះអង្គទ្រង់ញញើតបន្តិចសោះឡើយ តែផ្ទុយទៅវិញ គ្រឿងអាវុធទាំងនោះពុំបានធ្វើឲ្យព្រះអង្គឈឺចាប់ដល់ព្រះកាយបន្តិច សោះឡើយ ពោលគឺគ្រាន់តែធ្វើ ឲ្យព្រះអង្គសៅហ្មងបន្តិចបន្តួចប៉ុណ្ណោះ ប្រៀបដូចជាសត្វដ៏តូចមួយមកទិច ឬដូចជាស្រីក្រទៅបាវព្រាវតែ ប៉ុណ្ណោះៗ

## ៤ បណ្ឌិតកូបន្ទ្រៈ

លោកបណ្ឌិតរូបនេះគឺ ជាអ្នកប្រាជ្ញដ៏ល្បីល្បាញមួយរូបស្ថិតក្នុង រជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ (គ.ស១១៦១-១២១៨)ៗ លោកត្រូវបានព្រះ មហាក្សត្រ តែងតាំងជាអធិបតីលើគណៈអ្នកប្រាជ្ញទាំងឡាយ ហើយក៏ ជាទីប្រឹក្សារបស់ព្រះពជាផងដែរៗ តាមឯកសារ G.odes,Insc, du cambodge,1, p,228បានសរសេរថា លោកជាចៅក្រមដ៏ល្បីល្បាញមួយ រូបផង ព្រោះលោកជាអ្នកដែលមានស្មារតីទូលំទូលាយខាងផ្នែកច្បាប់ៗ

ស្នាដៃសិលាចារឹករបស់លោក មានបន្សល់ទុកនៅប្រាសាទ**ទរ** ស្ថិតក្នុងប្រទេសលាវសព្វថ្ងៃៗ ខាងក្រោមនេះ គឺជាអត្ថបទដកស្រង់នៃ សេចក្តីនៅក្នុងសិលាចារឹកនោះ

[...] ទ្រង់ជ្រាបថា ដែនដីព្រះអង្គដែលទ្រង់ចាងកសាងឲ្យក្លាយ ទៅជាស្ថានសួគ៌ដោយព្រះប្រាជ្ញាញាណ ត្រូវមរណៈព្យាចាងហើយ ទើបទ្រង់ដឹកនាំយកទឹកអម្រឹតធ្វើជាភេសជ្ជៈ ដើម្បីញុំាងសត្វដែល

លើនេះ បានបង្ហាញពីសម្រង់ពាក្យពេចន៍ ដែលជាស្នាដៃដ៏ល្អឯករបស់លោកបណ្ឌិត ភូបន្ទ្រៈដែលបានសរសើរ ពី ព្រះកិត្តិគុណរបស់ព្រះបាទជ័យវរ្ម័នទី៧ជាព្រះអង្គជាក្សត្រ ដែលប្រកប ដោយព្រះមេត្តាធម៌យ៉ាងក្រៃលែង ដែលព្រះអង្គបានកសាងមន្ទីរពេទ្យ សម្រាប់ព្យាបាលជាច្រើនកន្លែងសម្រាប់ប្រជាជន ដូចជាសេចក្ដីផ្ដើមបានសរសេរថា ដែនដីរបស់ព្រះអង្គខំកសាងឲ្យមានភាពសុខសាន្ត សម្បូរសប្បាយដូចស្ថានសួគ៌នោះ ឥឡូវត្រូវរោគរាតត្បាតញាំញីហើយ ទើបព្រះអង្គ បានណែនាំប្រជារាស្ត្រព្រះអង្គឲ្យកសាងខ្លួនតាមផ្លូវល្អ ពោលគឺផឹកនូវទឹកអម្រឹតរស់ដែលជាសីលធម៌របស់ពុទ្ធសាសនា និងកែរោគជនទាំងនោះដោយមានបង្កើតក្រុមគ្រូពេទ្យ សម្រាប់ព្យាបាលជំងឺផ្សេងៗដោយឱសថនានាដ៏សក្តិសិទ្ធ។

## ៦ ព្រះនាងឥន្ទ្រទេវី

ព្រះនាងជា ព្រះអគ្គមហេសីទី២របស់ព្រះបាទជ័យវរ្ម័នទី៧ បានសេចក្ដីថាព្រះនាងបានទទួលរាជាភិសេក ជាមួយព្រះចៅផែនដីក្រោយពេលដែលព្រះអគ្គមហេសីដើមព្រះនាមជ័យរាជទេវី ដែលត្រូវជាព្រះរាជកនិដ្ឋា បានចូលទីវង្គត។ ព្រះនាងឥន្ទ្រទេវីទ្រង់បានណែនាំព្រះរាជាឲ្យមានសទ្ធាជ្រះថ្លាក្នុងពុទ្ធសាសនា និងបានកសាង វប្បធម៌ជាតិយ៉ាងច្រើន ដូចជាបានកសាងសាលាបាលីជាន់ខ្ពស់សម្រាប់បង្រៀនកូនចៅខ្មែរ ព្រមទាំងបានបង្កើតរង់ល្ខោនសម្រាប់សម្ដែងទៀតផង។ ក្នុងសម័យនោះ ព្រះនាងបានក្លាយជាអគ្គសានូបត្ថម្ភខាងផ្លូវព្រះពុទ្ធសាសនាផង

ដែរ។ ក្រៅពីនេះព្រះនាងនៅបានកសាងសិលាចារឹកនៅប្រាសាទភិមានអាកាស ដូចមានសេចក្ដីសម្រង់មកថា៖

[...] ដោយមានភក្ដីភាពចំពោះស្វាមីលុះត្រានិព្វាន ព្រះនាងទ្រង់ធ្ងន់ធ្ងរទ្រង់ចាំឲ្យឃើញថា ព្រះរាជាទ្រង់ថ្វាយ ព្រះអង្គស៊ប់ក្នុងព្រះពុទ្ធឱវាទសិន ទើបព្រះនាងយាងចូលទៅកាន់ និព្វានជាក្រោយ...។

តាមន័យសេចក្ដីខាងលើ ព្រះនាងឥន្ទ្រទេវីបានចារឹកទុកពីទឹកព្រះទ័យនៃព្រះនាងជ័យរាជទេវីដែលជាព្រះរាជកនិដ្ឋា នឹងជាមហេសីដើមរបស់ព្រះបាទជ័យវរ្ម័នទី៧ ព្រះនាងមានភក្ដីភាពយ៉ាងស្មោះស្ម័គ្រជាមួយព្រះស្វាមី លុះអវសានហើយនៅមុនពេលដែលព្រះនាងសុគតទៅ ព្រះនាងនៅមានបំណងចង់ឃើញ ព្រះបាទជ័យវរ្ម័នទី៧ទ្រង់ងាកមកជឿស៊ប់លើព្រះពុទ្ធសាសនា ទើបគ្រាចុងបញ្ចប់ព្រះនាងទ្រង់ទីវង្គត។ ក្រៅពីបណ្ឌិតទាំងប្រាំមួយរូបខាងលើ ក៏នៅមានបណ្ឌិតពីររូបទៀតដែលល្បីល្បាញក្នុងសម័យអង្គរដែរ ដូចជាបណ្ឌិតយោគី ស្វរបណ្ឌិត និពន្ធសិលាចារឹកនៅប្រាសាទតាកែវខេត្តសៀមរាប និងបណ្ឌិតសិវាចារ្យនិពន្ធសិលាចារឹក ជាភាសាសំស្ក្រឹតនៅប្រាសាទតាកែវ នៅគោបុរៈខាងក្នុងផងដែរ។

សរុបសេចក្ដីមក អក្សរសាស្ត្រដែលបានចារលើផ្ទាំងសិលា គឺបានបង្ហាញឲ្យឃើញនូវអារ្យធម៌ខ្មែរបុរាណ ជាពិសេសគឺអក្សរសាស្ត្រយើងកាលពីសម័យអង្គរ។ ដូចដែលបានដឹងរួចមកហើយថា អក្សរ-សាស្ត្រខ្មែរយើងកាលពី សម័យនោះគឺស៊ីវិល័យភាសាសំស្ក្រឹត ព្រោះប្រទេសយើងបានយកភាសានេះធ្វើជាភាសាយាន តែក្រោយមកទើប

មានភាសាបាលី បានហូរចូលមកបំពេញបន្ថែមហើយក៏បានបង្កើតជាមូលដ្ឋាននៃអក្សរសាស្ត្រជាតិ។

ដើម្បីជាសក្ខីភាពសម្រាប់អ្នកសិក្សាដែលចង់ចេះ ចង់យល់បន្ថែមទៅលើអក្សរសិល្ប៍សម័យអង្គរ ថាមានរសជាតិយ៉ាងណានោះខាងក្រោមនេះខ្ញុំនឹងលើកយកមកបង្ហាញពីស្នាដៃអក្សរសិល្ប៍ សម័យអង្គរ នូវរឿងមួយគឺរឿង **រាមកេរ្តិ៍**មានសេចក្តីដូចតទៅ៖

# រឿង រាមកេរ្តិ៍

## I សេចក្តីផ្តើម

ស្នាដៃអក្សរសិល្ប៍រឿងរាមកេរ្តិ៍ ជាវណ្ណកម្មមួយដ៏ល្បីល្បាញរបស់ខ្មែរដែលត្រូវបានអ្នកសិក្សាចាត់ទុក ជាស្នាដៃមួយក្នុងចំណោមស្នាដៃដ៏ល្អមួយនៅទ្វីបអាស៊ី។ រឿងរាមកេរ្តិ៍ខ្មែរ ត្រូវបានលោកកវីនិពន្ធខ្មែរ ធ្វើការច្នៃកាឡៃចេញពីរឿង**រាមាយណៈ**របស់ឥណ្ឌា តែពុំមែនបានន័យថារឿងនេះចម្លងចេញពីរាមាយណៈទាំងស្រុងដែរ ពោលគឺលោកបានបញ្ចូលនូវឧត្តមគតិ ស្របនិងព្រលឹងជាតិពិសេស គឺស្របទៅតាមទេពកោសល្យដ៏ប៉ិនប្រសប់របស់លោកកវីអ្នក និពន្ធខ្មែរ។ រឿងរាមកេរ្តិ៍ខ្មែរត្រូវបានបញ្ចូលលក្ខណៈមនុស្សជាច្រើនជាងលក្ខណៈទេវៈ ជាពិសេស បញ្ចូលនូវលក្ខណៈជាតិនិយម តម្លៃវប្បធម៌ជាតិ និងតម្លៃនៃការពិចារណារកហេតុផលច្បាស់លាស់ទៅក្នុងនោះ ដែលញ៉ាំងឲ្យប្រជាពលរដ្ឋខ្មែរគ្រប់ស្រទាប់វណ្ណៈ មានការនិយមរាប់អានលើវណ្ណកម្មនេះ

រហូតដល់ពេលបច្ចុប្បន្ន។ បន្ថែមពីលើនេះ ពួកគាត់ថែមទាំងបានយករឿងនេះមកច្នៃចេញជាឈុតជាឆាក សម្រាប់សម្តែងជារឿងល្ខោនថែមទៀតផង។ អ្វីដែលរិតតែអស្ចារ្យទៅទៀតនោះ គឺបុព្វបុរសខ្មែរបានយកផ្នែករឿងមួយអន្លើ ទៅចារឆ្លាក់ជាប់នៅជញ្ជាំងប្រាសាទបុរាណខ្មែរ ហើយដែលរូបចម្លាក់ទាំងនេះហើយជាមូលដ្ឋាននៃទម្រង់របាំខ្មែរបុរាណ

## II. ប្រវត្តិរឿងរាមកេរ្តិ៍

ដូចអ្វីបានជម្រាបជូនខាងលើ ឲ្យបានជ្រាបស្រាប់ហើយថា រឿងរាមកេរ្តិ៍បានទទួលឥទ្ធិពលពីរឿងរាមាយណៈ របស់ប្រទេសឥណ្ឌា ហើយត្រូវបានជ្រាបចូលមកក្នុង ប្រទេសកម្ពុជាអស់កាលជាយូរលង់ណាស់មកហើយ គឺមុនសម័យអង្គរទៅទៀត។ រឿងរាមកេរ្តិ៍របស់ខ្មែរមាន១៦ខ្សែ គឺមានពីខ្សែទី១ ដល់ខ្សែទី១០ និងពីខ្សែទី៧៥ ដល់ខ្សែ ទី៨០ ដូច្នេះយើងឃើញថារឿងរាមកេរ្តិ៍ខ្មែរយើងនៅបាត់ពីខ្សែទី១១ ដល់ខ្សែទី៧៤ហើយរកសាច់រឿងពុំទាន់ឃើញ ចំពោះមូលហេតុនៃការបាត់បង់ គឺពុំទាន់ដឹងពីមូលហេតុពិតប្រាកដនៅឡើយទេ។

ទាក់ទិននិងមូលហេតុ នៃការបាត់បង់នេះបើតាមទស្សនៈរបស់លោក**លាង ហាប់អាន**ក្នុងសៀវភៅ សិក្សាអត្ថបទរឿងរាមកេរ្តិ៍ខ្មែរ និងរឿងរាមាយណៈឥណ្ឌា បានអះអាងថាការបាត់បង់សាច់រឿងដ៏ច្រើនសន្ធឹកសន្ធាប់នេះគឺ អាចស្ថិតនៅអាកាត់អាកាយនៅតាមវត្តអារាម ឬនៅទីជនបទនានាដែលយើងពុំអាចដឹង ព្រោះនៅទីវត្តអារាម មិនត្រឹមតែជាកន្លែងសម្រាប់បូជាខាងផ្លូវសាសនាប៉ុណ្ណោះទេ តែថែមទាំងជាឃ្លាំងសម្រាប់រក្សាក្បួនខ្នាតតម្រានានា។ ផ្ទុយពីនេះទៅវិញការបាត់បង់ក៏អាចបណ្តាលមកពីបញ្ហាសង្គ្រាមជាមួយបរទេសដូចជា សៀម បារាំង យួន ជាដើម ហើយដែលពួកវាបាន ជញ្ជូនយកទៅតម្កល់ទុកជាឯកសារ

របស់ពួកវា ហើយដែលពួកវាបានយកទៅកាឡៃច្នៃបន្ថំតាមវិធីផ្សេងៗ ឲ្យស្របទៅតាមជាតិសាសន៍របស់គេៗ

ចំពោះលោកអៀវ កើសបានពន្យល់នៅក្នុងសៀវភៅកាសាខ្មែរ របស់លោកថា សៀមមានទំនាក់ទំនងជាមួយ ខ្មែរចាប់តាំងពីសតវត្សទី ៣ រហូតដល់សតវត្សទី១៣ ហើយបន្តរហូតដល់ពេលដែលសៀមដណ្តើមបានសុខោទ័យ នៅសតវត្សទី១៣ បន្ទាប់មកគឺពួកវាបានបណ្តេញខ្មែរឲ្យចាកចោលក្រុងអង្គរៗ បន្ទាប់មកទៀតសៀមបានវាយបំបែកបន្ទាយលង្វែកនៅចុងសតវត្សទី១៦ ហើយវាបានប្រមូលគម្ពីរ សាស្រ្តាតម្រាផ្សេងៗ ព្រមទាំងបានកៀរយកអ្នកប្រាជ្ញ រាជបណ្ឌិត ព្រមទាំងប្រជាជនខ្មែរ និងទ្រព្យសម្បត្តិដ៏មានតម្លៃជាច្រើនទៀតៗ តាមការអះអាងនេះ អាចញ្ញាក់ថាប្រហែលមកពីបញ្ហានេះហើយ ដែលយើងត្រូវបាត់បង់រឿងរាមកេរ្តិ៍ពីខ្សែទី១១ដល់ខ្សែទី៧២ជាប្រាកដៗ ចំពោះលោក**ជូ កែវ**បានធ្វើការអះអាងនៅក្នុងសារណាបរិញ្ញា-បត្ររបស់លោកដែលមានចំណងជើងថា **ប្រៀបធៀបតួអង្គរឿងរាមកេរ្តិ៍ និងរឿងរាមាយណ:**ៗ លោកបានអះអាងថារឿងរាមកេរ្តិ៍អាចនឹងមិនត្រូវបាត់បង់ទេ ពីព្រោះតាមដំណើររឿងត្រឹមខ្សែទី១០ ក្រុងរាពណ៍បានបាត់បង់កូនទាំង ១០និងសេនាពូកែអស់ទៅហើយពុំមានលទ្ធភាព ធ្វើចម្បាំងទៀតទេ ផ្ទុយទៅវិញបើគេទៅពឹងមិត្តឈ្មោះមូលផលម៍នៅក្រៅចក្រវាឡឲ្យជួយធ្វើសង្រ្គាមខ្លួននោះ សាច់រឿងអូសបន្លាយយ៉ាងច្រើនត្រឹមមួយខ្សែប៉ុណ្ណោះនឹងត្រូវចប់ទៅហើយៗ ចំពោះការបាត់បង់នេះ លោកបានបន្តទៀតថា គឺដើម្បីឲ្យស្របទៅនិងជន្មាយុរបស់ព្រះពុទ្ធ គឺអំឡុងពេលដែលអ្នកនិពន្ធជាពុទ្ធសាសនិក បានព្យាយាមទាញរឿងរាមកេរ្តិ៍ពីរឿងរាមាយណ:ឥណ្ឌា គឺឲ្យស្របទៅនឹងអាយុកាលព្រះពុទ្ធដែលមានត្រឹមតែ៨០

ព្រះវស្សា ហេតុដូច្នេះទើបអ្នកនិពន្ធបង់លេខដេញចុះពី៨០មកក្រោមវិញៗ ចំពោះលោក**ឃើងហុកឌី**បានពន្យល់ នៅក្នុងសៀវភៅទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ ថាខ្សែទី៨០មិនមែនជាទីបញ្ចប់នៃរឿងរាមកេរ្តិ៍ទេ ហើយចន្លោះខ្សែទី១០ដល់៧៤ ដោយបាត់ឯកសារផងដោយពឹងលើការស្រាវជ្រាវផង លោកបានរកឃើញឧបកថាមួយទៀតដែលនៅក្នុងច្បាប់នានាអ្នកឯកទេសបានធ្វើការសិក្សាមកហើយៗ

### III កាលបរិច្ឆេទរឿង

រឿងរាមកេរ្តិ៍ខ្មែរ ពុំមានកាលកំណត់ច្បាស់លាស់ទេ ពោលគឺគ្រាន់តែ មានទស្សនៈខ្លះៗដែលសម្អាងទៅលើ ឥទ្ធិពលនៃសាសនាព្រាហ្មណ៍នៅក្នុងសង្គមខ្មែរនាសម័យអង្គរ ព្រោះនៅតាមជញ្ជាំងប្រា-សាទមួយចំនួន មានចម្លាក់ទាក់ទងនឹងរឿងរាមកេរ្តិ៍ខ្មែរផង រឿងរាមា-យណៈឥណ្ឌាផងៗ ប្រាសាទទាំងអស់នោះមានៈ

-ចម្លាក់នៅប្រាសាទបន្ទាយស្រី ក្នុងសតវត្សទី១០មានចម្លាក់ទាក់ទងនិងរឿងរាមកេរ្តិ៍ត្រង់ៈ ក្រុងរាពណ៍ឆក់នាងសីតា ព្រះរាមលបបាញ់ក្រុងពាលី ក្រុងរាពណ៍រញ្ជួយនៅឋានកៃឡាស(ទាក់ទងនិងរឿងរាមាយណៈ)ៗ

-ចម្លាក់នៅប្រាសាទបាពួន ពាក់កណ្តាលសតវត្សទី១១មានជាប់ទាក់ទងនិងរឿងរាមកេរ្តិ៍និងរឿងរាមាយណៈៗ

-នៅត្រង់ ព្រះរាមឲ្យនាងសីតាដើរកាត់ភ្លើង ព្រះរាមជួបនិងសុគ្រីព ៗ

-ចម្លាក់នៅប្រាសាទអង្គរវត្ត មានជាប់ទាក់ទងនិងរឿងរាមកេរ្តិ៍ត្រង់កូរសមុទ្រទឹកដោះ ព្រះរាម និងនាងសីតា នៅឋានសួគ៌ និងក្រុងរាពណ៍កាឡាខ្លួនឲ្យដូចព្រះរាមៗ ដោយផ្អែកតាមកស្តុតាងខាងលើនេះ

ឃើញថា រឿងរាមកេរ្តិ៍តែងឡើងក្នុងសម័យអង្គរ រវាងសតវត្សទី១០ឬទី១២នៃគ្រឹស្តសករាជ។ ផ្ទុយទៅវិញ បើពិនិត្យតាមឯកសាររបស់ព្រះអង្គម្ចាស់វិឡ្លនធាយាវង្សនៅខ្សែទី៧៩ដល់ ខ្សែទី៨០ឃើញថាភាសាដែលកត់ត្រាគឺអក្សរខ្មែរកណ្ដាល។ ប្រការនេះមកពីខ្មែរយើងទម្លាប់ចម្លងអត្ថបទនីមួយៗតគ្នា ដោយប្រែតួអក្សរស្របទៅតាមពេលវេលា ទើបនាំឲ្យមានការពិបាកក្នុងការសិក្សារកកាលបរិច្ឆេទច្បាស់លាស់។ ទោះបីជាយ៉ាងនេះក្តី ក៏គេអាចសន្និដ្ឋានថារឿងរាមកេរ្តិ៍ កើតឡើងក្នុងសម័យអង្គរដែរ ព្រោះសម្អាងលើចម្លាក់តាមជញ្ជាំងប្រាសាទក្នុងសម័យអង្គរ។

តាមទស្សនៈរបស់លោកបណ្ឌិតមីសែល ត្រាណេតាមរយៈសៀវ-ភៅការសិក្សារឿងរាមកេរ្តិ៍បានអះអាងថា រឿងរាមកេរ្តិ៍ខ្មែរក្លាយជាឧប-ករណ៍ស្ថិតនៅជាប់ដួងព្រលឹងខ្មែរ ក្នុងត្របៀក ក្នុងភ្នែកខ្មែរតាំងពីពាក់កណ្តាលសតវត្សទី៦មកម្លេះ ដាក់ស្តែងរូបចម្លាក់ព្រះលក្ស្មណ៍ រាមបរមសួរ និងពលរាមនៅក្នុងរចនាបថក្តំដា ជាសិលាចារឹក និងចម្លាក់នៅតាមជញ្ជាំងប្រាសាទខ្មែរមុនសម័យអង្គរជាដើម។

តាមទស្សនៈរបស់លោកញ៉ុក ថែមបានបញ្ជាក់ក្នុងតារាងប្រវត្តិអក្សរសិល្ប៍ខ្មែរថា៖

-ពីខ្សែទី១ដល់ខ្សែទី១០ ប្រហែលជារៀបរៀងនៅសតវត្សទី១៧-១៨រវាងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី២ មកទល់និងរជ្ជកាលព្រះអង្គអេងហើយសរសេរដោយអ្នកនិពន្ធម្នាក់។

-ពីខ្សែទី៧៥ដល់ខ្សែទី៨០ ប្រហែលជានិពន្ធក្នុងរជ្ជកាលព្រះអង្គអេង មកទល់នឹងរជ្ជកាលព្រះបាទអង្គឌួង ហើយសរសេរដោយអ្នកនិពន្ធម្នាក់ទៀត។ តាមទស្សនៈរបស់អ្នកស្រី**ពៅ សាវរស**បានអះអាងថា រឿងរាមកេរ្តិ៍បានចែកចេញជាពីរជំពូកគឺ៖

-ផ្នែកទីមួយត្រូវនឹង សៀវភៅពុទ្ធសាសនបណ្ឌិត្យភាគ១ ដល់ភាគទី១០មានទាំងអស់៥០៣២វគ្គ តែងឡើងរវាងសតវត្សទី១៦ឬទី១៧ប៉ុណ្ណោះ។

-ផ្នែកទីពីរ ត្រូវនឹងសៀវភៅពុទ្ធសាសនបណ្ឌិត្យភាគ៧៥ដល់ភាគទី៨០មានទាំងអស់មាន១៧៧២វគ្គ និពន្ធឡើងរវាងសតវត្សទី១៨នៃគ្រិស្តសករាជ។ បើតាមទស្សនៈរបស់លោក**សរ សារុន**បានវិភាគទៅលើកាលបរិច្ឆេទរឿងរាមកេរ្តិ៍តាមវិធីបីយ៉ាងគឺៈ

**វិធីទី១** គេអាចប្រៀបធៀបពាក្យសម្តី ឃ្លា ប្រយោគដែលមានប្រើក្នុងរឿងរាមកេរ្តិ៍ ទៅអក្សរសិល្ប៍សិលាចារឹកនៅសម័យណាមួយ។

**វិធីទី២** គេអាចប្រៀបធៀបដំណើររឿងរាមកេរ្តិ៍ទៅនឹងដំណើររឿងដែលមាននៅតាមជញ្ជាំង ប្រាសាទដែលមានប្រាសាទចំនួនបួនជាប់ទាក់និងរឿងរាមកេរ្តិ៍។ ប្រាសាទទាំងនោះរួមមានដូចជាៈ

-ប្រាសាទកោះកេរ្តិ៍ ដើមសតវត្សទី១០

-ប្រាសាទបន្ទាយស្រី ពាក់កណ្តាលសតវត្សទី២ដល់សវត្សទី១០

-ប្រាសាទបាពួន ពាក់កណ្តាលសតវត្សទី២ ដល់ទី១១

-ប្រាសាទអង្គរវត្ត ពាក់កណ្តាលសតវត្សទី១ ដល់ទី១២

តាមចម្លាក់ទាំងឡាយ ដែលមាននៅក្នុងប្រាសាទខាងលើនេះអ្នកសិក្សាពិបាកក្នុងការបញ្ជាក់កាលបរិច្ឆេទរឿងណាស់ ព្រោះដំណើររឿងតាមចម្លាក់មានជាប់ទាក់ទងរឿងរាមកេរ្តិ៍ខ្មែរផង និងរឿងរាមា- យណៈរបស់ឥណ្ឌាផង។

**វិធីទី៣** តាមរយៈរឿងរាមកេរ្តិ៍ខ្មែរ គេអាចដកស្រង់សង្គម បរិយាកាសមួយដែលស្ថិតនៅលើទំនាស់សាសនា គឺរវាងសាសនាព្រះពុទ្ធនិងសាសនាព្រះវិស្ណុ។ អ្នកនិពន្ធខ្មែរ មិនមានបំណងលើកតម្កើងព្រះរាម

ហើយក៏មិនមានការរិះគន់ព្រះរាមដែរ តែគ្រាន់តែធ្លៀតឱកាសតាមដំណើររឿង ដើម្បីបញ្ចុះតម្លៃព្រះរាមប៉ុណ្ណោះ។ មានពេលខ្លះអ្នក និពន្ធបានប្រើវិធីលើកតម្កើងព្រះរាមយ៉ាងខ្ពស់ ហើយបន្ទាប់មកក៏បញ្ចុះតម្លៃព្រះរាមវិញ។ ការបញ្ចូលដំណើររឿង ដែលទាក់ទងនឹងសង្គមបរិយាកាសរបស់ខ្មែរបែបនេះ បានធ្វើឲ្យរឿងរាមកេរ្តិ៍ខ្មែរមានតម្លៃពិសេសមិនអាចកាត់ថ្លៃបានរបស់ខ្មែរ ដែលបានបន្សល់ទុករហូតមកដល់សព្វថ្ងៃនេះ។ ដូច្នេះតាមរយៈបរិយាកាស នៃទំនាស់សាសនាតាមរយៈរឿងរាមកេរ្តិ៍ អាចឲ្យអ្នកសិក្សាសន្និដ្ឋានបានថា រឿងរាមកេរ្តិ៍ខ្មែរប្រហែល ជាត្រូវបាននិពន្ធឡើងនៅចុងសតវត្សទី១២និងដើមសតវត្សទី១៣នៃគ្រិស្តសករាជ។

## IV សង្ខេបរឿង

បន្ទាប់ពីព្រះរាម និងព្រះលក្ស្មណ៍បានរៀនចប់សិល្បវិជ្ជាពីឥសីពិស្វាមិត្រ លោកឥសីក៏បានរៀបចំហោមពិធីមួយ។ ខណៈនោះមានយក្សមួយឈ្មោះតាកនាសូរ បានហោះមកចឹកបំផ្លាញពិធីនោះអស់ លោកឥសីខឹងក៏ជបធ្នូសរ ឲ្យព្រះរាម ព្រះលក្ស្មណ៍បាញ់យក្សនោះស្លាប់ទៅ។

ចំណែកនៅនគរមិថិលា ព្រះរាជាព្រះនាមជនកបានទៅច្រត់ព្រះនង្គ័លក្បែរឆ្នេរស្ទឹងយមនា បានរើសទារិកាម្នាក់ដែលអណ្តែតតាមពោងពាយ ព្រះអង្គក៏រើសយកមកចិញ្ចឹមជាបុត្រហើយដាក់ឈ្មោះថានាងសីតា។ ពេលនាងសីតាពេញវ័យ ព្រះបាទជនកបានធ្វើពិធីលើកធ្នូស រើសអ្នកខ្លាំងពូកែមកធ្វើជាស្វាមីរបស់នាងសីតា។ បេក្ខជនជាច្រើនបានមកចូលរួមមានដូចជា ព្រះឥន្ទ្រ ព្រះព្រហ្ម ព្រះសុរិយា ទេវតាច្រើនអង្គទៀត ក្នុងនោះក៏មានព្រះរាម និងព្រះលក្ស្មណ៍ដែរ តែមានតែព្រះ

រាមទេដែលអាចលើកធ្នូនោះរួច។ ព្រះបាទទសរថត្រូវយាងមកពិធីរៀបអភិសេកបុត្រ ហើយពេលធ្វើដំណើរត្រលប់មកនគរវិញបានជួបយក្សរាមបរមសួរ។ រាមបរមសួរបានចោទព្រះបាទទសរថ ថាលួចឈ្មោះខ្លួនដាក់ឲ្យបុត្ររបស់ព្រះអង្គ ហើយក៏ត្រូវព្រះរាមផ្ចាញ់វាទៅ។ លុះត្រលប់មកដល់នគរអយុធ្យាវិញ ព្រះបាទទសរថបម្រុងផ្ទេររាជសម្បត្តិឲ្យព្រះរាមប៉ុន្តែនាងកៃកេសី ជាមហេសីទាមទារការប្រគល់រាជសម្បត្តិឲ្យព្រះភិរុតជាបុត្របង្កើតរបស់ខ្លួន តាមសន្យាដែលព្រះបាទទសរថយល់ព្រមជាមួយនាងកាលនាងជួយព្រះអង្គឲ្យច្បាំងឈ្នះព្រះអាទិត្យ។

ព្រះបាទទសរថចង់បែងចែកនគរជាពីរ ប៉ុន្តែនាងកៃកេសីមិនព្រមហើយបានសុំឲ្យនីរទេសព្រះរាមចេញពីនគរ១៤ឆ្នាំ។ ព្រះលក្ស្មណ៍ខឹងណាស់ក៏ដកធ្នូបម្រុងប្រហារនាងកៃកេសី តែត្រូវព្រះរាមឃាត់ទាន់។ ព្រះរាមក៏សម្រេចចិត្តទៅចូលព្រៃបួស១៤ឆ្នាំចំណែក ព្រះលក្ស្មណ៍និងនាងសីតាក៏សុំខ្លួនទៅតាមបម្រើព្រះអង្គដែរ។ នៅតាមផ្លូវបានជួបក្រុមឥសី និងថ្មើរព្រៃឈ្មោះកូខ័ន ដែលពួកគេសុំខ្លួនទៅបម្រើ និងផ្គត់ផ្គង់ព្រះអង្គគ្រប់បែបយ៉ាង តែព្រះរាមឲ្យនៅរក្សាព្រៃ និងសេនាចុះ បន្ទាប់មកក្សត្រទាំងបីក៏បន្តដំណើរទៅភ្នំចិត្រកូដទៀត។ នៅរដូវប្រាំងអាកាសធាតុក្តៅហួតហែង ធម្មជាតិក្រៀមក្រញ៉ម តែដោយសារបារមីរបស់ព្រះរាម ពេលទ្រង់ឆ្លងកាត់ទីនេះ រុក្ខជាតិទាំងឡាយនោះ ប្រែជារីកស្រស់ស្រាយចេញផ្លែផ្កាស្រស់បំព្រង ហើយធាតុអាកាស ប្រែជាត្រជាក់ស្រួលសត្វកាចប្រែជាស្លូត។ ក្សត្រទាំងបីបានសំណាក់អាស្រ័យនៅអាស្រមឥសីពារទ្វាទ្យ រួចបន្តដំណើរដល់ទន្លេកាលតីទើបព្រះលក្ស្មណ៍ធ្វើក្បូនឆ្លង និងបានទៅដល់ភ្នំចិត្រកូដនៅពេលរសៀល។ នៅនគរឲ្យយុធ្យាឯណេះវិញ ក្រោយពេលព្រះបាទទស-រថសោយទីវង្គត នាងកៃកេសីបាន

បញ្ជោតបុត្រឲ្យមកនគរដើម្បីសោយរាជ្យ តែព្រះភិរុតមិនយល់ព្រម ក៏ចូលក្នុងព្រៃយាងព្រះរាមឲ្យមកគ្រងរាជ្យវិញ តែព្រះរាមបានបំពេញនូវពាក្យសច្ចៈរបស់ព្រះបិតា ដោយត្រូវចម្រើនតបៈ១២ឆ្នាំសិន។ ដោយគិតឃើញថា ភ្នំចិត្រកូដនៅជិតពួយុធ្យាពេក ក្សត្រទាំងបីក៏បន្តដំណើរទៅមុខទៀត ហើយក៏បានជួបយក្សពិរាធដែលបម្រុងសម្លាប់ទ្រង់ដណ្តើមនាងសីតា តែក៏ត្រូវព្រះរាមផ្ទៃងសរបាញ់សម្លាប់ចោលទៅ។

នៅពេលព្រះរាម និងព្រះលក្ស្មណ៍កំពុងតាំងសិល្ប៍ស្រាប់តែមានយក្សមួយឈ្មោះនាងសូរបនខា បានប្រែក្រឡាជាស្រីស្អាតមកចែចង់រហូត ទាល់តែព្រះលក្ស្មណ៍ខឹងក៏ចាប់នាងយក្សនោះកាត់ច្រមុះ និងកោសក់នាង។ នាងយក្សស្រែកយំព្ទទ្រហឹង ហើយបានដឹងដល់បងប្រុសឈ្មោះក្រុងខរ ហើយនៅទីបំផុតសង្គ្រាមក៏បានកើតឡើង ដែលបណ្តាលឲ្យខុនទូសណ៍ជាប្អូន ត្រីសិរជាកូន និងក្រុងខរត្រូវព្រះរាមសម្លាប់ទាំងអស់។ នាងសូរបនខាបានហោះទៅក្រុងលង្កានឹងបាន ញុះញង់ក្រុងរាពណ៍ជាបងឲ្យជួយសងសឹក នឹងចាប់នាងសីតាដ៏ស្រស់ស្អាតមកទុកផង។ រាពណ៍បានប្រើមហារីកឲ្យកាឡាខ្លួនជាប្រើសមាសទៅបញ្ជោតព្រះរាម ព្រះលក្ស្មណ៍ ឯខ្លួនកាឡាជាឥសីទៅឆក់នាងសីតាយកទៅក្រុងលង្ការ។ នៅពេលដែលលង្កាចាប់នាងសីតាទៅ នៅតាមផ្លូវនាងសីតាបានជួបនឹងកុកស ហើយនាងបានផ្តាំកុកឲ្យជួយប្រាប់ព្រះរាមផងបន្ទាប់មករាពណ៍បានប្រយុទ្ធជាមួយនឹងគ្រុឌឈ្មោះជតាយុដែលជាមិត្រព្រះបាទទសរថ។ រាពណ៍ ដោះចិញ្ចៀនពីដៃនាងសីតាគប់គ្រុឌធ្លាក់ចុះហើយក៏បានយកនាងសីតាទៅលាក់ទុកក្នុងសួនអសោកលង្ការ។

ចំណែកឯព្រះរាម ព្រះលក្ស្មណ៍ត្រលប់មកវិញរកនាងសីតាមិនឃើញក៏យំសោកយ៉ាងខ្លាំង រួចក៏បានដើររកហើយបានជួបយក្សកុម្ភកាណ៍

ដែលប្រមាថទ្រង់ ទើបព្រះរាមសម្លាប់យក្សនោះចោលទៅ។ បន្តិចក្រោយមកក៏បានជួបកុក ដែលប្រាប់បណ្តាំនាងសីតា ហើយកុកបានតិះដៀលពីភាពឆោតល្ងង់របស់ព្រះរាម ព្រះលក្ស្មណ៍។ ព្រះរាមខឹងណាស់បម្រុងសម្លាប់កុក តែត្រូវបានកុកសុំខ្លួនបម្រើទើបព្រះរាមលើកលែងឲ្យទៅ។ ធ្វើដំណើរទៅមុខទៀតក៏បានជួបជតាយុ។ ដើម្បីតបស្នងសងគុណជតាយុ ព្រះរាមក៏បានបញ្ជូនវិញ្ញាណគេឲ្យទៅកើតនៅស្ថានសួគ៌។ នៅព្រៃហេមពាន្តមានស្តេចក្របីឈ្មោះមហឹង្សា បានសម្លាប់ក្របីឈ្មោលចោលទាំងអស់ ហើយវាទុកក្របីញីទាំងអស់ធ្វើជាប្រពន្ធវា។ មានក្របីញីមួយឈ្មោះសន្តតិរីបានលាក់កូនក្របីឈ្មោលមួយទុកឈ្មោះទូភី លុះវាធំឡើង ក៏បានសម្លាប់ឪពុកចោលហើយបានដើររករឿងគេដូចជាឥសីបញ្ចាលិង្គ ស្តេចស្វានៅខាសខិនបុរី។ ទូភីត្រូវ ពាលីសម្លាប់ក្នុងរូងភ្នំ ប៉ុន្តែដោយការយល់ច្រឡំគ្នាពាលីបានទះកំផ្លៀងប្អូនប្រុសឈ្មោះ សុគ្រីពរហូតវាបានរត់ទៅជ្រកជាមួយឥសីមតង្គ ឯពាលីខ្លាចត្រូវបណ្តាសារឥសីក៏ត្រឡប់មកវិញ។ ហនុមានបានជួបសុគ្រីពជាឪពុកមាដែលយំទឹកភ្នែករហូតក្លាយទៅជាស្ទឹង។ព្រះរាមបានផ្ទុំនៅក្រោមដើមស្វាយមួយ ទើបព្រះអាទិត្យមិនហ៊ានបរកាត់ដើម្បីទុកម្លប់ឲ្យដល់ទ្រង់។សុគ្រីពដឹង ក៏ប្រើហនុមានដើររកអ្នកមានបុណ្យ ហនុមានក៏បានឃើញកងចក្រនៅបាតដៃព្រះរាម ក៏ស្គាល់ថា ជាអ្នកមានបុណ្យក៏ក្លែងជាបេះស្លឹកស្វាយទម្លាក់លើព្រះរាម។ ព្រះលក្ស្មណ៍ខឹងបម្រុងសម្លាប់ តែព្រះរាមឃាត់ព្រោះឃើញកុណ្ឌលនៅត្រចៀក។ ខណៈនោះហនុមានក៏ស្ម័គ្រទៅបម្រើ ហើយបាននាំទៅជួបសុគ្រីព។ ព្រះរាមបានសន្យាជាមួយ សុគ្រីពដោយខ្លួនសុខចិត្តលួចបាញ់សម្លាប់ពាលីពីក្រោយខ្នង ដើម្បីដណ្តើមខាសខិនបុរីឲ្យសុគ្រីពហើយសុគ្រីពក៏បានសន្យាថានឹងកេណ្ឌទ័ពស្វាថ្វាយព្រះរាមដែរ។ ពាលី

ក៏បានស្លាប់ ហើយបានទៅកើតនៅស្ថានសួគ៌។ ដោយក្រឃើញទ័ពស្វា ព្រះរាមគំរាមរំលាយខាសខិនបុរីចោល ទើបសុគ្រីពភ័យក៏ប្រញាប់ កេណ្ឌទ័ពស្វាថ្វាយភ្លាមៗ។ពេលទ័ពស្វាមកជុំគ្នា ព្រះរាមចាត់ហនុមាន ទៅស៊ើបការណ៍នៅក្រុងលង្កា ដោយមានចិញ្ចៀនដាក់ស្តុតាងប្រាប់នាង សីតា។ ហនុមានហោះហួសលង្កាហើយបានជួបមុនីឥសី ទើបព្រះអគ្គិ ប្រាប់ផ្លូវទៅលង្កា និងឲ្យបាយបីពំនូត ហនុមានចំអកថាតិច ប៉ុន្តែស៊ីមិន អស់ក៏អៀនខ្មាស់ឥសី រួចហោះទៅដល់លង្កាជួបយក្សរិកតាដែលយាម ខ្លោងទ្វារ។ បន្ទាប់មកក៏ជួបកាមពាលី អតិកាយ និងឃើញរាពណ៍កំពុង ផ្ទុំជាមួយនាងមណ្ឌោគីរី ។ ហនុមានបានចងសក់យក្សទាំងពីរភ្ជាប់គ្នា។ មុនចេញទៅវិញហនុមានបានសរសេរថា បើចង់ស្រាយសក់ដែលចង ភ្ជាប់គ្នានេះ ត្រូវឲ្យនាងមណ្ឌោគីរីវាយក្បាលរាពណ៍បីដង។ ទីបំផុត ហនុមានបានជួបនាងសីតា និងឲ្យចិញ្ចៀនប្តូរដាក់ស្តុតាង។ មុនត្រលប់ មកវិញ ហនុមានបានសម្លាប់មេទ័ពយក្សឈ្មោះអតិកាយ និងសហស្ស កុមារ រួចពេលឥន្ទ្រជិតចាប់ហនុមានដុត ហនុមានបានធ្វើឲ្យឆេះក្រុង លង្ការ នឹងត្រលប់មកវិញបានទទួលរង្វាន់ពីព្រះរាមទៀតផង។ ដោយ ទ័ពស្វាតិចពេក ព្រះរាមចង់ចងសម្ព័ន្ធមេត្រីជាមួយមហាជំពូ តែ ហនុមានប្រែចរិតព្រហើន ទើបមហាជំពូខឹងក៏ចាប់ដាក់គុក។ ហនុមាន បានសណ្តំទ័ព លួចលើកយកគ្រែមហាជំពូមកដល់ទើបព្រះរាមប្រែក្រ លា ជាព្រះនា-រាយណ៍ធ្វើឲ្យមហាជំពូសុខចិត្តជួយ ដោយឲ្យខុននីល ខុននល ទៅជួយព្រះរាមជំនួសទ្រង់។ ពេលទ័ពស្វាសង់ស្ពានចូលទៅ កាន់លង្កាមានការរារាំងពីនាងមេខលា តែដោយព្រះរាមគំរាមធ្វើឲ្យទឹក សមុទ្រពុះ នាងក៏សុខចិត្តសង់ស្ពានថ្វាយ។ ពេលព្រះរាមនាំទ័ព ចូលមកដល់លង្កា រាពណ៍ក៏បានប្រមូលទ័ព ហើយក៏បានឲ្យពិភេកជា

ត្រូវទាយប្រចាំនគរធ្វើការទាយពីវាសនាក្រុងលង្កា។ ពិភេកទូលថាលង្កានឹងត្រូវរលាយ ប្រសិនណាមិនប្រគល់នាងសីតាឲ្យ ទៅព្រះរាមវិញទេ។រាពណ៍ខឹងក៏ដោះស្បែកជើងវាយក្បាលពិភេកនៅកណ្ដាលអង្គប្រជុំក៏បណ្ដាលឲ្យពិភេកខឹងរត់ចូលទៅខាង ព្រះរាម។ គ្រាមួយ ទ័ពស្វាដែលដឹកនាំដោយរុក្ខរៈ បានចេញទៅបេះផ្លៃឈើក៏ជួបប្រយុទ្ធគ្នា ជាមួយទ័ពយក្សដែលដឹកនាំដោយរុក្ខសេន។ ដោយរាពណ៍ច្រលំថាហនុមានស្លាប់ គេក៏លើកឆ័ត្រពេញអាកាស តែត្រូវព្រះរាមបាញ់កម្ទេចចោលអស់។ រាពណ៍បាននាំនាងសីតាហោះបញ្ឈឺព្រះរាម ទើបព្រះរាមសូត្រឲ្យរាពណ៍សន្ទប់ នឹងបានយកពេជ្រលើក្បាលរាពណ៍។ រាពណ៍ត្រូវបង្ខំកុម្ភកាណ៌ឲ្យទៅច្បាំង តែគេពន្យល់ថា រឿងហេតុទាំងអស់នេះគឺបណ្ដាលមកពីនាង សូបនខាទៅចង់ប្រុសខុសច្បាប់ប៉ុណ្ណោះ។ នៅទីបំផុតកុម្ភកាណ៌ត្រូវចេញមកច្បាំង ហើយគេក៏បានតិះដៀលពិភេកដោយខ្លួនមិនព្រមចុះចូលដាច់ខាត ជាមួយព្រះរាម រួចគេក៏បានចោលមោគ្គសក្តិត្រូវព្រះលក្ស្មណ៍របួសចាក់ឫសដល់ឋានបាតាល។ គ្រានោះព្រះរាមបានយំរហូតដល់សន្ទប់ ទីបំផុតហនុមាន បានទៅរកថ្នាំតាមបង្គាប់ពិភេកទាន់ទើបព្រះលក្ស្មណ៍បានជាសះស្បើយ។ សង្គ្រាមបន្ទាប់មកទៀត គឺព្រះលក្ស្មណ៍បានសម្លាប់កុម្ភកាណ៌ ក្រុងរាពណ៍ឲ្យឥន្ទ្រជិតផ្ទែងសរចងព្រះលក្ស្មណ៍។ ព្រះរាមបាន ទៅគំរាមបំផ្លាញឋានសួគ៌ ទើបទេវតាក៏យបានទៅអង្វរព្រះព្រហ្ម ហើយបានព្រលែងគ្រុឌដេញកម្ចាយនាគអស់ទើប ព្រះលក្ស្មណ៍បានរួចរស់ជីវិត។ក្រុងរាពណ៍បានភៀសខ្លួទៅស្ងួពិស ដើម្បីសម្លាប់ទ័ពស្វា តែត្រូវហនុមានតាមទៅបំផ្លាញពិធីរាពណ៍ទើប រាពណ៍បានឲ្យឥន្ទ្រជិតចេញមកច្បាំង ក៏ត្រូវព្រះលក្ស្មណ៍សម្លាប់ចោលក្នុងគ្រានោះទៅ។ បន្ទាប់មកកូនរាពណ៍ទាំងដប់ ក៏បានចេញមក

ច្បាំងហើយក៏ត្រូវស្លាប់អស់។ រាពណ៍អស់សង្ឃឹម ក៏បានទៅចងសម្ព័ន្ធជាមួយមិត្តម្នាក់នៅក្រៅ ចក្រវាឡឈ្មោះមូលផល័ម។

ព្រះរាមបានហៅស្វាមកដល់ក្រុងលង្ការ មានយក្សពីររូបឈ្មោះអតិកម្ម និងអតិកលំបាននាំដំណឹងទៅប្រាប់រាពណ៍។ រាពណ៍ក៏បញ្ជាននូស្សូរ ឲ្យទៅហៅបុត្រមហារីកពីររូបឈ្មោះននូវេក និងវៃយវេកឲ្យមកជួប រួចក៏បញ្ជាឲ្យយក្សទាំងពីរទៅឋានបាតាលហៅយក្សវៃយរាពណ៍មកជួយច្បាំងខ្លួននៅភ្នំគិជ្ឈកូដ។ នៅពេលស្វបំបាំងកាយថ្នាំរួចទើបត្រលប់មកវិញ។ នៅពេលដេកយប់វាបានសុបិនឃើញមានពន្លឺដ៏ត្រចះត្រចង់ រួចប្រែជាស្រអាប់បាត់ពីបាតាល ហើយក៏មានតារាមួយដួងបានរះជំនួសវិញ។ ហោរាបានទាយថា នឹងមានស្តេចថ្មីជារាជវង្សរបស់វៃរាពណ៍ មកស្នងរាជបន្ត បន្ទាប់ពីការស្លាប់របស់វៃយរាពណ៍។ យក្សនេះក៏យក៏បានចាប់វៃយវេកជាញាតិដាក់គុក រួចបានទៅ ចាប់ព្រះរាមដោយប្រើវិធីសណ្តំ នឹងបំបាំងរូប។ ហនុមានបានទៅបាតាលព្រមទាំងសម្លាប់ព្រាយគង្គា ព្រមទាំងប្រយុទ្ធជាមួយមច្ឆានុជាកូនបង្កើតខ្លួនដែលរាពណ៍រើសមកចិញ្ចឹម។ បន្ទាប់មកហនុមានបានជួយយក្សស្រីចាប់ឈ្មោះ កិរាយឃ្លួនជាម្តាយវៃយវេកដែលកំពុងយំសោក រួចក៏ប្រាប់ពីអាថ៌កំបាំងឲ្យសម្លាប់វាយរាពណ៍ដោយ ត្រូវបំផ្លាញទាំងរូបនិងដួងកែវរួមទាំងភ្នំគិជ្ឈកូដក្នុងពេលតែមួយ។ នៅទីបំផុត ព្រះរាមក៏បានត្រូវហនុមានសង្គ្រោះ មកដាក់នៅពន្លាជ័យវិញ។ បន្ទាប់ពីត្រលប់មកសោយរាជ្យនៅព្ធយុធ្យាវិញ នាថ្ងៃមួយពេលព្រះរាមនិងព្រះលក្ស្មណ៍ទៅប្រពាតព្រៃនាងសីតានៅក្នុងប្រាសាទ បានគូររូបរាពណ៍តាមការបញ្ឆោតរបស់ស្នំដែលជាតុពិតគឺជាយក្សអាតុ-ល័យ។ នៅពេលដែលគូររួចក៏ស្រាប់តែលុបមិនជ្រះ ទើបព្រះនាងយកទៅលាក់ទុកនៅក្រោមក្រលាបន្ទំ។ ព្រះ

រាមមានសេចក្តីក្តៅក្រហល់ក្រហាយ នៅពេលដែលដឹងការពិតរួចក៏បាន ចោទព្រះនាងសីតាថា នឹកក្រុងរាពណ៍ ក៏បញ្ជាព្រះលក្ស្មណ៍ឲ្យយកនាង ទៅសម្លាប់ទាំងមានផ្ទៃពោះក្នុងកណ្តាលរាត្រី។ ព្រះលក្ស្មណ៍ដកដាវ សម្លាប់តែដាវក្លាយជាកម្រងផ្កា បន្ទាប់មកព្រះលក្ស្មណ៍ក៏បានដោះ លែងនាង ដោយខ្លួនបានសម្លាប់សត្វទ្រាយវះយកថ្លើមទៅបង្ហាញព្រះរា ម។ ព្រះឥន្ទ្រមានចិត្តអាណិតនាងសីតា ក៏បាននាំផ្លូវទៅដល់អាស្រម ឥសីវុជ្ឈប្រិតឥសី រស់នៅជាមួយរហូតប្រសូតបានកូនប្រុសមួយឈ្មោះ រាមលក្ស្មណ៍។ នៅថ្ងៃមួយនោះ ឥសីស្មានថាបាត់កូននាងសីតាក៏បាន ជបកុមារម្នាក់ជំនួស លុះសីតាបាននាំកូនត្រលប់មកវិញដឹង ការពិត នាងក៏បានឃាត់រក្សាកូននោះទុកដោយដាក់ឈ្មោះថា ជប្បលក្ស្មណ៍។

លុះអាយុបានដប់ឆ្នាំ កុមារទាំងពីរបានរៀនចេះចប់គម្ពីរវេទ នឹងបានទទួលធ្នូជ័យពីឥសីទៀតផង។ កេរ្តិ៍ឈ្មោះរបស់កុមារទាំងពីរ បានធ្វើឲ្យព្រះរាមព្រួយបារម្ភយ៉ាងខ្លាំង។ ព្រះរាមបានប្រើល្បិចឲ្យកាប៉ិ យកសំបុត្រចងសេះដើរលេបតាមក្រោយ។ កុមារឃើញសេះស មុខខ្មៅ មាត់ក្រហមដោយមិនខ្វល់ថាជាអក្ខរបស់ព្រះរាម ព្រះលក្ស្មណ៍ឡើយ បែរជារាំឡើងជិះលេងយ៉ាងសប្បាយ។ ហនុមានបានស្ទុះមកចាប់កុមារ ទាំងពីរ ប៉ុន្តែត្រូវរាមលក្ស្មណ៍ វែធនឹងធ្នូសន្ទប់ រួចហើយបានចាប់ចង ហើយសាក់មុខបញ្ជូនឲ្យម្ចាស់ដើមវិញ។ ពេលស្រាយចំណងហនុមាន បានហើយ ព្រះរាមឲ្យពិភេកនិងសុត្រុតទៅចាប់កុមារទាំងពីរ។ រាមលក្ស្ម ណ៍ ត្រូវទ័ពព្រះរាមចាប់បានរួចបណ្តើរអាក្រោសក្នុងនគរនិងឃុំទុក ប្រហារជីវិតចោល។ ចំណែកឯជប្ប-លក្ស្មណ៍រត់ទៅរកមាតា ទើបនាង សីតាឲ្យចិញ្ចៀនមកជួយ ហើយក៏បានជួបជាមួយទេពធីតារម្ភា ដែល

ដំណែងខ្លួនជាអ្នកដងទឹកនាំចិញ្ចៀនទៅជួយរាមលក្សណ៍ ទើបរាមលក្សណ៍បានរត់រួចពីទ្រុង។

កុមារទាំងពីរ បានទៅស្កាត់ទ័ពព្រះរាមក្នុងព្រៃដើម្បីសងសឹក តែសរបស់វាក្លាយជាផ្កាភ្ញីបំពាក់ព្រះរាមទៅវិញ ឯព្រះរាមសង្ស័យក៏ផ្សងថា បើវាទាំងពីរជាវង្សរបស់ព្រះអង្គមែន សូមឲ្យសររបស់ព្រះអង្គក្លាយជាអាហារ ផ្កាភ្ញីទៅចុះ ហើយអ្វីៗក៏បានក្លាយជាការពិត។ ក្រោយពីសាកសួរដឹងថាជាបុត្រហើយ ព្រះរាមក៏បានសុំទៅតាមរកនាងសីតា។ នៅពេលទៅដល់នាងសីតា ពុំព្រមបើកទ្វារឲ្យលុះត្រាតែឥសីអង្វរទើបនាងព្រមជួបព្រះរាម។ ព្រះរាមលួងលោមសីតាឲ្យជាគ្នាពុំបាន ក៏បានលួងកូនឲ្យទៅនៅនគរដើម្បីឲ្យនាងសីតាទៅតាម តែក្មេងទាំងពីរទួញសោកនឹកមាតាពេក ក៏បាននាំកូនមកឲ្យនាងសីតាវិញដោយបង្កប់សំបុត្រអង្វរនាងសុំឲ្យត្រលប់មកនគរវិញតែសីតាត្រាស់ថា នឹងត្រលប់មកវិញលុះត្រាតែពេលណាព្រះរាមសុគតប៉ុណ្ណោះ។ ឮដូច្នេះព្រះរាមក៏បានប្រើល្បិចចូលកោដដើម្បីបញ្ឆោតនាងសីតា ដោយឲ្យនាម៉ឺនមន្ត្រីស្រីស្នំកាន់ទុក្ខថាទ្រង់សុគតហើយ។ ហនុមានបានទៅយំរៀបរាប់ប្រាប់នាងសីតា នាងក៏ជឿហើយមកយំសោកទាល់តែសន្លប់ ព្រះរាមខ្លាចនាងស្លាប់ក៏ចេញមកត្រកងនាងផ្លូតទឹកភ្នែកឲ្យនាង។ លុះពេលនាងដឹងខ្លួនថាចាញ់បោកស្វាមី នាងខឹងណាស់ក៏រត់ចេញពីនោះទោះបីព្រះរាម ព្រះលក្សណ៍ចាប់យ៉ាងណាក៏ពុំបាន។ នាងបានអធិដ្ឋាន ឲ្យព្រះធរណីបើកឲ្យនាងចាកផុតពីកណ្ដាប់ដៃព្រះរាម។ ព្រះគិរុណនាគាក៏បានទទួលនាងមកថែរក្សាឧបត្ថម្ភយ៉ាងល្អ។ ព្រះរាម ហនុមាន ទៅស៊ើបនៅឋានកុជង្គនាគមិនបានផល ក៏សរសេរអក្ខរាទៅក្រុងលង្ការដើម្បីសុំឲ្យភិភេកមកជួយ។

## V តួអង្គសំខាន់ៗក្នុងរឿង

១ ព្រះបាទទសរថ ស្ដេចនគរអយុធ្យា

២ ព្រះនាងកៃកេសី មហេសីព្រះបាទទសរថ

៣ ព្រះនាងកោសកល្យាណ មហេសីព្រះបាទទសរថ

៤ ព្រះនាងសមុទ្រ មហេសីព្រះបាទទសរថ

៥ ព្រះរាម បុត្រព្រះបាទទសរថនិងនាងកោសកល្យាណ (ព្រះនារាយណ៍បែងភាគ) ។

៦ ព្រះលក្ស្មណ៍ បុត្រព្រះទសរថនិងនាងសមុទ្រ

៧ ព្រះសុត្រុត បុត្រព្រះបាទទសរថនិងនាងកៃកេសី

៨ ព្រះភិរុត បុត្រព្រះបាទទសរថនិងនាងកៃសី

៩ ព្រះបាទជនក ស្ដេចនគរមិថិលាជាមាតាចិញ្ចឹមនាងសីតា

១០ នាងសីតា ជាបុត្រចិញ្ចឹមព្រះបាទជនក (រើសបានកាលទៅច្រត់ព្រះនង្គ័ល)។

១១ បេក្ខជនស្ដានទាំងបី ចូលរួមប្រឡងលើកធ្នូព្រោះចង់បាននាងសីតាជាភរិយា

១២ កូខ័ន ថ្មើរព្រៃរូបអាក្រក់ តែចិត្តល្អស្ម័គ្រតាមបម្រើព្រះរាម ព្រះលក្ស្មណ៍និងនាងសីតា

១៣ ឥសីពារទ្វាឲ្យ ឥសីទទួលក្សត្រទាំងបីឲ្យស្នាក់នៅបរមសាលា

១៤ នាងនិន្ទ្រាទេវី ទេពធីតាតំណាងឲ្យភាពងងុយដេក

១៥ ព្រះមុនីវិសិដ្ឋឥសី ជាអ្នករៀបចំពិធីនៅនគរអយុធ្យា

១៦ បិតាកៃកេសី អយ្យកោព្រះភិរុត

១៧ កាកនាសូរ យក្សក្លែងខ្លួនជាក្អែកមកចឹកបំផ្លាញហោម
ពិធីឥសីពិស្វាមិត្រ

១៨ ឥសីពិស្វាមិត្រ គ្រូរបស់ព្រះរាមព្រះលក្ស្មណ៍

១៩ រាមបរមសួរ យក្សដែលចោទថាព្រះបាទទសរថលួច
ឈ្មោះខ្លួនដាក់ឲ្យកូន

២០ បរទុស្ត យក្សដែលបង្ក រចលាចលដល់ផែនដីតែត្រូវព្រះ
បាទទសរថបង្រ្កាប

២១ ពិរាធ យក្សដែលចង់ឆក់នាងសីតាជាបុត្ររបស់ព្រះកាល២២

នាងសូរបនខា យក្ខិណីប្អូនស្រីក្រុងរាពណ៍ដែលមកចែរ
ចង់ព្រះលក្ស្មណ៍ព្រះរាមកាល កាលសំណាក់ធម៌នៅព្រៃ ហើយត្រូវ
ព្រះលក្ស្មណ៍ចាប់កោសក់ កាត់ច្រមុះនឹង នាងបានទៅឲ្យបងៗមកសង
សឹកជំនួសៗ

២៣ ក្រុងខរ បងប្រុសនាងសូបនខា

២៤ ក្រុងទុសណ៍ ប្អូនប្រុសក្រុងខរ

២៥ ក្រុងរាពណ៍ ស្តេចយក្សនៅនគរលង្កាជាបងប្រុស
នាងសូរបនខា

២៦ មហាកុម្ព័ន្ធ ឈ្មោះយក្ស

២៧ ត្រីមុខ ជាបុត្រក្រុងខរ

២៨ មហារីក បរិវាក្រុងរាពណ៍ដែលបានប្រែក្រលាជាប្រើស
មាសចាប់នាងសីតា

២៩ ព្រះធរណី ទេវតាថែរក្សាព្រះលក្ស្មណ៍ នាងសីតាកាល
ទ្រង់ទៅតាមព្រះរាម ។

៣០ ទេព្វារក្ស ទេវៈដែលព្រះលក្ស្មណ៍ឲ្យថែរក្សានាងសីតា
ពេលទ្រង់ទៅតាមព្រះរាម ។

៣១ អារ័ក្ស ទេវៈដែលព្រះលក្ស្មណ៍ឲ្យថែរក្សានាងសីតាពេល
ទ្រង់ទៅតាមព្រះរាម។

៣២ គិរីទេព្វារ័ក្សព្រឹក្សា ទេវៈដែលព្រះលក្ស្មណ៍ឲ្យថែរក្សា
នាងសីតាពេលទ្រង់ទៅតាមព្រះរាម ។

៣៣ កុក ជាសត្វដែលបាននាំដំណឹងនាងសីតាទៅប្រាប់ព្រះរាម

៣៤ ជតាយុ ស្តេចគ្រុឌដែលចង់សង្គ្រោះនាងសីតា

៣៥ មហិផ្សរាជ ស្តេចក្របីនៅព្រៃហេមពាន្ត

៣៦ សន្តគិរី ប្រពន្ធមហិផ្សរាជ

៣៧ ទូភី កូនមហិផ្សរាជ និងនាងសន្តគិរី

៣៨ ឥសីបញ្ចាលិន្ត ជាឥសីដែលទៅប្រាប់ទូភីឲ្យទៅប្រឡង
និងទូភី

៣៩ ពាលី ស្តេចស្វានៅខាសខិនបុរី

៤០ សុគ្រីព ប្អូនរបស់ពាលី

៤១ ព្រះមង្គលឥសី ឥសីដែលសង្គ្រោះសុគ្រីព

៤២ មហារាជិតា អ្នកនាំទេវតាបាចផ្កាអបអរពាលី

៤៣ ហនុមាន ត្រព្រះពាយ និងអញ្ជនទេវីជាសេនាព្រះរាម

៤៤ អង្គទរ បុត្រពាលី និងនាងមណ្ឌោគិរី

៤៥ ជម្ពូពាន ស្តេចស្វាដែលព្រះរាមបំភាន់ឲ្យបម្រើខ្លួន

៤៦ ខុនជីពទ្វារ សេនាស្វា

៤៧ ខុននន្ទ សេនាស្វា

៤៨ នាងវិកតាសី យក្សិនីចាំការពារបុរីលង្ការជាប្អូនរាពណ៍

៤៩ គន្ធព យក្សសេនារាពណ៍

៥០ រុក្ខធន្ទ យក្សសេនារាពណ៍

៥១ សិងអាសូរ យក្សសេនារាពណ៍

៥២ មណ្ឌាគិរី មហេសីរាពណ៍

៥៣ ទិព្វទេពកញ្ញា មហេសីរាពណ៍

៥៤ ទេពីទេពកញ្ញា មហេសីរាពណ៍

៥៥ ឥសីមុនី ឥសីដែលជួយបង្ហាញផ្លូវនឹងឲ្យបាយហនុមាន

៥៦ កាមពាលី ក្មួយរាពណ៍ និងជាបុត្រអសុរីបុរ

៥៧ អតិកាយ យក្សការពារកំពែងសំរិទ្ធ

៥៨ មហាកាយ យក្សការពារកំពែងទង់ដែង

៥៩ ឥន្ទ្រជិត កូនរាពណ៍

៦០ កុម្ភកាណ៍ ប្អូនរាពណ៍

៦១ ពិភេក ប្អូនរាពណ៍ នឹងជាហោរាបានចុះចូលជា
មួយព្រះរាម

៦២ ខុនទីល និងខុនទល សេនាមហាជម្ពូពាន

៦៣ ត្រីអង្គ និងត្រីបុត្រ សេនាព្រះរាម

៦៤ រាពណ៍ណាសូរិទ្រ ត្រី និងជាយក្សផងដែរ

៦៥ រុក្ខសេន សេនារាពណ៍

៦៦ រុក្ខរៈ ទាហានព្រះរាម

៦៧ ប្រហេតមន្ត្រី ហោររបស់រាពណ៍

៦៨ ក្អាងមឿង យក្ស

៦៩ ព្រះព្រហ្ម អ្នកឲ្យសរដល់ឥន្ទ្រជិត

៧០ អតមុខ ជាកូនរាពណ៍

៧១ មហាទរ ជាកូនរាពណ៍

៧២ បាសបុត្រ ជាកូនរាពណ៍

៧៣ ទសមុខ ជាកូនរាពណ៍

៧៤ ត្រីសិរ ជាកូនរាពណ៍

៧៥ នារត័ក ជាកូនរាពណ៍

៧៦ មហាក្បាល ជាកូនរាពណ៍

៧៧ ទូរមុខ ជាកូនរាពណ៍

៧៨ កុមគទាធរ ជាកូនរាពណ៍

៧៩ ពិតរក្ខ័ស យក្សដែលឃាត់រាពណ៍កុំឲ្យសម្លាប់នាងសីតា

៨០ ឧសភសនា កេសរ ស័ត សេនាព្រះរាម

៨១ រាក្ស និងមាលមាទ បរិវារពណ៍

៨២ អាតុល័យ យក្ខិនីដែលជាប់ញាតិរាពណ៍មកបញ្ឆោតសីតាដើម្បីសង់សឹក

៨៣ ត្រីមុខ និមិត្តជាសត្វទ្រាយឲ្យព្រះលក្ស្មណ៍វះវង្វើមឆ្ងាយព្រះរាម

៨៤ មហិង្សា សត្វក្របីដែលព្រះអង្គនិមិត្តនាំផ្លូវនាងសីតា៨៥ ឥសីវជ្ជប្រិត ឥសីជួយចិញ្ចឹមនាងសីតា និងបុត្រ

៨៦ ទេពអប្សរ ទេវតាចុះមកជួយយកអាសារនាងសីតាពេលប្រសូត្របុត្រ

៨៧ រាមលក្ស្មណ៍ បុត្រនាងសីតា និងព្រះរាម

៨៨ ជប្បលក្ស្មណ៍ បុត្រនាងសីតាកំតដោយឥសីជប្ប

៨៩ ទេវបុត្រ ទេវតាដែលយកធ្នូមកឲ្យកុមារទាំងពីរ

៩០ នាងទេពរម្ភារ ទេវតាចុះមកជួយយកអាសារាជកុមារ

៩១ ព្រះកិរុណនាគា ស្តេចនាគជួយយកអាសានាងសីតាទៅឋានកុជង្គនាគ

៩២ នាងរតនា មហេសីស្តេចនាគ

## VI វិភាគតួអង្គ

១ ព្រះរាម

### ចំណុចវិជ្ជមាន

-មានឫទ្ធិអំណាចខ្លាំងក្លា មានសិល្បវិជ្ជាគ្មានគូប្រៀបដូចជាការលើកធ្នូ ការផ្ចាញ់សត្រូវនានាជាដើម។

- មានតេជបារមីធ្វើឲ្យរុក្ខជាតិនានាដែលក្រៀមស្វិតប្រែជាស្រស់បំព្រង សត្វសាហាវប្រែជាស្លូត ព្រះអាទិត្យ មិនហ៊ានដើរលេងពេលព្រះអង្គកំពុងផ្ទំ នៅពេលដែលព្រះអង្គសម្លាប់សត្រូវតែងតែមានទេវតាបាចផ្កាជូនពរជានិច្ច។

-អាចបញ្ជូនព្រលឹងវិញ្ញាណ ទាំងឡាយឲ្យទៅកើតនៅស្ថានសួគ៌បាន ដូចជាបានបញ្ជូនព្រលឹងពាលី និងជតាយុជាដើម។

-ជាតំណាងសការៈល្អ កម្ចាត់យក្សកំណាចដែលបង្ករមហន្តរាយដល់មនុស្សលោក។

-ជាបុត្រកតញ្ញូគោរពមាតា រក្សាកិត្តិយសគ្រួសារ និងពាក្យសច្ចៈរបស់បិតា លះបង់ប្រយោជន៍ផ្ទាល់ខ្លួន ដោយសុខចិត្តទៅសាងផ្នួសក្នុងព្រៃ។

-ជាស្វាមីស្មោះត្រង់និងភរិយា សុខចិត្តលះបង់គ្រប់បែបយ៉ាងដើម្បីភរិយា។

-ជាបងប្រុសដ៏ប្រពៃ អាណិត ស្រឡាញ់ប្អូន ទួញសោកអាណិតប្អូនពេលត្រូវរបួសគ្រាំគ្រា ចេះអប់រំណែនាំ ប្អូនដោយទឹកចិត្តស្មោះត្រង់

-មានប្រាជ្ញាក្នុងសង្គ្រាម ចេះចងសម្ព័ន្ធមេត្រីអ្នកជិតខាង ដើម្បីកុំឲ្យបាត់បង់ពស្ត្រខ្លួន។ ចេះអូសទាញសត្រូវឲ្យចុះចូល ចេះដាក់ទោសនិងឲ្យរង្វាន់ដល់អ្នកដែលនៅក្រោមបង្គាប់ យល់ចិត្តសាស្ត្រមនុស្ស

លោក។

-មានចិត្តខន្តី មិនចង់អាឃាតនាងកៃកេសីទោះបីខ្លួនលំបាកយ៉ាងណាក៏ដោយ ហើយមិនតែប៉ុណ្ណោះ ថែមទាំងបានឃាត់ព្រះលក្ស្មណ៍កុំឲ្យសម្លាប់នាងទៀតផង។

**ចំណុចអវិជ្ជមាន**

-ក្នុងនាមជាអវតាម្នាក់របស់ព្រះទេវៈ ប៉ុន្តែព្រះរាមត្រូវចុះចាញ់នាងកៃកេសីដែលជាស្រីទន់ខ្សោយម្នាក់ ទើបបានជាត្រូវនិរទេសទៅរស់នៅក្នុងព្រៃរយៈពេល១៤ឆ្នាំ។

-ព្រះរាមត្រូវចាញ់កលរាពណ៍ពុំដឹងល្បិចគេ រហូតដល់គេបានឆក់នាងសីតាទៅបាត់។

-ជាអ្នកមានឫទ្ធានុភាពផុតគេនៅផែនដី តែបែរអសមត្ថភាពក្នុងការការពារ និងរំដោះមហេសីខ្លួន ដោយត្រូវពឹងពាក់គេគ្រប់គ្នា ហើយត្រូវធ្វើសង្គ្រាមរយៈពេល១៤ឆ្នាំ។

-ដើម្បីប្រយោជន៍បុគ្គល ព្រះរាមប្រើល្បិចគ្រប់បែបមានជាទេវៈផង ជាមនុស្សផង ហើយមានពេលខ្លះ ព្រះរាមបានប្រើល្បិចថោកទាបហួសការស្មានទៅទៀត ដូចជាគម្រាមសុគ្រីពឲ្យកេណ្ឌទ័ព លួចខ្ទីក្រឡាព្រះនារាយណ៍ មកបំភាន់ក្នែកមហាជម្ពូ និងគម្រាមនាងមនីមេខលាជាដើម។

-ព្រះរាមបានប្រើឧបាយកលញុះញង់ទឹកចិត្តពិភេក និងទ័ពស្វាដោយប្រើវង្វាន់លួងទឹកចិត្ត ដើម្បីឲ្យគេក្បត់ជាតិខ្លួនឯងមកចុះចូលជាមួយខ្លួន។

-ពុំមានសមត្ថភាពដឹងហេតុការណ៍ទាំងឡាយ ដូច្នេះត្រូវពឹងពាក់ពិភេកគ្រប់ពេលវេលា រួមទាំងការជួយសង្គ្រោះព្រះលក្ស្មណ៍ផង។

-ក្នុងនាមជាកូនប្រុសម្នាក់ តែបែរជាទួញសោកនៅពេលមានបញ្ហាធ្ងន់ធ្ងរ ដូចជាពេលនាងសីតាត្រូវគេចាប់ពេលព្រះលក្ស្មណ៍ត្រូវបបួសជាដើម ពិសេសទៅទៀតនោះគឺបានលួចបាញ់ពាលីពីក្រោយខ្នងធ្វើឲ្យពាលីតិះដៀលយ៉ាងអាម៉ាស់។

-ចាញ់កលយក្សអាតុល័យ ពិសេសទៅទៀតគឺបានសង្ស័យលើកក្តីភាពនាងសីតា និងបាត់បង់វិចារណញ្ញាណជាមនុស្សធម៌ដោយបានបញ្ជាព្រះលក្ស្មណ៍ ឲ្យយកប្រពន្ធរបស់ខ្លួនទៅសម្លាប់ទាំងកណ្តាលយប់ទាំងនាងមានផ្ទៃពោះ ហើយទាមទារយកថ្លើមមកបង្ហាញទៀត។

-មានគំនិតផ្តាច់ការខ្លាចអ្នកដ៏ទៃខ្លាំងពូកែជាងខ្លួន នឹងបានប្រើល្បិចចោទគេថាចង់បានរាជសម្បត្តិខ្លួនដើម្បីបានជាលេសនាំ ខ្លួនគេមកប្រហារជីវិត។ -

ព្រះរាមមានមាយាទអន់ពន់ពេក ព្រោះត្រូវនាំទ័ពទាំងនគរទៅចាប់កូនក្មេងវាយបណ្តើរអា-ក្រោសពេញនគរ។

-ចំណុចដែលធ្វើឲ្យព្រះរាមរិតតែអន់ទៅទៀតនោះគឺ សូម្បីវិបត្តិគ្រួសារផ្ទាល់ខ្លួនក៏ដោះ ស្រាយមិនរួច គឺមិនអាចឲ្យប្រពន្ធជឿជាក់ខ្លួនបាន ហើយបែរជាធ្វើល្បិចឲ្យខ្លួនស្លាប់(ព្រះរាមចូលកោដិបញ្ឆោតនាងសីតា)ដោយបញ្ជា ឲ្យប្រជារាស្ត្រនិងមន្ត្រីទូទាំងនគរធ្វើជាទួញសោកកាន់ទុក្ខគ្រប់គ្នាដើម្បីបោកនាងសីតា ព្រមទាំងរត់ដេញចាប់នាងសីតាពេញព្រះដំណាក់ដោយឥតខេះខ្មាស់អាមាត្រ នាម៉ឺន មន្ត្រី លុះទីបំផុតត្រូវនាងសីតាតិះដៀលយ៉ាងខ្លាំង ព្រមទាំងបានភៀសខ្លួនជ្រែកដល់ស្ថានបាតាលចោលព្រះរាម។

## ចំណុចវិជ្ជមាន

-ស្រីដែលមានរូបសម្រស់ស្អាតដាច់គេទូទាំងកពផែនដីធ្វើឲ្យពួកទេវៈ មនុស្ស ព្រមទាំងយក្សលើកគ្នាមក ប្រឡងប្រណាំងលើកធ្នូប្រកួតមហិទ្ធិឫទ្ធិនៅនគរព្រះបាទជនក ព្រោះតែចង់បាននាងសីតាមកធ្វើជាភរិយា។ អ្វីដែល អស្ចារ្យទៅទៀតនោះគឺសូម្បីតែពពណ៍ដែលមានក្បាលម្ភៃនិងភ្នែកមួយសែនក៏សរសើរនាងមិនដាច់ពីមាត់ដែរ។

-នាងជាភរិយាដ៏ស្មោះត្រង់ ចំពោះស្វាមីទោះបីជាត្រូវព្រាត់ឆ្ងាយពីស្វាមីរយៈពេល ១២ឆ្នាំក៏ដោយក៏នាងពុំបានផ្លាស់ប្តូរភក្តីភាពចំពោះព្រះរាមដែរ គឺនាងស៊ូស្លាប់មិនឲ្យអាស្រូវឈ្មោះ ឬរស់ដោយគ្មានព្រះរាមឡើយ។

-នាងសុខចិត្តលះបង់ សេចក្តីសុខផ្ទាល់ខ្លួនទៅតាមបម្រើស្វាមីនៅក្នុងព្រៃ។

-នៅពេលក្រុងកពណ៍ចាប់នាងយកទៅ នាងបានយំស្រែកផ្តាំគេឯងគ្រប់គ្នា មានទាំងព្រៃព្រឹក្សាបព្វតា ទេពអប្សា កុក និងជតាយុផង។

-នាងគិតគូដល់សុខទុក្ខព្រះលក្ស្មណ៍ ហើយអាណិតស្រឡាញ់ប្អូនស្មើជីវិត។

-សីតា ជាមាតាដ៏ល្អប្រពៃដែលព្យាយាមចិញ្ចឹមថែរក្សាកូនក្នុងព្រៃភ្នំជាមួយឥសី អប់រំប្រៀនប្រដៅស្រឡាញ់កូនដោយព្រហ្មវិហារធម៌ដ៏ប្រសើរទោះក្នុងគ្រាលំបាក កម្សត់កម្រយ៉ាងណាក្តី។

-ដោយបារមីនៃការគោរពពាក្យសត្យ បានធ្វើឲ្យនាងចាកចោលស្វាមីដែលឥតមនុស្សធម៌ហើយបានចុះទៅស្ថានបាតាល។

-នាងជាស្ត្រីជឿនលឿន មានសុភវិនិច្ឆ័យត្រឹមត្រូវគឺដោយសារ

ការបាត់បង់នូវគុណធម៌ ករុណា និងមេត្តាដល់ស្វាមី ធ្វើឲ្យនាងសម្រេចចិត្តរស់នៅឆ្ងាយពីព្រះរាមបន្តនូវការរស់នៅដោយសេរីភាពផ្លូវចិត្ត រស់ដោយមិនចាំបាច់ពឹងពាក់បុរសជាស្វាមីដូចនារីអន់ថយដ៏ទៃឡើយ។

**ចំណុចអវិជ្ជមាន**

-សីតា មានគំនិតលោភលន់ចង់បានប្រើសមាសទុកក្រាលរាជបល្ល័ង្កពេលត្រលប់ទៅសោយរាជ្យវិញ។

-នាងមានភាពតក់ក្រហល់ ឆាប់ជ្រួលច្របល់មិនចេះសង្កេតពិចារណា និងសង្ស័យលើសមត្ថភាពស្វាមី ទើបដេញព្រះលក្ស្មណ៍ រហូតកើតជារឿង។

-នាងឆោតល្ងង់បណ្ដាលឲ្យយក្សបោកបានម្ដងហើយ ម្ដងទៀតរួមទាំងការគូររូបរួចយកទៅលាក់នៅក្រោមក្រលាបន្ទំព្រះរាមជាដើម។

-នាងទៅយកកូនមិនបានប្រាប់ឲ្យឥសីដឹង បណ្ដាលឲ្យឥសីភ័យ ទើបបានជាបណ្ដាលឲ្យលោកតាជប្ប ឲ្យមានកំណើតរាមលក្ស្មណ៍ឡើង។

-នៅចំពោះមុខអាមាត្រ មន្ត្រីនានានាងបានតិះដៀលស្វាមីដោយមិនគិតពីសន្ដានចិត្តជាកិរិយាដែលត្រូវប្រកាន់សេចក្ដីអត់ធ្មត់។

៣ ព្រះលក្ស្មណ៍

**ចំណុចវិជ្ជមាន**

-ព្រះលក្ស្មណ៍ ជាប្អូនដ៏ល្អសុខចិត្តចេញទៅបម្រើបងនៅក្នុងព្រៃ និងជួយច្បាំងអស់រយៈពេល១៤ឆ្នាំ។

-ជាមនុស្សស្មោះត្រង់ មានភក្ដីភាពចំពោះបងប្រុស និងនាង

សីតាជាបងស្រីថ្លៃអស់ពីបេះដូង ដោយមិនទាមទារគុណស្រ័យទោះជាពេញចិត្តក្តី មិនពេញចិត្តក្តីក៏មិនហ៊ានជំទាស់នឹងទ្រង់ឡើយ។

-ជាអ្នកដែលវៀរចាកកាមគុណ មិនរវើរវាយជាមួយនាងសូបនខាទោះបីស្រីយក្សប្រែជាស្រីដ៏ស្រស់ប្រិមប្រិយ មកលៃរចង់ខ្លួនយ៉ាងណាក៏ដោយ ពិសេសនោះគឺមានករុណាចំពោះនាងសីតាដោយសុខចិត្តដោះលែងនាង។

-អង់អាចក្លាហាន ក្នុងសឹកសង្គ្រាមដោយមិនរាថយឡើយ ពិសេសគឺហ៊ានពលីជីវិតក្នុងសមរភូមិ ក្នុងនាមជាអ្នកដឹកនាំទ័ពប្រកបដោយមហិទ្ធិឫទ្ធិអស្ចារ្យ។

**ចំណុចអវិជ្ជមាន**

-ជាមនុស្សឆេវឆាវមិនមានការពិចារណា ឲ្យស្គាល់ខ្ពស់ទាបដោយចង់សម្លាប់នាងកៃកេសីជាម្តាយចុង។

-ជាអ្នកបង្ករទំនាស់ឲ្យរឹតតែធំឡើងៗ ដោយសារភាពរពឹលរប៉ូចលេងសើចឥតបេះគិតពិចារណា ដោយលេងសើចជាមួយនាងសូបនខាដោយចាប់នាងជាស្រីភេទកាត់ដៃ ច្រមុះ ត្រចៀក ដែលទង្វើនេះមិនសមជាមនុស្សដែលដឹងខុសដឹងត្រូវសោះ។

-អសមត្ថភាព ដោយសារចាញ់ដៃក្នុងសឹកសង្គ្រាមច្រើនដងច្រើនសារ រហូតស្ទើរតែបាត់បង់ជីវិត។

-ពុំបេះគិតពិចារណាឲ្យបានដិតដល់ បេះតែធ្វើតាមបញ្ជាគេដូចជាបញ្ជានាងសីតាឲ្យទៅចាប់ប្រើសមាស បណ្តាលឲ្យយក្សឆក់នាងបាត់ ពិសេសជាងនេះទៅទៀត បានស្តាប់បញ្ជាព្រះរាមដោយយកនាងសីតាទៅសម្លាប់ ទាំងយប់ពុំបេះដដែករកខុសត្រូវ ពោលគឺព្រះលក្ស្មណ៍ស្តាប់តាមបញ្ជាគេទាំងងងឹតងងល់។

-ភូតកុហក់បោកទាប ដោយបានរួមគំនិតជាមួយព្រះរាមបោកប្រាស់នាងសីតា(ព្រះរាមចូលកោដ្ឋ បញ្ឆោត នាងសីតា) ចេះភូតករស្តីតែព្រះរាម( យកជើមទ្រាយកុហកថាជើមនាងសីតា)។

៤ ហនុមាន

**ចំណុចវិជ្ជមាន**

-ហនុមានមានចិត្តអាណិតស្រឡាញ់ ជួយយកអាសារសុគ្រីពជាឪពុកមា ។

-ជាមេទ័ពមានឫទ្ធានុភាពអង់អាចក្លាហាន រាំងរៃលើសពួកយក្សនិងទេវតា។

-ជាសេនាស្មោះត្រង់បម្រើម្ចាស់ឥតងាករេ ឥតចង់បានសំណាងឡើយគឺដោយសារតែហនុមាន ដែលជាកម្លាំងសំខាន់នឹងចាំបាច់បំផុតដែលធ្វើឲ្យការរំដោះនាងសីតា ក្នុងចម្បាំង១៤ ឆ្នាំនេះអាចសម្រេចបានជោគជ័យ។

-ជាអ្នកមានស្មារតី និងរាងកាយមាំមួនរហ័សរហួន មានយុទ្ធសាស្ត្រខ្ពង់ខ្ពស់ក្នុងសង្គ្រាមដូចជាទៅស៊ើបអង្កេត នឹងបំផ្លាញលង្ការ ទៅបំផ្លាញពិធីស្វំពីសរបស់រាពណ៍ និងរកថ្នាំបន្សាបពិសលួចថ្នាំក្រោមខ្នើយរាពណ៍យកមកសង្គ្រោះព្រះលក្ស្មណ៍ជាដើម។

**ចំណុចអវិជ្ជមាន**

-ជាខ្ញុំបម្រើដាច់ថ្លៃរបស់បរទេស មិនចេះគិតគូរប្រទេសជាតិនិងប្រជារាស្ត្ររបស់ខ្លួន។

-មានចរិតរពិលរពូច ធ្វើការហួសបញ្ញាដូចជាទៅស៊ើបការណ៍សម្ងាត់ តែបែរជាទៅបង្ករចលាចលពេញលង្កា។

-មានអំនួតក្អេងក្អាង ប្រលើសបើសធ្វើឲ្យមហាជម្ពូខឹងសម្បា

យ៉ាងខ្លាំង។

-រូមគំនិតថោកទាបបោកប្រាស់នាងសីតា (វគ្គព្រះរាមចូលកោដិបញ្ឆោតនាងសីតា)។

-នៅក្នុងនាមជាមេទ័ពម្នាក់ ហនុមានបានចាញ់ដៃកូនក្មេងត្រូវវាចាប់គួរមុខរូចបញ្ជូនទៅឲ្យម្ចាស់ដើមវិញ ទើបអាចស្រាយរួច។

## ៥ សុគ្រីព

### ចំណុចវិជ្ជមាន

-ជាប្អូនដែលគោរព ស្ដាប់បញ្ជាបងប្រុសគ្រប់បែបយ៉ាងដោយគ្មានគំនិតក្បត់។

-ជាមនុស្សគោរពពាក្យសច្ចៈ ដឹងគុណចំពោះអ្នកដែលបានធ្វើគុណមកលើខ្លួន។

-ជាសេនាដ៏ស្មោះត្រង់ តាមបម្រើព្រះរាមដោយឥតងាករេ ដូចជាការកេណ្ឌទ័ពស្វាទៅវាយក្រុងលង្កា បង្ហាញផ្លូវឲ្យព្រះរាមទៅចងសម្ព័ន្ធមិត្តជាមួយ នីងមហាជម្ពូពានព្រមទាំងបានចេញច្បាំងសម្លាប់យក្សអស់ជាច្រើន។

### ចំណុចអវិជ្ជមាន

-ជាមនុស្សទន់ខ្សោយ អសមត្ថភាពជាកូនប្រុស ពេលដែលជួបបញ្ហាអន្ទុយយំរហូតអាចម៍ភ្នែកក្លាយជាភ្នំ ទឹកភ្នែកហូរក្លាយជាទឹកជ្រោះធ្លាក់ក្លាយជាទន្លេ។

-ជាមនុស្សដែល គិតពីប្រយោជន៍ផ្ទាល់ខ្លួនពុំបានពិចារណាឲ្យបានដិតដល់ព្រោះតែគំនុំផ្ទាល់ខ្លួន បែរជាហ៊ានសម្លាប់បងប្រុសបង្កើតដើម្បីអំណាចបុណ្យសក្តិ ដែលបរទេសលើកបន្តុបៗមិនតែប៉ុណ្ណោះគេហ៊ានលក់ជាតិ លក់ជីវិត ស្នេហ៍ បម្រើបរទេសដោយនាំទាំងពូជពង្សវង្ស

ត្រកូលទាំងមូលទៅធ្វើជាកញ្ជះគេ សុខចិត្តចេញ រងអាវុធស្លាប់គរទីក គរដីដើម្បីបម្រើបុគ្គលខ្លួនឯងម្នាក់ប៉ុណ្ណោះ។

-ភ្លេចគុណអ្នកដទៃ ពេលដែលគេមកជួយយកបានយសសក្តិហើយ សុគ្រីពបែរជាសប្បាយភ្លេចកេណ្ឌទ័ពថ្វាយព្រះរាម លុះត្រាតែព្រះរាមគម្រាមនឹងបំផ្លាញខាសខិនបុរីចោលទើបសុគ្រីពប្រញាប់កេណ្ឌថ្វាយ។

៦ ពាលី

**ចំណុចវិជ្ជមាន**

-មានកម្លាំងខ្លាំងលើសទូភី និងក្រុងរាពណ៍ ព្រមទាំងមានប្រាជ្ញាឈ្លាសវៃ។នៅពេលដែលដឹងថាតិបាក យកឈ្នះទូភី ក៏បានទៅប្រកួតក្នុងរូងភ្នំព្រោះគេយល់ថា នៅទីនោះចង្អៀតដែលសត្វក្របីពិបាកធ្វើចលនាក្នុង ការប្រយុទ្ធ។

-មានប្រាជ្ញាឈ្លាសវៃ ដោយបានឲ្យសុគ្រីពចាំបិទរូងភ្នំដើម្បីសម្លាប់ទូភី។

-ជាស្តេច និងជាស្វាមីដ៏ល្អព្រោះពេលឮថាពាលីស្លាប់ អាមាត្រ សេនា ស្នំក្រមការ ព្រមនាងតារាជាមហេសីបានទួញសោកស្តាយស្រណោះពេញនគរ។

-ជាវីរជនស្នេហាជាតិពិតមិនខ្លាចស្លាប់ មិនរាថយ មិនសុំជីវិតពីព្រះរាមឡើយ សុខចិត្តស្លាប់ក្នុងកិត្តិយស ប្រសើរជាងរស់នៅមានឈ្មោះថាជាជនអាយ៉ងសុំជីវិតពីខ្មាំងសត្រូវ។

**ចំណុចអវិជ្ជមាន**

-មានចរិតកាចឆេវឆាវ ខ្វះការពិចារណានឹងប្រើអំណាចផ្តាច់ការ មិនស្តាប់ការបកស្រាយរបស់សុគ្រីព ព្រមទាំងបណ្តេញសុគ្រីពឲ្យ

ចេញពីនគរ។

-មានកាមគុណក្រាស់ដោយ លួចស្រឡាញ់ប្រពន្ធរបស់ក្រុងពពណ៌ រហូតលួចស្រឡាញ់ប្រពន្ធប្អូនប្រុសនឹង យកមកធ្វើជាកម្មសិទ្ធិខ្លួនទៀតគឺនាងតារាទេពី។

៧ មហាជម្ពូ

**ចំណុចវិជ្ជមាន**

- ជាស្តេចស្វានៅនគរហេមពាន្តបុរី មានភ្នែកក្រលេកផេះ។

-មហាជម្ពូជាស្តេចមានប្រាជ្ញា និងស្រឡាញ់ប្រទេសជាតិដោយបានគិតធ្វើយ៉ាងណា ដើម្បីរកល្បិចដោះខ្លួនមិនព្រមលក់ជាតិជាចំណុះបរទេសឡើយ ពោលគឺសុខចិត្តបញ្ជូនខុនទីល និងខុននលជាក្មួយទៅច្បាំងប្រសើរជាងយកប្រជារាស្ត្រទៅបម្រើគេទាំងនគរ។**ចំណុចអវិជ្ជមាន**

-ជាតួអង្គដេកទ្រមក់ រហូតហនុមានលើកទាំងគ្រែថ្វាយព្រះរាម និងបានចាញ់កលព្រះរាមថាជាព្រះនារាយណ៍។

៨ ក្រុងពាពណ៍

**ចំណុចវិជ្ជមាន**

-ស្តេចសោយរាជ្យនៅនគរលង្កា នឹងជាស្វាមីនាងមណ្ឌោគិរី ជាបងប្រុសដែលចេះអាណិតស្រឡាញ់ប្អូន ពេលដែលឮថាប្អូនត្រូវគេធ្វើបាបកាប់សម្លាប់ ពពណ៍មានកំហឹងណាស់ ក៏មានគំនិតសងសឹកលើគូសត្រូវភ្លាម។

-ជាស្តេចយក្សអង់អាចក្លាហានម្នាក់ ពុំខ្លាចសឹកសង្គ្រាម តស៊ូស៊ិតស្វាញជាមួយសត្រូវប្រសើរជាងចុះញ៉មធ្វើ ឲ្យបាត់វីរភាព និងអាប់ឱន

កិត្តិយសជាពូជពង្សយក្ស។

-បេះយុទ្ធសាស្ត្រ និងល្បិចក្នុងសង្គ្រាមដោយឲ្យសេនាទៅយាមព្រៃកុំឲ្យទ័ពស្វាបេះផ្លៃឈើស៊ីបាន។

-រាពណ៍បានប្រើសង្គ្រាមចិត្តសាស្ត្រ ដោយបានបញ្ឆិះនាងសីតាបញ្ឈឺចិត្តព្រះរាម។

-ជាយក្សដែលរឹងមាំ មានការសម្រេចចិត្តឥតរារែកទោះបីអ្នកណាឃាត់ឃាំង ឬជំទាស់ក៏ដោយ សូម្បីតែនាងមណ្ឌោគិរី កុម្ភកាណ៌ ឬពិភេកក៏ដោយ។

**ចំណុចអវិជ្ជមាន**

-ជាបុរសល្មោភកាមតណ្ហា ដើរលួចប្រពន្ធគេឯងគ្រប់គ្នា ដូចជាលួចនាងទេពកញ្ញាជាប្រពន្ធព្រះឥន្ទ្រ នាងមណ្ឌោគិរីប្រពន្ធពាលី និងនាងសីតាប្រពន្ធព្រះរាមជាដើម។ សង្គ្រាមដែលរាពណ៍បង្កើតឡើង គឺពុំមែនកើតឡើងដោយការសងសឹក ឲ្យប្អូនប៉ុណ្ណោះទេគឺដោយសាររាពណ៍ឮនាងស្ទូបនខានិយាយអួតសរសើរពីសម្រស់នាងសីតាថា ល្អឯកធ្វើឲ្យក្រុងរាពណ៍កើតមោហៈឥតពិចារណាពីផលវិបាកចុងក្រោយ។

-ជាជនផ្តាច់ការ អត្តនោម័តពុំស្តាប់យោបល់អ្នកដទៃពុំគោរពសិទ្ធិក្នុងការបញ្ចេញមតិរបស់ពិភេក កុម្ភកាណ៌ និងមណ្ឌោគិរីបណ្តាលឲ្យក្រុងលង្កាត្រូវរលាយ។

-គម្រាមកំហែងផ្ទាញ់ផ្ទាលដើម្បីឲ្យសម្រេចបំណងខ្លួន ដូចជាគម្រាមកំហែងមហារីកថា "មឹងពុំខ្លាចអញដ៏ជា ឥស្សរមឹងថា **បល្ល័**ក៏មានឫទ្ធិក្រៃ។ មឹងកៀចកាចគួរត្រូវដៃ ដៃអញជ័យក្រៃ ពិជ័យនៃសាកាគរ"។

-រាពណ៍បញ្ឈឺញុះញង់ កុម្ភកាណ៌ថាខ្លាចស្វាដើម្បីឲ្យកុម្ភកាណ៌ចេញច្បាំង: "ត្រាសថាអានេះឥតក្រែង ហ៊ានទូលទាស់លែង ថាអញ

លុះលោកតណ្ហា ខ្លួនរាំខ្ទប់ខ្ចាចសត្វស្វា ខ្ចាចមនុស្សទ្វេរហោ ពុំហ៊ានកើតករចេញប្លាំង។

-ពុំចេះស្តាប់ហេតុផល និងបំណងល្អរបស់ពិភេកបែរជាខឹងដោះស្បែកជើងវាយក្បាលប្អូននៅចំពោះមុខមន្ត្រី បង្ករជាផលពិបាកសម្រាប់ខ្លួននៅចុងក្រោយ។

-មិនត្រឹមតែជាមនុស្សដែលមិនចេះស្តាប់ហេតុផលទេ ភពណ៍ថែមទាំងបានប្រើពាក្យសម្តីតិះដៀលមហេសីថា "ភពណ៍រីងក្រេវក្រោធរីងស្ពង់ បើដូចពាក្យហង់ ម្តេចក៏មូលនឹងពិភេក មឹងយកពិភេកជាប្តី ប្តីមឹងស្នេហា ចំណាំចំណង់ចិត្តហង់"។

-ភពណ៍ដេកទ្រមក់ ធ្វើឲ្យហនុមានលួចថ្មនៅក្រោមខ្នើយព្រមទាំងបានចងសក់ភពណ៍ ជាប់ជាមួយសក់នាងមណ្ឌោគិរីទៀតផង លុះត្រាតែនាងមណ្ឌោគិរីយកដៃឆ្វេងវាយក្បាលភពណ៍បីដងទើបរួចចំណង

-ឆោតល្ងង់ធ្វើឲ្យហនុមាន បោកប្រាស់រហូតឆេះក្រុងលង្កាទាំងមូល។

១០ ពិភេក

**ចំណុចវិជ្ជមាន**

-ជាហោរាសាស្ត្រ ដែលមានជំនាញច្បាស់លាស់ទស្សន៍ទាយមិនដែលចេះខុសម្តងណាឡើយ ដូចជាការទាយពី រាសនាក្រុងលង្កា និងពីហេតុភេទជាចម្ងល់ របស់ព្រះរាមពីអាថ៌កំបាំងរបស់ពួកយក្សជាដើម។

-មានជំនាញពេទ្យពូកែសក្តិសិទ្ធ ដូចជាករណីជួយព្យាបាលជំងឺព្រះលក្ស្មណ៍ពេលត្រូវពិសមោងសក្តិរបស់ កុម្ភកាណ៍ឲ្យបានជាសះស្បើយ។

-មានចរិតស្លូតត្រង់ នឹងចង់ឲ្យបងប្រុសខ្លួនលះបង់អំពើអាក្រក់ ដើម្បីឲ្យជាតិចៀសផុត ពីគ្រោះអន្តរាយ។

-មានស្មារតីនឹងនរ មិនតក់ស្លុតទោះបីស្ថិតក្នុងស្ថានភាពតឹងតែង ឬក្នុងសមរភូមិក៏ដោយ។

**ចំណុចអវិជ្ជមាន**

-ក្បត់ជាតិពូជពង្សសន្តានខ្លួន លក់ក្បាលបម្រើសត្រូវដោយសារតែគំនុំផ្ទាល់ខ្លួន។ ជាជនដែលនាំអ្នកក្រៅមកបំផ្លាញនគរនិងប្រជារាស្ត្រខ្លួនដោយពុំចេះធ្វើការពិចារណាវែងឆ្ងាយ។ ស្មោះត្រង់ជាមួយសត្រូវ ជួយព្យាបាលរបួសឲ្យសត្រូវ។

១០ កុម្ភកាណ៌

**ចំណុចវិជ្ជមាន**

-ជាយក្សកាន់សីល តែមានចេស្តាខ្លាំងអស្ចារ្យធ្វើឲ្យព្រះលក្ស្មណ៍ត្រូវរបួសស្ទើរស្លាប់។

-ប្រកាន់ចិត្តអត់ធ្មត់ សុខចិត្តធ្វើតាមបញ្ជាបង ទោះបីដឹងថាបងធ្វើខុសក៏ដោយ ក៏ព្រមចេញច្បាំងដោយចិត្ត អង់អាចក្លាហានដើម្បីរក្សាកិត្តិយសជូនបងប្រុស។

-មានការពិចារណាបានវែងឆ្ងាយ ស្គាល់ខុសស្គាល់ត្រូវ ស្គាល់គុណទោស អាក្រក់ល្អ ដូចជាការឈ្វេងយល់ថា រឿងរ៉ាវទាំងអស់គឺបណ្តាលមកពីនាងសូបនខាចង់ប្រុសខុសតម្រា និងរឿងតណ្ហាឥតព្រំដែនរបស់ក្រុងរាពណ៍។

-ស្រឡាញ់កិត្តិយស ពុំសុខចិត្តលក់ខ្លួនបម្រើបរទេសជា សត្រូវ

ដាច់ខាត មានឧត្តមគតិស្នេហាជាតិមាតុភូមិគ្រួសារ ទោះបីជាគេប្រើបុណ្យសក្តិទាក់ទាញយ៉ាងណាក៏ដោយ។

**ចំណុចអវិជ្ជមាន**

-ជាអ្នកកាន់សីលមែនតែបែរជាចូលសមរភូមិធ្វើសង្គ្រាមកាប់សម្លាប់គ្នាទៅវិញ។

-ដឹងថាកំហុសទាំងអស់មកពីនាងសូបនខា និងរាពណ៍ហើយតែនៅសុខចិត្តស្តាប់បញ្ជាចេញទៅច្បាំងដោយឥតប្រកែក។

-នៅពេលប្រយុទ្ធក្នុងសមរភូមិ កុម្ភកាណ៌បែរជាលើកលែងឲ្យសត្រូវដោយពុំគិតពីលទ្ធផលចុងក្រោយ នៅទីបំផុតព្រះលក្ស្មណ៍ត្រឡប់មកសងសឹកសម្លាប់ខ្លួនវិញ។

១១ ឥន្ទ្រជិត

**ចំណុចវិជ្ជមាន**

-មានសីលវិជ្ជាខ្លាំងពូកែ អាចយកជ័យជម្នះលើព្រះ-លក្ស្មណ៍បានដោយសារនាគបាសដែលបាញ់ទៅកើតជា នាគរយពាន់មកចាប់សត្រូវ។

-ចេញទៅសមរភូមិដោយអង់អាច ស្តាប់បង្គាប់មាតាគឺនាងមណ្ឌោគិរីដើម្បីជួយស្តារកិត្តិយសបិតា។

**ចំណុចអវិជ្ជមាន**

-ស្លាប់ក្នុងសមរភូមិដោយត្រូវព្រះលក្ស្មណ៍សងសឹកសម្លាប់យ៉ាងសាហាវវិញ។

១២ អង្គទ

**ចំណុចវិជ្ជមាន**

-មានឫទ្ធិពូកែអស្ចារ្យ និងជាសេនាដ៏ស្មោះត្រង់ដែលជាអ្នកនាំសារចម្បាំង។

-អង្គទចេះគោរពមាតាបិតា ដោយចេះលើកដៃធ្វេងប្រណម្យព្រមទាំងពោលពាក្យសសើរគុណមាតាថាជា អ្នកផ្ដល់កំណើតឲ្យបុត្រគ្រប់រូប ទោះបីជាម្ដាយខ្លួនមិនបានចិញ្ចឹមបីបាច់ថែរក្សាខ្លួនក៏ដោយ។

**ចំណុចអវិជ្ជមាន**

-លក់ឧត្ដមគតិ បម្រើផលប្រយោជន៍ឲ្យសត្រូវ ហើយបានសម្លាប់ឪពុកបង្កើតរបស់ខ្លួន។

-ជាកូនអកត្តញ្ញូមិនប្រតិបត្តិឪពុកបង្កើតរបស់ខ្លួន។

-ជាមនុស្សដែលធ្វើការហួសបទបញ្ជា ក្នុងនាមជាទូតម្នាក់គេបានបង្កចលាចលពេញក្រុងលង្កា។

១៣ ព្រះបាទទសរថ

**ចំណុចវិជ្ជមាន**

-ជាស្ដេចដែលមានអំណាចចេស្ដា អាចយកជ័យជម្នះលើព្រះសុរិយា។

-ស្រឡាញ់បុត្រគ្រប់គ្នា ដោយចេះអប់រំថែរក្សា នឹងបានបញ្ជូនកូនឲ្យទៅរៀនសិល្បវិជ្ជាគ្រប់គ្នា។

-ជាស្ដេចដែលគោរពពាក្យសត្យផង និងជារាជបវេណីផង ដោយសុខចិត្តបែងចែកនគរជាពីរចំណែកដើម្បី បញ្ចប់ទំនាស់ក្នុងរាជវង្ស។

**ចំណុចអវិជ្ជមាន**

-ពីឯកវិរិយាក្នុងការប្រយុទ្ធជាមួយព្រះអាទិត្យ ទើបបានជានាងកៃកេសីទទួលបានពាក្យសន្យា។

-ក្នុងនាមជាក្សត្រគ្រប់គ្រងនគរ ព្រះបាទទសរថបានប្រទានពាក្យសន្យាផ្ដេសផ្ដាស ទើបបានបង្កជារឿងហេតុរហូតបុត្រាបង្កើតរបស់ខ្លួនត្រូវនិរទេសទៅរស់នៅ រសាត់អណ្ដែតកណ្ដាលព្រៃអស់រយៈពេល ១៤ឆ្នាំ ដែលទង្វើនេះនាំឲ្យប៉ះពាល់ដល់ព្រះកិត្តិយសរបស់ព្រះអង្គជាខ្លាំង។

-ជាក្សត្រដែលមានប្រពន្ធច្រើន ហើយបង្ករការច្រណែន ទំនាស់ពុំចេះចប់ លុះដល់ពេលមានបញ្ហាច្រើន ឡើង ព្រះអង្គបែរជាគ្មានសមត្ថភាពក្នុងការដោះស្រាយទៅវិញ។

-ព្រះបាទទសរថ បានធ្វើឲ្យខុសក្រឹត្យក្រមបវេណីក្សត្រដែលមានតាំងពីយូរលង់ណាស់មកហើយ។

១៨ នាងកៃកេសី

**ចំណុចវិជ្ជមាន**

-បានជួយស្វាមីក្នុងសមរភូមិដោយមិនខ្លាចបាត់បង់អាយុជីវិត។

-ជាម្ដាយដែលមានចិត្តអាណិតស្រឡាញ់កូនពិតៗ ពិសេសគឺចង់ឲ្យកូនបានខ្ពស់មុខខ្ពស់មាត់។

**ចំណុចអវិជ្ជមាន**

-ជាបុគ្គលអាត្មានិយម មានចិត្តលោភលន់ តេវតាវមិនចេះស្ដាប់គេឯង ធ្វើអ្វីៗតាមតែទំនើងចិត្តបំពានលើទំនៀមទម្លាប់ដើម្បីបំពេញមហិច្ឆតារបស់ខ្លួន។

-ជាអ្នកដែលឈ្នានីស ព្រះរាមដោយបានបញ្ជូនព្រះរាមទៅនៅក្នុងព្រៃអស់រយៈពេល១៤ឆ្នាំ។

-ជាស្ត្រីដែលពោរពេញដោយមិច្ឆាទិដ្ឋិ បានធ្វើអំពើឲ្យប្តីពិបាកចិត្តរហូតដល់ស្លាប់បាត់បង់ជីវិត នាងគឺជាឃាតករសម្លាប់ប្តីដោយប្រយោល។

១៥ ព្រះភិរុត និងសុត្រុត

**ចំណុចវិជ្ជមាន**

-គោរពស្រឡាញ់បងប្រុសដោយអស់ពីចិត្តពីថ្លើម។

-គោរពស្រឡាញ់ និងអាលោះអាល័យដល់បិតាជានិច្ច ហើយគោរពតាមបវេណីរបស់រាជវង្សសំខាន់ជាងការ លោភលន់ចង់បានអំណាច។

-ចង់ឲ្យពាក្យសត្យ របស់បិតាបានសម្រេចដើម្បីរក្សាកិត្តិយសទ្រង់។

**ចំណុចអវិជ្ជមាន**

-ជាមនុស្សឆេវឆាវ ឥតចេះគិតពិចារណាឲ្យបាននវែងឆ្ងាយពីបំណងល្អរបស់មាតាខ្លួន តែបែរជាចង់សម្លាប់ មាតាខ្លួនដោយកាត់ជាបីកំណាត់ទៅវិញ។

១៦ រាមលក្ស្មណ៍ និងជប្បលក្ស្មណ៍

**ចំណុចវិជ្ជមាន**

-ចេះអាណិតស្រឡាញ់គ្នាទៅវិញទៅមក នឹងចេះជួយគ្នាទៅវិញ

ទៅមក។

-មានសមត្ថភាព និងសិល្បវិជ្ជាខ្ពង់ខ្ពស់ស្មើព្រះនរាយណ៍ គេមានអាយុទើបតែ១០ឆ្នាំតែមានសិល្បវិជ្ជាខ្ពស់ លើសគេ។

-គោរពស្រឡាញ់មាតា ហើយបានព្យាយាមផ្សះផ្សាទំនាស់រវាងអ្នកមានគុណទាំងពីរ។

-អាចចាប់ហនុមានជាមេទ័ពខ្លាំងពូកែចងស្វាបសេក ហើយបញ្ជូនឲ្យម្ចាស់ដើមពិតប្រាកដស្រាយគឺព្រះរាម ទើបអាចស្រាយចំណងនេះរួច។

**ចំណុចអវិជ្ជមាន**

-រឿលប៉ូចហ៊ានល្មើសនឹងបម្រាម ដូចជាបានចាប់សេះព្រះមហាក្សត្រជិះលេងទោះបីបានឃើញសេះមាន ចងសារជាប់នៅក ក៏ដោយ។

-ព្រហើនកោងកាចពុំចេះគោរពមនុស្សចាស់ ពុំចេះគួរសមដោយវាទាមទារឲ្យព្រះរាមប្រាប់វង្សសន្តានមុន ទើបបានវាប្រាប់តាមក្រោយ។

-ជាក្មេងដែលមានអំនួតក្អេងក្អាងហួសពីសមត្ថភាព ដូចជាករណីខ្លួនវាមានតែពីរនាក់ហើយជាកុមារតូចៗ បែរជាហ៊ានតតាំងនឹងព្រះមហាក្សត្រដែលមានទ័ពច្រើន នឹងពូកែៗ។ នៅទីបំផុត រាមលក្ស្មណ៍ត្រូវចាញ់ដៃព្រះគិរុត នឹងត្រូវសុត្រុតចាប់បានហើយអាក្រោសពាសពេញនគរ។ ឆ្លងកាត់តាមការសិក្សា នឹងវិភាគខាងលើរួចមក យើងអ្នកសិក្សាឃើញថាអ្នកនិពន្ធមានសិល្បវិធីអស្ចារ្យ នៅក្នុងការតាក់តែងរឿងឲ្យបានល្អ និងរស់រវើកដែលមានតម្លៃពុំអាចកាត់ថ្លៃបាន។ រឿងនេះមានតម្លៃសម្រាប់ សង្គមមនុស្សនៅក្នុងសង្គមខ្មែរនៅគ្រប់សម័យកាល ទោះបីជាសាច់រឿងមានភាពអស្ចារ្យក៏ដោយ ក៏អត្ថរសនិង អត្ថន័យ ជាតម្លៃដ៏វិសេសនៃការអប់រំនៅតែមាន សម្រាប់អ្នកសិក្សាដដែល ពិសេសនោះគឺ

តម្លៃរឿងនៅតែបង្ហាញលក្ខណៈមនុស្សជាដរាប ដែលលក្ខណៈមនុស្សនិយមនេះហើយបានផ្សាភ្ជាប់និងជំនឿ ប្រពៃណី ទំនៀមទម្លាប់ ខ្មែរ និងការរស់នៅរបស់មនុស្សខ្មែរមួយចំនួនធំទៀត។ ដូច្នេះក្នុងនាមជាកូនខ្មែរយើងទាំងអស់គ្នា ចាំបាច់ត្រូវមានចំណេះដឹងឲ្យបានទូលំទូលាយផ្នែកអក្សរ-សាស្ត្រខ្មែរ ដើម្បីលើកកម្ពស់ស្នាដៃបុព្វបុរសយើងឲ្យកាន់តែថ្កុំថ្កើងឡើងថែមទៀត ពិសេសនោះគឺត្រូវជួយផ្សព្វផ្សាយស្នាដៃ ឲ្យជនបរទេសបានស្គាល់ពីតម្លៃសិល្បៈខ្មែរបន្ថែមទៀត។

# អក្សរសិល្ប៍សម័យលង្វែក

## ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍សម័យលង្វែក

*នៅចុងសម័យអង្គរ ពិធីទេវរាជត្រូវ បានថមថយឥទ្ធិពលបន្តិចម្តងៗ ហើយទន្ទឹមនិងនេះដែរលទ្ធិព្រះពុទ្ធ សាសនាបែបហីនយាន ដែលនាំចូលមកពីស្រីលង្កា ក៏បានចូលមកផ្សព្វផ្សាយលើជ្រោយសុវណ្ណភូមិ។ ទោះបីជា សាសនានេះជា សាសនាថ្មីដែលទើបនឹងហូរចូលមកស្រុកខ្មែរក៏ដោយ ក៏សាសនាដែលគេស្គាល់ថាជាសាសនា ដែលអប់រំពុទ្ធបរិស័ទឲ្យបេះខន្តីបានរីកចម្រើនយ៉ាងឆាប់រហ័សក្នុង សន្តានចិត្តរបស់ប្រជាពលរដ្ឋខ្មែរនៅសម័យនោះ។ ទន្ទឹមនឹងការហូរចូលសាសនាថ្មីនេះដែរ ខ្មែរយើងក៏បាន ទទួល ភាសា ថ្មីមួយ ទៀតគឺ**ភាសាបាលី** ហើយខ្មែរសម័យនោះក៏ចាប់បោះបង់ភាសាសំស្ក្រឹតបន្តិចម្តងៗ ប៉ុន្តែខ្មែរមិន បានបោះបង់*

បោលភាសារបស់ខ្លួនឡើយ ផ្ទុយទៅវិញខ្មែរបានកាឡៃ ភាសានេះឲ្យទៅជាភាសា របស់ខ្លួនបន្ថែមទៀត។

ឧទាហរណ៍: ជយ (ជ:យ:) → ជ័យ

អក្សរសិល្ប៍សម័យក្រោយអង្គរ ឬសម័យកណ្តាល គឺគេសម្តៅដល់បណ្តា វណ្ណកម្ម ទាំង ឡាយណាដែល អ្នកនិពន្ធបានចងក្រង ឡើងដោយប្រើពាក្យពេចន៍ជាភាសាខ្មែរ កណ្តាល (មិនប្រើ ភាសាបាលីសំស្ក្រឹត ហួរហៀរពេក) ពោលគឺចាប់ពីសតវត្សទី១៥ ដល់ទី១៩ដែលជា សម័យ កាលបរិបទថ្មីនៃអក្សរសាស្ត្រខ្មែរ។

បើតាមលោកសាស្ត្រាចារ្យ**លាង ហាប់អាន**បានសរសេរ នៅក្នុងសៀវភៅ **សិក្សាប្រវត្តិ អក្សរសាស្ត្រខ្មែរ សម័យនគរភ្នំដល់សម័យឧដុង្គ** (សតវត្សទី១ ដល់ឆ្នាំ១៨៥៩) បោះពុម្ពឆ្នាំ១៩៦៧ ទំព័រទី៥ ដល់ទី១១ បានបែងចែកសម័យកាលអក្សរសាស្ត្រខ្មែរជាបួនផ្នែកធំៗគឺ៖

- សម័យកាលទី១ សម័យនគរភ្នំ(សតវត្សទី១ ដល់សតវត្សទី៦)

-សម័យកាលទី២ មុនសម័យអង្គរ (គ្រិស្តសករាជទី៥៥០ ដល់គ្រិស្តសករាជ៨០២)

-សម័យកាលទី៣ សម័យអង្គរ (គ្រិស្តសករាជសទី៨០២ ដល់គ្រិស្តរាជស១៣៣៦)

-សម័កាលទី៤ សម័យក្រោយអង្គរ (ចុងសតវត្សទី១៤ រហូតដល់បច្ចុប្បន្ន)

នៅសម័យកណ្តាលគឺសម័យទី៤ លោកបានធ្វើការបែងចែកអក្សរសិល្ប៍ជាបីផ្នែកសំខាន់ៗទៀតគឺ៖

-ផ្នែកទី១ អក្សរសិល្ប៍សម័យលង្វែក (គ្រិស្តសករាជ ១៣៣៦ ដល់គ្រិស្តសករាជ១៥៩៣)

-ផ្នែកទី២ អក្សរសិល្ប៍សម័យក្រុងឧដុង្គមានជ័យ (គ្រិស្តសករាជ ១៦១៨ដល់គ្រិស្តសករាជ១៨៥៩)គឺចាប់ពីរាជព្រះបាទជ័យជេដ្ឋា(១៦១៨-១៦២៨)រហូតដល់រាជព្រះបាទអង្គឌួង (១៨៤៥-១៨៥៩)។

-ផ្នែកទី៣ អក្សរសិល្ប៍សម័យចតុមុខ ( គ្រិស្តសករាជ១៨៥៩ រហូតដល់សម័យបច្ចុប្បន្ន ដែលមានចែកជាបីសម័យកាលទៀត គឺ សម័យអាណានិគម សម័យកាលឯករាជ្យ និងសម័យ សង្គមរាស្រ្តនិយម

ទន្ទឹមនិងនេះដែរ បើតាមលោកសាស្ត្រាចារ្យបណ្ឌិត **ឃីង ហុកឌី** នៅក្នុងសៀវភៅ **ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ** លោកបានធ្វើការបែងចែកអក្សរសិល្ប៍ខ្មែរជាពីរនិន្នាការ គឺតាមបែប ប្រវត្តិវិទ្យា និងតាមបែបភាសាវិទ្យា។ តាមប្រវត្តិវិទ្យាលោក ក៏បានធ្វើការបែងចែកចេញជាប្រាំសម័យកាល៖

-**មុនសម័យអង្គរ** (ស វទី១ ដល់ទីស វទី៩)

-**សម័យអង្គរ** (ស វទី៩ ដល់ស វទី១២)

-**ក្រោយសម័យអង្គរ** (ស វ ទី១៥ ដល់ស វទី១៨)

-**សម័យអាណានិគមបារាំង** (គ ស ១៨៦៣ ដល់គ ស១៩៥៣)

-**សម័យបច្ចុប្បន្ន** (គ ស ១៩៥៣ រហូតដល់បច្ចុប្បន្ន)

ចំណែកនៅផ្នែកភាសាវិទូ បានបែងចែកអក្សរសិល្ប៍ខ្មែរតាមការវិវត្តនៃភាសា និងនិរុត្តិសាស្ត្រ(គម្ពីរ សិក្សាពីរបៀបបញ្ចេញ សូរសំឡេង) ហើយបាន បែងចែកអក្សរសិល្ប៍ ជាបីសម័យកាលធំៗគឺ៖

-**សម័យបុរាណ ឬភាសាខ្មែរបុរាណ** គិតចាប់ពីសតវត្សទី៧ដល់ទី១២ គឺជាសម័យកាល នៃភាសាខ្មែរ ដែលបុព្វបុរសយើងបានចារនៅសិលាដែលគេហៅថា**សិលាចារឹក**។

-**សម័យកណ្តាល ឬសម័យភាសាខ្មែរកណ្តាល** គឺភាសាខ្មែរមាននៅសិលាចារឹកខ្លះៗ តែសម្បូរនៅលើ សាស្ត្រាស្លឹករិត ក្រាំងគម្ពីរ ក្បួនច្បាប់ផ្សេងៗក្នុងអំឡុងសតវត្សទី១៩

-**សម័យបច្ចុប្បន្ន** ជាសម័យនៃភាសាទំនើបគឺជាភាសាខ្មែរនិងអក្សរខ្មែរយើងនិយាយសរសេរ និងប្រើការ រហូតមកដល់បច្ចុប្បន្នពេលគឺចាប់តាំងពីពាក់កណ្តាលសតវត្ស ទី១៩រហូតមកៗ

នៅសម័យកណ្តាល ជាសម័យកាលមួយដែលអក្សរសិល្ប៍ខ្មែរមានការប្រែប្រួលយ៉ាងខ្លាំងផ្នែកអត្ថរូប អត្ថន័យ និងអត្ថរសដោយសារតែអ្នកនិពន្ធ ចេះផាកមកចាប់អារម្មណ៍លើផ្នែករស់នៅរបស់មនុស្សក្នុងសង្គមជាក់ស្តែងវិញ ដែលខុសប្លែកពីអត្ថន័យសិលាចារឹកបង្ហាញតែពីការបូជា លះបង់ក្នុងបុព្វហេតុសាសនាជាដើមៗ ស្នាដៃទាំងនេះភាគច្រើនបានកត់ត្រានៅលើស្លឹករិត ដែលខ្មែរនិយមហៅថា **សាស្ត្រាស្លឹករិត** ។ ប្រសិនណាជាយើងជជីករកឫសគល់ នៃការផ្លាស់ប្តូរចរន្តអក្សរសិល្ប៍នេះ គឺគេអាចនិយាយបានថាមកពីមានការប្រែប្រួល នៃស្ថានភាពរស់នៅរបស់សង្គម រួមទាំងប្រវត្តិសាស្ត្រ នយោបាយដឹកនាំ ពិសេសគឺជំនឿសាសនាដែលជាកត្តាចម្បង នៃការផ្លាស់ប្តូរខាងសិក្សាអប់រំតាមបែបព្រហ្មណាចារ្យ មកសិក្សាតាមសាលាវត្តព្រះពុទ្ធសានាវិញៗ

បើតាមការស្រាវជ្រាវរបស់លោកបណ្ឌិត**ឃីង ហុកឌី** នៅក្នុងសៀវភៅ**ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ** បានសរសេរថា អត្ថបទអក្សរ-សាស្ត្រសម័យកណ្តាល យើងបានរកឃើញជាច្រើនពាន់ក្បាលនៅបណ្ណាល័យក្នុងស្រុកខ្មែរ និងបណ្ណាល័យឯកទេសនៅអឺរ៉ុប ដូចជា៖

-បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ មាន១៦៤៧ឈ្មោះ(សាស្ត្រាបញ្ជីឆ្នាំ១៩៦៥)ៗ

-បណ្ណាល័យជាតិក្រុងប៉ារីសមាន៣៥០ឈ្មោះ (សាស្ត្រាបញ្ជីឆ្នាំ ១៩៥៣ ធ្វើដោយលោក **អូឈឿង**)។

-បណ្ណាល័យសាលាបារាំងចុងបូព៌ាប្រទេសមាន១៤៩ចំណង ជើងធ្វើដោយលោក **ល្វី ហ្វីណូត៍** នៅក្នុងចំណងជើងនីមួយៗជួនកាល មានច្រើនខ្សែ គឺមានប្រហែលជា៥០០ច្បាប់ជាសៀវភៅដែលបានចម្លង ដោយដៃ បញ្ជីដែលយើងបាន ធ្វើនៅឆ្នាំ១៩៧៨។

-បណ្ណាល័យប្រតិកូបរទេស នៃគ្រឹះសាសនានៅទីក្រុងប៉ារីស មាន១២៦ ឈ្មោះ(សាស្ត្រាបញ្ជី ដែលយើងបានធ្វើនៅឆ្នាំ១៩៧២)

-សារមន្ទីរមនុស្សក្រុងប៉ារីសមាន១៩ឈ្មោះ (សាស្ត្រាបញ្ជីធ្វើ ដោយអ្នកស្រី**សូឡង់ ប៊េរី** ឆ្នាំ១៩៦២)

ចំពោះការកត់ត្រាលើឯកសារទាំងអស់នោះមានបីបែប សំខាន់ៗដូចជា៖

**បែបទី១** កត់ត្រាលើក្រាំងដែលមានសន្លឹកបើកបានទាំងសង ខាង។ ការកត់ត្រាដោយស្វាបប៉ាកាឬស្វាបសត្វ ជាមួយទឹកខ្មៅចិន។ សន្លឹកក្រដាសនេះធ្វើ នៅក្នុងប្រទេសដែលមានកម្រាស់ក្រាស់អាចរក្សា ទុកបានយូរ។ ក្រដាសនេះត្រូវ បានធ្វើពីស្លឹកស្មាយ និងស្លឹកមន។

**បែបទី២** មានការកត់ត្រាដូចបែបទីមួយដែរ តែផ្ទៃ ក្រដាស មាន ពណ៌ខ្មៅហើយចារដោយដីសថ្ម។

**បែបទី៣** កត់ត្រាលើស្លឹករឹតដោយប្រើដែកចារ ចោះទម្លុះ ដោយមានការចោះខ្សែតាមលេខរៀងទំព័រ។ កំណត់ត្រានេះគេហៅ ថា **សាស្ត្រាស្លឹករឹត**។

នៅក្នុងចំណោមឯកសារសម័យកណ្តាល លោក**អូ ឈឿង** បាន ធ្វើការបែងចែកសាស្ត្រាជាបីគឺ៖

**សាស្ត្រាទេសន៍** ជាអត្ថបទដែលទាក់ទងនិងការសម្ដែងធម៌ ពោលគឺជាទ្រឹស្ដីអប់រំទាក់ទងជាមួយព្រះ ពុទ្ធសាសនា។

**សាស្ត្រាល្បែង** ជាកម្រងអត្ថបទសម្រាប់ការកម្សាន្តសប្បាយ បំពេរអារម្មណ៍ឲ្យរន្ធត់ កម្សត់ ទៅតាមកម្រងស្នាដៃដែលអ្នកនិពន្ធបាន ប្រារព្ធឡើងប្រកបដោយភាសាដ៏ប្រណីត។

ក្នុងគោលបំណងមួយជួយបំបាត់ ទុក្ខកង្វល់បន្ទាប់ពីបំពេញការ កិច្ច អស់រយៈពេលមួយថ្ងៃហើយនោះ គេបង្កើតសាស្ត្រានេះឡើងដើម្បី ជួយសម្រួលអារម្មណ៍មនុស្សទាំងនោះបានមួយគ្រា។ មនុស្សនៅសម័យ នោះមានចំណូលចិត្តស្ដាប់រឿងសាស្ត្រាណាស់ ។ ពួកគេស្ដាប់សាស្ត្រា នេះ ដោយមានអ្នកអានម្នាក់ប្រើងសូត្រធ្វើបែបបទយ៉ាងពីរោះ។ សាច់ រឿងដែលកម្សត់ ក៏ធ្វើបទជាតំអូញតំអក់ទៅតាមនោះ។ ដូច្នេះអ្នកស្ដាប់ ទាំងប៉ុន្មាននាំគ្នាសើច ឬយំទៅតាមសាច់រឿងនោះដែរ។

អ្នកដែលអាចអានសាស្ត្រានេះបាន លុះត្រាតែអ្នកនោះបានបួស រៀន ឬបានសិក្សាច្បាស់លាស់ខាងវិជ្ជាអក្សរសាស្ត្រ។ ពេលយប់ខែភ្លឺ គេ តែងបបួលគ្នាទៅស្ដាប់សាស្ត្រាជារឿយៗ។ សាស្ត្រាសម័យនោះប្រហែល ជាដូចភាពយន្តសម័យនេះដែរ។

សាស្ត្រាប្រភេទនេះ ត្រូវបានចារជាកំណាព្យប្រកបដោយពាក្យ ពេចន៍ពីរោះរណ្ដំណែងណង។ ទេពកោសល្យនេះគឺជាវិជ្ជាមួយបែប សម្រាប់ជំរុញខឿនអក្សរសិល្ប៍ខ្មែរឲ្យរឹតតែមានលក្ខណៈ ជឿនលឿន បន្ថែមទៀត។

**សាស្ត្រាក្បួន** គឺជាកម្រងសេចក្ដី ដែលនិយាយពីបែបបទនៃគោល ចារីកទុកជាក្បួនច្បាប់ដូចជា ក្បួនទាយ ក្បួនថ្នាំព្យាបាលរោគ ក្បួនច្បាប់ ក្បួនសាវតា ជាដើម។

## អំពីអ្នកនិពន្ធនិងស្នាដៃ

ដូចអ្វីដែលបានរៀបរាប់ខាងលើមកហើយថា នៅសម័យលង្វែក វណ្ណកម្មអក្សរសិល្ប៍ខ្មែរ ភាគច្រើនជាអត្ថបទសាស្ត្រាល្បែងប៉ុន្តែមិនមានកាលបរិច្ឆេទច្បាស់លាស់។ សាច់រឿងច្រើនតែសរសេរជាពាក្យកាព្យដែលមានច្រើនខ្សែ ច្រើនភាគហើយការសរសេរអ្នកនិពន្ធពឹងផ្អែកលើមនោគតិស្រមើស្រមៃ ផ្ទៃរឿងលាតត្រដាង ពីមន្តអាគម តួអង្គចេះហោះហើរ ជ្រែកមេឃ ជ្រែកទឹក ជ្រែកដីមិនសមហេតុផលនៃជីវិតពិតនៅលើផែនដី។

មូលហេតុដ៏ចម្បងដែលនាំឲ្យអ្នកនិពន្ធសរសេរ សាច់រឿងដូច្នេះ គឺលោកចង់សម្រាលទុក្ខលំបាករបស់ប្រជាជនដែលរងទុក្ខវេទនា ដោយសារបញ្ហាស្រុកទេសជួបកលយុគទាំងក្នុងស្រុក និងក្រៅស្រុក (ចម្បាំងជា មួយសៀមឈ្លានពាន និងយួន)។

ក្រៅពីអត្ថបទទាំងអស់នោះ ក៏នៅមានអត្ថបទជាច្បាប់ ទូន្មានកូនចៅជំនាន់ក្រោយៗដែរដែលការសរសេរ ត្រូវបានកត់ត្រាជាសាស្ត្រាស្លឹករិតនិងក្រាំង។ គួរឲ្យសោកស្ដាយណាស់ដែលក្បួនច្បាប់ទាំងអស់នោះ ត្រូវបានវិនាសខ្ទិចខ្ទីរដោយសារភ្លក់ភ្លើងសង្គ្រាម ។ ទោះបីជាយ៉ាងណាក៏ក្បួនច្បាប់ទាំងអស់នោះ មិនបានរលាយសាបសូន្យទាំងអស់ដែរ ព្រោះខ្មែរនៅមានវត្តអារាមដែលបានរក្សាទុក ប៉ុន្តែក្បួនច្បាប់ ឬរឿងរ៉ាវផ្សេងៗពុំត្រូវបានអ្នកនិពន្ធបង្ហាញឈ្មោះឡើយ ព្រោះតែខ្លាចមានទោសដល់ខ្លួនក៏អាចថាបាន។

ជាបន្តខ្ញុំនឹងលើកយកអ្នកនិពន្ធ រួមជាមួយស្នាដៃមកសិក្សា នៅពេលនេះ។ អ្នកនិពន្ធទាំងនោះមានៈ

## ១ **អ្នកប៉ាង**

លោកអ្នកនិពន្ធនេះបានសរសេររឿងល្បើក**អង្គរវត្ត** អំឡុងឆ្នាំ ១៥៩៨ ដែលផ្ទៃរឿងសរសេរជាកំណាព្យ ប្រកបដោយចំណាប់ចូនរណ្ដំ ណែងណងល្ងងល្ងាយពាយពាក្យពីរោះផ្អែមល្ហែម។ សាច់រឿងល្បើក អង្គរវត្តជាអក្សរសិល្ប៍ដ៏អស្ចារ្យនោះ ត្រូវបាននិយាយរៀបរាប់ពីការ កសាងប្រាសាទអង្គរវត្តជាលក្ខណៈទេពនិទាន។ ចំណែកលោក **ឃួន សុខម្ហ** បានសរសេរនៅក្នុង **គំនិតរិះគន់សង្គមក្នុងអក្សរសិល្ប៍ខ្មែរ** សន្និសីទផ្ញើ

នៅសាលាជាតិខាងរដ្ឋបាលនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៤នាទីក្រុង ភ្នំពេញ ថា អក្សរសិល្ប៍ រឿងល្បើកអង្គរសេរសេរនៅឆ្នាំ១៦០៩ទៅវិញ។

បើតាមការសន្និដ្ឋានរបស់លោកឃីងហុកឌី សរសេរក្នុងសៀវ ភៅ**ល្បើកអង្គរវត្ត** ឆ្នាំ១៩៨៥ ទំព័រ១១៨ថា អ្នកប៉ាងជា ព្រះសុគន្ធដែល មានសាមណ្ណសក្តិធំមួយព្រះអង្គ និងជាសម្តេចសង្ឃគណៈធម្មយុត្តិនិ កាយ ហើយសម្តេចព្រះសុគន្ធនេះទៀតសោតប្រហែលជាមានឈ្មោះថា ប៉ាង ឬប៉ង ឬប៉ាន ដែលជាអ្នកប្រាជ្ញខ្មែរមួយរូបនៅក្នុងរាជ្យព្រះបាទអង្គ ឌួង។ ការសរសេរនេះ សបញ្ជាក់ឲ្យឃើញថា អ្នកប៉ាងជាអ្នកកាន់ព្រះ ពុទ្ធសាសនាមួយរូប។

ខាងក្រោមនេះ ខ្ញុំនឹងលើកយកអត្ថបទសម្រង់នៃរឿងល្បើក អង្គរវត្តមកបង្ហាញជូនដល់ប្រិយមិត្តអ្នកអានដូចតទៅ ៖

...ព្រះកេតុសូរ្យវង្ស មៀងមើលរូបទ្រង់
អស់នាងកញ្ញា សើចលេងក្អាកក្អាយ
សប្បាយណាស់ណា មុខគួរស្នេហា

នូវនាងទាំងឡាយ ។

ស្តេចគិតអាឡោះ អាល័យស្រណោះ
ពុំចង់ឃ្លាតឆ្ងាយ គន់គិតជញ្ជឹង
វិតឹងសព្វសាយ វង់គិតវង់ស្តាយ
ពុំចង់ឃ្លាឃ្លាត ។

រីអស់ទេពផង នាំគ្នាត្រសង
ក្រាបទូលឥន្ទ្រា ឲ្យស្តេចឆាប់នាំ
បុត្តស្ងួនពុំងា រួសរាន់ម្ចីម្ចា
មិនឲ្យយូរលង់ ។

រីព្រះឥន្ទ្រា ចមនោះទេវា
អំបូរពូជពង្ស អាសូរបុត្រស្ងួន
ខ្ញីមខ្លួនវរវង្ស កបរូបកបទ្រង់
លើសលែងនានា ។

ទើបស្តេចឆ្លាសឆ្លើយ ថាហៃមាសអើយ
កុំបីសង្ការ អញនឹងនាំបុត្រ
បរិសុទ្ធពុំងា ចរចាកលីលា
រួសរាន់ទៅហោង ។

ស្តេចលោមបុត្រា មាសស្ងួនស្នេហា
សម្ងាញ់ស្នេហា ឪពុកនឹងជូន
កូនស្ងួនទៅហោង ឥឡូវជាម្តង
ឥតឯរួញរា ។

ចៅកេតុសូរិយា វិសេសសេដ្ឋា
ឆ្នូតឆ្នើមលោកា លើកករបង្គំ

ប្រណម្យបិតា ទើបទូលក្រាបថា
បពិត្រម្ចាស់ថ្លៃ ។
ផ្តើមអស់លោកា ច្បងលើទេវតា
នៅនាឋានត្រៃ- ត្រឹង្សាពិភព
ស្ងួតសក្តិសព្វថ្លៃ ចិត្តខ្ញុំអាល័យ
ពុំចង់ឃ្លាតឆ្ងាយ ។
សម្តេចចក្រិន ចមពៅនរិន្ទ
ស្តាប់បុត្រឆោមឆាយ ថាដ្បិតស្រណោះ
អាឡោះស្ថានអាយ ស្រួលសុខសប្បាយ
ឥតឯគណនា ។
ទើបស្តេចឆ្ពាស់ឆ្លើយ ថាហៃស្ងួនអើយ
កុំថប់រួញរា នឹងពិភពឋាន
ពិមានស្ងួតា ឪពុកជានា
សាងឲ្យអ្នកថ្លៃ ។...

នារីស្រស់ស្រីដ៏ប្រពៃ ហាក់កើតឯងនៃ កំលេចពីក្បែបបុប្ផា ។
ខ្លះក្លាយកែជាមុខរាហ៍ ខ្លះក្លាយជាមហា ហែមហង្សប្រសើរបវរ ។
ខ្លះក្លាយជានាគជាមករ ខ្លះជាគ្រុឌា ករចាប់នាគាធក់ធី ។
ឆ្ងៅធ្លាក់ចម្លាក់អស់ក្តី ក្បែបក្លាយជាក្បី ហាក់មានវិញ្ញាណរួរស់ ។
ប្រាសាទប្រាំរួតស្រេចស្រស់ ថ្កល់ថ្កើងខ្ពង់ខ្ពស់ ត្រដឹងត្រដែត-
ស្រោងស្រួច ។
ត្រីស្ងូលកំពូលច្រូងច្រួច ដុងដោមបីត្រដួច ត្រដែតកណ្តាលវេហាស៍។
ធ្លាក់ធ្លុកត្របកបទុមា ក្បូរក្បាច់រចនា រំយោលសម្រាប់ស្អាតស្អាង ។
គាងឃ្លាយបីត្រដាចច្រូងច្រាង សីមាដាំខាង ត្រចៀកក្របីស្រស់ស្រេច។

ផងក្ដារពពារមុខដាច់ ឆ្មៅឆ្លាក់ក្បូរក្បាច់ រំលេចបុប្ផាបីប្រពៃ ។
មុខព្រហ្មសាតសមថ្កើងក្រៃ ទាំងបួនទិសនៃ ប្រាកដប្រកបសាយសព្វ។
ផ្ទះផ្ទាំងបីជញ្ជាំងជួបចប់ ផ្ទះខ្វៃងដ៏ប្រសព្វ នូវមុខសម្រាប់ឥតថ្កង។
កាំយូរសីមាដាំខ្សង ស៊ីកខ្នុរនោះផង ដាំរំលេចជួរចារ ។
សរសេរស្ដម្ភទ្រវៀងភល ជ្រុងជ្រោយស្ទឹងសារ- ពើសូតប្រកិតរៀងរូច។
ផ្ទះផ្ទាំងជញ្ជាំងបង្អួច ដើងទៀនរល់រូច ចម្លាក់ក៏ឆ្លាក់ល្អក្រៃ ។
ប្រដាប់ស្រាប់បីប្រពៃ ដំបូលនោះនៃ ល្បើរួតប្រាសាទស្រាប់ស្រេច។
ផ្ទះត្រៃឡែងកែងមុខដាច់ សោតសង់ស្រស់ស្រេច ប្រាសាទផុសតកណ្ដាល។
ប្រាសាទទាំងបួនមានទ្វារ គ្រប់សព្វនូវប្រការ បន្ទាប់ទ្រាប់ត្រួតលើគ្នា។
ផ្ទះផ្ទាំងជញ្ជាំងប្រាង្គប្រា- សាទសួគ៌សោភា ចម្លាក់ចម្លៅអស់ក្ដី។
ឆ្លាក់ជារូបរតន៍នារី ហៅគគរតី គឺស្រីប្រសើរសួគ៌ា។
រូបទ្រង់បញ្ចង់សោភា ឈរឈមរៀងគ្នា លេងលើប្រាសាទសោតហោង។
ខ្លួនមូលសសូលឥតហ្មង ទន់ភ្លន់មុខឈ្នង ប្រកបនូវលក្ខណ៍បានខ្នាត។
ផ្ចិតចារភ្ញើញរស្អាងស្អាត ខ្វះបួងខ្វះកាត់ កែមកាល់កេសាសោតសម។
ចង្កេះរៀវឆ្នៀវមូលខ្ចំ ដោះសោតសីងក្បំ ក៏ដូចក្រពុំបទុមា ។
ស្រលះសជ្រះអង្គា សឹងពាក់មាលា គន្ធាគមរាកាឡី ។
ចងនូវចំណងកេសី ពេនព័ន្ធទង់ភ្ញី សក្ដិសមបន្ទាយល្អក្រៃ។...
ផ្ទាំងមួយកុម្ភការណ៍រាជា លើកទ័ពលីលា ព្រះរាមស្ដេចយល់អស្ចារ្យ។
ផ្ទាំងមួយឆ្លាក់ជាកុម្ភកាណ៌ ធាត់ធំសាមាន្យ ប្រយុទ្ធនឹងព្រះលក្ស្មា។
ព្រះលក្ស្មណ៍ផ្ទែងសរក៏ផ្ទា ផ្ចុលកុម្ភកាណ៌ ក៏លុះអំណាចព្រះអង្គ។
ផ្ទាំងមួយឥន្រ្ទជិតឆោមយង់ ផ្ទែងសរបាញ់បង់ សូបនក៏ជានាគា។
ពានពាក់ព្រះលក្ស្មណ៍អនុជា នូវអស់ពលស្វា ក្រញែនៗទីទៃ។
ផ្ទាំងមួយព្រះរាមខ្វាល់ក្រៃ កាច់កៅទណ្ឌជ័យ នឹងបោះឲ្យឆេះសួគ៌ា។

ធ្លាក់ជាគ្រុឌនាគមហិមា ហិចហោះមកណា ក៏នាគនោះរត់ខ្វាត់ខ្វាយ។
ផ្កាំងមួយព្រះលក្ស្មណ៍ពណ្ណរាយ ទ្រើសទ្រង់ឫទ្ធី សាយទ្រង់កៅទណ្ឌសរថ្វា។
ផ្ទុលឥន្ទ្រជិតយក្សា កណ្តាលពសុធា វិនាសទាំងពលយក្សយង់ ។
ផ្កាំងមួយសោតធ្លាក់ជាក្រុង រាពណ៍ក្រោធបទ បង់ព្រះរាជបុត្រច្បងណា។
ទសមុខសែនសោយសោកា ក៏កាន់ខ័នថ្វា ក៏ហួតមហាគ្រវី ។
យក្សកាន់សិរសាក្សត្រី សីតាទេពី ប៉ុនប៉ងពិឃាតឲ្យមរណ៍ ។
ផ្កាំងមួយធ្លាក់ជាមហាសរ លើកពលចេញចរ ប្រយុទ្ធនូវអង្គទណា។
អង្គទរក៏កាន់ខ័នថ្វា ថ្វាញមហាសរណា ក៏លាញវិនាសអន្តរាយ។
ធ្លាក់ជាក្រុងមហាអតិកាយ នូវលក្ស្មណ៍ពណ្ណរាយ ក៏តប្រយុទ្ធនូវគ្នា។
ព្រះលក្ស្មណ៍ទ្រង់សរផ្កាញផ្កា ផ្ទួលអតិកាយ មហាយក្សានូវពលណាស់នៃ។
ផ្កាំងមួយធ្លាក់ជាត្រីសិរ លើកពលមកមីរ សំញើញសំញែងរឿងរុង ។
ធ្លាក់ជាព្រះរាមស្តេចគង់ ក្រៅទណ្ឌបីតម្រង់ ប៉ុនចង់ទទួលយក្សា។
ធ្លាក់ជាភិភេគហោរា បង្គំរាជា សូមឃាត់ព្រះរាមស្តេចឈប់ ។
ផ្កាំងមួយធ្លាក់ជាឧសក ហនុមានប្រតិរុទ្ធ ប្រយុទ្ធនូវត្រីសិរណា។
ត្រីសិរថ្លៃងសរសក្តិផ្កា ហនុមានមហិមា ឧសកក៏ស្ទុះចូលចាប់ ។
បានកៅទណ្ឌទាញបីត្រលប់ វិលវៃធៀងឆាប់ សម្ងាប់អសុរត្រីមុខ។
ផ្កាំងមួយធ្លាក់ជាវនុត លើកពលតត្រុក ករកាន់នូវទណ្ឌសរថ្វា ។
ធ្លាក់ជាពិភេគសេនា ករកាន់ខ័នថ្វា ទទួលប្រយុទ្ធរឿងរុង ។
ពិភេគស្ទុះស្ទាវដ៏ត្រនង់ ពះអង្គនូវអង្គ ក៏ដួលនូវរាលមរណា ។
ផ្កាំងមួយធ្លាក់ជាមហា ក្បាលធំមហិមា ក្រុទាករកាន់ដំបង ។
ឧសកសេនាទ្រើសឃ្នង កាន់ខ័នបីសំពង់ ក៏ពះប្រយុទ្ធមហិមា។
ពាក់ព័ន្ធប្រវណ្ឌផង់គ្នា ឧសកមហិមា គ្រុទាក៏ផ្ទួលមហាក្បាល... ។
យល់មករពិន្ទុងថ្លៃថ្វា ហែលលេងលីលា លលកកណ្តាលជលធី ។

ក្ងុកក្ងៅស្មើស្មាទាំងពីរ ស្រកាស្រកី រូបហានវិញ្ញាណរូបរស់។
វាត់វាយទឹកខ្វាយខ្ពង់ខ្ពស់ អស់អង្គស្រេចស្រស់ ប្រដាប់សឹងមាសច្រាសច្រាល។
រូបនាគលោលោកពពារ អវឯងបីត្រអាល ក៏ហែលលេងលើជលសា។
ឃ្មាតខ្មាញ់ហាក់ដេញកច្ឆា ត្រីផងនានា រេរាទីងខ្វាចនាគនោះ។
រូបរាជ្រាជសីហ៍ហៀរហោះ ប្រែប្រាណស្វាញស្ទុះ ក៏ចាប់អម្រឹតយង់ឃ្នង។
យន្តកេសររាជសីហផង ចរចេញលេងលង ក៏ហោះកណ្តាលនភី។
ចរចាប់ទងកេសរភ្ញី ចាប់បានចាប់ធី រូបហានរូវរស់វិស័យ ។
ប្រែប្រឹងបីសន្ធឹងវិលវៃ នេត្រនោះរំពៃ ក្រឡេកក្រលួងបីសម្ងឹង។
យន្តមួយធ្វើជារូបហង្ស ឈរឈប់ប្រែប្រឹង ក្រឡេកក្រឡៅនេត្រា ។
យន្តស្មាន់នូវយន្តកា ពារយុទ្ធនឹងគ្នា កណ្តាលនៃអាកាសកង។
បន្តហង្សរាជរូបឱតតត្ផង ចរចេញលេងលង ក៏ហោះកណ្តាលវេហាស៍។
រីយន្តកៃលៃនលេលា ទៀបនឹងមនោរា ប្រយុទ្ធកណ្តាលនភី។
យន្តហង្សក៏សឹងពាំភ្ញី ទាំងទងរីកថ្មី ត្របកបទុមសុវណ្ណា ។
យន្តគ្រុឌឆៀងឆាបនាគា នាគព័ន្ធហត្ថា សម្តែងនូវឫទ្ធិបីពន្ធិក ។
រូបខ្វាចាប់អង្គអម្រឹត ក្រាបក្រោមព្រៃព្រឹក្ស ក្រលាស់ក្រលាប់ហានក្រៃ ។
ហាក់ដូចរូបរស់វិស័យ សក្តិសមពេកក្រៃ ក៏ស្ទុះលោលោកវិលលវៃ ។
រូបគជសារស្គឹមស្គៃ គោតគោព្រិចព្រៃ ក៏ស្រពក្រោមម្លប់អធ្វា។
រូបគោរូបគោមហិង្សា រូបហង្សនានា អនេគអនន្តណាស់នៃ ។
រូបបក្សីផងក្រាស់ក្រៃ ទុំដោយព្រឹក្សព្រៃ ប្រចឹកប្រចាប់ទងភ្ញី។
រូបខ្វះលោតលេងដោយដី ខ្វះលើកទងភ្ញី ក៏ទុំលេងលើព្រឹក្សា។
រូបសេកនូវរូបសារិកា ទុំទឹមខាងគ្នា ក៏ចឹកនូវបុប្ផាផង។
រូបកិន្នរីសោតហោង យាងយាសឆ្មៀងផ្អង ទាំងគូបក្សារេពំ ។
កែងកាងយាងយាសបីទន្ទាំ បានបទលំនាំ ជរជាយជជួរកែងករ។

ធ្វើរូបនាងទេពអប្សរ ទ្រង់ពស្ត្រាពរ កំកាច់នូវភ្ញីទាំងទង។
រេរាំទន់ភ្លន់បីវិញង ស្រស់ស្រេចឥតឆ្គង ស្រឡះស្រលូតឆោមឆាយ។
កាលនោះព្រះកេតុមាលា ពិសេសសោភា ស្ដេចឲ្យប្រដាប់គ្រប់សព្វ។
ទើបស្ដេចឲ្យរៀបប្រដាប់ ប្រាប់ប្រើពលទ័ព ឲ្យរៀបនូវគ្រឿងគ្រប់ដៃ។

ឆ្លងតាមការលើកមកបង្ហាញខាងលើនេះ យើងសង្កេត ឃើញថាស្នាដៃអក្សរសិល្ប៍រឿងល្បើកអង្គរវត្តជា ស្នាដៃដ៏ល្អឯកមួយនៅក្នុងចំណោមស្នាដៃនានាក្នុងប្រទេស។ ដោយសារលោកកវីជាពុទ្ធសាសនិកជនទើបលោក បានរិះគន់ទៅលើលទ្ធិព្រាហ្មណ៍សាសនាតាមរយៈការលាតត្រដាងឲ្យឃើញពីគុណវិបត្តិរបស់តួអង្គព្រះឥន្ទ្រ ពោលគឺកវីបានលាតត្រដាងពីភាពអយុត្តិធម៌ របស់ព្រះឥន្ទ្រដែលបានលើកស្ទួយព្រះកេតុមាលាជាកូនឲ្យទៅរស់នៅ ស្ថានសួគ៌ដោយមានលក្ខណៈជាទេវតា។ បច្ច័យទាំងនេះហើយ ទើបបង្កឲ្យមានភាពចលាចលនៅស្ថាន សួគ៌ ព្រោះតែសារជាតិជាមនុស្សលោក របស់តួអង្គរូបនេះ។

គំនិតសំខាន់មួយទៀតដែលអ្នកនិពន្ធចង់បង្ហាញដល់អ្នកសិក្សា គឺលោកចង់បង្ហាញ ពីភាពសច្ចៈនិងលក្ខណៈប្រជាធិបតេយ្យនៅស្ថានសួគ៌ មានន័យថាសារជាតិមនុស្សលោករបស់ព្រះកេតុមាលាដែលជាជនមិនមាន សម្ថភាពគឺមិនអាចរស់នៅស្ថានសួគ៌បានទេខុសប្លែកពីព្រះពិស្ណុការ ដែលមានជាតិជាមនុស្សលោកដែរ តែជាតួអង្គ មានសមត្ថភាព ពិតប្រាកដត្រូវបានរស់នៅ ស្ថានសួគ៌សុខសាន្តដូចទេវតាអង្គដទៃទៀតដែរ។ ទោះបីជា ព្រះកេតុមាលាមានអន្តរាគមពីព្រះឥន្ទ្រយ៉ាងណាក៏ដោយ ក៏សារជាតិពិតរបស់ ព្រះកេតុមាលាមិនត្រូវបានបិទបាំងជិតពីពួកទេវតាបានដែរ។ នៅទីបំផុត ភាពសច្ចៈ និងការរួមមតិភាគច្រើននៅតែអាច

យកជ័យជម្នះលើអំណាចបុគ្គលបានដដែល។ ត្រង់ចំណុចនេះ គឺជាគោលគំនិតមួយដែលបានពញ្ញាក់ស្មារតីមនុស្សម្នាក់ៗ ឲ្យចេះគិតនិងពិចារណាថា បុគ្គលដែលមានអំណាច ទោះបីជាធំប៉ុណ្ណាក៏ដោយប្រសិនជាបុគ្គលនោះរស់នៅ សង្គមប្រជាធិបតេយ្យគឺត្រូវតែគោរពធម្មនុញ្ញរាស្ត្រ និងគិតគូប្រយោជន៍ជាតិជាធំ ដូចជាករណីព្រះឥន្ទ្រដែលជាអ្នកគ្រប់គ្រងស្ថានសួគ៌ត្រូវបង្ខំចិត្តគោរពបំណងរបស់ពួកទេវតាយ៉ាងហ្នឹងឯង។ ដោយឡែក លោកកវីក៏ចង់បង្ហាញ ពីមនោសញ្ចេតនារវាងឪពុកម្ដាយ និងកូនតាមរយៈតួអង្គព្រះឥន្ទ្រ។ ទោះបីជាកូនស្ថិតនៅឆ្ងាយពីខ្លួនយ៉ាងណាក៏ មនោសញ្ចេតនាមួយនេះនៅជិតដាមជាប់ជានិច្ចរហូតដល់ព្រះឥន្ទ្រខិតខំពុះពារទៅយកបុត្រមករួមរស់ជាមួយ ទាំងបំពាន។ នៅទីបំផុត ព្រះឥន្ទ្រថែមទាំងបានសាងប្រាសាទទុកជាចំណងដៃកូនថែមទៀតផង។

សរុបសេចក្ដីមក ស្នាដៃអក្សរសិល្ប៍រឿងល្បើកអង្គរវត្ត គឺជាអក្សរសិល្ប៍ដ៏វិសេសវិសាលមួយនៅសម័យកណ្ដាល ដែលបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីការប្រើប្រាស់ ភាសាខ្មែរដែលមានលក្ខណៈលាយចម្រុះគ្នា ហើយការសរសេរនិយមសរសេរតាមសូរអាន។ ចំណុចសំខាន់មួយទៀត ដែលផុះចេញពីស្នាដៃនេះ គឺការវិវត្តន៍ពាក្យពេចន៍ដែលជាប្រភព យ៉ាងសំខាន់សម្រាប់អ្នកសិក្សាផ្នែកនិរុត្តិវិទ្យាដែលត្រូវសិក្សាផ្ដើមចេញពីស្នាដៃអក្សរសិល្ប៍ ជាចាំបាច់។ មិនតែប៉ុណ្ណោះ ល្បើកអង្គរវត្តអ្នកនិពន្ធបានអួតសរសើរ ពីសំណង់ស្ថាបត្យកម្មដ៏ល្អឯកនៃប្រាសាទអង្គរវត្ត ។ សំណង់ដ៏ល្អវិចិត្រនេះ គឺជាសក្ខីភាពមួយក្នុងការលាតត្រដាងពីអរិយធម៌ វប្បធម៌ដ៏ត្រចះត្រចង់របស់ជាតិខ្មែរកាលសម័យមហានគរ។

សំណង់ប្រាសាទអង្គរវត្ត គឺជាសំណង់ប្រាសាទប្រវត្តិសាស្ត្ររបស់ជាតិខ្មែរ និងជាសម្បត្តិវប្បធម៌ ដ៏ល្បីល្បាញរបស់ខ្មែរនៅលើ

សកលលោក ពោលគឺជាសម្បត្តិបេតិកភ័ណ្ឌពិភពលោក។ ពិសេសជាងនេះទៅទៀត អាស្រ័យដោយសារប្រាសាទអង្គរវត្តជាស្នាដៃឯកនៃសិល្បៈខ្មែរនិងជាដួងព្រលឹងជាតិខ្មែរ និងសកលលោក។ នៅពាក់កណ្ដាលក្នុងឆ្នាំ២០០៧អង្គការ UNESCO បានរៀបចំពិព័ណ៌វប្បធម៌**អង្គរ ឃ្យូឃ្យូ**នាទីក្រុងសៀមរាប។ បន្ទាប់មក ប្រាសាទអង្គរវត្ត ក៏បានជាប់ឆ្នោតជាអច្ឆរិយវត្ថុទាំងប្រាំពីរ ក្នុងចំណោមអច្ឆរិយវត្ថុ២០ទៀតនៅលើសកលលោកថែមទៀតផង។

## ២ បណ្ឌិតជ័យនន្ទ

បណ្ឌិតជ័យនន្ទ គឺជានាម៉ឺនមួយរូបក្នុងរជ្ជកាលព្រះបាទធម្មរាជា។ លោកមានភរិយាឈ្មោះនាងប៉ែន សន ដែលមានរូប សម្រស់ស្អាតត្រកាលជាច់ស្រីនានា។ លោកមានងារជាសេនាបតី បន្ទាប់មកលោកបានទៅ បម្រើការជាមន្ត្រីស្ដីទីនៅខេត្តត្បូងឃ្មុំ បន្ទាប់មកបានទទួលឋានៈជាឧកញ៉ាយមរាជ ចំណែកភរិយារបស់លោក ក៏បានឡើងយសជាជំទាវដែលមាននាមសន្មតថា ជំទាវសុពណ៌។

លោកបណ្ឌិត បានតាក់តែងសិលាចារឹកមួយខណៈដែលលោកបានទៅធ្វើបុណ្យយ៉ាងអ៊ឹកធឹក នៅឯប្រាសាទអង្គរវត្តដែលអត្ថន័យសិលាចារឹកនិយាយតែពាក្យស្តុតី និងការនិយាយបួងសួងប្រាថ្នាឲ្យបានសម្រេចដូចបំណង ទៅជាតិខាងមុខ។ ខាងក្រោមនេះ ខ្ញុំនឹងលើកយកកំណាព្យប្រែជាពាក្យទំនើបមកបង្ហាញដល់មិត្ត អ្នកសិក្សា៖

**បទនុជង្គលីលា**

នេះបទកុជន្តលីលា លើកដោយកាព្យ ជាល្បាទាំងឡាយ។
លាអស់លោកទោសសម្ពាយ លាភ័យអន្តរាយ ព្រាត់ព្រាយប្រាស់គ្នា។ខ្ញុំ
ក្រាបទូលព្រះពុទ្ធា ព្រះអើយខ្ញុំលា ត្រង់ណាទុកសោក។
ខ្ញុំលាត្រង់កំណើតថោក កើតមកអស់លោក សើចដៀលសន្តាន។
ខ្ញុំលាសព្វជាតិពៀរស្ពាន ក្តីអាស្រូវស្ពាន កុំមានឡើយណា ។
ខ្ញុំលាត្រង់ឥតប្រាជ្ញា ឆ្កួលខ្លៅមោហា ខ្មាស់គេអៀនប្រៀន។
ខ្ញុំលាត្រង់ឥតរបៀន ចូលជំនុំស្ងៀម ពុំចេះឆ្លើយថា ។
ខ្ញុំលាពិសព្យាធីពេគា ប្រាសបុត្រភរិយា ស្លាប់ឧបាសប្រាណ។
ខ្ញុំលាវិបាកបូរាណ ជាទុកក្នុងប្រាណ ស្រែកឃ្លាននោះផង។
ខ្ញុំលាអស់បាបពៀរហោង ចតុរាបាយផង បួនកុំទៅសោយ ។
ខ្ញុំលាត្រង់គំនិតធ្លោយ លាខ្ជិលកុំសោយ ហើយស្មារតីតិច។
ខ្ញុំលាពុំចេះកលកិច្ច សិល្បសាស្ត្រការស្រេច ពាក្យពេចន៍នោះណា។
ខ្ញុំលាត្រង់ឥតប្រាជ្ញា ពុំចេះភាសា ស្រដីនឹងគេ ។
ខ្ញុំលាត្រង់ខ្សត់ខ្លួនទេ ត្រមោចឯកឯង ឥតព្រាងនូវភ្ញា ។
ខ្ញុំលាឥតទ្រព្យភោគា ទាសីទាសា ពុំមានដល់ម្នាក់ ។
ខ្ញុំលាត្រង់ចិត្តប្រត្យក្ស ស្រដីឲ្យអាក់ អន់អៀនចិត្តគេ ។
ខ្ញុំលាត្រង់ពាក្យស្រាប់ស្រេ ស្រដីដូចគេ មមើឆ្កួតណា។...
ខ្ញុំលាបើមានទ្រព្យផង អាក្រក់នោះហោង កុំត្រាយល់ឡើយ។
ខ្ញុំលានេះជាបង្ហើយ បាបពៀរនេះអើយ កុំមានឡើយណា។
ខ្ញុំលាវេរភ័យវេរា កើតឡើងកាលណា ថ្ងៃល្អស្រេហោង។
កើតសុខនិងក្តីបំណង លាត្រង់នោះហោង កុំកើតមានឡើយ។...

## បទកាកគតិ

ខ្ញុំថ្វាយបទុមា សម្តេចកគវា
ស្រោចស្រង់ប្រោសប្រាណ ខ្ញុំកាន់បុប្ផា
វន្ទាស្រេចបាន ឧបជ្ឈាយ៍បួសប្រាណ
សូទ្រកម្មរៀចហោង ។

ខ្ញុំបួសនេះនៃ សំណាក់ព្រះត្រ័យ
សរណគមន៍ផង ខ្ញុំសូមឲ្យដឹង
កំណើតសត្វហោង តាមដោយគន្លង
នៃព្រះពុទ្ធត្រាស់... ។

ខ្ញុំសូមមានម្នាច ឫទ្ធិអំណាច
អានុភាពដោយចង់ ខ្ញុំសូមសិល្បជប
ធុតដូចព្រះអង្គ ព្រះឥសូរស្តេចទ្រង់
ជបនាងកគវតី ។

សូមម្នាចពុទ្ធាយ ដូចកាលព្រះនារាយណ៍
ចុះចាកអំពី សួគ៌មកកើតជា
ព្រះរាមទេពីឡី ផ្ចាញ់អស់តិរ្តិយ
អសុរលង្កា... ។

ខ្ញុំសូមទ្រព្យធន មាសប្រាក់រ័ត្នតន់
កែវមណីជោតជ្រះ ខៀនព្រៃកាសា
ចៀមព្រំពេញផ្ទះ ពួកពិតានមនៈ
ដូចជោតកសេដ្ឋី ។

ខ្ញុំសូមបរិពារ អស់ស្រីស្រឹង្គារ
ត្រកាលប្រិមប្រិយ រូបល្អលើសលន់
ទន់ភ្លន់មានស្រី សម្បុរសខៀវខ្ចី

តាមរយៈអត្ថបទខាងលើ លោកបណ្ឌិតជ័យនន្ទបាន បង្ហាញឲ្យឃើញថា សង្គមខ្មែរសម័យនោះបាន ប្រកាន់របបរាជានិយម ហើយព្រះរាជា ជាមនុស្សដែលប្រសើរជាងគេបំផុតនៅក្នុងប្រទេស។ តាមរយៈអត្ថបទនេះដែរ យើងឃើញថា សង្គមខ្មែរសម័យនោះមានការបែងចែកវណ្ណៈជាបួនគឺវណ្ណៈស្តេច មន្ត្រី សេដ្ឋី និងរាស្ត្រ ហើយលោកបណ្ឌិតប្រាថ្នាសូមឲ្យកើតជាស្តេចនៅបរលោក។ បន្ថែមពីលើនេះទៅទៀត តាមរយៈអត្ថបទខាងលើនេះ បានបង្ហាញឲ្យឃើញថា សង្គមខ្មែរសម័យនោះ បានគោរពបូជាព្រះពុទ្ធសាសនាហើយមានជំនឿជាក់យ៉ាងមាំ ទៅលើបញ្ហាកម្មផល ចំណែកខាងផ្នែកសង្គមកិច្ចខ្មែរពុំទាន់មានថ្នាំសង្កូវសម្រាប់ព្យាបាលជំងឺ ពិស ស្រែងនិងជំងឺឃ្លង់ទេ។

សរុបសេចក្តីមក អក្សរសិល្ប៍សម័យលង្វែក ទោះបីជាវណកម្មនោះ មានទំនោរទៅរកការស្រមៃយ៉ាងណាក្តី ក៏វណ្ណកម្មនេះ ជាគោលដៅដ៏ចម្បងមួយនៅក្នុងការផ្សព្វផ្សាយអក្សរសាស្ត្រ អក្សរសិល្ប៍ឲ្យបានជ្រាប ដល់បណ្តាប្រជារាស្ត្រដែលកំពុងរស់នៅក្នុងភាពភ័យខ្លាចដោយសារតែសង្គ្រាមដែលបានឆាបឆេះនៅក្នុងស្រុក។ ទុរភិក្ស ភាពលំបាកក្រខ្សត់ គឺជាឫសគល់នៃការអាប់ឱនជាតិ អ្នកនិពន្ធដែលមានគំនិតជាអ្នកស្នេហាជាតិ ស្នេហាអក្សរសាស្ត្រ លោកត្រូវមានភារកិច្ចនៅក្នុងការផ្សះផ្សាផ្លូវចិត្តរាស្ត្រខ្លួនជានិច្ច ទើបលើកខិតខំរិះរកវិធីយ៉ាងណាដើម្បីអប់រំផ្លូវចិត្តឲ្យបានធូរស្បើយល្ហើយពីទុក្ខកង្វល់នានានៅក្នុងសង្គម។

ផ្ទៀតឱកាសដែលប្រទេសជាតិ កំពុងទទួលនូវភាពចលាចល ព្រោះតែបញ្ហាសង្គ្រាមរ៉ាំរ៉ៃ ពួកបច្ចាមិត្រ ពិសេសគឺសៀមតែម្តងដែលមានវប្បធម៌ អរិយធម៌ស្រដៀងគ្នានិងខ្មែរដែរនោះ ក៏បានចាត់បញ្ជូនអ្នកអក្សរសាស្ត្រជាតិវា មកក្នុងប្រទេសកម្ពុជា ហើយបានប្រារព្ធរឿងនិទានមួយចំនួនទុកជាការអួតសរសើរពីព្រះរាជាប្រទេសវា និងកំណើតទឹកដីវាថាមានអាយុកាលរាប់សែនឆ្នាំមកហើយ។ បានជាខ្ញុំហ៊ានអះអាងដូច្នេះ ក៏ព្រោះតែខ្ញុំបានសង្កេតមើលឃើញរឿងព្រេងខ្មែរមួយចំនួន មានជាប់ ទាក់ទងជាមួយទឹកដី អំណាចព្រះរាជាប្រទសសៀមថា មានអំណាចមានវិសាលភាពធំទូលាយជាងប្រទេសខ្មែរ តាំងពីរាប់សតវត្សមកហើយ ហើយប្រទសខ្មែរ ច្រើនតែជាចំណុះនគរសៀមជាញឹកញយដូចជារឿងភ្នំបាយ័ង់កោជាដើម។ ទោះបីជារឿងមានកាលបរិច្ឆេទទឹកដីខ្មែរ ព្រះរាជា ខ្មែរ ពិសេសទោះបីជាសាច់រឿងបង្ហាញថា សៀមត្រូវទទួលបរាជ័យដោយត្រូវកម្មផលផ្ទុយយ៉ាងក៏ដោយ ក៏នេះជាកិត្តិយសមួយរបស់ខ្មែរដែរ ព្រោះវាជាសាច់រឿងដែលបញ្ច្រាស់ភាពពិតនៃប្រវត្តិសាស្ត្រ។

ភាពអសកម្មទាំងនេះ ក៏ព្រោះតែកាលនោះ ភាពសម្បូរបែបនៃវណ្ណកម្មអក្សរសិល្ប៍ នៅក្នុងសង្គមខ្មែរដែលកំពុងទទួលរងសង្គ្រាមមានវិសាលភាពទូលាយពេក ទើបមិនមានការត្រួតពិនិត្យបានច្បាស់លាស់ម្យ៉ាងទៀត ព្រោះតែបញ្ហាសន្តិសុខសង្គម ទើបវណ្ណកម្មទាំងនេះ មានឱកាសមកលុកលុយបំភាន់ការពិតនៅក្នុងសង្គមខ្មែរបាន។ យើងអាចគិត

ថា ចុះអ្នកប្រាជ្ញខ្មែរទៅណាអស់ បានជាបណ្ដោយឲ្យវណ្ណកម្មទាំងនេះមកលុកលុយក្នុងអក្សរសិល្ប៍ខ្មែរបាន?

ទោះបីជាមានភាពបញ្ច្រាស់ទិសនៃចំណេះដឹងអក្សរសិល្ប៍ នៅក្នុងសង្គមខ្មែរយ៉ាងណាក៏ដោយ ក៏សព្វថ្ងៃវាបានក្លាយទៅជាអក្សរសិល្ប៍របស់ខ្មែររួចទៅហើយ ហើយក៏កំពុងត្រូវបានសិក្សានៅសាលាចំណេះទូទៅផងដែរ។

ខ្ញុំមិនបានរៀបរាប់ឲ្យវែងឆ្ងាយពីបញ្ហានេះទេ សូមប្រិយមិត្តដែលមានគំនិតសិក្សាអំពីអក្សរសិល្ប៍ខ្មែរ អញ្ជើញអានបន្ថែមទៀតទៅសៀវភៅ**ភាពមិនត្រឹមត្រូវជាមួយប្រវត្តិសាស្ត្រខ្មែរតាមរយៈរឿងព្រេង** ដែលខ្ញុំបានចងក្រងដើម្បីជាការរិះគិតទាំងអស់គ្នាអំពីអក្សរសិល្ប៍ខ្មែរ។

# អក្សរសិល្ប៍សម័យឧដុង្គ (១៦១៨ ១៨៦៣)

## ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍សម័យឧដុង្គ

សម័យឧដុង្គ ជាសម័កាលមួយដែលពោរពេញទៅដោយវិបត្តិផ្ទៃក្នុងនៃរបបសក្តិភូមិនៅកម្ពុជា និងមានការជ្រៀតជ្រែកពីសំណាក់សត្រូវឈ្លានពានសៀម យួនៗ នៅក្នុងសម័យនេះ មិនមានការខុសប្លែកពីសម័យលង្វែកប៉ុន្មានទេ គឺកុលបុត្រកុលធីតាខ្មែរនាសម័យនោះ ត្រូវទទួលការរងទុក្ខវេទនាសព្វបែបយ៉ាង នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃៗ មកដល់ពេលនេះទៅហើយ ពួកចោរសៀមយួននៅតែមានបំណងប្ញន់

យកទឹកដីខ្មែរ ហើយវាមានគំនិតបំផ្លាញនូវសម្បត្តិវប្បធម៌ អរិយធម៌ជាតិខ្មែរឲ្យវិនាសសាបសូន្យចាប់ពីសម័យនោះមក។ ទោះបីជានៅសម័យលង្វែក ជាយុគខ្មៅងងឹតក្នុងប្រវត្តិសាស្ត្រខ្មែរយ៉ាងណាក៏ដោយក៏អ្នកអក្សរសាស្ត្រខ្មែរ នៅសម័យនោះខិតខំប្រឹងប្រែងថែរក្សាអក្សរសាស្ត្រជាតិមិនឲ្យរលុបរលាយទៅវិញដោយពួកខ្មាំងប្រវត្តិសាស្ត្រឡើយ ដែលព្រះសង្ឃក្នុងវត្តព្រះពុទ្ធសាសនានេះឯងជាអ្នកគ្រប់គ្រង និងថែរក្សាឲ្យបានឋិតថេរ គង់វង្សរហូតមក។

លុះមកដល់សម័យឧដុង្គ ត្រូវបានអ្នកអក្សរសាស្ត្រជាតិខ្មែរដែលនិយមស្រឡាញ់និងឲ្យតម្លៃលើមុខវិជ្ជានេះចាត់ទុកថា ជាសម័យមាសនៃប្រវត្តិអក្សរសាស្ត្រខ្មែរ មានន័យថា មកទល់និងសម័យនេះអក្សរសាស្ត្រខ្មែរមានការរីកចម្រើនជាងសម័យសតវត្សមុនៗ។

## អំពីអត្ថន័យ និងស្នាដៃអ្នកនិពន្ធ

អត្ថបទរឿងរ៉ាវផ្សេងៗនៅក្នុងសម័យឧដុង្គ សុទ្ធសឹងតែ មានលក្ខណៈជាការប្រឌិតឡើងតាមមនោគតិអ្នកនិពន្ធ ហើយការសរសេរភាគច្រើនមានលក្ខណៈមនោសញ្ចេតនា។ ផ្ទៃរឿងអ្នកនិពន្ធ បានជ្រើសរើសយករឿង នៅក្នុងជាតកបែបបាលីមកច្នៃការឡែទៅតាមទស្សនៈរបស់ខ្លួនដើម្បីសម្រេចគោលដៅតាមជំនឿ ការរស់នៅរបស់ មនុស្សនៅក្នុងសម័យកាលនោះ។

ការរស់នៅរបស់មនុស្ស ក្នុងសង្គមហាក់ដូចជាអស់សង្ឃឹមក្នុងជីវិត ដែលបញ្ហានេះហើយជំរុញឲ្យ ពួកគេស្រមៃទៅលើហេតុផលម្យ៉ាងដែលអស្ចារ្យ ហើយខ្លួនគិតថាអ្វីទាំងនោះអាចជួយរំដោះទុក្ខនិងសេចក្ដីកង្វល់របស់គេបាន។ ក្នុងន័យនេះ ទស្សនៈកម្មផលរបស់ព្រះពុទ្ធ

សាសនាបានត្រូវដើរតួនាទីជាចំណោទបញ្ហា និងបានដោះស្រាយបញ្ហាកង្វល់ ដែលកើតមានឡើងនៅក្នុងសន្តានចិត្តគេម្នាក់ៗ។ ដោយមានសម្គាល់ដូច្នេះហើយបានជាអ្នកនិពន្ធ បានលើកឡើងនូវរឿងដែលពោរពេញទៅដោយអច្ឆរិយៈដូចជាក្នុងរឿង តម្រូវឲ្យមានតួអង្គដូចជាទេវតា យក្ស អារក្ស អ្នកតា ឬមនុស្សដែលមានមន្តអាគមខ្លាំងពូកែដូចជា ចេះហោះហើរ បែងភាគ ឬកាប់មិន មុតដុតមិនឆេះ ជាដើម។ការកើតឡើងនៃវត្តមាននៃទស្សនៈកម្មផល បុណ្យបាប នៅក្នុងបណ្តាស្នាដៃនានានៅក្នុងសម័យឧដុង្គ ក៏ព្រោះតែការភិតភ័យ សេចក្តីលំបាកវេទនា និងការរងទុក្ខទោស ទារុណកម្មទាំងផ្លូវកាយ ផ្លូវចិត្តដោយសារចម្បាំងរាំងជល់ដ៏ឧក្រិដ្ឋពីសំណាក់ពួកសត្រូវឈ្លានពានបូន់យកទឹកដី។ មនុស្សខ្មែរកាលពីសម័យនោះបើកភ្នែកឡើង ឃើញតែការកាប់សម្លាប់ ការរត់ពួន ការអត់ឃ្លាន ពោលគឺពួកគាត់រកសេចក្តីសង្ឃឹមនៅក្នុងជីវិតមិនបាន ម្ល៉ោះហើយ ដើម្បីរំលែកសេចក្តីទុក្ខសោកទាំងនេះ ទើបកវីនិពន្ធខ្មែរសម័យនោះ ខិតខំរិះរកមធ្យោបាយដើម្បីព្យាបាលផ្លូវចិត្តឲ្យបានជ្រះស្រលះ។ ហេតុដូច្នេះហើយទើបនៅក្នុងសាច់រឿង លោកបានឲ្យផ្ទាន់ទៅលើតួអង្គដែលល្អដូចជាតួអង្គនោះ ប្រសិនជាស្លាប់ទៅនឹងទៅកើតនៅស្ថានសួគ៌ តួអង្គណាដែលអាក្រក់នឹងត្រូវធ្លាក់ចុះស្ថាននរក ដោយទទួលទារុណកម្មសព្វបែបយ៉ាងជាដើម។

និយាយជារួមមក ស្នាដៃអក្សរសិល្ប៍នៅក្នុងសម័យឧដុង្គ ជាស្នាដៃមួយដែលអ្នកកវី និពន្ធមានគោលដៅមួយ យ៉ាងសំខាន់ គឺការបំពេរលួងលោម អារម្មណ៍មនុស្សសម័យនោះដែលកំពុងជួបប្រទះការព្រាត់ប្រាស់ ទុក្ខសោក ភិតភ័យឲ្យបានជួបការសប្បាយរីករាយ និងមានសង្ឃឹមនៅក្នុងជីវិត។

អត្ថបទអក្សរសិល្ប៍ នានានៅក្នុងសម័យឧដុង្គបានប្រើពាក្យកាព្យជាមធ្យោបាយក្នុងការសរសេរ។ នៅគ្រប់អត្ថបទមានការប្រើពាក្យកាព្យផ្សេងៗពីគ្នា ដូចជាបទកាកគតិ បទព្រហ្មគីតិ បទពំនោល ឬបទបន្ទោលកាក ជាដើម។ ចំពោះរបៀបតាក់តែងអត្ថបទនេះ គោរពគោលការណ៍បីសំខាន់ៗដូចខាងក្រោមៈ

**-សេចក្តីផ្តើម** ច្រើនសរសេរជាបទនមស្ការព្រះរតនត្រ័យ រំឭកគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ រំឭក គុណព្រះមហាក្សត្រ ព្រះមាតាបិតា គ្រូបាអាចារ្យជាដើម។ ឯកសារខ្លះទៀតបានបញ្ជាក់ថាមានកាលបរិច្ឆេទនៃអ្នកនិពន្ធដែលគេច្រើនប្រើពុទ្ធសករាជ មហាសករាជ និងមានប្រាប់ឈ្មោះ ង៉ារសក្តិអ្នកនិពន្ធដែរ។ទោះបីជាបែបនេះក្តី ក៏ស្នាដៃរឿងមួយភាគធំបែរជាមិនមាន ឬបាត់កាលបរិច្ឆេទ និងអ្នកនិពន្ធទៅហើយដែលជាផលលំបាកសម្រាប់អ្នកសិក្សាជំនាន់ក្រោយ។

**-ដំណើររឿង ឬតួរឿង** នៅក្នុងដំណើរសាច់រឿងទាំងមូល អ្នកនិពន្ធបានប្រើភាសាបាលី(មគធភាសា) ឬភាសាសំស្ក្រឹតច្របូកច្របល់គ្នារួមផ្សំជាមួយចំណេះដឹងដែលមាននៅក្នុងខ្លួន រួចទើបបង្កើតបានជាស្នាដៃថ្មីមួយឡើង។ នៅក្នុងដំណើររឿងទៀតសោត ក៏និយាយតែពីបញ្ហាកម្មផល ដូចអ្វីដែលយើងពោលមកខាងដើមស្រាប់ មកជាគោលគំនិតនៃការអប់រំអ្នកអាន អ្នកស្តាប់។

**-ការបញ្ចប់រឿង** អ្នកនិពន្ធបញ្ចប់រឿងដោយធ្វើការឧទ្ទិសកុសលផលបុណ្យបែបជាអធិដ្ឋាន ឬមានការសៅ ជាតិដែលដំណើររឿងមានប្រភពមកពីគម្ពីរព្រះពុទ្ធសាសនា។

សាច់រឿងទាំងមូល ត្រូវបានអ្នកនិពន្ធសរសេរមានបញ្ចូលនូវភាពអស្ចារ្យដែលមិនមានពិតក្នុងជីវិតសង្គម មានកម្សត់ មានព្រាត់

ប្រាស់ កំប្លែង ការសេជាតិជាដើមមកបញ្ចូលនៅក្នុងស្នាដៃ ហើយតម្លៃទាំងនេះបានទួលមកពីគម្ពីរព្រះពុទ្ធសាសនាដែលជាមូលដ្ឋានដើម។

## អំពីអ្នកនិពន្ធ និងស្នាដៃ

ដោយសារភាសាបាលីមាន អនុភាពមកលើការសរសេរនិពន្ធរឿងរ៉ាវផ្សេងៗ ហេតុដូច្នេះហើយ បានជាយើងសម្លឹងឃើញគម្ពីរ ឬសាស្ត្រាផ្សេងៗសរសេរសុទ្ធ តែភាសាបាលីនៅគង់វង្សរហូតមកដល់សព្វថ្ងៃយ៉ាងច្រើនក្រាស់ក្រែល។ មិនត្រឹមតែប៉ុណ្ណោះ អ្នកនិពន្ធបានផ្ទេភាសាបាលីមកជាពាក្យកាព្យយ៉ាងពីរោះរណ្តំណែងណងដូចជាភាសាខ្មែរដែរ។

វាសនាអក្សរសិល្ប៍ខ្មែរមកដល់សម័យកាលនេះ សមណាស់ទទួលបានការរុងរឿងបំផុត ព្រោះមានការជួយឧបត្ថម្ភតាំងពីមជ្ឈដ្ឋានរាស្ត្ររហូតដល់ព្រះមហាក្សត្រ ដែលព្រះអង្គក៏មានការចាប់អារម្មណ៍ទៅលើបញ្ហានេះដែរ ព្រមទាំងមានការជួយជ្រោមជ្រែងអស់ពីព្រះទ័យថែមទៀតផង។

ទោះបីជាស្រុកទេស ជួបប្រទះសង្គ្រាមពុំរ៉ៃយ៉ាងណាក៏ដោយ ក៏យើងនៅតែរកឃើញស្នាដៃអក្សរសិល្ប៍ ជាច្រើនដែលសរសេរក្នុងន័យទ្រទ្រង់តម្លៃវប្បធម៌ខ្មែរនៅសម័យនោះ។ មានអ្នកនិពន្ធជាច្រើននាក់ដែលមានឋានៈ គ្រប់ជាន់ថ្នាក់បានពុះពារប្រឹងប្រែងសរសេររៀបជារឿងរ៉ាវទុកសម្រាប់ជាប្រយោជន៍រួម ដល់ប្រជាជនជំនាន់ក្រោយ មានទាំងព្រះសង្ឃ មានទាំងគ្រហស្ថ ជាមន្ត្រី ប្រជាជនសាមញ្ញ។ ចំណែកឯខាងព្រះមហាក្សត្រវិញ ក៏មានការចាប់អារម្មណ៍ខាងសរសេរវណ្ណកម្មអក្សរសិល្ប៍ដែរ ដែលព្រះរាជាទាំងនោះរួមមាន ព្រះបាទស្រីធម្មរាជា

ព្រះរាជាសម្ភារ ព្រះបាទជ័យជេដ្ឋា ព្រះបាទសម្តេចព្រះហរិរក្សរាមាធិបតីព្រះអង្គឌួងជាដើមៗ

អត្ថបទដែលចារឹកនៅក្នុងសម័យកាលនោះមានពីរប្រភេទ គឺបែបពាក្យកាព្យ និងបែបពាក្យរាយៗ ខាងក្រោមនេះខ្ញុំដកស្រង់ប្រភេទអត្ថបទទាំងនេះដាក់តាមចំណាត់ថ្នាក់ដូចតទៅ៖

## ក អត្ថបទដែលសរសេរជាប្រភេទកាព្យ

១ ច្បាប់ព្រះរាជសម្ភារ ព្រះរាជសម្ភារ សរសេរឆ្នាំ១៦២២

២ ច្បាប់រាជនីតិ ព្រះរាជសម្ភារ សរសេរឆ្នាំ ?

៣ លិខិតផ្ញើទៅថ្វាយព្រះម៉ៃយូរវត្តី ព្រះរាជសម្ភារសរសេរឆ្នាំ ?

៤ ពាក្យកាព្យចារឡើងកំពូលចុងត្នោត ព្រះរាជសម្ភារ ចារមុនពេលសុគត

៥ សរសើរហេមន្តមាស ព្រះរាជសម្ភារសរសេរឆ្នាំ១៦២៩

៦ កន្ទង់មាសមង្គលថ្ងៃ ព្រះរាជសម្ភារ សរសេរឆ្នាំ?

៧ ព្រលឹងមាសអើយ ព្រះរាជសម្ភារ សរសេរឆ្នាំ?

៨ ច្បាប់ក្រម ព្រះរាជសម្ភារ សរសេរឆ្នាំ?

៩ ច្បាប់ហៃសាធុជន ឬត្រីនេត្រ ព្រះរាជសម្ភារសរសេរឆ្នាំ?

១០ ហិនលក្ខណ៍សល់ ព្រះរាជសម្ភារសរសេរឆ្នាំ១៦៣០

១១ កាព្យនិរាស ព្រះរាជសម្ភារសរសេរឆ្នាំ១៦៦០

១២ រឿងខ្យងស័ង្ខ មិនស្គាល់ឈ្មោះ រៀបរៀងនៅចុងសតវត្សទី១៧ គឺប្រមាណជាឆ្នាំ១៧២៩

១៣ រឿងក្រុងសុភមិត្រ ឧកញ៉ាកោសាធិបតីកៅ សរសេរឆ្នាំ១៧៩៨

១៤ ច្បាប់សុភាសិត ឧកញ៉ាព្រះឃ្លាំងនង សរសេរឆ្នាំ១៧៩០

១៥ លោកនេយ្យជាតក ព្រះឃ្លាំងនង សរសេរឆ្នាំ១៧៩២

១៦ រឿងបុណ្ណាសាសិរសា ព្រះឃ្លាំងនង សរសេរឆ្នាំ១៧៩៨

១៧ រឿងភោគុលកុមារ ព្រះឃ្លាំងនង សរសេរឆ្នាំ១៨០២

១៨ រឿងវរនេត្រវរនុជ ព្រះឃ្លាំងនង សរសេរឆ្នាំ១៨០៦

១៩ រឿងព្រះសមុទ្ទ ព្រះឃ្លាំងនង សរសេរឆ្នាំ១៨០៨

២០ រឿងនាងកាកី ព្រះបាទអង្គឌួង សរសេរឆ្នាំ១៨១៣

២១ រឿងចម្ប៉ាថោង មិនស្គាល់ឈ្មោះ សរសេរឆ្នាំ១៨១៦

២២ រឿងរបាក្សត្រ ព្រះបុទុមបារមីពេជ្រ សរសេរឆ្នាំ១៨១៨

២៣ រឿងជេតពន ឧកញ៉ាសោទសខែម សរសេរឆ្នាំ១៨១៥

២៤ រឿងមុជលិន បណ្ឌិតសំអាត សរសេរឆ្នាំ១៨៣៣

២៥ រឿងដាររឿង ឧកញ៉ាចក្រីកែវ សរសេរឆ្នាំ១៧២១

២៦ រឿងព្រះជិនវង្ស អរិយគាមុនីកឹង សរសេរឆ្នាំ១៨៥២

២៧ រឿងពេជតា ធម្មបញ្ញា ម៉ែន សរសេរឆ្នាំ១៨៥៧

២៨ រឿងវិមានចន្ទ ឧកញ៉ាធិបតីយ៉ែមសរសេរឆ្នាំ១៨៥៨

២៩ ល្បើកស្រីវិជ័យ ពញាវិជិត្រ ស្រី សរសេរឆ្នាំ១៨៥៨

៣០ រឿងទេវន្ទ ឧកញ៉ាសន្ធរម៉ុក សរសេរឆ្នាំ១៨៥៩

៣១ រឿងទុំទាវ (ដំបូងសន្ធរម៉ុក ទាវឯក)ក្រោយមកត្រូវបាន រៀបរៀងជាថ្មី ឡើងវិញដោយព្រះបទុមថេរសោមដោយព្រះសសេរឆ្នាំ ១៩១៥

## ១ ប្រភេទអត្ថបទសរសេរជាពាក្យរាយ

១ សិលាចារឹកអង្គរវត្ត មិនមានឈ្មោះសរសេរសតវត្សទី១៦

២ ព្រះរាជក្រឹត្យក្រមផ្សេងៗ សរសេរក្នុងរាជព្រះបាទជ័យជេដ្ឋាទី២
សរសេរសតវត្សទី១៦
៣ មហាវេស្សន្តរជាតក កែសម្រួលបោះពុម្ពដោយលោកញ៉ុក ថែម

តាមការអះអាងរបស់លោក **លី ធាមតេង**នៅក្នុងសៀវភៅអក្សរសាស្ត្រខ្មែរ បោះពុម្ពនៅបណ្ណាគារ **សេង ង៉ួនហួត** បានសរសេរថា នៅមានអ្នកនិពន្ធជាច្រើនទៀតដែលមិនមានចារឹកឈ្មោះ និងពេលវេលានៃការសរសេរ ស្នាដៃ តែគេរង្វាយតម្លៃថា ស្នាដៃទាំងនេះក៏ស្ថិតនៅក្នុងសម័យកាលជាមួយគ្នានេះដែរ ព្រោះមានលំនាំនៃការប្រើ ពាក្យពេចន៍ និងរបៀបតាក់តែងកំណាព្យកាព្យឃ្លោង ស្រដៀងគ្នានិងស្នាដៃទាំងឡាយដែលបានរៀបរាប់ខាងលើដែរ ចំណែកឯផ្ទៃរឿងទៀតសោតក៏ប្រហាក់ប្រហែលគ្នាដែរៗ

នៅតាមបណ្ដារឿងទាំងនោះ មានដូចជារឿងលិនថោង រឿងសុវណ្ណវង្ស រឿងសុវណ្ណផល្លា រឿងកិនវង្ស រឿងហង្សយន្ត រឿងសុវណ្ណក្ដាមស រឿងព្រះសង្ខ័ាត រឿងព្រះចិន្ដកុមារ រឿងស្ដេចក្មេង រឿងព្រះបាទកងកប រឿង ព្រះបាទវិនា រឿងព្រះបាទនារ៉ៃ រឿងមគ្គផល រឿងទឹកពាំផ្កាពាំ រឿងកូងម៉ាល័យ រឿងព្រះសុភោគជាដើមៗ ក្រៅពីរឿងទាំងអស់នេះ នៅមានរឿងខ្លីៗជាច្រើនទៀតដែលបុរាណហៅថាល្បើក តែសាច់រឿងមិនសូវជាពីរោះពិសាប៉ុន្មានទេ ទំនងជាអត្ថបទទាំងនេះអ្នកនិពន្ធសរសេរក្នុងការសាកល្បងនៅឡើយៗ បានជាហ៊ានអះ អាងដូច្នេះព្រោះ គេសម្គាល់ទៅលើផ្ទៃរឿងដែលមានទំហំខ្លី សាច់រឿងក៏មិនសូវច្បាស់លាស់ តែពោរពេញទៅដោយខ្លឹមសារប្រសើរណាស់ៗ

សរុបជារួមមក យើងអាចសន្និដ្ឋានបានថា រឿងទាំងអម្បាល

មាណដូចបានរៀបរាប់មកខាងលើ ប្រហែលជាកើតនៅក្នុងសម័យតែមួយ ព្រោះបើតាមការសង្កេតឃើញថា សាច់រឿងមានលំនាំប្រហាក់ប្រហែល គ្មានមិនឃ្លាតឆ្ងាយពីគ្នាប៉ុន្មានទេ ទាំងឈ្មោះតួអង្គ ទាំងគំនិតជឿនលឿន ទាំងការអប់រំរបស់អ្នកនិពន្ធគឺសុទ្ធតែ មានលក្ខណៈប្រហាក់ប្រហែលគ្នា។

**ឧទាហរណ៍** សាច់រឿងតែងមានយក្សដ៏កំណាចកាចសាហាវ ហើយតួអង្គនេះបានមកផ្គួនមនុស្សដែល ជាតួអង្គល្អ យុត្តិធម៌ជានិច្ច។ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺ តួអង្គល្អនេះតែងទទួលរងនូវអំពើឃោរឃៅពីតួអង្គ យក្សជានិច្ច ប៉ុន្តែកម្មផលរបស់ពួកយក្សមិនឋិតថេរឡើយ ព្រោះនៅក្នុងទ្រឹស្តីព្រះពុទ្ធសាសនា បានដាក់ទោសទៅលើពួកជនទុច្ចរិតដោយប្រការផ្សេងៗសមនិងច្បាប់ធម្មជាតិ ដែលតម្រូវឲ្យអ្នកប្រព្រឹត្តអំពើល្អត្រូវចេះរក្សាសេចក្តីសុខ ជួយគ្នានៅគ្រាមានអាសន្នទើបទទួលបាននូវសុភមង្គលពិតប្រាកដ។

ទោះបីជាការសរសេរ ពោរពេញទៅដោយការអប់រំយ៉ាងនេះក្តី ក៏អ្នកសិក្សានៅតែសង្កេតឃើញថា ការតាក់តែងរឿងអ្នកនិពន្ធប្រើសិល្បវិធីមិនទាន់បានសមរម្យនៅឡើយ ព្រោះបើពិនិត្យនៅលើអក្ខរាវិរុទ្ធគឺមានពាក្យស្ទួនគ្នាច្រើន សាច់រឿងមានលក្ខណៈច្រំដែលអូសបន្លាយឆ្ងាយឥតប្រយោជន៍។ ចំពោះសំពៅទវិធីនៅក្នុងសាច់រឿងវិញក៏ច្រើនតែច្របូកច្របល់គ្នា ស្តាប់ឬអានពិបាកយល់ ហើយតួអង្គប្រើតែពាក្យបាលី-សំស្រ្កឹតពិបាកយល់ សេចក្តីណាស់។ បញ្ហានេះហើយនាំឲ្យ អ្នកអានពិបាកយល់សេចក្តីដែលមាននៅក្នុងអត្ថបទ គឺមានតែអ្នកដែល រៀនបានវិជ្ជាខ្ពង់ខ្ពស់ ទើបអាចងាយយល់ងាយស្តាប់បាន។ ខ្ញុំងាកទៅខាងដើមបន្តិច ទាក់ទងនិងការសរសេររបស់អ្នកនិពន្ធនៅក្នុងស្នាដៃនានា

ដែលនិយមតែការសរសេរជាភាសាបាលី បញ្ជាក់លក្ខណៈកម្មផលនៅក្នុងសាច់រឿងៗ បើតាមការអះអាងរបស់លោកលី ធាមតេង់នៅក្នុងសៀវភៅ អក្សរសាស្ត្រខ្មែរបានឲ្យដឹងថា ឫសគល់នៃរឿងទាំងអស់នេះគឺមានប្រភពមកពី គម្ពីរមួយឈ្មោះថា **បញ្ញាសជាតក** ដែលសរសេរឡើងជាភាសាបាលីសុទ្ធ ហើយអ្នកនិពន្ធខ្មែរបានយកលំនាំនៃការសរសេរទាំងនេះមកបញ្ចូលនៅក្នុងស្នាដៃរបស់ខ្លួនៗ ប្រភពខាងដើមបានបញ្ជាក់បន្តទៀតថា ប្រសិនណាគេសង្កេតគម្ពីរទាំងឡាយណាដែលសរសេរជាភាសាបាលីសុទ្ធដូច្នេះ គឺគេថាគម្ពីរនោះកើតពីសម័យពុទ្ធកាលមិនខានៗ **បញ្ញាសជាតក** មានន័យថាហាសិបរឿងនៃដំណើរជាតិព្រះពុទ្ធដែលនិយាយ ពីការត្រាស់ដឹងរបស់ព្រះអង្គ ពោលគឺការសន្សំបារមីៗតាមលោក**ឆ** ***សោ***សរសេរក្នុងសៀវភៅ***អក្សរសិល្ប៍ពុទ្ធិនិយម***បានបញ្ជាក់ថា រឿងទាំងនោះមានជាអាទិ៍៖

| | | | |
|---|---|---|---|
| ១ | រឿងសមុទ្ទឃោសៈ | ២ | រឿងសធនកុមារ |
| ៣ | រឿងសុត្តធនុ | ៤ | រឿងរតនប្បជោត |
| ៥ | រឿងសិរិវិបុលកិត្តិ | ៦ | រឿងវិបុលរាជ |
| ៧ | រឿងសិរិចូឡាមណី | ៨ | រឿងចន្ទរាជ |
| ៩ | រឿងសព្វមិត្ត | ១០ | រឿងសិរីធរសេដ្ឋី |
| ១១ | រឿងសព្វសិទ្ធ | ១២ | រឿងទុលកបណ្ឌិត |
| ១៣ | រឿងអាទិត្តរាជ | ១៤ | រឿងទុកមានិក |
| ១៥ | រឿងមហាសុរសេន | ១៦ | រឿងសុវណ្ណកុមារ |
| ១៧ | រឿងកនករាជ | ១៨ | រឿងវីរិយបណ្ឌិត |
| ១៩ | រឿងធម្មសោណ្ឌក | ២០ | រឿងសុទស្សនមហារាជ |
| ២១ | រឿងវត្តង្គុលីរាជ | ២២ | ហោពណកបិលបុរនរិន្ទ |

| | | | |
|---|---|---|---|
| ២៣ | ធម្មិកបណ្ឌិត | ២៤ | រឿងមហាបុរិស |
| ២៥ | រឿងធម្មរាជ | ២៦ | រឿងនរជីវ |
| ២៧ | រឿងសុរូប | ២៨ | រឿងមហាបទុមកុមារ |
| ២៩ | រឿងកណ្ហាគារកុមារ | ៣០ | រឿងពហុលគាវី |
| ៣១ | រឿងសេតបណ្ឌិត | ៣២ | រឿងបុប្ផរាជ |
| ៣៣ | រឿងពារាណសិរាជ | ៣៤ | រឿងព្រហ្មឃោសរាជ |
| ៣៥ | រឿងទេវរុក្ខកុមារ | ៣៦ | រឿងសលក |
| ៣៧ | រឿងសិទ្ធិសារ | ៣៨ | រឿងនរជីវ |
| ៣៩ | រឿងអតិទេវរាជ | ៤០ | រឿងសិម្ពនាទ |
| ៤១ | សុវណ្ណសង្ខរាជកុមារ | ៤២ | រឿងសុវត្ត |
| ៤៣ | រឿងទេវន្ទ | ៤៤ | រឿងសុវណ្ណកច្ឆប |
| ៤៥ | រឿងសុបិន្តកុមារ | ៤៦ | រឿងសុវណ្ណហង្ស |
| ៤៧ | រឿងសិទ្ធិសារ(វរនុជវរនេត្រ) | | |
| ៤៨ | រឿងសិរីសរាជកុមារ | ៤៩ | រឿងចន្ទឃាត |
| ៥០ | រឿងសទ្ធាតិស្សចក្កវត្តិ | | |

លោក**លី ធាមតេង** បានអះអាងនៅក្នុងសៀវភៅ **អក្សរសាស្ត្រខ្មែរ**ថា គម្ពីរបញ្ញាសជាតក គឺជាស្នាដៃ របស់អ្នកប្រាជ្ញនៅជ្រោយសុវណ្ណភូមិជាអ្នកបង្កើតឡើងពិតប្រាកដ ព្រោះគម្ពីរមួយនេះគេឃើញមានតែនៅក្នុងប្រទេសខ្មែរ ថៃយ៍ លាវ និងភូមាប៉ុណ្ណោះ ចំណែកនៅកោះលង្កាដែលជាមូលដ្ឋានព្រះពុទ្ធសាសនាដ៏ធំបំផុត គេពុំដែលប្រទះឃើញគម្ពីរបែបនេះទេ។ ដោយសម្អាងហេតុផលដូច្នេះហើយ ទើបបានជាលោកអះអាងបន្ថែមទៀតថា ស្នាដៃទាំងនេះពិតជាប្រសូតចេញពីអ្នកប្រាជ្ញខ្មែរ លាវ ថៃយ៍ជាមិនខាន គ្រាន់តែសាច់រឿងផ្តេកទៅតាម ទ្រឹស្តីព្រះពុទ្ធ

សាសនាជាមូលដ្ឋានប៉ុណ្ណោះ។ គេអាចនិយាយបន្ថែមទៀតថា អស់លោកអ្នកប្រាជ្ញទាំងនេះ ទំនង ជាតុបតែងអត្ថបទនេះឡើងនៅក្រោយសម័យពុទ្ធកាលជាយូរអង្វែង ដើម្បីទុកជាគ្រឿងណែនាំដល់សតិអារម្មណ៍ ពុទ្ធិបរិស័ទឲ្យប្រព្រឹត្តតាមផ្លូវល្អ គឺសម្មាទិដ្ឋិនៃគន្លងពុទ្ធោវាទ។

ជាបន្តទៅទៀត ខ្ញុំលើកយកស្នាដៃអ្នកនិពន្ធ និងប្រវត្តិអ្នកនិពន្ធមួយចំនួននៅក្នុងសម័យឧដុង្គ ដែលមានលក្ខណៈល្អសមរម្យ និងមានចារឹកឈ្មោះអ្នកនិពន្ធច្បាស់លាស់មកអធិប្បាយ។ ស្នាដៃជាដំបូងគឺលើកយកស្នាដៃណា ដែលមានអាយុចំណាស់ជាងគេនិងតាមលំដាប់លំដោយដូចតទៅ៖

## ១ ព្រះបាទស្រីធម្មរាជា

តាមឯកសាររបស់លោកលី ធាមតេង ក្នុងសៀវភៅអក្សរសាស្ត្រខ្មែរបានបញ្ជាក់ថា ព្រះបាទស្រីធម្មរាជា ឬព្រះរាជសម្ភារមានព្រះនាមដើម**ចៅពញាតូ** ជាព្រះរាជបុត្ររបស់ព្រះបាទជ័យជេដ្ឋាទីពីរ។

យោងតាមការបំភ្លឺរបស់លោក**លាង ហាប់អាន** នៅក្នុងសៀវភៅ**ព្រះរាជសម្ភារ អ្នកនិពន្ធខ្មែរ** បោះពុម្ព ដោយបណ្ណាគារសេង ង៉ួនហួត ដែលជាឯកសារបោះពុម្ពលើកទី៣ ឆ្នាំ១៩៦៦មានសេចក្ដីរៀបរាប់យ៉ាងពិស្ដារ អំពីខ្សែជីវិតរបស់ក្សត្រអង្គនេះដូចតទៅ៖

" ព្រះពុទ្ធសករាជ២១៧១ មហាសករាជ១៥៤៩ ចុល្លសករាជ៩៧៩ ឆ្នាំថោះនព្វស័ក គ្រិស្តសករាជ១៦២៧ ថ្ងៃ៥កើតខែកត្តិកម៉ោង៧ព្រឹក ជាថ្ងៃមានមង្គលឫក្សប្រពៃ ព្រះស្រីធម្មរាជាជាបុត្រច្បងនៃព្រះបាទជ័យ ជេដ្ឋា ព្រះជន្ម២៦ឆ្នាំ ស្ដេចឡើងរាជាភិសេកសោយរាជសម្បត្តិ តពី

សម្តេចព្រះសេតុច្ឆា សម្តេចព្រះបរមរាជា មហាឧបរាជ ព្រមទាំងព្រះរាជគ្រូបុរោហិតថ្វាយព្រះឧទកធារាបុប្ផាភិសេក។

ថ្ងៃក្រោយស្តេចចេញប្រទក្សិណព្រះនគរ៣ថ្ងៃ។ ទ្រង់បញ្ជាមុខក្រសួង ឲ្យទៅសាងព្រះរាជវាំងគង់នៅកោះឃ្លោក ទៀងញ៉ស្ពានជ្រោយចង្វាក្នុងខេត្តភ្នំពេញ (ក្រោយមកទីនេះជាខេត្តខ្សាច់កណ្តាលវិញ)។

ព្រះស្រីធម្មរាជា ទ្រង់មានបញ្ញាឆ្លៀវឆ្លាសចេះនូវព្រះត្រៃបិដកយ៉ាងជំនាញ ទាំងគតិធម៌ គតិលោក ទាំងព្រម។ ទ្រង់ជ្រាបស្ទាត់នូវការតែងបញ្ហាកាព្យឃ្លោងនិងបាលី។ ទ្រង់តែងច្បាប់ប្រាប់ប្រាមប្រដៅដូចជា

-ច្បាប់ហៃសាធុជន ឲ្យឈ្មោះថា ច្បាប់ត្រីនេត្រ

-ច្បាប់ក្រម (សម្រាប់ប្រដៅមនុស្សឲ្យប្រព្រឹត្តដោយយុត្តិធម៌)

ព្រះរាជា ទ្រង់សព្វព្រះទ័យយាងទៅក្រសាលសាកសួរបញ្ហាបាលីនិងព្រះសុគន្ធមានបុណ្យ (ងារជាព្រះសុគន្ធាធិបតីមហាសង្ឃរាជ)គង់ក្នុងអារាមមួយនៅក្រុងឧដុង្គមានជ័យ។

តាំងពីព្រះបាទសម្តេចព្រះស្រីធម្មរាជា ជាអម្ចាស់ទ្រង់សោយរាជសម្បត្តិមក ព្រះពុទ្ធសាសនាថ្កើងរុង រឿងឡើង។ បណ្តារាស្ត្របានសេចក្តីសុខក្សេមក្សាន្ត។លុះដល់ឆ្នាំមមី ទោស័ក ទ្រង់ប្រារព្ធនិងសេនាបតីមន្ត្រីទាំងពួងថា គួរលើកទ័ពទៅវាយស្រុកសៀម ពីព្រោះព្រះចៅក្រុងអយុធ្យា ពុំញញើតខ្មែរពីកាលសម្តេចព្រះវររាជបិតាគង់ ព្រះជន្មនៅ វាហ៊ានលើកព្យូហយាត្រាមកយុទ្ធនាការពីរដង។ ទ្រង់ព្រះរាជបញ្ជាឲ្យកេណ្ឌរាស្ត្រខេត្របាភ្នំ រំដួល ស្វាយទាប ទ្រាំង សំរោងទង បាទី ចំនួនបីម៉ឺននាក់ ដំរី៥០ សេះ២០០ ឲ្យកេណ្ឌរាស្ត្រខេត្រព្រះត្រពាំង ក្រមួន សទ្រាំងត្រើយត្បូងឃ្មុំ បន្ទាយមាស កំពត បញ្ចូលជាកងទ័ពដាក់គយល្បាតរក្សាបង្ការក្រែងសៀមលើកមកតាមជើងទឹក។

នៅថ្ងៃ១រោជ ខែមិគសិរ ឆ្នាំមមី ទោស័ក ទ្រង់ក៏ចាត់ឧកញ៉ាក្រឡាហោម សួស ឧកញ៉ាចក្រី ម៉ៅ និងឧកញ៉ា យោធាសង្រ្គាម ប៉ុល ឲ្យលើកទ័ពតាមផ្លូវជើងគោកតម្រង់ទៅស្រុកមហានគរវត្ត ហើយលើកហួសទៅវាយស្រុកនគររាជសីមា។ ទ័ពខ្មែរមានជ័យជម្នះ ចាប់បានសៀមឈ្លើយ ស្បៀងអាហារ សាស្ត្រាវុធ ដំរីសេះជាច្រើនក៏លើកទ័ពមកក្រុងកម្ពុជាវិញ។ ព្រះរាជាទ្រង់ខ្ញាល់នឹងមេទ័ពទាំងបីដែលលើកទ័ព ទៅវាយស្រុកសៀមឈ្នះ ហើយបង្ហួសទៅវាយដល់ទីក្រុងយកជ័យជម្នះទៀត។ទ្រង់ ឲ្យនាំសៀមឈ្លើយទាំងនោះទៅប្រគល់ឲ្យព្រះឥន្ទវិជ័យឲ្យនៅក្នុងខេត្តបរិបូណ៌ ចំណែកពួកចិនបានដឹងថា នគរកម្ពុជា ជាទីសុខសប្បាយបរិបូណ៌ ក៏ចុះសំពៅមកនៅរកទទួលទានកាន់តែច្រើនឡើងៗ។

ទ្រង់ព្រះមេត្តាប្រោសព្រះអង្គនន់ ជាព្រះរាជបុត្រច្បងនៃសម្តេចព្រះបរមរាជាមហាឧបរាជ ត្រូវជាព្រះអនុជព្រះអយ្យកោជាមួយនិងព្រះអង្គ ជាសម្តេចព្រះបទុមរាជា។

ទ្រង់ឲ្យរើសចិនបួននាក់តាំងជាមន្ត្រី ជានាយត្រួតពួកចិន មានដូចជា៖

- បុងតុក១
- ឡុកបុងអៀ១
- សាមចាន់ទៀវ១
- ចុងចិនតុក១

ក្រោយនោះ សម្តេចព្រះបរមរាជាមហាឧបរាជទ្រង់មានអាពាធជាទម្ងន់។ ព្រះរាជាទ្រង់យាងទៅរក្សាព្រះរោគសម្តេចព្រះបេតុច្ឆា នៅព្រះបរមរាជវាំងឧដុង្គ។ វេលានោះសម្តេចទ្រង់ត្រាស់បង្គាប់ព្រះម៉ែយួរវត្តីរាជទេពី ឲ្យរៀបគោជនាហារថ្វាយសម្តេចព្រះស្រីធម្មរាជាសោយរាល់

ថ្ងៃ។ ខណៈនោះព្រះស្រីធម្មរាជា ទ្រង់មានព្រះទ័យប្រតិព័ទ្ធនឹងព្រះម៉ែយួរវត្តី ជាព្រះរាជទេពីសម្តេចព្រះបិតុច្ឆា ត្រូវជាព្រះអនុជផ្សេងព្រះមាតា លបលាក់ប្រើ ទៅមកលុះទាល់តែសម្តេចព្រះមហាឧបរាជសះព្រះរោគ។

នៅខែចេត្រ ឆ្នាំមមី ត្រីស័ក សម្តេចព្រះមហាឧបយោរាជ ទ្រង់យាងទៅថ្វាយព្រះពុទ្ធបដិមានៅព្រះមហានគរវត្ត។ សម្តេចព្រះស្រីធម្មរាជាក៏ទូលថា តាមហែរទៅផង។ ព្រះបាទសម្តេចព្រះស្រីធម្មរាជា កាលស្តេចឡើងទតប្រាសាទ ទ្រង់ឃើញព្រះម៉ែយួរវត្តីរិតតែមានព្រះទ័យស្នេហាខ្លាំងឡើង ប្រើព្រះនេត្រគន្លាទៅវិញទៅមក រួចស្តេចយាងចុះមកមុនសម្តេចព្រះបិតុច្ឆា។ លុះព្រលប់ ស្តេចតែងព្រះអង្គក្លែងជាចិន ទ្រង់ឈរបន្ទំនិងពួកចិនលេងភ្លេង។ដល់ព្រលប់ ងងឹតនោះសម្តេចព្រះមហាឧបយោរាជ ទ្រង់យាងចុះមកអំពីប្រាសាទជាក្រោយ សម្តេចព្រះធម្មរាជា ទ្រង់លបចាប់ហត្ថព្រះម៉ែយួរវត្តី ដោយព្រះទ័យស្នេហា មត់សញ្ញាទៅវិញទៅមក។

ព្រះបាទសម្តេចព្រះស្រីធម្មរាជា ស្តេចយាងមកវិញទ្រង់ព្រះបរិវិត្តកនឹកដល់ព្រះម៉ែយួរវត្តី យ៉ាងខ្លាំងក្លៃចទាំងស្រង់ សោយ រួចទ្រង់តែងព្រះលិខិតជាសេចក្តីកាព្យ ស្តេចចាត់ឲ្យពួកស្រីចាស់ទុំនាំទៅថ្វាយ ព្រះម៉ែយួរវត្តី។

ព្រះម៉ែយួរវត្តីទតចប់ រិតមានព្រះទ័យស្នេហាយ៉ាងខ្លាំង ព្រោះព្រះវរាជបិតាទ្រង់បានផ្សំទុកតាំងពីកុមារមកម្ល៉េះ។

លុះដល់ខែជេស្ឋ ឆ្នាំមមែ ត្រីស័ក ព្រះម៉ែយួរវត្តី ក្រាបថ្វាយបង្គំទូលព្រះស្វាមីដោយឧបាយថា ទៅលេងបឹងផ្ទុំមួយយប់ ពីរយប់។ ទើប

ក្សត្រីទ្រង់នាំពួកស្រីចាស់ទុំដែលរួមគំនិតចុះគង់ព្រះទីនាំង នាវាចេញពីឧដុង្គ ឲ្យចែវហួសរហូតដល់ព្រះរាជកោះឃ្លោក ខែត្រខ្សាច់កណ្តាល ដែលសន្មត់ហៅថា កោះឧកញ៉ាតី។ សម្តេចព្រះស្រី ធម្មរាជាទ្រង់ជ្រាបស្តេចយាងចេញទទួលព្រះម៉ែយួរវត្តីដោយព្រះទ័យស្នេហា ទ្រង់ឃាត់ទុក៣យប់។ មន្ត្រីដែលមិនបានចូលគំនិត ក៏ត្រលប់មកក្រាបបង្គំទូលសម្តេចព្រះមហាឧបយោរាជ តាមរឿងគ្រប់ប្រការ។ ទ្រង់ក្រោធយ៉ាងខ្លាំង ទើបចាត់ទាហានបារាំង និងមន្ត្រីសម្រាប់ព្រះអង្គជាកងទ័ពទឹកមានពល៥០០ ទូកចម្បាំង៣០០ ឲ្យលើកទៅធ្វើសង្គ្រាមនិងសម្តេចព្រះកត្តនិយោ(ក្មួយ)។ ព្រះស្រីធម្មរាជា ក៏ទ្រង់ព្រះរាជបញ្ជានូវសេនាបតីមន្ត្រីសម្រាប់ឯក ឲ្យប្រមូលទាហានចិនសម្រាប់ព្រះអង្គមកជួបជុំ។ ទ័ពប្រទះគ្នានៅព្រែកព្នៅក៏បាញ់កាំភ្លើងទៅវិញទៅមក។ កងទ័ពខាងសម្តេចព្រះមហាឧបយោរាជមានកាំភ្លើងច្រើន បាញ់ទៅត្រូវពលសម្រាប់ឯកស្លាប់ច្រើន នាក់ណាស់។ ពួកទាហានចិនខ្មែរទ្រាំពុំបាន ក៏បាក់ថយចែវទូកទៅវិញ។ ខាងសម្តេចព្រះឧបយោរាជមានជ័យជម្នះ លើកដេញរឿងទៅដល់កោះឃ្លោក ឡើងគោកចំបក់ទ័ពរត់ខ្ចាត់ខ្ចាយ។ ព្រះស្រីធម្មរាជាទ្រង់គ្រឿងរាជសម្រាប់យុទ្ធនា នាំយោធារក្សាព្រះអង្គចេញទទួល ទ្រង់ចាត់មេទ័ពចិនទាំងបួននាក់ ចូលប្រុកាប់ប្រចាក់នឹងពួកបារាំងខ្មែរ។ មេទ័ពចិនក៏ត្រូវទាហានបារាំងបាញ់ស្លាប់ បាក់ទ័ពបរាជ័យ។ ព្រះរាជាឃើញថា សឹកលើសកម្លាំង ក៏នាំមន្ត្រីរត់ចេញចោលព្រះរាជវាំង។ ខាងសម្តេចព្រះឧបយោរាជដេញតាម។ ព្រះរាជាស្តេចបែកទ័ព រត់និងរាជគេរីដោះយកជីវិត ចុះគង់ព្រះទីនាំងនាវាឆ្លងទៅត្រើយខាងកើត។ ពួកបារាំងខ្មែរដេញតាមទៅដល់ខេត្តស្រីសឈរ ។ ទីនោះគ្មានព្រៃ។ ព្រះបាទសម្តេចព្រះស្រីធម្មរាជារត់ទៅតែមួយព្រះអង្គ។ លុះរាជសត្រូវដេញ

ទៅជិត ទ្រង់ព្រះតម្រិះថា មុខជារត់ពុំរួចនឹងគេ ស្តេចទតឃើញរបោះព្រៃត្នោតច្រើន ក៏ឡើងពួនបំបាំងព្រះអង្គនៅលើចុងត្នោត ទ្រង់យកព្រះស្នែងស្នៀត កាត់កំពូលត្នោតចារឹកជាពាក្យកាព្យ។ ទាហានបារាំងដើរមើលពុំសល់ដើមត្នោត បានឃើញស្តេចនៅលើចុងត្នោតហើយហៅគ្នាចោម លើកកាំភ្លើងឡើងនឹងធ្វើគត។ ទ្រង់ទតឃើញដូច្នេះ ស្តេចរាជព្រះហស្តមានព្រះតម្រាស់ដោយសូរសៀងយ៉ាងខ្លាំងថា៖

"ចាកាំងអប្បលក្ខណ៍ រាជេញចាញ់អ្នក ព្រះរាជសម្ភារឡើងលើចុងត្នោត ពុំកោតចេស្តា អ្នកលើកហត្ថា
រាកាំងឃាត់ខុក"។

ក្រោយការចារកាព្យឃ្លោងព្ធដ៏កំពូលចុងត្នោតចប់ ទ្រង់ទម្លាក់ចុះឲ្យពួកបារាំង ហើយមានព្រះរាជតម្រាស់ផ្តាំថា "បើអ្នកឯងរាល់គ្នាសម្លាប់អញហើយ អាណិតយកសេចក្តីនេះទៅក្រាបបង្គំទូលថ្វាយសម្តេចព្រះបិតុច្ឆាឲ្យអញផង"។

នៅថ្ងៃ៩រោចកើត ខែកត្តិកទ្រព្យ ឆ្នាំមមែ ត្រីស័ក វេលារសៀលត្រជាក់ ទាហានបារាំង ព័ទ្ធយគ្រួសបាញ់ទៅ ត្រូវព្រះអង្គក្សយព្រះជន្មធ្លាក់ពីលើចុងត្នោតមកដល់ដី។

ព្រះរាជសម្ភារទ្រង់គង់ក្នុងរាជសម្បត្តិបានប្រាំឆ្នាំ ព្រះជន្មបាន៣០ឆ្នាំស្តេចទីវង្គត ព្រះរាជបុត្រគ្នានៗមន្ត្រីខាងព្រះឧបយោរាជប្រជុំគង់ទ័ពអញ្ជើញព្រះសព ដាក់ក្នុងព្រះស្តានរួចដង្ហែត្រលប់មកព្រះរាជវាំងកោះឃ្លោក ចាប់ព្រះម៉ៃយួរវត្តីដាក់ក្តី រួចជញ្ជូនព្រះរាជទ្រព្យចុះទូកមកព្រះបរមរាជវាំងឧដុង្គមានជ័យ។ សម្តេចព្រះឧបយោរាជ ទ្រង់ទតឃើញមានបន្ទូលថា គួរស្តាយណាស់ដ្បិតរកក្សត្រឯណាមានបញ្ញាដូចគ្មាន តែទុកឲ្យនៅ នឹងខ្ទូចប្រវេណី ដ្បិតពុំតម្រង់ដោយទសពិធរាជធម៌ជាព្រះ

រាជក្រឹត្យរបស់ព្រះមហាក្សត្រ។ ទ្រង់ត្រាស់ឲ្យគេធ្វើគតព្រះម៉ែឃួរវត្តី តាមច្បាប់។

តាមឯកសារដែលចេញផ្សាយដោយអង្គការ **SIPAR** មានចំណងជើងថា **ខ្ញុំចង់ដឹង** បានសរសេរថា ព្រះរាជសម្ភារ ឬព្រះស្រីធម្មរាជាជាក្សត្រដែលមានចំណូលចិត្តស្រឡាញ់អក្សរសាស្ត្រ និងសិល្បៈណាស់។ ហេតុដូច្នេះហើយបានជាព្រះអង្គចាកចោលគូដណ្ដឹងនាមនាងចន្ទវត្តី(បុប្ផាវតី) ដើម្បីទៅបួសនៅឯអង្គរវត្ត។ បន្ទាប់ពី នោះមកនាងចន្ទវត្តីក៏ត្រូវរៀបការ ជាមួយព្រះឧទ័យដែលត្រូវជាម្ចាស់មារបស់ព្រះអង្គ។ ក្រោយពីចាកសិក្ខាបទ មកគ្រងរាជវិញ ព្រះអង្គក៏ចាប់មានចិត្តស្រឡាញ់គ្នាជាមួយនាងបុប្ផាវត្តីឡើងវិញ។ ដោយសេចក្ដីស្នេហាត្រូវបែកការ ព្រះឧទ័យខ្ញាល់ខ្លាំង ក៏លើកទ័ពចេញទៅតាម មានទាំងជនបរទេសទៅជាមួយដែរ។ ខណៈនោះព្រះរាជសម្ភារច្បាំងចាញ់ក៏គៀសខ្លួនជាមួយនាងចន្ទវត្តី។ គូស្នេហ៍ទាំងពីរក៏ត្រូវគេតាមទាន់។ ព្រះអង្គឡើងពួននៅលើចុងត្នោត រួចក៏ត្រូវគេធ្វើគត់ដោយប្រើកាំភ្លើងបាញ់ទម្លាក់ ឯក្សត្រីត្រូវគេចាប់យកទៅធ្វើទោស។

## អំពីស្នាដៃ

ស្នាដៃដែលមានឱជារសផ្នែកអក្សរសិល្ប៍ ហើយដែលយើងបានដឹងជាវណ្ណកម្មដ៏ពិសិដ្ឋរបស់ព្រះអង្គ គឺមានចំនួនច្រើនណាស់ដែរ ដែលគ្រប់ស្នាដៃ គឺសុទ្ធតែមានតម្លៃដ៏ពិសេសសម្រាប់ការសិក្សាស្រាវជ្រាវរបស់អ្នកសិក្សាអក្សរសិល្ប៍។ ស្នាដៃទាំងនោះរួមមាន៖

| | | |
|---|---|---|
| ១ | ច្បាប់ព្រះរាជសម្ភារ | សរសេរឆ្នាំ១៦២២ |
| ២ | ច្បាប់រាជនីតិ | សរសេរឆ្នាំ ? |

| | | |
|---|---|---|
| ៣ | លិខិតផ្ញើទៅថ្វាយព្រះម៉ែយូរវត្តី | សរសេរឆ្នាំ ? |
| ៤ | ពាក្យកាព្យចារឮដកំពូលចុងត្នោត | ព្រះរាជសម្ភារ ចារមុនពេលសុគត |
| ៥ | សរសើរហោមន្តមាស | សរសេរឆ្នាំ១៦២៩ |
| ៦ | កន្ទង់មាសមង្គលថ្ងៃ | សរសេរឆ្នាំ? |
| ៧ | ព្រលឹងមាសអើយ | សរសេរឆ្នាំ? |
| ៨ | ច្បាប់ក្រម | សរសេរឆ្នាំ? |
| ៩ | ច្បាប់ហៃសាធុជន ឬត្រីនេត្រ | សរសេរឆ្នាំ? |
| ១០ | ហិនលក្ខណ៍សល់ | សរសេរឆ្នាំ១៦៣០ |
| ១១ | កាព្យនិរាស | សរសេរឆ្នាំ១៦៦០ |

ជាបន្តទៅទៀត ខ្ញុំនឹងចម្លងយកស្នាព្រះហស្តរបស់កវីឯករូបនេះ មកធ្វើការបង្ហាញជូនដល់អ្នកសិក្សា ឲ្យបានជ្រាបជាសម្រង់ដូចតទៅ៖

## លិខិតផ្ញើទៅព្រះម៉ែយូរវត្តី

មិត្តមេស្នេហ៍ស្ងួន		គួរសាងនឹងបង់
កាលកអវិជ្ជា		តែងត្រេចរង្គាត់
ក្នុងវដ្តភពភា		ធ្លាស់ធ្លងប្រវាល
គម្ពីរជលស័យ ។

អន្ទោលតាមបង់		រួមសុខទុក្ខផង
ជាអចិន្ត្រៃយ៍		កាលកប្បខ័ន្តខាំង

កំបាំងឆ្ងាយក្រៃ　　　　លន្ងោចទោព្ធ
សង្សារកពចក្រ។
ជាតិនេះបងបាន　　　　ជួបកែវកល្យាណ
កាយកបនរលក្ខណ៍　　　　ស្មានថាអញបង
បានត្រង់រូមរ័ក្ស　　　　ប្រតិព័ទ្ធនឹងអ្នក
ប្រក្រតីលង់ទៅ។
ហេតុតែមានកម្ម　　　　ពីព្រេងនាយនាំ
ឲ្យបងនិងពៅ　　　　និរាសចាកបីរ
ជាពីរលំនៅ　　　　ពុំបានរ័ក្សពៅ
ដូចក្តីប្រាថ្នា។
សូមទានអម្រិ-　　　　ន្ទ្រិយ៍ទ្រង់ករុណា
សហស្សនេត្រនៃ　　　　នៅត្រៃចក្រវាឡ៍
ព្រះមកជួយជា　　　　ទិសទិព្វញាណ។
ទាំងទេពទិសទស　　　　ទូទាំងសោឡស
មហាព្រហ្មមាន　　　　ឫទ្ធីអំណាច
អង់អាចអភិញ្ញាណ　　　　សោតសឹងសោយឈាន
និរាសទុក្ខា។
សូមបងបានមូល　　　　មាសមិត្តបណ្តូល
បណ្តាច់ស្នេហា　　　　កុំឲ្យបងប្រាស់
និរាសច្នេះណា　　　　ប្អូនអើយបងផ្សា
ទ្រូងក្តៅសៅហ្មង ។
សូមសព្វៗជាតិ　　　　កុំឲ្យបងឃ្លាត
ពីប្អូនស្នេហ៍ស្នង　　　　ឲ្យបងបានជួប

នឹងស្ងួនន្ងួនល្អង　　　　កុំឲ្យបងរង
តែទុក្ខខ្លោចផ្សា។

អញខ្ញុំឧទ្ទិស　　　　សម្មាពុទ្ធស្ស
ជាម្កុដលោកា　　　　ជាតិជាប្រធាន
ទិព្វញ្ញាណថ្លៃថ្លា　　　　តែងជួយឲ្យប្រា-
កដកាលណិធាន។

សូមប្អូនបានជា　　　　បាទបរិចាគា
អរិយពោធិញ្ញាណ　　　　ស្រង់សត្វដាក់ដល់
ត្រើយថ្នល់និព្វាន　　　　លះលោកលែងឋាន
អបាយទុក្ខា។

ស្រណោះប្អូនស្ងួន　　　　ទើបមូលជាខ្លួន
ខ្ទឹមសង្សារសោច់　　　　រួមរស់មេត្រី
ឥតបីមានដាច់　　　　វិះរួតសម្រេច
សមរសស្នេហា ។

បងចាំនោះនៅ　　　　នាបងបានទៅ
ហោមន្តមាសា　　　　រហើយរហាត់
កាន់កត់រង៉ា　　　　ព្រះពាយវាតា
ពាសពី ឧត្តរ។

ប្អូនអើយបងធ្យាន　　　　យល់បុណ្យបុរាណ
ហើយទើបបងបរ-　　　　បូណ៌បទបងបាន
សេពសាន្តសាទរ　　　　នឹងព្រះប្អូនវ-
មិត្រមាសកល្យាណ។

ទោះគន់គិតទៅ　　　　នាបងបានចៅ
មិនគប្បីបាន　　　　ហេតុបុណ្យបារមី

ពិតពីបុរាណ ទើបប្អូនរួមឋាន
មូលមួយនិងបង។
យល់បុណ្យបងច្បាស់ បារមីក្រៃក្រាស់
បានប្អូនស្ងួនគ្រង លុះលើគំនិត
លើចិត្តបំណង មកមូលរួមរង
រាជរម្យស្នេហ៍ស្នាល។
ប្អូនអើយសុរិយ៍ សួស្តីសូមរស្មី
ធ្លុះភ្លឺកណ្តាល វេហាស៍ មណ្ឌល
សួស្តីដល់សម្ភារ ពិសេសពិសាល
ឯអាកាសនាយ ។
រីបងនិងពៅ រួមមេត្រីនៅ
មណ្ឌលទីអាយ ភ្លឺផ្ទេកធរណី
រស្មីព្រាងព្រាយ រួមរក្សាសាយ
កម្ពុជធានី ។
មួយព្រះឥន្ទ្រា មាននាងសុជាតា
ជាផ្តើមទេពី សោយរាជ្យរុង្វរុង
ចមចុងគិរី ជាឯកអគ្គត-
សួរសព្វទេវា។
ឥឡូវនួនល្អង កើតកាលនេះម្តង
ជាជេដ្ឋជាយា រួមគ្រងរាជ្យរម្យ
សួស្តីសមសោភា បរិបូណ៌រាមា
គឺរូបនារី។
ប្អូនជាតិជាថ្មើម សាច់ស្ងួតដង្ហើម

និងបងពិតពី បុព្វណានាយណា
ទើបគ្រានា ឥឡូវលុះប្អូនស្រី
ដល់តូចចិន្តា។

ប្អូនអើយបងធ្យាន នាបងបានកាណ៌
បានស្និទ្ធស្នេហា មូលមិត្រមេត្រី
បេត្តីជាអា- ចិណ្ណចិត្តមមា
មមៃនឹងមាស។

ឱយើងលង់ឆ្ងាយ លុះដល់កាលនាយ
កំព្រាហៅប្រាស់ ចង់ឲ្យស្នេហ៍ស្និទ្ធ
ផ្ដេកផ្ដិតសេយ្យាសន៍ និងមេមិត្រមាស
អស់កាលនាយនោះ។

ឲ្យបងនិងសួន ប្អូននៅនៃបខ្ទួន
កុំឲ្យបងបោះ កុំឲ្យបងប្រាស់
ប្អូនមាសចេញស្មោះ ឲ្យរួមក្ដួចកោះ
មេត្រីអាល័យ។

បើបានដូចចិត្ត ចំណងគំនិត
មូលមួយហឫទ័យ ទាំងនេះហៅបុណ្យ
ពីមុនក្រាស់ ក្រៃ ទើបបានមូលមៃ
ត្រឹមត្រូវអភិភាស។

សំនួនដ៏ផ្អែមល្ហែមនៃលិខិតនេះ បានជំរុញឲ្យសេចក្ដីស្នេហាព្រមទាំងកម្រងអនុស្សាវរីយ៍ទាំងឡាយ កាលពីនៅកុមារភាព ពិសេសនោះគឺជាបណ្ដាំ របស់ព្រះម៉ែយួរវត្តីវិតតែពុះកញ្ជ្រោលថែមទៀត។

សំនួនទាំងនេះក៏  ហាក់ដូចជាដួចនូវកំហឹងទ្វេថែមទៀតចំពោះព្រះបិតុច្ឆាដែលបានរំលោភបំពានបណ្ដាំព្រះបិតា។

ខ្លឹមសារដ៏ធំធេងនៃអត្ថបទកំណាព្យសំបុត្រនេះ  ក៏ជាកម្លាំងចិត្តមួយជំរុញឲ្យព្រះម៉ែយួរវត្តី  ប្ដេជ្ញាតស៊ូ  លែងខ្លាចស្លាប់  ហើយបានរត់ចេញពីព្រះតំណាក់ ព្រះស្វាមីមករួមសុខរួមទុក្ខជាមួយអតីតសង្សារវិញ

## ពាក្យកាព្យចារឭដរកាំពូលត្នោតមុនពេលទ្រង់សុគត ដោយការចាញ់នៃជាហានចាក់ង

សាធុសម្ដាយ	កុំបីភយមាយ	នឹងក្ដីកាមាតែង
ឲ្យវង្វេង	ក្នុងវដ្ដសង្សារ	ស្លាប់ទៅកាលណា
បានសោយតែទុក្ខ ។

ហេតុតែក្សត្រី	នាំឲ្យអប្រីយ៍	ដូចត្រីក្នុងភក់
បើបុរសផង	ចង់ធ្លងនរក	កុំធ្វើរីរក់
ដូចអញច្នេះណា។

ពីព្រោះកាមេ	ឥឡូវទាល់តែ	ក្សិណក្ស័យមរណា
សូវស្លាប់ទៅគាប់	ឲ្យជាប់ធម្មា	សូមអស់ទេវា
ជួយជាទិព្វញ្ញាណ។

ទើបព្រះភូមិ-	ន្ទ្រាធិបតិន	ទ្រង់អធិដ្ឋាន
ពីនេះទៅមុខ	ខ្ញុំសូមឲ្យបាន	ជាព្រះពុទ្ធញ្ញាណ
នាំសត្វទាំងឡាយ។

ឲ្យអ្នកទាំងពួង	ជាទាហានហ្លួង	នាំយកទៅថ្វាយ
ព្រះបិតុច្ឆា	ទ្រង់ជ្រាបអធិប្បាយ	កុំទ្រង់ភយមាយ
នឹងក្ដីកាមេ។"

កំណាព្យបណ្តាំនេះ មានប្រយោជន៍យ៉ាងវិសេសវិសាល សម្រាប់លុបលាងនូវកំហុសរបស់ទ្រង់ដែល បានប្រព្រឹត្តខុសក្នុងផ្លូវកាម ល្មើសជាមួយម្ចាស់ពូ ។ ប្រសិនណា ជាគេពិភាគឲ្យស៊ីជម្រៅទៅទៀត នោះឃើញថា កំណាព្យនេះ ហាក់ដូចជាពាក្យទូន្មានប្រៀនប្រដៅ ចំពោះព្រះបាទឧទ័យជាព្រះតុច្ឆា ដែលព្រះអង្គបានប្រព្រឹត្តល្មើសបណ្តាំ ព្រះបិតាទ្រង់ គឺព្រះបាទជ័យជេដ្ឋាដែលព្រះអង្គបានផ្សំផ្គុំព្រះរាជសម្ភារ ជាមួយព្រះម៉ែយូរវត្តី តាំងពីព្រះអង្គនៅជារាជកុមារម្ល៉េះៗ ចំពោះអ្នក សិក្សាជាជនានុជនជំនាន់ក្រោយ កំណាព្យនេះជាបណ្តាំប្រកបដោយ ពាក្យទូន្មានប្រៀនប្រដៅដ៏លើសលប់ ដែលអត្ថន័យបញ្ជាក់ពីទោសនៃ កាមតណ្ហា និងការបំពានធម៌ ដែលអំពើនេះ ត្រូវបានចាត់ទុកជាបាប កម្មមួយគួរឲ្យខ្លាចៗ អត្ថន័យនៃកំណាព្យដ៏ពិសិដ្ឋនេះ បញ្ជាក់យ៉ាង ច្បាស់ថា ព្រះរាជសម្ភារ ពិតជាគតិវិញ្ញូជនមួយរូប ព្រោះនៅគ្រាអវសាន្ត ទ្រង់បានដឹងនូវកំហុសធ្ងន់យ៉ាងធំ ដែលកំហុស នេះព្រះអង្គបានយល់ យល់ថា ជាកំហុសមួយមិនអាចអធ្យាស្រ័យបាន ទើបបានជាទ្រង់ហ៊ាន សម្តែងនូវកំហុស ទាំងអស់នេះចំពោះសាធារណជនទូទៅដោយមិន លាក់លៀម ហើយទ្រង់ស៊ូស្លាប់ឲ្យបាត់ពីលោកីយ៍នេះជាមួយ អំពើលា មករបស់ព្រះអង្គៗ

ទន្ទឹមនឹងការធ្វើឃាតព្រះអង្គ ឯកសារបានបញ្ជាក់ថា ព្រះរាជ សម្ភារត្រូវទាហ៊ានបរទេសបាញ់សម្លាប់ ខណៈដែលព្រះអង្គចារកំណា- ព្យ ចប់ៗ ការស្លាប់បែបនេះបានគួសបញ្ជាក់ពីកំហុសរបស់ព្រះឧទ័យ ដែលជាស្តេចមា មានឈាមជ័រជាខ្មែរតែបែរជាប្រើទាហ៊ានបរទេសមក

សម្ងាប់ជនជាតិដូចគ្នាដោយឥតមានការខ្មាស់សតិសម្បជញ្ញៈបន្តិចបន្តួចសោះ។

## ២ ឧកញ៉ាកោសាធិបតី កៅ

ឧកញ៉ាកោសាធិបតី កៅ លោកគឺជាកវីដ៏ចំណានមួយគ្មានអ្នកប្រៀបដែលស្ថិតក្នុងរជ្ជកាលព្រះបាទអង្គ**ច័ន្ទ** ។ លោកមិនត្រឹមតែជាអ្នកប្រាជ្ញដែលបានរៀនសូត្រចេះដឹង ជ្រៅជ្រះខាងផ្នែកអក្សរសាស្ត្រជាតិទេ លោកថែមទាំងបានរៀនចេះចាំស្ទាត់ គ្រាន់បើខាងភាសាបាលីទៀតផង ។ ផ្នែកកិច្ចការរាជការលោកក៏ជាអ្នក ដែលមានការចេះដឹងជ្រៅជ្រះដែរ ហេតុដូច្នេះហើយបានជាព្រះនរបតី ទ្រង់ប្រោសព្រះរាជទានឲ្យលោកកាន់តំណែងជា ចៅហ្វាយឃ្លាំងមនីរត្នន៍នៅក្នុងព្រះបរមរាជវាំង និងក្រោយមកលោកបានក្លាយជាទីប្រឹក្សារបស់ព្រះអង្គខាង ច្បាប់ទៀតផង។

នៅក្នុងស្នាដៃអក្សរសិល្បវិញ លោកបាសររសេររឿងតែមួយគត់ ដែលរឿងនេះលោកបានដកស្រង់ចេញពីរឿងបញ្ញាសជាតក ត្រង់ជាតកទី៩ជាភាសាបាលី តែវណ្ណកម្មថ្មីនេះលោកបានជាអត្ថបទប្រភេទកំណាព្យកាព្យឃ្លោង ប្រកបដោយចំណាប់ចូនយ៉ាងល្អងល្អាយ។ អត្ថបទជាស្នាដៃរបស់លោកមានចំណងជើងថា "**រឿងក្រុងសុភមិត្រ**" ដែលមានសេចក្តីជាសង្ខេបថា៖

ព្រះរាជាមួយព្រះអង្គមានព្រះនាមថា ក្រុងសុភមិត្រមាន ព្រះអគ្គមហេសីព្រះនាមនាងកេសនី ព្រមទាំងបុត្រពីរព្រះអង្គគ្រងរាជសម្បត្តិនៅនគរពោរាណសី។ មានថ្ងៃមួយនោះ ព្រះអនុជរបស់ព្រះអង្គមានព្រះនាមថា អសុភមិត្រ បានប៉ងប្រាថ្នានិងធ្វើឃាតព្រះអង្គដើម្បីដ

ណ្ដើមយកព្រះរាជសម្បត្តិ។ ដំណឹងនេះបានជ្រាបទៅដល់ ព្រះបាទក្រុងសុកមិត្រភ្លាមៗ ខណៈដែលព្រះអង្គទទួលដំណឹងនេះភ្លាម ព្រះអង្គក៏មិនមានការប្រទូសរ៉ាយជាមួយអនុជដែរ ព្រះអង្គសុខចិត្តនាំព្រះមហេសីនិងបុត្រទាំងពីរព្រះអង្គភៀសខ្លួនចេញពីព្រះនិវេសន៍ ទុកឱកាសឲ្យព្រះអនុជយករាជសម្បត្តិដោយស្រួល។ ព្រះអង្គធ្វើយ៉ាងនេះក៏ព្រោះតែព្រះអង្គមានព្រះទ័យ អាណិតស្រឡាញ់ប្រជារាស្ត្ររបស់ព្រះអង្គ មិនចង់ឲ្យស្រុកទេសជួបប្រទះចម្បាំងរាំងជល់ដែលជាហេតុនាំឲ្យព្រះនគរមិនមានសេចក្ដីសុខចម្រើន។

ព្រះបាទក្រុងសុកមិត្រ ទ្រង់យាងកាត់ព្រៃភ្នំក្រំថ្មមិនមានអាហារសម្រាប់សោយទេ គឺព្រះអង្គសោយតែ ផ្លែឈើដែលដុះនៅក្នុងព្រៃតែប៉ុណ្ណោះ។ លុះយាងកាត់ព្រៃភ្នំអស់ជាច្រើនថ្ងៃមក ព្រះអង្គក៏បានមកដល់ស្ទឹង យ៉ាងធំមួយ ព្រះអង្គក៏មានបំណងឆ្លងស្ទឹងនោះទៅទៀតតែមិនមានទូកសម្រាប់ចម្លងទេ ទើបព្រះអង្គសម្រេចព្រះទ័យថានឹងហែលទៅឲ្យដល់ត្រើយម្ខាង។ ពេលនោះព្រះអង្គក៏ទុកព្រះរាជបុត្រទាំងពីរឲ្យនៅចាំឯត្រើយម្ខាង ចំណែកព្រះអង្គក៏បានពរ មហេសីរួចខំហែលទៅដល់ត្រើយម្ខាង។ ថ្ងៃងពីរាជបុត្រទាំងពីរព្រះអង្គដែលនៅចាំព្រះបិតានៅឯច្រាំងនាយវិញ កាលបើព្រះក្រុងសុកមិត្រហែលចេញផុតទៅ គាប់ជួនជាពេលនោះ ក៏មានព្រានប្រម៉ង់ ប្ដីប្រពន្ធបានចែវទូកមកដល់។ កាលបើបានឃើញរាជកុមារពីរ នាក់បងប្អូននៅត្រមែងត្រមោចយ៉ាងនេះគាត់ក៏លើកដាក់នៅលើទូករួចក៏ចែវចេញទៅ។

ចំណែកឯព្រះរាជា ខណៈដែលព្រះអង្គបានហែលនាំមហេសីមកដល់ត្រើយម្ខាងហើយ ព្រះអង្គក៏បាន ដាក់មហេសីឲ្យនៅក្រោមដើមឈើមួយដើមធំ។ បន្ទាប់ពីផ្ដែផ្ដាំនាងឲ្យនៅចាំទ្រង់កុំយាងចេញទៅណា

ផ្តេសផ្តាស់រួចមក ព្រះអង្គក៏បានហែលត្រលប់មករកពជបុត្រទាំងពីររបស់ព្រះអង្គវិញ។

គ្រាដែលព្រះអង្គហែលចេញផុត បានបន្តិចក៏ស្រាប់តែមានសំពៅជំនួញមួយបានបើកក្តោងមកដល់។ នាយកេត្រាសម្ញឹងឃើញនាងជាមហេសីព្រះបាទក្រុងសុកមិត្រនៅតែម្នាក់ឯងដូច្នេះ ក៏បបួលគ្នីគ្នាចាប់នាងយកទៅជាមួយក្នុងគ្រានោះទៅ។ព្រះបាទក្រុងសុកមិត្រ ខំត្រដរហែលមករកបុត្រដល់ត្រើយហើយ ក៏រកមើលបុត្រពុំឃើញ ទើបបានជាព្រះអង្គខំស្រែកដង្ហោយហៅពេញព្រៃព្រឹក្សា។ លុះអស់សង្ឃឹមថា នឹងរកបុត្រឲ្យឃើញពុំបាន ទើបព្រះអង្គខំហែលត្រលប់មករកមហេសីវិញ។

គ្រាដែលព្រះអង្គ មកដល់ក្រោមដើមឈើដែលបានដាក់មហេសីឲ្យចាំទ្រង់ ក៏ស្រាប់តែពេលនេះមិនមានព្រះនាងឡើយ។ ក្នុងគ្រានោះ ព្រះអង្គមានវិតក្កយ៉ាងក្រៃលែង។ បន្ទាប់ពីនោះមក ព្រះអង្គក៏សម្រេចព្រះទ័យ យាងតែមួយព្រះអង្គឯងកាត់ព្រៃគ្រោកព្រៃត្រាញ់រហូតដល់ទ្វានគរមួយឈ្មោះថា នគរតេកសីលា។ នៅនគរដែល ព្រះបាទក្រុងសុកមិត្រយាងទៅដល់នោះឥតមានព្រះមហាក្សត្រទេ គាប់ជួនជាពេលនោះ សេវកាមាត្រទាំងឡាយកំពុងតែរៀបក្បួនគជេន្ទ្រផ្សងរកអ្នកមានបុណ្យមកសោយរាជ្យសម្បត្តិ។ ក្បួនគជេន្ទ្រក៏បានទៅយាងព្រះបាទក្រុងសុកមិត្រឲ្យមកគ្រងរាជសម្បត្តិនៅតក្កសីលា។

ព្រះបាទក្រុងសុកមិត្រ មកគ្រងរាជសម្បត្តិនៅនគរនេះ ប្រជារាស្ត្របានតែសេចក្តីសុខឥតមានជំងឺតម្កាត់ អ្វីមកបៀតបៀនទេ។ គាប់ជួនជាមានថ្ងៃមួយនោះនាយព្រានប្រម៉ង់ បាននាំកុមារពីររូបទៅថ្វាយព្រះអង្គធ្វើជា មហាតលិក តែទ្រង់ពុំស្គាល់ថា កុមារពីររូបនោះជារាជបុត្ររបស់ព្រះអង្គនៅឡើយ។ នៅសម័យថ្ងៃមួយ នាយកេត្រាសំពៅ ក៏

បាននាំបណ្ណាការមកថ្វាយព្រះរាជាព្រះបាទក្រុងសុកមិត្រ ទើបកាលនោះព្រះអង្គទ្រង់ឃាត់ ឲ្យនាយសំពៅនៅសំណេះសំណាលគ្នាលេងសិន។ ព្រះអង្គបានចាត់ឲ្យមហាតលិកក្មេងៗទាំងពីរទៅចាំសំពៅជំនួស។ ក្នុងពេលដែលបានចាំសំពៅនាយកេត្រា កំឡោះទាំងពីរនាក់បានសួរដេញដោលគ្នារកដើមដានអំពីរឿងមាតាបិតាខ្លួន ស្រាប់តែគ្រានោះនាងកេសនីដែលបានពួនក្នុងបន្ទប់ក្បែរនោះ ឮសួរសំឡេងក៏បានចេញមកឱបកូនសោយសោក នាំឲ្យពួកសំពៅផ្អើលឆោឡោ នឹងបានចាប់អ្នកកម្ទោះទាំងពីរនាក់យកទៅថ្វាយព្រះមហាក្សត្រ សុំឲ្យព្រះអង្គជួយវិនិច្ឆ័យ ទោសអំពើល្មើសក្មេងនេះព្រោះតែគេចោទថា កំឡោះទាំងពីរនេះបានលបចាប់នាងកេសនី។

ខណៈដែលមានការជំនុំវិនិច្ឆ័យ ព្រះបាទក្រុងសុកមិត្រទ្រង់មានទសពិធរាជធម៌ ទ្រង់បានសួរនាំទៅមហាតលិកទាំងពីរទើប អ្នកទាំងពីរបាននិទានពីដំណើររឿងតាំងពីរដើមដល់ចប់។ ព្រះរាជាទ្រង់ជ្រាបថានេះពិតជារាជបុត្រព្រះអង្គ និងជាមហេសីព្រះអង្គពិតប្រាកដដែលបានបែកគ្នាជាយូរណាស់មកហើយ។ ព្រះអង្គ មានសេចក្ដីសប្បាយរីករាយឥតឧបមា ដែលបានជួបជុំគ្រួសារវិញក្នុងគ្រានោះ និងបានគ្រង់រាជ្យសម្បត្តិបានជាសុខសាន្តរហូតតទៅ។

តាមរយៈអត្ថបទខាងលើ ឃើញថាលោកឧកញ៉ាកោសាធិបតីកៅ លោកខិតខំប្រិតប្រៀនពាក្យពេចន៍ឲ្យ បានល្អសមរម្យឥតខ្ចោះពិសេសគឺពាក្យកាព្យដែលលោកបានរៀបចំសមស្ងួនហើយ មានរណ្ដាប់ចួនណែងណង និងមានន័យយ៉ាងពិសិដ្ឋទៀតផង។ កត្តាទាំងនេះ បានធ្វើឲ្យអ្នកសិក្សាគ្រប់មជ្ឈដ្ឋានមានការកោតសរសើរស្ងៃ របស់លោកជាខ្លាំង។ អ្វីដែលជាការចាប់អារម្មណ៍សម្រាប់អ្នកសិក្សាអក្សរសាស្ត្រ

ជាតិថែមទៀតនោះគឺ ស្នាដៃ របស់លោក គឺបានរៀបចំក្បួនកាព្យខ្មែរបុរាណយ៉ាងមានរបៀបទៀតផង។

នៅខាងក្រោមនេះ គឺជាសេចក្តីសម្រង់ដែលខ្ញុំលើកយកមកបង្ហាញមិត្តអ្នកអានពីសេចក្តីជាកំណាព្យកាព្យឃ្លោងដែលលោកកវីបានសរសេរឡើង។ កំណាព្យរឿងនេះ ត្រូវបានសរសេរជាកំណាព្យរួមមាន បទកាកគតិ បទព្រហ្មគីតិ បទកុជង្គលីលា និងបទពំនោល។ ដើម្បីឲ្យរិតតែច្បាស់លាស់បនថែមទៀត ខាងក្រោមនេះខ្ញុំដកស្រង់ជាអត្ថបទកាព្យមកបង្ហាញជូនមិត្តអ្នកអានដូចតទៅៈ

## រឿង ក្រុងសុទមិត្រ

### បទកាកគតិ

| | | |
|---|---|---|
| កាលនោះមហាក្សត្រ | បើកបន្ទូលថ្វាត់ | និងរាជអមច្ចា |
| ថាមហាឧបរាជ | អំណាចចេស្តា | នាំពលយោធា |
| | ចូលចោមបុរី ។ | |
| បើយើងតតាំង | កងទ័ពចេញច្បាំង | ឲ្យយល់ឫទ្ធី |
| ក្រែងកើតកង្វល់ | អម្ពល់សេចក្តី | អាសូរប្រេណី |
| | រាស្ត្ររដ្ឋទាំងឡាយ | ។ |
| នឹងកើតផ្សាក្តៅ | ព្រាត់ប្រាសកូនចៅ | ហិនហោចខ្ចាត់ខ្ចាយ |
| ស្លុតស្លាប់សូន្យសោះ | ហេតុនោះអញណាយ | មិនឲ្យអន្តរាយ |
| | ជនជាតិឡើយហោង | ។ |
| បើអនុជគាត់ | ចង់យកសម្បត្តិ | ឥស្សរគ្រប់គ្រង |
| អញនឹងចៀសចាក | លះលែងចេញផ្គង | ទៅនៅដោយដង |
| | ព្រៃព្រឹក្សហេមពាន្ត | ។ |

ស្តេចបន្ទូលទៀត ប្រែព្រះភក្ត្រផ្ទៀត កាន់នាងកល្យាណ
ឯកអគ្គមហេសី ក្សត្រីប្រធាន សំណេះស៊ិងស៊ាន
ប្រាយប្រាប់ជាយា ។
ប្អូនអើយឥឡូវ មានរាជសត្រូវ មោះមកប្រាថ្នា
ដណ្តើមសម្បត្តិ រម្យរដ្ឋសីមា ចូលចោមហើយណា
ពន្ទឹកក្រាស់ក្រៃ ។
គឺព្រះអនុជា លោកលន់មោហា ចិត្តចោរកាចក្រៃ
ទ្រុស្តក្បត់យករាជ្យ ពុំខ្លាចឡើយនៃ តាំងទ័ពទីទៃ
យុទ្ធយករដ្ឋ ។...

## បទកុជង្គលីលា

មើលផ្កាបុប្ផាស្រស់ស្រេច បូបុស្សរំលេច រីករុះសាយសព្វ។
ចម្ប៉ាក្តាំងឆាឈ្មុយឈ្ងប់ ដោរដូចអ្នកអប់ ទាំងព្រៃព្រឹក្សា។
កាកែសចេកទេសយុថ្កា ម្លិះរួតម្លិះលា ខ្សឹងខ្សុំស្វាកី។
មហាហិង្គុប្រយង្គុនួនស្រី ស្រឡិតមាលតី លាយលេចប្បាប្រាល។
លន្តែពុតឆ្វេរន្ធាល រំដេកដាសដាល ដុះដោយទីទួល។
ព្រឹក្សាបុប្ផាជង្គួរ ហាក់ដូចអ្នកព្យួរ សំយុងយោនយាន។
កន្ទួងត្រាច់ត្រង់សព្វស៊ាន សៀងស្វាយរូហាន ក្លែងតូច្បតន្ត្រី។
ត្រាច់ត្រើបជញ្ជក់ភ្ញិនភ្ញី កេសររីកថ្មី ពិដោរសព្វសាយ។...

## បទព្រហ្មគីតិ

ស្តេចវរជយា រាជធីតាអគ្គមហេសី
ប្អូនអើយបងនឹងលី- លាទៅឋានបុត្រទ្វេហារ ។

ចូរចៅទៅប្រយ័ត្ន ក្រោយគ្រែងសត្វាហិង្សា
ប្អូនចាំនៅនេះណា នេត្ររំពៃសព្វទិសទី ។
បងនឹងលាទៅផ្គង ទៅចម្ងងបុត្រទាំងទ្វី
ឲ្យជួបជួនទាំងបី ស្រេចហើយបងនឹងរុកពន ។
ចរចេញពីនេះទៅ កាត់សម្ដៅព្រៃហិមពាន្ត
នាងនៅឲ្យសុខសាន្ត សោះអំពល់សេចក្ដីគិត ។
សន្សំសាងសីលា ពឹងព្រឹក្សាឲ្យស្នេហ៍ស្និទ្ធ
ដរាបអស់ជីវិត ឲ្យរៀងរួចពៀរវេរា ។
ស្ដេចផ្ដាំហើយផ្ដាំទៀត ទ្រង់ចង្អៀតឈឺខ្លោចផ្សា
ស្រយុតអស់អង្គា គិតព្រះប្អូនពន់ពេកសល់ ។...

## បទពំនោល

ទើបស្ដេចវិលវិងទៅវិញ ស្ថានដែនពោធិ៍ ទុកព្រះរាជបុត្រនោះណា។
ក្រោមដើមទម្លាប់ព្រឹក្សា ផ្ដេករាជបុត្រា មើលមានស្នាមជើងជាក់ជាន់។
ស្ដេចទ្រង់ចិន្ដាគ្នេរគ្នាន់ ទើបក្សត្រសោកណ៍ ឈ្ងែងយល់ដោយព្រះប្រាជ្ញា។
ដឹងដើមមានមនុស្សយាត្រា ត្រាច់ព្រៃព្រឹក្សា មកឃើញបុត្រទាំងពីរពង្ស។
វើសយកនាំទៅពុំលង់ ឡើយលុះព្រះអង្គ ជ្រាបជាក់អស់អាថ៌សេចក្ដី។
កាលនោះព្រះពង្សពោធិ៍ វិងសោយសោកពី លាបលន់ពន្ទឹកថ្លែងថា។

## បទព្រហ្មគីតិ

កាលនោះក្សត្របួនប្រាណ ជួបប្រមស្ថានក្នុងសំពៅ
សឹងសោយសោកសុបសៅ អួលអាណិតអានាថា ។
ថាឱបុណ្យមិត្រមាស កាលយើងប្រាសព្រាត់ពីគ្នា

អំឡុងយូរម្ល៉េះណា ទើបថ្ងៃនេះបានជួបចៅ ។
បងស្មានថាប្អូនស្រី ក្ស័យជីវីសោះសូន្យសៅ
កណ្ដាលអរញ្ញត្រជៅ ឃើញតែសត្វម្រឹគពាលា ។
ម្ដេចមេមាសព្រលឹង នាងនៅនិងនាយកេត្រា
ត្រាច់ត្រង់ដោយចក្រវាឡ៍ ចេញជួញចូលជួបដល់អាយ។
នាងនាថទៀងទូញទូល ដោយទំនួលបទនិយាយ
ពីព្រាត់ក្សត្រពណ្ណរាយ នៅទៀបធ្នេរសាគរ ។
កាលស្ដេចហែលជញ្ជូន ទៅយកកូនទាំងទ្វេហារ
ក្រោយនោះអ្នកកេត្រា បើកសំពៅទៅបុរី ។...

ការបង្ហាញតាមរយៈអត្ថបទសម្រង់ខាងលើ បានបញ្ជាក់ថា លោកឧកញ៉ាកោសាធិបតីកៅ បានសរសេរអត្ថបទរឿងរបស់លោកជាកំណាព្យកាព្យឃ្លោងប្រកបដោយការ ចូនរណ្ដំណែងណង លង់លង្វាយពីរោះគួរជាទីទាក់ចិត្តផ្ដិតជាប់ អារម្មណ៍ពីសំណាក់អ្នកអានគ្រប់ស្រទាប់ជាន់ថ្នាក់។ នៅក្នុងអត្ថបទសម្រង់ខាងលើ លោកបានបង្ហាញវគ្គមួយនៅក្នុងរឿង កាលដែលនាងកេសនីត្រូវបាននាយ កេត្រាសំពៅចាប់យកទៅ នាងត្រូវស្រែកយំ នឹកអាល័យដល់ព្រះបាទក្រុងសុកមិត្រជាស្វាមីនឹកអាល័យថា ពេលដែលព្រះអង្គវិលមកវិញ ប្រាកដជាស្រែករកនាងពេញព្រៃជាមិនខាន ខណៈមិនបានឃើញនាងនៅរង់ចាំទ្រង់កន្លែងដែលបានណាត់គ្នា។ ម្យ៉ាងវិញទៀត កូនតូចរបស់នាងប្រាកដជាពេលដែលវាឃ្លាន វានឹងយំទ្រហឹងរកបៅមិនខាន ព្រោះថាកូននៅតូចណាស់ប្រាកដជាមិនទម្លាប់បែកពីម្ដាយទេ។

## ២ ឧកញ៉ាព្រះឃ្លាំង នង

ចំពោះជីវប្រវត្តិរបស់លោក តាមសៀវភៅ**ប្រវត្តិអក្សរសាស្ត្រខ្មែរ** របស់លោក **លាងហាប់ អាន** បានសរសេរថា ចំពោះថ្ងៃខែ ឆ្នាំកំណើត ស្រុកកំណើត និងនាមមាតាបិតារបស់លោក គឺមិនមានការចុះកំណត់ឲ្យបានច្បាស់លាស់ទេ។ លោកបានបួសរៀនភាសាបាលី ព្រះត្រៃបិដក បានចេះដឹងជ្រៅជ្រះ ហើយបានប្រឡងភាសាបាលីនៅទីក្រុងបាំងកក ជាប់បានជាទីមហា។

លោកមានងារមួយទៀតគឺ ឧកញ៉ាសារពេជ្ញ នង គឺជាអ្នកប្រាជ្ញឯកមួយខាងវិស័យអក្សរសាស្ត្រជាតិក្នុងសម័យឧដុង្គ ព្រោះតែលោកបានរៀនសូត្រចេះចាំយ៉ាងស្ទាត់ភាសាបាលី រួមជាមួយភាសាសៀម។ កាលពីរាជព្រះបាទអង្គចន្ទ លោកទទួលងារជាឧកញ៉ាវង្សសារពេជ្ញ ដ្បិតតែលោកចេះចាំគម្ពីរព្រះត្រៃបិដក និងអក្សរសាស្ត្រជាតិយ៉ាងពិតប្រាកដ។ កាលពីសម័យនោះ លោកត្រូវបានព្រះរាជាទ្រង់ព្រះរាជទានតាំងលោកធ្វើជាគ្រូលើសំណាក់ព្រះសង្ឃ និងគ្រហស្ថទាំងឡាយនៅក្នុងព្រះនគរ។

ចំណេរក្រោយមក លោកបានក្លាយទៅជាចៅអធិការវត្តចតុទិស នៅក្រុងឧដុង្គ និងទទួលជាសាមណសក្តិជាទីមហាព្រហ្មមុនី និងបានទៅជាគ្រូព្រះរាជបុត្តព្រះបាទសម្តេចព្រះនារាយណ៍រាមាធិបតី មានបួនព្រះអង្គ គឺព្រះអង្គអេង ព្រះអង្គចន្ទ ព្រះអង្គម៉ី ព្រះអង្គឌួង ហើយក៏បានជាឧបជ្ឈាយ៍បំបួសព្រះអង្គឌួងជាសាមណៈ នៅឆ្នាំ ១៨១០ទៀតផង។

ស្ថិតក្នុងឆ្នាំរកា ចត្វាស័ក ព្រះឃ្លាំងនង បាន ដង្ហែរព្រះអង្គអឹមជាទីសម្តេចព្រះស្រីពិជ័យជេដ្ឋា មហាឧបរាជនិងព្រះអង្គឌួងយាងទៅទីក្រុងបាងកកប្រទេសសៀម។ លុះពេលត្រលប់ មកវិញ លោកបានលាចាក

សិក្ខាបទមករស់ជាមួយព្រះអង្គឌួងនៅស្រុកមង្គលបុរី ខេត្តបាត់ដំបង និងមានភរិយាទីមួយឈ្មោះនាង **មាស**។ មុនពេលដែលសោយរាជសម្បត្តិ ព្រះអង្គឌួង បានព្រះរាជទានអ្នកម្នាងម្នាក់ ឈ្មោះអ្នកម្នាង**តួច**ឲ្យបានទៅជាភរិយាម្នាក់ទៀតរបស់លោក ហើយបានរួមរស់ជាមួយគ្នាបានបុត្តធីតា៩នាក់។ ចំណែកខាងប្រពន្ធដើមគឺនាងមាស មានបុត្រចំនួន៦នាក់ ក្នុងនោះមានស្រីចំនួន៥ ប្រុសចំនួន១នាក់ ឯខាងនាងតួចមានបុត្រចំនួន៣នាក់ ប្រុស២នាក់ ស្រី១នាក់។ កូនប្រុសៗសុទ្ធតែបានធ្វើអ្នកធំទាំងអស់។

នៅក្នុងរជ្ជកាលព្រះបាទព្រះអង្គឌួង ព្រះឃ្លាំង នង ត្រូវបានឡើងជាទីប្រឹក្សា និងជារាជសហការីផ្ទាល់របស់ព្រះរាជា។ ព្រះអង្គពេញព្រះរាជហឫទ័យ ប្រោសព្រះរាជទានឋានន្តរសក្តិជាចាងហ្វាងឃ្លាំងព្រះរាជទ្រព្យ ទើបមានងាររជាឧកញ៉ាព្រះឃ្លាំង។

នៅក្នុងស្នាដៃអក្សរសិល្ប៍ លោកបានបន្សល់ស្នាដៃជាច្រើនដូចជា

១ ពាក្យកាព្យជារឿងជាតក សរសេរនៅក្នុងងាររជាឧកញ៉ាវង្សាក្សត្រី

២ ច្បាប់សុភាសិត សរសេរជាពាក្យកាព្យ

៣ ច្បាប់ស្រី មិនមែនជាច្បាប់ស្រីរបស់បណ្ឌិត**ម៉ែយ** ទេ

៤ ព្រះរាជពង្សាវតារក្រុងកម្ពុជា

៥ សាស្ត្រាភោគកុលកុមារ

៦ បុញ្ញាសារសិរសា

៧ ព្រះសមុទ្ទ

៨ លោកនេយ្យជាតក

៩ វរនុជវរនេត្រ

នៅខាងក្រោម យើងខ្ញុំបានលើកយក អត្ថបទសង្ខេបនៃរឿង**គោគកុលកុមារ** មកសិក្សាជាឧទាហរណ៍ជូនមិត្តអ្នកអាន។ រឿងគោគកុលកុមារ ត្រូវបាននិពន្ធឡើងនៅក្នុងពុទ្ធសករាជ២៣២៧ មហាសករាជ ១៧២៦ ចុល្លសករាជ១១៦៦ ត្រូវនិងឆ្នាំ១៨០៤ ក្នុងរជ្ជកាលព្រះបាទអង្គច័ន្ទទី២ ដែលអត្ថបទនេះសរសេរជាពាក្យកាព្យ។ ខាងក្រោមនេះ ខ្ញុំដកស្រង់ជាអត្ថបទសង្ខេបជាពាក្យរាយហើយនៅបន្តជាពាក្យកាព្យ ដូចតទៅ៖

កាលព្រះសម្មាសម្ពុទ្ធគង់នៅវត្តជេតពន ក្រុងសាវត្ថីភិក្ខុទាំងឡាយបានប្រជុំគ្នា ក្នុងធម្មសភានិយាយពីរឿងភិក្ខុទេវទត្តដែលព្យាយាមពិឃាតព្រះពុទ្ធជាម្ចាស់ តែមិនបានសម្រេចដូចបំណង ក៏បែរជាទទួលគ្រោះថ្នាក់ខ្លួនឯងទៅវិញ ដោយត្រូវព្រះធរណីស្រូបទាំងរស់ ទៅកើតក្នុងមហានរកអវចី។ ព្រះសាស្តាយាងមកកាន់ទីប្រជុំនោះទ្រង់ត្រាស់សួរពួកភិក្ខុថា "ប្រជុំគ្នានិយាយពីរឿងអ្វី?"។ ពួកភិក្ខុក្រាបទូលថា "ប្រជុំនិយាយពីរឿងទេវទត្តព្យាយាមពិឃាតព្រះអង្គ" ។ ព្រះអង្គបានត្រាស់ថា "ទេវទត្តព្យាបាទសម្លាប់ព្រះអង្គ ហើយវិនាសខ្លួនឯង មិនមែនបច្ចុប្បន្នជាតិនេះទេពីបុព្វជាតិមក ក៏ដូច្នេះដែរ" ។ ភិក្ខុទាំងនោះបានសូមអារាធនាព្រះអង្គឲ្យសំដែងពីរឿងនេះ ទើបទ្រង់ផ្តើមនាំអតីតនិទាន ដូចយើងបំព្រួញដោយសង្ខេបតទៅនេះ។

ក្នុងអតីតកាល គ្រាដែលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពារាណសី កាលនោះ មានមហាសេដ្ឋីម្នាក់ឈ្មោះគោគវិណ្ណីមានទ្រព្យសម្បត្តិច្រើនដល់ទៅ ១៨ កោដិឃ្លាំង ព្រមទាំងមានសន្តានចិត្ត

សប្បុរស បានបរិច្ចាគធនធានធ្វើបុណ្យឲ្យទាន ទាល់តែអស់ទ្រព្យសម្បត្តិ ធ្លាក់ខ្លួនទៅជាអ្នកកំសត់ទុគ៌ត ។ គាត់មានកូនប្រុស តែមួយសន្មតនាមថា គោគវណ្ណី ស្របគ្នានិងនាមរបស់គាត់ជាឪពុកដែរ ។ សេដ្ឋីជាបិតាបានទទួលមរណកាលទៅ ដោយពេគចាស់ជរា បានទៅកើតជាព្រះឥន្ទ្រាធិរាជឮដឹងថា គោគវណ្ណីជាកូនរបស់ខ្លួនមានសេចក្ដីលំបាក តោកយ៉ាកតែពីរនាក់ប្ដីប្រពន្ធ ក៏បានសុំអញ្ជើញព្រះបរមពោធិសត្វ ដែលឋិតនៅស្ថានត្រៃត្រឹង្ស ឲ្យចុះមកកើតជាព្រះរាជបុត្រី ព្រះបាទសត្តកុដរាជនៅសត្តកុដបុរី ដើម្បីឲ្យបានជាភរិយារបស់ព្រះពោធិសត្វ ។ កាលព្រះពោធិសត្វប្រសូតមក មាតាបិតាបានដាក់នាមថា គោគកុលកុមារ ។ លុះគោគកុលកុមារមានអាយុ១០ឆ្នាំ មាតាបានទទួលអនិច្ចកម្មទៅ ដល់អាយុ១៥ឆ្នាំ គោគវណ្ណី ជាបិតា ទទួលមរណកាលទៅទៀត នៅកំព្រាតែម្នាក់ឯង ។ គោគកុលកុមារ ប្រកបរបរធ្វើចំការនៅទីទួលព្រៃមួយ ដោយព្រះឥន្ទជាជីតា បានជួយជ្រោមជ្រែងនិម្មិតធ្វើទីព្រៃនោះឲ្យស្អាតពបល្អស្មើជា ដំបូង ។ កុមារនេះ បានសុំកូនឆ្កែស មួយពីជូនចាស់ម្នាក់គ្រាន់បានជាគ្នា ។ ជូនចាស់នោះបានសុំគោគកុលកុមារធ្វើ ជាកូនធម៌ ។ គ្រានោះ ព្រះឥន្ទ្រាធិរាជបានទៅសុំព្រះរាជធីតានៃព្រះបាទសត្តកុដរាជ យកទៅផ្សំផ្គុំជាភរិយារបស់ គោគកុលកុមារ ។ ក្នុងការបំពេញករណីកិច្ចនេះ ព្រះឥន្ទបានបីពយកនាងទៅដាក់ក្នុងចម្ការនៃគោគកុលកុមារព្រម ទាំងបាននិម្មិតថង់ស្បែកមួយ ឲ្យនាងចូលពួនក្នុងថង់នោះហើយថា បើនាងត្រូវការវត្ថុអ្វី នាងអាចលូកយកក្នុងថង់ នេះបានទាំងអស់ តាមបំណង ។ គោគកុលកុមារបានដឹងដោយសារសុនខរបស់ខ្លួនព្រុសជាដំបូង ទើបទៅរើសថង់នោះ យកមកទុកក្បែរដំណេកក្នុងខ្ទម ។ ព្រឹកឡើងកុមារចេញទៅជម្រះស្មៅចម្ការបាត់ទៅ នាងកញ្ញាចេញពីក្នុងថង់មកក្រៅ

បោសប្រាសសំអាតទីលំនៅ រៀបចំចម្អិនភោជនាអាហារ ទុកឲ្យភោគកុលកុមារសព្វគ្រប់ហើយ ក៏ចូលទៅពួនក្នុងថង់នោះវិញទៅ ។ កុមារកម្សត់ ត្រលប់មកពីចម្ការវិញ បានឃើញចំណីអាហាររៀបចំស្រេចស្រាប់ ក៏បរិភោគដោយក្ដីរីករាយនិងដោយក្ដីមន្ទិលសង្ស័យផង ។ នាងកញ្ញាតែងតែធ្វើរបៀបនេះរៀងរាល់ថ្ងៃ ។ ថ្ងៃក្រោយភោគកុលកុមារ ធ្វើឧបាយថាទៅធ្វើចម្ការហើយវិលត្រលប់មកពួនលបចាំមើល បានឃើញនាងក៏សាកសួរ អំពីប្រវត្តិហេតុរបស់នាង ៗនិយាយប្រាប់សព្វគ្រប់តាមដំណើរ ។ អ្នកទាំងពីរបានគ្នាជាភរិយាស្វាមីតាំងពីពេលនោះតទៅ ។ ភោគកុលកុមារ បានសន្មតនាមនាងថាសុខុមាលន្ទាទេវី

ថ្ងៃក្រោយមក គាមភោជក (មេស្រុក) បានឃើញភរិយារបស់ភោគកុលកុមារមានរូបស្រស់ប្រិមប្រិយ ស្រឡាញ់ចង់បាននាងមកធ្វើជាប្រពន្ធខ្លួន តែឃើញថានាងមានឋានៈខ្ពស់ មិនងាយនឹងស្រឡាញ់នាងបាន ក៏ចូលទៅក្រាបបង្គំទូលព្រះបាទព្រហ្មទត្ត ជានាំប់រង់ថានឹងរិះរកមធ្យោបាយយកនាងមកថ្វាយជាអគ្គមហេសី ទាល់តែបាន ព្រះបាទព្រហ្មទត្តមានព្រះរាជហឫទ័យស្របតាមដោយសេចក្ដីរីករាយ រួចហើយទ្រង់ធ្វើឧបាយកលផ្សេងៗ តាមការណែនាំនៃគាមជក គឺទ្រង់ត្រាស់បង្គាប់ឲ្យភោគកុលកុមាររកមាន់មកប្រជល់នឹងមាន់ព្រះអង្គ ឲ្យរកដំរីមកប្រជល់នឹងដំរីព្រះអង្គ ឲ្យលូកទឹកក្ដៅក្នុងខ្ទះ ដោយដាក់កំហិតថា បើភោគកុលកុមារចាញ់ ត្រូវថ្វាយនាងសុខុមាលន្ទាទៅជាអគ្គមហេសី។ ភោគកុលកុមារមានជ័យជម្នះជាដរាប ដោយសារឧបាយកលរបស់នាងជាភរិយា ដែលបានធ្វើតាមបណ្ដាំព្រះឥន្ទ។ ព្រះរាជាកើតទុក្ខទោមនស្សជាខ្លាំងអស់សង្ឃឹមក្នុងរឿងនេះ ទើបរិះរកឧបាយកលមួយផ្សេងទៀត ដើម្បីបំផ្លិចបំផ្លាញនាងឲ្យព្រាត់ប្រាសពីភោគកុលកុមារទៅ

វិញ គឺការបង្ខិតបង្ខំឲ្យភោគកុលកុមារ បរិភោគចំណីអាហារ លាយដោយស៊ុតមាន់ទាដែលត្រូវតម រហូតទាល់តែនាងសុខុមាលទ្ធា កើតសេចក្តីក្តៅក្រហាយរត់ទៅនគរនាងបាត់ទៅ។

ឯភោគកុលកុមារ ធ្វើដំណើរដោយលំបាកច្រើនថ្នាក់ទៅតាមរកនាងសុខុមាលទ្ធា រហូតដល់សត្តកុដបុរី ក៏បានទទួលរាជាភិសេកគ្រប់គ្រងរាជសម្បត្តិនៅនគរនោះ ប្រកបដោយសិរីសួស្តីជ័យមង្គលដ៏អស្ចារ្យ ។ កាលរាជាភិសេករួចហើយ ព្រះពោធិសត្វ(ភោគកុលកុមារ) និងព្រះអគ្គមហេសី ក្រាបថ្វាយបង្គំលា ព្រះវររាជមាតាបិតាវិលត្រលប់ទៅនគរពារាណសីវិញ ដើម្បីចង់ដឹង ឧបាយកលរបស់តាមភោជក និងព្រះបាទព្រហ្មទត្តតើនឹងធ្វើដូចម្តេចទៀត។ ក្នុងដំណើរនេះ ព្រះពោធិសត្វសុំយកតែសេះជាអាជានេយ្យ១ និងធ្នូជ័យ១ ។ ទ្រង់បានទៅដល់ទីចម្ការ ក៏ធ្វើហាក់មិនដឹងព្រឿងអធិកអ្វីទាំងអស់ គឺទ្រង់នៅក្នុងខ្ទមនោះដូចធម្មតារៀងមក។ ដំណឹងនេះ ក៏លេចឮដល់តាមភោជក ៗក៏បានទៅទូលញុះញង់ព្រះបាទព្រហ្មទត្តថា ភោគកុលកុមារមានចិត្តក្បត់ចង់ប្លាំងដណ្តើមយកនគរពារាណសី។ ព្រះបាទព្រហ្មទត្ត ក៏លើកទ័ពទៅឡោមព័ទ្ធព្រះពោធិសត្វ ៗយិតធ្នូថ្ងៃងសរឮសូរកក្រើករំពើកអស់ទាំងព្រះធរណី។

ស្តេចជាបច្ចាមិត្ត និងតាមភោជកស្លុតរន្ធត់ធ្លាក់ពីលើខ្នងដំរីក្សិណក្ស័យជីវិតក្នុងគ្រានោះទៅ។ ពួកមន្ត្រីនិងសេនាយោធា ក៏បានចុះចូលមូលមកសុំអញ្ជើញព្រះពោធិសត្វ ឲ្យសោយរាជ្យក្នុងនគរពារាណសី។កាលបាន ទទួលរាជ្យរួចហើយ ព្រះពោធិសត្វព្រមទាំងព្រះអគ្គមហេសីស្តេចយាងត្រលប់ទៅនគរសត្តកុដវិញតាមផ្លូវទឹក ដើម្បីសួរសុខទុក្ខព្រះវរមាតាបិតា ។ គង់នៅទីនោះបាន៣ខែ ក្សត្រទាំងពីរអង្គ ក៏ថ្វាយបង្គំលាព្រះវរមាតាបិតា វិលត្រលប់ទៅក្រុងពារាណសីវិញទៀត ដើម្បី

គ្រប់គ្រង រាជ្យនៅទីនោះជាស្ថាពរតទៅ ។ គ្រានោះ ព្រះបាទសត្តកុដ ទ្រង់ បានប្រទានព្រះរាជដំបូន្មានក្រើនរំឭកព្រះពោធិសត្វ ឲ្យប្រព្រឹត្ត តាមទសពិធរាជធម៌កុំបីឃ្លៀងឃ្លាត ។ ឯព្រះវរមាតា ក៏បានទូន្មាន ព្រះ រាជបុត្រីឲ្យប្រព្រឹត្តប្រតិបត្តិតាមក្រិត្យក្រមរបស់ស្ត្រីដែរ ។ ព្រះបាទភោគ កុលនិងព្រះអគ្គមហេសី ទ្រង់សោយរាជសម្បត្តិក្នុងក្រុង ពារាណសី ប្រកបដោយទសពិធរាជធម៌ ព្រមទាំងទ្រង់ប្រទានដំបូន្មានខាងផ្លូវលោក និងផ្លូវធម៌ច្រើនបែបច្រើនបទ ដល់ប្រជារាស្ត្រឲ្យ បានសេចក្ដីសុខ ចម្រើនសម្បូរសប្បាយជរាបដល់ទ្រង់ចាស់ជរា សោយព្រះទីវង្គតទៅ ទ្រង់បានទៅសោយសម្បត្តិសួគ៌នាស្ថាន តុសិតទាំងពីរព្រះអង្គ ។

នៅក្នុងអត្ថបទជាពាក្យកាព្យ លោកព្រះឃ្លាំង នង បានរៀបចំ ពាក្យពេចន៍ជាកំណាព្យកាព្យឃ្លោង ប្រកបដោយការចាប់ចុងចួនពីរោះ រណ្ដំណែងណង មិនចាញ់កវីឯកនានានៅក្នុងសម័យមុនៗឡើយ។ នៅ ក្នុងអត្ថបទរឿងរបស់លោក អ្នកកវីរូបនេះបានសរសេរជាពាក្យកាព្យ តាំងពីដើមដល់ចប់ ដែលរួមមានដូចជាបទ កាកគតិ បទព្រហ្មគីតិ បទ ពំនោល និងបទកុជង្គលីលា។

ដើម្បីឲ្យរឹតតែច្បាស់លាស់បន្ថែមទៀត ខ្ញុំសូមដកស្រង់អត្ថបទជា ពាក្យកាព្យមកបង្ហាញជូនមិត្តអ្នកអាននៅនាទីនេះដូចតទៅៈ

## រឿង ភោគកុលកុមារ

### បទ ព្រហ្មគីតិ

នាក្នុងរាត្រីកាល នោះនាងនាថវរទេវី
ករិយាភោគវង្សី យង់យោសប្តិប្ងព៌និមិត្ត ។
យល់ដូចផើងសុវណ្ណា តម្រួតគ្នាទាំងពីរពិត

នៅនាក្នុងឋានឋិត ដាក់កណ្ដាលមណ្ឌលទី ។
មានដើមចម្ប៉ាដុះ លើផើងនោះបែកបង់បាត់
លុះលង់ទៅទៀតថ្វាត់ យូរប្រមាណថ្នាំស្បា ។
ផើងមាសមួយវិញទៀត បែកបង់ម្សៀតសូន្យសោះប្រា-
កដកូវដើមចម្ប៉ា នោះអណ្ដែតត្រសែតទៅ ។
ឋិតកណ្ដាលនភី មានរស្មីភ្លឺសន្ធៅ
ហើយធ្លាក់ចុះមកនៅ នាកណ្ដាលនគររា ។
មានមែកបែកសន្ទឹក ល្អពន្លឺកពេកមហិមា
ប្រកបនូវបុប្ផា ពិដោរសាយសព្វទិសផង ។
នាងភ្ញាក់ឡើងប្រាយប្រាប់ ស្វាមីស្ដាប់ដោយទំនង
យល់អស្ចារ្យកន្លង ដោយនិមិត្តមិនដែលយល់ ។
លុះព្រឹកភ្លឺស្រេចស្រាង ក្សិណនោះនាងនាថនិម៌ល
កាន់ស្វាម្ចូដើរដល់ ឋានអ្នកប្រាជ្ញរាជបណ្ឌិត ។...

**បទភាកគតិ**

វីថៅភោគកុល- កុមារនិម៌ល
និត្យនៅត្រីហា កណ្ដោចកណ្ដោង
ម្នាក់ឯងកំព្រា មិនមានអ្នកណា
នៅជាពីរផង ។
អ្នកគិតអនិច្ចា ខ្លួនអើយកំព្រា
ពេកពន់កន្លង ឥតញាតិកា
មេបារៀមច្បង មិត្រសម្លាញ់ផង
គ្រាន់ពឹងអាស្រ័យ ។

ច្នេះគួរអញរក សត្វឆ្កែមួយមក
ចិញ្ចឹមសព្វថ្ងៃ នឹងធ្វើចម្ការ
នៅនាក្នុងព្រៃ គ្រាន់ពឹងអាស្រ័យ
កំដរអាត្មា ។

គិតដូច្នោះស្រេច ពន្ទកសារពេជ្ជ
ពូជពង្សសាស្តា ចុះចាកមណ្ឌល
ដើរដល់គ្រឹហា ជូនចាស់មួយជា
មេម៉ាយឥតប្តី ។

គាត់ចិញ្ចឹមឆ្កែ ញីមួយជាមេ
មានកូនបានបី មួយលឿងមួយប្រាល
ពពាលពិសី មួយដូចសំឡី
សសុទ្ធសោភា ។

ឯចៅគោគកុល- កុមារមើលយល់
កូនសុនខា អ្នកឡើងទៅថ្កាន
ដល់ឋានគ្រឹហា សំពះពោលថា
បពិត្រលោកយាយ ។

ខ្លួនខ្ញុំនេះជា អ្នកខ្សត់កំព្រា
ឥតឪពុកម្តាយ ឥតញាតិផៅផង
រៀមច្បងទាំងឡាយ តាមតែអ្នកយាយ
អាសូរករុណា ។

ខ្ញុំមកនេះមិញ ប្រាថ្នាសូមទិញ
កូនសុនខា បានមួយយកទៅ
ទុកនៅជាគ្នា គ្រាន់ធ្វើចម្ការ

ចិញ្ចឹមជីវី ។

## បទ កុជង្គលីលា

ទេវីស្រស់ស្រីនិម៌ល គាប់គួរតម្កល់ ឲ្យជាករិយា ។
កោកុលនិម៌លកុមារ ជាគូផងគ្នា កុំឲ្យឃ្លៀងឃ្លាត។
គិតស្រេចសម្ដេចនរនាថ ចេញចាកប្រាសាទ សួគ៌ត្រៃត្រឹង្សា ។
ហោះដល់មណ្ឌលសីមា សត្តកុពជមហា- នគររម្យរ័ត្ន ។
ព្រះសួរបន្ទូលទៅថ្វាត់ ថាមហាក្សត្រ សត្តកុជរាជា ។
យើងមករួសរកប្រាថ្នា សូមរាជធីតា បុត្តមហេសីធំ ។
យើងនឹងយកទៅផ្សំផ្សំ នឹងប្រុសឧត្តម មួយមានចេស្ដា។
ជាគូនៃបនិត្យស្នេហា អ្នកនឹងបានជា ក្សត្រថ្លៃថ្កើងថ្កាន។
សោយរាជ្យអំណាចហៅហាន គ្រប់គ្រងពារ- ណសីនគរ ។
ទើបមហាក្សត្រាបវរ សោមនស្សសាទរ ទៀងទូលទៅថា។
សក្កោទេវរាជា ទ្រង់ព្រះប្រាថ្នា ចង់បានបុត្រី ។...

## បទពំនោល

ព្រះពោធិសត្វស្ដែងស្ដាប់ អាជ្ញាប្រាយប្រាប់ អ្នកព្រួយព្រះទ័យមហិមា។
ប្រែប្រាប់ទៅថ្កានករិយា ហៃប្អូនពុំងា សំឡូតសម្ងាញ់ស្នេហ៍ស្និទ្ធ ។
នេះសមមេស្រុកកាចក្លាត់ មកយល់ប្អូនរ័ត្ន ទ្រង់គោមប្រសើរលើសស្រី ។
ទើបទៅទូលក្សត្រធិបតី រិះរកកលក្តី ឧបាយនឹងយកប្អូនភ្ងា ។
ឯនាងសុខុមាលន្ធា ស្ដាប់ហើយឆ្លើយថា បពិត្រអ្នកជាស្វាមី ។
ទុកងារនេះលើប្អូនស្រី រកមាន់កុំបី អម្ចាស់ព្រួយព្រះចិន្តា ។
ទើបនាងទៅខាងចម្ការ ដែលទីតន្ទ្រា ស្ដេចដាក់ចង់ស្បែកនៅនិត្យ។

នាងថ្វាយបង្គំតាំងចិត្ត អធិដ្ឋានគិត ដល់គុណព្រះឥន្ទ្រាទ្រង់ ។
ស្រេចនាងលូកទៅក្នុងថង់-ស្បែកទិព្វបញ្ចង់ ក៏បានមាន់ឈ្មោលមួយមាន។
កម្លាំងខ្លាំងក្រៃហាវហាន នាងនាំមកថ្កាន ឲ្យព្រះស្វាមីចមចៅ ។
ថាអ្នកយកមាន់នេះទៅ ជាញជល់ក្នាល់នៅ នឹងមាន់ក្សត្រាធិបតី ។
កាលនោះព្រះពង្សពោធិ សោមនស្សរីករាយ អ្នកបីមាន់ចេញទៅថ្វាត់ ។
ឡើងលើព្រះរាជពេងវ័ត្ត ក្រួញក្រាបប្រណិប័តន៍ បង្គំប្រណម្យនិត្យនៅ
។ទើបមហាក្សត្រាចមចៅព្រះអង្គទតទៅ យល់ហៅគោកុលកុមារ ។
បីមាន់ចរចូលត្រអាល ស្តេចមានឱង្ការ បង្គាប់ទៅមេស្រុកថា ។
ឲ្យហៅគោគកុលកុមារ ទៅអង្គុយនា ឋានទីដែលនឹងជលមាន់ ។
ស្តេចប្រើអាមាត្យខ្មីខ្មាន់ ឲ្យទៅយកមាន់ ព្រះរាជទ្រព្យមកថ្វាត់ ។
មាន់នោះមានរូបធំធាត់ មានកម្លាំងក្តាត់ន ក្រៃលែងនឹងមាន់នានា ។
ទើបស្តេចបន្ទូលត្រាស់ថា ហៃចៅកុមារ យើងនឹងជល់មាន់លេងលង។
ក្នាល់គ្នាកាលគ្រានេះម្តង មុខមន្ត្រីផង អង្គុយមើលមីរពាសពេញ ។
ថាបើមាន់ចៅជល់ចាញ់ បរាជ័យមាន់អញ អញឲ្យទៅយកភរិយា ។
នៃចៅមកទុកធ្វើជា ខ្ញុំក្នុងគ្រឹហា បម្រើអង្គអញប្រក្រតី ។
ទើបស្តេចឲ្យលែងមាន់ខ្មី ចូលទៅក្នុងទីឋាន ស្នាមដែលនឹងជាញជល់។
កាលនោះមានចៅគោគកុល រមិលមើលយល់ នូវមាន់មហាក្សត្រច្បាស់ច្បង។
ទទះស្លាបនោះបីដង រងាវរំពង រំពៃរំពឹងចង់ជល់ ។
ហើរហោក្រទាទៅជល់ វិលវៃកិច្ចកល ចាំចឹកនៃមាន់ក្សត្រា ។
ខ្ទាក់ក្អែកទាំងសងសោះសា ងងិតអន្ធការ ចាលចាញ់រូចរត់ចេញថ្វាត់ ។
អស់មហាជនជុំច្រើនក្តាត់ សេនាបរិស័ទ្យ យល់ជាអស្ចារ្យគួរស្ញែង។
សឹងគន់សឹងគិតកោតក្រែង ខ្សឹបខ្សៀវគ្នាឯង ថាអ្នកនេះមានសិល្ប៍សាស្ត្រ។

ឯមហាក្សត្រាស្តេចខ្មាស ប្រជានុរាស្ត្រ ពុំចេញព្រះសូរសោសង៍ ។
កោគកុលដឹងដើមទំនង លាក្សត្របា្លស់ប្តូរ វិលទៅលំនៅអាត្មា... ។

តាមរយៈការរៀបរាប់នៅក្នុងអត្ថបទសម្រង់ខាងលើនេះ បានបង្ហាញយ៉ាងច្បាស់ថា លោកឧកញ៉ាព្រះឃ្លាំង នង ជាកវីដែលពោរពេញទៅដោយទេពកោសល្យយ៉ាងប៉ិនប្រសប់ ក្នុងការតាក់តែងអត្ថបទជាពាក្យកាព្យប្រកបដោយក្បួនក្បិន ខាងសំនួនវោហារយ៉ាងអស្ចារ្យ ដែលជាវិធីដឹកនាំអ្នកអានឲ្យលង់អារម្មណ៍ ទៅតាមសំនួនទឹកដៃរបស់លោក។

មួយវិញទៀត តាមរយៈអត្ថបទនេះ ក៏បានបង្ហាញឲ្យយើងឃើញថា ការរីកចម្រើនពីវិស័យអក្សរសាស្ត្រជាតិកាលពីសម័យបុរាណ ដែលការលូតលាស់គួរឲ្យចាប់អារម្មណ៍ពីសំណាក់អ្នកសិក្សាទាំងឡាយ និងបានបន្សល់ទុករហូតមកដល់សព្វថ្ងៃនេះ។

នៅស្នាដៃផ្សេងទៀត លោកឧកញ៉ា បានសរសេរបទជាកំណាព្យយ៉ាងពីរោះល្អល្អាយ និងមានការគោរពតាមក្បួនជើងកាព្យខ្មែរយ៉ាងល្អ ។ ដើម្បីជាសក្ខីភាពបន្ថែមទៀត ខ្ញុំសូមលើកយកអត្ថបទសម្រង់ខ្លីៗមកបង្ហាញជូនដូចខាងក្រោមៈ

***លោកនេយ្យជាតកៈ*** អត្ថបទនេះ ត្រូវបានលោកសរសេរឡើងនៅក្នុងឆ្នាំ១៧៩៤ ស្ថិតនៅក្នុងរជ្ជកាលព្រះបាទអង្គអេង ដែល ជាព្រះបិតាព្រះអង្គឌួង។អត្ថបទនេះនៅផ្នែកច្បាប់ដើមជាភាសាបាលី តែលោកបានប្រែជាភាសាខ្មែរ ដោយលោកបាននិពន្ធជា កំណាព្យទៅតាមបទផ្សេងៗត្រឹមត្រូវតាមក្បួនជើងកាព្យខ្មែរ និងមានពាក្យពេចន៍រស់រវើក។

"ខ្ញុំអរឱនអង្គ លុតលើក កផ្ទង់ ដាក់ដល់សិរសី

អង្គញកាយំ　　បញ្ចង់ប្រដិ-　　ស្ថានស្ថិតអភី
　　ភាទវរបង្គំ　　។
ក្រាបក្រោមកង់ចក្រ　　ព្រះបាទលាយលក្ខណ៍　　សូមសរសើរសំ-
ណាង់នៃស្តេចស្តែង　　លើសលែងឥន្ទព្រហ្ម　　ទេពទាំងយក្សយម
　　រាជរួញខ្លាចខ្លប　　។...

***ច្បាប់សុភាសិត:*** សរសេរនៅឆ្នាំ១៧៩០ ដែលជាស្នាដៃដំបូងគេបង្អស់របស់លោកក្នុងការដែលលោកក្លាយជាកវីយ៉ាងចំណានៗ

"ឯអង្គអញខ្ញុំ　　នាមនង់សោតសម　　ចិត្តចេតនា
សូមមានមនោ　　បយោសទ្ធា　　ព្យាយាមឧស្សាហ៍
　　ត្រេកត្រង់កុសល　　។
ដ្បិតខ្ញុំនេះណា　　ទើបរៀនចង់ជា　　កាព្យកិច្ចការកល
គន់គិតដោយនារ　　ប្រាជ្ញាយោបល់　　ពុំសូវឆ្ងាយយល់
　　ជ្រៅជ្រះកាព្យ　　។...

***រឿងបុណ្ណាសារសិរសា:*** អត្ថបទរឿងនេះ ត្រូវបាននិពន្ធឡើងនៅថ្ងៃសុក្រ ទី៨រោច ខែអស្សុជ ឆ្នាំម្សាញ់ នក្សត្រ ពុទ្ធសករាជ ២៣២០ មហាសករាជ ១៧១៩ គ្រិស្តសករាជ១៧៩៧ ជាអត្ថបទប្រភេទកំណាព្យ មានច្រើនបទ ដូចជាបទកាកគតិ បទពំនោល បទព្រហ្មគីតិ និងបទកុជង្គលីលា។

សាច់រឿងនៃអត្ថបទនេះ ខ្ញុំសូមលើកយកឡោលៗដូចតទៅ៖

"នមាមិហំ　　ពុទ្ធសេដ្ឋំ　　លោកជេដ្ឋោ
បរមសត្ថា　　ទេវាមនុស្សា　　លោកុត្តមោ
　　អនន្តញាណំ...។

ទសករកំបង់ បទបាទឱនអង្គ ឱនអញ្ជលី
មនោវាចា កាយាវន្ទី បញ្ចប្រតី-
ស្ឋានបិតអភិវាទ ។
ព្រះស្រីសម្មា ព្រះពុទ្ធសាស្តា ធម្មិកលោកនាថ
ឯកឥតទុតិយំ ទេពទាំងលោកធាតុ ក្រាបក្រោមព្រះបាទ
ព្រះបរមសារពេជ្ញ ។...
ខ្ញុំគិតកាព្យ កាលជាឧកញ៉ា វង្សាក្សត្រី
ជាខ្ញុំព្រះបាទ នរនាថចក្រី រាមាធិបតី
ទ្រង់រាជថ្កើងថ្កាន ។
ស្តេចសោយវិលា ល័យលុះជន្មា ពិធីចាកឋាន
ខ្ញុំសោតរវល់ ខ្វាយខ្វល់ពុំបាន គិតកាព្យនេះខាន
គិតពុំទាន់ចប់ ។
ដ្បិតលោកចៅហ្វា- ទឡ្ហៈជាតិជា បិតាធម៌ថប់
តាក់តែងមន្ត្រី សេនីយសាយសព្វ សង់មេរុមណ្ឌល
ប្រាសាទរចនា ។
ធ្វើបុណ្យសព្វថ្ងៃ ពេញពីរវស្សា ឲ្យទានទ្រព្យធន
ពេកពន់មហិមា ទើបបានបូជា ថ្វាយព្រះអគ្គី ។
ហើយលោកគន់គិត តែងឲ្យធ្វើឥដ្ឋ សាងព្រះចេតិយ
បញ្ចុះព្រះធាតុ ព្រះបាទចក្រី ធ្វើបុណ្យប្រក្រតី
ឧទ្ទិសថ្វាយទៅ ។
លោករួមរក្សា ព្រះរាជបុត្រា ទាំងបួនចមចៅ
គ្រប់គ្រងធានី បុរីឥតសៅ អស់រាស្ត្រក្នុងក្រៅ
សឹងសុខសប្បាយ ។

លោកឲ្យសក្កា ខ្ញុំជាឧកញ៉ា ព្រះឃ្លាំងចៅហ្វាយ
ឃ្លាំងមណីរត្ន ទើបគិតទូលថ្វាយ កាព្យកិច្ចបរិយាយ
តែងចងរចនា ។

ទុកតជាកេរ ក្រោយក្រែងចំណេរ អនាគតា
ក្រែងសោះសូន្យស្ងាត់ បទបាទបរិហារ ជាព្រះសិរសា
បរមចក្រពត្តិ ។

ពាក្យខ្ញុំសុភាព ពុំពីរោះរាប ក្រែងភ្លាំងភ្លេចភ្លាត់
ពិតពុំទាក់ទង កន្ទងបរមត្ថ អ្នកណាចេះស្ទាត់
តម្រង់ឲ្យទាន ។

តំណសាសនា ប្រាំពាន់វស្សា ជាតិព្រះទ្រង់ញាណ
ក្នុងហាសិបជាតិន៍ និបាតមែនមាន អស់អាចំនិទាន
និដ្ឋិតែងចប់ ។...

## ៣ ឧកញ៉ាចក្រីកែវ

អ្នកនិពន្ធមួយរូបនេះ ពុំបានបន្សល់ទុកជីវប្រវត្តិជាក់ច្បាស់លាស់ដែរ។ កវីរូបនេះ បានរស់នៅក្នុងរជ្ជកាលមហាក្សត្រអង្គអេង អង្គចន្ទ និងមហាក្សត្រីអង្គម៉ី។

ទាក់ទងនិងស្នាដៃអក្សរសិល្ប៍ ឧកញ៉ាចក្រីកែវ បានបន្សល់ស្នាដៃចំនួនពីរដែលយើងរកឃើញ មានដូចជា កំណាព្យរឿង **សមុទ្ទឃោសៈ** ដែលសរសេរទាញចេញពីគម្ពីរបញ្ញាសជាតក នាឆ្នាំ១៨១៨ សរសេរជាបទជាកាកគតិ បទពំនោល បទព្រហ្មគីតិ បទ កុជង្គលីលា កាលពីលោកមានគោរម្យងារជាបញ្ញាធិបតី។ ដោយឡែករឿងនេះ ក៏មាននៅប្រទេសថៃយ៍ ប្រទេសឡាវ ប្រទេសភូមា (ប្រទេសមីយ៉ាន់ម៉ា) ផងដែរ។

ក្រោយមកនៅឆ្នាំ១៨៣៧ លោកបានសរសេររឿងមួយទៀត មានចំណងជើងថា សាស្ត្រា**ដាវរឿង** ដែលមាន៨ខ្សែ ហើយត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៥៥ ដោយបណ្ណាគារគីម គី នៅភ្នំពេញ។ រឿងនេះយើងឃើញមានឯកសារ ៤ច្បាប់តម្កល់នៅសាលាបារាំងចុងបូព៌ាប្រទេស គឺជាឯកសារស្លឹករឹតពីរហើយត្រូវបានចុះបញ្ជីលេខ៥៦ និងលេខ៣២៧ ចំណែកឯកសារសរសេរលើក្រដាសពីរទៀតចុះលេខP៦១ និងP៨០[១] ។

ខាងក្រោមនេះ ខ្ញុំលើកយកស្នាដៃសាស្ត្រារឿង **ដាវរឿង** មកបង្ហាញជាសម្រង់ដល់អ្នក សិក្សាឲ្យបានជ្រាបះ

សាស្ត្រារឿង **ដាវរឿង** ត្រូវបាននិពន្ធ និងរៀបរៀងឡើងនៅថ្ងៃសុក្រ ៧កើត ខែផល្គុណ នាខែហេមន្តរដូវ ឆ្នាំរកា ពុទ្ធសករាជ ២៣៨០ មហាសករាជ១៧៥៩ ត្រូវនិងឆ្នាំ១៨៣៧។

អ្នកនិពន្ធបានបញ្ជាក់ប្រកពថា អត្ថបទរឿងនេះ ត្រូវបានដកស្រង់ចេញពីរឿងជាតក គឺចៅពញាអញ្ចិត ស្រី ដែលលោកបាននាំរឿងនេះមកពីស្រុកសៀម។

| | | | |
|---|---|---|---|
| អហំនមោ | នមក្ការោ | | អញ្ជលិយំ |
| សុសិរសា | ពុទ្ធសេដ្ឋំ | | លោកុត្តមំ |
| | តមោនុរោ | ។ | |
| នមធម្មំ | សុខាវហំ | | អរិយបថោ |
| ទេវជមំ | មោក្ខមគ្គោ | | សន្តិករោ |
| | និយ្យានិកំ | ។ | |
| នមសង្ឃោ | វរវិសុទ្ធោ | | ទក្ខិណេយ្យំ |

[១] យ៉ង់ ហុកឌី ម៉ាលីបទអក្សរសិល្ប៍ខ្មែរ សតវត្សទី១៩ ឆ្នាំ២០០៣

សន្តិន្ទ្រិយ បុញ្ញាក្ខេត្តំ អនាសវំ
សមិទ្ធិយោ ។
អហំវីខ្ញុំ នមោបង្គំ នមស្សកាពោ
ក្រួញក្រាបនមស្ការ វន្ទាសេដ្ឋោ អញ្ជលិយោ
លើកអញ្ជលី ។
សុសិរសា ផ្ទុំផ្ទុំហត្ថា ដាក់លើសិរសី
ពុទ្ធសេដ្ឋោ វន្ទាព្រះស្រី សារពេជ្ជមុនី
ប្រសើរស្ងួស្តីសម។...

ភិក្ខុអើយរម្ងូលគោត កម្ងៅធោតធុតគិតតែ
កន្ទ្រិសឫស្សាគេ ជាទេវទត្តពុំឃ្លាតឃ្លា ។
វិនាឯសម្រិទ្ធិ ចេរវឹងថ្ងាត់យោនយកជាតិ
ជាចិញ្ចាឯងអាច ប្រពន្ធទេវទត្តស្មោះ ។
ហៃអស់ទាំងជនផង ចូរត្រាប់ត្រងព្រះធម៌ថ្លៃ
ព្រះធម៌នេះគាប់ក្រៃ ចូរមហាជនគន់គិតយក ។...

## ៤ បណ្ឌិតស្អាត ឫស់អាត

អ្នកនិពន្ធរូបនេះ ពុំបានបន្សល់ទុកជីវប្រវត្តិឲ្យបានច្បាស់លាស់ឡើយ។ លោកប្រសូតមករវាងសតវត្សទី១៩ និងបានសរសេររឿងមួយមានចំណងជើងថា **សាស្ត្រាមុច្ចលិន** ឬ **ព្រះចន្ទគោរព** នាឆ្នាំ១៨៣៣ ដែលមានចំនួន៧ខ្សែ។ អ្នកនិពន្ធបានបញ្ជាក់ថា ជារឿងប្រែពីភាសាសៀម រូបលោកយកមកតែងជាកំណាព្យ បទកាកគតិ បទពំនោល បទព្រហ្មគីតិ និងបទកុជង្គលីលា។ សាស្ត្រារឿង ព្រះចន្ទគោរព ត្រូវបានលោកសរសេរឡើងនៅថ្ងៃសុក្រ ទី៥កើត ខែអាសាឍ ឆ្នាំម្សាញ់ ។ ខាង

ក្រោមនេះ ខ្ញុំដកស្រង់សាច់រឿងខ្លះៗមកបង្ហាញមិត្តអ្នកអានដូចតទៅៈ

ទសករផ្តុំ ស្មោះស្មើបទុម ដាក់ដល់សិរសា
បង្គំសម្តេច សារពេជ្ញពុទ្ធា ប្រសើរឧត្តមា
លើសលែងលោកា ។
ស្តេចជាគ្រូគ្រប់ ទូទាំងភូមិភព ពីងព្រះបេស្តា
ឥន្ទ្រព្រហ្មយមយក្ខ ហ្មឺនចក្រវាឡ មូលមកវន្ទា
បង្គំភក្តី ។...
សកវាជតាំងត ទោត្រីស័កធ មង្គលសួស្តី
ម្សាញ់នក្សត្រ វិវឌ្ឍសិរី អាសាធមាសី
សុក្រ៥កើតដាក់ ។
នៃនាមអញខ្ញុំ តាមដោយគោរម្យ ឧត្តមសិទ្ធិសក្តិ
បណ្ឌិតសំអាត សង្ខាតរួសរក្ស ចិត្តចង់ស្មោះស្ម័គ្រ
គាប់កាលចិន្តា ។...

និទាននេះទៀងគេ ពិតពីខ្មែរប្រាំមួយខ្មី
តែងតាមបទបាលី ដោយពាក្យស្រីនិយាយទេ ។
ទោះបីបើខាតខុស ខ្លះលើសលួសពីពាក្យគេ
កែគិតឲ្យគ្រប់តែ ប្រាំពីរខ្មែរសួរេចហោង ។

## ៤ ព្រះអរិយគាមមុនី ហ៊ីង

អ្នកនិពន្ធរូបនេះ មិនបានបន្សល់ទុកជីវប្រវត្តិឲ្យបានច្បាស់លាស់ដែរ តែគេអាចដឹងថា លោកប្រហែលជាមានកំណើតនៅដើមសតវត្សទី ១៩។ លោកបានបួសរៀនជាព្រះសង្ឃ និងមានឋានៈជារាជាគណៈ

សម័យក្រុងឧដុង្គមានជ័យ ដែលមានឋានៈជា **ព្រះអរិយតាមមុនី** ។ នៅផ្នែកអក្សរសិល្ប៍លោកបានបន្សល់ស្នាដៃមួយគឺសាស្ត្រារឿង**ព្រះជិនវង្ស**

សាស្ត្រារឿងព្រះជិនវង្ស ត្រូវបានរៀបរៀងឡើងនៅក្នុងឆ្នាំពេងអដ្ឋស័ក ពុទ្ធសករាជ ២៣៩៩មហាសករាជ១២១៨ ត្រូវនិងឆ្នាំ១៨៥៦ តាមការអះអាងនេះ លោកញ៉ុក ថែម បានអះអាងថា សករាជទាំងបីហាក់ដូចជាមិនចុះសម្រុងគ្នាទេ។ លោកបានបញ្ជាក់ថា ទុកឱកាសឲ្យអ្នកសិក្សាជំនាន់ក្រោយសិក្សាស្វែងយល់បន្តទៅទៀតចុះ។

អត្ថបទសាស្ត្រារឿង ព្រះជិនវង្សត្រូវបានសរសេរជាកំណាព្យ ក្នុងនោះមានបទកាកគតិ បទពំនោល បទព្រហ្មគីតិ បទកុជង្គលីលា។

ប្រសិនណាជាសង្កេតមើលពីសកម្មភាពតួអង្គ ពិសេសគឺគោលគំនិតនៃរឿង គឺមានលក្ខណៈសមស្របទៅនិងគោលគំនិតព្រហ្មណ៍និយមក្នុងអក្សរសិល្ប៍ព្រហ្មណ៍និយមដែរ ប៉ុន្តែអ្វីដែលមានលក្ខណៈដាច់ស្រលះនោះគឺ លោកកវីបានរចនាសាច់រឿងឲ្យមានលក្ខណៈសមស្របទៅ និងរឿងជាតកក្នុងគោលការណ៍ពុទ្ធនិយម រួចក៏បានលើកតួអង្គឯកថាជាតួអង្គព្រះពោធិសត្វ ពិសេសគឺការបញ្ចប់រឿងមានលក្ខណៈសជាតិ។

តាមសេចក្តីនេះដែរ តាមឯកសាររបស់លោក **លាង ហាប់អាន** បានធ្វើការអះអាងនៅក្នុងសៀវភៅ **ប្រវត្តិអក្សរសាស្ត្រខ្មែរសម័យនគរភ្នំដល់សម័យឧត្តុង្គ (សតវត្សទី១ ដល់១៨៥៩** ថារឿងនេះមានជាសាស្ត្រាស្លឹករឹតចំនួន១២ខ្សែចប់ តែមានឯកសារខ្លះទៀតអះអាងថា មាន១៩ខ្សែ ។ គម្ពីរមាន១១ខ្សែមាននៅពុទ្ធសាសនបណ្ឌិត្យលេខសាស្ត្រា៥៦០ ចំណែកឯកសារមាន១៩ខ្សែចប់ លេខសាស្ត្រា៥៦១ត្រូវបានចុះ។

មហាកំណាព្យរឿងព្រះជិនវង្ស ត្រូវបានចាត់ទុកជារឿងដ៏វែងបំផុតមួយក្នុងចំណោម អត្ថបទកំណាព្យខ្មែរប្រភេទរឿងនិទានដែលស្នា

ដៃមួយនេះត្រូវបានប្រសូតឡើងដោយស្នាដៃអ្នកនិពន្ធតែម្នាក់ គឺព្រះអរិយគាមមុនី**ហ៊ីង** នាសម័យក្រុងឧដុង្គមានជ័យ។ មានឯកសារខ្លះទៀតបានធ្វើការអះអាងក្នុងការបោះពុម្ពថា រឿងនេះជាស្នាដៃរបស់អ្នកនិពន្ធ **ភីង** តែមានឯកសារខ្លះទៀតក៏បាននិយាយថា ជាស្នាដៃរបស់អ្នកនិពន្ធ **ហ៊ីង** ។ តែទោះបីជាយ៉ាងនេះក្តី ភីង ជាឈ្មោះអ្នកនិពន្ធមួយដែលយើងមិនបានស្គាល់ពីមុនក្នុងចំណោមអ្នកនិពន្ធក្នុងសម័យក្រុងឧត្តុង្គឡើយ។ម្យ៉ាងទៀត តាមឯកសារដែលយើងទទួលបាន គឺមានតែអ្នកនិពន្ធ **ហ៊ីង** តែប៉ុណ្ណោះដែលជាម្ចាស់រឿងនេះ។

ជាបន្តទៅទៀត ខ្ញុំសូមលើកយកអត្ថបទសម្រង់រឿងកំណាព្យដ៏មហាវែងរបស់ព្រះអរិយគាមុនី **ហ៊ីង** មកបង្ហាញជូនមិត្តអ្នកអានដូចខាងក្រោម៖

| | | |
|---|---|---|
| បទកាកថ្ងៃនោះ | ឆ្នាំរោងកាលណោះ | អដ្ឋស័កសាសនា |
| សកពជបពិត | សម្តេចព្រះមហា | លោកនាថសាស្តា |
| | ថ្ងៃយើងនេះកូវ | ។ |
| ទើបបានពីរពាន់ | បីរយគ្រប់គ្រាន់ | វស្សានឹងកៅ |
| សិបប្រាំបួនផង | មហាសកពជ ...[១] | ឆ្នាំសោតកន្ទង ។ |
| មួយពាន់ប្រាំបី | រយចិតសិបខ្មី | ខែប្រាំបួនផង |
| ទើបឯព្រះចុល្ល- | សកពជកន្ទង | មួយពាន់ឆ្នាំហោង |
| | ពីររយប្រាំបី | ។ |
| ដណ្តប់វស្សា | គ្រានោះពជមហា | ក្សត្រាពិសី[២] |
| ហរិក្សពមា | ឥស្សរាធិបតី | ចមចៅបុរី |
| | ឥន្ទបទរដ្ឋា | ។... |

---

[១] ត្រង់នេះប្រហែលជាបាត់មួយឃ្លា [២] ឯកសាររបស់លោក លាង ហាប់អាន ថា ក្សត្រាពិសីហ-កាលណាដាក់យ៉ាងនេះនាំឲ្យបាត់ពាក្យចួនធ្ងន់ល្បះខាងលើដែលថា ពីររយប្រាំបី

ទ្រង់ត្រាស់ទេសនា ប្រោសអស់នោះណា បានលុះអស់ផង
បានចូលនិព្វាន ទៅអស់ហើយហោង នេះគឺទំនង
ដំណើរសេចក្តី ។
ចែងចប់ពាក្យកាព្យ ពេចន៍អភិប្រាយ តែម្ល៉េះឯងនៃ
ដំណើរអំពើ ព្រះសាងបារមី ពង្រួមស្រដី
តែម្លេះឯងហោង។

## ៦ ចៅពញាភជា កក្តី
## ចៅពញាជំនិតក្សត្រី
## ចៅពញាស្រី អញ្ជិត

អ្នកនិពន្ធទាំងបីរូបខាងលើ ក៏ពុំបានបន្សល់ទុកជីវប្រវត្តិសម្រាប់ការសិក្សាដែរ ហើយក៏ពុំបានបន្សល់ទុកព្រះនាមពិត ប្រាកដសម្រាប់ធ្វើការសិក្សាពីស្នាដៃរបស់លោកឡើយ។ តែទោះបីជាយ៉ាងនេះក្តី ក៏គេអាចសន្និដ្ឋានបានថា លោកទាំងបីរូបខាងលើនេះ ប្រហែលជាកើតនៅសម័យសតវត្សទី១៨ នេះបើតាមការសិក្សាតាមរយៈស្នាដៃរបស់លោក។

ដោយឡែក លោកចៅពញាស្រីអញ្ជិត ជាអ្នកដែលមានចំណេះដឹងជ្រៅជ្រះខាងព្រះពុទ្ធសាសនា ព្រមទាំងបានចេះចាំគាថាបាលីយ៉ាងស្ទាត់ជំនាញ។ នៅខាងផ្នែកស្នាដៃអក្សរសិល្ប៍វិញ លោកបាជួយតែងរឿង **សុវណ្ណជលសារ** និងរឿង**ចន្ទឃាត** ជាមួយលោកចៅពញាជំនិតក្សត្រី និងលោកចៅពញាភជា កក្តី រវាងអំឡុងឆ្នាំ១៨៥៨ ដែលមានទាំងអស់ចំនួន១០ខ្សែ។ រឿងទាំងនេះ សរសេរជាបទកាកគតិ បទពំនោល បទព្រហ្មគីតិ បទភុជង្គលីលា ដែលកាលនោះចៅពញាស្រីអញ្ជិត មានងារជា ព្រះអញ្ជិត ពញាស្រីអញ្ជិត។ ដើម្បីបញ្ជាក់ឲ្យរិតតែ

ច្បាស់បន្ថែមទៀត ខ្ញុំសូមស្រង់ស្នាដៃរបស់លោកកវីទាំងបីរូបខាងលើនោះដែលបានរួមគ្នានិពន្ធ ស្នាដៃអក្សរសិល្ប៍រឿងចន្ទឃាតមកបង្ហាញជូនមិត្តអ្នកអានឲ្យបានជ្រាប។

សាស្ត្រារឿង ចន្ទឃាត ត្រូវបាននិពន្ធឡើងនៅថ្ងៃព្រហស្បតិ៍ ៨ កើត ខែជេស្ឋ ឆ្នាំមមី ពុទ្ធសករាជ ២៤០១។ រឿងនេះ មានប្រភពសម្រង់ចេញពីរឿងបញ្ញាសជាតកក៏ ដែលឯកសារជាស្ត្រាស្លឹករឹត មានចំនួន១០ ខ្សែចប់ ហើយត្រូវបានតម្កល់ទុកនៅពុទ្ធសាសនបណ្ឌិត្យ ដែលបានមកពីវត្តសំរោង ស្ថិតក្នុងស្រុកកៀនស្វាយ ខេត្តកណ្ដាលដែលត្រូវបានយកមកចម្លងទុកកាលពីអំឡុងឆ្នាំ១៩៤២ ដែលមានលក្ខណៈដូចតទៅះ

កាកបទា អតិទុក្ខវា បឋមបទំ
បរមបញ្ញោ អកោសលំ ជិវាមាមំ
គរហិតា។
មយំវន្ទេ មសម្ពុទ្ធេ សិរសាទា
នសង្កុលិ បតិដ្ឋិតា អវបាទា
លោកនាថោ ។...
មយំដើមបទ យើងខ្ញុំលំអុត ឱនអង្គអភី
ផ្គងផ្គាប់ផ្គុំតាំង បញ្ចាង្គប្រកី ក្រាបក្រោមព្រះបាទ[១]
វិសេសសុទ្ធសាស្ដា ។
ព្រះអង្គត្រូវគ្រប់ ត្រានត្រើយត្រៃភព ឯកអង្គនាថា
ប្រោសប្រាណប្រែប្រាស លាកលះលែងលា ទុក្ខចៀសចោលអ-
បាយបាបអង្គទៅ ។...
ចន្ទឃាតជា តកនិដ្ឋិកា និទានព្រះបាទ

[១]ឯកសារលោក លាង ហាប់អាន ដាក់ថា "ក្រាបក្រោមបាទ" ដោយបាត់ព្យាង្គទើបបានជាខ្ញុំដាក់ថា **ក្រាបក្រោមព្រះបាទ**

ចន្ទឃាតថ្ងៃថ្វា ក្នុងហាសិបជាតកក៏ នៅក្នុងនិបាត
បែងចប់សេចក្តី ។
និទានកាព្យ នេះនាមចៅពញា ជំនិតក្សត្រី
លើកជាល្បើកថ្វាយ បរិយាយសេចក្តី ដោយបទបាលី
ជុំជាតិសព្វគ្រប់ ។
ជាតកសេចក្តី នេះខ្ញុំទាំងបី តែងទាំងថ្ងៃយប់
ដោយប្រាជ្ញាខ្លៅ ពុំសូវប្រសប់ តែងទៅទាំងយប់
ជូនចប់និទាន ។
ថ្ងៃពុធប្រាំបី ពេជស្រាពណ៌មាសី ឆ្នាំមមីបាន
សកពជសាសនា ព្រះអនាវញ្ញាណ ឯខែនោះបាន
ចតុមាសា ។
ថ្ងៃបានកំណត់ ប្រាំពីរថ្ងៃគត់ ឯឆ្នាំគណនា
ពីរពាន់បួនរយ និងមួយវស្សា សង្ខេបគាថា
សូរេចម្ទេះហោង។

## ៧ ភិក្ខុជម្មបញ្ញា ម៉ែន

កវីរូបនេះ ក៏មិនបានបន្សល់ទុកជីវប្រវត្តិសម្រាប់អ្នកសិក្សាអក្សរសាស្ត្របានដឹងដែរ តែគេបានដឹងថា លោកមានកំណើតកើតនៅចុងសតវត្សទី១៨ ទើបបានបួសរៀនក្នុងសំណាក់ព្រះគ្រូព្រះនាម**ស្រី** និងបានបំពេញជាភិក្ខុដោយគ្រូឧបជ្ឈាយ ទើបព្រះគ្រូស្រីបានប្រគេននាមបញ្ញត្តិជា **ធម្មបញ្ញា** លោកកវីរូបនេះ បានចេះចាំភាសាបាលីស្ទាត់ជំនាញណាស់ ពោលគឺលោកអាចប្រែគម្ពីរធម៌អាថ៌ មកជាភាសាខ្មែរប្រកបដោយភាពច្បាស់លាស់បាន។

នៅក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរ លោកបានប្រែរឿងជាភាសាបាលីមកជាភាសាខ្មែរមួយ គឺរឿងសាស្ត្រាពេជ្ជតា ឬ ពពេច នា អំឡុងឆ្នាំ ១៨៥៩ដែលមានតែមួយខ្សែចប់។ រឿងពេជ្ជតា ត្រូវបានលោកប្រែមកជាកំណាព្យ មានច្រើនបទ ដូចជា បទកាកគតិ បទពំនោល បទព្រហ្មគីតិ បទកុជង្គលីលា ។ តាមការសង្កេត និងសិក្សា រឿងនេះ ប្រហែលជារឿងជាតកដែរ តែគ្មានការសរជាតិដូចជាតកនានាឡើយ។

នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ រឿងនេះត្រូវបានរក្សា ទុករហូតដល់ឆ្នាំ១៩៧០ ដែលត្រូវបានចុះបញ្ជីលេខ៦១២។ ឯកសារជាសាស្ត្រាស្លឹករឹតមានមួយខ្សែចប់ដែលមាន៦៣សន្លឹក។ ឯកសារមួយនេះពុទ្ធសាសនបណ្ឌិត្យបានមកពីវត្ត **កងតាណឹង** ខេត្តកំពង់ចាម។ រឿង**ប្រពេច**មានសេចក្តីតំណាលថា ៖

យើងខ្ញុំបង្គំ ក្រួញក្រាបប្រណម្យ ដោមដាក់សិរសា
ឆ្ពោះស្មោះតម្រង់ ព្រះអង្គកគវា ក្រួញក្រាបវន្ទា
ប្រក្រតីសព្វថ្ងៃ ។

ដ្បិតខ្ញុំនេះកាត់ ចិត្តខ្ជាំងពេកក្តាត់ លាកិលេសនៃមក
បួសសំណាក់ ក្នុងពុទ្ធញាណញោយ្យ ឧស្សាហ៍សព្វថ្ងៃ
តាមពុទ្ធវចនា ។...

ប្រពេចញីខឹង គន់គិតសញ្ជឹង សច្ចាប្តេជ្ញា
មិនឲ្យស្រដី នឹងប្រុសណាៗ ដល់កើតជាតិជា
មនុស្សស្រដី ។

ប៉ុន្តែប្រពេច ឈ្មោលចិត្តមិនដាច់ ពីគ្នាឡើយនៃ
សច្ចាឲ្យបាន ឈ្មះស្រីទីទៃ ទើបបានមូលមៃ
ជាគូគ្នាវិញ ។

ចប់មួយនិទាន លោកប្រើឲ្យបាន ដីងអាចំនោះមិញ

ទើបគិតលើកគ្នា លោកប្រែថែងចេញ ចប់និទានមិញ និដ្ឋិតំសូវេច ។

## ៨ ព្រះចានសម្តេចព្រះហរិរក្សរាមា ឥស្សរាធិបតី ព្រះបរមកោដ្ឋ ព្រះអង្គឌួង

ព្រះអង្គ ជាព្រះរាជបុត្រពៅរបស់ព្រះបាទសម្តេចព្រះអង្គ**អេង**។ ព្រះអង្គ ប្រសូតនៅនៅឆ្នាំ១៧៩៦។ព្រះអង្គបានភៀសព្រះកាយទៅប្រទេសសៀមអស់រយៈកាលជាងមួយទសវត្ស ទើបបានយាងត្រលប់មកប្រទេសកម្ពុជាវិញនៅឆ្នាំ១៨២១ ហើយព្រះអង្គបានគ្រងរាជនៅឆ្នាំនោះនៅក្រុងឧដុង្គមានជ័យ តែកាលនោះព្រះម្ចាស់ក្សត្រីអង្គ**ម៉ី** មិនទាន់ចូលទីវង្គតនៅឡើយ។ ព្រះអង្គឌួងទ្រង់បានទទួលរាជាភិសេក នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ១៨២៨ក្នុងជន្មាយុ៥២ព្រះវស្សា។ ព្រះអង្គមានព្រះរាជបុត្របីព្រះអង្គ គឺមានព្រះអង្គរាជាវតី(នរោត្តម) ព្រះអង្គស្រីស៊ីសុវត្ថិ(ស៊ីសុវត្ថិ) និងព្រះអង្គជ័យវង្សា ស្រីវឌ្ឍា ឬស៊ីសុវត្ថា ។

នៅរាជព្រះអង្គ តាមឯកសារបញ្ជាក់ថា ព្រះអង្គទ្រង់ប្រកបដោយព្រះប្រាជ្ញាឈ្លាសវៃណាស់។ កាលនោះសៀមសុំផ្តាច់យកខេត្តមង្គលបុរី ទន្លេរពៅ និងខេត្តឯទៀតៗ ព្រះអង្គបានមានព្រះតម្រាស់ថា "ខ្ញុំមិនឲ្យអ្វីទៅសៀមទាំងអស់"។ដោយសៀមខ្លាំងពូកែ ព្រះអង្គ ទ្រង់ឲ្យសៀមយកតែខេត្តណា ដែលសៀមធ្លាប់បានយកមកពីមុនសិនចុះ។

ព្រះមហាក្សត្រអង្គនេះ ទ្រង់បានរៀនសូត្រស្គាល់តម្លៃអក្សរសាស្ត្រពិតប្រាកដ និងបានបណ្តុះបណ្តាលឧបត្ថម្ភឲ្យបានរីកចម្រើនដូចជាព្រះអង្គបានបង្កើតឲ្យមានទីប្រជុំអ្នកប្រាជ្ញ ដែលសម័យនោះហៅថា**រាជបណ្ឌិត** ដោយចាត់ឲ្យមានការប្រឡងប្រជែងស្នាដៃដែលទើបបាន

និពន្ធថ្មីៗទៀត។

ព្រះមហាក្សត្រអង្គនេះ ទ្រង់ប្រកបដោយទសពិធរាជធម៌បាន ប្រារព្ធសង្គ្រោះប្រទេស បាក់បែកដោយសង្គ្រាមៗទ្រង់មានសេចក្តីស្អប់សង្គ្រាមពន់ពេក។

ព្រះអង្គបានកសាងសមិទ្ធិសំខាន់ៗសម្រាប់ប្រទេសជាតិគឺៈ

-ព្រះអង្គបានកសាងព្រះវិហារនៅឧដុង្គ និងបានចាត់អាចារ្យឲ្យបង្រៀនព្រះបរិយត្តិធម៌គឺ **គម្ពីរព្រះត្រៃបិដក**។

- ទ្រង់បានកសាងសាលាទាន។

-ទ្រង់ឲ្យអ្នកប្រាជ្ញ រាជបណ្ឌិតផ្ទៀងកែព្រមទាំងតែងច្បាប់តាមសម័យនិយម។

- ទ្រង់ជ្រើសរើសនាម៉ឺនយកសុទ្ធតែមានចំណេះដឹងជ្រៅជ្រះ

-ទ្រង់បានបញ្ជា ឲ្យកុមារទៅរៀននៅវត្តដើម្បីបង្កើនបានជាចំណេះដឹងបន្ថែម។

-ទ្រង់បញ្ញត្តិដាក់ទណ្ឌកម្ម ដល់នាម៉ឺនទុច្ចរិតស៊ីសំណូកនិងប្រព្រឹត្តអបាយមុខ មានជក់អាភៀនជាដើម។

- ទ្រង់បញ្ញត្តិមិនឲ្យយកពន្ធលើសលប់ និងចងការប្រាក់យកការធ្ងន់ពីប្រជារាស្ត្រឡើយ។

- ទ្រង់ឲ្យធ្វើពុម្ពសម្រាប់ បោះប្រាក់ចាយវាយនៅក្នុងសង្គម។

- ទ្រង់សាងផ្លូវមួយពីឧដុង្គទៅកំពត និងសំពៅជំនួញមួយ។

-ទ្រង់ចំណាយព្រះរាជទ្រព្យចាត់ឲ្យយុវជនខ្មែរ ទៅរៀនភាសាបរទេសនៅសិង្ហបុរី។

នៅក្នុងរាជព្រះបាទសម្តេចអង្គឌួង បានសុខក្សេមក្សាន្តរហូតដល់ឆ្នាំ១៨៥៩ ទ្រង់ចូលទីវង្គតនៅឧដុង្គមានជ័យ ក្នុងគ្រិស្តសករាជ ១៨៦០

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍វិញ ព្រះអង្គបានបន្សល់ស្នាដៃជាច្រើនសម្រាប់ជាកេរតំណែល រហូតមកដល់សព្វថ្ងៃនេះ។ ស្នាដៃទាំងនោះ រួមមាន៖

-រឿងចម្ប៉ាថោង (ទ្រង់និពន្ធក្នុង គ្រិស្តសករាជ១៨១០ កាលនៅសិក្សាពុំទាន់ឡើងគ្រងរាជ្យនៅឡើយ)។

- រឿងកាកី (គ្រិស្តសករាជ ១៨១៥) ទ្រង់និពន្ធក្នុងគ្រាដែលទ្រង់មានព្រះជន្ម១៩វស្សា ។

- ច្បាប់ស្រី (ទ្រង់និពន្ធក្នុង មហាសករាជ១៧៥៩ ចុល្លសករាជ ១១៩៩ ពុទ្ធសករាជ២៣៨០ គ្រិស្តរាជ១៨៣៧ ក្នុងវេលាទ្រង់មានព្រះជន្ម២១ព្រះវស្សា) ។

ខាងក្រោមនេះ ខ្ញុំនឹងដកស្រង់ស្នាដៃព្រះអង្គមួយចំនួនមកធ្វើការបង្ហាញជូនមិត្តអ្នកអានដើម្បីធ្វើការសិក្សាស្វែងយល់ដូចតទៅ៖

## ច្បាប់ស្រី

នៅក្នុងកំណាព្យនេះ ព្រះបាទសម្ដេចព្រះអង្គឌួង ព្រះអង្គបានសរសេរថ្លែងអំពី សុចរិត៨ប្រការដែលជាមង្គលរបស់ស្ត្រីដែលមានសេចក្តីថា៖

នេះនឹងសម្ដែង បរិយាយចារចែង ដើមបទអដ្ឋា-
ហិឋានេហិ សុចរិតា ឥត្ថីលក្ខណា
មង្គលច្នេះពិត ។
ប្រែថាស្រីជា កើតកបលក្ខណា ដោយនូវសុចរិត
មង្គលប្រាំបី ឲ្យស្រីពិនិត្យ ចាំយកជាក្រឹត្យ

គ្រប់រូបស្រីៗ ។

ដើមបទព័ណ៌នា លោកថាស្រីជា សុចរិតកក្តី
ឬករាបស្រគត់ ផ្គង់ផ្គត់សម្តី ការកេរ្តិ៍ខ្មាសស្រី
បរិសុទ្ធមែនមួន ។

លោកថាស្រីត្រង់ កាន់សុចរិតផ្គង់ គំនិតបេះស្ងួន
អស់ទ្រព្យសម្បត្តិ ប្រយ័ត្នថែជួន ទុកដាក់ខ្ជាប់ខ្ជួន
មិនមានប្រមាទ ។

លោកថាស្រីគាប់ កាន់សុចរិតខ្ជាប់ ឧស្សាហ៍សង្វាត
ធ្វើការសន្សំ តឿនខ្ញុំឲ្យឃ្នាត ឲ្យខ្មីសង្វាត
មិនមានស្ងៀមដៃ។

លោកថាស្រីប្រាជ្ញ សុចរិតអង់អាច បេះអធ្យាស្រ័យ
ញាតិព្រៀងទៅមក រាប់រក្សសរៃ ទោះជនដទៃ
ក៏រាប់តាមពិត ។

លោកថាស្រីស្អាត សុចរិតគ្មានឃ្វាត មែនមានគំនិត
បេះរាប់អាហារ ភ្នាក់ងារស្រីពិត រណ្តាប់ផ្គាប់ចិត្ត
ប្តីគ្រប់វេលា ។

លោកថាស្រីស្មោះ កាន់សុចរិតត្តោះ ចាំចិត្តស្នេហា
តែនឹងអង្គប្តី ឥតបីវេរា ស្ម័គ្រស្មោះស្មើជា
និត្យនៅរៀបរៀង ។

លោកថាស្រីស្លូត សុចរិតរហូត អបអត់ឥតល្មៀង
តាមពាក្យប្តីផ្តាំ ចង់ចាំទុកទៀង ពោលពាក្យមិនឃ្លៀង
មិនឃ្វាតសត្យា ។

លោកថាស្រីស្មើ សុចរិតសារពើ អាចរងធានា

ទម្ងន់ចិត្តប្តី ទោះបីទុក្ខា ខ្សត់ក្រម្តេចម្តា
អាចទទួលប្រាណ។

សុចរិតប្រាំបី ជាមង្គលស្រី ប្រសើរក្រមាន
អ្វីមកផ្ទឹមផ្ទាល់ ឲ្យដល់នេះបាន ស្រីណាអាចធ្យាន
ចិត្តចាំរៀនយក៍ ។

ទាំងប្រាំបីច្បាប់ ហៅស្រីមហាគាប់ លោកីយ៍កម្រ
ស្រីកាន់សុចរិត ប្រព្រឹត្តល្អិតល្អ ស្រីណាថាក្រ
ធ្វើតាមពុំបាន។

លោកថាស្រីនោះ ចិត្តអាក្រក់ស្មោះ ស្អប់ដំបូន្មាន
ផ្សាដោយសារចិត្ត ទុច្ចរិតសន្តាន បង្ខិនធនធាន
បើកអាសមាយា។

ក្តីជួច្រើនកល ក្រដឹងចេះដល់ លែបខាយពុតវា
បើចិត្តចង់ស្រាប់ ចង់ស្តាប់ហាក់ជា ផាយដាយសោះសា
ចេះឯងដឹងឯង។

ឯត្រង់ច្បាប់ល្អ តិចទេយល់ក្រ កម្រក្រៃលែង
ក្រព្រោះមិនចង់ ប្រុងអង្គ ឲ្យស្តែង ក្រដោយចិត្តល្បែង
ចំណង់តណ្ហា។

អំពើសុចរិត អធ្យាស្រ័យចិត្ត សម្អាតឧស្សាហ៍
ស្មើស្មោះស្ងួតត្រង់ ផ្គត់ផ្គង់ក្រីត្យា ប្រាបីនេះណា
សុចរិតប្រាកដ។

ឯសុចរិតស្រី ផ្គត់ផ្គង់ស្វាមី លោកឲ្យអបអត់-
ឱនអៀនចិត្តទន់ ចេះគន់បែបបទ តាមតែចិត្តពត់
ម្តេចៗតាមបាន។

មិនមានប្រកែក មិនមានជជែក ថាធ្វើមិនបាន
ទោះអៀនអន់អត់ សង្កត់ចិត្តប្រាណ តាមចិត្តប្ដីធ្យាន
ម្ដេចៗមិនថា ។

ច្បាប់នេះគួរស្រី នៅនាលោកីយ៍ ផ្ចង់ចិត្តឧស្សាហ៍
កាន់ក្ដីសុចរិត ជាក្រិត្យថ្លៃថ្លា ឲ្យខ្ជាប់ជាក់ជា
ចរិតសព្វថ្ងៃ ។

កាន់បានដូច្នោះ នឹងឮកេរ្ដិ៍ឈ្មោះ ប្រសើរពេកក្រៃ
នឹងបានសុខសាន្ត ចៀសទុក្ខចង្រៃ ដល់បរលោកថ្ងៃ
សោយសុខសួគ៌សិទ្ធ។

សម្ដែងសេចក្ដី ពីមង្គលស្រី ប្រសើរពេកពិត
គ្រប់ទាំងប្រាំបី ក្រឹត្យស្រីសុចរិត ចែងចប់ភាសិត
តាមព្រះបាលី ។

## សាស្ត្រារឿង កាកី

រឿងនេះជាស្នាដៃនិពន្ធ របស់ព្រះករុណាសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី ព្រះអង្គឌួង ដោយសេចក្ដីព្រះរាជប្រារព្ធ សឹងមាននៅខាងដើមនៃរឿងនេះស្រាប់ថា ទ្រង់និពន្ធទុកក្នុងកាលពុទ្ធសករាជ២៣៥៨ ព្រះករុណាព្រះអង្គនេះ ប្រាកដព្រះកិត្តិនាមរហូតដល់សព្វថ្ងៃនេះថាជាឯកអគ្គអ្នកប្រាជ្ញទ្រង់ជំនឿជំនាញក្នុងមគធភាសា និងកាព្យឃ្លោងរកគូប្រៀបបានដោយកម្រ។

រឿងកាកីសរសេរជាកំណាព្យរួមមានបទ កាកគតិ ព្រហ្មគីតិ ពំនោល កុជង្គលីលា។ ខាងក្រោមនេះ គឺជាអត្ថបទសម្រង់ខ្លះដែលយើង

ខ្ញុំបានស្រង់ចេញពី រឿងកាកីដែលជាស្នាព្រះហស្តព្រះករុណាសម្តេច ព្រះអង្គឌួង៖

## បទពំនោល

បទពោលកាលក្រុងគ្រុឌី រាជរួសចរលើ លាលុះព្រះជ្រៃសាខា។
សួត្រសេពទិព្វមន្តវិទ្យា ប្រែប្រាណវិញជា គ្រុឌរាជរឹងឬទ្ធិកន្ទង់។
ស្ទុះហោះផ្ទោះហើរហិចផ្សង់ លាន់ឮគឹកកង រំពង់នៃបក្ខាខែង។
រារាំងបិទបាំងសូរ្យសែង សូរសឹងស្ងប់ស្ញែង អន្ធការមេឃមីរមណ្ឌល។
សន្ធាប់សន្ធឹកឫទ្ធិពល បណ្តាលព្យុះខ្យល់ គគុកគគឹកមហិមា។
កក្រើករំពើងពសុធា ញាប់ញ័រសោះសារ ទូទាំងទសទិសវិបត្តិ។
ព្រះបាទបរមព្រហ្មទត្ត យល់អស្ចារ្យក្តាត់ ស្តេចស្តែងលាលីធាប់ខ្មី។
ចេញគង់ផ្តោះមុខមន្ត្រី អស់ទាំងសេនីយ៍ ផ្អកផ្អើលរជ័យទីទៃ។
កាលនោះឯក្រុងវេនតេយ្យ ហិចហោះធាប់ក្រៃ ដួចដល់នៃព្រះកៅរតារ។
ចរចូលគង់ខាងធីតា ឥតក្វឹកសោះសា សំណេះសំណាលក្រអែស។
ថាហៃមាសថ្លៃពិសេស ពិសីទ្រទេស ទ្រទន់ៗក្ងន់កាយា។
បងយល់ពីថ្ងៃបងមហា ស្រឡាញ់ស្ងួនភ្ងា ខំពារមកដល់នេះហើយ។
ម្តេចមេមាសមិត្រកន្តើយ ផ្ទុំលក់ព្រងើយ ធ្វើហាក់មិនដឹងមិនយល់។
ឯមករកប្អូនទិម្មល ឬមួយមាសស្គល់ ឬមិត្រមាសមិនមេត្រី។
ឯអង្គបងនេះណាស្រី គឺមាណពពី- ថ្ងៃមុិញនោះឯងហោងណា។
បងនឹងនាំនាងយាត្រា ទៅទៃនអាសនា ទីទិព្វសម្បត្តិសួគ៌ស្ថាន។
ទៅសេពជាសុខសម្រាន្ត ប្អូនអើយពិមាន ទូរទីមណ្ឌល់ទូលាយ។
សឹងវ័តន៍ពិចិត្រព្រោងព្រាយ ព្រោងព្រាតលេចលាយ ច្រឡំសុវណ្ណរចនា។
បងនឹងនាំពៅពុំងា ហៀរហោះវេហាស៍ ទៅលេងមើលអស់ទួលទី។
មើលសត្តបរិភ័ណ្ឌគិរី សីទន្តរជលធី ទាំងព្រះសុមេរុបពិត។

មើលទាំងនព្វមហាសមុទ្រ ធារធំប្រាកដ ប្រកបនូវខ្សាច់កែវប្រាល។
ភ្លឺផ្លេកក្រលេករន្ទាល រន្ទះដេញដាល ប្រវាត់វិរោធន៍រង្សី ។
ហើយទៅហិមពាន្តគិរី អនោតស្រះស្រី ព្រៃព្រឹក្សពន្លឹកពេញពាស។
បងនឹងនាំមេមិត្តមាស លេងលើកៃលាស សម្រើបសម្រាន្តឥន្ទ្រិយ។
មើលទេពអប្សរកិន្នរី កិន្នរាប្រិមប្រិយ ប្រដាប់នូវគ្រឿងអស់អង្គ។
សឹងរ័តន៍ពិចិត្របញ្ចង់ ព្រោងព្រាយរលង់ រលើបរំលេចសោភា។
ច្រូចច្រៀងរៀងរាំព្រមគ្នា ថ្វាយវវន្ទា ព្រះឥសូរាគម្តែង ។...

## បទ កាកគតិ

| | | |
|---|---|---|
| នៃបនិត្យក្រសោប | ជួញជិតអង្គឱប | អង្អែលឥន្ទ្រិយ |
| បើបថៃកាយា | កត្រាកាកី | ក្លួចកើតមេត្រី |
| | រាគរសតណ្ហា | ។ |
| នាងកាកីកំ- | លៀងលបលួចសំ- | ឡក់លកិរិយា |
| ករកាត់ទះទាត់ | ប្រានផាត់គ្រុឌា | ទើបមានវាចា |
| | ឆ្លាសឆ្លើយទៅថ្កាន | ។ |
| ថាឱព្រះអង្គ | ពុំគួរត្រេកត្រង់ | រួមរស់ជិតដាន |
| នឹងអង្គអញខ្ញុំ | យល់ពុំសមប្រាណ | ដ្បិតខ្ញុំនៅមាន |
| | ស្វាមីមិត្រហើយ ។ | |
| គួរឬព្រះអង្គ | ព្រះទ័យពុំត្រង់ | នឹងម្ចាស់ខ្ញុំឡើយ |
| លបលួចយកខ្ញុំ | មកផ្តុំផ្តឹមខ្មើយ | ឱព្រះអង្គអើយ |
| | ពុំគិតក្សត្រា | ។ |
| បំណាច់ចាប់ចិត្ត | ជាមិត្រស្នេហ៍ស្និទ្ធ | សម្លាញ់ផងគ្នា |
| ព្រះអង្គធ្វើបាន | ពុំមានមេត្តា | ព្រះទ័យព្រះមហា |

ក្សត្រក្សាន្តដល់តិច ។

បងបើខ្ញុំដោយ យូរទៅឯក្រោយ ស្រាប់តែនឹងគេច
យកស្រីសួគ៌ា ឯណាល្អលេច ម៉្លោះហើយនឹងភ្លេច
ចោលខ្ញុំបងសៀត ។

បើម៉្លោះសមខ្ញុំ នឹងមានទុក្ខធំ ទ្រូងត្រួតចង្អៀត
ថែមទាំងដំណៀល គេដៀលផ្ដួនទៀត ថាស្រីស្រើបឆ្លៀត
មានប្ដីគ្រុឌា ។

ហើយគេនឹងដៀល ដំណាលដំណៀល ដល់ព្រះពជា
ថាស្ដេចស្នែងស្ទះ លាកលះលីលា ទៅលួចករិយា
គេមកសិម្ពលី ។

គ្រុងគ្រុឌឆ្លើយថា បងដឹងហើយណា ប្អូនជាមហេសី
ស្ដេចទុកជាច្បង កន្លងលែងស្រី ហើយព្រះចក្រី
ស្រឡាញ់អស់អញ ។

ទោះបីបើក្ស- ត្រាទ្រង់ជ្រាបថ្វាត់ ក្រោធក្រៃគ្នាន់ក្នាញ់
បងពុំខ្លាចឡើយ ប្អូនអើយព្រឹកមិញ បើដោយស្រឡាញ់
ប្អូនមាសប្រសើរ ។

តែគិតកេរ្ដិ៍កោះ បើកុំប៉ុណ្ណោះ កន្ទ្រាក់យកយើរ
ពីមុខអ្នកស្ដេច បងផ្ដាច់មិនស្ទើរ ពារពហោះហើរ
មករួមស្នេហ៍ស្នង ។

ប៉ុន្តែការកេរ្ដិ៍ ខ្លាចមានទាំងពីរ ទាំងប្អូនទាំងបង
បានជាបងឈប់ លុះយប់ទើបផ្គង នាំប្អូនមកត្រង
ទីទេនសេយ្យាសន៍ ។

ប្អូនអើយមាសថ្លៃង មាសថាខ្លាចក្រែង ពាក្យពោលទាំងផ្ដាស

គេដៀលដល់បង ថាបងនាំមាស ហើរហោះវេហាស៍
មកស្ថានសួគ៌ា ។
នាកាលអញបង យកប្អូនស្នេហ៍ស្នង នោះមាននរណា
យល់ជាបងយក មាសមកស្នេហា ប្អូនអើយកុំបា-
រម្ភ រិះការប្រាណ។
អំបាលស្រីស្ងួគំ គំនាប់គំនួរ ស្រៀបស្រស់កល្យាណ
ម្ដេចបងពុំប៉ង ចិត្តបងចង់បាន បានជាបងគ្មាន
ស្រីស្រស់កញ្ញា ។
ឯអង្គកាកី ចិត្តចង់មេត្រី រាគរសស្នេហាផ្ញើ
ពោលពាក្យពើ ថាយើស្ងួគាំ គ្មានស្រីមួយជា
ត្រូវចិត្តឬអ្វី ។
អំបាលស្រីស្ងួគំ គំនាប់គំនួរ ម្ដេចមិនមេត្រី
ថ្នះអ្វីខ្ញុំជា មនុស្សនាផែនដី កាលណាឡើយត-
ស្សូរស័ព្ទទយា ។
សព្វតែព្រះឱស្ឋ ព្រះអង្គថាប្រោស លើសលែងនានា
ព្រះបន្ទូលផ្អែម ល្ហិមល្ហែមណាស់សា ព្រះអើយខ្ញុំមហា-
សង្ស័យកន្ទង ។
ទើបគ្រុឌលោមថា មែនហើយស្ងួនភ្ងា អស់ស្រីស្ងួគំផង
ល្អល្អះមែនពិត ឯកឥតមានហ្មង ប៉ុន្តែអញបង
ពុំត្រូវហឫទ័យ ។...

## បទព្រហ្មគីតិ

ចាប់ចងចំណងនិ- ទានទៅពីក្សត្រត្រើសទ្រង់

រាជរដ្ឋកាលកើតក- ង្វល់រំភែវរកោលាហល ។
ដោយឫទ្ធិរាជគ្រុឌា បណ្ដាលជាព្យុះព្យោមសល់
លុះស្ងាត់បាត់ព្យុះខ្យល់ ស្ដេចចូលដល់ទៃទនមណី។
ពុំឃើញវរជយា នៅក្រឡាបន្ទំទី
ទៀងទើបព្រះភូមី ស្ទុតព្រះទ័យព្រះរាជា ។
ស្ដេចគន់ស្ដេចគិតឆ្ងល់ បទពុំយល់វរជាយា
ដណ្ដឹងស្នំស្នេហា នាងទៅណាបាត់ពុំយល់។
អស់ស្រីសឹងភ្ញាំងកាំង ភ័យភិតភាំងរត់រចល់
រត់រកនាងនិម្មល សព្វមន្ទីរមណ្ឌលា ។
បាត់សោះបាត់សូន្យសល់ រកពុំយល់វរធីតា
មកទូលមហាក្សត្រា ស្ដេចរឹងភាំងរឹងភិតភ័យ។
ស្ងួតស្ងប់ជ្រប់ព្រះភក្ត្រ អន់អួលអាក់ក្នុងព្រះទ័យ
ក្ដួលក្ដៅឱពក្រៃ គិតអាល័យអាឡោះលន់។
ទ្រង់ព្រះកន្សែងសោក សែនអមោក្សស្ដាយពេកពន់
ព្រះផ្អូកព្រះប្អូនតន់ ទួញទន្ទឹងទន្ទេញថា ។
ឱមាសមិត្រកល្យាណ បងរកគ្មានស្រីឯណា
ឲ្យដូចកែវកេនិដ្ឋា ភ្ញិនក្រអូបក្រអែបឯង ។
ឱស្ដាយភក្ត្រសោភ័ណ ហាក់ព្រះចន្ទ្រត្រចះចែង
សួនសមជាស្ដេចស្ដែង ឯកស្ត្រីស្រីកល្យាណ ។
ស្ដាយចេះចែងចរចា ស្ដាយប្រាជ្ញាចេះរិះធ្យាន
ដឹងអត់ដឹងឱនប្រាណ ដឹងសមគួរសមគាប់ការ។
ស្ដាយសមជាមហេសី ធំលើសស្រីស្រស់ស្រីឆ្អា
ស្ដាយចេះដឹងសព្វសា- រពើ ការពុំមានឆ្ងៃឆ្ងល់ ។

បម្រុងស្រីបម្រើ ចិត្តស្មោះស្មើគ្មានកិច្ចកល
ដឹងទោសដឹងទុក្ខទល់ អស់ស្រីស្និទ្ធស្និទ្ធទាំងឡាយ។
បងរកបងរិះគ្រប់ ពុំប្រសព្វប្រសើរកាយ
ឲ្យដូចប្អូនឆោមឆាយ ស្រីសំលូតសម្លាញ់បង ។
ឥឡូវប្អូនប្រែប្រាស ព្រាត់និរាសរៀមហើយហោង
រៀមរកនារីស្នង ពុំដូចមាសមិត្រភ្ញាប្រិយ។
ឱប្អូនធ្លាប់ផ្ទុំផ្ទឹម ទៀបទន្ទឹមលើទែនទី
ពុំដែលពុំដាច់ពី អង្គអញបង់បាត់ច្នេះណា។
ឱប្អូនធ្លាប់គង់ជិត នៅនែបនិត្យនិងរៀមអា៎
ក្រសាលសុខទ័យា ម្ដេចឡើយប្រាសនិរាសទៅ។
ឱបងធ្លាប់យល់កក្រ្ត ប្អូនរលក្ខណ៍គង់គាល់ហៅ
បម្រើសព្វថ្ងៃនៅ ឥឡូវបាត់បង់បងឆ្ងាយ ។
ប្អូនធ្លាប់ស្រង់គង្គា នឹងរៀមអា៎ក្សាន្តសប្បាយ
និរទុក្ខសុខស្កប់កាយ រួមកិរម្យរសទាំងទ្វី ។
ឱប្អូនថ្ងៃត្រកាល កំពុងពាលពេញពិសី
ពុំគួរឡើយប្អូនស្រី ប្រាសចាកពីប្រសើរសុខ។...

## បទ កុជង្គលីលា

បក្សីតើនពីបន្ទុំ លោមនាងឧត្ដម ត្រេកត្រាស់ទៅថា។
ប្អូនមាសវរពាសសោភា បងនឹងយាត្រា នានាំប្អូនពៅ។
លេងដោយជ្រុងជ្រោយព្រៃជ្រៅ មើលភ្នំហើយទៅ ស្រះស្រង់ជលស័យ។
ត្រាសស្រេចទើបស្ដេចវេនតេយ្យ បំបមស្រីថ្លៃ ចរចេញចាកទី។
ហើយហោះចំពោះគិរី សុមេរុជាទី កម្សាន្តទ័យា ។

រៀបរាប់ប្រាយប្រាប់ទៅថា   ប្អូនអើយបព្វតា   សុមេរុវង្គល។
នាងអើយនេះហើយកំពូល   ខ្ពង់ខ្ពស់បណ្ដូល   បណ្ដាប់គួរស្ញែង។
ត្រសៃតអណ្ដែតឯកឯង   ត្រដួចចិញ្ចែង   ចិញ្ចាចសឹងមណី។
បព្វតាថ្លៃងថ្លារង្សី   ដូចសែងសុរិយ   សន្ធោសន្ធៅ។
ថ្មទទឹមថ្លាប្រាលផ្ដៅ   ប្រាលផ្ទិនចាប់នៅ   ចាប់នឹងថ្មនិល។
មរកតពិសុទ្ធស្រស់ស្រិល   ពព្រោងពព្រិល   ប្រពាឡរ័តន៍រាយ។
ថ្មពេជ្រផ្ទុះលេចពិទាយ   ពៃទូរ្យពណ្ណរាយ   ពព្រាកបូបុស្សរ័ ។
សត្តរ័តន៍នព្វរ័តន៍ស្រិលស្រស់   ភ្លឺផ្លេកទាំងអស់   ទាំងឯមុក្តា។
ស្វាយប្រាលពពាលសថ្លា   លឿងអនរតនា   បៃតង់ខៀវខ្មៅ។
ព្រាតប្រុះផ្កាសផ្ទុះផ្ទិនផ្ដៅ   ផ្ទិនផ្ទិតសន្ធៅ   សន្ធោរស្មឹ។
ទតស្រេចទើបស្ដេចបក្សី   ហិចហើរហោះខ្មី   ដល់សត្តបរិភ័ណ្ឌ។
ប្រាប់ឲ្យមើលដោយភ្នំខ័ណ្ឌ   ទាំងប្រាំពីរជាន់   សុមេរុរាជ។
ប្អូនភ្លាមើលរ៉ាត្រដាច   ត្រដឹងគួរខ្លាច   ស្កឹមស្កៃបវរ។
ចន្លោះត្រង់នោះសាគរ   ឈ្មោះសីទន្តរ   ប្រាកជ្រៅពេកក្រៃ។
ទឹកស្អិតហៅឥតសរសៃ   ធ្លាក់អ្វីដល់ឮ   ទឹកសឹងលិចលង់។
ប្រាយប្រាប់ស្រេចស្រាប់ពអង្គ   កាកីទៅត្រង់   សមុទ្រជលស័យ។
ដល់ស្រេចទើបស្ដេចវេនតេយ្យ   បង្ហាញទៅឮ   សមុទ្រគង្គា។
ប្អូនពៅនេះហៅជលសា   ឈ្មោះលោណមហា   សមុទ្រទឹកប្រៃ។
ធំធ្លាយទូលាយពេកក្រៃ   ប្អូនអើយរំពៃ   មើលមានមច្ឆា ។
ធំៗនោះមកកាន់គ្នា   តូចៗហ្វូងវា   ក្រាសក្រៃកន្ទង ។
ឯធំប៉ុនភ្នំជាម្ដង   កៀងគូត្រសង   ហែបហែលដេញគ្នា។
ប្រែប្រឹងសម្ទឹងរោ   លេចលើគង្គា   មើលហាក់ត្រើយត្រាណ។
សន្ធឹកដំទឹកប្រឹងប្រាណ   ហែបហែលលលាន   លលេលលាំ ។

ខ្វះសោតលោហិតទោពាំ ចំណីទន្ទាំ ទន្ទេងទៅមក ។
ខ្លាខ្លែខ្លាយខ្វរលេក មច្ឆាតូចជ្រក ខ្ញុំបខ្ញាចប្រួញប្រាណ។
ប្អូនមាសវរវាសមើលមាន ទ្វីបប្អូនជាស្ថាន មនុស្សលោកនៅនិត្យ។
ទ្វីបនោះមានកោះប្រកិត ពីរពាន់ដុះជិត ជាតិជាបរិវារ។
ប្រាប់គ្រប់សោយសព្វប្រការ ស្រេចនាំនាងនាថ ទៅភ្នំហេមពាន្ត។
ដល់ហើយគ្រុឌឆ្លើយប្រាប់ថ្កាន ហៃប្អូនកល្យាណ មាសមើលគិរី។
ហេមពាន្តជាស្ថានទូទី មើលណាប្អូនស្រី ជាធំស្ដុកស្ដម្ភ ។...

## បទ ព្រហ្មគីតិ

ព្រះចន្ទ្រចរត្រចះ ចែងស្រឡះភ្លឺព្រោងព្រាយ
ពពកសាត់លលាយ លលេលើមេឃាខណ្ឌ ។
ព្រះចន្ទ្រដូចព្រះបង ត្រាកផងកាយណាស់ណាន់
ដូចស្រីស្ងំតាប់តាន់ គង់គាល់ហៅនៅប្រក្រតី។
ឱប្អូនធ្លាប់វែងនៅ នឹងព្រះចៅជាមហេសី
គឺកម្មកាយប្អូនស្រី នានាំនៃបនឹងគ្រុឌា ។
កម្មម្ដេចនាំប្រសព្វ នឹងគន្ធព្វទៀតពីរគ្រា
ទាំងនេះហេតុវេរា នឹងនិរាសរៀមទៀតទៅ។
ដូច្នេះតើនឹងថា អ្នកឯណាឯងឲ្យក្ដៅ
គឺកម្មកាយនិត្យនៅ តែងអន្ទោលតាមដោយដាន។
គ្រប់រូបគ្រប់នាមា ដូចឆាយាតែងតាមប្រាណ
ពុំដែលចរចៀសបាន នឹងវេរាពៀរកម្មកាយ ។
ខ្លួនខុសឬនឹងខំ ខិតផ្សែផ្សំឲ្យសប្បាយ

តាមតែទេពទាំងឡាយ ជួយចម្រុងចម្រើនផង ។
ពុំដឹងខ្លួនមានកម្ម និងនាំគ្រានេះម្តង
កម្មគ្រាស់ក្រៃកន្ទង លើសលែងកម្មគេទាំងឡាយ ។
ឱកម្មនេះកម្មពៀរ ជាតំនៀរកេរ្តិ៍កម្មកាយ
កម្មគ្រាស់អ្វីមាលយ្ហាយ គួរនឹងណាយនឹងនឹកបង់។
មោះឬកម្មពីព្រេង ឲ្យវង្វេងចិត្តភិសវង់
ពុំឲ្យអង្គអញគង់ និងព្រះរៀមព្រះរាជា ។
ឱធ្លាប់រួមផ្ទឹមផ្ទុំ ទិព្វបន្ទំមណ្ឌលា
ប្រាកដប្រកបជា ចមព្រះមហាព្រះមហេសី។
ស្រណោះកាលធ្លាប់នៅ និងព្រះចៅចមចក្រី
នៃបនិត្យជិតប្រក្រតី គ្មានរកៀសរកាំកាយ ។
មួយកាលនៅនាទី សួគ៌សិម្ពលីសែនសប្បាយ
គន្ធ័នផ្ញើលេបខាយ ឲ្យអន្តរាយរូបដល់ម្ទេះ ។
មករងទុក្ខវេទនា ឲ្យឈឺផ្សាផ្សព្វដូច្នេះ
ទ្រូងអើយហាក់នឹងប្រេះ ព្រោះចំណេះចំណាង់ឯង។
សមបាបពីបុព្វេ ឲ្យវេចវេរះបង្វែង
ឲ្យចេញចាកចម្បែង ប្រាសប្រាសាទប្រសើរសុខ។
ពីថ្ងៃនេះទៅហើយ ឱខ្លួនអើយតាំងតែទុក្ខ
រាប់ថ្ងៃតទៅមុខ សមនិងក្សិណក្ស័យអសារ។...

..................

បក់បោកលោកប៉ប្លង ប៉ប្លិបក្នុងទឹកវិលវល់
កណ្តោងកណ្តាលជល លុះគម្រប់សត្តទិវា ។
រលកបោកពោងពាយ បែកខ្ទាត់ខ្ចាយចេញពីគ្នា

លិចលង់នាងក្នុងមហា- សមុទ្រមិញក្ស័យជីវី ។
ក្សត្រីស្រីណាគាប់ កុំត្រង់ត្រាប់កែវកាកី
គំនិតក្បត់ចិត្តប្តី ចោលស្វាមីសេពសាហាយ។
កំពុងពេញស្នេហា ត្កកេសានឹកនឿយណាយ
ផាយផិតប្តីទាំងផាយ ព្រោះចោរចិត្តចង់សម្ព័ន្ធ។
គួរកាន់ច្បាប់ធម្មា តាមគាថាប្រសើរលន់
ទុកឲ្យនរជាតិជន ជាប្រសិទ្ធិប្រសើរក្រៃ ។
គួររៀនរកខ្ទឹមសារ ព្រះអាចារ្យចែងកែខៃ
ជាបុណ្យបានខ្លួនថ្លៃ ពិតពិនិងពំនាក់កាយ ។
កុំធ្វើដូចក្សត្រី កែវកាកីគេនឿយណាយ
និរទេសអង្គអន្តរាយ រូបកណ្តែងកណ្តោចលន់។
ព្រោះតែពីគំនិត បើកចារចិត្តស្រាលសរសន់
ទាល់តែអង្គឯងអ- ន្តរាយរូបអង្គទុក្ខពេកក្តាត់។
បាបនោះឯងមកផ្ត- ន្ទាទាន់ហាន់ដល់ដូចចិត្ត-
កំណាចព្រោះគំនិត ត្រិះត្រង់ត្រេកត្រឹមត្រអាល។
មករងពៀរវេទនា តែឯកាឯកោកាល-
នោះនៅនាកណ្តាល មហាសមុទ្រទល់ទុក្ខា
ស្លាប់ទៅនៅនរក រងទោសទុក្ខតាមវេរា
លុះដល់មកសាសនា ពុទ្ធយើងនេះបានត្រាស។
ទើបបន្ទូលទេសនា ជាគាថាជុំជាតក៍ច្បាស់
ថាកាកីនោះផ្ទាស់ ជាតិជានាងចិញ្ចាជាក់ ។
វីនាយនាដកូវេន សិល្បសាស្ត្រក្វែនសិទ្ធិស័ក្តិ
ចេរិលរឹងជាអ- គ្គសាវកគឺមោគ្គល្លាន ។

ឯអគ្គព្រះព្រហ្មទត្ត វិសេវិសេថ្វាត់មិញមកបាន
ជាអគ្គសាវញ្ញាណ គឺអគ្គព្រះសារីបុត្រ។
ឯគ្រូឧកាជបក្សា គឺព្រះសម្មាសម្ពុទ្ធ
ត្រាសទ្រង់បុណ្យបរិសុទ្ធ តែងទេសន៍ទូន្មានសព្វសត្វ។
ឲ្យលុះដោយមគ្គផល បរិបូណ៌ដល់ព្រះអរហត្ត
សេពសោយសុខសម្បត្តិ និពាន្តពន់ពៀរវេរ ។
ដំណើរនាងកាកី ប្រែសេចក្ដីសៀមភាសា
ជាពាក្យខ្មែរកាព្យា សូររចរឿងចប់ម្ទេះហោង ។

## ៩ ឧកញ៉ាសន្ធរ៉េហារ- ម៉ុក

នៅចុងសម័យឧដុង្គ គេបានប្រទះឃើញអ្នកនិពន្ធមួយរូបទៀត ឆ្នើមណាស់ដែរ ដែលពេលនេះខ្ញុំលើកយកនិយាយនៅក្នុងទីនេះ គឺលោកឧកញ៉ាសន្ធរ៉េហារ-**ម៉ុក**។

លោកអ្នកនិពន្ធរូបនេះ មានស្រុកកំណើតនៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ កាលលោកនៅកុមារ លោកបានទៅបួសរៀននៅសំណាក់លោកគ្រូពជធម្ម **អន** គង់នៅក្នុង វត្ត**គុក** ស្ថិតក្នុងភូមិឧដុង្គ។នៅក្នុងវ័យក្មេង កុមារម៉ុក ជាមនុស្សឧស្សាហ៍ណាស់។ លោកខំរៀនសូត្រអត់មានធ្វេសស្រហែសទេ ហេតុដូចនេះហើយបានជាលោកក្លាយទៅជាមនុស្សត្រូវព្រះទ័យរបស់លោកគ្រូ។ នៅពេលដែលរៀនសូត្រ កុមារម៉ុក មិនមានអ្វីសម្រាប់ការកត់ត្រាដូចជាដីស ឬក្ដារឈ្នួនឡើយ គឺលោកតែងតែសរសេរធ្យូងនៅលើអម្បែងក្បឿង។ ទាំងនេះ ក៏ព្រោះតែ គ្រួសារលោកជាអ្នកដែលមានជីវភាពខ្វះខាត ក្រីក្រណាស់។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏កុមារម៉ុក នៅតែមានចិត្តតស៊ូរៀនសូត្រឥតមានរង្គើះចិត្តអ្វី

ឡើយ។

លុះគម្រប់អាយុ ក៏បានបួសជាសាមណេរ រួចញាត់ភិក្ខុជាភិក្ខុនៅក្នុងវត្តនោះដដែល។ ក្រោយមក ក៏បានលាចាកសិក្ខាបទពីភេទជាសង្ឃ ក៏ត្រូវបានព្រះរាជធម្ម**អន** នាំទៅថ្វាយព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម ដើម្បីធ្វើជាភ្នាក់ងារក្នុងក្រុមព្រះអាលក្ខណ៍។

ដោយព្រះរាជបញ្ញាញាណ ដ៏ភ្លឺស្វាងដែលព្រះករុណាទ្រង់ឲ្យតម្លៃដល់អ្នកចេះពិតប្រាកដ ក្រោយមក ព្រះអង្គក៏ទ្រង់តែងតាំងឲ្យធ្វើជាចាងហ្វាងក្រុមព្រះអាលក្ខណ៍ទៅវិញ ព្រមទាំងបានជាគ្រូលើនាម៉ឺនទាំងឡាយខាងការបង្ហាត់ពីច្បាប់ផែនដីទៀតផង។

អ្វីដែលគួរឲ្យស្តាយសម្រាប់រូបសម្បត្តិកម្ចោះម៉ុកនោះ គឺលោកបានពិការដៃឆ្វេងម្ខាងដោយសារតែរោគអុតធំទាញសរសៃ ទើបបានជាមានពាក្យគេតំណាលថា "**ម៉ែងក្រញ៉ុក ម៉ុកក្រង៉ើង**"។

នៅពេលទំនេរពីការងាររាជការ លោកម៉ុក តែងតែឆ្លៀតសរសេររឿងរ៉ាវល្អៗ ហើយរឿងទាំងនោះក៏បានក្លាយជាការសព្វព្រះទ័យរបស់ព្រះបាទសម្តេចព្រះនរោត្តម។ ជាពិសេសនៅពេលដែលព្រះអង្គយាងទៅណាមកណា ព្រះអង្គតែងតែព្រះរាជទានឲ្យសន្ធ-ម៉ុកតាមដង្ហែព្រះអង្គជានិច្ច ព្រោះតែលោកតែងតែលើកកាព្យបានជាការចាប់ចុងចួនពីពេះណែងណងក្លាមមិនបានព្រាងទុក ហើយមានន័យល្អពីពេះណាស់ ដូចជាប្រយោគមួយលោកបានលើកឡើងថា:

"**នែវើយអាចិកធាមួយកាក់ អាចិកកន្ទ្រាក់បានសាច់ខ្ទៃ**
**ទាញខ្វាកកាប់ខ្ទាប់សាប់ញាប់ដៃ វើយលៃឲ្យធាប់ប្រញាប់ធាន់**" ។

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ គេបានរកឃើញស្នាដៃរបស់លោកសរសេរមានពីរ ដែលការប្រើពាក្យពេចន៍សម្តី ឃ្លោងឃ្លាខុសស្រលះពី

គ្នា។ រឿង**ទេវន្ទ** លោកសរសេរសុទ្ធតែជាពាក្យពិបាកៗដែលអ្នកដែលមានកម្រិតវប្បធម៌ទាបពិបាកនឹងសិក្សាស្វែងយល់ណាស់។ ចំណែករឿងមួយទៀតគឺរឿង**ទុំទាវ** លោកបានសរសេរជាពាក្យងាយអាន ងាយយល់ ពោលគឺលោកសរសេរជាពាក្យស្រាលៗដើម្បីឲ្យសមទៅនឹងសម័យកាលរឿងដែលបានកើតឡើង។ ខាងក្រោមនេះ ខ្ញុំលើកយកស្នាដៃរបស់លោក ក្នុងរឿងទេវន្ទជាសម្រង់មកបង្ហាញជូនមិត្តអ្នកអាន។ នៅក្នុងនេះ លោកបានបង្ហាញប្រាប់ពីទ្រង់ទ្រាយប្រាសាទមួយដែលស្ថិតនៅជិតព្រៃហេមពាន្តៈ

| | | |
|---|---|---|
| ទីរាជសីមា | ឥសូសុខា | ក្សត្រថ្ងៃវរវង្សអធិក |
| ពិស្តារ | ធិការភិម- | ង្គលគាប់ឧត្តុង្គ |
| | ឧត្តមឧត្តលា ។ | |
| នៅខាងខេត្តខែម | ខេត្តខណ្ឌព្រះហែម- | ពាន្តខាងឧត្តរា |
| បន្ទាយជុំវិល | ប្រាំពីរជាន់មហា | ទីឃោដោយទ្វារ |
| | សឹងមានមណ្ឌល | ។ |
| គូគោតថ្នាក់ថ្នល់ | ឥតជលមានផល | ពិចិត្រក្រៅគ្រប់ |
| ផ្កាព័ទ្ធផ្កាពែន | ខ្វាត់ខ្វែងប្រសព្វ | ប្រសើរសឹងអ- |
| | ព្ភិរម្យគួរខ្វាច | ។ |
| រូសត្តបរិ- | កណ្ឌសីទន្តរ | ព័ទ្ធសុមេរុរាជ |
| ប្រាសាទរចនា | ប្រការស្វាច | ចិញ្ចែងចិញ្ចាច |
| | រូរត្តៈចន្ទ័ | ។... |

នៅខាងក្រោមនេះ ខ្ញុំក៏សូមដកស្រង់ពាក្យកាព្យដែលលោកបានសរសេរដើម្បីបង្ហាញមនោសញ្ចេតនាដូចតទៅ៖

ស្រឡាញ់ស្រីតូច ស្រីទៀតមិនដូច មិនដល់មាសបង
មាសបានសាងផល កុសលឥតហ្មង ឥតមានប្រឡង
ប្រឡះកាំបាន ។

ភ័ព្វនាងបានជួន បានជួបនីងនួន និងនាងកល្យាណក
ល្យាណ៍កបលក្ខណ៍ ចិត្តស្ម័គ្រស្នោះស្នាន ស្នោះស្មើនៅឋាន
នៅថិតមូលគ្នា ។

ប្រសិនចេះហោះ ចេះហើរចេះផ្ទោះ ទៅជួមអង្គា
អង្អៀកប៉ះពាល់ រៀងរាល់វេលា ពិលាបដោយនា
ដោយនៅកន្ទុង ។

ក្រៅពីបណ្ដាអ្នកនិពន្ធ ដែលយើងខ្ញុំបានធ្វើការរៀបរាប់ខាងលើ ក៏មានអ្នកនិពន្ធជាច្រើនរូបទៀត ដែលលោកទាំងអស់សុទ្ធតែជាអ្នកដែលស្រឡាញ់វិស័យអក្សរសាស្ត្រជាតិណាស់ ហើយលោកតែងតែខិតខំចំណាយពេលវេលាដ៏មានតម្លៃ ក្នុងជីវិតរបស់លោកមកចងក្រងជាស្នាដៃអក្សរសិល្ប៍ទុកសម្រាប់កូនខ្មែរជំនាន់ក្រោយបានសិក្សាដែរ។ អ្វីដែលគួរឲ្យសោកស្ដាយនោះ គឺលោកមិនបានបន្សល់ទុកប្រវត្តិរូបសម្រាប់ការស្រាវជ្រាវរបស់យើងទេ។ នៅក្នុងនោះ ក៏មានអ្នកនិពន្ធម្នាក់ជាជនជាតិចិន ក៏អ្នកនិពន្ធរូបនេះមានចំណូលចិត្តស្រឡាញ់អក្សរសាស្ត្រជាតិខ្មែរ។ អ្នកនិពន្ធម្នាក់នោះគឺលោក **កួយ** មានដើមកំណើតជាជនជាតិចិនពូជហុកគៀន។ អ្នកនិពន្ធម្នាក់នេះ មុនដំបូងគឺលោកបានបួសរៀននៅវត្តស្រះចក រាជធានីភ្នំពេញ ក្នុងសំណាក់លោកគ្រូធំរជា **ព្រះសាងនារា** ហើយបានតែងកាព្យដោយប្រែរឿងចិនមួយជាភាសាខ្មែរនៅឆ្នាំ១៨៦០ ដែលមានចំណងជើងថា **ហ៊ានប៊ុន** ឬ **ហានប៊ុន**។ រឿងនេះមានមួយច្បាប់ នឹងត្រូវបានតម្កល់ទុកនៅបណ្ណាល័យជាតិក្រុងប៉ារីស

ដែលមានតែមួយខ្សែចប់។

អ្នកនិពន្ធមួយចំនួន ដែលយើងមិនបានសិក្សាជីវប្រវត្តិបានស៊ីជម្រៅដើម្បីបង្ហាញជូនមិត្ត អ្នកអាននោះរួមមានដូចជាៈ

-អ្នកឧកញ៉ា ឧទេន សរសេររឿង មាយមាណព មានតែមួយខ្សែចប់។

- ភិក្ខុបណ្ឌិត ខៀវ សាស្ត្រា សរសេររឿង ចន្ទលីវង្ស និងរឿងពលកូន។

- កវីចន្ទ សរសេររឿងភិនសុវណ្ណ មាន៦ខ្សែចប់។

- កវីញ៉ែម សរសេររឿងវិមានចន្ទ មាន៨ខ្សែចប់។

- ឧកញ៉ា ធម្មាធិបតីចន្ទ សរសេររឿងសុខមាណព មាន១ខ្សែចប់។

-ចៅពញ៉ាភក្តីសង្គ្រាមបាល សរសេររឿងសុភោគ មានចំនួន៥ខ្សែចប់។

បន្ថែមពីលើអ្វីដែលមាន គឺថា នៅសម័យកណ្តាលនេះ ពោរពេញដោយអ្នកនិពន្ធជាច្រើនរូប តែលោកទាំងនោះមិនបានបង្ហាញឈ្មោះពិតប្រាកដទេ។ យើងខ្ញុំក៏មិនបានដឹងពីមូលហេតុពិតប្រាកដដែរ តែតាមការស្មានប្រហែលជា មកពីរបត់សង្គមក៏ថាបានព្រោះតាមការ អង្កេត រឿងភាគច្រើនត្រូវបានសរសេរដោយអ្នកមានងារធំៗ ។ ឬមួយពីនេះទៅវិញ ក៏ប្រហែលជាអត្ថបទរបស់លោកទាំងនោះគ្រាន់តែជាការសរសេរសាកល្បង ហើយក៏បានផ្សាយដោយការនិទានបន្តពីមាត់មួយទៅមាត់មួយក៏មានការល្បីសុះសាយ ទើបមិនបានដឹងពីប្រភពដើមពិតប្រាកដ។

ជាសំណូមពរ ខ្ញុំសូមឲ្យបណ្តាអ្នកដែលស្រឡាញ់អក្សរសាស្ត្រ

ជាតិ មេត្តាជួយសិក្សាស្វែងយល់ពីឫសគល់ពិតប្រាកដនៃការដែលអ្នកនិពន្ធយើងមិនព្រម បង្ហាញឈ្មោះពិតប្រាកដរបស់លោក សម្រាប់ជាទីសម្គាល់នៃអ្នកអាន។

ជាបន្តទៅទៀត ខ្ញុំនឹងលើកយកសាស្ត្រារឿងពីរដែលមិត្តអ្នកអានមួយចំនួនមានការយល់ច្រឡំគ្នា។ រឿងមួយគឺមានចំណងជើងថា "រឿងស័ង្ខសិល្បជ័យ" ចំណែករឿងមួយទៀតមានចំណងជើងថា "រឿងខ្យងស័ង្ខ" ដែលរឿងទាំងពីរនេះ ជារឿងដែលត្រូវបានកើតឡើងនៅសតវត្សទី១៧ដូចគ្នា ឬក៏មានខុសគ្នាបន្តិចបន្តួច។

ប្រភេទអក្សរសិល្ប៍ប្រជាប្រិយទាំងពីរនេះ ជាកម្រងអក្សរសិល្ប៍ដ៏មានតម្លៃសម្រាប់ការសិក្សារបស់អ្នកអក្សរសាស្ត្រជាតិ។ វាជាតម្លៃដ៏ពិសិដ្ឋមួយដែលបុរាណបានចងក្រងឡើង ប្រកបដោយទេពកោសល្យដ៏ពិសេស។ សូមមិត្តអ្នកអាន ធ្វើការសិក្សាជាមួយគ្នាដូចតទៅៈ

## សាស្ត្រារឿង ខ្យងស័ង្ខ

ជាប្រភេទសាស្ត្រាល្បែងកើតឡើងនៅសតវត្សទី១៧ ប្រមាណជាឆ្នាំ១៧២៩ សរសេរជាកំណាព្យសុទ្ធពីដើមដល់ចប់ តែនៅពេលនេះ ខ្ញុំសម្រង់សេចក្តីសង្ខេបជាពាក្យពេជដូចតទៅៈ

"នៅសោឡសមហានគរ សោយរាជសម្បត្តិដោយព្រះបាទយសវិមលរាជ។ ព្រះអង្គមានមហេសីពីព្រះអង្គ។ មហេសីទី១មានព្រះនាមចន្ទទេវី និងមហេសីទី២ព្រះនាមនាងចន្ទា។ មហេសីទាំងពីនេះពុំមានបុត្តដូចគ្នា ក៏ធ្វើពិធីសុំបុត្រ។

អាស្រ័យដោយនាងចន្ទទេវីប្រឹងធ្វើបុណ្យ រក្សាសីល ព្រះឥន្ទ្រក៏បានទៅយាងព្រះពោធិសត្វឲ្យមកចាប់បដិសន្ធិនៅផ្ទៃនាង។ ចំណែក

នាងធន្នាពុំបានរក្សាសីលអ្វីសោះ នាងបានត្រឹមតែបូជាផ្កា ម្ទូស្វា ដល់ដើមព្រះជ្រៃ ទើបបានជាទេពធីតារក្សាដើមព្រះជ្រៃយាងមកចាប់បដិសន្ធិនៅក្នុងផ្ទៃនាង។

នៅយប់ដែលព្រះពោធិសត្វយាងមកចាប់បដិសន្ធិនៅក្នុងផ្ទៃនាងចន្ទទេវី នាងបានយោសប្តិឃើញពហូពាំព្រះចន្ទមកថ្វាយព្រះនាង។ ព្រះនាងស្រវាចាប់ព្រះចន្ទ្រភ្លឺថ្លាក៏ក្លាយជាស្រអាប់ទៅវិញហើយបាត់នៅក្នុងដៃនាង។ ទើងបព្រឹកឡើង នាងបានយកដំណឹងនេះមកទូលព្រះបាទយសវិមលរាជ។ ព្រះអង្គបានហៅហោរមកគន់គូរទើបមានសេចក្តីថាព្រះនាងនឹងមានព្រះរាជបុត្រាមួយ ព្រះអង្គមានរូបឆោមលោមពណ៌ល្អណាស់ ព្រមទាំងមានអំណាចចេស្តានឹងបានឡើងសោយរាជស្នងព្រះបិតា។ នៅពេលដែលពុទ្ធទំនាយនេះ នាងធន្នាមានសេចក្តីច្រណែនក៏បានទៅរកគ្រូស្នេហ៍យាយស្នេធា មកសែកឲ្យតែព្រះបាទយសវិមលរាជស្រឡាញ់តែនាង ទើបបាននាងអុជអាលស្តេចឲ្យដេញនាងចន្ទទេវីចេញពីព្រះរាជវាំងទៅនៅក្នុងព្រៃ។

ព្រះនាងចន្ទទេវីក៏បនាចេញពីវាំង ហើយត្រូវបានយាយចាស់ម្នាក់នៅព្រៃជួយយកអាសារ។ នាងនៅជាមួយដូនចាស់នោះ រហូតដល់ប្រសូត្របានស័ង្ខមួយ ទើបបានដាក់ព្រះនាមថា "ខ្យងស័ង្ខ" ចំណែកនាងធន្នាវិញ ក៏បានប្រសូត្របានបុត្រីមួយអង្គ ក៏បានដាក់ព្រះនាមថា "ធន្នី"។

លុះអាយុបានបីឆ្នាំ នៅពេលដែលនាងចន្ទទេវីចេញទៅរកឱសក្នុងព្រៃ ខ្យងស័ង្ខតែងតែចេញមកពីក្នុងស្រោមជួយធ្វើការម្តាយជាប្រក្រតី ។ បញ្ហានេះបណ្តាលឲ្យនាងចន្ទទេវីមានកាមន្ទិលសង្ស័យជាខ្លាំងទើបបានជានៅថ្ងៃមួយ នាងបានប្រើល្បិចជាហាលស្ទូវរួចចេញទៅក្រៅខ្យងស័ង្ខនឹកស្មានថា ម្តាយទៅបាត់ក៏ចេញពីក្នុងស្រោមមកជួយដេញមាន់។

ព្រះនាងបានឃើញបុត្តមានរូបឆោមលោមពណ៌ល្អ ក៏ស្ទុះចេញមកពីកន្ទេងដែលបានពួនមកចាប់ឱបបុត្ត ទើបព្រះនាងបានវាយកម្ទេចស្រោមខ្យងនោះចេញ។ ក្រោយមក អាណាប្រជានុរាស្ត្រទាំងឡាយបានដឹងថា ព្រះនាងជាអតីតអគ្គមហាសីព្រះរាជាក៏នាំគ្នានាំដង្វាយមកថ្វាយទ្រង់ជាហូរហែរ។

ចំណែកនាងឆន្ទា ដែលបានដឹងដំណឹងនេះ ព្រះនាងមិនសប្បាយព្រះទ័យទេក៏នាំដំណឹងនេះទៅកាឡៃថ្វាយព្រះរាជាថា ព្រះនាងចន្ទទេវីមានសហាយ ទើបទូលស្តេចឲ្យយកខ្យងស័ង្ខទៅពិឃាតចោល។ ស្តេចយសវិមលរាជ ក៏បញ្ជាឲ្យពេជ្ឈឃាតយកខ្យស័ង្ខទៅសម្លាប់ចោលមួយរំពេច។ ពេជ្ឈឃាតយកអាវុធកាប់ខ្យងស័ង្ខ តែគួរឲ្យអស្ចារ្យណាស់អាវុធទាំងនោះក៏ប្រែជាអាហារសម្រាប់ព្រះអង្គទៅវិញ។ ពេជ្ឈឃាតក៏ខ្លាចថ្វាយបង្គំព្រះពោធិសត្វ។ ព្រះមហាក្សត្រក៏បញ្ជាឲ្យគេយកព្រះអង្គចងផ្អោបជាមួយថ្ម រួចក៏យកទៅពន្លិចទៅទឹកសមុទ្រ។ ព្រះនាងចន្ទទេវីមិនឃើញបុត្រអណ្តែតស្មានតែសុគតព្រះនាងក៏ទួញសោកជាខ្លាំង។

ខណៈនោះខ្យងស័ង្ខ បានលិចទៅដល់ឋានបាតាលដែលសោយរាជដោយស្តេចកុជង្គនាគ ព្រះអង្គក៏បាននិម្មិតជាផ្កាឈូកមាសមួយមកទ្រខ្យងស័ង្ខ នឹងទទួលព្រះអង្គជាបុត្រចិញ្ចឹម។ ខ្យងស័ង្ខមិនអាចរស់នៅឋាននាគបាន ទើបស្តេចកុជង្គនាគបានបញ្ជូនព្រះអង្គមកឋានមនុស្សលោកតាមសំពៅមាសមានភោជនអាហារគ្រប់បែបយ៉ាង ដោយព្រះអង្គបានអធិដ្ឋានថា "បើខ្យងស័ង្ខជាសព្វញ្ញូ សូមឲ្យសំពៅអណ្តែតទៅដល់នគរតាវ៉ែ ហើយយក្ខិនី ពន្ធុរសជាមហាក្សត្រីនៅនគរនោះ ចិញ្ចឹមថែរក្សាជាបុត្រ"។

រយៈពេលជាច្រើនខែកន្លងមក សំពៅមាសក៏បានមកដល់នគរ

នេះ ទើបព្រះនាងយក្ខិនីពន្ធរសបានចិញ្ចឹមថែរក្សាខ្យងស័ង្ខទុកជាបុត្រ ចិញ្ចឹម។ គ្រាដំបូង ព្រះនាងក៏បានធ្វើពិធីហៅព្រលឹងខ្យងស័ង្ខដើម្បីឲ្យ ខ្យងស័ង្ខមានឋាមភាពឡើងវិញ។

ថ្ងៃមួយព្រះនាងពន្ធរស បានលាបុត្រទៅព្រៃដើម្បីទៅរកអាហារ មុនពេលព្រះនាងទៅ ក៏ហាមប្រាមបុត្រមិនឲ្យទៅស្រះមាសស្រះប្រាក់ ដែលជាស្រះព្រលឹងរបស់ព្រះស្វាមីខ្លួនឲ្យសោះ។

កាលខ្យងស័ង្ខនៅជាមួយពន្ធរស ខ្លួនមិនបានដឹងថា ព្រះនាងគឺ ជាយក្សស៊ីសាច់មនុស្សទេ លុះកាលបានដឹងក៏រត់ចេញពីនគរនោះ គ្រា ដែលព្រះនាងពន្ធរសទៅរកស៊ីនៅព្រៃ។

លុះព្រះនាងពន្ធរសត្រលប់មកវិញ មិនឃើញបុត្រ ព្រះនាងក៏ ហោះតាមរក។ ពេលជួបជាមួយខ្យងស័ង្ខ ព្រះនាងបានអង្វរបុត្រទៅ នគរវិញ តែខ្យងស័ង្ខមិនព្រមទៅ ទើបព្រះនាងបានប្រាប់ពីអាថ៌កំបាំង វត្ថុសក្តិសិទ្ធទាំងបី គឺស្រោមជើងជាអាវក្រោះការពារអាវុធគ្រប់ប្រភេទ ច្រត់អាចហោះហើរលើអាកាសដល់ចក្រវាឡតែមួយពព្រិចភ្នែក ចំណែ ក ស្បែកជើងកែវ អាចដើរលើទឹកបាន។ ជាចុងក្រោយ ព្រះនាងក៏បាន បង្រៀនដល់បុត្រពីវិជ្ជាដែលអាចកោះហៅត្រី សត្វនានា និងសម្បត្តិកែវ កងផ្សេងៗបាន។ បន្ទាប់ពីនោះមក ព្រះនាងក៏បានសោយទីវង្គត់ទៅ។ ខ្យងស័ង្ខក៏បានចាត់ចែងព្រះសពមាតាទៅតាមប្រពៃណី។ បន្ទាប់ពីនោះ ព្រះអង្គក៏បានពាក់ស្រោមជើង ធ្វើដំណើរតទៅទៀត។

និយាយពីព្រះបាទសាមល សោយរាជសម្បត្តិនៅសាមលនគរ មានអគ្គមហេសីសាមលទេវីដែលមានបុត្រី ៧អង្គប្រកបដោយរូបឆោម

ល្អណាស់។ ថ្ងៃមួយព្រះអង្គក៏បានប្រកាសរើសស្វាមីសម្រាប់បុត្រីគ្រប់អង្គ ដោយបានផ្ញើសារទៅនគរចំណុះ១០១នគរឲ្យនាំបុត្រាមក។ បងៗពៅរើសបានម្នាក់មួយៗគ្រប់អង្គ ប៉ុន្តែនាងពៅរើសមិនបានសោះ ទើបរាជអាមាត្រយកម៉េះមកឲ្យព្រះនាងរើស។ ខ្យងស័ង្ខដែលពាក់ម៉េះបានអធិដ្ឋានថា " បើនាងពៅពិតជាគូពីបុព្វេមែន សូមឲ្យនាងមើលឃើញពីរូបពិតខ្លួននៅស្រោមម៉េះនេះ"។ បន្ទាប់ពីនោះមក នាងពៅក៏បានមើលឃើញរូបពិតរបស់ម៉េះ ទើបបានជាព្រះនាងរើសយកម៉េះជាស្វាមីដែលបណ្តាលឲ្យអ្នកចំណុះនគរសើចចំអកព្រះអង្គ។ ព្រះរាជាក៏បានបណ្តេញនាងពៅឲ្យចេញទៅក្រៅនគរ។

ក្នុងការរួមរស់ជាមួយគ្នា ម៉េះបានដោះស្រោមចេញមកផ្ទុំជាមួយនាងពៅតែពេលរាត្រី។ យប់មួយ នាងពៅបានលួចយកស្រោមនេះទៅដុតចោលតែដុតមិនឆេះ ទើបពីពេលនោះមក ខ្យងស័ង្ខបានពាក់ម៉េះលែងដោះចេញរហូត។

បន្ទាប់ពីរកល្បិចចាប់ទោសម៉េះមិនបាន ព្រះបាទសាមល បានឲ្យម៉េះមកលេងឃ្លីកូនគោលដោយត្រូវមានសម្លៀកបំពាក់ល្អ នឹងត្រូវមានរូបរាងល្អដែរ។ នាងពៅបានអង្វរប្តីឲ្យដោះស្រោមម៉េះចេញ តែម៉េះមិនព្រម នាងពៅយំរហូតស្លាប់ទៅ ជាហេតុនាំឲ្យព្រះឥន្ទប្រើព្រះពិស្ណុការឲ្យទៅទូលស្តេចសាមល ឲ្យមកលេងឃ្លីកូនគោលជាមួយព្រះអង្គដោយភ្នាក់ដាក់នគរ។ ស្តេចយល់ព្រម ហើយព្រះទេពីក៏ទៅរកម៉េះឲ្យមកជួយបិតាក្មេក។ ពេលព្រះនាងយាងទៅដល់ ក៏ឃើញបុត្រីស្លាប់។ ម៉េះក៏បានប្រស់នាងឲ្យរស់ឡើងវិញ នឹងបានយល់ព្រមថាទៅលេងឃ្លីកូនគោលជាមួយព្រះឥន្ទ។ ព្រះបាទសាមលចាំយូរពេកក៏បានយាងមកតាម គាប់ជួនជាពេលនោះបានឃើញរូបពិតស័ង្ខសិល្ប៍ជ័យល្អស្អាត

ស្តេចក៏បានទៅចាប់ឱបផ្ដោះ ហើយសន្យាថា នឹងលើករាជថ្វាយ ព្រម ទាំងតែងតាំងនាងរចនាទេវីមានយសសក្តិខ្ពស់ជាងបងទាំង៦អង្គ។

ចំណែកនៅនគរស្តេចយសវិមលរាជ កាលរាត្រីមួយព្រះអង្គបាន យោសប្តិឃើញព្រះឥន្ទចុះមកពីឋានត្រៃត្រឹង្ស ព្រមដោយមានកាន់ ដំបងមួយធំប៉ុនគល់ត្នោតហើយបំភ័យព្រះអង្គថា បើព្រះអង្គមិនទៅ យកព្រះនាងចន្ទទេវីជាអតីតមហេសីមកវិញទេ ព្រះឥន្ទនឹងសម្លាប់ព្រះ អង្គ។ ព្រឹកឡើង ព្រះអង្គក៏បានចាត់មន្ត្រីឲ្យដើររកអតីតមហេសីព្រះអង្គ វិញ ហើយបានឃើញព្រមទាំងបានបានយាងមកវាំង។ ព្រះនាងបាន ដើរឆ្លងកាត់ភ្លើងបញ្ជាក់ពីសេចក្តីបរិសុទ្ធ។ ព្រះយសវិមលរាជ ព្រះអង្គ យល់ថា ត្រូវស្នេហ៍នាងឆន្ទា ក៏បញ្ជាឲ្យទាហានចាប់នាងឆន្ទា និងយាយ ស្មេជាយកទៅសម្លាប់។

បន្ទាប់ពីនោះមក ព្រះបាទយសវិមលរាជ និងព្រះនាងចន្ទទេវីក៏ បានយាងទៅរកខ្យងស័ង្ខកុមារ។ បន្ទាប់ពីបានបោះជំរុំនៅក្រៅនគរ ហើយ ព្រះអង្គទាំងពីរក៏បានធ្វើដំណើរទៅរកបុត្រាជាបន្ត។ នាងចន្ទទេវី ក៏បានក្លែងក្លាយខ្លួនជារាស្ត្រ សាមញ្ញចូលទៅបម្រើការជាចុងភៅស្តេច។ បន្ទាប់មកព្រះនាង បានចិត្តបន្លែធ្វើម្ហូបដោយបានឆ្លាក់ជារឿងតាម ដំណើរដែលបានបែក ពីបុត្រពីដើមដល់ចប់។ខ្យងស័ង្ខឃើញយល់សេច ក្តី រួចក៏បានជួបជាមួយមាតានិងបិតាវិញ។

ក្នុងគ្រាដែលព្រះអង្គបានយាងមកសោយរាជ្យនៅនគរព្រះបាទ យសវិមលរាជ ព្រះអង្គក៏បាន រៀបអភិសេកជាមួយនាងឆន្ទីដោយទុក នាងជាព្រះជយាទីពីរ។ ខ្យងស័ង្ខកុមារបានសោយរាជដោយទទួលនាម ហៅថា "ព្រះបរមឧត្តមពោធិសត្វ" ទ្រង់គ្រងរាជនគរពីរប្រកបដោយទស

ពិធរាជធម៌។ ក្រោយមកព្រះនាងរចនាទេវីជាអគ្គមហេសីដើមបានប្រសូតបានបុត្រាមួយព្រះនាមថា "សុវណ្ណកុមារ" ចំណែកនាងសុវណ្ណរាជធីតាបានប្រសូត្របុត្រីមួយមាននាមថា "សុវណ្ណទេវី"។

១៦ឆ្នាំកន្លងមកទៀត ឲ្យស័ង្ខបានរៀបការកូនទាំងពីរហើយបានប្រគល់រាជសម្បត្តិឲ្យគ្រប់គ្រងនៅសោឡសមហានគរ។ លុះពេលដែលព្រះអង្គសោយទីវង្គត់ទៅ ព្រះអង្គបានទៅឋានសួគ៌ជួបជុំអគ្គមហេសីនិងព្រះមាតាបិតា។

## សាស្ត្ររឿង សង្ខសិល្ប៍ជ័យ

នៅនគរបញ្ចាលបុរីមានព្រះបាទកុត្តរាជ ជាស្តេចសោយរាជ្យ។ ទ្រង់មានមហេសីមួយអង្គ គឺព្រះនាងសុមន្ទា ដែលមានព្រះរាជបុត្រច្បងព្រះនាមសេនាកុត្តរាជ និងព្រះរាជបុត្រីព្រះនាមកេសរសុមន្ទា។ លុះព្រះបាទកុត្តរាជ ជាមហាក្សត្រឡើងគ្រងរាជ្យ ហើយព្រះបាទសេនាកុត្តរាជទ្រង់ឲ្យហោរាទាយជតារាសីឲ្យព្រះនាងកេសរសុមន្ទា ជាព្រះរាជកនិដ្ឋា កាលនោះតាហោបានទាយថា ព្រះនាងមានព្រះជន្ម១៥ព្រះវស្សា នឹងមានយក្ស១មកចាប់យកទៅធ្វើជាប្រពន្ធ។

អំឡុងក្រោយមក គម្រប់អាយុ១៥វស្សា ថ្ងៃមួយព្រះនាងកេសរសុមន្ទា មានក្តីអផ្សុកជាខ្លាំងក្នុងព្រះកាយ ក៏បានទៅសុំរាជាអនុញ្ញាតព្រះរាមចេញទៅក្រសាលនៅសួន។ ព្រះរាមបានឃាត់ណាស់ដែរ ព្រោះជាឆ្នាំត្រូវគ្រោះនាង តែព្រះនាងពុំស្តាប់ ទើបព្រះអង្គសម្រេចជូនព្រះរាជកនិដ្ឋាដោយមានពលជាច្រើនអមទៅជាមួយ។

នៅពេលកំពុងតែក្រសាលនោះ ស្រាប់តែយក្សមួយក្បាលជាយក្សកម្លោះមានឈ្មោះថា កុម្ភណ្ឌដែលជាស្តេចយក្សស្ថិតក្នុងប្រាសាទ

មួយក្នុងព្រៃហេមពាន្តក៏បានចេញមកកម្សាន្តព្រៃដែរ ហើយក៏បានឃើញនាងកេសរសុមន្ទាក៏កើតសេចក្តីស្រឡាញ់ ទើបយក្សនោះបានប្រែកាឡាខ្លួនធ្វើជាមនុស្សធម្មតា ទៅបន្ទំជាមួយរាជបរិពារទើបមានឱកាសចាប់ព្រះនាងយកទៅនគររាបានភ្នាម។

ហេតុតែនិស្ស័យកម្មជាមួយយក្ស បន្ទាប់ពីបានយក្សចាប់មកដល់នគរហើយ យក្សក៏តែងតែយកចិត្តទុកដាក់ជាមួយព្រះនាងគ្រប់ពេលវេលា គេតាមយកចិត្តទុកដាក់ជាមួយព្រះនាងណាស់ ទើបបានជាព្រះនាងបែរជាមានសេចក្តីស្នេហាជាមួយយក្សវិញដែរ។ នៅថ្ងៃមួយ កុម្ភណ្ឌបានលានាងកេសរសុមន្ទាទៅគាល់ព្រះនាពយណ៍ ព្រមជាមួយការរៀបរាប់ពីដំណឹងល្អដែលខ្លួនរកបានភរិយាមួយប្រាប់ព្រះអង្គ ទើបព្រះនាពយណ៍បានប្រទានស្បៃមួយជាចំណងដៃ។

នៅជាមួយគ្នាមិនបានប៉ុន្មាន ព្រះនាងកេសរសុមន្ទាក៏ប្រសូត្របានបុត្រីមួយព្រះអង្គ ហើយបានដាក់ព្រះនាមថា សុពណ៌ទេវី។ ក្រោយមកព្រះនាងសុពណ៌ទេវី ក៏បានទៅទៅជាភរិយាស្តេចកុជង្គនាគដោយសារតែយក្សជាបិតាភ្នាល់ល្បែងបាស្កាចាញ់។

នៅនគរបញ្ចាលបុរី ព្រះបាទកុត្តរាជបន្ទាប់ពីបុត្រីនាងកេសរសុមន្ទាត្រូវបានយក្សកុម្ភណ្ឌចាប់បាត់ទៅ ព្រះអង្គក៏បានចាត់ឲ្យពលទាហានតាមរកណាស់ដែរ តែគ្មានដំណឹងទាល់តែសោះ ទើបព្រះអង្គទ្រង់ខកព្រះទ័យ លះបង់រាជសម្បត្តិចេញទៅសាងផ្នួសនៅវត្តមួយ។

ថ្ងៃមួយអ្នកស្រុកនិគ្រោតគ្រាម ដែលមានដូនចាស់មួយបាននាំបុត្រីទាំង៧នាក់ ទៅបេះផ្កាថ្វាយព្រះពុទ្ធរូបនៅវត្តដែលព្រះបាទកុត្តរាជគង់នៅ។ ព្រះរាជាទតឃើញក៏មានសេចក្តីប្រតិព័ទ្ធ។ លុះពេលនាងទាំង

៧ត្រលប់ទៅផ្ទះវិញ ព្រះរាជាក៏បានលាចាកសិក្ខាបទ ទើបបានយាងទៅស្រុកនិគ្រោធគ្រាមសុំដណ្ដឹងនាងទាំង៧នាក់ជាភរិយា មកអភិសេកជាមហេសី។

បន្ទាប់ពីនោះមិនបានប៉ុន្មាន នាងបងៗទាំង៦នាក់ប្រសូតបានបុត្រប្រុសម្នាក់មួយព្រមគ្នាក្នុងថ្ងៃតែមួយ។

នៅបន្ទាប់ពីនោះមក នាងកេសរបុប្ផាជាស្នំឯកបានប្រសូតបុត្តមួយជាសត្វរាជសីហ៍។ ចំណែកនាងបុទុមាជាប្អូនពៅនាងទាំង៦ ក៏បានប្រសូតបុត្រប្រុសមួយដែលមានដៃម្ខាងកាន់ធ្នូសិល្ប៍ ដៃម្ខាងកាន់ខ្យងស័ង្ខ ទើបបានដាក់ព្រះនាមថា "ស័ង្ខសិល្ប៍ជ័យ"។

បន្ទាប់ពីស័ង្ខសិល្ប៍ជ័យប្រសូតមក ព្រះរាជាបានឲ្យហោរាគន់គូរពីជោគវាសនានគរ។ ហោរាបានទទួលសំណូកពីព្រះនាងបងៗទាំង៦អង្គ ក៏បានទាយបង្វែរថា ហេតុភេទនេះជាឧត្បាទចង្រៃដល់ព្រះនគរណាស់ ពិសេសគឺអាចនាំទោសទុក្ខដល់ព្រះរាជាដែរ។ ហេតុដូច្នេះ ព្រះនាងជាបងៗ រួមគ្នាជាមួយតាហោរ បានទូលព្រះបាទកុត្តរាជឲ្យបំបរបង់នាងចេញពីនគរ។

ដោយសារហេតុនេះហើយ ទើបបានជាព្រះរាជាធ្វើការនិរទេសព្រះនាងបទុមា ព្រះនាងកេសរបុប្ផា រួមជាមួយរាជសីហ៍ និងស័ង្ខសិល្ប៍ជ័យចេញពីព្រះរាជវាំងឲ្យទៅរស់នៅក្នុងព្រៃ។ ដោយហេតុតែព្រះរាជកុមារស័ង្ខសិល្ប៍ជ័យមានជាតិជាពោធិសត្វ ទើបបានជាព្រះឥន្ទចាត់ព្រះពិស្ណុការមកសង់ប្រាសាទដែលមានកំពែងការពារជុំវិញថ្វាយ។ ចាប់តាំងពីពេលនោះមក ព្រះស័ង្ខសិល្ប៍ជ័យ បានរួមរស់ជាមួយព្រះមាតាបានសុខសប្បាយរហូតមក។ ប្រាសាទដែលព្រះឥន្ទចាត់ព្រះពិស្ណុការមកសាងថ្វាយនោះមានឈ្មោះថា "ប្រាសាទពិស្ណុនគរ"។

ព្រះនាងដែលជាបង។ លុះវេលាក្រោយមក ក៏បានដឹងដំណឹងថា ព្រះនាងបុទុមា និងព្រះនាងកេសរបុប្ផា ព្រមជាមួយបុត្រមិនទាន់ស្លាប់ ថែមទាំងរស់នៅក្នុងប្រាសាទដ៏ស្កឹមស្កៃទៀតនោះ ក៏បានរិះរកមធ្យោបាយសម្លាប់ជាបន្ត។ ដំបូងគេឲ្យបុត្រគេទាំង៦អង្គយកនំចំណីទៅថ្វាយ ស័ង្ខសិល្បជ័យដែលមានបង្កប់ថ្នាំពុល តែស័ង្ខសិល្បជ័យមិនបានសោយទេ។

លុះវេលាក្រោយមកទៀតព្រះនាងទាំង៦អង្គ បានយាងមកគាល់ព្រះបាទកុត្តរាជ រួចរាជាអនុញ្ញាតសុំព្រះអង្គប្រទានរាជសម្បត្តិឲ្យមកកូនរបស់ខ្លួន ទើបបានព្រះបាទកុត្តរាជទ្រង់មានបន្ទូលឲ្យបុត្រទាំង៦ទៅរកម្រឹគីម្រឹគា និងបក្សាបក្សី មច្ឆាពីភ្នំហេមពាន្តមកថ្វាយព្រះអង្គ។ ការនេះរាជបុត្រទាំង៦បានទៅពឹងស័ង្ខសិល្បជ័យឲ្យជួយ។ ស័ង្ខសិល្បជ័យបានផ្លុំងសរកើតជាសត្វបក្សាបក្សី ម្រឹគីម្រឹគា និងមច្ឆាថ្វាយព្រះរាជកុមារក្លាម ទើបព្រះរាជកុមារយកទៅថ្វាយព្រះបិតា ទើបព្រះអង្គស្គាល់ថាជាស្នាដៃរបស់ស័ង្ខសិល្បជ័យ។

ខណៈដែលរាជកុមារសុំរាជសម្បត្តិ ព្រះបាទកុត្តរាជមានបន្ទូលបន្តទៀតថា រាជកុមារទាំង៦ទៅរំដោះព្រះនាងកេសរសុមន្ទាជាម្តាយមីងទើបអាចសោយរាជសម្បត្តិបាន។ ព្រះរាជកុមារទាំង៦ក៏បានទៅពឹងខ្យងស័ង្ខកុមារឲ្យជួយក្នុងការកិច្ចនេះ។ ខ្យងស័ង្ខកុមារ បានសម្រេចចិត្តជួយបងដោយឥតមានចិត្តអស់អែកបន្តិចសោះ។ ក្នុងដំណើរយាងទៅរំដោះព្រះមាតុច្ឆា ខ្យងស័ង្ខកុមារបានកម្ចាត់បិសាច ព្រាយមាយា ឥតមាននរណាជាមារមកទប់ទល់បានឡើយ។

លុះធ្វើដំណើរទៅជិតដល់ ព្រះអង្គក៏បានទុកបង់ៗរបស់ខ្លួនឲ្យនៅចាំក្បែរស្ទឹងមួយធំៗ ចំណែកខ្លួន ក៏បានជិះស័ង្ខទៅស៊ើបការណ៍រកនគរយក្សកុម្ភណ្ឌ។ គាប់ជួនជាពេលទៅដល់តាមរយៈការបំភ្លឺផ្លូវពីសំណាក់ទេវតា ក៏បានដឹង នឹងស្គាល់នគរយក្សកុម្ភណ្ឌនេះ ទៃពេលនោះយក្ស វាបាចេញទៅក្រៅបាត់ទៅហើយ ទើបព្រះរាជកុមារមានឱកាសមកជួបព្រះមាតុច្ឆាៗ ជាមួយគ្នានេះដែរ យក្សកុម្ភណ្ឌដែលចេញទៅរកអាហារថ្ងៃនេះក៏ស្រាប់តែមានអាក្ការៈឈឺក្បាល ចុកពោះ ដើរជ្រុលជ្រកទៅតាមព្រៃ ខំត្រដរដើរត្រលប់មកកាន់ប្រាសាទវិញនឹងដេកលក់ទៅ។ ព្រះរាជកុមារ បាននិយាយរៀបរាប់ពីប្រវត្តិការណ៍ចប់សព្វគ្រប់ រួចឆ្លៀតឱកាសដែលយក្សកំពុងតែដេកលក់ ខ្លួនក៏បាននាំព្រះមាតុច្ឆារត់គេចបាត់ទៅ។

មកដល់ពាក់កណ្ដាលផ្លូវ ស័ង្ខសិល្បជ័យក៏បានទុកព្រះមាតុច្ឆាឲ្យគង់នៅគុហាកែវមួយ រួចខ្លួនក៏បានត្រលប់ទៅសម្លាប់យក្សកុម្ភណ្ឌវិញ។ ការប្រយុទ្ធគ្នារវាងស័ង្ខសិល្បជ័យជាមួយយក្សកុម្ភណ្ឌ គឺមិនមែនជាការងាយណាស់ណាទេ ពីព្រោះយក្សនេះមានជីវិតដល់ទៅ១០០ សម្លាប់រួចក៏ត្រូវកើតឡើងវិញជាបន្តបន្ទាប់។ លុះសម្លាប់ច្រើនលើកច្រើនគ្រាហើយ ស័ង្ខសិល្បជ័យ ក៏បានត្រឡប់មកជួបជាមួយព្រះមាតុច្ឆាវិញ។ ក្រោយមកបានបន្តិច កុម្ភណ្ឌក៏កើតឡើងវិញ រួចក៏បានបង្កទ័ពជាច្រើនតាមមកប្រយុទ្ធជាមួយស័ង្ខសិល្បជ័យ។ បន្ទាប់ពីបានប្រយុទ្ធជាមួយគ្នាអស់ជាយូរណាស់មកហើយ កុម្ភណ្ឌក៏ត្រូវស័ង្ខសិល្បជ័យសម្លាប់ជាច្រើនលើកទៀត។ នៅដំណាក់ចុងក្រោយ កុម្ភណ្ឌក៏ត្រូវស័ង្ខសិល្បជ័យសម្លាប់បានជាស្ថាពរ។ នៅដំណាក់កាលចុងក្រោយ រាជកុមារឃើញព្រះមាតុច្ឆាយំ

សោកនៅចំពោះកុម្ភណ្ឌ។ ឃើញដូច្នេះ រាជកុមារក៏ផ្ទៃងសរកលតជាប្រាសាទមួយសម្រាប់បញ្ចុះសពកុម្ភណ្ឌដើម្បីកុំឲ្យមានពៀរតទៅទៀត។

បន្ទាប់ពីនោះមក ព្រះមាតុច្ឆាព្រះអង្គក៏បានសំណូមពរព្រះស័ង្ខសិល្ប៍ជ័យឲ្យទៅជួយរំដោះនាងសុពណ៌ទេវី ពីឋានកុជង្គនាគមកសិន។ ព្រះរាជកុមារ ក៏បានលាព្រះមាតុច្ឆាត្រលប់ទៅឋានកុជង្គនាគ ដោយឲ្យព្រះនាងគង់ចាំនៅក្រោមកល្បព្រឹក្ស។ បន្ទាប់ពីបានច្បាំងឈ្នះនាគ ព្រះរាជកុមារក៏បាននាំនាងសុពណ៌ទេវីត្រលប់មកជួបព្រះមាតុច្ឆាវិញ ។

លុះពេលបានមកជួបជាមួយព្រះរាមទាំង៦អង្គ ស្តេចនោះក៏កើតមានគំនិតអាក្រក់ ដោយគេបានល្បួងស័ង្ខសិល្ប៍ជ័យទៅបេះផ្កា ព្រមទាំងនិយាយលួងលោមព្រះរាជកុមារទុករាជសីហ៍ និងស័ង្ខ ព្រមទាំងធ្នូសិល្ប៍ទើបបាននាំព្រះអង្គទៅច្រានទម្លាក់ទៅក្នុងជ្រោះភ្នំ ព្រមទាំងបាននាំគ្នាលើកថ្មមកបាំងបិទសន្ធាប់។ បន្ទាប់ពីនោះមក គេក៏បានមកនិយាយកុហក់ព្រះនាងសុមន្ទាថា ស័ង្ខសិល្ប៍ជ័យធ្លាក់ទៅជ្រោះភ្នំស្លាប់បាត់ទៅហើយ។

នៅពេលឮដំណឹងដូច្នេះ ព្រះនាងព្រះកន្សែងជាខ្លាំង ទើបព្រះនាងយកព្រះសុកក័ដែលបានមកពីព្រះឥសូរ ចំណែកព្រះនាងសុពណ៌ទេវី ក៏បានយកស្បៀតសក់បានមកពីកុម្ភកណ្ឌ រួចពីនាក់ម្តាយកូនក៏ផ្សងថា ប្រសិនណាជាស័ង្ខសិល្ប៍ជ័យនៅរស់ សូមឲ្យមានគេយកស្បៃ និងស្បៀតសក់នេះមកជូនព្រះនាងនៅស្រុក ប្រសិនណាជាគេស្លាប់ ក៏សូមឲ្យបាត់ស្លាត់ទៅចុះ។

ស្តេចពាលទាំង៦អង្គ ក៏បានចាប់បង្ខំព្រះនាងទាំងពីឱរយកទៅនគរវិញជាបន្ទាន់។

និយាយពីពជសីហ៍វិញ កាលបើបាត់ស័ង្ខសិល្បជ័យពុំឃើញត្រលប់មក គេក៏បានហោះកេសព្វទិសទី តែពុំបានឃើញ ទើបបានជាគេខាំពាំផ្គ ស័ង្ខត្រលប់ទៅព្រះនគរឯពិស្ណុនគរវិញ។ កាលបើដឹងថា បុត្របាត់ខ្លួនហើយ ព្រះនាងកេសរបទុមា កេសរបុប្ផាក៏បាននាំគ្នាដើររកណាស់តែរកពុំឃើញ។ ស័ង្ខសិល្បជ័យជាប់ឃុំនៅជ្រោះនោះ ក៏មាន

សេចក្តីក្តៅក្រហាយដល់ព្រះឥន្ទ ទើបទ្រង់មកបើកថ្មនោះចេញ ទើបបានស្រោចស្រង់ដោយទិព្វវារី ព្រះអង្គក៏មានរូបកាយស្អាតលើសដើម។ បន្ទាប់ពីនោះមក ព្រះឥន្ទក៏បាននាំព្រះអង្គមកជួបព្រះមាតាវិញ។

ចំណែកស្តេចពាលទាំង៦ កាលដែលនាំព្រះនាងសុមន្ទា និងព្រះនាងសុពណ៌ទេវី មកដល់បញ្ចាលនគរ មុនពេលនាំព្រះនាងចូលគាល់ព្រះរាជា គេបានបង្ខំព្រះនាងឲ្យនិយាយថា គេជាអ្នកសម្លាប់យក្សកុម្ភណ្ឌ តែព្រះនាងបែរជាទូលថា ស័ង្ខសិល្បជ័យជាអ្នកសម្លាប់ទៅវិញ។

ស្តេចពាលទាំង៦ កាលបើបានឮដូច្នេះក៏មានបន្ទូលថា ខ្លួនជាអ្នកសម្លាប់ នឹងបានសុំឲ្យព្រះរាជាកុំជឿ។ ដោយមានការប្រកែកប្រណាំងគ្នា ព្រះរាជា ក៏បានមានបន្ទូលថា ប្រសិនណាជាការនិយាយខុសគ្នា រឿងអ្វីក៏ត្រូវបញ្ឈប់ត្រឹមនេះសិន។ ក្រោយមក ក្នុងពេលដែលព្រះបាទសេនាកុត្តរាជកំពុងតែធ្វើពិធីមង្គលចងដៃក្សត្រីទាំងពីព្រះអង្គ ក៏ស្រាប់តែមាននាយសំពៅយកស្បៃ និងស្មៀតសក់មកថ្វាយព្រះនាងវិញ ទើបព្រះនាងបានទូលទៅព្រះរាជាថា មុនពេលដែលព្រះនាងយាងមកកាន់ពជរាំងទ្រង់បានផ្សងថា ប្រសិនណាកូនស័ងសិល្បជ័យនៅរស់មានជីវិត សូមឲ្យមានគេយកស្មៀតសក់ និងស្បៃនេះមកថ្វាយព្រះនាងវិញកុំបីខាន។ ព្រះ

បាទកុត្តរាជ ឮដូច្នោះ ក៏បានយកព្រះនាងទាំងពីរព្រះអង្គទៅទុកនៅប្រាសាទ ជាទីសប្បាយ តែទោះបីជាយ៉ាងនេះក្តី ក៏ព្រះនាងទាំងពីរព្រះអង្គនៅតែមិនបាត់សោយសោកឡើយ។

ឆ្លៀតឱកាសល្អ ស្តេចពាលទាំង៦អង្គ បានទៅទូលព្រះរាជាថា ព្រះនាព្រះកន្សែងនឹកប្តីពេកទៅជាឆ្កួត ក៏សុំឲ្យព្រះរាជាទ្រង់រកមេមត់មកលៀងលោមបរបក់ព្រលឹងទើបបានជាសះស្បើយ។ ព្រះរាជាក៏ទ្រង់បានធ្វើតាម តែព្រះនាងទាំងពីរអង្គមិនព្រមធ្វើតាមសោះ ទោះបីជាមានការបង្ខំយ៉ាងណាក្តី។ ដោយសសេចក្តីនេះ ទើបបានជាព្រះរាជាក៏បានចាត់ឲ្យសេនាអាមាត្រ រៀបចំធ្វើរាជដំណាក់មួយនៅខាងក្រៅវាំង ដើម្បីបានជាទីអាស្រ័យរបស់ព្រះនាងទាំងពីរអង្គ។

មានពេលមួយ ព្រះរាជាទ្រង់យាងទៅកាន់រាជរោង ក្នុងកាលនោះពួកសេវកាមាត្រកំពុងគាល់តគ្រៀបត្រា ក៏ស្រាប់តែមានសត្វជីងចក់មួយក្បាលបានធ្លាក់មកចំព្រះអង្គ ព្រះអង្គក៏បានឲ្យហោរាគន់គូមើល តាហោបានទស្សទាយថា ព្រះអង្គនឹងបានជួបព្រះរាជបុត្រដែលមានឫទ្ធិអស្ចារ្យលើសស្តេចនានាក្នុងជម្ពូទីប។

ហេតុនេះ ព្រះអង្គក៏បានទៅសួព្រះនាងសុមន្ទាពិទីកន្លែងដែលព្រះស័ង្ខសិល្បជ័យរស់នៅ លុះពេលដែលបានដំណឹងហើយ ព្រះអង្គក៏បានយាងទៅជួបជុំបុត្រ និងមហីសីទាំង៥អង្គវិញ។ ព្រហរាជាក៏បានយាងស័ង្ខសិល្បជ័យ ព្រមទាំងកេសរបទុមា និងនាងកេសរបុប្ផាមកបញ្ចាលនគរវិញ ព្រមទាំងបានអភិសេកស័ង្ខសិល្បជ័យជាមួយព្រះនាងសុពណ៌ទេវី ជាព្រះអយអគ្គមហេសី និងព្រះនាងសុរអេមច្ចណាជាបុត្រី

នគរដទៃជាមហេសីបន្ទាប់។ ពិធីដ៏អស្ចារ្យនេះ បានប្រព្រឹត្តទៅអស់រយៈពេល៧យប់ ៧ថ្ងៃ។

បន្ទាប់ពីនោះមក ព្រះបាទសេនាកុត្តរាជ ក៏បានហៅស្តេចពាលទាំង៦មកសួរដេញដោលពីរឿងដែលខ្លួនអួតថា ជាអ្នកបានទៅរំដោះព្រះនាងសុមន្ទា ពីយក្សកុម្ភណ្ឌ និងព្រះនាងសុពណ៌ទេវីពីនាគ។ នៅទីបំផុត រឿងទាំងនេះ ត្រូវបានបែកការ គ្រាដែលព្រះរាជកុមារស័ង្ខសិល្ប៍ជ័យ សុំសាកល្បងឫទ្ធិ ដែលបណ្តាលឲ្យស្តេចពាលទាំង៦មានការបាក់បបខ្ទបខ្ទាច។ ព្រះរាជា ក៏បានបញ្ជាឲ្យពេជ្ឈឃាតយកស្តេចពាលទាំង៦ និងម្តាយរបស់គេទៅសម្លាប់ចោល ក៏ប៉ុន្តែដោយសារតែតាចាស់ដូនចាស់មកសុំទោស ទ្រង់ក៏បានអត់ទោសឲ្យ គ្រាន់តែនិរទេសម្តាយកូននេះ ឲ្យទៅរស់នៅជាមនុស្សសាមញ្ញកំព្រាអនាថាវិញ។

ព្រះស័ង្ខសិល្ប៍ជ័យក៏បានសោយរាជ្យស្នងបិតា បន្ទាប់មកព្រះនាងសុពណ៌ទេវីប្រសូតបានបុត្រាមួយអង្គវិជ័យកុមារ ចំណែកព្រះនាងសុរអេមច្ចណាប្រសូត្បានបុត្រីមួយដាក់ព្រះនាមថា សីលរ័តន៍ទេវី ព្រមទាំងបានអភិសេកបុត្រទាំងពីរជាប្តីប្រពន្ធជាមួយគ្នា រួចព្រះអង្គក៏បានផ្ទេររាជ្យសម្បត្តិឲ្យបុត្រគ្រប់គ្រងនគរបានសុខជាអង្វែងទៅ។

សរុបសេចក្តីមក អក្សរសិល្ប៍សម័យឧដុង្គ គឺជាផ្នែកមួយនៃវណ្ណកម្មដែលមានការរីកចម្រើនណាស់ហើយ បើទោះបីជាមិនទាន់មានការរីកចម្រើនដល់កំពូលក៏ពិតមែន ក៏ប៉ុន្តែបានឈានដល់កម្រិតមួយដែល

អាចទទួលយកបានសម្រាប់ការសិក្សារបស់មនុស្សសម័យនោះ កំដូចជាកម្រងឯកសារយ៉ាងពិសេសសម្រាប់មនុស្សនៅសម័យខាងក្រោយដែរ។

---

## អក្សរសិល្ប៍សម័យអាណានិគមនិយមបារាំង

### ទិដ្ឋភាពទូទៅ អក្សរសិល្ប៍សម័យអាណានិគម

សម័យអាណានិគមនិយមបារាំង ត្រូវបានគិតចាប់ពីខែសីហា ឆ្នាំ១៨៦៣ រហូតដល់ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ តែនៅក្នុងអំឡុងឆ្នាំនេះគឺប្រមាណជា ឆ្នាំ១៩៣៩-១៩៤៥ប្រទេសកម្ពុជាត្រូវស្ថិតនៅក្រោមការត្រួតត្រារបស់ប្រទេសជប៉ុន តាមរយៈសង្គ្រាមលោក លើកទី២ដែលបានជះឥទ្ធិពលមកដល់ប្រទេសខ្មែរ។

នៅអំឡុងជិតមួយសតវត្សនេះ អក្សរសាស្ត្រ អក្សរសិល្ប៍នៃប្រទេសខ្មែរត្រូវបាន រត់ទៅជ្រកពួននៅវត្តអារ៉ាមដែលមានព្រះសង្ឃជា

ប្រធាននៃការថែរក្សាអក្សរសាស្ត្រជាតិទុករហូតមកដល់ សព្វថ្ងៃនេះ ព្រោះតែរយៈកាលនោះ ម្ចាស់អាណានិគមបានបំបិទមិនឲ្យកូនខ្មែរបាន រៀនសូត្រអក្សរសាស្ត្រជាតិខ្លួនបានជ្រៅជ្រះទេ តែអ្វីដែលគេបានដាក់ ជំនួសនោះ ការសិក្សាអក្សរសាស្ត្ររបស់បារាំងទៅវិញ។

ក្នុងទង្វើមួយដើម្បី លុបបំបាត់អក្សរសាស្ត្រដួងព្រលឹងខ្មែរ រដ្ឋាភិបាលបារាំង បានអនុវត្តគោល នយោបាយមួយចំនួនដូចជា៖

-គេបានដាក់ទីប្រឹក្សាអមព្រះមហាក្សត្រខ្មែរ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង។ អ្វីដែលគួរឲ្យឈឺចាប់បំផុតនោះ គឺគេបាន ប្រមូលឯកសារ ឬជារបស់មានតម្លៃដូចជាចម្លាក់ ជាដើមយកទៅស្រុកវា ហើយថែមទាំងបានបង្ហាត់ពង្វក់ឲ្យកូនខ្មែរស្អប់វប្បធម៌ជាតិខ្លួនថែមទៀតផង។

-ក្នុងវិស័យសិក្សាអប់រំ បារាំងបានកសាងសាលាជាច្រើនតែសម្បូរតែនៅទីក្រុងប៉ុណ្ណោះ។ បារាំងបានផ្សាយមនោគមវិជ្ជាជាលក្ខណៈអក្សរសាស្ត្រថា អក្សរសាស្ត្រខ្មែរគ្មានតម្លៃដូចជាអក្សរសាស្ត្របារាំងទេ ដូច្នេះនៅសម័យនោះ អក្សរនិងភាសាដែលគេនិយមប្រើជាផ្លូវការគឺភាសាបារាំង ចំណែកអក្សរសាស្ត្រខ្មែរ ត្រូវបានគៀសខ្លួនទៅជ្រកពួននៅវត្តព្រះពុទ្ធសាសនា ដែលមានព្រះសង្ឃគ្រប់អង្គជាអ្នកមើលការខុសត្រូវ។ ក្រោយមកទៀត រាជការបារាំងក៏បានបង្កើតពុទ្ធសាសនបណ្ឌិត្យដែលជាទីប្រមូលផ្ដុំអ្នកប្រាជ្ញអក្សរសាស្ត្រជាតិខ្មែរ។ ការបង្កើតនេះ ប្រសិនណាជាមើលពីសម្បកក្រៅទៅ គឺហាក់ដូចជាក្នុងគោលបំណងបម្រើផលប្រយោជន៍ខ្មែរ តែផ្ទុយទៅវិញ ប្រយោជន៍ដែលបានមក គឺដើម្បីបំពេញមហិច្ឆតារបស់ម្ចាស់អាណានិគមប៉ុណ្ណោះ។

នៅក្នុងវណ្ណកម្មអក្សរសល្ប៍វិញ ដោយសារតែឥទ្ធិពលនៃ វប្បធម៌ពាលាដែលបារាំងបានសាបព្រោះពង្វក់ខួរក្បាលខ្មែរនេះ ហើយបានបង្កជាចលាចលមួយ នៅក្នុងសង្គមអក្សរសិល្ប៍ជាតិ។ បារាំងបានបណ្ដុះនិងបង្ហំកូនខ្មែរ ជាលក្ខណៈចំហរក្នុងគោលបំណងឲ្យកូនខ្មែរចេះស្អប់

ជាតិខ្លួន ហើយចាត់ទុកបារាំងជាទេវតាជាអ្នកដែលអស្ចារ្យ។ ចំណែកវិស័យតែងនិពន្ធ ករិនិពន្ធមួយណាដែលសរសេរជាប់ទាក់ទងដល់ការអប់រំមិនត្រូវបានគេឲ្យតម្លៃទេឬក៏អាចមានទោសកំហុសទៅវិញ ផ្ទុយពីនេះ បានរាំងបានចាប់បង្ខំក្នុងន័យជាម្ចាស់អំណាចបង្ខំឲ្យអ្នកនិពន្ធ អ្នកករិត្រូវតែសរសេរលើកតម្កើងថា បារាំងអស្ចារ្យ ប្រទេសបារាំងគឺជាពិភពស្ថានសួគ៌ជាដើម។ ទោះបីជាមានការបង្ខិតបង្ខំផ្លូវចិត្តយ៉ាងណា ក៏ឧត្តមគតិជាអ្នកនិពន្ធរបស់ ជនជាតិខ្មែរមិនត្រូវបានបោះបង់ក្នុងគ្រានេះឡើយ តែផ្ទុយទៅវិញ លោកតែងតែឆ្លៀតបង្កប់គំនិតអប់រំ ស្នេហា ជាតិនៅក្នុងស្នាដៃអក្សរសិល្ប៍ជានិច្ច។

មកដល់សម័យនេះ អ្នកនិពន្ធខ្មែរបានងាកមកសរសេរជារឿងពិតដែលកើតនៅក្នុងសង្គមបច្ចុប្បន្នវិញ មិនដូចសរសេររឿងរើរវាយទៀតឡើយ។ ការងាកមកនេះ ក៏ព្រោះតែមានបញ្ញាបពុទ្ធិខាងតំណែងនិពន្ធជាលក្ខណៈអក្សរសិល្ប៍បច្ចិមប្រទេសមកក្នុងស្រុកខ្មែរ។ គោលការណ៍សំខាន់មួយ រឿងទាំងនេះ ជាគំនិតជឿនលឿន បែបប្រតិកិរិយាបម្រើប្រយោជន៍ក្នុងសម័យអាណានិគម។

អក្សរសិល្ប៍សម័យអាណានិគមបារាំង ត្រូវបានអ្នកសិក្សាចែកជាពីរដំណាក់កាលសំខាន់ៗគឺ៖

**ដំណាក់កាលទី១**

នៅក្នុងសម័យនេះ គេគិតចាប់ពីដើមសតវត្សទី២០ បន្តរហូតដល់ឆ្នាំ១៩៣០ ដែលនៅក្នុងសម័យកាលនេះ អក្សរសិល្ប៍ខ្មែរមិនមានការផ្លាស់ប្តូអ្វីទេ។ អ្នកនិពន្ធច្រើនតែសរសេរជាលក្ខណៈច្នៃប្រឌិត ដែលគោលគំនិតត្រូវបានទាញចេញពីស្នាដៃ របស់បុព្វបុរសសម័យកណ្តាល

មកចងក្រងឡើង គ្រាន់តែគោលគំនិតចាស់មួយចំនួន ត្រូវបានផ្លាស់ប្ដូរ ហើយងាកមកការចាប់អារម្មណ៍ទៅលើសកម្មភាពនៅផែនដី។

អ្នកនិពន្ធសំខាន់នៅក្នុងសម័យនេះរួមមាន៖

## ១ តាមាស (១៨២៨ - ១៩១០)

តាមាសកើតនៅឆ្នាំជូត សំរឹទ្ធិស័ក គ្រិស្តសករាជ ១៨២៨ ចុល្លសករាជ១១៩០ ដែលលោកមានងារជាបាឡាត់ខេត្តលង្វែក ហើយជីតារបស់លោកមានងារជាចៅហ្វាយស្រុក។ មាតាលោកត្រូវទទួលមរណភាពនៅគ្រាដែលប្រទេសខ្មែរ ត្រូវបានយួនវាយចូលក្នុងបន្ទាយលង្វែក ចំណែកបងប្អូនប្រុសលោកបីនាក់ ក៏ត្រូវស្លាប់ក្នុងសង្គ្រាមនេះដែរ។ លោកប្រហែលជាទទួលមរណភាព នៅទសវត្សទី១០នៃសតវត្សទី២០ គឺប្រហែលជាឆ្នាំ១៩១០ប៉ុណ្ណោះ។

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ គេប្រទះឃើញស្នាដៃមួយដែលនិយាយពីបទពិសោធន៍ជីវិតលោក ហើយត្រូវបានដាក់ចំណងជើងថា **បណ្ដាំ**[១]**តាមាស** ដែលនៅពេលនេះ ខ្ញុំសូមលើកយកអត្ថបទដើមរបស់លោកមកបង្ហាញជូនមិត្តអ្នកអានដូចតទៅ៖

"ឯខ្ញុំឈ្មោះមាស ជាចាស់ព្រឹទ្ធាចារីយ៍ អាយុស្ម័ជាង ៨០ឆ្នាំហើយ កើតក្នុងឆ្នាំជូត សំរឹទ្ធិស័ក្ស ចុល្លស័ក្ករាជ១១៩០ បើគិតជាស័ក្ករាជបារាំងត្រូវថែមឡើក១ទៀតទើបត្រូវនឹងឆ្នាំ១៨២៨ តែឯជាពាក្យបណ្ដាំមនេះទុកឲ្យកូនចៅចៅឯក្រោយចូលចាំមគ្រប់គ្នា នឹយាប្រាប់គ្នាតវៗទៅ។

កាលដើមឡើយអាពុកខ្ញុំ ធ្វើជាចាឡ្ញាត់ខែត្រលង្វែក ជាខែត្រដែរ កាលណោះជីតាខ្ញុំធ្វើជាចៅហ្វាយស្រុកណោះ ខ្ញុំនាំងជីតាខ្ញុំ គាត់ច្បាំងនិងយួនកាលរាជហ្លួងអង្គឌួង ហើយគាត់ចាត់បង់ក្នុងដាព់ ក៏មកទៀតអាពុកខ្ញុំ គាត់ជាំម កាងដាព់នៅដេញយួនៗ ក៏ចាក់រត់ខ្ចាត់ខ្ចាយទៅគ្រប់ទិស ឯខ្លួនគាត់ក៏ចាត់មិន

ដឹងជានៅឯណា មិនឃើញគាត់ត្រលប់មកផ្ទះវិញ ជីដូនខ្ញុំគាត់ចាត់បងជា១១ ឆ្នាំ ១២ឆ្នាំមុនជីតាខ្ញុំនៅកណ្ដាលផ្លូវដែរ នៅពីចាត់ជំបងនៅចាំងកក ដ្បិតតា ឈ្មោះ ពួកកងទ័ពសៀមកៀរគាត់នាំមនៅជាឈ្លើ ឯម្ដាយខ្ញុំគាត់ចាត់បង នៅ វេលាដែរយួនលើកមកលុកប៉ុង់បន្ទាយលង្វែក បងប្អូនប្រុសខ្ញុំ៣នាក់ អនិច្ច កម្មក្នុងជីចំបាំង ការឈ្មោះនៅចំបាំងជាមួយនិងមាគាត់២នាក់ ហើយនិងបង ប្អូនជីដូនមួយច្រើននាក់ ដែរនាំមពួកកងទ័ពស្រុះចិត្តគ្នានៅចំបាំង ឯខ្លួនខ្ញុំ ចូលចំបាំងនិងគេបាន៣ឆ្នាំ

(១) ខ្ញុំរក្សាអក្ខរាវិរុទ្ធដើមទុកដដែល

ជីកប់ផាល់តែស្រុកសានត្រាន ហើយហ្លួងអង្គឌួងចុះសញ្ញា ធ្វើជាស្ពានមេត្រីនិង សៀមនិងយួន។ នៅវេលានោះខ្ញុំក៏ធំមានអាយុស្ម័គ្រេល ល្មមឃើញស្គាល់ ចាំមការគ្រប់ជុំពួក

បាន ហើយបានយល់ពុច្បាស់ដែរ ពួកតាម៉ឹងៗគេនិយាយគ្នានៅប្រាប់ខ្ញុំៗចាំមបាន ទាំងអស់។

ស្រុកការឈ្មោះចាត់បែកត្រាលាល់ក្នុងមួយភូមិៗ រកច្រាត់មួយ រៀលគ្មាន រត់ចោលស្រែចំការច្បារដំណាំមខានទាំមផ្ទះរាស់ ស្ងួងព្រស់សាប ព្រោះខ្លាចក្រែងយួនសៀម រាមកកុំហែងច្រូតយកស្រូវក្នុងស្រែ ដើមដូង ដើម ស្លា និងដើមឈើស៊ីផ្លែទាំងបុផ្អាន កាប់ចោលអស់ជាងពាក់កណ្ដាល ហើយ ក្នុងភូមិដែលជីតា ដែលអាពុកខ្ញុំគាត់ ធ្លាប់ឃើញស្គាល់ ពីដើមមាន១៥០នោះ ឃើញតែផ្ទះ៦០ ផ្ទះ៥០ ផ្ទះ២៥វិញ ឯរាស្ត្រចំណុះស្រុកក៏តិចជាងពីដើម ពួក សមណៈ ជីព្រាហ្មក៏កើតទុក្ខវេទនា ព្រោះរាលុកប៉ុង់ ព្រះវិហារភ៏ម ជន្លួនយក ព្រះពុទ្ធរូបណាដែលជាមាសប្រាក់ ជាសំរឹទ្ធិ៍ ហើយរាដុតព្រះវិហារវត្តអារ៉ាមជា ច្រើនអន្លើហ៍ វត្តណាដែរនៅសល់នោះរកដំបូលគ្មាន ដំបូលនោះស្រុតចាត់ ធ្លាក់នៅត្របលើអាសនៈព្រះរតន៍ណា និងមានចិត្តកិតជួសជុលគ្មាន ព្រោះរវល់ តែនិងចំបាំងកាំងដលរៀងមកជាប់៥០ឆ្នាំ ស្រុកភូមិចាត់បែក រត់ចោលស្ងាត់ ស្ងួនឈិង មុក្ខក្លូឲ្យស្រងះស្រពោចខ្លោចផ្សាណាស់ ណាវេទនានិងស្រីដែល មានកូនតូចៗអង្គុយឱបក្បាលជង្គង់ មុក្ខច្រមិស់មើលតែមុក្ខកូនក្ទិះៗ។

លុះបានស្រុកសានត្រាន បានចុះសញ្ញាជាស្ពានមេត្រីនោះ ហ្លួងអង្គឌួងបានស្ដេចរាជជាស្ដេចហើយ នោះរាស្ត្រាល់គ្នា ត្រាំងមានចិត្តសប្បាយហើយគេនិយាយសរសើរថាស្ដេចល្អត្រង់ធម៌ ព្រះឡៃសប្បុរស់ជ្រះថ្លា និងអរគោកអន្សា

ស្រែ ប៉ុន្តែស្រុកយើងកាលណោះខ្សត់ណាស់ អស់អាណាប្រជានុរាស្ត្រលំបាក ក្រៃពេកពន់ប្រមាណ ចេះតែនៅទ្រាំមចាំមសៀមពុំបានធ្វើការរកស៊ីអ្វីសោះ។

ឯខ្លួនខ្ញុំកាលណោះក៏ក្រណាស់ ហើយគ្មានញាតិនៅសាច់សណ្ដានព្រៀងលានណោះ ឯចំណែះវិជ្ជាការក៏ឥតថយស្គាល់តែសេចក្ដីទុក្ខសោកវេទនា ក៏មានចិត្តកាត់ដំឡាសទ្ទាចដំបួសស្រេចហើយ ក៏ចូលឱបសម្បូកក្នុងសំណាក់ព្រះពុទ្ធសាស្នានៅក្នុងអារ៉ាម១ក្នុងក្រុងឱដុងមានជ័យ ដើម្បីនឹងបានមគ្គផលនៅជាតិក្រោយកុំឲ្យអកុសលដូចជាតិនេះហើយនឹងបានរៀនសូត្រធម៌អាត្ត័ស ត្រាចារ្យផង រួចចុះថែមបាំងអកុសលឯក្នុងវត្តសោត ក៏រករៀនធម៌អាត្ត័ស ត្រាចារ្យគ្មាន ភ្លើងឆេះខូចអត្តក៉្យខ្លះ សៀមវាលួចយកខ្លះ យួនវាបំផ្លាញខូចខ្លះ ឯនៅក្នុងវត្តប្រាជ្ញដែរខ្ញុំបួសកិក្ខុណោះសោត ក៏នៅសល់តែលោកសង្ឃល្ងង់ខ្លៅ ពុំមានគិតរកសាស្ត្រាវិន័យ និងគម្ពីរព្រះអភិធម្មព្រះត្រៃបិដកក់ឡើយ

ឯកើតច្បាំងក្នុងស្រុកខ្មែរ ហើយចុះសញ្ញាធ្វើស្ពានមេត្រីរួចហើយនោះ ពួកមហាសត្រូវយើងទាំងសង្ខាង គឺស្ដេចសៀម ហើយនិងស្ដេចយួនវានៅតែក្លួយកដីយើងទៀត ឯស្ដេចសៀមយកខេត្តចំណែកខាងជើង គឺស្រុកសៀមរាប មានគរជំមក្រុងស្រុកខ្មែរយើង ហើយស្រុកបាត់ដំបង ម្លូព្រៃ ទន្លេរពៅ ហើយនិងខេត្តយើង ខ្មែរទាំងប៉ុន្មានដែលនៅមាត់ស្រមុទខាងលិចទាំងស្វ៊ិម ឯស្ដេចយួនយកដីដែលស្រុកខ្មែរទាំងប៉ុន្មាននៅខាងត្បូងគឺព្រៃនគរ កូសាំងស៊ីនសព្វថ្ងៃនេះរហូតនៅដល់ជល់និងព្រែកជីកខេត្តពាមខាងឯលិច ខាងឯកើតយករហូតនៅឆ្ពិមនិងក្រុងភ្នំពេញ។ ឯស្ដេចម្ចាស់ផែនដីយើងលោកកើតទុក្ខព្រួយព្រះទ័យដូចជាភស្តុដែរ ព្រោះទ្រង់ឈ្វេងយល់ថា សៀមហើយនិងយួនវាគិតយកស្រុកខ្មែរបង្កួលក្នុងស្រុកវារាល់គ្នា ប៉ុន្តែវាបង្កួលមិនទាន់បានព្រោះវាសត្រូវនិងគ្នា ហើយចែកគ្នាមិនកើតដ្បិតវាចង់បានតែទាំងអស់រាល់ខ្លួន។ ម្ចាស់យើងលោកព្រួយព្រះទ័យ១ជំពូកទៀត ព្រោះសៀមវាចង់ជំនុកបំរុងលោកៗពុំសព្វព្រះទ័យព្រោះវាមិនទុកលោកជាស្ដេចផែនដីស្រុកខ្មែរ វាទុកលោកដូចជាចៅហ្វាយស្រុកខ្មែរនៅវិញ ឯយួនវាទុកលោកជាចំណុះវា ហេតុដូច្នេះព្រះអង្គក៏ព្រួយព្រះរាជហឫទ័យ ក្រែងកើតចម្បាំងជាថ្មីទៀត ក្រែងស្រុកខ្មែរនឹងវិនាសអន្តរាយ ហើយផុតមានអស់ពូជខ្មែរក្រែងនៅសល់តែសៀម ឬនៅតែខ្មែរដែរទុកសក់បួងពីក្រោយដូចជាពួកពួង សៀងយកកន្សែងរុំក្បាលដូចជាយួន។

ឯហ្វូងយើងការស្មោះ លោកចេះតែខំប្រឹងតាមការទ្រង់ចាត់ឲ្យចំ ឡងសាស្ត្រាចាស់ៗ ច្បាប់ទំលាប់ហើយស៊ើបសួររកពង្សាវតារដែលនៅសល់ឃើញ តាំងប៉ុន្មានឲ្យយកមកចំឡងទុក ព្រោះលោកមានព្រះរាជហឫទ័យដើម្បីនឹង រៀបចំស្រុកខ្មែរយើងឲ្យរបបរៀបរយ តែទ្រង់នៅមានព្រះវិតក្កក្រែងតែនៅ មុខ សៀមហើយនិងយួនវាយកស្រុកយើងខ្មែរចែកគ្នា ទ្រង់ព្រះចិន្តាតែម៉្លោះ ដើ ពទ្រង់ឈ្នះយល់ថា និងពឹងរកស្រុកប្រទេសយូរ៉ុបណា១ ឲ្យជួយទំនុកបំរុង ឥឡូវនិងនឹពឹងបុណ្យអាំងក្លេស ព្រោះអង់គ្លេសបានស្រុកក្លិង ហើយនិងស្រុក សិង្ហៈបួរហើយ ឥឡូវនិងនៅពឹងបុណ្យវីឡាណ្ដា ទ្រង់ពុំសព្វព្រះទ័យ ដ្បិតវីឡាណ្ដាធ្វើ ជាចៅហ្វាយនៅស្រុកយ៉ាវ៉ា ស្រុកសូម៉ាត្រាហើយ ឥឡូវនិងនៅពឹងបុណ្យអ៊ិះស្ប៉ា ញ៉ុល បុប្រតូកេស ដ្បិតសាសន៍ទាំងនោះពុំពូកែ ទ្រង់ព្រះចិន្តាតែម៉្លោះស្រេចហើយ ក៏ទ្រង់សំរេចថា និងពឹងបារាំងសែសដ្បិតបារាំងសែសគ្មានស្រុកចំណុះនៅ ប្របស្រុកខ្មែរ

១ទៀតកាលពីដើមទ្រង់គង់នៅស្រុកបាងកក បានជួបនិងបារាំង សែស ហើយទ្រង់គិតយល់រីករាយ មិនធ្វើងកង្វើង និងនរណាកក់ជាក់រាប់អាន អ្នកទាំងពួង ហើយចិត្តថ្លើមក៏មានធម៌

## រឿង តេជោដំខ្ទិន

ឯព្យាបាទ ធ្វើលម្អិត ផ្សារពោធិ៍សត្វ
នឹងចែងចាត់ ជាសំណាង សង់ក្សត្រា
ខេត្តចាន់បូណ៌ នោះមកថ្វាយ ព្រះចក្រា
តាំងរាជការ ចៅហ្វាយស្រុក ខ្មែរត្រួតចុះ ។
ក្រាបទូលថ្វាយ ទ្រព្យប៉ុន្មាន តាមបញ្ជី
សូមភូមី ស្ដេចទទួល ដោយស្រួលស្រុះ
យើងលើកថ្វាយ មកសម្ដេច ទ្រង់កិត្តិយស
ដោយស្ម័គ្រស្មោះ កុំរង្កៀស ព្រះទយា ។
ឯស្នួយសារ ដំបារមាស តើប៉ុន្មាន

សូមក្សត្រក្សាន្ត តាំងជាច្បាប់ សន្យាគ្នា
នឹងនាំថ្វាយ តាមសញ្ញា ព្រះរាជា
ល្មមជានា រ៉ាប់រងបាន មិនធ្ងន់ពេក ។
ចប់សំបុត្រ ផុតសេចក្ដី តែប៉ុណ្ណោះ
ព្រះអង្គរិះ ក្នុងព្រះទ័យ ហើយទ្រង់ត្រេក
មានឱង្ការ តម្រាស់ថា យើងសង្វេគ
អាណិតពេក នឹងបន្ទូល ក្រុមរាំងណា ។
និយាយមក ពេញហៅត្រូវ ផ្លូវសេចក្ដី
ព្រះចក្រី ឲ្យអញ្ជើញ ព្រះសូរិយា
ស្ដេចមកដល់ ហើយគង់លើ ព្រះអាស្នា
ឆ្វេងក្សត្រា គំនាប់គ្នា តាមសណ្ដាប់ ។
ព្រះបុទុម សូរិយាវង្ស ពង្សចក្រី
បន្ទូលថ្មី បណ្ដោយន័យ សម្ដែងប្រាប់
ថាព្រះបង គ្រានេះហោង មានសារច្បាប់
ពីអណ្ដាប់ ញាតិវង្សា ក្រុំរាំងណា ។
សូមព្រះអង្គ ទៀងទតមើល សេចក្ដីចុះ
ត្រូវឬខុស ពីព្រះទ័យ ព្រះជេដ្ឋា
មានព្រះសង្ស័ ទាំងប្អូនអង្គ គង់ប្រសិទ្ធិយ៉ា
ខុសត្រង់ណា សូមលុបចោល តាមព្រះទ័យ ។
បើត្រូវហើយ សូមឡាយព្រះ- ហស្ដលេខា
ហើយក្សត្រា ក្សាន្តស្បថស្បាន តាមវិន័យ
ឯខាងខ្ញុំ នោះកុំឲ្យ ព្រះអង្គភ័យ
នឹងលកលៃ បទយ៉ាងណា ចេះតែបាន ។

ឯព្រះចៅ ព្រះចមជាតិ អង្គពុល្វចក្រ
ឈៀងព្រះកគ្រូ ស្ដេចទៀងទត ន័យសារសាន
ចប់ទាំងមូល ហើយបន្ទូល តាមលំអាន
ពាក្យប៉ុន្មាន ខ្ញុំក៏ព្រម តាមទាំងអស់ ។...

## ២ លោកសើន ឡៀប

លោកសើន ឡៀបកើតនៅឆ្នាំ១៨៥៥០ ជាជនជាតិកម្ពុជាក្រោម រស់នៅស្រុកទ្រាំង។ លោកបានរៀនភាសាបារាំងជាមួយអ្នកបួសកាតូ-លិក ក្រុមបេសកកម្មបរទេស។ នៅឆ្នាំ១៨៨៥-១៨៨៦ លោកត្រូវបានបារាំងចាប់បង្ខាំងទុក ដើម្បីកុំឲ្យលោកបកប្រែភាសាបារាំងមកជាភាសាខ្មែរ ខណៈដែលបារាំងបានបង្ខំស្ដេចនរោត្តមឲ្យចុះហត្ថលេខាព្រមទទួលបារាំងជាអាណាព្យាបាលនៅកម្ពុជា។

នៅឆ្នាំ១៨៧០ រដ្ឋការអាណានិគមបារាំងបានតែងតាំងលោកជាមនុស្សមួយរូប ដែលមានតួនាទីយ៉ាងសំខាន់ខាងផ្នែកនយោបាយនិងស្រាវជ្រាវ ហើយក៏បានជួយរៀបចំវចនានុក្រមបារាំងខ្មែរជាមួយព្រះសង្ឃកាតូលិក**គ្គេដុង** ក្រោយមកលោកក៏បានក្លាយជាចៅហ្វាយស្រុកទ្រាំង ដែនដីកម្ពុជាក្រោម។

នៅរាជស្ដេចហ្លួងស៊ីសុវត្ថិ លោកសើន ឡៀបក៏បានក្លាយជាមន្ត្រីចតុស្តម្ភដែលមានងារជា ឧកញ៉ាក្រឡាហោម។ លោកប្រែជាស្លាប់នៅចុងរាជព្រះបាទស៊ីសុវត្ថិ តែមិនដឹងកាលបរិច្ឆេទពិតប្រាកដឡើយ។

តាមការស្រាវជ្រាវបានឲ្យដឹងថា លោកសើន ឡៀបមានបុត្រីម្នាក់បានធ្វើជាស្នំព្រះរាជបុត្រា**ស៊ីសុវត្ថិមុនីពង្ស** ដែលត្រូវជាព្រះរាជបុត្ររបស់ហ្លួង**ស៊ីសុវត្ថិ** ហើយក្រោយមក ចៅស្រីបង្កើតរបស់លោកនាម ស៊ី

សុវត្ថិសុវេទវង្ស(១៩៤៥-១៩៩៧) ដែលមានឈ្មោះក្រៅហៅថា ឡូឡា ឬលីឡាជាអ្នកតំណាងរាស្ត្រនៅប្រទេសកម្ពុជា។

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ លោកសើន ឡៀបបានបន្សល់ទុកកម្រងកំណាព្យមួយដែលមានចំណងជើងថា **ល្បើកពីស្រុកព្រៃនគរទៅក្រុងប៉ារាំងផ្សែសនៅទីក្រុងតុះ** អត្ថបទនេះ គឺជាប្រភេទអត្ថបទពិពណ៌នាអំពីទីក្រុងប៉ារីសដែលលោកបានទៅដល់។ ខាងក្រោមនេះ គឺជាអត្ថបទសម្រង់ដែលបានដកស្រង់ចេញពីស្នាដៃ របស់លោកក្នុងកម្រងកំណាព្យខាងលើ ដែលខ្ញុំរក្សាទុកអក្ខរាវិរុទ្ធដើមមកបង្ហាញជូនមិត្តអ្នកអានដូចតទៅ៖

| | | |
|---|---|---|
| បារីស៍អេលីសសេទីរ្យសម្រេច | ប្រសើរល្បើលេចក្នុងដែនដាន | |
| ឪដំមសាកសំមគ្រុបក៏មាន | ជាស្ថានសម្រាប់ច្បាបពាក្យារ | ។ |
| ផ្លូវធ្លាមាតាទូលាយស្អាត | ប្រកិតសុតសាតថ្មសីលា | |
| ផ្លូវខ្វះប្រកិតដើមព្រិក្សា | សិងអារបួនជ្រុងរេបន្សរ... | ។ |

## ២ ព្រះភិក្ខុសោម

ភិក្ខុសោមមាននាមដើមឈ្មោះ **ង៉ួន សោម** កើតនៅឆ្នាំ១៨៩២ មានទីលំនៅកំណើតនៅភូមិកំព្រៅ ឃុំកំព្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង។ លោកមានឪពុកព្រះនាម **ង៉ួន** និងមាតាព្រះនាម **យិន** មានបងប្អូនទាំងអស់៧នាក់សុទ្ធតែប្រុស។ កុមារសោមជាកូនដែលមានចរិតសុភាពរាបសារជាងគេ ហើយកាលពីកុមារលោកមានចំណូលចិត្តខាងតន្ត្រី និងកំណាព្យ។

លុះគម្រប់អាយុចូលសិក្សា កុមារសោមបានចូលទៅរៀននៅសាលាបឋមសិក្សានៅឯវត្ត រហូតដល់អាយុ១៥ឆ្នាំក៏បានសាងផ្នួសបួស

ជាសាមណេរនៅឯវត្ត**ឥន្ទកាលារាម** ហៅវត្ត **កំព្រៅ** ស្ថិតនៅក្នុងស្រុកស៊ីធរកណ្តាល។ លុះព្រះជន្មបាន២១វស្សាក៏បានបំពេញការជាភិក្ខុដោយមាននាមថា **ព្រះបទុមត្ថេរ**។

បន្ទាប់ពីបានបញ្ចប់ការសិក្សានៅភ្នំពេញមក ព្រះបទុមត្ថេសោម ក៏បាននិមន្តត្រលប់មកស្រុកកំណើតវិញ នឹងបានទទួលនាទីជាចៅព្រះចៅអធិការក្នុងវត្តកំព្រៅ ហើយទទួលងារជា **ព្រះសង្ឃវង្ស** ហើយទទួលមរណភាពនៅឆ្នាំ១៩៣៥ ក្នុងជន្មាយុ៨៣វស្សា។

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ ព្រះភិក្ខុសោមបានបន្សល់ស្នាដៃអក្សរសិល្ប៍ចំនួនពីរ គឺរឿងទុំទាវ និងរឿងសព្វសិទ្ធ(មិនមែនសព្វសិទ្ធរបស់ម៉ឺនអក្សរកេត្តិតន់ទេ) ដែលបច្ចុប្បន្នរឿងទុំទាវកំពុងតែទទួលបានការវាយតម្លៃថាជាវណ្ណកម្មអក្សរសិល្ប៍ដែលមានលក្ខណៈអន្តរជាតិខាងផ្នែកផ្សាយវប្បធម៌ខ្មែរ។ ម្យ៉ាងវិញទៀត រឿងនេះ ជារឿងមួយដែលមានលក្ខណៈពិសេសដោយឡែកពីបណ្តាវណ្ណកម្មដទៃទៀត។ រឿងទុំទាវត្រូវបាននិពន្ធឡើងនៅឆ្នាំ១៩១៥ ក្នុងពុទ្ធសករាជ២៤៥៨ ក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ ដោយត្រូវបារៀបរៀងជាកំណាព្យបទពាក្យ៧តាំងពីដើមដល់ចប់។

ទេពកោសល ដ៏ប៉ិនប្រសប់របស់លោកភិក្ខុសោមនៅក្នុងការតាក់តែងស្នាដៃមួយនេះឡើង គឺលោកបានបញ្ចូលនូវសិល្បវិធីដ៏ ប៉ិនប្រសប់ជាច្រើន ទើបបណ្តាលឲ្យស្នាដៃ របស់លោកត្រូវបាន ទទួលស្គាល់ជាផ្លូវការនៅលើឆាកអន្តរជាតិ។ ជាទូទៅស្នាដៃមួយមុន ពេលឈានទៅដល់ការទទួលស្គាល់ជាលក្ខណៈអន្តរជាតិបាន លុះត្រាត្រាតែស្នាដៃនោះ ត្រូវបានមជ្ឈដ្ឋានជាតិទទួលស្គាល់ពីគុណភាពជាមុនសិន។ ដោយឡែករឿងទុំទាវ មតិជាតិគេមានការគាំទ្រជាទូទៅ បន្ទាប់មកមតិអន្តរ-

ជាតិក៏បានទទួលស្គាល់ពីគុណភាពនេះដែរ។ មានចំណុចជាច្រើនដែលនាំឲ្យវណ្ណកម្មអក្សរសិល្ប៍នេះក្លាយ ខ្លួនជាអក្សរសិល្ប៍អន្តរជាតិ។

ផ្អែកតាមការសិក្សាស្រាវជ្រាវ ចំណុចទីមួយនោះគឺរឿងនេះបង្ហាញអំពីជំនឿនៅក្នុងសង្គមខ្មែរ។ ប្រជាជនខ្មែរ គ្រប់និគមជនបទរហូតដល់ទីក្រុង តែងរស់នៅជាមួយជំនឿនេះហើយគ្រប់គ្នា គ្មាននរណាអាចបង្វែរសេចក្តីជឿសិប់នៃជំនឿនេះបានដែរ។ គ្មាននរណាម្នាក់អាចរកឃើញពីអាថ៌កំបាំងដែលមាននៅក្នុងជំនឿនេះដែរ ផ្ទុយទៅវិញជំនឿនេះនាំឲ្យពួកគេរិតតែមានការជឿជាក់លើសមត្ថភាព របស់ខ្លួនទៅទៀត ។ ចុះអ្នកមិនជឿជាក់លើជំនឿ តើត្រូវទទួល នូវផលកម្មអ្វី? នៅក្នុងរឿងទុំទាវ អ្នកនិពន្ធបានបង្ហាញច្បាស់ណាស់ អំពីស្ថានភាពនេះ។ តួអង្គទុំដែលសឹកខុសពីបណ្តាំគ្រូ ហ៊ានលួចទៅសឹកដោយអង្គឯងគ្មានគ្រូអាចារ្យជាអ្នកចាត់ចែង ម្យ៉ាង វិញទៀតការសឹកនេះទៀតសោត ក៏ខុសនិងបណ្តាំគ្រូដែលថា ឆ្នាំក្រោយទើបអាចសឹកបាន។ នៅទីបំផុត ទុំត្រូវស្លាប់ជាប្រាកដដូចអ្វីដែលលោកគ្រូ ចៅអធិការវត្តវិហារធំបានលើកឡើងប្រាកដមែន។

ចំណុចមួយទៀត គឺរឿងនេះបានបង្ហាញអំពីរបបគ្រប់គ្រង។ ប្រទេសកម្ពុជា សម័យនោះគ្រប់គ្រងនិងដឹកនាំដោយព្រះមហាក្សត្រ។ ព្រះអង្គជា អ្នកដឹកនាំប្រកបដោយបញ្ញាឈ្លាសវៃផង ព្រមទាំងជាតុលាការផង។ នៅក្នុងរឿងនេះ អ្នកនិពន្ធបានលើកយកតួអង្គព្រះបាទរាមាជើងព្រៃមកសិក្សា និងបង្ហាញដល់អ្នកសិក្សាថា ប្រព័ន្ធគ្រប់គ្រងសម័យបុរាណមានលក្ខណៈតឹងតែងណាស់ ពិសេសគឺមនុស្សម្នាក់ៗដែលបានប្រព្រឹត្តខុសត្រូវមានទោសយ៉ាងធ្ងន់ធ្ងរជាទីបំផុត។ ស្រុកទេសដែលដឹកនាំដោយព្រះបាទរាមា ជើងព្រៃ គឺមានច្បាប់ទម្លាប់ល្អ។ របនាសម្ព័ន្ធក្រោម

អំណាចព្រះមហាក្សត្រ គឺមានស្តេចត្រាញ់ជាអ្នកគ្រប់គ្រងដែនដីរបស់ខ្លួន។ នៅក្នុងរឿង គេឃើញ មានអរជូនជាងារស្តេចត្រាញ់នៅសម័យនោះ។ ស្តេចត្រាញ់ដែលដឹកនាំនៅដែនដីនោះគឺមានអំណាចខ្លាំងណាស់ ។មួយវិញទៀត តាមរយៈរឿងនេះដែរ គឺបានបង្ហាញពីបញ្ហាតុលាការ។ តុលាការប្រទេសកម្ពុជាសម័យបុរាណគឺមានលក្ខណៈផ្តាច់ការ តែតឹងរឹងចំពោះ ជនដែលប្រព្រឹត្តអាក្រក់។ ខណៈដែលតួអង្គទុំទាវស្លាប់ដោយសារតែ កណ្តាប់ដៃអរជូន គេឃើញមានព្រះរាជាបានយាងមកកាត់ក្តីរកយុត្តិធម៌ជូនអ្នកស្លាប់ទៅ។ ដោយសម្អាងទៅលើកស្មុតាងដែលមានស្រាប់ ព្រះបាទរាមាជើងព្រៃដែលព្រះអង្គកាន់ច្បាប់តុលាការដែរនោះ បានប្រជុំអស់ពួកមន្ត្រី សេនាបតីកាត់ទោសអរជូន ព្រមទាំងបក្សពួកប្រហារជីវិត។ អ្នកសមគំនិតក៏ត្រូវទទួលទោសប្រហារជីវិតដូចគ្នា។ នៅក្នុងរឿងគេឃើញអ្នកសមគំនិត ត្រូវកប់ត្រឹមក្បាល រួចអួសរនាស់ដែកពីលើ។បន្ទាប់ពីនេះ រឿងទុំទាវបានបង្ហាញពីសាសនា។ ប្រទេសកម្ពុជាសម័យនោះ ក៏ប្រកាន់យកសាសនាព្រះពុទ្ធដែរ។ ទុំដែលបានធំពេញរូបពេញរាង គឺត្រូវម្តាយយកទៅបួសរៀនឯវត្តព្រះពុទ្ធសាសនា។ តែអ្វីដែលចម្លែកគឺថា ព្រះសង្ឃសម័យនោះចេះដើររកស៊ីជំនួញដូចគ្រហស្ថដែរ។ នៅក្នុងសាច់រឿង ទុំនិងពេជ្រជាសង្ឃដែលដើររកស៊ីជំនួញនេះ គឺពួកគេធ្វើជំនួញតោក ដែលឧបករណ៍មួយនេះមានន័យថា ភាជនៈឈើឬស្នាច់មានជើងស្រដៀងនឹងតុស្តាន់ រាងកាច់ជ្រុងក្រឡូមជ្រៅជាងតុ ច្រើនដាំខ្យង ឬដាំកញ្ចក់, បិទមាសសម្រាប់ដាក់ទ្រអ្វីៗដែលជាវត្ថុចេញមុខ ។

ក្រៅពីនេះ ក្នុងរឿងមានបង្ហាញពីស្នេហារបស់យុវវ័យ ដែលពួកគេកំពុង តែមានការរើបម្រាស់ពីប្រពៃចាស់បុរាណ ដែលការទុកដាក់

កូនចៅស្រេចតែ ទៅលើឪពុកម្ដាយ កូនគ្មានសិទ្ធតវ៉ា ជជែករកហេតុផលឡើយ។ គំនាបសង្កត់ផ្លូវចិត្តបែបនេះក៏នាំឲ្យតួអង្គទុំទាវហ៊ានចេញមុខមុនគេក្នុងការរើបម្រាស់នេះ។ សេចក្ដីសុខនៃគូស្នេហ៍ម្នាក់ៗ គឺការដែលបានរួមរស់ជាមួយគ្នា មិនមែនការចាប់បង្ខំដូចអ្វីដែលម្ដាយនាងទាវបានប្រព្រឹត្តឡើយ។ ដោយយល់ដូច្នេះហើយបានជាតួអង្គទុំក្ដី នាងទាវក្ដីហ៊ានចេញមុខយ៉ាងអង់អាច ដើម្បីសេចក្ដីស្នេហារបស់ខ្លួនជាជពប ទោះបីជាខ្លួនកំពុងស្ថិតនៅមុខព្រះភក្ត្រ ព្រះរាជាក៏ដោយក៏គូស្នេហ៍នេះហ៊ានចេញមុខសារភាព ពីស្នេហាខ្លួនប្រាប់ទៅព្រះរាជា រហូតព្រះអង្គមានសេចក្ដីប្រោសប្រណីរៀបចំផ្សំផ្គុំឲ្យពួកគេទាំងពីរនាក់បានគ្នាជាប្ដីប្រពន្ធដូចបំណង។

នៅក្នុងស្នាដៃរបស់លោក លោកបានចងក្រងជាកំណាព្យប្រកបដោយពាក្យល្អល្ដាយ ពីរោះរណ្ដំណែងណង ដែលទឹកដៃនេះហើយរឹតតែទទួលបានការចាប់អារម្មណ៍ ពីសំណាក់អ្នកអានគ្រប់ស្រទាប់វណ្ណៈជាន់ថ្នាក់។ ខាងក្រោមនេះគឺជាសម្រង់អត្ថបទរឿងទុំទាវមកបង្ហាញជូនមិត្តអ្នកអាន ដើម្បីបានជ្រាបពីទឹកដៃរបស់លោកនៅក្នុងការនិពន្ធរឿងជាកំណាព្យបទពាក្យ៧ ហើយរឿងនេះក៏ជាចន្ទមួយនៃអក្សរសិល្ប៍ខ្មែរ ដែលធ្វើការផ្លាស់ប្ដូរពីការស្រម៉ៃនិយមមកជារឿងប្រាកដនិយម ដែលលោកខំសរសេរចងក្រងជាលក្ខណៈតថៈនៅក្នុងសង្គមនេះវិញ។

ខាងក្រោមនេះ ខ្ញុំលើកយកអត្ថបទសម្រង់នេះជូនមិត្តអ្នកអាន ដើម្បីបានជាការសិក្សាជាមួយខ្ញុំដូចតទៅ៖

ថ្វាថ្ងៃសម្ដែងដើមឈ្មោះទុំ នៅខេត្តបាភ្នំដែនដីស្រែ

កើតកបទំនៀមមានឪម៉ែ ប៉ុន្តែហេតុជ្ឍិតឥតសម្តែង ។
កើតមកលុះធំល្មមប្រមាណ ឆ្នាំច្រើនសោតបានម្តាយតុបតែង
យកទៅឲ្យរៀនចោលគ្រឿងល្បែង ស្វះស្វែងនៅវត្តវិហារធំ។
លោកគ្រូទទួលស្រួលព្រះទ័យ ប្រិតប្រៀនទុំវ័យខាងអាគម
អាចគាប់ដោយប្រាជ្ញប្រឹងជញ្ជុំ ខិតខំចង់បួសផ្នួសសាមណេរ ។
សំណាក់បិតបេរចំណេរលង់ មាននេនមួយអង្គគ្រាន់បើដែរ
នាមឈ្មោះនេនពេជ្រលេចក្រសែ នេនទាំងពីរកែតែតោកលក់ ។
ទុំមានប្រាជ្ញាវោហារផ្សេង មានទាំងសំឡេងរូបខ្ចីល្អក់
ល្អទ្រង់អង្គកាយសាយទឹកមុខ រូបទុកនេនពេជ្រស្រេចជាប្អូន ។
នេនពេជ្របេះស្រេចខាងផ្ទុំប៉ី ឈ្លាសវៃប្រសប់ភ្លេងមាំមួន
អ្នកនេនពីរពិតគិតគំកួន ចំណេះក្នុងខ្លួនប្រហែលគ្នា ។
ធ្វើតោកធ្វើទុកលក់ដាច់ខ្វះ នៅផ្ទះទៀបវត្តជាមីងមា
លុះដល់រដូវត្រូវវេរា ព្រឹប្រុងអង្គាជាទុក្ខព្រួយ ។
អកុសលដល់គ្របសង្កត់កាយ ជួបនេនពេជ្រពាដូចខ្លួនមួយ
ថានេនពេជ្រអើយចូរគាត់ជួយ យើងលក់តោកមួយៗយូរហើយ ។
វាគ្មានចំណេញជំនួញទាល់ កុំធ្វល់ដូចពាក្យបុរាណឆ្លើយ
ថានៅរៀងអាយជិតបង្កើយ លំហែលំហើយតែប្អូនស្រី ។
បុរាណលោកថាមិនខុសសោះ ខ្លួនយើងកម្ទោះក្នុងលោកិយ
បួសស៊ីបាយបាត្រមិនបេះអ្វី នៅថ្វីចោលម្សៀតធ្មៀតដើរឆ្ងាយ ។
គិតស្រេចព្រមព្រៀងមៀងមើលគ្រប់ ខំទប់មិនឈ្នះរៀបខ្វល់ខ្វាយ
ទៀនធូបបានស្រាប់ប្រញាប់កាយ ឡើងដាក់អង្គថ្វាយបង្គំគាល់ ។

……………………………

ទុំថាឱទាវនឹមនួនល្អង ថ្ងៃនេះអញបង់ឃ្លាឃ្លាតពិត

មិនបានរួមស្ថានដួងជីវិត ម្ទេះសមតោមស្និទ្ធនៅកំព្រា ។
ដើរហើយពុំស្បើយរីងចង្អៀត ខំផ្ទៀតរំពៃក្នុងអដ្វា
ទុំរាប់ដើមឈើផងនានា ដុះខាងមាត់ជាជួរជ្រំ ។
មើលមានជ្រៃជ្រែសង្កែថ្វាន់ ត្រៀលត្រល់ក្រវាន់គុយស្រគំ
ស្រឡីស្រឡៅក្របៅក្តម្ព ទ្រនំអាអូដ្ឋអង្គួរត្នោត ។
ដង្កោទ្រយឹងខ្ទឹងក្រសាំង អំពិលភ្ញងភ្ញាំងទាំងភ្ញុបាត
គូលៃនទុរេនមានលាំងសាត មាក់បាតបង្កៅឡោចាន់ចារ ។
ត្របែកត្រសេកអំបែងថ្ងៃ អង្គ្រង់ស្មាច់ស្មែពេគរកា
ក្រូចក្រាយស្វាតស្វាយត្រាចត្រៀលស្វា សេដាសណ្តាន់ថ្វាន់ជ្រៃជ្រៃ ។
មានទាំងដកពាយរាយដកព សង្ស័រពង្រក់រាំងស្មី
ភ្នំភ្លេងផ្តៃស្រែងលោតលាំងដៃ សន្ទែកក្រខុបផុបក្រឡាញ់ ។
កប្បាសបុស្សនាគច្រកែងទួយ ប្រផេញគោមួយឈើទាលត្រាញ់
រាជកីសធ្មេញត្រីរអែញាញ អង្កាញ់អង្កោលកណ្តាលបាត ។
ត្រាចត្រៀកបង្រៀកប្រេសខ្ទឹមក្តម្ព គគីរាំងភ្នំបេងបាយម៉ាត
ស្តុកស្តុលស្តីស្តៅត្រាវក្លូចក្តាត លាំងសាតសត្បារកាស្រល់ ។
ទុំដើរក្នុងព្រៃរំពៃសត្វ ស្រង្ហួតស្រងាត់ក្នុងចិត្តស្រល់
វិត្តកក្នុងកាយចិត្តខ្វាយខ្វល់ នឹកដល់ទាវស្រីមិនមានស្បើយ ។

..................

ព្រះចមចក្រពង្សទ្រង់កម្សាន្ត ត្រាសថ្កានព្រះអង្គបញ្ឈប់ភ្លេង
នូវក្រុមកុមារីស្រីក្មេងៗ ស្តេចថ្លែងត្រាសថាឲ្យចេញទៅ ។
ទ្រង់ត្រាសកំហែងថ្លែងឱង្ការ ត្រាសថាយមរាជអាចតម្រូវ
ជំនុំកាត់ទោសឲ្យត្រឹមត្រូវ ហើយហៅនគរបាលធាប់ថ្វាត់ ។
នគរបាលបង្គំព្រះចក្រី ត្រាសខ្មីស្ទុះភ្វាមទៅចែងចាត់

ធ្វើតាមទោសានុទោសសត្វ　ត្រូវចាត់ផាត់មូលចូលរណ្ដៅ ។

ជីកលុងក្នុងដីជ្រៅច្រហ　ប្រមាណត្រឹមករួចចាត់ហៅ

ប្រាំពីរសណ្ដានប្រានកូនចៅ　សាច់ផៅកពផុងក្នុងវេទនា ។

ទើបយកក្របីទឹមនោស់　ដែកដីករួចរាស់ទោសមួយឃ្នា

នគរបាលបែងមិនប្រែងរា　កម្មពៀរវេកស្នាលាហើយ ។

ចាត់ចែងអ្នកទោសដែលធំៗ　ប្រជុំចូលដល់ពុំលង់ឡើយ

ត្រូវស្ងោតឡូវទោសអ្នកអើយ　ឥតមានចម្លើយចំលើប្រាណ ។

ផុតភ្លើងដាំទឹកពន្ទឹកពុះ　ដាក់ឧសបង្គ់រខ្ពស់ប្រមាណ

ឆេះលេចអណ្ដាតផុតដើងគ្រាន　ពោះប្រាណផ្ទៃប៉ិចលិចរលួយ ។

រលត់ផុតខ្យល់ដល់សង្ខារ　អនិច្ចំអនិច្ចានរណាជួយ

រលាយជីវិតខ្លួនមួយៗ　ទុក្ខព្រួយព្រោះកម្មនាំវង្វេង ។

វិលវល់អំពល់ក្នុងសង្សារ　រាល់រូបបណ្ដារាចាលេង

គួរយកទុក្ខំតាំងរិះឈ្វេង　អនិច្ចំនោះឯងពុំទៀងនៅ ។...

## ២　លោកឧកញ៉ាសុតន្តប្រិយជាឥន្ទ្រ

លោកឧកញ៉ាសុតន្តប្រិយជាឥន្ទ្រ ប្រសូតនៅថ្ងៃចន្ទ ទី២២ខែកក្ដដា ឆ្នាំ១៨៥៩ នៅភូមិរការកោង ស្រុកមុខកំពូល ខេត្តកណ្ដាល ។ មាតាលោកព្រះនាមមុំ បិតាព្រះនាម**បញ្ញង់កែ** មានមុខរបរជាកសិករ និងបិតាលោកក៏ជាគណៈកម្មការអចារ្យវត្តដែរ។ នៅអាយុបាន១៥ឆ្នាំ បិតាបាននាំទៅរៀនអក្សរខ្មែរនៅវត្ត បន្ទាប់មកក៏បានរៀនប្រែធម៌ភាសាបាលី និងបួសជាសាមណេរនៅវត្តព្រែកពោធិ៍។ លោកបានបួសមួយវស្សាក៏បានលាចាកសិក្ខាបទ រួចក៏បានបន្តការសិក្សាជាមួយលោកអាចារ្យ**ពេជ្រ** ស្រុកព្រះត្រពាំង កម្ពុជាក្រោម។ នៅអាយុ១៨ឆ្នាំ លោកក៏បានទៅបន្ត

ការសិក្សា ជាមួយលោកគ្រូព្រះពុទ្ធឃោសាចារ្យ**ប្រាក់**នៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ។ រៀនបានមួយឆ្នាំ ក៏បានទៅបន្តការសិក្សាជាមួយលោកគ្រូអាចារ្យ**សុខ** ស្ថិតនៅវត្តកែវ ខេត្តបាត់ដំបង លុះអាយុ២០ឆ្នាំ លោកក៏បានបួសជាភិក្ខុនៅវត្តកែវនេះបានមួយវស្សា ទើបលាលោកគ្រូឧបជ្ឈាយាចារ្យ ទៅបន្តការសិក្សានៅប្រទេសថៃបាន៧ឆ្នាំទើបត្រលប់មកកម្ពុជាមកគង់នៅវត្តកណ្តាល ខេត្តបាត់ដំបង។

លោកបានរក្សាភេទសង្ឃបាន១០វស្សា ទើបលោកបានលាចាកសិក្ខាបទមកជាមនុស្សសាមញ្ញ និង៍មានភរិយានៅភូមិផ្លូវធំ។ខ្ញុំមានការសោកស្តាយណាស់ដែរ ដោយមិនបានដឹងពីឈ្មោះឧត្តមភរិយាលោក។ លុះក្រោយមក លោក**កថាថន**បានតែង៍តាំង៍លោកជាជាទីហ្លួង៍វិចិត្រវោហារ ដោយកាលនោះ លោកបានប្រែភាសាបាលីជាសម្រាយមានឈ្មោះ ៤៤ឈ្មោះ ដែលសៀវភៅខ្លះក៏ជាស្ទឹករិតដែរ។

នៅអាយុ៥៥ឆ្នាំ រាជការបានចាត់ឲ្យលោកមកបម្រើ ការងារនៅក្រុង៍ភ្នំពេញ ដោយទទួលងារជា **ឧកញ៉ាសុតន្តប្រិយជា** និង៍ឲ្យលោកជួយតែង៍សព្វវចនាធិប្បាយខ្មែរនៅទីសាលាបាលី។ បម្រើការជូនជាតិបាន១០ឆ្នាំ លុះអាយុបាន៦៥ឆ្នាំ លោកក៏បានលាការងាររាជការមករស់នៅឯខេត្តបាត់ដំបង៍ជាមួយប្រពន្ធកូនវិញ។ ជាអកុសល្យនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ១៩៤៤ លោកក៏បានទទួលមរណៈកាលទៅដោយសារតែពេទ្យកព្យាបាលពុំជាសះស្បើយ។

លោកគឺជាគំរូនៃអ្នកប្រាជ្ញមួយរូបខាង៍ទំនៀមទម្លាប់ ដែលលោកបានចេះចាំយ៉ាង៍ស្ទាត់នូវព្រះពុទ្ធសាសនា និង៍ចេះភាសាថៃភាសាបាលីយ៉ាង៍ច្បាស់ទៀតផង៍។

ក្រោយពីមរណៈកាលទៅ លោកឧកញ៉ាសុតន្តប្រិយជាឥន្ទបាន បន្សល់ស្នាដៃមួយចំនួនរាប់ថា ជាការចូលរួមថែរក្សាអក្សរសាស្ត្រជាតិ រួមមានដូចជា៖

- គតិលោក បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ។

- និរាសនគរវត្ត អត្ថបទជាពាក្យកាព្យ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ។

- រឿងអំបែងបែក សរសេរឆ្នាំ១៨៨៩ ជាសាស្ត្រាស្លឹករឹត បោះពុម្ពនៅឆ្នាំ១៩៥៣ ដែលមានចំនួន២ភាគ។

- បឋមសម្ពោធិ អត្ថបទសរសេរជាក្រាំង។

- លោកនិតិបករណ៍ អត្ថបទសរសេរជាពាក្យកាព្យភាសាបាលីរួចអធិប្បាយជាភាសាខ្មែរបោះពុម្ពលើកទី២ដោយពុទ្ធសាសនបណ្ឌិត្យ។

- សុភាសិតច្បាប់ស្រី ជាអត្ថបទកំណាព្យ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ។

- ព្រះរាជពង្សាវតាខ្មែរ ច្បាប់ចម្លងដោយដៃរក្សាទុកនៅបណ្ណាល័យ "សង្គមបេសសកកម្មបរទេសនៅក្រុងប៉ារីស" បកប្រែជាភាសាបារាំងដោយលោកម៉ាទីនព្យ៉ាត (Martine Piat) ។

- ក្បួនមេកាព្យ

ក្រៅពីនេះ លោកបានបន្សល់ស្នាដៃជាច្រើនទៀតដែលបូកសរុបទាំងអស់មានចំនួន២២ស្នាដៃ។

ជាបន្តទៅទៀត ខ្ញុំនឹងលើកយកអត្ថបទ និរាសនគរវត្តមកបង្ហាញជូនមិត្តអ្នកអានដូចខាងក្រោម៖

អនិច្ចាតោថ្មលោកកសាង មើលថាថាងយ៉ាងរស់ស្អុះប្រែប្រាយ

ឥឡូវមកឆ្ងាយធ្លាក់បាក់ខ្ចាត់ខ្ចាយ ស្ដាយអើយស្ដាយមិនគួរមកពិការ។
មានអ្នកព្រៃចង្រៃឥតគំនិត ទៅសំលៀងកាំបិតគ្រឿងប្រហារ
ឲ្យខូចខាតសាច់បង់អសារ មិនស្ដាយការស្នាដៃបុរាណសោះ ។
ឱគោអើយគោឈរមិនមើលមៀង មកឲ្យគេសំលៀងខ្នងគោចុះ
ម្ដេចមិនខឹងខាំវាសំលៀងនោះ ឲ្យវាលុះក្ដីមរណ៍យក៍វាទៅ ។
អាណាអើយបំផ្លាញរូបគោលោក គ្មានប្រយោគឲ្យយល់ការវាក់ជ្រៅ
គួរឬលោកខំសាងតាំងទុកនៅ មកសត្រូវបំផ្លាញរបស់លោក ។
គន់ៗស្ពានស្ពានថ្មតប្រជិត ជាក្ដារដោសជិតប្រកិតគោក
ទោះដំរីថ្មបរជាន់ក៏គ្មានយោក ឥឡូវជ្រោកស្រុតចុះខ្វះតែដើរបាន។
បង្កាន់ដៃថ្មវាសុក្រី ដប់សិរសីដូចស្និតជិតជុំប្រាណ
លើកពពារឡើងពក្នាក់ហាក់ហៅហាន សម្ដែងប្រាណប្រួញរូបជាមួយគ្នា។
មើលនាគរាជអង់អាចអំណាចស្វែង ខ្លួនក៏វែងក្បាលក៏វក់តាមទ្វារ
លូនលើស្ពានមានដើងកលគង្គា កន្ទុយបែកញែកគ្នាតាមទ្វារផ្លូវ។
ឱរូបវាសុក្រីឥតក្រែងគ្រុឌ តាំងសម្ដែងឫទ្ធិរុទ្ធតសត្រូវ
ប្រសិនគ្រុឌមកយល់យ៉ាងពុំនៅ គង់ស្ទុះទៅជ្រកក្នុងកសិណនេះ។
នាគអើយនាគបាសាណបូរាណសាង ពីដើមយ៉ាងល្អឯងម្ដេចអេះ
ឥឡូវនាគងាកធ្លាក់របេះ ឃើញតែរាងយ៉ាងនេះអស់លម្អ ។
ខ្លួនក៏ឃ្លាតក្បាលឃ្លៀងទៅដោយខ្លួន ឃើញតែក្បួនដើងទៀនប្រចាំទ្រ
ស្ដាយអើយស្ដាយស្នាដៃលោកតែងមក មិនតាំងតថាវរៈឲ្យវែងទៅ ។
ឱអនិច្ចាសង្ខារនាគាថ្ម ហ្មាយតស្ថិតស្ថេរចីរកាលទៅ
នេះពុំទាន់ប៉ុន្មានមកហ្មងសៅ មករុះរាយឆ្ងាយទៅទីផ្ដាស ។

ជាបន្តទៅទៀត ខ្ញុំនឹងលើកអត្ថបទសម្រង់ស្នាដៃរបស់លោក បន្ថែមទៀតនៅក្នុងស្នាដៃអក្សរសិល្ប៍**គតិលោក** ដែលស្នាដៃនេះ ត្រូវបានលោកសរសេរចែកជា១០ភាគ និងត្រូវបាន**ពុទ្ធសាសនបណ្ឌិត្យ**បោះពុម្ពឡើងវិញលើកទី៦នៅពុទ្ធសករាជ២៥៣៩ ត្រូវនិងគ្រិស្តសករាជ ឆ្នាំ១៩៦៦ នៅក្នុងភាគទី៣ដែលមានចំណងជើងថា "**ព្រានព្រៃនិងសត្វសេក**" ដូចមានសេចក្តីតំណាលថា ៖

មានចៅព្រានព្រៃម្នាក់ តែងដើរបរបាញ់សត្វម្រឹគបក្សី យកមកចិញ្ចឹមជីវិតនៅជាប្រក្រតី ថ្ងៃ១ចៅព្រានព្រៃ ទៅស្វែងបរបាញ់ក្នុងព្រៃ លុះពេលល្ងាច ក៏ត្រលប់មកផ្ទះវិញ ដើរមកដល់ព្រៃ១ មានដើមឈើធំ១ដើម ដុះនៅខាងផ្លូវ មានមេសេក១ទៅធ្វើសំបុកភ្ញាស់កូននៅលើចុងឈើនោះឯង។

ចៅព្រានព្រៃដើរមកជិតនោះ ហើយពោលពាក្យថា ថ្ងៃនេះ ពេលក៏ចួនណាស់ អញនឹងឡើងយកកូនសេកនៅសំបុកនេះក៏ពុំទាន់ បើដូច្នេះចាំព្រឹកស្អែកចុះ នឹងយកវាទៅស្ងួស៊ី។ ថាហើយ ចៅព្រានព្រៃក៏ដើរហួសទៅផ្ទះ។

ឯមេសេក នៅលើសំបុក លុះបានឮពាក្យព្រានព្រៃគុំនឹងយាយីដូច្នេះ ក៏កើតក្តីភិតភ័យសោកស្តាយបុត្រ នឹងជីវិតអាត្មាថា ឱអញអើយ! កើតមកជាសេកនេះ ជាសត្វឥតពិស ឥតអាវុធនឹងតនឹងមនុស្សនោះសោះ ឥឡូវវាថាព្រឹកស្អែកនេះ វានឹងមកយកកូនអញទៅអាស្រ័យ, ឱ! បើកូនអញដល់នូវសេចក្តីវិនាសហើយ តើជីវិតអញឯណាក៏នឹងតាំងនៅបាន គង់អញស្លាប់តាមកូនអញមិនលែងឡើយ, ឱ កូនអញអើយ! តូចៗពេក ពុំទាន់ដុះក្រាស ដុះស្លាបឲ្យមាំមួន នឹងបាននាំបង្ហើរចេញឲ្យផុត

អំពីសត្រូវនេះ, មួយទៀត អញនឹងគិតរកសត្វណា អាចនឹងជួយបាន
អេះ!

ឱ! បើគិតទៅឃើញឧបាយ១ ល្មមកែខ្លួនបាន គឺអញមានសត្វ
ពស់វែក១ នៅដំបូកខាងនោះ ពស់នោះ ជាសម្លាញ់អញមកយូរហើយ
ចាំអញទៅនិយាយ ឲ្យសម្លាញ់ជួយដោះទុក្ខនេះទើបបាន។ កាលដែល
សេកនោះនោះ គិតដូច្នេះ ក៏ហើរទៅកាន់សំណាក់ពស់ ដល់ហើយទៅ
កាន់សំណាក់ពស់ ដល់ហើយក៏និយាយប្រាប់ពស់ តាមរឿងចៅព្រាន
ព្រៃ វានឹងមកចាប់កូនខ្លួន ក្នុងវេលាថ្ងៃព្រឹកនេះឯង។

ឯពស់វែកឮដូច្នេះ ក៏អាណិតសេកជាសម្លាញ់ទើបទទួលជួយ
ដោះទុក្ខសេក ទើបផ្តាំសេកថា បើព្រាននោះវាឡើងនឹងយកកូនសេក
ឯងកាលណា ឲ្យសេកឯងនិយាយអង្វរស្លូកវាថា លែងតែអ្នកមេត្តាកុំ
យកកូនខ្ញុំទៅចុះ ខ្ញុំនឹងប្រាប់ទីកំណប់មាស ប្រាក់កែវកងនៅទីដំបូក
នោះឲ្យអ្នក ក៏ឯជាតិមនុស្សនោះ តែឮត្រង់កំណប់មាសប្រាក់ហើយ គង់
ចង់បានលើសកូនសេក១-២នោះជា១០០គុណ គង់ឲ្យសម្លាញ់ឯងនាំផ្លូវ
មកដំបូកនេះ សម្លាញ់ឯងចូរប្រាប់វាថា ទីត្រង់នេះហើយ វានឹងលូកដៃ
មកក្នុងរន្ធនេះមិនខាន បើវាលូកដៃមកកាលណាហើយ ខ្ញុំឯងនឹងចឹកវា
ឲ្យលុះដល់មរណកាលនៅទីនេះឯង ឯសម្លាញ់ឯងក៏នឹងរួចពីអន្តរាយ។

មេសេកនោះ បានស្តាបឧបាយកលពស់ប្រាប់ដូច្នោះហើយ ក៏...

សម្រង់អត្ថបទខាងលើសបញ្ជាក់ថា លោកសុតន្តប្រិយជាឥន្ទ
ពិតជាអ្នកនិពន្ធម្នាក់ ដែលមានទេពកោសលដ៏អស្ចារ្យក្នុងការបង្កើតរូបា-
រម្មណ៍ ដែលពោរពេញទៅដោយការអប់រំយ៉ាងទូលាយទូលំសម្រាប់ជា
គន្លឹះដោះស្រាយបញ្ហាជីវិតឲ្យទទួលបាននូវបទពិសោធ ការត្រិះរិះពិចារ

ណា ឲ្យបានល្អិតល្អន់មុននឹងសម្រេចជឿទៅលើអ្វីមួយ។ ពិសេសគឺការអប់រំមិនឲ្យយកសេចក្ដីលូង់ខ្លៅមកដាក់ក្នុងជីវិត។

## ៤ ព្រះភីរម្យភាសាអ៊ូ ហៅងុ៉យ

អ្នកភីរម្យភាសាអ៊ូ ហៅងុ៉យកើតនៅឆ្នាំ១៨៦៥ នៅឃុំកំបូល ស្រុកភ្នំពេញ(ស្រុកអង្គស្នួល) ខេត្តកណ្ដាល។ លោកមាននាមដើមអ៊ុក អ៊ូ ប៉ុន្តែមាតាបិតា លោកច្រើនហៅក្រៅថា **ងុ៉យៗ**ក៏បានជាប់នាមនេះរហូតមក។

បិតាលោកមាននាម**អ៊ុក** ធ្វើជាមេឃុំនៅឃុំកំបូលដែលទទួលគោរម្យងាររថា **ចៅពញាធម្មធារា** ចំណែកមាតាលោកជាកូនចៅពញាម៉ុក មេឃុំស្ពានថ្ម ស្រុកខេត្តជាមួយគ្នា។ តាមឯកសារខ្លះថា មាតាបិតាលោកគឺជាបងប្អូនជីទូតមួយនិងគ្នា។

នៅវ័យកុមារ ក្រមងុ៉យ បានទៅសិក្សាជាមួយព្រះគ្រូចៅអធិការវត្តអង្គបឹងចក ស្ថិតនៅស្រុកកំណើត។ នៅកុមារភាព លោកគឺជាក្មេងដែលឧស្សាហ៍រៀនសូត្រណាស់ លុះបានបួសជាសាមណេរ លោកក៏បានចេះដឹងខាងផ្នែកភាសាបាលីជ្រៅជ្រះដែរ។ បន្ទាប់មកនៅអាយុ២១ ឆ្នាំ សាមណេរងុ៉យ ក៏បានបំពេញឧបសម្បទាជាភិក្ខុនៅវត្តអង្គបឹងចក។

ក្នុងភេទជាសង្ឃ ភិក្ខុងុ៉យ ខិតខំស្វះស្វែងសិក្សាធម៌អាថ៌បានជ្រៅជ្រះណាស់ ដោយលោកខិតខំជួយប្រែគម្ពីរព្រះត្រៃបិដកជាលើកតំបូងនៅសំណាក់លោកគ្រូអាចារ្យ**ទិត្យ** បន្ទាប់ពីនោះមកលោកក៏បានរៀនវិបស្សនាកម្មដ្ឋាននៅក្នុងសំណាក់លោកគ្រូអាចារ្យ ជាច្រើនវត្តទៀតផង។

បន្ទាប់ពីបានលាចាកសិក្ខាបទ ជាសង្ឃមកជាគ្រហស្ថវិញ លោកក៏បានរៀបអាពាហ៍ពិពាហ៍នៅឃុំបែកចាន ស្រុកភ្នំពេញ ខេត្តកណ្ដាល រួចក៏ប្រកបមុខរបរជាអ្នកស្រែចម្ការរស់ក្នុងជីវភាពថ្លៃថ្នូរនៅសង្គម ប៉ុន្តែអ្វីដែលជាលក្ខណៈពិសេសទៅទៀតនោះ គឺទោះបីជាលោកបានលាចាកសិក្ខាបទក៏ដោយ ក៏ពុទ្ធបរិស័ទដែលជាអ្នកមានជំនឿលើព្រះពុទ្ធសាសនា នៅតែអញ្ជើញលោកទៅទេសនាដូចជាសង្ឃដែរ។

ក្នុងជីវភាពជាអ្នកស្រែចម្ការដែលរស់ក្នុងជីវភាពថ្លៃថ្នូរ នឹងជាដែលធ្លាប់បានបួសរៀន លោកតែងតែឆ្លៀតពេលពាក្យប្រៀនប្រដៅប្រជាជនណាស់ពីការរស់នៅក្នុង សង្គមតាមរយៈបទចម្រៀងសាដៀវដែពីពេះរណ្តំប្រកបដោយពាក្យសម្ដីកំប្លុកកំប្លែងជាលក្ខណៈ ដាស់តឿនផង អប់រំផង និងជាពិសេសមានបញ្ចូលការតិទៀនសង្គមសម័យអាណាព្យាបាលផងដែរ។ លោកក៏ធ្លាប់បានច្រៀងឲ្យពួកអ្នកស្រាវជ្រាវបារាំងស្ដាប់ក៏ពេញចិត្ត ទើបត្រូវបានគេចម្លងមកបោះពុម្ពបាន២ច្បាប់ហើយគេក៏បាននាំលោកទៅលេងស្រុកសៀមជាដំណើរទស្សនៈកិច្ច។

ទោះបីស្ថិតក្នុងជីវភាពជាកសិករក្ដី ក្រមង៉ុយគឺជាមនុស្សដែលមានប្រជាប្រិយភាពយ៉ាងខ្លាំងក្នុងចំណោមមហាជនទៅទៀត។ តាមរយៈខ្សែសាដៀវ ដែលបង្ហើរសំឡេងដ៏ត្រលួចពីភូមិមួយទៅភូមិមួយនារដូវចម្រូត ឬរដូវស្ទូងដករួច ក៏រិតតែនាំឲ្យលោកមានឈ្មោះល្បីបន្ថែមទៀតរហូតដល់អ្នកភូមិស្រុកហៅលោកថា **ភិរម្យង៉ុយ**ទៀតផង។ បន្ទាប់មក រដ្ឋអំណាចក្នុងជួររាជការបារាំងសែសក៏បានតាំងលោកជា **ក្រម** មានន័យថា ជា**ការជនដែលបានធ្វើទំនាក់ទំនងរវាងរដ្ឋបាល និងប្រជាជននៅក្នុងឃុំ**។ ក្រោយមក ភាពល្បីល្បាញរបស់អ្នកភិរម្យង៉ុយ ឬក្រមង៉ុយក៏បានសាយរន្ទឺរហូតដល់រាជវាំងនៅទីក្រុង ក៏ត្រូវបានសម្ដេចចក្រីហៅលោក

ឲ្យទៅច្រៀងថ្វាយស្តេចស៊ីសុវត្ថិ ដែលធ្វើឲ្យព្រះអង្គសព្វព្រះទ័យយ៉ាងខ្លាំងក៏ប្រទានងារជា **ព្រះភិរម្យភាសា** និងបានប្រទានរង្វាន់មាសប្រាក់ជាច្រើនដល់លោកទៀតផង។

សំនួនដ៏ពីរោះប្រកបដោយ ការទូន្មានប្រៀនប្រដៅមិនប្រកាន់វណ្ណៈនេះ ក៏នាំឲ្យលោក**សឺ ដេស** G. Coedesជាសមាជិកសាលាបារាំងចុងបូព៌ាប្រទេសក៏បាននាំលោកទៅជួបជាមួយអ្នកស្រី**ស៊ុសានកាពលេស** Suzanne Kapeles ដែលកាលណោះលោកស្រីជានាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។ អ្នកស្រីក៏បានអញ្ជើញអ្នកព្រះភាសាអ៊ូ ង៉ុយ ច្រៀងចម្រៀងសាដៀវជាច្បាប់អប់រំមួយៗរួចក៏ចាត់ឲ្យអ្នកប្រាជ្ញ នៅវិទ្យាស្ថានជាអ្នកកត់ត្រាតាមចម្រៀងដែលលោកបានច្រៀង។ បន្ទាប់ពីធ្វើការកត់ត្រារួច គេក៏បានបោះពុម្ពកំណាព្យនេះជាប្អូនក្បាលដោយធ្វើជាកូនសៀវភៅ។ បន្ទាប់ពីការកត់ត្រាសៀវភៅនេះចប់ អ្នកស្រីក៏បានជូនប្រាក់ទៅលោកចំនួន១រៀលផងដែរ។ គួរបញ្ជាក់ថា ប្រាក់១រៀលនៅសម័យនោះមានតម្លៃថោក តែជាកិច្ចការប្រវត្តិសាស្ត្រចង់បញ្ជាក់ថា បារាំងមិនមែនជាម្ចាស់អាណានិគមដែលមានចិត្តអាក្រក់មកលើខ្មែរទេ ក៏នៅមានបារាំងខ្លះដែលចេះអាណិតខ្មែរដែរ។

ព្រះភិរម្យភាសាង៉ុយ ទទួលមរណភាពនៅឆ្នាំ១៩៣៩ ក្នុងជន្មាយុ៧១ឆ្នាំ។ ចំណងស្នេហារបស់លោកបានបន្សល់ទុកកូន៦នាក់ ដែលក្នុងចំណោមកូនទាំង៦នាក់នោះ មានកូនម្នាក់ជាអ្នកបន្តវេនពីលោក ហើយក៏ជាកូនដែលល្បីខាងសំនួនវោហារណាស់ដែរ តែត្រូវជាប់គុកនយោបាយក្នុងឆ្នាំ១៩៥៥ ខណៈដែលស្រុកខ្មែរកាលនោះមានការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ។

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ អ្នកព្រះភិរម្យអ៊ូ ង៉ុយ បានបន្សល់ស្នាដៃជាកំណាព្យច្បាប់អប់រំមានដូចជា៖

- ច្បាប់ល្បើកថ្មី បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យឆ្នាំ ១៩២២

- សេចក្តីរំឭកដាស់តឿន បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ១៩៣១

- ច្បាប់កេរកាលថ្មី បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ១៩២២

- ច្បាប់ទូន្មានជនប្រុសស្រី បោះពុម្ពផ្សាយដោយពុទ្ធសាសបណ្ឌិត្យ ឆ្នាំ?

- បណ្តាំក្រមង៉ុយ បោះពុម្ពផ្សាយឆ្នាំ១៩៣៥ ដោយ?

ក្រៅពីស្នាដៃខាងលើ នៅមានស្នាដៃមួយចំនួនទៀតដែលអ្នកសិក្សាអក្សរសាស្ត្របានសន្និដ្ឋានថា គឺជាស្នាដៃរបស់លោកដែរ។ ស្នាដៃដែលគេរកឃើញនោះជាទំនុកចម្រៀងមានដូចជា៖

- ការប្រែប្រួលនៃស្រុកទេស

- កត្តញ្ញូកតវេទី

- ត្រៃលក្ខណ៍

ខាងក្រោមនេះ ខ្ញុំនឹងលើកអត្ថបទសម្រង់ខ្លះដែលជាស្នាដៃរបស់អ្នកព្រះភិរម្យភាសាអ៊ូ ង៉ុយដូចតទៅ៖

## ច្បាប់ កេរ្តិ៍កាលថ្មី

កូនអើយការកេរ្តិ៍ឈ្មោះ កុំចង់រស់តែម្នាក់ឯង
គិតអ្វីគិតឲ្យវែង ក្រែងក្រក្រោយសិយគំនិត ។

កំណើតពាល់រូបកាយ ចេញជួញឆ្ងាយស្ដាយជួញជិត
ចិញ្ចឹមជន្មជីវិត គិតឲ្យស្រេចទើបបានស្រួល ។
ធ្វើស្រែចង់បានស្រូវ ដើមរដូវធ្វើស្រែទួល
ស្រែទាបមើលទំនួល លើកទំនប់ឲ្យមាំមួន ។
កូនអើយកេរ្តិ៍មេបា ចាំរក្សាមើលថែថួន
ធុញថប់ថយថោកខ្លួន ជួនជាខ្សត់គេថាខ្ជិល ។
ស្រូវខ្សោយអង្ករថ្លៃ លក់សំចៃទុកឆ្នាំក្រោយ
អ្នកក្រុករកញយៗ ឲ្យអ្នកសុំជាអ្នកខ្ចី ។
សប្បុរសពេកថយធន មូទូជនថយរាសី
ប្រពន្ធច្រើនអាប់ប្ដី ពាក្យអប្រិយចាញ់អាត្មា ។
ឈើផ្លែចាញ់សន្ទូក ត្រីវរកទឹកមិនថ្លា
កំណាញ់ក្រៅតម្រា សោតសឹងអាប់ប្រយោជន៍យស។
នឹងឲ្យៗមើលភាព ឲ្យអ្នកទាបជាអ្នកខ្ពស់
អ្នកទិញឈប់សិនចុះ ក្នុងតែរស់មិនស្លាប់ឆាយ... ។
កុំខ្ជិលកុំល្ងង់ពេក ឲ្យចេះដេកឲ្យចេះដើរ
ចេះសព្វគាប់ប្រសើរ កុំចង់ហើរហួសភាពខ្លួន ។
ចង់ក្ដីឲ្យរៀនច្បាប់ រស់និងស្លាប់ឲ្យចេះក្បួន
ចេះអ្វីចេះឲ្យមួន កុំបន្ទំផ្សំនិងគេ ។
កុំដេកចាំសំណាង កុំភ្លេងភ្លាំងចាំបុព្វេ
ខំរកកុំទំនេរ រៀនរិះចេះឲ្យគ្រប់ ។
នឹងដើរស្វែងរកផល មិនទាន់ដល់កុំអាលឈប់
ឈានខ្លាំងពេកជំពប់ បើដេកយប់ឲ្យស្ដាប់យាម ។
កុំដេកយូរទ្រមឹក លក់ហួសព្រឹកខុសទំនៀម

តែក្តីឡើងភ្ញាក់ភ្ញាម ព្រហាមឡើងក្រោកធ្វើការ... ។

## ច្បាប់ ល្បើកថ្មី

កុំដៀលអ្នកស្រែ ត្រកូលឯងខ្មែរ កុំប្រែក្រឡាស់
ក្រលេកឃើញគុណ ទន់ខ្លួនសំពះ កុំធ្វើអ្នកណាស់
កុំត្មះអ្នកក្រ ។

អ្នកកុំភ្លេចគុណ គ្រូលេខនព្វន្ត គ្រូសូត្រអក្សរ
កុំចាប់ដៃទាញ គំនាប់ផក់ក កុំជដែកត
ស្មើមិត្តសម្លាញ់ ។

រាស្ត្រត់ចូលជ្រក កុំថាគេថោក កុំអើងឯងអញ
ពាក្យពុំពីរោះ គេកើតមួក្នាញ់ គេដៀលផ្ដាលផ្ដាញ់
អន្តរាយកេរ្តិ៍ឈ្មោះ ។

កុំឆ្មើងអាងបុណ្យ ស្រដីឲ្យទន់ ពោលពាក្យពីរោះ
ខ្លួនអ្នកនឹងថ្កើង នឹងឡើងសក្តិយស កុំឆ្មៀតនាំឈ្មោះ
ញុះញង់អ្នកធំ ។

កុំស្អប់អ្នកតូច បើឃើញគ្នាខូច គួចគិតប្រមុំ
ទោសគ្នាតិចតួច ផ្លួចឡើងជាធំ ផ្សែងពូតជាដុំ
ផ្ទុំនេះជាភ្លើង ។...

តាំងពីឆ្នាំចរ ចាំជាតំណ ទំនិញឡើងថ្លៃ
ចង់ក្សិនឲ្យតឹង ប្រឹងកុំសំចៃ សញ្ជឹងយប់ថ្ងៃ
កុំឲ្យក្រខ្សត់ ។

បើចង់ស្រាលខ្លួន រៀនសូត្រឲ្យមួន ឲ្យមាំឲ្យស្ទាត់
កុំចេះស្ទាក់ស្ទើរ ល្ងីល្ងើឥតបទ បើចេះប្រាកដ

ប្រាក់រត់តាមហៅ ។

កុំថ្នមកម្លាំង កាប់ជីកចូកចាំង កុំថារង៉ាក្តៅ
រៀនអ្វីឲ្យឆ្អិន កុំឲ្យខ្វោចឆៅ កុំដេកតែខ្ជៅ
គ្រគ្រៅសណ្តាប់ ។

បើល្ងង់ឲ្យចេះ រៀនរកតម្រិះ រិះរកតម្រាប់
ឥន្ទ្រិយឆ្វេងស្តាំ កុំចាំគេប្រាប់ រៀនស្តីរៀនស្តាប់
រៀនមើលឲ្យស្តែង ។...

សម្អាតផ្ចិតផ្ចង់ លើកភ្លឺឲ្យត្រង់ កុំលើកឲ្យកោង
អ្នកកុំប្រហែស ក្រែងមានប្រហោង លើកមើលទំនង
ទំនាបទឹកហូរ ។

ចំនួនទឹកស្ទឹង ទឹកព្រែកទឹកបឹង ទឹកវាលទឹកអូរ
អ្នកលើលិចស្រូវ ត្រូវបើកចំហរ អ្នកក្រោមកុំថ្ងូរ
បង្ហូរហួសទៅ ។

រាំងរីងថ្ងៃយប់ ឆាប់លើកឆាប់ទប់ កុំឲ្យបាក់ជ្រៅ
កក្តិកចេញខ្យល់ តម្កល់ទឹកនៅ បើចង់បានស្រូវ
ស្រួចនៅត្រឹមថៃ ។

កុំយកគ្រាប់ត្នោត ទៅដាំទៅដោត ពីលើភ្លឺស្រែ
ចិត្តគិតប្រមាណ ចង់បានផ្កាផ្លែ ដាំដុះបង្ហែ
បង្អិនខ្លួនឯង ។

ដល់ត្នោតឡើងគល់ ឡើងកើតនាំខ្វល់ ជាងលូតឡើងវែង
ភ្លូវរាស់ជាប់នឹម គ្របីជាប់ស្នែង ទទើសទទែង
ភ្លូវឆ្វេងមិនត្រូវ ។

ដល់ត្នោតវាធំ មានស្លឹកវាធំ វាជ្រុះក្នុងស្រូវ

ស្រែឆ្ងាយពីផ្ទះ ឃ្លាតណាស់ពីផ្លូវ ទម្រាំតែទៅ
រលួយស្រូវអស់ ។
កុំអើយកុំនោត បើចង់បានត្នោត ដាំឲ្យកៀនកោះ
ដីទួលចម្ការ ឯណាចន្លោះ ដាំជាររបោះ
ជាយជួររបង ។
របៀបចម្ការ ថែទាំរក្សា យូរៗស្រះម្តង
ស្រះឲ្យត្រូវជួរ មើលគួរសមផង កុំបើកមុជឆ្ងង
ទៅស្រះខាងក្រៅ ។
មិនគាប់ប្របសើរ របងវាដើរ អ្នកម្ចាស់វាក្តៅ
កើតក្តីកើតក្តាំ អស់ខោអស់អាវ ខឹងអស់ញាតិផៅ
ពីព្រោះចម្ការ... ។

## ពាក្យកាព្យប្រដៅជនប្រុស-ស្រី

...ព្រាត់គូសម្បត់វត្តសង្ឃា ដូចលក់ដីតាលក់ដីដូន
ពុំនោះលក់បងបំបែកប្អូន ងងិតឈឹងសូន្យមើលពុំយល់។
ខ្លះទៅនរកមិនទាន់មក ខ្លះឃ្លាតទៅជ្រកពួនអសុរ
ជវនសង្សារឡប់ឡប់វិលវល់ អំពល់តែកើតស្លាប់កើតស្លាប់។
កម្មកិតតាមខ្លួនមិនដែលឃ្លាត គ្រប់ប្រាំរយជាតិមិនដែលធាប់
សត្វជ្រូកមាន់ទាគេចាក់កាប់ សម្រាប់គេស៊ីជាអាហារ ។
សត្វគោក្របីដំរីសេះ គេជិះគេទឹមជាធម្មតា
គេកាប់លក់សាច់ផ្តាច់សង្ខារ រកចិត្តមេត្តាករុណាគ្មាន ។
រូបខន្ធរលត់រលាយទៅ សល់នៅសង្ខារនិងវិញ្ញាណ

## ៦ លោកឧកញ៉ា ធូ កន

លោកឧកញ៉ាធូ កន ប្រសូតនៅឆ្នាំ១៨៧៤ ស្ថិតក្នុងភូមិអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ។ មាតារបស់លោកមាននាម**អ៊ុក**និងបិតាមាននាម **ធូ**មានមុខរបរជាកសិករ តែមានជីវភាពថ្លៃថ្នូរ។

អាយុបាន៩ឆ្នាំ ឪពុកលោកក៏នាំទៅឲ្យរៀនវិជ្ជាអក្សរសាស្ត្រជាតិនៅវត្តត្នោត ដើម្បីបានជាចំណេះដឹងខាងផ្លូវលោក។ ក្រោយមកអាយុបាន១៤ឆ្នាំ លោកក៏បានបួសជាសាមណេរបានមួយព្រះវស្សានៅក្នុងវត្តនោះ។

គម្រប់អាយុបាន១៧ឆ្នាំ លោកក៏បានធ្វើជាលេខាធិការឲ្យលោកចៅហ្វាយខេត្តទ្រាំង ដែនដីកម្ពុជាក្រោម។ នៅឆ្នាំ១៨៩១ លោកក៏បានចូលបម្រើការងារ នៅការិយាល័យព្រះបរមរាជវាំង។ បម្រើការនេះបានរយៈកាលតែ៤ឆ្នាំ ក៏បានផ្លាស់មកបម្រើការងារនៅក្រសួងសុរិយោដីនិងខាងរតនាគារ។

នៅឆ្នាំ១៩០២ រាជការបារាំង មានការប្រឡងប្រជែងអ្នកប្រាជ្ញអក្សរសាស្ត្រ លោកក៏បានប្រឡងជាប់បានចំណាត់ថ្នាក់លេខ១ ទើបត្រូវបានរដ្ឋាភិបាលសម័យនោះ បញ្ជូនលោកទៅបន្តការសិក្សានៅប្រទេសបារាំង។ ក្រោយពីបន្តការសិក្សាចប់ លោកក៏បានវិលមករកមាតុភូមិវិញ ទើបរាជការបារាំងសែស ចាត់លោកឲ្យទៅធ្វើចៅហ្វាយខេត្តកំពង់សៀម ជាចាងហ្វាងសាលាដំបូង ជាចាងហ្វាងសាលាឧទ្ធរណ៍ និងជារដ្ឋលេខាធិការក្រសួងកសិកម្ម។

ដោយការយកចិត្តទុកដាក់ជាមួយកិច្ចការរដ្ឋ និងការថែរក្សាសុខទុក្ខប្រជារាស្ត្រ ក៏នាំឲ្យលោកមានប្រជាប្រិយភាពជាខ្លាំងក្នុងដែនដីរបស់លោក។ ហេតុដូច្នេះហើយ ទើបនៅឆ្នាំ១៩៤៦ លោកក៏បានជាប់ឆ្នោតជាតំណាងរាស្ត្រនៅមណ្ឌលកោះសូទិន។

លុះលោកអាយុបាន៧៣ឆ្នាំ ក៏មានជំងឺចាស់ជរាមិនអាចព្យាបាលបានជាសះស្បើយ ក៏ទទួលមរណភាពទៅ។ លោកទទួលមរណៈភាពក្នុងឆ្នាំ១៩៤៧នៅគេហដ្ឋាន លោកឯក្រុងកំពង់ចាម។

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ លោកនូ កនបានបន្សល់ទុកស្នាដៃអក្សរសិល្ប៍ជាច្រើនដូចជា៖

- រឿងទាវឯក ជាប្រភេទរឿងសាស្ត្រល្បែង សរសេរជាកំណាព្យឆ្នាំ១៩៤២ ដែលមានចំនួន៥ភាគ។ រឿងនេះលោកបានបញ្ជាក់ថា លោកចងក្រងរឿងនេះ តាមការតំណាលពីពាក្យចាស់បុរាណ និងសាស្ត្រាល្បែងដែលមានអាយុកាលប្រមាណប្រាំរយឆ្នាំម្យ៉ាងវិញទៀត លោកក៏បានចាំសម្ដីអ្នកចម្រៀងហ្គងរាជស្តេចនរោត្តម ដែលលោកបានចាំក៏យកមកសរសេរជារឿងនេះឡើង។

- រឿងសាមកុក ជារឿងរបស់ចិនដែលបានប្រែជាភាសាថៃតែលោកក៏បានប្រែជាភាសាខ្មែរ។ រឿងនេះត្រូវបានបោះពុម្ពផ្សាយជាបន្តបន្ទាប់នៅទំព័រ ទស្សនាវដ្ដីកម្ពុជសុរិយាតាំងពីឆ្នាំ១៩៤៨ រហូតដល់ឆ្នាំ១៩៧៣- ១៩៧៤ ជាពេលដែលទស្សនាវដ្តីមានជីវិត។

- រឿងពិម្ពានិព្វាន ជាប្រភេទសាស្ត្រល្បែង សរសេរនៅឆ្នាំ១៩២៣ ហើយក៏ត្រូវបានបោះពុម្ពផ្សាយឡើងវិញលើកទី៣ នៅឆ្នាំ១៩៦០នៅរាជធានីភ្នំពេញ។

- រឿងតុងឈិន ជាប្រភេទប្រលោមពាក្យរាយសរសេរនៅឆ្នាំ ១៩៤៧ ជាស្នាដៃដំបូងគេបង្អស់របស់លោកដែលបានសរសេរក្នុងសម័យដែលប្រលោមលោកបានកើតឡើង។ តាមពិត លោកនូកន បានប្រើពាក្យប្រលោមលោកនេះ ដោយមានការបកប្រែពីភាសាបារាំង Roman មានន័យថា ជាអត្ថបទពាក្យរាយខុសពីប្រភេទរឿងល្បែងដែលមានតំណែងជាពាក្យកាព្យ។

- រឿងឥណាវ សរសេរជាពាក្យរាយ មិនទាន់បានបោះពុម្ព
- រឿងលួងតានភក្តី សរសេរជាពាក្យរាយ មិនទាន់បោះពុម្ព
- រឿងមហាសុបស្សីតាបស មិនទាន់បោះពុម្ព
- រឿងសមុទ្រដេជ្ជា មិនទាន់បានបោះពុម្ព

ខាងក្រោមនេះ គឺជាអត្ថបទសម្រង់ដ៏ខ្លីដែលដកស្រង់ចេញពីរឿងទាវឯក ជាស្នាដៃរបស់លោក៖

...លោកនេនទុំពុំផ្ទេសទេសបទស្មូត
តរហូតផុតរឿងអ្នកផងព្ទ
ចេញអស់បែបលេបខាយសាយរន្ទឺ
នោះក៏គឺអាគមផ្សំរាំបហារ ។
ស្រីប្រុសខ្លះគ្រាស់កាមដាមប្រឡាក់
គិតតែស្នេហ៍ត្រូវជាក់ដល់រលំចិន្តា
នឹកឃើញរឿងក្នុងខ្លួនមានសង្សារ
ពីកាលណានិរាសប្រាសទីទៃ ។
ខ្លះក៏ប្រាសទាំងរស់ខ្លះក៏ស្លាប់
លុះមកស្តាប់ស័ព្ទស្មូតកើតរីងរៃ
នឹកដល់ដើមកម្សត់មិត្តមាសមៃ

ផ្អែតហឫទ័យន័យនឹងស្រក់ទឹកនេត្រា ។
ខ្វះអាល័យអាឡោះស្រណោះផ្សេង
ដោយសំឡេងអន្ទងរីងសម្ដេទ
ដូចជាដើរក្នុងព្រៃឆ្ងាយទូរេត
ពេលសុរិយេតសាយណ្ហទន់ត្រជាក់ ។
ខ្វះពោះម៉ាយស្ដាយមិត្តគិតខ្មោចនាង
ឯមេម៉ាយស្ដាយរាងរូបខ្មោចអ្នក
គាអាណោចខ្មោចយាយកយមាយភ្ញាក់
យាយញ័រញាក់នឹកខ្មោចដល់ខ្មោចតា ។...

## ៧ លោកបាន តេង

លោកបាន តេង ប្រសូតនៅខែមិគសិរ ឆ្នាំមមែ ពុទ្ធសករាជ ២៤២៥ ត្រូវនិងឆ្នាំ១៨៨២ នៅសង្កាត់លេខ៤ រាជធានីភ្នំពេញ។ មាតាលោកនាម**ត្រយ៉ង់** និងបិតាមាននាម**បាន** ដែលជាមន្ត្រីបម្រើការនៅក្នុងព្រះបរមរាជវាំង ។ កាលពីកុមារភាព លោកបានចូលរៀននៅសាលាបឋមសិក្សាបារាំងខ្មែរ។ ក្រោយមក នៅអាយុ១៤ឆ្នាំ លោកបានបួសជាសាមណេរនៅវត្តបទុមវតីក្នុងសំណាក់លោកគ្រូសម្ដេចមង្គល អៀម តែបាន១វស្សា លោកក៏បានលាចាកសិក្ខាបទមកវិញ។ បន្ទាប់មក លោកក៏បានបន្តការសិក្សាភាសាបារាំង និងបានសិក្សាភាសាសៀមទៀតផង។ ក្រៅពីវិជ្ជាទាំងនេះ លោកបាន តែងក៏ធ្លាប់បានរៀនក្បួនកាព្យសម្រាប់ការតែងកំណាព្យពីលោកឧកញ៉ាសុត្តន្តប្រិយជាឥន្ទ និងព្រះធម្មរក្ខិត ប៉ាត គង់នៅវត្ត សុគន្ធមានបុណ្យឧដុង្គ។

នៅឆ្នាំ១៩១៩នៅរតនាគារ រួចក្រោយមកលោកក៏ធ្វើជាស្មៀននៅព្រះបរមរាជវាំង។ លុះដល់ឆ្នាំ១៩២១លោកក៏បានចូលបម្រើការងារជូនជាតិជាគ្រូបង្រៀន ដោយរដ្ឋាភិបាលសម័យនោះបានចាត់លោកទៅបម្រើការនៅខេត្តកោះកុង។ លោកបម្រើការងារនៅទីនោះបាន៥ឆ្នាំទើបផ្លាស់មកនៅរាជធានីភ្នំពេញវិញ។ លោកទទួលមរណភាពនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥០ក្នុងជន្មាយុ៦៨ឆ្នាំ។

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ លោកបាន តេង បានបន្សល់ស្នាដៃជាច្រើនដូចជាៈ

- ឱវាទនារី ជាពាក្យកាព្យ បោះពុម្ពផ្សាយក្នុងប្រតិទិន ឆ្នាំ ១៩៤៦
- សប្បុរសធម៌៧ប្រការ ផ្សាយចេញពីពុទ្ធសាសនបណ្ឌិត្យ
- រឿងនាងស្រីហ្សានដាក៏ ជារឿងបកប្រែ
- រឿងលោកធម្មត្តចរិយា
- រឿងឆន្ទន្តជាតក មិនទាន់បោះពុម្ព
- រឿងពិម្ពាពិលាប មិនទាន់បោះពុម្ព
- រឿង ទិព្វសង្វា មិនទាន់បោះពុម្ព
- អត្ថបទសរសេរតាមសូត្រ ព្រមទាំងមានរឿងខ្លីប្រែជាច្រើនទៀតដែលអ្នកសិក្សាមិនបានចាំ គ្រាន់តែដឹងថា គឺមានច្រើនណាស់ខាងផ្នែកវណ្ណកម្មនេះ។

## ៨ អ្នកស្រី សូ សិទ្ធ

អ្នកស្រីសូ សិទ្ធ ប្រសូតនៅថ្ងៃពុធ ខែមិគសិរ ពុទ្ធសករាជ ២៤២៤ ត្រូវនឹងគ្រិស្តសករាជ១៨៨១ នៅសង្កាត់លេខ៤ រាជធានី

ភ្នំពេញ។ លោកស្រីជាកូនស្រី របស់លោក **ពិពិធសិរី** ជាចាងហ្វាងមន្ត្រី ព្រះបរមរាជវាំង។ មាតាអ្នកស្រីមាននាមអ្នកស្រី **ភួង** ។

កាលពីកុមារភាព អ្នកស្រីសូ សិទ្ធបានរៀនអក្សរខ្មែរនៅក្នុង សំណាក់ព្រះបិតា លុះត្រាតែដឹងថេះ ច្បាស់ទើបបានទៅរៀនអក្សរនិង ភាសាសៀមក្នុងសំណាក់មាតា និងអ្នកជិតខាងខ្លះទៀតរហូតអាចមើល អានសរសេរបាន និយាយបានដូចគេ។ ក្រោយមក អ្នកស្រីក៏បានទៅបន្ត ការសិក្សានៅប្រទេសសៀមផងដែរ។

លុះពេលពេញវ័យក្រមុំ មាតាបិតាបានផ្សំផ្គុំឲ្យរៀបការមាន គ្រួសារជាមួយលោក**ផាក់ អាំ** ជាមន្ត្រីបម្រើការរដ្ឋនៅក្រសួងយុត្តិធម៌។ ចំណងស្នេហាមួយនេះ បានបន្សល់ទុកកូនមួយឈ្មោះនាង**ឃុន សាវឌុន** ក៏អ្នកស្រីសម្រេចចិត្តចែកផ្លូវជាមួយប្តី ដោយសារតែប្តីអ្នកស្រីជាមនុស្ស ដែលមានចិត្តកំណាញ់ខ្លាំងពេក។ កាលនោះបុត្រីរបស់អ្នកស្រីទើបតែ មានអាយុបាន៣ឆ្នាំប៉ុណ្ណោះ។

ក្រោយពីបានធ្វើការលែងលះគ្នាជាមួយស្វាមីមក បិតាអ្នកស្រីក៏ បាននាំអ្នកស្រីចូលបម្រើការងារនៅក្នុងព្រះបរមរាជវាំង។ នៅគ្រានេះ អាស្រ័យដោយមានការអប់រំពីមាតានូវចំណេះដឹងនានា អ្នកស្រីក៏បាន រៀនច្រៀងជាមួយគ្រូចម្រៀង និងរបាំបានចេះចាំយ៉ាងឆាប់រហ័ស។ អាស្រ័យដោយអ្នកស្រីមានសំឡេងពីរោះ ហ្វូងស៊ីសុវត្ថិ ក៏បានតាក់តែង អ្នកស្រីជាចាងហ្វាងភ្លេងហ្លួង និងជាលេខាធិការទទួលខុសត្រូវលើ ក្រុមរបាំនិងជាអ្នកតែងកំណាព្យ បែបបទសករាទីសម្រាប់យកមកច្រៀង នៅពេលមានបុណ្យនានា។ នៅពេលទំនេរពីការងារ អ្នកស្រីតែងឆ្លៀត ឱកាសនិពន្ធកំណាព្យ រឿងសរសេរជាពាក្យរាយ ជាច្រើនសៀវភៅ

ដែលសៀវភៅខ្លះក៏បានបោះពុម្ព និងមួយចំនួនទៀត ក៏នៅពយប៉ាយពិបាកក្នុងការប្រមូលយកមកចងក្រង។

ក្នុងនាមជាស្ត្រីខ្មែរម្នាក់ អ្នកស្រីសូ សិទ្ធ តែងតែប្រកាន់នូវប្រពៃ-ណីខ្មែរយ៉ាងខ្ជាប់ខ្ជួន ពោលគឺ អ្នកស្រីតែងតែកាត់សក់ផ្កាថ្កូវ ពាក់ខ្សែកមាស ពាក់ទំហូរទងត្រង់ជាគ្រឿងអលង្ការនៅត្រចៀក ចំណែកការស្លៀកពាក់គឺអ្នកស្រីតែងតែស្លៀកផាមួង ឬក៏ស្លៀកខៀវចងក្បិន ជួនក៏មានស្លៀកសំឡុយដែរ គឺស្លៀកសំពត់ហូលពាក់អាវកមូលដៃខ្លី ពានាផាហ៊ុមពណ៌ស។

លុះដល់បស្ចិមវ័យ អ្នកស្រីក៏បានទៅសំណាក់ធម៌នៅវត្ត លុះត្រាតែជរាមែនទែនទើបបុត្រីនាងឃុន សាវឃុនដែលជាស្នំហ្លួងមុនីវង្សបានយកមកថែរក្សានៅគេហដ្ឋាន។ អ្នកស្រីបានទទួលមរណភាពនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៦៣ ក្នុងជន្មាយុ៨២ឆ្នាំ។

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ អ្នកស្រីសូ សិទ្ធ បានបន្សល់ស្នាដៃមួយចំនួនដូចជា៖

- រឿងពិម្ពាពិលាប សរសេរនៅឆ្នាំ១៨៩៩ ជាប្រភេទសាស្ត្រល្បែង បោះពុម្ពដោយបណ្ណាគារ គីម សេង ភ្នំពេញ ប្រហែលជាឆ្នាំ១៩៤១ មានចំនួន៦៤ទំព័រ។

- រឿងគួរសាងមិត្តមិនទ្រុស្តមិត្ត សរសេរនៅឆ្នាំ១៩៤០ ជាប្រភេទប្រលោមលោកបោះពុម្ពដោយបណ្ណាគារសោយ ប៉ាន ឆ្នាំ១៩៥២ មានចំនួន៦០ទំព័រ និងបានចុះផ្សាយនៅកាសែតកម្ពុជាវង់ឆ្នាំ១៩៤៧

- រឿងចិត្តសត្យា សរសេរនៅឆ្នាំ ១៩៥២ជាប្រភេទប្រលោមលោក បានបោះពុម្ពផ្សាយនៅបណ្ណាគារសោយ ប៉ាន នៅឆ្នាំ១៩៥៣ ដែលមានកម្រាស់៧៣ទំព័រ។

ខាងក្រោមនេះ គឺជាសេចក្ដីសម្រង់ស្នាដៃរបស់អ្នកស្រី ដើម្បីបង្ហាញជូនមិត្តអ្នកសិក្សា បានជ្រាបពីស្នាដៃរបស់លោកស្រីនៅក្នុងរឿងពិម្ពាពិលាប។ សូមប្រិយមិត្តអញ្ជើញអានជាមួយអត្ថបទសម្រង់នេះដូចតទៅ៖

…ប្ដីបើនាងខឹងប្រឹងស្រែកដេរ មិនទេមិនទើងខឹងសោះឡើយ
ប្ដីនាងត្រូវសរស្លាប់ទៅហើយ នាងអើយគឺកម្មនាំសរទៅ ។
ចិត្តបងគ្មានប៉ងនឹងប្រមាថ តែព្រួញវាផ្លាតខ្វាតទៅត្រូវ
បងបាញ់សត្វសោះចុះឥឡូវ ស្រីពៅនៅប្ដីព្រៃព្រឹក្សា ។
យំសោករកប្ដីអាល័យរស់ គឺមោះនឹងបានប្រាណស្នេហា
នេះទៅជាខ្មោចខ្វូចអសារ សោកាធ្វើប្ដីស្រីតាមបង ។
បងនេះជាស្ដេចសោយរាជវង្ស នាមព្រះព្រហ្មទត្តសោយរាជផង
មានទាំងប្រាសាទស្អាតកន្ទង ជាច្បងលើសលប់កពមនុស្សា ។
ពុំទាន់មានគូមកយូរឆ្នាំ ជាកម្មនាំបងឲ្យយាត្រា
កម្មបងប៉ងបាញ់សត្វសកុណា កម្មស្វាមីប្អូនប្រជួនគ្រោះ ។
កម្មសរប្រហារជីវ៉ាក្ស័យ កម្មបងអាល័យស្រីសមយស
កម្មប្អូនឲ្យក្ដៅសៅហ្មងមោះ កម្មប្ដីអស់រស់ហើយមាសថ្លៃ… ។

## ជំណាក់កាលទី២

នៅសម័យអាណានិគមបារាំងដំណាក់កាលទី២នេះ គឺចាប់ផ្ដើមពីមានកំណរកំណើតអក្សរសិល្ប៍ទំនើប ដែលបានចាប់ផ្ដើមពីឆ្នាំ ១៩៣៨រហូតដល់សម័យឯករាជ្យ។ អក្សរសិល្ប៍ទំនើបនេះ គឺគិតពីការដែលអ្នកនិពន្ធចាប់ផ្ដើមសរសេរវណ្ណកម្មរបស់គាត់ជាពាក្យរាយ។ ស្នាដៃ

របស់អ្នកនិពន្ធដែលស្ថិតក្នុងសម័យនេះ ខ្ញុំសុំលើកយកមកបង្ហាញជូនមិត្តអ្នកអានដូចតទៅ៖

## ១ លោករីម គីន

លោករីម គីន កើតនៅថ្ងៃទី ៨ខែវិច្ឆិកា ឆ្នាំ១៩១១ នៅបាក់ទូក សង្កាត់ទី៥ រាជធានីភ្នំពេញ។ បិតាលោកមាននាម**គីម** ជាចៅហ្វាយខេត្តកំពង់ស្ពឺ មាតានាម**សោ**។ កាលពីនៅកុមារ មានឈ្មោះហៅថា **ពន្ទក**និង បានរៀនសូត្រនៅវត្តស្វាយដង្គំ ក្នុងសំណាក់លោកគ្រូ **សាំង**ដែលត្រូវជាឪពុកមា។

នៅវ័យសិក្សា កុមារពន្ទកបានរៀនអានសាស្ត្រច្បាប់ និងបានរៀនអានសាស្ត្ររឿងជាច្រើន។ ការរស់នៅក្នុងវត្ត លោកបានគ្រេបសេជាតិពុទ្ធសាសនា និងបានស្គាល់ពីជីវភាពនៅវត្តបានច្បាស់ណាស់។ លុះអាយុបាន១០ឆ្នាំ ក៏បានទៅចុះឈ្មោះចូលរៀននៅសាលាឧដាជីឡាគ្រេ។ បន្ទាប់មក គាត់ក៏បានប្តូរឈ្មោះមកជាកាំងវិញ។

មូលហេតុដែលឈ្មោះគាត់មកជារីម គីនវិញ ពីព្រោះមកពីមេឃុំគាត់សរសេរឈ្មោះខុសពី**គិម កាំង** ទៅជា**រីម គីន**វិញ។ នៅបន្ទាប់ពីបានរៀនចប់នៅសាលាឧដាជីឡាគ្រេមក គាត់ក៏បានចូលទៅរៀននៅសាលាអនុវិទ្យាល័យស៊ីសុវត្ថិនៅឆ្នាំ១៩២៥ បន្ទាប់មក គាត់ក៏បានចូលបម្រើការងារជាគ្រូបង្រៀននៅខេត្តបាត់ដំបង។

នៅថ្ងៃពុធ ទី១៦ខែមករា ឆ្នាំ១៩៣៥ លោកក៏បានរៀបការជាមួយចៅស្រីលោកចៅក្រម**ស្រ៊ីន** មានឈ្មោះថា នាង**ស៊ុមន** ។ លោកទទួលនាទី ជាអនុរក្សនៅអនុវិទ្យាល័យស៊ីសុវត្ថិនៅឆ្នាំ១៩៣៤បន្ទាប់មកទៀតក៏បានទៅបង្រៀននៅសាលាចាក់អង្រែ។ នៅឆ្នាំ១៩៤៧ក៏បាន

ផ្លាស់មកភ្នំពេញវិញ និងបានទៅបង្រៀនសាលាគរុវិជ្ជា។ លោកក៏ធ្លាប់បានបង្រៀនភាសាខ្មែរនៅសាលាទាហាន ដែកាក្នុងឆ្នាំ១៩៥៥-១៩៥៦ដែរ។ នៅក្នុងឆ្នាំដដែលនេះ លោកក៏បានជាប់ឆ្នោត ជាប្រធានសមាគមអ្នកនិពន្ធខ្មែរនៅភ្នំពេញដែរ។ បន្ទាប់មកនៅឆ្នាំ១៩៥៧ លោកក៏បានបង្រៀននៅសាលាភូមិន្ទរដ្ឋបាល។ លោកទទួលអនិច្ចកម្មនៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៥៩ ក្នុងជន្មាយុ២៨ឆ្នាំដោយសារោគរលាកខួរក្បាល។

ជាបន្តទៅនេះ ខ្ញុំសូមលើយកពីទឹកចិត្តលោករីម គឺនក្នុងវិជ្ជាតែងនិពន្ធបន្តិចជូនមិត្តអ្នកអានដើម្បីឲ្យដឹងថា លោកពលីអ្វីខ្លះក្នុងនាមលោកជាកូនខ្មែរមួយរូប ។លោកបានធ្វើការមួយ ដែលសមត្ថភាពលោកមាន និងជាពិសេសកិច្ចការនោះ គាត់អាចធ្វើបានជូនជាតិ។

នៅអាយុ១៨ឆ្នាំ គ្រាដែលលោករៀននៅអនុវិទ្យាល័យស៊ីសុវត្ថិ ក្នុងឆ្នាំ១៩២៩-១៩៣០ ដែលគ្រានោះ សាលាអនុវិទ្យាល័យនេះជាសាលាឥណ្ឌូចិន ទើបមានសិស្សសាលាយួនជាច្រើន គឺមានចំនួនមិនចាញ់ខ្មែរទេបានចូលមកសិក្សា។ គួរកត់សម្គាល់ថា ប្រទេសយួនកាលនោះ ក៏ជាប្រទេសមួយដែលស្ថិតក្រោមអាណានិគមបារាំងដែរ តែប្រទេសនេះ ក៏មានអ្នកនិពន្ធជាច្រើនបានសរសេរសៀវភៅរឿងនឹងត្រូវបានបោះពុម្ពផ្សាយ។ កាលនោះ នៅតាមទីប្រជុំជននានាក្នុងប្រទេស គឺមានការដាក់លក់សៀវភៅប្រភេទនេះ ជាច្រើនត្រូវបានដាក់លក់។ កាលដែលគាត់ឃើញដូច្នេះ ក៏កើតមានចិត្តមួយនឹកអៀនខ្មាស់ចំពោះជាតិសាសន៍នេះ ទើបបណ្ដាលឲ្យគាត់មានសេចក្ដីឈឺចាប់ ក៏បណ្ដាលឲ្យគាត់ហាត់សរសេរបង្ហាញពីមនោសញ្ចេតនាខ្លះជាពាក្យកាព្យ ហើយតែងតែយកមកអានធ្វើជាបទនៅពេលដែលចេញលេង ឬនៅពេលយប់។ ប្រការដែលធ្វើឲ្យគាត់ហាត់សរសេរនេះ ក៏បណ្ដាលឲ្យគាត់ត្រូវបោះ

បង់ការសិក្សាមុខវិជ្ជា មួយចំនួនទើបធ្វើឲ្យការសិក្សាត្រូវថមថយ។ មិត្តភក្តិអ្នកសិក្សាជាមួយគ្នា នៅពេលដែលឃើញគាត់មានការយកចិត្តទុកដាក់ការសរសេរដូចនេះ ពួកគេម្នាក់ៗ ក៏នាំគ្នានិយាយចំអកនិងដាក់ងារឲ្យគាត់ថាជាភាសាបារាំងថា "ប៉ូអែត" ដែលមានន័យថា កវីនិពន្ធ។ បើទោះបីជាយ៉ាងនេះក្តី ក៏លោកនៅតែមានមហិច្ឆតាចង់ប្រែរឿងរបស់ ម៉ូលីយែរ ដោយមិនបានចាប់អារម្មណ៍ខឹងនិងនរណាឡើយ។ អ្វីដែលផ្ទុយពីនេះទៅវិញ លោករិតតែមានការស្មុះស្មារក្នុងការបន្តស្នាដៃទៅទៀត។

នៅផ្នែកវណ្ណកម្ម អក្សរសិល្ប៍លោកបានបន្សល់ស្នាដៃជាច្រើនដូចជា៖

- រឿងសូផាត បោះពុម្ពនៅឆ្នាំ១៩៣៨ ដោយការបោះពុម្ពសៀវភៅនេះលោកបាន ខ្ចីប្រាក់ពីហិបសមាគមមិត្តអនុវិទ្យាល័យវិទ្យាល័យស៊ីសុវត្ថិចំនួន៣០០រៀលដើម្បីបានបោះពុម្ព។ នៅឆ្នាំ១៩៤២រឿងសូផាតត្រូវបាននាំពីពេងពុម្ពមាន់សាន់ នៅ **ច្រើឡឹង**ប្រទេសវៀតណាមខាងត្បូង ចំនួន២០០០ក្បាលមកដល់ប្រទេសកម្ពុជា។ សាច់រឿងនេះ គឺជាប្រលោមលោកលើកទី១ របស់ខ្មែរដែលបានទាក់ទាញអារម្មណ៍អ្នកអាននៅស្រុកខ្មែរឲ្យមានការចាប់អារម្មណ៍ជាច្រើន។ រយៈពេលតែ៦ខែប៉ុណ្ណោះ រឿងប្រលោមលោកទាំងអស់ត្រូវបានលក់ដាច់ពីបណ្ណាគារនៅទូទាំងរាជធានីភ្នំពេញ។

- រឿងចិត្តចងចាំ លោកបានសរសេរនៅឆ្នាំ១៩៤៨ រឿងនេះត្រូវបានយកទៅសម្តែងនៅក្នុងរាត្រីសមោសរមួយ ហើយក៏ត្រូវបានប្រឡងជាប់ ចំណាត់ថ្នាក់លេខ១ក្នុងការប្រកួតប្រជែងស្នាដៃអក្សរសិល្ប៍នៅទូទាំងប្រទេស។

- រឿងស្រីកំព្រា រឿងប្រលោមទំនើបមួយនេះ ត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៥១ ហើយក៏ទទួលបានការចាប់អារម្មណ៍ពីសំណាក់អ្នកអានក្នុងប្រទេសដែរ។

- រឿងមើលព្រះចន្ទ្រា ត្រូវបានបោះពុម្ពនៅឆ្នាំ១៩៥២

-រឿងនាងសមាការី ត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៥២ ក្រោយមក លោកក៏បានបកប្រែរឿងនេះទៅជាភាសាបារាំងតាមការសន្យារបស់លោក **បារេ**ថាយកទៅបោះពុម្ពផ្សាយ តែគេមិនបានឃើញបោះពុម្ពទេ។

- រឿងពលវង្សា បោះពុម្ពនៅឆ្នាំ១៩៥៣

-រឿងនាងរតននារី ត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៥៤ តែរឿងនេះលោកបានសរសេរនៅឆ្នាំ១៩៥២ជាអត្ថបទកំណាព្យ។

- រឿងឈាមរកឈាម លោកបានបោះពុម្ពនៅឆ្នាំ១៩៥៥នឹងត្រូវបានសរសេរនៅឆ្នាំ១៩៥៣ ជាអត្ថបទប្រភេទកំណាព្យ។

- រឿងសេនាកម្សត់ សរសេរនៅឆ្នាំ១៩៥៣

- រឿងរៀនមើលពន្យល់ បោះពុម្ពនៅឆ្នាំ១៩៥៧

-រឿង រឿងខ្ញុំ សរសេរនៅឆ្នាំ១៩៣៥

-រឿងមនុស្សគមទាំងបួន សរសេរនៅឆ្នាំ១៩៣៧ជាប្រភេទល្ខោន។ ការសរសេររឿងនេះ គឺដើម្បីឆ្លើយតបនឹងសេចក្ដីត្រូវការរបស់សមាគមសិស្សចាស់ និងមិត្តនៃអនុវិទ្យាល័យ និងវិទ្យាល័យស៊ីសុវត្ថិ សម្រាប់យកទៅលេងល្ខោន។

- រឿងចោរគួចេតនា មិនបានដឹងកាលបរិច្ឆេទ

- រឿងនាងសាមណើ សរសេរនៅឆ្នាំ១៩៤៣

-រឿងអ្នកកុដុម្ពីរមន្ត្រីកិត្តិយស ប្រហែលជាសរសេរនៅ អំឡុងឆ្នាំ ១៩៦២-១៩៦៥ ជាប្រភេទល្ខោនដែលលោកបានសរសេរយកលំនាំតាម លោកម្ចូលីយែ ហើយរឿងនេះក៏បានយកទៅសម្ដែងក្នុងឱកាសបុណ្យកឋិនម្តង និងរាត្រីសមោសរម្តងដោយសិស្សសាលាគរុវិជ្ជា។

- ថ្វាងផ្ទុះធ្វាយ ជាប្រភេទអត្ថបទល្ខោន។

- ក្បាលគ្នាទំពែក ជាអត្ថបទប្រភេទល្ខោន។

- កម្លោះអាយុ៥០ឆ្នាំ ជាអត្ថបទប្រភេទល្ខោន។

-គិនវិឡ្លី សរសេរនៅឆ្នាំ១៩៦៦ សម្រាប់ការយកទៅសម្តែងក្នុងឱកាសបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រវដ្តសភាទី១ ក្នុងគោលបំណងការពារ ផលប្រយោជន៍ឲ្យគណបក្សប្រជាធិបតេយ្យ ។

- វិស្សមកាល សរសេរនៅឆ្នាំ១៩៦៦ ជាអត្ថបទប្រភេទល្ខោន សម្រាប់ការយកទៅសម្តែង នៅរាត្រីសមោសរដើម្បីជួយសង្គមនិសិត្សខ្មែរ។

-រឿងលួចស្រឡាញ់លួចកើតទុក្ខ សរសេរនៅឆ្នាំ១៩៦៨ជាអត្ថ-បទប្រភេទល្ខោន។

-រឿងក្លាហាន ជាអត្ថបទប្រភេទប្រលោមលោក សរសេរនៅឆ្នាំ ១៩៦៩ ហើយនៅឆ្នាំ១៩៥៣ត្រូវបានបោះពុម្ពផ្សាយ។

-ទឹងមមីង សរសេរនៅឆ្នាំ១៩៥០ និងនៅឆ្នាំ១៩៥៣ត្រូវបានបោះពុម្ពផ្សាយ។

- រឿងព្រះរាជកុមារ មិនបានដឹងកាលបរិច្ឆេទ។

- រឿងសេនាក្លាហាន សរសេរនៅឆ្នាំ១៩៥៥

- រឿង ជំទាវ មិនបានដឹងកាលបរិច្ឆេទ។

- រឿងជីម៉ៅ មិនបានដឹងកាលបរិច្ឆេទ។

- រឿងប្រច័ណ្ឌ មិនបានដឹងកាលបរិច្ឆេទ។

- រឿង ឲ្យស្គាល់ សរសេរនៅឆ្នាំ១៩៣៥

-រឿង កូនអ្នកកាប់ឱស ជាអត្ថបទប្រភេទល្ខោនដែលលោកបាន សរសេរទុកជាអនុស្សាវរីយ៍ គ្រាដែលលោកត្រូវបែកពីអនុវិទ្យាល័យក្នុងឆ្នាំសិក្សា១៩៣៣-១៩៣៤ សម្រាប់យកទៅសម្ដែងដែលរឿងនេះក៏ជាប្រភេទកំណាព្យដែរ។

- រឿងអ្នកត្រកូលខ្ពស់ម្នាក់ជាអ្នកក្រ ជាអត្ថបទរឿងប្រភេទបកប្រែពីភាសាបរទេស។

- រឿងឡឺស៊ីត និងរឿងគ្មានគ្រួសារ ជាអត្ថបទបកប្រែពីស្នាដៃរបស់លោក គ័រណៃ (Corneille)។

ខាងក្រោមនេះ ខ្ញុំសូមដកស្រង់អត្ថបទសម្រង់រឿងសូផាតនិងរឿងនាងសមាការីដែលជាស្នាដៃដ៏វិសេសរបស់លោករឹម គីនមកបង្ហាញជូនមិត្តអ្នកអានដូចតទៅៈ

## រឿង សូផាត

លោកសួនជាចៅហ្វាយស្រុក ស្រុកសេរីសោភ័ណ ជានាហ្មឺនប្រកបដោយរូបឆោមល្អឆើតឆាយ សមសួននឹងតម្រេះវិជ្ជា លោកមានអាយុទើបតែ២៣ឆ្នាំទេ ប៉ុន្តែលោកមកកាន់កាប់ស្តីទីរាជការចំនួនពីរឆ្នាំហើយ ក្នុងស្រុកសេរីសោភ័ណនេះ។ លោកមិនបានជណ្ដឹងស្ត្រីឯណាមួយធ្វើជាគូគាប់ចិត្តសោះ ប៉ុន្តែរាស្ត្រទាំងពួងដឹងជាក់ថាលោក បានទៅរួមរ័ក ដោយលាក់កំបាំងនឹងស្ត្រីកំព្រាម្នាក់ឈ្មោះនាង សូយាចំនួនប្រាំពីរខែហើយ។

ថ្ងៃមួយលោកសួន បានទទួលសំបុត្រពីរាជការធំ ដែលនៅភ្នំពេញផ្លាស់លោកទៅទីក្រុង ដើម្បីទៅកាន់កាប់ទីរាជការថ្មីទៀត។

លោកសួនគិតថា ខ្លួនអើយ! មកនៅស្រុកនេះចំនួនពីរឆ្នាំហើយ ឃ្លាតចេញពីក្រុងភ្នំពេញ ដែលជាស្រុកកំណើតរបស់ខ្លួន ហើយដែលខ្លួនមិនដែលបានទៅណាមកណាឃ្លាតយូរដល់ម្ល៉េះសោះ!

អ្នកម្ដាយមេម៉ាយនៅតែម្នាក់ឯង ឯរាជធានី តែងនឹករឭកខ្លួនរាល់ថ្ងៃ។ ការដែលរាជការតម្រូវឲ្យត្រលប់ឲ្យទៅស្រុកវិញ ជាការប្រសើរណាស់។...

ថ្ងៃមួយមុននឹងទៅធ្វើការ សួផាតចូលទៅជម្រះកាយក្នុងបន្ទប់ទឹក។ វេលាដែលលុបលាងខ្លួន សួផាតដោះចិញ្ចៀនដែលអ្នកទើបនឹងបញ្ចេញពាក់ប៉ុន្មានថ្ងៃនេះ ទុកនៅក្បែរពាងទឹក លុះងូតទឹកស្រេច ក៏ប្រញិបប្រញាប់ចេញពីបន្ទប់ទឹកភ្លាមភ្លេចគិតដល់ចិញ្ចៀន។ ក្រោយមកនាងម៉ាន យ៉ានចូលទៅក្នុងបន្ទប់នោះដែរ នាងភ្ញាក់ស្មារតីព្រើតដោយក្រលេកឃើញត្បូងចិញ្ចៀន ចាំងមាសភ្លឺក្រហមទេង ចិញ្ចៀនពីណាអេះ? នាងរើសយកមកមើលទើបពិចារណាថា "ពេជ្រនេះល្អណាស់! មាសសុទ្ធល្អ ចិញ្ចៀនអ្នកណា! បើរបស់មីង ឬលោកប៉ា ម្ដេចក៏អញមិនដែលឃើញ?"

នាងកាន់ចិញ្ចៀនចេញពីបន្ទប់ទឹក ទើបឡើងលើផ្ទះ។ លោកអធិបតីកំពុងតែងខ្លួននឹងអញ្ជើញទៅសាលា។...

លោកអធិបតីសេនាសួន ចាប់ដៃសួផាតទាំងពីរ "កូនប្រុសឯងជាកូនអញ បង្កើត អញនេះហើយឈ្មោះសួន ពីដើមអញធ្វើបាល័ដ្ឋនៅសេរីសោភ័ណ...ពុកស្មានថាជាអ្នកស្លាប់យូរណាស់មកហើយ!" ទើប

លោកបែរមកចាប់ស្មាម៉ាន យ៉ានទាំងពីរ "កូនស្រី! ឪពុកស្មានថា កូនលង់ទឹកស្លាប់..."

ស្ទូផាតនិងម៉ាន យ៉ានស្ទុះទៅឱបឪពុកជាថ្មីទៀត ហូរទឹកភ្នែកសស្រាក់ៗ ឧកញ៉ាសួន អញ្ជើញទៅជិតសំណាងទើបមានប្រសាសន៍ថា "នាង! បណ្ណាការទាំងប៉ុន្មានដែលអ្នកបានជូនខ្ញុំ ខ្ញុំនឹងបង្វិលជូនអ្នកឲ្យគ្រប់ចំនួន ខ្លួនអ្នកមិនមែនជាគូព្រេង និងក្លាយប្រពន្ធខ្ញុំទេ នាងម៉ាន យ៉ានមានចិត្តចេតនាតែលើកូនខ្ញុំនេះ លោកចង្អុលស្ទូផាត ខ្ញុំនឹងផ្សំផ្គុំរៀបការអ្នកទាំងពីរឲ្យបានជាគ្នាជាភរិយាស្វាមីតទៅ។

សំណាងសំពះលាលោកឈ្មោកមុខដើរចេញ។

ប៉ុន្មានថ្ងៃក្រោយមក គេរៀបការស្ទូផាត និងម៉ាន យ៉ានយ៉ាងអ៊ឹកធឹកគគ្រឹកគគ្រេង។ ក្នុងបណ្ដាភ្ញៀវទាំងប៉ុន្មាន មេស្រុកនិងនាយក៏ សើចក្អាកក្អាយជាងគេទាំងអស់។

## រឿង សមាគារី

មេចោរនិងកូនចោរ បានចាប់នាងសមាគារីនាំទៅដល់សំណាក់វា។ លុះមេចោរក្រឡេកឃើញប្រពន្ធវារត់មកទទួលវា វាក៏និយាយប្រាប់ថា ៖ "អញរកបានខ្ញុំយកមកឲ្យបម្រើឯង ម៉េចឯងពេញចិត្តទេ?"

និយាយដូច្នោះហើយ មេចោរច្រាននាងសមាគារីទៅជិតប្រពន្ធវា៖ "ម្ដេចមិនសំពះសួរនាយចៅហ្វាយ មេឈ្លើយ មេនេះឈ្លើយមែន"។

នាងសមាគារីលើកដៃសំពះចោរីដោយទើសទាល់។

ប្រពន្ធមេចោរធ្វើមុខក្រញូវ៖ "ហាងឯងជាសាហាយនឹងប្ដីអញឬ?"។

អាប្ដីឆ្លើយកាត់ៈ "ឲ្យតែឃើញស្រី ចេះតែម៉ែថាគេសាហាយនឹងអញ ប្រចណ្ឌអីក៏ប្រចណ្ឌម្ល៉េះ"។

-មិនឲ្យខ្ញុំប្រចណ្ឌឯណាបាន ដើរបាត់ៗពល់តែយប់។

-អញដើរបាត់ៗ អញទៅធ្វើការអញ...

-ធ្វើទុច្ចរិតកម្ម។

-យើ! ឥឡូវនេះ គេចេះចរិយាសាស្ត្រច្រើនណាស់។ បើឯងជាមនុស្សសុចរិត ហេតុដូចម្ដេចក៏មកយកអញជាមនុស្សដើររកស៊ីលួចប្លន់គេ?

ប្រពន្ធមេចោរសើចៈ "នាងរត់រកអ្នក ខាតលក្ខណ៍រត់រកកំបាក់អន្សា"។

ទាំងពីរនាក់ប្ដីប្រពន្ធសើចឡើងព្រមគ្នា។

ចោរនិយាយទៅកាន់នាងក្រមុំៈ "ហាងឯងធ្វើការអីកើត"។

នាងសមាការីលើកដៃសំពះៈ "ចាះ! ខ្ញុំចេះបោស និងចេះរៀបចំផ្ទះធ្វើម្ហូបចំណីយ៉ាងចំណាប់ចំណាន"។

-នាងឯងចេះតែការឥតប្រយោជន៍។ ផ្ទះចោរមិនចាំបាច់បោសសម្អាតអីទេ យើងត្រូវការអាហារថ្ងៃថ្លាអីទេ។ មីនាងឯងចេះជិះសេះទេ? ណ្ហើយ ចេះក៏ដោយ មិនចេះក៏ដោយត្រូវរៀនធ្វើការទៅ អញនឹងប្រើនាងឯងយកសេះទៅលាងពល់ថ្ងៃ។ សល់ពីពេលលាងសេះ ត្រូវនៅបម្រើអញ គក់ច្របាច់ដើងដៃធ្វើសរសៃឲ្យអញ។

ស្ដាប់ប្រពន្ធមានវាចា មិនទាន់ចប់ពាក្យប៉ុន្មានម៉ាត់ខាងលើនេះផង មេចោរក៏ដើរចេញត្ដោះទៅពិនិត្យទ្រព្យសម្បត្តិដែលទើបនឹងប្លន់បានមក។

ប្រពន្ធមេចោរនិយាយកាន់ទៅនាងសមាការីទៀតថា...

## ២ លោកឈុង ហាច

លោកប្រសូតនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩១៦ នៅឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង។ បិតារបស់លោកមាននាម ឃួន នៅ ចំណែក មាតានាមឱរ មួច។

លោកមានវ័យគម្រប់ចូលសិក្សា បិតាក៏បានយកទៅឲ្យសិក្សា នៅវត្តក្នុងភូមិកំណើត ។ ក្នុងការសិក្សានេះ លោកបានចេះចាំយ៉ាងស្ទាត់ ជំនាញខាងអក្សរសាស្ត្រជាតិ និងចេះអានគម្ពីរសាស្ត្រាយ៉ាងស្ទាត់ជំនាញទៀតផង។

មកដល់ឆ្នាំ១៩៣២ លោកក៏បានប្រឡងជាប់ចូលរៀននៅ សាលាអនុវិទ្យាល័យស៊ីសុវត្ថិ រហូតមកដល់ឆ្នាំ១៩៣៩ លោកក៏បាន ប្រឡងជាប់មធ្យមសិក្សាភាគទី១ រួចក៏បានចូលបម្រើការងារជូនជាតិជា ចៅក្រម។ បន្ទាប់មក លោកក៏បានផ្លាស់ទីលំនៅមករស់នៅរាជធានី ភ្នំពេញបន្ទាប់អីលោកបានរៀបអាពាហ៍ ពិពាហ៍។

លោកក៏ធ្លាប់បម្រើ ការងារនៅក្រសួងឃោសនាការកាលពីឆ្នាំ ១៩៤៧ ដែលកាលនោះលោកទទួលនាទីជាអ្នកកាន់កាប់ខាងការផ្សាយ កាសែតកម្ពុជា។ ជាបន្តមកទៀត នៅឆ្នាំ១៩៤៨ លោកក៏ត្រូវបានជ្រើស រើសធ្វើជាលេខាផ្ទាល់របស់ទ្រង់យុទ្ធិវង្ស ដែលកាលនោះព្រះអង្គទ្រង់ គង់ជានាយករដ្ឋមន្ត្រី។ ក្រោយមក ព្រះអង្គក៏ទ្រង់សោយទីវង្គត លោកក៏ បានត្រលប់មកកាន់ការជានាយខុទ្ទកាល័យ នៅក្រសួងឃោសនាការ វិញ។

លោកក៏បានធ្វើជាមន្ត្រីក្រសួងការបរទេស ដែលទទួលនាទីជា

មន្ត្រីការទូតខ្មែរ នៅឆ្នាំ១៩៥២ដែលកាលនោះ ប្រទេសខ្មែរស្ថិតនៅក្រោមការត្រួតត្រារបស់បរទេសនៅឡើយ។ មកដល់ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៥២ ដល់ថ្ងៃទី២៣ ខែមករាឆ្នាំ១៩៥៣ លោកក៏ត្រូវបានសម្តេចនរោត្តមសីហនុ ដែលកាលនោះព្រះអង្គទ្រង់គង់ជានាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា បានសព្វព្រះទ័យតែងតាំងលោក ជារដ្ឋលេខាធិការនៃក្រសួងសាធារណការ និងគមនាគមន៍។

លោកក៏ជាសមាជិកម្នាក់ នៃសមាគមអ្នកនិពន្ធខ្មែរសម័យថ្ងៃទី ១៧ ខែមករា ឆ្នាំ១៩៥៨ ហើយក្រោយមក នៅតំណាក់កាលចុងក្រោយនៃតំណែងការងាររបស់លោក នៅឆ្នាំ១៩៦៩ លោកក៏បានវិលមក កាន់ការជាឯកអគ្គរាជទូតខ្មែរប្រចាំប្រទេសឥណ្ឌូនេស៊ី។ លុះដល់ឆ្នាំ១៩៧២ លោកក៏បាននិវត្តន៍មកក្រុង ភ្នំពេញវិញ រួចនៅឆ្នាំ១៩៧៥ដល់ឆ្នាំ ១៩៧៩ លោកក៏បាត់ខ្លួនមិនមានដំណឹងតាំងពីពេលនោះមក។

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ លោកនូហាចបានបន្សល់ទុកស្នាដៃអក្សរសិល្ប៍សំខាន់ៗដូចជា៖

- រឿងផ្កាស្រពោន ប្រលោមសរសេរជាពាក្យរាយ បោះពុម្ពឆ្នាំ ១៩៤៩ ដោយពិនិត្យឃើញថារឿងនេះមានគតិល្អសម្រាប់ការអប់រំ ក៏ត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សារដ្ឋនៅឆ្នាំ១៩៥៨

- រឿងនារីជាទីស្នេហា បោះពុម្ពឆ្នាំ១៩៥៣ ជាប្រភេទប្រលោមលោកសរសេរជាពាក្យរាយ។

-លាណា្យ និងវង្ស ត្រូវបានបោះពុម្ពនៅឆ្នាំ១៩៥៥ ជាប្រលោមសរសេរជាពាក្យរាយ។

- រឿងមាលាដួងចិត្ត បោះពុម្ពនៅឆ្នាំ១៩៧២ ជាអត្ថបទប្រលោមសរសេរជាពាក្យរាយ។

ខាងក្រោមនេះ គឺជាអត្ថបទសម្រង់នៅក្នុងរឿង "មាលាដួងចិត្ត" ដែលខ្ញុំលើកយកមកបង្ហាញជូនមិត្តអ្នកអានដូចតទៅ៖

"សេចក្ដីចង់ដឹងទាំងនេះ បាននាំឲ្យទីឃាវុធប្រញាប់ប្រញាល ទៅទិញសំបុត្រនឹងគេ ដោយភ្នែករំពៃមើលម្ដងៗទៅលើស្ត្រីចម្លែកៗពីរបីនាក់ តែកន្ទុយភ្នែកនាយកម្លោះសង្កត់ទៅលើមាណវីច្រើនជាងៗ យី! នារីនេះប្រកបដោយសោភណភាពឥតងាយរកមកផ្ទឹមបានទេ ហើយស្លៀកពាក់តែងខ្លួនក៏រមិលមើលមិនទាស់ភ្នែកសោះ! មើលចុះអាយុមិនលើសពី១៨ឆ្នាំទេ កក្រូផូរ សាច់ម៉ដ្ឋ រាងមូលទ្រវែងបន្តិចតែប្រកបដោយគំនូសយ៉ាងសុក្រិត សក់រលកអង្កាញ់ទូលាយ ហើយសិតរាបយ៉ាងឆើតឆ្មើមាត់តូច ដែលមានបបូរពណ៌ទទឹមសែតបណ្ដែតញញឹមបង្ហាញនូវធ្មេញសល្អិតស្មើគ្នាឥតខ្ចោះ អាវបើកកពណ៌ផ្កាឈូក ដែលមានកញ្ចុំបីដូចចង្កោមផ្កាមកជួយរំលេចលម្អ ហើយសាកឹត ស៊ុីនួនខ្ទីសំយុងពាក់កណ្ដាលស្មង បង្ហាញនូវកំភួនរៀវស្រសូលដែលមានភាគចុងបញ្ចប់បង្កប់ទៅក្នុងស្បែកជើងពណ៌ក្រមៅខាត់រលោងស្រិល។

ក្នុងសេចក្ដីឃោសប្ដិ ក្នុងការរើរាយទាំងភ្នែកស្រស់របស់ខ្លួន ទីឃាវុធតែងតែបែងចែកលម្អនារីជាបីប្រភេទទីទៃពីគ្នា។

ប្រភេទទីមួយ បានដល់ពួកយុវតីដែលប្រកបដោយសោភណ-ភាព ឃោរឃៅហៅបបួលឲ្យស្ទុះទៅចាប់ក្រញី ឬលេបដូចចំណី ព្រោះបរិបូណ៌ដោយសម្ផស្សដែលដេញ ដែលទាញសម្រើបយ៉ាងខ្លាំងៗ នារីប្រភេទនេះ តាមយោបល់ចៅមាណពយើង មិនសូវបេះតែងខ្លួនទេ ច្រើនស្លៀកពាក់ពណ៌ឆើតៗលេចធ្លោ ពាក់មាសពេជ្រស្អេកស្កះហើយមានកាយវិការឆ្ងាយពីសេចក្ដីស្រគត់ស្រគំទៀតផង។

បើលម្អឃោរឃៅជាបាតុកម្មខាងក្រៅ ឯលម្អទីពីរតែងមានគុណភាពកប់ជ្រៅនៅខាងក្នុងវិញ គឺលម្អចេញឲ្យឃើញ ឲ្យសរសើរឲ្យស្ងើចបន្តិចម្ដងៗ នូវទឹកដមចិន្ដាថ្វាហ្មត់ហ្មងទន់ត្រជាក់ សរុបសេចក្ដីទៅស្រ្ដីដែលប្រកបដោយសោភណភាពបែបនេះ ទំនៀមទម្លាប់យើងតែងតែហៅថាល្អគន់ តែទីឃាវុធដែលមាន គំនិតចាក់ស្រេះបន្ដិច តែងចាត់ថាជាលម្អដែលទាញនូវសមានចិត្តនិងសេចក្ដីគោរព ដូចមនោសញ្ចេតនាដែលអ្នកផងតែងមានចំពោះបងស្រីៗ

សោភណភាពទីបី របស់ទីឃាវុធ តែងប្រគល់ដល់នារីមានកិរិយាទន់ភ្លន់ មានគុណភាពស្រួយស្ដើង នាំឲ្យចិត្តបុរសចង់ជួយយកអាសារ ឬស្ទុះចេញការពារតទល់នឹងសត្រូវ ទោះបីសត្រូវនោះមានរូប ឬឥតរូបក៏ដោយៗ គឺលម្អនេះហើយ ដែលតែងតែអង្រួនបេះដូងកវីបញ្ចេញពាក្យកាព្យនៅគ្រប់ភាសា...ៗ

នាងចន្ទមណី នាំទីឃាវុធដើរតាមភ្លឺពីស្រែមួយទៅស្រែមួយទៀតក្រោមពន្លឺនៃព្រះអាទិត្យៗ ជួបនឹងពួកអ្នកច្រូត នាងតែងឈប់សួរពីដំណើរនៃការដែលកំពុងធ្វើៗ ឯទីឃាវុធ ក្មេងខ្លួនជាកូនឈ្នួយខេត្តក៏ហៅមាហៅមីងហើយសើចលេងនិងគេលាន់ៗ

-នុ៎ះ បងវត្តជ្រោយម្ទេសៗ

កូនឈ្នួយកម្លោះបែរមុខមើលនារីផ្ដើមជីវិត ដែលសេចក្ដីស្និទ្ធស្នាលបង្គាប់ឲ្យហៅថា "បងៗ" ឡើងវិញនោះ ទើបដាក់ភ្នែកដេញតាមនាងចង្អុរៗ

ដូចកោះមួយអណ្ដែតលើសាគរពណ៌មាសទុំ រុក្ខជាតិស្ញុំកបៃតងចាស់ប្រាកដរូបឡើង នៅចំចក្ខុវិញ្ញាណអ្នកដើរកាត់វាលស្រែៗ ដំបូលព្រះវិហារនិងជហ្វាពងស្មើតស្ទួយ បន្ទចខ្លួនឱនផុតចុងឈើ ផ្សាយសន្តិ

ភាព បរមសុខដល់ទីជិតខាង។ កណ្ដឹងសិរិទ្ធយោងរណើងរណ្ដងនៅដំបូលបូស្ដ សំឡេងព្រាបថ្ងូរ មាត់សិស្សមើលសាស្ត្រាស្ទឹករិតបានដឹកដួងចិត្ត ទៅកាន់សាកលមួយខុសពីទីជុំវិញ។

យុវជនទាំងពីរនាក់ ចូលក្នុងខឿនវត្ដហើយតម្រង់ទៅរកបូជនីយដ្ឋានដែលឈរជំស៊ីមស្ដៃជាច់ពីកុដនានា។ ដោយពេលឃើញទ្វារបង្អើបចោលឥតមានជនណានៅ អ្នកទាំងពីរក៏នាំគ្នាដោះស្បែកជើង ហើយថ្វាយបង្គំព្រះជីវ ដើម្បីធ្វើសក្ការៈបូជា។អនុស្សាវរីយ៍កាលខ្លួននាំគ្នាថ្វាយបង្គំព្រះអង្គចូលនិព្វាន នាក្នុំគួលេនក៏ប្រាកដរូបស្ដែងឡើងក្នុងសេចក្ដីនឹករឭកនៃយុវជន។ លុះសូត្រនមស្ការចប់កាលណា ទីឃាវុធលុតជង្គង់លើកដៃប្រណម្យម្ដងទៀត ហើយប្រកាសថា៖

-កាលពីមុនខ្ញុំព្រះករុណាបានតាំងសច្ចាប្រណិធានថា លុះត្រាតែទឹកដីខ្មែរ ដែលបាត់បង់ទាំងប៉ុន្មានក្នុងឱកាសសង្គ្រាមថៃឥណ្ឌូចិន បានត្រឡប់មករួមក្នុងមាតុភូមិវិញ ទើបខ្ញុំព្រះករុណាអាចចងមិត្តភាព ឬសម្ព័ន្ធភាពអ្វីៗជាមួយជនជាតិសៀមបាន។ ឥឡូវពាក្យសច្ចាទាំងប៉ុន្មានក៏បានសម្រេចទាំងអស់ហើយ។

រួចហើយទើបបែរមុខ មករកនាងដែលអង្គុយបត់ជើងក្រញឹមនៅជិត ម៉េចអូនពាក្យសន្យាជាន់ដើមផ្ទាល់ខ្លួនយើងទាំងពីរនៅមានជីវិតមែនឬទេ?

ពោះទ្រូងនាងញ័ររំចប្រប់ ដោយសេចក្ដីត្រេកអរទឹកភ្នែកនៃសុភមង្គលក៏ពោរហើយហូរដោរជន់ធ្លាក់មក។ កាលនោះ នាងពុំតបថាអ្វីទេ គ្រាន់តែលូកដៃស្ដាំទៅស្រវាចាប់ដៃស្ដាំមិត្តនាង រួចហើយនាំគ្នាក្រាបគោរព ហាក់ដូចសន្យាជាថ្មីទៀត ក្នុងជីវិតនេះលែងមានព្រាត់ប្រាស់គ្នាទៀតហើយ។

នៅខាងក្រៅ ត្រង់ដំបូលតូចមួយដែលមានដើមចារមួយកំពុងចោលម្ចប់យ៉ាងខាត់ខៃប ព្រោះថា រដូវពេយស្ទឹក ហើយបញ្ចេញផ្កាពណ៌រងើកភ្លើង កម្ពោះគង្វាលគោម្នាក់ពាយទំនុកក្ដែងៗតែឯការៗសំឡេងស្រួយប្រាវ ដែលភាពស្ងាត់ថ្វារបស់អាកាសជួយសម្អាតឲ្យកាន់តែរងំថែមទៀតបានពាយសេចក្ដីដូចតទៅ...។

## ៣ លោក ញ៉ុក ថែម

លោកញ៉ុក ថែម ប្រសូតនៅថ្ងៃសៅរ៍ ទី២២ ខែមិថុនា ឆ្នាំ ១៩០៣ ត្រូវនិងថ្ងៃទី១១រោច ខែជេស្ឋ ឆ្នាំថោះ ។ លោកមានស្រុកកំណើតនៅភូមិរតនៈ ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង។ ឪពុកលោកមានព្រះនាម ញ៉ុក ញ៉ូ និងម្ដាយនាមហៀក ដែលមានអាជីវកម្មជាជាងទង។ ក្រោយមក បិតាលោកក៏បានលះបង់អាជីពនេះចោល រួចក៏បានមករស់ស្នាក់អាស្រ័យនៅភូមិអូតាគី ឃុំជ្រៃស្រុក ខេត្តបាត់ដំបង។

លុះមានអាយុ១០ឆ្នាំ គឺប្រមាណជានៅឆ្នាំ១៩១៣ ឪពុកម្ដាយលោកក៏បាននាំលោក មកសំណាក់រៀនសូត្រជាមួយព្រះគ្រូអាចារ្យ**សន** គង់ក្នុងវត្តពោធិវាល ស្រុកសង្កែ ខេត្តបាត់ដំបង ដើម្បីបានក្រេបជញ្ជក់នូវវិជ្ជាអក្សរសាស្ត្រជាតិ ព្រមទាំងវិជ្ជាខាងព្រះពុទ្ធសាសនា។ ក្រោយមកគឺប្រមាណជាមួយឆ្នាំព្រះគ្រូអាចារ្យសនក៏ទទួលអនិច្ចកម្មទៅ ទើបឪពុកមារបស់លោកញ៉ុក ថែមបាននាំលោកឲ្យទៅសំណាក់រៀនជាមួយព្រះគ្រូ **អ៊ីវ ហួត** ។

នៅឆ្នាំ១៩១៨ គឺលោកមានអាយុ១៥ឆ្នាំ ព្រះគ្រូអ៊ីវ ហួត ក៏បានបំបួសលោកជាសាមណេរក្នុងសំណាក់លោកគ្រូចៅអធិការ**សំ** ដែលជាចៅអធិការគង់នៅវត្តពោធិវាលនោះ។ ចាប់តាំងពីពេលនោះមក សាម-

ណោរអង្គនេះ បានសង្វាតរៀនសូត្រភាសាបាលី និងធម្មវិន័យក្នុងសំណាក់ព្រះគ្រូអាចារ្យទាំងឡាយ ដោយសេចក្តីប្រតិបត្តិនិងការយកចិត្តទុកដាក់។

នៅឆ្នាំ១៩១៩ គឺជាវេលាដែលសង្គ្រាមលោកលើកទី១ត្រូវបានបញ្ចប់ សាមណេរញ៉ុក ថែមបានទៅបន្តវិជ្ជាខាងព្រះពុទ្ធសាសនា នៅទីក្រុងបាងកក ប្រទេសសៀមបន្ថែមទៀត។ ការធ្វើដំណើរនៅសម័យនោះ គឺលោកបានទៅជាមួយនឹងរទេះគោពួកឈ្មួញ។ ការធ្វើដំណើររយៈពេល១០ថ្ងៃ ទើបបានមកដល់**បាចិនបុរី**ទើបធ្វើដំណើរតាមផ្លូវទឹកបន្ថែមទៀត ចុងក្រោយបង្អស់ គឺលោកបានបន្តដំណើរតាមរទេះភ្លើងទៅទៀត វេលាព្រលប់ធំ ទើបបានមកដល់ទីក្រុងបាងកក។ ពួកឈ្មួញបាននាំសាមណេរញ៉ុក ថែមទៅសំណាក់រៀនសូត្រជាមួយព្រះគ្រូ**ព្រះមហាយ៉ៅវ៍** ដែលលោកក៏ព្រះសង្ឃខ្មែរដែលគង់នៅសៀមយូរឆ្នាំណាស់មកហើយ

ដោយសេចក្តីព្យាយាម សាមណេរញ៉ុក ថែមក៏បានប្រឡងជាប់សញ្ញាបត្រធម្មសិក្សាជាន់ត្រីនៅក្នុងឆ្នាំ១៩២១ បន្ទាប់មកទៀតនៅឆ្នាំ១៩២៣លោកក៏បានប្រឡងជាប់សញ្ញាបត្រ មធ្យមសិក្សាជាន់ទោ។ នៅអំឡុងឆ្នាំ១៩២៤ គឺលោកមានព្រះជន្មាយុ២១វស្សាក៏បានបំពេញឧបសម្បទ័ជាភិក្ខុ ហើយនៅក្នុងឆ្នាំនោះដដែលលោកក៏បានប្រឡងជាប់សញ្ញាបត្របរិយត្តិភាសាបាលីទីមហា៣ប្រយោគ លុះមកដល់ឆ្នាំ១៩២៦ក៏បានប្រឡងជាប់ទីមហា៤ប្រយោគទៀត ។ នៅក្នុងឆ្នាំ១៩២៨ លោកក៏បាន ប្រឡងជាប់សញ្ញាបត្របរិយត្តិភាសាបាលីទីមហា៥ប្រយោគ លុះដល់ឆ្នាំ១៩២៩ក៏បានប្រឡងជាប់ទីមហា៦ប្រយោគ។

ក្នុងបេសកកម្មសិក្សានៅប្រទេសសៀមព្រះភិក្ខុអង្គនេះ ក៏ធ្លាប់បានធ្វើជាសាស្ត្រាចារ្យបង្រៀនភាសាបាលីនៅវត្តព្រះកេតុ ។ លោកក៏ធ្លាប់ធ្វើជា

គណៈមេប្រយោគជាផ្លូវការ នឹងបានចូលរួមកែវិញ្ញាសាប្រឡងនៃសាម-ណេៈនិស្សិតផងដែរ។ ជាមួយគ្នានេះដែរលោកក៏បានសរសេរនឹងបោះពុម្ពផ្សាយជាភាសាសៀម-បាលីដូចជាសៀវភៅ **នមោជីកាកថា នានាជាដកវណ្ណន ធម្មបទនិទ្ទេស ទេវតាភាសិត** និង **ពុទ្ធភាសិត** ដែលកម្រងអត្ថបទទាំងនេះត្រូវបានបោះពុម្ពផ្សាយនៅលើសាស្ត្រស្លឹករឹត។

នៅឆ្នាំ១៩៣០ លោកក៏បានវិលត្រឡប់មកនៅស្រុកខ្មែរវិញ កាលណោះ រាជការបារាំងបានឲ្យលោកធ្វើជាសមាជិកក្នុងក្រុមជំនុំបកប្រែព្រះត្រៃបិតក។ នៅឆ្នាំ១៩៣៦ លោកក៏បានលាចាកសិក្ខាបទ មកជាគ្រហស្ថ។ នៅឆ្នាំ១៩៣៧ លោកក៏បានរៀបការជាមួយនាង **ឆ្នួន ណៃស៊ុម** នៅផ្សារឧត្តុង្គ សង្កាត់រាំងចាស់ ស្រុកឧដុង្គ ខេត្ត កំពង់ស្ពឺ ។ ជីវិតស្នេហាដ៏ផ្អែមល្ហែមរបស់លោក ក៏បានបង្កើតកូនប្រុស ស្រីចំនួន៧នាក់ ក្នុងនោះស្រីមានចំនួន២នាក់។

នៅឆ្នាំ១៩៣៨ លោកក៏បានធ្វើជានិពន្ធនាយកទស្សនាវដ្តី កម្ពុជសុរិយា ដែលចេញផ្សាយរហូតដល់ឆ្នាំ១៩៧៥ ហើយក៏បានធ្វើការនៅព្រះរាជបណ្ណាល័យកម្ពុជាផងដែរ។

នៅឆ្នាំ១៩៤២ ដល់ឆ្នាំ១៩៤៦ លោកក៏បានធ្វើជាអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ។ ក្នុងកាលនោះ អ្នកស្រីកាបីឡែស និងក្រោយមកលោកប៉ៀរឌុយម៉ុងជាអ្នកគ្រប់គ្រង បានយល់ឃើញថាលោកគឺជាអ្នកប្រាជ្ញអក្សរសាស្ត្រមួយរូបដ៏ល្អកម្ររក ទើបស្ថាប័ននេះបានតែតាំងលោកជាតំណាង ដើម្បីធ្វើកម្មវិធីសិក្សាពុទ្ធសាសនា និងសម្ពោធអគារពុទ្ធសាសនាផ្សេងៗទាំងនៅស្រុកលាវ និងស្រុកយៀកណាមខាងត្បូង។

ឆ្នាំ១៩៤៥ លោក**អឡេចសង្វ្រៃយ**ជាឧត្តមស្នងការបារាំង ក៏បាន

តម្រូវឲ្យលោក ធ្វើជាក្រុមការទូតនៃសហរដ្ឋឥណ្ឌូចិនបារាំងសែសប្រចាំនៅព្រៃនគរ។ កាលនោះ លោកក៏បានធ្វើជាអ្នកបកប្រែភាសាបារាំង ខ្មែរ សៀម នៅក្នុងកម្មវិធីវិទ្យុនៅទីនោះដើម្បីទាមទារដែនដីបាត់ដំបង និង ខេត្តសៀមរាបពីសៀមវិញ បន្ទាប់ពីសៀមយកកាលពីសង្គ្រាមលោកលើកទី២គ្រាដែលជប៉ុនបានប្រគល់ទៅឲ្យនោះ។

នៅឆ្នាំ១៩២៩ លោកក៏បានវិលត្រឡប់មកភ្នំពេញវិញ ហើយក៏បានធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងធ្វើជាគ្រូបង្រៀននៅវិទ្យាល័យស៊ីសុវត្ថិ។ នៅឆ្នាំ១៩៥០ ក្រសួងអប់រំជាតិ បានតែងតាំងលោក ជា សាស្ត្រាចារ្យ រហូតដល់ឆ្នាំ១៩៥៧លោកក៏បានចូលនិវត្តន៍។ ដោយគុណបំណាច់ដ៏ធំធេង ដែលលោកបានបន្សល់គ្រាកន្ទងមក ក្រសួងអប់រំ ក៏បានតែងតាំងលោកជា សាស្ត្រាចារ្យឧត្តមសិក្សាកិត្តិយសនៃវិទ្យាស្ថានគរុកោសល្យ មហាវិទ្យាល័យអក្សរសាស្ត្រព្រមទាំងពុទ្ធិកមហាវិទ្យាល័យ។ នៅក្នុងឆ្នាំ១៩៥៦ លោកក៏បានបង្កើតសមាគមអ្នកនិពន្ធខ្មែរឡើងក្នុងគោលបំណងលើកកម្ពស់វិស័យតែងនិពន្ធផង និងការប្រមូលអ្នកនិពន្ធមកជុំគ្នាផង។

លោកប្រហែលជាទទួលមរណភាពនៅអំឡុងឆ្នាំ១៩៧២ ដែលក្នុងការបូជារបស់លោកដើម្បីជាតិ ទឹកដី លោកក៏បានទទួលគ្រឿងឥស្សរិយយសជាគុណបំណាច់ផ្សេងៗ ទាំងពីបរទេស ក៏ដូចជាពីមាតុ-ភូមិខ្លួនដែរ ដូចជា ឥស្សរិយយសប្រទេសកម្ពុជាឈ្មោះ**មុនីសារាភរណ៍** នៅក្នុងឆ្នាំ១៩៤០ មេដាយអនុស្សរា ប្រទេសកម្ពុជា នៅឆ្នាំ១៩៦០ មេដាយអស្សរិទ្ធិ នៃព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ១៩៦២ជាដើម។

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ លោកញ៉ុក ថែម បានបន្សល់ស្នាដៃជាច្រើនដូចជា៖

-ពុទ្ធប្បវត្តិសង្ខេប

-អនុពុទ្ធប្បវត្ត ភាគ១-២

-ប្រជុំភាសិត ភាគ១-២

-ជាតិ សាសនា ព្រះមហាក្សត្រ

-ឯកសហាពត្រី "ភាគខ្លះប្រែ"

-ចូឡវេទល្លសូត្រ "ប្រែ"

-វិធីប្រតិបត្តិធម៌

- រឿងបិសាចស្នេហា បោះពុម្ពឆ្នាំ១៩៤២

- រឿងកុលាបប៉ៃលិន បោះពុម្ពឆ្នាំ១៩៤៦

- រឿងមហាវេស្សន្តជាតក

- ប្រជុំពុទ្ធភាសិត

- ពន្លឺអាស៊ីទ្វីប (អត្ថបទបកប្រែ)

- រឿងបញ្ញាសជាតកសង្ខេប ភាគ១-ភាគ២

ខាងក្រោមនេះ ខ្ញុំនឹងដកស្រង់អត្ថបទរឿងកុលាបប៉ៃលិនដែលជាស្នាដៃដ៏ល្បីរបស់លោកមកបង្ហាញជូនមិត្តអ្នកអាន។ ហើយស្នាដៃមួយនេះ ក៏ត្រូវបានក្រសួងអប់រំជាតិ បានដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សាផងដែរ។

គ្រានោះ ព្រះសុរិយទេវបុត្រ ទ្រង់គង់លើវិមានកែវផលិក (ផ្លេក) ដែលជារថព្រះទីនាំង ទឹមដោយសេះអាជានេយ្យមួយពាន់ ទ្រង់បរប្រទស្សិណក្នុំព្រះសិនេរុរាជតាំងអំពីទិសបូព៌ា យាត្រាសម្ដៅទៅទិសបស្ចិមតាមចក្រភាសីនៃសុរិយចក្រវាឡ លុះដល់កំណាត់បត់ព្រះរាជរថ ចូលបាំងជ្រុងមហាបព្វតា រស្មីព្រះសុរិយា ក៏ជ្រៀងជ្រេចូលកាន់សន្ធ្យាពត្រី

នាវេលានោះ ជាខាងខ្នើត ១៥កើត ខែកក្តិក ឆ្នាំច ចត្វាស័ក ព ស ២៤៧០ ព្រះចន្ទទេវបុត្រ យាងឡើងគង់លើវិមានប្រាក់ ជាពជរថព្រះទីនាំង បរចេញមកពីទិសបូព៌ាធ្ទុះពន្លឺពណ៌ប្រាក់ ទៅសព្វផែនពសុធា ព្រះចន្ទ្រាហាក់ដូចជាមៀងមើលមកយ៉ាងស្រស់ញញឹម ផ្តោះចំទៅលើដំបូលគេហស្ថានមួយ នៅខាងលិចផ្សារស្វាយប៉ោ ដែលជាផ្សារវិល ក្នុងទីរួមខេត្តបាត់ដំបង។

ឯគេហស្ថាននោះ ជាផ្ទះចាស់ ប្រក់ក្បឿង ដំបូលពីរជាន់ ជញ្ជាំងក្តារ ក្រាលក្តារ សសរមូល នៅហោជាងមានរូបចម្លាក់ឈើធ្វើជារូបពហ្វូលេបខៃ នៅខាងក្រោមរូបនេះ គេឆ្លាក់អក្សរមូលធំៗថា"**សិរីពង្ស**" ជាផ្ទះខ្មែរបែបបុរាណដែលនៅសេសសល់មកសម័យឥឡូវនេះ។...

ចៅចិត្រងើងងោងទៅមួយស្របក់ ស្ទើរតែមិនជឿត្រចៀកខ្លួនថា ខ្លួនបានឮអ្វីអម្បាញ់មិញនេះ កាលបានស្មារតីក៏ឱនក្រាបនៅចំពោះមុខលោកហ្លួង ថ្លែងពាក្យអរគុណច្រើនជាអនេកដោយបីតិត្រេកអរដ៏លើសលប់ តែគេមិនអាចឮពាក្យពេចន៍ដែលចៅចិត្រនិយាយថាដូចម្តេចឡើយក្នុងខណៈនោះ។

លុះបានឫកវេលាល្អ តាមឫក្សហោរាសាស្ត្រទើបហ្លួងរតនសម្បត្តិចាត់ចែងរៀបមង្គលការ អាពាហ៍ពិពាហ៍រវាងនាងក្រមុំនារីបុត្រីលោកជាគូនឹងចៅចិត្រ។ នៅក្នុងឱកាសនោះលោកបានអញ្ជើញអ្នកមុខអ្នកការ ទាំងអ្នកពជការ អ្នកជំនួញទាំងជាតិខ្មែរ ជាតិភូមា ចិន យួន និងបារាំង សឹងមានចំនួនណែនណាន់តាន់តាប់ ហើយលោកបានចែកមត៌កឲ្យគូស្វាមីភរិយាថ្មី ជាងពាក់កណ្តាលទ្រព្យសម្បត្តិទាំងអស់របស់លោក ព្រោះលោកមានបុត្រីតែមួយជា បណ្តូលចិត្តរបស់លោក ក្រៅពីនេះលោកនៅមានក្មួយតូចៗពីរបីនាក់ទៀត សុទ្ធតែកំព្រាឪពុកម្តាយទាំង

អស់ ដែលលោកត្រូវថែរក្សាទំនុកបំរុងតទៅទៀត ហើយលោកត្រូវចែកមត៌កឲ្យកូនកំព្រាទាំងនេះតាមសមគួរផង។

លុះអំណើសកាលតមក គូស្វាមីភរិយាទាំងពីរនាក់ ក៏បានទៅរួបរួមជាមួយគ្នាជាសុខក្សេមក្សាន្ត ត្រាតែកើតកូន ពូនជាចៅតវង្សត្រកូលរៀងទៅហោង។

## ៤ លោកអៀង សាយ

លោអៀង សាយប្រសូតនៅថ្ងៃព្រហស្បតិ៍ ខែផល្គុន ឆ្នាំឆ្លូវ ក្នុងគ្រិស្តសករាជ១៩០០ នៅភូមិព្រៃជ ឃុំស្វាយពរ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ បិតារបស់លោកមាននាម **តាម អៀង** មានមុខ របរជាជាងគំនូរ ចំណែកមាតាលោកមាននាម**លឿង** មានមុខរបរជាមេផ្ទះ។ បិតារបស់លោក ក្រៅពីមានមុខរបរជាជាងគំនូរ គាត់ក៏ជា លេខាធិការរបស់លោកឧកញ៉ា **ទេព និម្មិត** ចាងហ្វាងម៉ក់ នៅបរមរាជវាំង ដែលបានស្ថាបនាគំនូររឿងរាមកេរ្តិ៍នៅលើជញ្ជាំងវត្តព្រះកែវមរកត។

ក្រុមគ្រួសារលោក បានមករស់នៅទីក្រុងភ្នំពេញ តាំងពីលោកមានអាយុ៧ឆ្នាំមកម្ល៉េះ គឺអំឡុងឆ្នាំ១៩០៧ ដែលកាលបានមករស់នៅ ទីក្រុងភ្នំពេញ លោកក៏ធ្លាប់បានទទួលការអប់រំខ្លះៗ។នៅអាយុ១១ឆ្នាំ ម្តាយរបស់លោកបាននាំលោកឲ្យទៅរៀនសូត្រនៅវត្តបុទុមវតី ក្នុងសំណាក់លោកគ្រូបាឡាត់ថាប់។ ក្រោយមកដល់លោកអាយុបាន១៣ឆ្នាំ គឺនៅឆ្នាំ១៩១៣ ទើបលោកចាងហ្វាងម៉ក់បានជួយទិញគ្រឿងស្បង់ជីពរ និងគ្រឿងបរិក្ខាផ្សេងៗ សម្រាប់ការសាងផ្នួសមកបំបួសលោកជាសាមណេរ ដែលកាលនោះមានសម្តេចព្រះមង្គលទេព្វាចារ្យធ្វើជាព្រះគ្រូឧបជ្ឈាយ៍ ដែលមានព្រះនាមថា **បញ្ញាអត្ត** ។

លោករក្សាភេទជាសង្ឃបានតែបីវស្សា លោកក៏បានលាចាកសិក្ខាបទមកជាគ្រហស្ថវិញ។ គួរឲ្យអនិច្ចា បន្ទាប់ពីសឹកមកនៅក្នុងអាយុ ១៦ឆ្នាំនោះមក លោកអៀង សាយ ពុំមានចំណេះអ្វីដែលជាកេរពីសង្ឃល្មមអាចចិញ្ចឹមជីវិតបានឡើយ។ គ្រានោះ រាជការបានបង្កើតសាលារចនាឡើងជាប់នៅកំពែងវាំង ដែលបានបើកឱកាសសម្រាប់កូនខ្មែរប្រុសស្រីបានចូលរៀននូវមុខជំនាញដូចជា រៀនត្បាញសំពត់ រៀនគូររូបជាដើម ដែលការសិក្សានេះ គេក៏ឲ្យប្រាក់ខែផងដែរ។ ការគ្រប់គ្រងសាលា គឺមានលោក**គ្រោសលីយេរ** ជាចាងហ្វាង ចំណែកលោក**ទេពនិម្មិតម៉ក់** ជាចាងហ្វាងរង។

លោកអៀង សាយក៏បានទៅចូលសិក្សានៅសាលារចនានេះដែរ ដោយលោកបានឆ្លៀតរៀនអក្សរ និងរៀនភាសាបារាំងបន្ថែមទៀត។

ឆ្នាំ១៩១៩ លោកក៏បានបញ្ចប់ការសិក្សានៅសាលារចនាហើយក៏បាន ចេញទៅបម្រើការងារជាគ្រូបង្រៀនគំនូរនៅខេត្តកំពង់ឆ្នាំង។ ដោយប្រាក់ខែគ្រូតិចពេក បម្រើការងារបានតែមួយឆ្នាំ ក៏បានសុំឈប់សម្រាក។បន្ទាប់មក ក៏បានទៅបម្រើការងារនៅឯខេត្តក្រចេះទៀត។ ដោយសារតែបញ្ហាប្រាក់ខែចាយមិនគ្រប់គ្រាន់ លោកក៏បានវិលត្រលប់មកភ្នំពេញវិញ។ ពេលបានមករស់នៅភ្នំពេញ លោកក៏បានរកស៊ីធ្វើជាងគំនូរ ដែលមុខរបរនេះ អាចឲ្យលោកបានប្រាក់កាក់ចាយវាយធូរជាងមុន។

លោកបានរៀបការជាលើកតំបូង ខ្ញុំមិនបានស្រាវជ្រាវដឹងទេ តែគ្រាន់តែដឹងថា លោកបានលះលែងគ្នាជាមួយប្រពន្ធទី១បន្ទាប់ពីនាងនេះមិន ចេះទុកដាក់ទ្រព្យសម្បត្តិដែលលោកបានរកមកដោយលំបាក។ គ្រានោះ លោកទើបតែបានកូនមួយប៉ុណ្ណោះ តែកូននោះទៀតសោតក៏

បានស្លាប់ទៅ។ លោកបានចែកផ្លូវជាមួយប្រពន្ធទី១នៅអាយុ ២២ឆ្នាំ។ បន្ទាប់ពីនោះមក លោកបានរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធទី២ទៀត ឈ្មោះនាង**សា គុន** ដែលមានមុខរបរជាមេផ្ទះ។ ប្រពន្ធនេះ មានទីលំនៅនៅភូមិកំពង់ចម្លងឃុំកោះនរា ស្រុកកៀនស្វាយ ខេត្តកណ្ដាល។ បន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍រួច លោកក៏បានមករស់នៅជាមួយឪពុកម្ដាយក្មេកហើយក៏បានបន្តមុខរបរជាជាងគំនូរ ដោយបានយកគំនូរដែលបានគូររួចទៅលក់នៅផ្សារស៊ីញែក ក្រុងភ្នំពេញ។

ជីវិតអាពាហ៍ពិពាហ៍ របស់លោកបានបន្សល់ទុកបុត្តធីតាចំនួន ៤នាក់ដូចមានរាយនាមខាងក្រោម៖

- លោកអៀង សាកសុន ធ្វើជាវេជ្ជបណ្ឌិត
- លោកអៀង គុនសាគី ធ្វើជាសាស្ត្រាចារ្យ
- លោកអៀង ស៊ីសាគីម ធ្វើជាគ្រូបង្រៀន
- លោកអៀង ស៊ីមសាគូ ធ្វើអភិបាលការពារជំងឺ និងចិញ្ចឹមសត្វ

នៅឆ្នាំ១៩២២ លោកក៏បានចូលបម្រើការងារនៅសាលាដោយធ្វើជាជាងលាបពណ៌ ដែលទទួលបានប្រាក់ខែ៣០រៀល។ ដោយសេចក្ដីឧស្សាហ៍ រៀនសូត្រខ្លួនឯងតាមរយៈសៀវភៅដែលបានផ្ញើទិញពីប្រទេសបារាំង ជាបន្តបន្ទាប់ពីគំនូរនានាមានដូចជាគំនូរម៉ាស៊ីនជាដើម ទើបឆ្នាំ១៩២៤ លោកក៏ត្រូវបានប្រកាសជាគ្រូបង្រៀនម៉ាស៊ីននៅសាលាឧស្សាហកម្ម។

ក្រៅពីស្នាដៃគូរគំនូរ លោកអៀង សាយក៏ចេះតែងរឿងផងដែរ ដូចជាគាត់បានសរសេររឿងផ្កាវីក ផ្កាពេយដែលជារឿងជាប់ជ័យលាភីហើយក៏ត្រូវបាន យកទៅចុះផ្សាយនៅលើទំព័រកាសែតកម្ពុជារហូតដល់

ចប់។ បន្ទាប់មកទៀត រឿងនេះក៏ត្រូវបានបណ្ណាគារ គីម-សេងទិញយកទៅបោះពុម្ពធ្វើជាសៀវភៅលក់។ ក្រៅពីនេះ លោកក៏បានថតខ្សែភាពយន្តវែងមួយខ្សែ និងខ្លីមួយខ្សែដែលរឿងនេះ ត្រូវបានដាក់បញ្ចាំងនៅរោងកុនជិតវាលមេរុ។ អ្វីដែលនឹកស្មានមិនដល់ គឺរយៈពេលតែមួយសប្តាហ៍ លោកក៏អាចរកប្រាក់ចំណូលបាន៩០.០០០រៀលឯណោះ។ លោកក៏ជាសមាជិកសមាគមអ្នកនិពន្ធខ្មែរដែរ ដែលលោកក៏បានបង្រៀនវិជ្ជាតែងកាព្យផងដែរ។ ក្រៅពីសមត្ថភាពខាងការគូរគំនូរខាងតែងអក្សរសិល្ប៍ លោកក៏មានវិជ្ជាខាងថ្លឹនក្អែកដែរ ដែលវិជ្ជានេះ លោកបានចេះចាំយ៉ាងស្ទាត់ជំនាញ តាំងពីលោកបានអាយុ១២ឆ្នាំមកម្ល៉េះ។ រហូតមកដល់ឆ្នាំ១៩៣២លោក ក៏បានបង្កើតក្រុមសៀកមួយឈ្មោះថា **ក្រុមខេមរវិជ្ជា** ។ លោកទទួលមរណភាពនៅក្នុងជន្មាយុ៧៥ឆ្នាំ។

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ដែលបានបន្សល់សម្រាប់ការសិក្សាស្រាវជ្រាវ លោកបានបន្សល់ស្នាដៃជាច្រើនទាំងប្រលោមលោក ក៏ដូចជាប្រភេទល្ខោនដែរ។ ស្នាដៃទាំងនោះមានដូចជា៖

- រឿងសេនាក្លាហាន ជាប្រភេទល្ខោនខ្នាតវែង
- រឿងសុបិន្តនិមិត្ត ជាប្រភេទល្ខោនខ្នាតវែង
- រឿងស្រីសុភាព ជាប្រភេទល្ខោនខ្នាតវែង
- រឿងរត់ទ័ព ជាប្រភេទល្ខោនខ្នាតវែង
- រឿងព្រះរាជសម្ភារ ជាប្រភេទល្ខោនខ្នាតវែង
- រឿងជាងឈើប្រាជ្ញព្រោក ជាប្រភេទល្ខោនខ្នាតវែង
- រឿងកេរមត៌ក ជាប្រភេទល្ខោនខ្នាតវែង
- រឿងរើសរកប្តី ជាប្រភេទល្ខោនខ្នាតវែង

រឿងសាវ៉ាកាន ជាប្រភេទប្រលោមលោក

-រឿងគូព្រេងគូកម្ម ជាប្រភេទប្រលោមលោក
-រឿងស្រីប្ដីដោះ ជាប្រភេទប្រលោមលោក
-រឿងអ្នកជាប់ទោស ជាប្រភេទប្រលោម
-រឿងផិតក្បត់ ជាប្រភេទប្រលោមលោក
-រឿងផ្ការីកផ្ការោយ ជាប្រភេទប្រលោមលោក

## ៤ លោកគឹម ហាក់

លោកគឹម ហាក់ មានឈ្មោះមួយទៀតថា ឆេង ហាក់ប្រសូតនៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩០៥នៅរាជធានីភ្នំពេញ។ បិតាលោកមាននាមអ៊ុក ឆេង និងមាតានាមកែវ ប៊ុន ។ កាលនៅវ័យកុមារលោកបានទទួលការសិក្សានៅសាលាបឋមសិក្សាឱ្យជាជីឡាគ្រេ និងបន្តការសិក្សានៅសាលាបឋមសិក្សាជាន់ខ្ពស់នៅសាលាអនុវិទ្យាល័យស៊ីសុវត្ថិ។ មកដល់ឆ្នាំ១៩២៤ លោកបានធ្វើការនៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឋានៈជាអភិបាល។ ក្រោយមកនៅឆ្នាំ១៩២៩លោកក៏បានរៀបការជាមួយនាងស៊ិន ចឹកនិងបានរួមរស់ជាមួយគ្នាបានបុត្រទាំងអស់ប្រាំមួយនាក់។ មកដល់ឆ្នាំ១៩៤៣ លោកក៏បានផ្លាស់ទៅបម្រើការនៅក្រសួងអប់រំជាតិ ដើម្បីកាន់ការជានាយកការិយាល័យឃោសនាការ និងវិចិត្រសិល្បៈ ហើយពេលនោះ លោកមានមុខងារជាចាងហ្វាងសារព័ត៌មាន "កម្ពុជា" ផងដែរ។

នៅឆ្នាំ១៩៤៤-១៩៤៥ លោកក៏បានកាន់ការជាអគ្គលេខាធិការនៃគណៈកម្មការវប្បធម៌ និងសមាគមអាយម៉ូនីញេ។

ឆ្នាំ១៩៤៦-៤៧ លោកក៏មកកាន់ការជានាយកការិយាល័យទី១ និងជានាយកការិយាល័យ កិច្ចការនយោបាយនៅក្រសួងមហាផ្ទៃ។

ហើយនៅឆ្នាំ១៩៤៧-៤៨ លោកក៏បានមកធ្វើជានាយកការិយាល័យក្រសួងធម្មការនិងជានាយការិយាល័យ កិច្ចការនយោបាយនៅក្រសួងមហាផ្ទៃនៅភ្នំពេញវិញ។

ឆ្នាំ១៩៥០-៥២ជានាយខុទ្ទកាល័យ ហើយបន្ទាប់មកជាភូ ឈួយក្រុងភ្នំពេញ។ ឆ្នាំ១៩៥២-៥៦ជាចាងហ្វាងនៃការផ្សាយ និងជាប្រធានសមាគមសុជារស។ ឆ្នាំ១៩៥៥-៥៩ជាភូឈួយអគ្គលេខាធិការ ហើយនៅក្រោយមកធ្វើជាអគ្គលេខាធិការ នៃឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ ដោយមានឋានៈនិង បុព្វសិទ្ធិស្មើនិងរដ្ឋលេខា ធិការនៃរាជរដ្ឋាភិបាល។ ទើបមកដល់ឆ្នាំ១៩៥៩-៦០លោកក៏បានធ្វើជាអភិបាលខេត្ត ហើយត្រូវតែងតាំងជានាយកពិធីការក្នុងបរមរាជវាំង។ នៅឆ្នាំ១៩៦១-៦២លោកក្លាយជានាយកក្រុមរដ្ឋបាល នៃព្រះបរមរាជវាំងមានឋានៈស្មើនិងរដ្ឋលេខាធិការនៃរាជរដ្ឋាភិបាលដែរ។

ក្រៅពីការបំពេញ ភារកិច្ចយ៉ាងច្រើនសន្ធឹកសន្ធាប់យ៉ាងនេះជូនជាតិ លោកគីម ហាក់ក៏នៅតែផ្ញើតបន្សល់ស្នាដៃរបស់លោកមួយចំនួនដល់បណ្តាមិត្តអ្នកអាន និងអ្នកសិក្សាជំនាន់ក្រោយដែរ។ ស្នាដៃដ៏ពិសិដ្ឋក្នុងន័យលើកកម្ពស់វិស័យអក្សរសាស្ត្រជាតិនោះមានដូចជា៖

-រឿងទឹកទន្លេសាប បោះពុម្ពឆ្នាំ១៩៤១

-រឿងកោសផ្ទះ ឬសេចក្ដីខ្ជិល ចុះផ្សាយក្នុងកម្ពុជសុរិយា

-មួយរយសាមសិបមួយថ្ងៃ ចុះផ្សាយក្នុងកម្ពុជសុរិយា

-សេកសោមបណ្ឌិត សរសេរឆ្នាំ១៩៣២ បោះពុម្ពឆ្នាំ ១៩៣៣ ដោយពុទ្ធសាសនបណ្ឌិត្យ

-យុវសីមា សរសេរឆ្នាំ១៩៣៩ (មិនទាន់បោះពុម្ព)

ជាបន្តទៅទៀត ខ្ញុំដកស្រង់រឿង**ទឹកទន្លេសាប** ដែលជាស្នាដៃ

និពន្ធរបស់លោកមកធ្វើការបង្ហាញជូនមិត្តអ្នកអានឲ្យបានជ្រាបដូចត ទៅ៖

... នាងម៉ាល៉ាបានស្តាប់ពាក្យប្តីលួលោមឲ្យដេកដូច្នេះហើយ ក៏មានចិត្តរីករាយ ខំធ្មេចនេត្រាទាំងសងខាងដេកលង់លក់ទៅដល់ជិតភ្លឺ នាងយល់និម្មិតមួយចម្លែកអស្ចារ្យណាស់ យល់ហាក់ដូចជាតាចាស់ម្នាក់កាន់កាំបិតយ៉ាងមុត ស្ទាចមកវះយកថ្លើមរូចហើយដើរទៅខាងទិសទិសនិរតីបាត់ទៅ ដល់យូរបន្តិចតាចាស់ដដែលនេះកាន់យកនូវថ្លើមមកដាក់ឲ្យដូចដើមវិញ មានចិត្តភិតភ័យពេកណាស់ ភ្ញាក់ឡើងដាស់ស្វាមីនិយាយសព្វគ្រប់ប្រការ ចៅហោមស័យក្រោកអង្គុយសញ្ជឹងសញ្ជប់ពិចារណានូវសុបិន្តនិមិត្តឃើញថា នេះប្រាកដជា មានសេចក្តីព្រាត់ប្រាស់ដល់អញ និងប្រពន្ធមិនខានឡើយ ប៉ុន្តែយូរទៅនឹងបានជួបគ្នាវិញ បើអញនិយាយប្រាប់នាងនេះ ដោយត្រង់ សមជាវានឹងសោកសៅកើតទុក្ខមិនខាន បើដូច្នេះអញរកឧបាយកលនិយាយបង្វែងទៅវិញ ទើបបែរទៅកៀកកប្រពន្ធបីថ្នមដាក់លើភ្លៅ ហើយនិយាយថា កែវអើយនិមិត្រ[១] នេះជាប្រផ្នូលល្អណាស់ ដែលឃើញថាតាចាស់មកកាត់យកថ្លើមនោះ គឺជាបញ្ហាឲ្យនាងដឹងថា កាលអូនឯងនៅក្រមុំនៅឡើយ រូបរាងលោម

(១) សរសេរតាមច្បាប់ដើម

ពណ៌សីងតែល្អស្អាត ចិត្តក៏គ្មានរវើរវាយទៅណាទៀត ឥឡូវនាងមានប្តីហើយ កែវអើយរូបរាងនាងក៏កាន់តែអន់ថយទៅដោយនូវការផ្សេងៗ ត្រង់ថា ឃើញតាចាស់នោះយកថ្លើមមកដាក់ឲ្យនាងវិញនោះ គឺថាដល់យូរបន្តិចទៅប្អូននឹងមានរូបរាងល្អដូចពីដើមវិញ បុរសណាបានឃើញហើយច្បាស់ជា...។

ប្រឡែងលេងបានយូរបន្តិចទៅ កម្មអាក្រក់តាមមកទាន់អ្នកទាំង

ពីនោក់នេះ ចៅហោមស័យនិយាយប្រាប់ប្រពន្ធថា ម្នាលប្អូនចាំបងហែលឲ្យប្អូនមើល បងហែលបានឆ្ងាយណាស់ ថាហើយគេក៏លោតហែលស្កុង បណ្ដោយតាមទឹកហូរយ៉ាងខ្លាំង រួចត្រឡប់មកវិញហែលឡើងពុំរួចអស់កម្លាំង ខ្សែទឹកក៏ក្ដួចចៅហោមស័យទៅឆ្ងាយបាត់ទៅ។

ចៅហោមស័យ ដោយអំណាចខ្វាចលិចលង់ទៅក្នុងទឹក ហើយទឹកក្អកដល់ប្រពន្ធ ប្រឹងហែលបណ្ដែតខ្លួនតាំងពីក្បាលព្រលប់ រហូតដល់ស្វាងច្បាស់ អណ្ដែតទៅប៉ះជាប់ច្រាំងខាងចុងទន្លេសាបដល់ទីនោះចៅហោមស័យសន្លប់បាត់ស្មារតីដោយសារហត់នឿយហួសកម្លាំង។

មេឃងងឹតសូន្យឈឹង ពពកពាសពេញលុបបាត់អស់ពន្លឺព្រះតារាទាំងឡាយ សត្វរៃយំរ៉ៃៗនៅក្នុងគុម្ពស្មៅ ស្លឹកឈើដែលស្រពោនស្រពន់ក្នុងវេលាថ្ងៃ រើបរីករីងឡើងដោយអំណាចយប់ត្រជាក់ នាងម៉ាលាប្រឹងដើរយ៉ាងលឿនកុំឲ្យអ្នកផងទាំងពួងឃើញ ដល់កន្លែងប្ដីនាំនាងទៅងូតទឹក នាងគក់ទ្រូងស្រែកយំថា ...

ក្រៅពីអ្នកនិពន្ធ យ៉ាងល្អឆើតទាំងនេះ នៅសម័យអាណានិគមនិយមបារាំងក៏នៅមានអ្នកនិពន្ធជាច្រើនទៀត គ្រាន់តែខ្ញុំមិនបានស្រង់អស់មកបង្ហាញជូនមិត្តអ្នកអានបានជ្រាបតែប៉ុណ្ណោះ។ ជាបន្តទៅទៀតខ្ញុំនឹងស្រង់យកអ្នកនិពន្ធមួយចំនួនទៀត គ្រាន់តែបង្ហាញនាម និងស្នាដៃរបស់លោកតែប៉ុណ្ណោះដើម្បី ទុកជាស្ពានមួយក្នុងការសិក្សាពីចរន្តអក្សរសិល្ប៍យើង។ អ្នកនិពន្ធទាំងនោះមានដូចជា៖

១ **លោកហេង យ៉ាន់:** លោកកើតនៅថ្ងៃទី២៦ ខែមករា ឆ្នាំ ១៩២១នៅសង្កាត់លេខ៣ រាជធានីភ្នំពេញ។ លោកទទួលមរណភាព

នៅក្នុងឆ្នាំ១៩៦៧ក្នុងជន្មាយុ៦៦ឆ្នាំ។ ស្នាដៃរបស់លោករួមមានដូចជា៖

-រឿងកំពូលកម្សត់ ជាអត្ថបទប្រលោមលោក បោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដីកម្ពុជសុរិយា លេខ១-១២ឆ្នាំ១៩៦៦ដែលកាលនោះលោកបានដាក់ឈ្មោះថា **ហាន់ យេង**។

-រឿងកំពូលស្នេហា ប្រលោមលោក បោះពុម្ពផ្សាយនៅទស្សនាវដ្ដីកម្ពុជាសុរិយា លេខ១-១២ឆ្នាំ១៩៦៦

-ប្រជុំរឿងល្បើក ពាក្យកាព្យ សរសេរនៅភ្នំពេញ នឹងត្រូវបានបោះពុម្ពនៅពេជពុម្ពខ្មែរឆ្នាំ១៩៥១

-គោលប្រវត្តិសាស្ត្រនៃអក្សរសាស្ត្រខ្មែរ សរសេរនៅភ្នំពេញ

-រឿងល្បើកស្រីហិតោបទេស

-អំពីការថ្វៃងនៃវដ្ដសង្សារ បោះពុម្ពឆ្នាំ១៩៥៨

-អត្ថបទខ្វីជាច្រើនទៀត ដែលត្រូវបានចុះផ្សាយក្នុងទស្សនាវដ្ដីមិត្តសាលាបាលី

ក្រៅពីនេះ លោកក៏បានបន្សល់ទុកស្នាដៃមួយចំនួនទៀត ខ្វះក៏បានលាយឡំជាមួយស្នាដៃលោក ឃួន សុខម្ហដែរ។

## ២ លោកជៀ ជុំម

លោកកើតនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩២១ នៅអង្គាញ់ ខេត្តតាកែវ។ បិតានាមជៀ អ៊ឹម មុខរបរជាអាចារ្យវត្ត។ ខ្ញុំមិនបានដឹងនាមម្ដាយរបស់លោកទេ។ លោកក៏ជាអ្នកនិពន្ធយ៉ាងឯកមួយរូបដែរដែលបានបន្សល់ស្នាដៃមួយចំនួនដូចជា៖

-រឿងវណ្ណៈ ប្រលោមលោកពាក្យរាយ សរសេរឆ្នាំ១៩៥១

-រឿងបកប្រែពីបារាំង៖

- រឿងហិបហោះ ១៩៥២

-រឿងហ៊ឺឡា ១៩៥២

-រឿងកាឡាបូ និងទូរ៉ាម ១៩៥២

៣ **ធម្មបញ្ញាអ៊ិក** សរសេររឿងមរណមាតា ឆ្នាំ១៨៧៧

៤ **ព្រហ្មបរកក្តី** សរសេររឿងពោធិវង្ស ឆ្នាំ១៨៨១

៥ **ឃុនសន្ធាពិនិត្យ** សរសេររឿងចៅមាស ឆ្នាំ១៨៨៧

៦ **ចៅអធិការវត្តព្រៃកប្រណាក** សរសេររឿងព្រះលក្ខិណវង្ស ឆ្នាំ១៨៩០

៧ **នូច សឹមហាន** សរសេររឿងកែបមាត់សមុទ្រឆ្នាំ១៩២២

៨ **អ៊ុម ហ៊ឺ** សរសេររឿងមហាអភ័ព្វ ឆ្នាំ១៩២៥

៩ **នង ឈុំ** សរសេររឿងចៅកើតកុសល ឆ្នាំ១៩២១

១០ **កែ នេត្រ** សរសេររឿងលើកមទ្រី ឆ្នាំ១៩២២

គួរកត់សម្គាល់ដែរថា ទោះបីជាសម័យអាណានិគមបារាំងដែលពួកវាមានបំណងបំបិទអក្សរសាស្ត្រខ្មែរ ហើយឲ្យកូនខ្មែរងាកមកការសិក្សាភាសាបារាំង អក្សរសាស្ត្របារាំងក្តី ក៏នៅតែមានកូនខ្មែរមួយចំនួនធំតែងដក់ជាប់ទឹកចិត្តស្រឡាញ់វិស័យអក្សរសាស្ត្រជាតិដែរ ហើយអស់លោកទាំងនោះ តែងតែឡៀតសរសេរជាកម្រងវណ្ណកម្មអក្សរសិល្ប៍ដើម្បីជាការបំពេរអារម្មណ៍ ឲ្យបានធូរស្បើយគ្រាដែលប្រទេសជាតិមានទុក្ខលំបាក។ ការសរសេរនេះ មិនមែនបានន័យថា មិនបញ្ចូលការអប់រំនៅក្នុងនោះទេ ។ ការមើលតែសម្បកខាងក្រៅ គឺមិនឃើញពីតម្លៃពិតនៃទឹកដៃរបស់អស់លោកឡើយ។ មកដល់ចុងសម័យអាណានិគម ក៏មានអ្នកនិពន្ធ ជាច្រើននាក់ទៀតដែលបានប្រែក្លាយស្នាដៃអក្សរសិល្ប៍ដែលធ្លាប់តែនិយាយ អ្វីមិនមែនជាលក្ខណៈសច្ចៈនៅលើផែនដី ក៏បានងាកមកការសរសេរជាលក្ខណៈពិតវិញ ដែលចរន្តនៃការផ្លាស់ប្តូរនេះ មិនមែន

បានន័យថា អ្នកនិពន្ធខ្មែរចង់បំបាត់ធាតុដើមរបស់ខ្លួនទេ តែផ្ទុយទៅវិញ គឺគាត់រិតតែធ្វើឲ្យបវរន្ត មានការផ្លាស់ប្តូរទៅរកភាពទាន់សម័យនិយម ដែលពិភពតែងនិពន្ធលើពិភពលោកកំពុងតែទទួលយក។

ខ្ញុំមានការសោកស្តាយណាស់ ដោយខ្ញុំមិនបានស្រង់នាមអ្នកនិពន្ធ និងប្រវត្តិរបស់លោកមកអស់ដើម្បីបង្ហាញជូនមិត្តអ្នកអានទុកជាការស្រាវជ្រាវជាបន្ត។

អ្វីដែលបានបង្ហាញជូនតាមទំព័រខាងលើ គឺខ្ញុំរើសយកតែ អ្នកនិពន្ធដែលមានស្នាដៃផេតប៉ុណ្ណោះ ចំណែកអ្នកនិពន្ធខ្លះទៀតមាននៅសល់តែស្នាដៃ នឹងនាំឲ្យពិបាកក្នុងការសិក្សា ហើយស្នាដៃទាំងនោះមាននៅរាត់រាយដែលមានអ្នកស្រុកខ្លះចេះចាំ តែមិនមានភាពច្បាស់លាស់។

សរុបសេចក្តីមក ទោះបីជាវណ្ណកម្មអក្សរសិល្ប៍របស់ខ្មែរសម័យអាណាព្យាបាល មានលក្ខណៈតូចចង្អៀតម្តេចក្តី ក៏គេបានសម្លឹងឃើញនៅប្រទេសខ្មែរសម័យនោះ ម្ចាស់អាណាព្យាបាលបាននាំចូលមកដល់ប្រទេសខ្មែរនូវកុនដែលជាលំនាំថ្មី នៃការផ្សព្វផ្សាយវណ្ណកម្មអក្សរសិល្ប៍មកដល់បណ្តាមហាជនទូទៅ។

តាមពិតសញ្ញាណកុនខ្មែរ គឺមានលំនាំតាមរយៈល្ខោនស្បែក ដែលជាចម្លាក់ដែលគេឆ្លាក់នៅលើស្បែកគោ សម្រាប់បញ្ចាំងស្រមោលរូបនៅលើផ្ទាំងសំពត់។ នេះជាការសម្តែងម្យ៉ាង ដែលសព្វថ្ងៃយើងហៅថា "កុន" ។

នៅប្រទេសកម្ពុជា នាដើមសតវត្សទី២០ កុនត្រូវបាននាំចុលមកដល់ប្រតេសខ្មែរ ពោលគឺនៅក្នុងឆ្នាំ១៩០៩ មានការសម្ភោធន៍រោងកុនមួយនៅទីក្រុងភ្នំពេញដែលមានឈ្មោះថា Brignon ហើយរឿងដែលគេយកមកសម្តែងនៅឱកាសនោះ គឺជារឿងដែលផលិតនៅប្រទេសបារាំង

និងនៅប្រទេសអាមេរិកកាំង។

នៅពាក់កណ្តាលទសវត្សរ៍១៩៥០ កុនឥណ្ឌាក៏បានចូលមកដល់ប្រទេសខ្មែរ នឹងបានបញ្ចាំងជូនប្រជាជនខ្មែរទស្សនា ហើយក៏ទទួលបានការពេញនិយមពីសំណាក់អ្នកទស្សនាសម័យនោះ ព្រោះតែនៅភាពយន្តឥណ្ឌាមានតយអង្គស្តេច ឥសី មានប្រើសិល្បអាគមជាដើម។

នៅទសវត្សឆ្នាំ១៩៥០ ប្រទេសកម្ពុជាក៏ចាប់មានការថតកុនដោយខ្លួនឯង ដោយមានព្រះបាទសម្តេចនរោត្តមសីហនុជាថតកុនដំបូងគេ។ បញ្ហាកុននេះ ក៏ចាប់រីកសាយភាយខ្លាំងនៅសម័យសង្គមរាស្រ្តនិយមតទៅ ហើយមានភាពល្បីរន្ទឺនៅក្នុងតំបន់ទៀតផង។

## អក្សរសិល្ប៍សម័យសង្គមរាស្រ្តនិយម

## ទិដ្ឋភាពទូទៅអក្សរសិល្ប៍សម័យសង្គមរាស្ត្រនិយម

សម័យសង្គមរាស្ត្រនិយម គិតចាប់ពីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ មកដល់ឆ្នាំ១៩៧០ គឺជាពេលដែលប្រទេសខ្មែរទទួលបានឯករាជ្យពីប្រទេសបារាំងដែលបានដាក់អាណានិគម។ តាមពិតផ្នែកវប្បធម៌ ប្រទេសកម្ពុជាបានរួចពីការគ្រប់គ្រង ដ៏តឹងតែងពីសំណាក់បារាំងតាំងពីឆ្នាំ១៩៤៩មកម្ល៉េះ មានន័យថា នៅឆ្នាំនេះតទៅ បារាំងមានលក្ខណៈបន្ធូរបន្ថយច្រើន លែងមានការគាបសង្កត់ទៀតហើយ។ ដូច្នេះ ចាប់តាំងពីឆ្នាំនេះមក វិស័យតែងនិពន្ធ ក៏មានសន្ទុះឡើងវិញ ដោយគេឃើញមានអ្នកនិពន្ធជាច្រើនបានប្រារព្ធស្នាដៃខ្លួន ព្រមទាំងបានចេញផ្សាយជាបន្តបន្ទាប់។

បន្ទាប់ពីទទួលបានឯករាជ្យបរិបូរណ៍ពីបារាំង គ្រប់វិស័យនានានៅក្នុងសង្គមក៏មានការរីកចម្រើន មានដំណើរឡើងវិញ។ ទាំងនេះ អាចនិយាយបានថា គឺជាគុណបំណាច់ដ៏ធំមហិមាដែលអង្គសម្ដេចឪ ព្រះករុណានរោត្តមសីហនុ ព្រះអង្គបានទាមទារមកជូនប្រជាជន ក៏ដូចជាប្រទេសជាតិរបស់ព្រះអង្គទាំមូលដែរ។ ក្ដីសង្ឃឹមមួយក៏បានកើតមានឡើងវិញ បន្ទាប់ពីការដេកស្រមៃក្នុងក្ដីសង្ឃឹមអស់ជិតមួយសតវត្សកន្លងមក។ អក្សរសាស្ត្រអក្សរសិល្ប៍ដែលជាដួងព្រលឹងជាតិក៏មានជីវិតតាមរយៈការបង្ហាញរបស់អ្នកនិពន្ធ។ ដូច្នេះគេអាចនិយាយបានថា អ្នកនិពន្ធគឺជា កម្រងជីវិតនៃតថភាពអក្សរសិល្ប៍។ មកដល់សម័យដែលមានការឲ្យតម្លៃ អ្នកនិពន្ធយើង លោកក៏បានលើកកម្ពស់ ព្រមទាំងបានពង្រឹង សមត្ថភាពខ្លួនឯងឲ្យរឹតតែមានការរីកចម្រើនបន្ថែមទៀត។ គេឃើញថា មកដល់សម័យនេះ អ្នកនិពន្ធបានងាកមកការប្រារព្ធស្នាដៃ

ខ្លួន ដោយចេះជ្រើសរើសប្រធានបទនានាដែលទាក់ទងនឹងជីវិតពិតនៅលើផែនដីបច្ចុប្បន្នដូចជា ជីវិតជនក្រីក្រ បុគ្គលដែលគ្មានអំណាចហើយទទួលការជិះជាន់ពីមនុស្សក្នុងសង្គមដូចគ្នា អំពីជីវិតទាហាន ជីវិតក្មេងកំព្រា ឬមួយទាក់ទងទៅនឹងការបំផុសស្មារតីក្នុងការការពារជាតិ ស្នេហាជាតិជាដើម។ ទាំងនេះ អាចបញ្ជាក់យ៉ាងច្បាស់ថា អក្សរសិល្ប៍ខ្មែរ បានឈានទៅដល់ដំណាក់កាលមួយដែលមានការផ្លាស់ប្តូរ ទៅរកការរីកចម្រើនជាងសម័យមុន ដែលការសរសេរផ្តេកផ្តួលទៅលើការស្រមៃក្នុងមនោគតិ។ អក្សរសិល្ប៍សម័យសង្គមរាស្ត្រនិយម គេអាចហៅម្យ៉ាងទៀតថា ជាអក្សរសិល្ប៍សម័យឯករាជ្យ ព្រោះប្រទេសខ្មែរបានរំដោះផុតពីការគ្រប់គ្រងរបស់បារាំង។ ឬមួយទៀតគេក៏អាចហៅថាជាអក្សរសិល្ប៍សម័យរាជាណាចក្រទីមួយ។ តើអ្នកនិពន្ធពិតជាចង់ចិញ្ចឹមជីវិតខ្លួននោះលើចុងប៉ាកកាមែនដែរឬទេ?

គ្រប់សម័យកាល ការដែលចង់បានលាភសក្ការៈពីសិល្បៈតំណែងរបស់ខ្លួនពិតជាមានមែន តែអ្វីដែលសំខាន់នោះ គឺអស់លោកទាំងនេះ លោកចង់បន្សល់ស្នាដៃទុកជាកេរសម្រាប់ឲ្យអនុជន នៃជនជាតិខ្លួនបានស្គាល់ខ្លួនតាមរយៈវណ្ណកម្មតែប៉ុណ្ណោះ ហេតុដូច្នេះហើយ បានជាមកដល់សម័យនេះ គេក៏បានឃើញមានអ្នកនិពន្ធជាច្រើនបានបង្ហាញស្នាដៃរបស់ខ្លួន សម្រាប់ជាការកំដរប្រិយមិត្តអ្នកអានគ្រប់ស្រទាប់ជាន់ថ្នាក់នៅក្នុងសង្គម។

ស្របពេលជាមួយនឹងការរីកចម្រើនខាងវិជ្ជានិពន្ធ នៅឆ្នាំ ១៩៥៦សមាគមអ្នកនិពន្ធខ្មែរ ក៏ត្រូវបានបង្កើតឡើងក្រោមព្រះរាជក្រម

លេខ២៦១ ន.ស ចុះខែមករា ឆ្នាំ១៩៥៦ ដែលសេចក្តីក្នុងនោះ បានបើកឱកាសដល់អ្នកនិពន្ធទាំងឡាយក្នុងការនិពន្ធស្នាដៃខ្លួន។

ហេតុដូច្នេះហើយ បានជាប់ពីឆ្នាំ១៩៥៧មក ការតែងនិពន្ធមានការផ្លាស់ប្តូរជានិច្ច មានន័យថា ចំនួនអ្នកនិពន្ធដែលបានមកចូលជាសមាជិកកាន់តែមានចំនួនច្រើនឡើង។ តាមរបាយការណ៍បានឲ្យដឹងថា គិតមកត្រឹមឆ្នាំ១៩៥៦ មកដល់ឆ្នាំ១៩៧២ ចំនួនអ្នកនិពន្ធ កវីនិពន្ធមានចំនួនកើនដល់១៩០នាក់។ របាយការណ៍ជាបន្តទៀតបានឲ្យដឹងថា វណ្ណកម្មអក្សរសិល្ប៍ដែលត្រូវបាននិពន្ធឡើង នឹងត្រូវបានបោះពុម្ពផ្សាយក៏មានចំនួនច្រើនណាស់ដែរ ដោយនៅឆ្នាំ១៩៥៧មានចំនួន៦៤ស្នាដៃ និងនៅឆ្នាំ១៩៦៦មានចំនួន៩៦ស្នាដៃ។ ទាំងនេះសបញ្ជាក់យ៉ាងច្បាស់ថា វិស័យតែងនិពន្ធនៅស្រុកខ្មែរមានកើនឡើងយ៉ាងសន្ធឹកបើប្រៀបធៀបជាមួយនិងបណ្តាឆ្នាំនាសម័យមុនៗមក។ ទាំងនេះ ក៏ដោយសារតែបរិយាកាសសង្គម មានអំណោយផលល្អសម្រាប់ការបញ្ចេញស្នាដៃរបស់ខ្លួន ទើបធ្វើឲ្យអ្នកនិពន្ធយើងខិតខំចងក្រងវណ្ណកម្មរបស់ខ្លួនដើម្បីបម្រើតម្រូវការមិត្តអ្នកអាន។ អាចនិយាយបានថា កូនខ្មែរបានឲ្យតម្លៃទៅលើ ការសរសេរជាខ្លាំងទើបបានជាកម្លាំងចិត្តសម្រាប់ការតែងនិពន្ធថ្មី។ អ្នកនិពន្ធពីមុនៗមក ក៏ត្រូវបានបាត់រូបលែងឃើញមានការសរសេរជាថ្មី ចំណែកអ្នកនិពន្ធក្មេងជំនាន់ក្រោយក៏ត្រូវបានផុសឡើងប្រៀបដូចជារដូវភ្លៀងធ្លាក់នាខែភ្ជុំបិណ្ឌដូច្នោះ។ ពួកគេម្នាក់ៗខិតខំបញ្ចេញស្នាដៃដើម្បីប្រឡងប្រណាំងគ្នា តែស្នាដៃទាំងនោះច្រើនជាប្រភេទអត្ថបទខ្លីៗ ហើយក៏ពុំសូវមានបទឬមាតិការឿងដែលលើកយកមកដាក់ជាគោល ដើម្បីអធិប្បាយពង្រីកសេចក្តីឲ្យល្មមស្តាប់បានឡើយ។ ចំពោះរបៀបរៀបចំសាច់រឿងវិញ គេក៏មិនសូវប្រិតប្រៀនដូចគ្រាមុនៗដែរ

ទោះជាខាងអត្ថរសក្តី និងខាងទម្រង់សេចក្តី ក្តី។ មូលហេតុទាំងនេះ បាននាំឲ្យចរន្តអក្សរសិល្ប៍ខ្មែរយើង បានជួបប្រទះការអោក់អួលអស់មួយគ្រាដែរ។

នៅសម័យនេះ បញ្ហាអក្សរសាស្ត្រយើង ត្រូវមានបញ្ហាច្រើន ព្រោះមានអ្នកស្នេហា អក្សរសាស្ត្រជាច្រើនពួកគាត់ម្នាក់ៗសុទ្ធតែមានការត្រិះរិះពោរពេញដោយវិចារណញ្ញាណរៀងៗខ្លួន ពិសេសគឺមានការយល់ឃើញប្លែកៗពីគ្នា ហើយស្នាដៃទាំងនេះ ស្ទើរជាស្នាដៃបច្ចេកទេសមិនអាចវែកញែកបាន ព្រោះអ្នកនិពន្ធបានកាឡៃបញ្ចូលបែបទាំងពីរផ្ញើជារឿងតែមួយ ម្ល៉ោះហើយរឿងរ៉ាវទាំងនោះពុំបានដាក់លាក់សម្រាប់អ្នកអានទេ មានន័យថា ស្នាដៃទាំងនោះគ្រាន់តែនាំសតិអារម្មណ៍អ្នកអានឲ្យអណ្តែតអណ្តូង ទៅតាមចំណង់តណ្ហាឬមនោសញ្ចេតនារវើរវាយតែប៉ុណ្ណោះ។

អាស្រ័យដោយការរីកចម្រើននៃសង្គម ភាពសម្បូរបែបនេះក៏ជាកត្តាមួយជួយជំរុញខឿនវប្បធម៌ផ្នែកការតែងនិពន្ធ ឲ្យរិតតែទទួលបាននូវការគាំទ្រ ក៏ដូចជាកត្តាមួយជួយផ្សព្វផ្សាយអក្សរសិល្ប៍ជាតិដល់បណ្តាមនុស្សទាំងឡាយ នៅប្រទេសបានក្រេបនូវរសជាតិអក្សរសាស្ត្របានគ្រប់ទិសទី។ អក្សរសិល្ប៍ទំនើបខ្មែរ ទើបតែត្រូវបានកសាងខ្លួនឡើងវិញក្នុងរយៈពេលមួយដ៏ខ្លីប៉ុណ្ណោះ ប៉ុន្តែបណ្តាស្នាដៃដែលបានលេចជារូបរាងឡើង បានបង្កើតនូវសញ្ញាជាពិសេសសម្រាប់សម្គាល់ការរីកចម្រើនលូតលាស់ទៅសម័យក្រោយទៀត។ ការតស៊ូរវាងទស្សនៈប្រពៃណី និងទស្សនៈផ្លាស់ប្តូរថ្មីក៏នៅតែប្រព្រឹត្តទៅយ៉ាងវែងអន្លាយ ហើយមានលក្ខណៈស្មុគស្មាញជានិច្ច។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏អក្សរសិល្ប៍ ដ៏ទំនើបរបស់ខ្មែរចេះតែស្វែងរកស្វែងរកប្រកពបណ្តុះគំនិតក្នុង

ការអនុវត្តន៍នៃជីវភាពរស់នៅ ដោយចេះប្រើប្រាស់ទុនអក្សរសិល្ប៍ និង សិល្បៈ ដែលជាទម្រង់បុរាណមកធ្វើជាមូលដ្ឋានដើម្បីជាកត្តាលីករមួយ ក្នុងការស្ថាបនាអក្សរសិល្ប៍ទំនើបមួយក្នុងសង្គមខ្មែរសម័យថ្មី។

ជាបន្ត ខ្ញុំនឹងលើកជីវប្រវត្តិនិងអត្ថបទដែលជាស្នាដៃរបស់អ្នកនិពន្ធជំនាន់តមួយចំនួនមកបង្ហាញជូនមិត្តអ្នកអានដូចតទៅ៖

## ១ អ្នកស្រី ស៊ិម វណ្ណាស៊ី

អ្នកស្រីប្រសូតនៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩២០ នៅសង្កាត់លេខ ៣ រាជធានីភ្នំពេញ។ បិតារបស់អ្នកស្រីមាននាមឧកញ៉ាសរ៉ាពិជិត "ស៊ិម" បម្រើការងារនៅខុទ្ទកាល័យនៃសម្តេចព្រះស៊ីសុវត្ថិមនីវង្ស។ មាតានាមអ្នកស្រី ចាំ អ៊ុន។

កាលពីវ័យកុមារអាយុបាន៧ឆ្នាំ បិតាបាននាំអ្នកស្រីទៅសិក្សាជាមួយអ្នកស្រី គឹម ស៊ីវីដែលត្រូវជាភរិយារបស់លោក អៀវកើសនៅរាជធានីភ្នំពេញដែរ។ លុះមកដល់ឆ្នាំ១៩៤០ អ្នកស្រីក៏បានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សា នៅក្នុងឆ្នាំនេះដដែលអ្នកស្រីក៏មានតួនាទីជាលេខាធិការបណ្ណារក្សនៅពុទ្ធសាសនបណ្ឌិត្យ។ លុះមកដល់ឆ្នាំ១៩៤១ ក៏បានប្រឡងជាប់ចំណាត់ថ្នាក់លេខ២ ក្នុងការសរសេរតែងសេចក្តីជាភាសាបារាំងដែលមានប្រធានបាវចនាបីម៉ាត់ "ការងារ គ្រួសារ មាតុភូមិ" នៅឆ្នាំ១៩៤២ អ្នកស្រីក៏បានចូលសិក្សាក្នុងសាលាជាន់ខ្ពស់ខាងគ្រប - ខ័ណ្ឌនៃយុវជននៅ ដាក់ឡាក់ ប្រទេសវៀតណាមខាងត្បូង។ បន្ទាប់ពីបានវិលត្រឡប់ មកដល់មាតុភូមិវិញនៅឆ្នាំ១៩៤៥អ្នកស្រីបានបម្រើការជាអ្នកបកប្រែភាសាបារាំង-ខ្មែរនៅក្រសួងការបរទេស។ អ្នកស្រីក៏បានបន្តការសិក្សានៅសាលាច្បាប់នាឆ្នាំ១៩៥១-១៩៥២ ដោយមានបញ្ហា

ខាងការងារផ្នែកនយោបាយ នៅឆ្នាំ១៩៥៣អ្នកស្រីក៏បានជាប់គុកអស់រយៈពេល១២ខែ។

នៅឆ្នាំ១៩៥៩ អ្នកស្រីក៏បានចូលជាសមាជិកសង្គមរាស្ត្រនិយមក្រោមការដឹកនាំរបស់សម្ដេចព្រះនរោត្តមសីហនុ។ លុះមកដល់ឆ្នាំ១៩៦១ អ្នកស្រីក៏បានទទួលអាហារូបករណ៍ទៅបន្តការសិក្សាឯកទេសសង្គមសាស្ត្រនៅឯប្រទេសស្វីស រួចបន្តមកប្រទេសប៊ែលស៊ិក ប្រទេសបារាំង និងសហរដ្ឋអាមេរិកអស់រយៈពេល៤ឆ្នាំទើបបានត្រឡប់មកស្រុកកំណើតវិញ។

មកដលឆ្នាំ១៩៧០ អ្នកស្រីក៏បានចូលខ្លួនជាអ្នកតំណាងរាស្ត្រនៃគណបក្សសង្គម សាធារណរដ្ឋ ហើយមកដល់ឆ្នាំ១៩៧២ក៏បានចូលជាសមាជិកនៃគណបក្សសង្គមសាធារណរដ្ឋពេញសិទ្ធិ។

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ អ្នកស្រីបានបន្សល់ស្នាដៃ ចំនួនបីក្នុងនោះមាន៖

-រឿង សង្ឃឹមជានិច្ច បោះពុម្ពនៅឆ្នាំ១៩៥៨

-រឿងបកប្រែពីភាសាបារាំង មានពីររឿងតែពុំទាន់បានបោះពុម្ពនៅឡើយ។ រឿងទាំងនោះមាន៖

-រឿងត្រពាំងបិសាច

-អាប៉ូលអាសាច់ក្នុងរឿង១០០១

## ២ លោក គង់ លឹម

លោកប្រសូតនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៣១មានទីលំនៅភូមិវាល ឃុំកំពង់លាវ ស្រុកកំពង់លាវ ខេត្តព្រៃវែង។ បិតាលោមាននាមគង់

ប៉ូ ត្រូវបានស្លាប់នៅអំឡុងឆ្នាំ១៩៧០ ចំណែកម្ដាយមាននាម ហាង់ យន់ ទទួលមរណភាពនៅឆ្នាំ១៩៥៤នៅស្រុកកំណើត។

អាយុបាន៨ឆ្នាំ បិតាបាននាំទៅឲ្យសិក្សានៅសាលាបឋមសិក្សាក្រុងព្រៃវែង (សព្វថ្ងៃហៅថា ព្រៃវែងក្រុង) លុះដល់ឆ្នាំ១៩៤៥ គ្រាដែលសង្គ្រាមលោកលើកទី២ត្រូវបានផ្ទុះលើពិភពលោក ។ប្រទេសខ្មែរដែលស្ថិតក្រោមការត្រួតត្រារបស់បារាំង ក៏ត្រូវបានប្រទេសជប៉ុនដែលបានឈ្នះសង្គ្រាម ជាមួយបារាំងបានចូលមកលុកលុយរួចធ្វើការចាប់បារាំង។ ហេតុការណ៍នេះ បានបណ្ដាលឲ្យសាលារៀនទាំងអស់ត្រូវបានបិទទ្វារ។ ទោះបីជាយ៉ាងដូច្នេះក៏ដោយក៏លោកគង់ លឹមនៅតែមានសេចក្ដីព្យាយាមក្នុងការរៀនសូត្រដដែល ដោយលោកបានឆ្លៀតឱកាសទៅសិក្សាបន្ថែមផ្នែកភាសាបាលី និងច្បាប់ផ្សេងៗនៅវត្តឯកការ៉ាមនៅព្រៃវែងក្រុងអស់រយៈពេលមួយឆ្នាំ(សព្វថ្ងៃ វត្តនេះអ្នកស្រុកជិតឆ្ងាយហៅថា **វត្តថ្មី** ស្ថិតនៅជិតវិទ្យាល័យហ៊ុន សែនកំពង់លាវ) ។

នៅឆ្នាំ១៩៤៦ លោកក៏បានចូលរៀនដល់ថ្នាក់ទី៧សម័យសង្គមចាស់ ហើយក៏បានប្រឡងជាប់សញ្ញាបត្របឋមសិក្សា។ លុះមកដល់ឆ្នាំ១៩៤៧-១៩៥២ លោកក៏បានបន្តការសិក្សានៅសាលាគរុវិជ្ជាឯទីក្រុងភ្នំពេញ។ ឆ្នាំ១៩៥២រហូតដល់ឆ្នាំ១៩៥៤លោកក៏បានធ្វើជាគ្រូជំនួយឲ្យក្រសួងអប់រំជាតិ។ នៅឆ្នាំ១៩៥៥បានផ្លាស់ទីកន្លែងធ្វើការមកនៅសាលាល្ខោនជាតិក្នុងទីក្រុងភ្នំពេញ។ ឆ្នាំ១៩៥៦ ក៏បានផ្លាស់ទីកន្លែងធ្វើការទៅខេត្តបាត់ដំបង រួចក៏បានផ្លាស់មកបម្រើការនៅស្រុកកំណើតឯខេត្តព្រៃវែងនៅឆ្នាំ១៩៥៧ លោកបម្រើការបានតែ៤ឆ្នាំ ក៏បានផ្លាស់ទៅបម្រើការនៅឯខេត្តក្រចេះក្នុងឆ្នាំ១៩៦១បានចំនួន៤ឆ្នាំ។ នៅឆ្នាំ១៩៦៥ លោកក៏បាន ប្រឡងជាប់ជាគ្រូបង្រៀនបឋមសិក្សាបំពេញវិជ្ជាទើបបាន

ផ្លាស់មកបម្រើការនៅខេត្តព្រៃវែងវិញ។ ជាចុងក្រោយនៃប្រវត្តិការងារ របស់លោក នៅឆ្នាំ១៩៧១ លោកក៏ត្រូវបានផ្លាស់មកបម្រើការនៅនាយកដ្ឋាន បឋមសិក្សាឯភ្នំពេញដោយបានទទួលបន្ទុកជាអ្នកកាន់ស្ថិតិបុគ្គលិក។

ទោះបីជាលោក មានប្រវត្តិបម្រើការងារជាច្រើនកន្លែងក្តីតែលោក ក៏ជាអ្នកដែលមានចិត្តស្រឡាញ់វិស័យអក្សរសាស្ត្រយ៉ាងអស់ពីចិត្តពីថ្លើម។ បទពិសោធន៍នៃជីវិតរបស់លោក បាននាំឲ្យលោកបន្សល់ស្នាដៃអក្សរសិល្ប៍ មួយចំនួនដើម្បីជាប់ឈ្មោះជាអ្នកនិពន្ធក្នុងបញ្ជីអក្សរសាស្ត្រជាតិ។ ស្នាដៃមួយចំនួនដែលលោកបានចងក្រងឡើងក្នុងទស្សនាវដ្តីនេះរួមមាន៖

-រឿងស្នេហាជាតិ សរសេរជាពាក្យកាព្យនៅឆ្នាំ១៩៤២ និងត្រូវបានទស្សនាវដ្តីកម្ពុជសុរិយាបោះពុម្ពផ្សាយនៅឆ្នាំ១៩៥២

-រឿង ស្លាប់ព្រោះជាតិ អត្ថបទសរសេរជាពាក្យពាយ ត្រូវបានទស្សនាវដ្តីបោះពុម្ពផ្សាយនៅឆ្នាំ១៩៥២-១៩៥៣

-រឿងបំរើជាតិ អត្ថបទសរសេរជាពាក្យកាព្យ

-រឿងគិតដល់ជាតិ អត្ថបទសរសេរជាពាក្យកាព្យ

-រឿងអតីតជាតិ អត្ថបទសរសេរជាពាក្យកាព្យ

-រឿងជួយជាតិ អត្ថបទសរសេរជាពាក្យកាព្យ

-រឿងដួងចិត្ត ប្រលោមលោកសរសេរជាពាក្យពាយ

## ៣ អ្នកស្រី ស៊ុយ ហៀង

អ្នកស្រីប្រសូតនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩២៥ នៅសង្កាត់លេខ៦ រាជធានីភ្នំពេញ។ បិតានាមអ៊ឹង ទិនឡាយ មានមុខរបរជា អ្នកជំនួញ។

មាតាមាននាម ហេង លួយ មានមុខរបរជាអ្នកជំនួញ។អ្នកស្រីបានសិក្សាត្រឹមថ្នាក់ទី១០ សម័យសង្គមចាស់ ដោយកាលពីនៅកុមារ អ្នកស្រីបានទៅសិក្សាសិក្សានៅសាលាកុមារី **ប៉ារី** ។ ខណៈដែលស្ថិតក្នុងការសិក្សាម្ដាយរបស់អ្នកស្រីបានទទួលអនិច្ចកម្ម ។ កាលនោះ អ្នកស្រីទើបតែមានអាយុ១៤ឆ្នាំប៉ុណ្ណោះ អ្នកស្រីក៏សម្រេចចិត្តបោះបង់ចោលការសិក្សាទាំងស្ដាយស្រណោះមកជួយគ្រប់គ្រងមុខរបរជំនួញជាមួយឪពុក។ អ្នកស្រីបានកាន់កាប់ផ្ទះលក់សៀវភៅឈ្មោះ "**ខេមរបណ្ណាគារ**"។ ទោះបីជាអ្នកស្រីបានឈប់រៀនក្ដី ក៏អ្នកស្រីនៅតែមានចិត្តស្រឡាញ់ការអានសៀវភៅណាស់ ពិសេសសៀវភៅអក្សរសាស្ត្រជាតិតែម្ដង។

នៅឆ្នាំ១៩៤៥ អ្នកស្រីបានរៀបការជាមួយលោកលី វូអុងដែលបម្រើការជាអ្នកអភិរក្សនៅសារមន្ទីរជាតិទីក្រុងភ្នំពេញ។ ចំណងស្នេហាអ្នកស្រីជាមួយលោក វូអុងបានបន្សល់ទុកកូន៤នាក់ក្នុងនោះមានស្រី២នាក់ប្រុស២នាក់។ ក្រោយមកនៅឆ្នាំ១៩៥៥ដោយមានភាពរកាំរកូសនៅក្នុងគ្រួសារ អ្នកស្រីក៏បានធ្វើការលែងលះគ្នាជាមួយលោកវូអុង ហើយបន្ទាប់ពីនោះមកបាន៣ឆ្នាំ ក៏បានរៀបការជាមួយប្ដីថ្មីដែលមានមុខរបរជាទាហាន តែមិនបានប៉ុន្មាន ចំណងស្នេហានេះក៏ត្រូវបាក់បែកទៅទៀត ។ ក្រោយពីនោះមក អ្នកស្រីក៏បានរៀបការជាមួយប្ដីជនជាតិបារាំង រួចក៏បានបង្កើតកូនចំនួន២នាក់ទៀត។ អ្នកស្រីក៏ជាអ្នកបង្កបង្កើតសមាគមអ្នកនិពន្ធខ្មែរដែរ ហើយនៅក្នុងឆ្នាំ១៩៥៦-១៩៥៧ អ្នកស្រីក៏បានជាប់ជាសមាជិកក្រុមអភិបាលពីរលើកដែរនៅក្នុងសមាគមនេះ។ ជាចុងក្រោយនៅឆ្នាំ១៩៧២ អ្នកស្រីក៏ចេញទៅរស់នៅប្រទេសបារាំងជាមួយស្វាមីទៅ។

ស្នាដៃរបស់អ្នកស្រីក្នុងវណ្ណកម្មអក្សរសិល្ប៍ខ្មែររួមមាន៖

-រឿងវាសនានៃនាងណាត្រី ឆ្នាំ១៩៥២
-រឿងស្និងក្រហម ភាគ១-ភាគ២ ឆ្នាំ១៩៥២
-រឿងកូនក្រកមេបោរ ភាគ១-ភាគ២ ឆ្នាំ១៩៥៣
-រឿងផ្ការីកផ្កាពោយ ឆ្នាំ១៩៥៣
-រឿងចន្ទ្រាដីខ្មែរ ឆ្នាំ១៩៦៣
-រឿងបេះដូងសីថា ឆ្នាំ១៩៧១
-រឿងបញ្ហាទុក្ខា ឆ្នាំ?

ខាងក្រោមនេះ គឺជាអត្ថបទសម្រង់នៅក្នុងរឿង **ផ្ការីកផ្កាពោយ** របស់អ្នកនិពន្ធខាងលើ ដែលខ្ញុំលើកយកមកបង្ហាញអ្នកអានខ្លះៗដើម្បីសិក្សាស្វែងយល់ពីទឹកដៃរបស់អ្នកនិពន្ធរូបនេះ។

...ស៊ីផា អើវើយ! ស្ត្រីនេះរូបរាងល្អមែន តើកូនចៅអ្នកណាបានជាហ៊ានដើរមកកន្លែងនេះតែម្នាក់ឯង។ កំឡោះតារា ជាមនុស្សធាប់ខិលកាលបើស្តាប់ស៊ីផា ជាមិត្រនិយាយមកផុតសេចក្តីហើយក៏បបួលមិត្រដើរតម្រង់ទៅរកនាងផាលាភ្លាម។

ឯកញ្ញាផាលា កាលបើបានឮសូរស្បែកជើងមនុស្សដើរព្រឹបៗមកជិតខ្លួននាងក៏ភ្ញាក់ព្រើត ហើយក្រឡេកមើលទៅត្រង់ចំទិសដែលឮសូរនោះ នាងឃើញច្បាស់ជាយុវជនទាំងពីរដើតម្រង់មករកនាង នាងនឹកក្នុងចិត្តថា "យី! មនុស្សប្រុសក្មេងៗនេះមកពីណាមក បានជាដើរតម្រង់មករកអញ តែអញមានចិត្តគួចមេត្រីទៅលើបុរសម្នាក់ដែលមានរូបល្អនោះ"...។ នាងផាលា នឹកដូច្នោះហើយ នាងក៏ងើយមើលរុក្ខជាតិនានាទៅវិញ នាងធ្វើកិរិយាព្រងើយហាក់ដូចជាមិនបានដឹងខ្លួន ព្រោះនាងមិនចង់ឲ្យយុវជននេះដឹងចិត្តនាង។

តាពបានដើរជិតនាងផាលា ហើយបញ្ចេញវាចាទៅថា: "ខ្ញុំបាទសុំទោសអ្នកស្រី សូមអ្នកអត់ទោសឲ្យខ្ញុំបាទសូមសួរបន្តិចអ្នកអញ្ជើញមកក្នុងទីនេះតែម្នាក់ឯងទេឬ?"។

នាងផាលាឆ្លើយថា "ចាំ" រួចនាងឈ្ងោកមុខមើលទៅដីដោយនាងមានសេចក្ដីភ័យនឹងសេចក្ដីខ្មាស់យ៉ាងពន់ពេក ត្បិតនាងពុំដែលធ្លាប់ចរចា ជាមួយនឹងប្រុសកំឡោះឯណាក្នុងទីស្ងាត់សោះឡើយ។

តាព-យី! បើដូច្នេះខ្ញុំបាទមានសេចក្ដីស្ដាយណាស់ព្រោះខ្ញុំបាទមានបំណង ចង់ថតរូបកញ្ញាឯណាម្នាក់ដែលមានរូបល្អដូចជារូបអ្នកស្រីឲ្យបានថតជាប់ជាមួយនឹងប្រាសាទដ៏ឧត្តុង្គឧត្តមនេះ បើសិនអ្នកមេត្តាជួយបំពេញបំណង របស់ខ្ញុំបាទប៉ងមកនេះបានឬទេ?ខ្ញុំបាទសូមអរគុណទុកជាមុន ព្រោះខ្ញុំបាទនឹកថា បើទោះជាយ៉ាងណាគង់តែអ្នកអាណិតមេត្តាឲ្យខ្ញុំបាទថតរូបអ្នកពុំខាន ហើយខ្ញុំបាទសូមសន្យាជូនអ្នកថា ខ្ញុំបាទនឹងលាងពង្រីកឲ្យបានរូបមួយសន្ធឹកយ៉ាងធំ យកមកជូនដល់អ្នកដើម្បីទុកជាអនុស្សាវរីយ៍របស់ខ្ញុំបាទតទៅអនាគត។...

មួយសន្ទុះមកភ្លើងឧសដ៏ក្រហមឆ្អិនឆ្អៅ ក៏ឆេះឆាបបុគ្គលនាងផាលា ហើយបង្ហុយផ្សែងខ្មៅហុយយ៉ាងទ្រលោមទៅលើអាកាស។ ចំនួន ពីរបីម៉ោងក្រោយមកនាងផាលា ក៏រលាយបាត់ៗ នៅសល់តែឆ្អឹងសប្រផេះយ៉ាងផុយតូចៗប៉ុនៗកូនដៃលាយនឹងធ្យូងខ្មៅ គេឃើញតាពរើសធ្យូងឧសរើសឆ្អឹង នាងផាលាមកមួយកញ្ចប់ តាព ស្រពោនឡើងខ្មៅបន្តិចមកបុរសបង្ហូរទឹកភ្នែក ហើយពោលល្ហឹមៗឡើងថា: "ឱ! ផាលា! ផាលា! អូនអើយ! នាងមិនគួរស្លាប់ចោលបងសោះ អូ! រូបអញអើយ ! ថ្ងៃណាក៏សាបសូន្យដូចជារូបផាលាដែរ អញមិនអាចនឹងចៀសសេចក្ដី

ស្លាប់នេះបានទេ! គួរសង្វេគរូបណាស់ ដើម្បីលាងផុតពីអំពើទុក្ខគ្រប់ប្រការ លាផុតអំពើលាមកទាំងអម្បាលម៉ាណ មានតែអញត្រូវទៅបួសប្រយោជន៍ឲ្យឃើញជាក់ស្តែង សេចក្តីដ៏បរិសុទ្ធសុចរិតរបស់អញ តបទៅលើរូបនាងផាលា និងយាយចាន់វិញ នែ! ចិត្តគំនិតខ្ញុំអើយ ! បើបានជាប្រព្រឹត្តខុសម្តងនេះទៅហើយ ខ្ញុំមិនត្រូវធ្វើឲ្យខុសតទៅអនាគតទៀតទេ"។ ផាលាអូនអើយ ! ចាប់តាំងពីថ្ងៃនេះតទៅ បងលះបង់អំពើទុច្ចរិតរបស់បងហើយ បងខំស្វែងរកធម៌ប្រតិអធិដ្ឋានបញ្ជូន កុសល្យទៅឲ្យអូនដើម្បីបានជាតិក្រោយបងសូមប្រាថ្នាឲ្យបានជួបនឹងអូនវិញ សូមកុំឲ្យវេទនាអកុសលក្នុងជាតិនេះ។

ប៉ុន្មានថ្ងៃក្រោយមក គេបានដឹងដំណឹងថាៈ "តាពទៅបួសធ្វើជាភិក្ខុសង្ឃមួយអង្គ ហើយសង្ឃនេះតែងតែចូលចិត្តទៅគង់លើកំពូលភ្នំ ឬក្នុងព្រៃណាជ្រៅៗ ដែលជាស្ថានលំនៅស្ងប់ស្ងាត់របស់ពពួកសត្វ ភិក្ខុអង្គនេះតែងចូលចិត្តយកសត្វម្រឹគីម្រឹគាធ្វើជាញាតិ"។

## រឿង វាសនានៃនាងណារត្រី

វណ្ណកម្មអក្សរសិល្ប៍មួយនេះ ខ្ញុំមិនបានសំណៅដើមដែលលោកស្រីធ្វើការបោះពុម្ពគ្រាដំបូងនោះទេ។ ខ្ញុំបានទទួលឯកសារមួយមួយនេះនៅគ្រាដែលត្រូវបានបោះពុម្ពសារជាថ្មីដោយលោក **សុត សារ៉ន** ដែលធ្វើការ បោះពុម្ពនៅឆ្នាំ១៩៩៩បន្ទាប់ពីប្រទេសខ្មែរទទួលបានសុខសន្តិភាពរួចហើយ។

សាច់រឿង ត្រូវបានបង្ហាញអ្នកអានឲ្យមើលឃើញ ពីវិនាសសង្គ្រាមលោកលើកទីពីរ ដែលត្រូវបានកើតនៅស្រុកខ្មែរ។ ផលអាក្រក់

នេះ បណ្ដាលមកពីស្រុកយើងត្រូវបានគេជិះជាន់ បាត់បង់នូវអធិប-តេយ្យភាពរបស់ខ្លួនៗ ជម្ទោះមហាអំណាចធំៗ ជំនាន់នោះ ម្ខាងជាអាល្លឺម៉ង់ និងម្ខាងជាជប៉ុនលើជំហរហ្វាស៊ីស ជល់ជាមួយមហាបក្សសម្ព័ន្ធបារាំង អង់គ្លេស អាមេរិកៗ

ដែនដីកម្ពុជា ក៏ត្រូវទទួលផលវិបាកដោយសារតែគេជិះជាន់ដែរអាណានិគមបានក្ដាប់ស្រុកខ្មែរតាំងពីចុងសតវត្សទី១៩មកៗ ខែតុលាឆ្នាំ១៩២៥ ទ័ពបារាំង អង់គ្លេសបានដណ្ដើមទឹកដីឥណ្ឌូចិនពីជប៉ុនវិញគ្រានោះហើយដែលមហាបក្សសម្ព័ន្ធបារាំង អង់គ្លេស អាមេរិកបានរួមគ្នាវាយរំដោះដែនដីដែលជប៉ុនដណ្ដើមខ្លួនមកវិញ ចំណែកទីក្រុងភ្នំពេញក៏ត្រូវបានទទួលគ្រាប់បែកជាលើកដំបូងនៅចំផ្សារកណ្ដាល ជ្រុងវត្តឧណ្ណាលោមដែលបណ្ដាលឲ្យប្រជាជនទទួលរងគ្រោះជាច្រើននាក់ៗ ជាមួយគ្នានេះដែរ ខ្ញុំបានឃើញវណ្ណកម្មអក្សរសិល្ប៍ពីរត្រូវបានកើតឡើង មួយគឺរឿង**គូលីកំណោន** ជាស្នាដៃរបស់លោក**អ៊ឹម ថុក**និងមួយទៀតគឺរឿង **វាសនានៃនាងណាត្រី** ជាស្នាដៃរបស់លោកស្រី**ស៊ុយហៀង**នេះឯងៗ

ជាបន្តទៅទៀត ខ្ញុំសូមអញ្ជើញមិត្តអ្នកអាន អញ្ជើញអានរឿងវាសនានៃនាងណាត្រី ដែលខ្ញុំដកស្រង់មកបង្ហាញជូនមិត្រអ្នកអានដូចតទៅៈ

...លុះបានប្រហែលជា២៥នាទីក្រោយមក ស្រាប់តែឮសូរ គ្រឹលៗគ្រឹល ញ័ររញ្ជួលរំជួល កក្រើកព្រះធរណី ផ្សែងខ្មៅក៏ផុសហុយទ្រលោមឡើងលើអាកាស ឯមនុស្សទាំងឡាយរីងរិតតែភិតភ័យតក្កមាញ័ររន្ធត់លើសដើមៗ

ចំណែកក្នុងលេណដ្ឋានរាជការ មានមនុស្សកាន់ច្រើន រត់ចេញពីក្នុងផ្ទះប្រសាចមកជ្រក អ្នកខ្លះមុខស្ងក់ស្លាំងធ្វើឡិនឡង់ អ្នកខ្លះនឹងអំពាវ នាវរកគុណមាតាបិតា គ្រូអាចារ្យ ខ្សឹបៗជាប់នឹងមាត់ៗ ឯចិនយួននឹកបន់ស្រន់រកអ្នកតា ក្នុងមាត់ខ្សឹបរហឹមៗថា "អុងតាៗ" ។ អ្នកទាំងអស់គ្នាខំអំពាវនាវរាវរកគុណសុំឲ្យជួយទ្រទ្រង់ជីវិត ឲ្យបានឆ្លងផុតពីសេចក្តីអន្តរាយ ក្នុងគ្រានេះ។

ស្គរសំឡេងគ្គីលៗ រំជួយរញ្ជួយកក្រើកព្រះធរណី នេះហើយគឺជាស្គរគ្រាប់បែក ដែលពួកសម្ព័ន្ធមិត្តហោះតាមអាកាសយានមកទម្លាក់បម្រុងចង់បំផ្លាញទ័ពជប៉ុន ដែលជាបច្ចាមិត្តខ្លួននៅក្នុងប្រទេសយើង។...

...ពេលនោះគាត់កាត់ចិត្តដើរចេញពីកន្លែងនេះទៅ ខ្នងកោងដំណើរមួយៗ ទប់ខ្លួននឹងដំបងឈើច្រត់ ចក្ខុរំពៃមើលនាយអាយក្នុងចិត្តព្រួយគ្មានរសាយ តាមគ្រប់ជំហានជើងនៃដំណើររបស់គាត់ លុះបានទៅដល់មុខវត្តឧណ្ណាលោម ចោលភ្នែកទៅស្រាប់តែឃើញចេតីយធំមួយ នៅជ្រុងខាងជើងព្រះវិហារបាក់រលំគ្របសង្កត់លើកុដិព្រះសង្ឃ ដែលបិតនៅក្បែរនោះ ព្រះសង្ឃក៏មានសុគតខ្លះ រួចពីនេះទៅ គាត់ក៏ដើរកាត់ថ្នល់តម្រង់ឆ្ពោះទៅរកមាត់ទន្លេ ប្រទះឃើញដីត្រង់មាត់ច្រាំងធ្លុះខួងជ្រៅជម្រៅប្រហែល៥ម៉ែត្រ នៅជិតនោះ មានឃើញកូនទូកបាក់ជាកំណាត់ៗ ប៉ើងខ្ទាយពីក្នុងទន្លេមកជាច្រើន ឯក្នុងទន្លេមានទូកតូចធំបាក់បែកខ្ទេចខ្ទីអណ្តែតព្រោងព្រាត ហាក់ដូចជាសំណាត់ មនុស្សក្នុងទូកទាំងប៉ុន្មានស្លាប់អស់គ្មានសល់ រួចពីនោះគាត់ដើរតម្រង់សម្តៅទៅរកមន្ទីរ ដែលគេយកមនុស្សរងគ្រោះថ្នាក់ទាំងអម្បាលម៉ាន ចាប់តាំងពីមនុស្សរងគ្រោះថ្នាក់របួស រហូតដល់មនុស្សអនិច្ចកម្មៗ ក្នុងពេលដែល

គាត់កំពុងទៃពិនិត្យរកមើលកូន ស្រាប់តែឮសូរសំឡេងយ៉ាងគ្រលួច ស្រែកហៅគាត់មកថា "លោកតា ៗ" តាគីមឡេងភ្ញាក់ខ្លួនព្រើត រួចងាក មើលតាមខ្យល់នៃសំឡេងនោះទៅចំទិសខាងកើត ឃើញច្បាស់ជាក្មេង ស្រីជំទង់ម្នាក់ ដែលវានៅបម្រើគាត់ៗ កាលបើគាត់ក្រឡេកទៅឃើញ ក្មេងនោះ ក្នុងចិត្តនឹកអរព្រួចមានសេចក្តីសង្ឃឹមឡើងថា "កូនរបស់អញ ច្បាស់ជារស់ជីវិតនៅក្នុងកន្លែងនេះ ម្ល៉ោះហើយសេចក្តីទុក្ខព្រួយ សេចក្តី អស់សង្ឃឹមទាំងប៉ុន្មាន ក៏រលាយសាបសូន្យពីក្នុងសន្តានចិត្តគាត់ភ្លាម ហើយដើរផ្លោះទៅចំក្មេងនោះ រួចនិយាយថា "កិរុណាចុះអ្នកនាងឯង... នៅក្នុងកន្លែងនេះដែរឬទេ?"

កិរុណ- ចាំ! នៅក្នុងទីនេះមិនឃើញទេ

ត គ ឡ - ឱ! អម្បាញ់មិញនេះអញនឹកសង្ឃឹមក្នុងចិត្តថា ច្បាស់ជាអ្នកនាងឯងនៅក្នុងទីនេះជាមួយនឹងឯងដែរៗ

កិរុណ- ចាំ ខ្ញុំចេះតែគន់មើលគាត់ដែរ ប៉ុន្តែមិនឃើញសោះ ទឹក ភ្នែកហូរចេញមករហាម ទើបពោលតទៅទៀតថា "ឱលោកអើយ! អ្នក ទៅឯណាបាត់ទៅ ប្រហែលជាចេញមិនផុតពីក្នុងផ្ទះនោះទេដឹង?

ត គ ឡ- ចុះកាលនោះឯងនៅឯណា បានជាបែកគ្នាដូច្នេះ?

កិ រ- ចាំ កាលនោះ ខ្ញុំនៅក្នុងផ្ទះដែរ ប៉ុន្តែខ្ញុំនៅខាងមុខ ចំណែក អ្នកនៅខាងក្រោយជិតផ្ទះបាយ អ្នកមាលា យាយគ្រីម អ្នកតូច ប្អូនតូច នៅជុំគ្នាក្នុងផ្ទះបាយ កំពុងតែចម្អិនម្ហូបអាហារ ដល់ឮសូរសន្ធឹកកប៉ាល់ ហោះៗមកធាបជំបូលផ្ទះ អ្នកស្រែកពីក្នុងមកថា ឲ្យរត់ចេញៗ ខ្ញុំក៏ស្ទុះ ច្រានទ្វារខាងមុខចេញមកៗ ស្រាប់តែ...ស្រាប់តែខ្ញុំ...ខ្ញុំដួលសន្ទប់ពុំដឹង ខ្លួន លុះត្រាតែគេយកខ្ញុំមកដល់កន្លែងនេះ ទើបខ្ញុំបានដឹងខ្លួនឡើង "កិ រុណា នាងក៏សើយសំពត់បង្ហាញជើងដែលត្រូវរបួសជាទម្ងន់ បង្ហាញខ្លួន

ប្រាណ រហូតដល់សម្លៀកបំពាក់ឃើញប្រឡាក់សុទ្ធតែកំបោរសសំព្រុស ហើយធំក្លិនដូចជាក្លិនរំសេវ។

ត គ ឡ- ភិរុណ ឱចៅឯងនេះ ចំជាអាយុថ្ងៃមែន អើចុះពេលនោះ បើអ្នកឯងដឹងខ្លួនបានទាំងស្រែកដូច្នោះដែរ តើឯងបានឃើញនាំគ្នារត់ចេញមកដែរឬទេ ?

ភី រ- ចាំ ខ្ញុំបានងាកមើលទៅមួយភ្លែត ឃើញគាត់រត់ចេញមកដែរ ប៉ុន្តែមិនដឹងជាផុតពីក្នុងផ្ទះឬទេ។ ឯចំណែកខ្ញុំ ស្ទុះលឿនចេញមុនគាត់មក ដោយខ្ញុំនៅមុខស្រាប់។

តាផៀងត្រចៀកស្តាប់ពាក្យភិរុណសព្វគ្រប់ហើយ ទើបហូតយកកូនកន្សែងពីក្នុងហោប៉ៅមកជូតទឹកភ្នែក ដែលហូរធ្លាក់សស្រាក់ ហើយទាញយកកាបូបមកបើករាប់ប្រាក់ ឃើញមានចំនួនតែ៥០រៀល គាត់ក៏ហូតយកក្រដាស ៥រៀលមួយសន្លឹកហុចទៅឲ្យភិរុណហើយនិយាយថា "តាគិតខំដើរទៅរកមើលអ្នកឯងទៀតហើយ..."

## ៤ លោកស្នួន ស៊ិន្ទ

លោកប្រសូតនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៣០ នៅសង្កាត់ជ្រៃ ស្រុកសង្កែ ខេត្តបាត់ដំបង។

អ្នកនិពន្ធដ៏ឆ្នើមម្នាក់នេះ ពុំបានបន្សល់ទុកជីវប្រវត្តិជាលក្ខណៈពិស្តារសម្រាប់ការស្រាវជ្រាវឡើយ។

ប្រសិនជាផ្អែកទៅលើស្នាដៃ ដែលមានតែមួយរបស់លោកគឺរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ខ្ញុំគិតថា លោកគឺជាអ្នកដែលរៀនបានចំណេះដឹងចេះគួរសម ពិសេសគឺបញ្ហានយោបាយសេដ្ឋកិច្ច ក៏គាត់ហាក់បានដឹងច្បាស់ពោល គឺសាច់រឿងបានសង្កត់ធ្ងន់ទៅទៅលើរបៀប

គ្រប់គ្រងពីរសម័យកាល គឺសម័យដែលប្រទេស ស្ថិតក្រោមការត្រួតត្រារបស់បរទេស និងសម័យកាលដែលប្រទេសមានឯករាជ្យរួចផុតពីការគាបសង្កត់ ហើយមានអ្នកដឹកនាំដ៏មានប្រាជ្ញាឈ្លាសវៃតែស្ថានភាពរស់នៅរបស់ប្រជាជនមានការរីកចម្រើន ទទួលបាននូវសិទ្ធិសេរីភាពគ្រប់គ្រាន់ដូចជា សម័យសង្គមរាស្ត្រនិយមដែលអ្នកនិពន្ធបានមើលឃើញដូច្នោះឯង។ វណ្ណកម្មមួយនេះលោកបានប្រារព្ធឡើង ក្នុងអំឡុងដែលលោកមានអាយុបាន៣០ឆ្នាំទៅហើយ អាចនិយាយបានថា លោកគឺជាមនុស្សដែលមានការចេះសង្កេត ចេះប្រៀបធៀបនិន្នាការនយោបាយច្បាស់បានច្បាស់លាស់ណាស់។

បើដូច្នេះ តើគេអាចចាត់ទុកលោកជាមនុស្សដែលមានឋានៈរបៀបណានៅក្នុងសង្គម?

តាមការសង្កេតមើលនៅក្នុងពាក្យឧទ្ទិស លោកប្រហែលជាមនុស្សដែលបានប្រសូតចេញពីត្រកូលកសិករ តែប្រហែលជាគ្រួសារមួយដែលមានជីវភាពថ្លៃថ្នូរមិនអត្តខាត់ទេ ហើយគ្រួសារនោះប្រហែលជាបានបណ្តុះលោកជាអ្នកដែលបានរៀនសូត្រជ្រៅជ្រះទៀតផង។

វណ្ណកម្មអក្សរសិល្ប៍ របស់លោកបន្សល់គឺមានតែមួយប៉ុណ្ណោះដែលអ្នកសិក្សាបានស្គាល់រួចមកហើយ។ ស្នាដៃនេះ ក៏បានជាប់ជាជ័យលាភីក្នុងការប្រឡងប្រជែង ពានរង្វាន់អក្សរសិល្ប៍ឥន្ទ្រទេវីលើកទី១ដែរបានន័យថា កិច្ចការតែងនិពន្ធរបស់លោកមានការចេះដឹងជ្រៅ ដោយលោកចេះរៀបចំឃុតឆាក បានច្បាស់លាស់មិនទាក់ទងសាំញ៉ាំគ្នា ចំណែកពាក្យពេចន៍ដែលបានប្រើនៅក្នុងវណ្ណកម្មនេះទៀតសោត ជាពាក្យថ្លៃថ្នូរទៅតាមកម្រិតនៃបរិយាកាសសង្គមរស់នៅ។

ស្នាដៃដ៏ល្អឯកមួយនេះ ត្រូវបានលោក **អ៊ូច ឯក** យកទៅបោះពុម្ពផ្សាយនៅឆ្នាំ១៩៦១ក្នុងឆ្នាំបន្ទាប់មក។

ខាងក្រោមនេះ ខ្ញុំនឹងលើកអត្ថបទរបស់លោកក្នុង**រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់** ដើម្បីបានជាកស្តុតាងបញ្ជាក់ថា លោកគឺជាអ្នកនិពន្ធមួយរូបដែលមានគំនិតជឿនលឿន ទស្សនៈជាតិនិយមស្រឡាញ់ ការរស់នៅក្នុងសង្គមដែលមិនមានការជិះជាន់គ្នាមានអធិប-តេយ្យម្ចាស់ការក្នុងជីវិតខ្លួនឯង ដោយលោកបានលើកយកសម័យសង្គមរាស្ត្រនិយមមួយ មកជាកស្តុតាងក្នុងវណ្ណកម្មរបស់លោក។សូមប្រិយមិត្តអញ្ជើញអានជាអត្ថបទសម្រង់ ដែលខ្ញុំលើកមកបង្ហាញដូចតទៅ៖

"...គ្រាន់តែមួយថ្ងៃ ដែលនាងបានចូលមកជ្រកនៅក្រោមដំបូលផ្ទះរបស់ថៅកែហុកនេះ នាងសយក៏នឹកតក់ស្លុតក្នុងចិត្តជាខ្លាំង...

ស្រីបម្រើច្រើននាក់បានខ្សិបខ្សៀវប្រាប់នាងថា ថៅកែហុកនេះជាមនុស្សខិលខូចនឹងស្រីញីណាស់ ព្រោះពួកស្រីបម្រើនៅក្នុងផ្ទះនេះច្រើនតែធ្លាក់ខ្លួន ទៅជាចំណីនៃសេចក្តីសប្បាយរបស់ថៅកែហុកស្ទើរតែទាំងអស់។

ក្នុងពេលដែលនាងសយ កំពុងតែរៀបចំបោសសម្អាតបន្ទប់តូចនៅខាងក្រោយ ជាបន្ទប់ដែលនាងត្រូវនៅនោះថៅកែហុកក៏បានចូលទៅជួបនឹងនាងតែពីរនាក់តទល់។ គាត់ចេះតែរំពៃសម្លឹងមើលនាងដោយការយកចិត្តទុកដាក់។ តែបើទុកជាថៅកែនេះញញឹមដាក់នាងយ៉ាងណាក៏ដោយ នាងសយក៏នៅតែនឹងតក់ស្លុតរន្ធត់ក្នុងចិត្តមិនតិចឡើយ ព្រោះនាងនឹកដល់សម្តីដែលស្រីបម្រើចាស់ៗនិយាយប្រាប់នាងកាលពីថ្ងៃ...

"សយ!" ថៅកែហុកនិយាយឡើងទាំងមុខញញឹម "សយឯងដូចជាមានស្នេហ៍នៅក្នុងខ្លួន ធ្វើឲ្យខ្ញុំនឹកអាណិតអាសូរជាខ្លាំង"

ក្នុងយប់នោះ... យប់ដែលនឹងត្រូវមកដល់មិនហួសពីរបីម៉ោងទៀតនោះ ថៅកែហុកមានគ្រោងការណ៍នឹងរំលោភលើរូបកាយនាងសយស្រីបម្រើគួរឲ្យអាណិត ដែលមានសភាពមិនខុសគ្នាពីពងមាន់នៅក្នុងក្រញាំដៃគាត់ឡើយ។

ម៉ោង២១ហើយ...ភ្លៀងធ្លាក់ជោគជាំ...

នាងសយកំពុងអង្គុយក្រៀមក្រំដោយការព្រួយបារម្ភ នៅក្នុងបន្ទប់ដេករបស់នាងតែម្នាក់ឯង... នាងកំពុងនឹកដល់ប្ដីសម្លាញ់នឹងកម្សត់កម្ររបស់នាង ហើយនាងក៏នឹកដល់សេចក្ដីអាភ័ព្វរបស់នាង...

ខណៈនោះ នាងសយឮសូរគោះទ្វារបន្ទប់ផ្ទួនៗគ្នាជាច្រើនដង។ នាងព្រឺក្បាលខ្លាក នឹកខ្លាចហេតុការណ៍ដែលនឹងត្រូវកើតឡើងដូចសម្ដីស្រីបម្រើចាស់ៗនិយាយប្រាប់នាងកាលពីថ្ងៃ...

"អ្នកណា ?" នាងស្រែកសួរដោយសំលេងតិចៗហើយញ័រ

"ខ្ញុំ!..."

នាងសយបុកពោះភឹប ព្រោះស្គាល់សំឡេងរបស់ថៅកែហុក។ នាងសន្សឹមៗ ក្រោកឡើងឈរមួយសន្ទុះហើយក៏កាត់ចិត្តដើរទៅបើកទ្វារ។ នាងគិតថា ប្រសិនបើថៅកែហុកប្រព្រឹត្តរំលោភមកលើរូបនាង នាងនឹងសំពះអង្វរករគេ ដើម្បីយោងខ្លួនឲ្យរួចផុតពីគ្រោះថ្នាក់នោះ។

លុះទ្វារបន្ទប់របើកឡើង នាងសយក៏បានជួបមុខនឹងថៅកែហុកក្នុងរយៈពេលដ៏ជិត។ "កំពុងធ្វើអីសយ ?" ថៅកែហុកសួរទៅនាងដោយទឹកមុខញញឹម។...

សមបានត្រលប់មកពីកន្ទេងនោះវិញ ហើយចេះតែដើរសោត់អណ្តែតទៅទៀតក្នុងឋានៈជាកម្មករ រកការងារធ្វើមិនបានម្នាក់ៗទីបំផុតការម្យ៉ាងដែលជាការពិតនោះគឺសម ត្រូវចាប់ផ្តើមអត់ការងារធ្វើទៀតហើយ...សមមិនមែនអត់អាហារដើម្បីធ្វើទុក្ខកិរិយាកម្ម ក្ងដកម្មដើម្បីទាមទារសិទ្ធិសេរីភាព អ្វីឡើយតែសមអត់អាហារព្រោះគ្មានអាហារបរិភោគៗ

ដូចជាសាកសព ដែលអាចកម្រើកខ្លួនបានសមចេះតែដើរសោត់អណ្តែតទៅដោយគ្មាន គោលបំណងឬទីដៅអ្វីឡើយ...សមមានទឹកមុខខ្មៅជាំខុសធម្មតា មានប្រស្រីក្អែកដែលគ្មានរស្មីនៃសេចក្តីរីករាយហើយមានម្ទៀកបំពាក់ និងខ្លួនប្រាណមិនខុសគ្នាពីស្នូមយាចក...តាំងពីថ្ងៃត្រង់ដល់ថ្ងៃរសៀល រហូតដល់ពេលល្ងាចសេចក្តីស្រេកឃ្លានបានធ្វើទុក្ខបុកម្នេញសមជាខ្លាំងៗ សមបានផឹកតែទឹកម៉ាស៊ីននៅចិញ្ចើមថ្នល់ដើម្បីផ្សើមបំពង់កប៉ុណ្ណោះៗ សមដូចជាស្រយុតស្រយ៉ង់ ពេយស្រពោនទន់អស់ទាំងពងកាយៗ

ហើយក្នុងវេលាប្រហែលជាម៉ោង១៧កន្លះ សមក៏បានជួបប្រទះនឹងឧបទ្វហេតុ ដែលគួរឲ្យព្រឺខ្លួនក្នុងខណៈដែលបានឆ្លងកាត់វិថីដោយអារម្មណ៍អណ្តែតអណ្តូង ហើយមិនបានឃើញរថយន្តមួយដែលលូនចូលមកក្នុងរយៈដ៏ជិត អ្នកបើកបរខំទប់ហ្វ្រាំងបញ្ឈប់រថយន្តនោះ ក៏បុកកម្មករពោះម៉ាយ ដែលគួរឲ្យអាណិតនោះដួលដេកនៅលើវិថីនាកណ្តាល សំឡេងស្រែកភ្ញាត់មាត់ភ្ញាត់ករបស់ស្រីៗ២ ៣នាក់ដែលបានឃើញហេតុការណ៍ដ៏គួរឲ្យខ្លាចនោះៗ

គ្រោះថ្នាក់បែបនេះ រាប់ថាជាគ្រោះអាក្រក់សម្រាប់អ្នកមានតែវា ជាគ្រោះល្អសម្រាប់អ្នកក្រដូចជារូបសម ព្រោះគ្រោះថ្នាក់នេះជាហេតុធ្វើឲ្យសមមានការដើរធ្វើៗ សុភាពបុរសកម្ពោះម្នាក់ ដែលអង្គុយនៅលើរថយន្តខាងក្រោយនោះជារដ្ឋមន្ត្រីនៃក្រសួងមួយ ដែលលោកទើបតែនឹងត្រលប់មកពីប្រទេសបារាំងកាលពីឆ្នាំទៅ ហើយលោកទើបនឹងត្រូវជ្រើសតាំងជារដ្ឋមន្ត្រីកាលពីប៉ុន្មានខែមុននេះៗ ដោយសារការភ័យខ្លាចនឹងអាណិតអាសូរ លោករដ្ឋមន្ត្រីកម្ពោះក៏បើកទ្វាររថយន្តចុះទៅមើលភ្លាមៗ

ខណៈនោះអ្នកបើករថយន្ត ស្ទុះចូលទៅត្រកងលើកសមឡើងៗ តែគ្រោះថ្នាក់នេះក៏មិនជាធ្ងន់អីប៉ុន្មាន គឺគ្រាន់តែបែកក្បាលជង្គង់ និងត្រេចកជើងខាងស្តាំប៉ុណ្ណោះៗ លោករដ្ឋមន្ត្រីជួយលើកសម ហើយពិនិត្យមើលដោយក្រសែភ្នែក ដែលសម្តែងនូវសេចក្តីអាណិតអាសូរ...»

## ៤ លោកអ៊ុម ជុក

លោកមានស្រុកកំណើតនៅឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបងៗ លោកគឺជាអតីតចាងហ្វាងកាសែតវត្តភ្នំៗ លោកគឺជាអ្នកនិពន្ធដែលមានគំនិតជឿនលឿន ម្នាក់ដែលបានសរសេរបង្ហាញប្រាប់ពីសេចក្តីត្រូវការរបស់សង្គម រស់នៅរបស់ប្រជាជននាសម័យមួយធ្មុះបញ្ចាំងមកសម័យមួយទៀតៗ នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ បានប្រារព្ធស្នាដៃចំនួនបីដែលយើងបានស្គាល់មានដូចជា៖

-រឿងគូលីកំណែន ឆ្នាំ១៩៥៦

-រឿងស៊ីមអ្នកបរឡាន ឆ្នាំ១៩៥៧

-រឿងគ្រូបង្រៀនស្រុកស្រែ ឆ្នាំ១៩៥៧

ខាងក្រោមគឺជាអត្ថបទរឿងគ្រូបង្រៀនស្រុកស្រែ ដែលជាស្នាដៃរបស់លោកអ៊ឹម ថុកបានសរសេរឡើង ហើយរឿងនេះ ត្រូវបានបោះពុម្ពផ្សាយនៅអំឡុងខែកុម្ភៈ ឆ្នាំ១៩៥៧បន្ទាប់ពីរឿងគូលីកំណែន។ តាមការបញ្ជាក់របស់គណៈកម្មការអក្សរសិល្ប៍ និងភាសាឆ្នាំ១៩៨៣ បានបង្ហាញថា រឿងនេះគឺជាគំនិតបំផុសការតស៊ូនយោបាយដែលមានលក្ខណៈជ្រៅជ្រះ។ អ្នកនិពន្ធបានរៀបរាប់ពីចលនាឃោសនាផ្សព្វផ្សាយគំនិតប្រជាធិបតេយ្យតាមរយៈខិតប័ណ្ណបដា ឬការជេជែកគ្នារបស់តួអង្គ។

ដូចនេះ ខ្ញុំនឹងលើកអត្ថបទរឿងនេះជាលក្ខណៈសម្រង់មកបង្ហាញជូនមិត្តអ្នកអានដូចខាងក្រោម៖

"...ម៉េចហើយឡឹងមានផ្លូវទេ ភូមិឬស្សីបងប្អូនយើងសុខសប្បាយទេ?

-សុខតែមិនសប្បាយទេ ដូចលោកបងឃើញហើយគ្នាក្រណាស់សព្វថ្ងៃនេះគ្មានបាយសុទ្ធស៊ីទេ គ្នាស៊ីបាយលាយពោត។

-ភូមិឬស្សីបានបើកភ្នែកខ្ញុំឲ្យឃើញទុក្ខវេទនាពស្ត្រ ម៉ៅស្រឡាញ់អ្នកភូមិនេះណាស់។

-អើម៉េចទៅលោកគ្រូម៉ៅ "ឡឹងបានសួរ" ខ្ញុំឮគេចាប់គាត់ខ្ញុំញ័រខ្លួនអាណិតគាត់ជាពន់ពេក គេមានវាយដាក់ខ្នោះទេ...?

-ខ្ញុំមិនសូវបានដឹងដែររឿងនេះ ព្រោះខ្ញុំបានឈប់ជួបគាត់ជិតមួយខែ តាំងពីពេលក្រោយពីពេលក្រោយត្រលប់ពីភូមិនេះទៅ...។ បានដំណឹងថាសព្វថ្ងៃគាត់ជាប់គុកនៅកំពង់...។

-នេះបានចំ ខ្ញុំចូលចិត្តគាត់ណាស់ អ្នកភូមិឬស្សីសរសើរគាត់គ្រប់មាត់។

អាចារ្យសមបានកាត់៖

-មើលហាមឯងបាននិយាយថា ភូមិឫស្សីបានបើកភ្នែកខ្លួនតើមានអ្វីខ្លះ? ខ្ញុំនៅជិតភូមិនេះដែរតែដូចជាមិនឃើញមានអ្វីខុសគេ?

-លោកបងអាចារ្យមិនដែលបានទៅបានជាអីចឹង។ កាលពីខែមុនខ្ញុំនិងប្អូនម៉ៅ ព្រមទាំងគ្រូៗបួនប្រាំនាក់ជិះកង់លើភ្លឺទៅភូមិនោះ។ អ្នកស្រុកក្រហៅមហាក្រ បានទទួលយើងដូចស្គាល់គ្នាប៉ុន្មានឆ្នាំហើយអីចឹង។ គេនិយាយប្រាប់យើងគ្រប់។គេមិនដែលស្គាល់នាម៉ឺនមកភូមិនេះទេ។ រាល់ឆ្នាំគេមានរឿងតែជាមួយមេសែរៀនបឹង។ បងអាចារ្យដឹងទេ មេសែរៀនបឹងបានចាត់អ្នកលេងប៉ាវ ឲ្យមកលើក មកកាប់ទ្រូ កាប់លបអ្នកស្រុក។ ចៅកែបឹងមានអ្នកលេងកាប់ៗចាក់ៗសំឡុតអ្នកស្រុកដែលដាក់ទ្រូ ដាក់លបបន្តិចបន្តួចគ្រាន់នឹងចិញ្ចឹមឆ្នាំង។ ចៅកែបឹងរំលោភអស្ចារ្យហើយ គេបានប្រកាន់ថា បឹងគេមានព្រំត្រឹមត្រូវ ទឹកឡើងរហូតដល់រហូតដល់មាត់ភូមិក្នុងស្រែ អ្នកស្រុក...។ រាល់ឆ្នាំអ្នកភូមិត្រូវមេសែរៀនធ្វើបាប ហើយអ្នកលេងបឹងនោះកាចសាហាវ មានអំណាចអស្ចារ្យគេអាច សម្លាប់អ្នកភូមិបានគ្មានទោស។ គេបង្វែងដានបានទាំងអស់។ ចៅកែគេបានស្គាល់អស់លោកនាម៉ឺននៅខេត្តស្រុកស្រេច។

-ខ្ញុំគ្មានដឹងសោះ "អាចារ្យសមលាន់មាត់"...

...........

-ការដោះទុក្ខកែប្រែការរស់នៅ របស់ប្រជាជនយើងគ្រប់គ្នាជាការពិបាក ជាការយូរមិនឆាប់ដូចមាត់ទេ។ ព្រោះមនុស្សធ្វើមិនមែនទេវតាឯណាធ្វើជួសយើង...។ យើងត្រូវអប់រំខ្លួនយើង និងអប់រំកែប្រែអ្នកភូមិឲ្យយល់ ជឿលើកម្លាំងខ្លួន ហើយឲ្យដឹងថា ទាល់តែយើងរួមកម្លាំងសាមគ្គីគ្នា បានយើងអាចនឹងទប់ទល់នឹងអ្នកលេងដៃជើងចៅកែសែរៀន

បាន។ នៅស្រុកស្រែជាមួយយើង វាអាងអ្នកលេង នៅទីក្រុងវាអាងនឹងទឹកប្រាក់...។ បើដូចនេះ បើចង់រួចខ្លួនចង់បានស្រួល ចង់បានយុត្តិធម៌ ទាល់តែអ្នកភូមិនេះចេះបង្រះកែប្រែខ្លួនឡើង។ ការរៀបចំភូមិឃុំ ជាការចាំបាច់មុនគេបង្អស់ចំពោះក្រុមយើង។ដោយហេតុនេះ បានជាខ្ញុំយល់ឃើញថា ដល់រួចរាល់ឆ្នាំក្រោយៗនេះ យើងត្រូវតែឲ្យមានសិទ្ធិប្រជាជនបោះរើសនាយកឃុំ ហើយមានការៈកែប្រែអ្នកភូមិឃុំយើង មិនមែនជាការៈតែដើរជិះជាន់សង្កត់សង្កិនរាស្ត្រ ដូចអាណានិគមបារាំងបង្កបង្កើតនោះទេ។ នាយកឃុំយើង ជាតំណាងប្រជាជននៅឃុំ ហើយមានការៈកែប្រែអ្នកភូមិពីក្តីវេទនាគ្មានអាវពាក់ អំពើចោរកម្ម ពីការគម្រាមកំហែង។ យើងត្រូវមានគ្រោងការណ៍ដូចតទៅ៖

១ ខាងនយោបាយការពារ និងពង្រីកសិទ្ធិសេរីភាព លទ្ធិប្រជាធិបតេយ្យជាក់ស្តែងពិតៗឲ្យប្រជាជនអ្នកស្រែ មានអំណាចបោះឆ្នោតជ្រើសរើសរបៀបគ្រប់គ្រងឃុំភូមិរបស់ខ្លួន។

២ ខាងសេដ្ឋកិច្ច បង្កើតផ្នែកសហករណ៍ ឬសមាគមកសិករនៅក្នុងភូមិ ឃុំការពារផលដំណាំ ពោត ស្រូវ ស្ករ កុំឲ្យពួកចៅកែហាងឆេងមកវាយបន្ថោកយកចំណេញកប់ក្តោងដូចសព្វថ្ងៃ។ ម្យ៉ាងទៀតខាងបឹងព្រៃវិញ ប្រមូលប្រជាជនធ្វើសមាគមការពារផលធម្មជាតិទាំងនោះ ទុកចែកសម្រាប់គ្រប់គ្នា មិនឲ្យមេសៃរៀនក្តាប់ចំណេញរាប់សែនយកទៅជូលអ្នកលេងឲ្យមកធ្វើបាបអ្នកភូមិដូចសព្វថ្ងៃនេះទេ...។

៣ ខាងសង្គមកិច្ច ចាត់តាំងឲ្យមានផ្នែកសមាគមនារី សមាគមយុវជន សមាគមអ្នកស្រែចម្ការ បង្កើតផ្ទះពេទ្យ...។

៤ ខាងវប្បធម៌ ពង្រីកនិងបង្កើតសាលារៀននៅគ្រប់ភូមិ គ្រប់វត្ត

ឲ្យមានចំនួនគ្រប់គ្រាន់ ដើម្បីគ្រប់ក្មេងបានចូលរៀនសូត្រ។បង្កើតសាលារៀនមនុស្សចាស់ ប្រុស ស្រីមិនចេះអក្សរ...ឧបត្ថម្ភគ្រូបង្រៀនឲ្យជួយរៀបចំដាក់កម្មវិធីសិក្សារបៀបប្រជាធិបតេយ្យពិតប្រាកដ។ បង្កើតបណ្ណាល័យទិញសៀវភៅឲ្យប្រជាជនខ្ញុំមើលខ្ញុំសិក្សា...”។

## ៦ លោក ឡឿក អំ លោកឌឹក គាម

លោកឡឿក អំ ប្រសូតនៅឆ្នាំ១៩៣៤ នៅស្រុកមោងឫស្សីខេត្តបាត់ដំបង។ លោកធ្លាប់បានបួសរៀននៅពុទ្ធកមហាវិទ្យាល័យភ្នំពេញ ។ លោកក៏ធ្លាប់បានសិក្សា នៅមហាវិទ្យាល័យអក្សរសាស្ត្រមនុស្សសាស្ត្រព្រមតាំងបានចេះភាសាបារាំង និងភាសាអង់គ្លេសយ៉ាងស្ទាត់ជំនាញទៀតផង។នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ គេឃើញលោកបានសរសេរស្នាដៃចុះផ្សាយនៅទស្សនាវដ្ដីកង៍ទ័ព បន្តមកមានរឿងភូមិតិរច្ឆានដែលត្រូវបានក្រសួងដាក់បញ្ចូលក្នុងកម្មវិធីសិក្សានេះ។

លោក ឌឹក គាម ប្រសូតនៅថ្ងៃទី០៥ ខែមករាឆ្នាំ១៩៣៦នៅខេត្តក្រចេះ។

លោក គឺជាមនុស្សមួយរូបដែលស្រឡាញ់ការសិក្សាណាស់ប្រឹងប្រែងសិក្សារហូត ដល់មានការងារធ្វើនៅពុទ្ធសាសនបណ្ឌិត្យផ្នែកស្រាវជ្រាវ។ នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ខ្មែរវិញ លោកបានបន្សល់ស្នាដៃសំខាន់ដូចជា៖

-រឿងមកបង់ទៅផ្ទះ ឆ្នាំ១៩៥៦

-រឿងព្រះនាងឥន្ទ្រទេវី

-រឿងចៅពញាហុក

-រឿងភូមិតិរច្ឆាន ឆ្នាំ១៩៦៥

-អក្ខរានុក្រម វេវចនស័ព្ទខ្មែរ ឆ្នាំ១៩៦៥

-វេយ្យាករណ៍ដោយរូបភាព

ខាងក្រោមនេះ ខ្ញុំនឹងស្រង់អត្ថបទសម្រង់នៅក្នុងរឿងភូមិ-តិរច្ឆាន ដែលជាវណ្ណកម្មមួយរបស់លោកអ្នកនិពន្ធទាំងពីរមកបង្ហាញជូនមិត្តអ្នកអានដើម្បីធ្វើការសិក្សាស្វែងយល់។

មុនដកស្រង់រឿងនេះ ខ្ញុំសូមធ្វើការបង្ហាញជូនអ្នកអានពីមូលហេតុដែលនាំឲ្យអ្នកនិពន្ធបានចងក្រងអត្ថបទនេះឡើង។ រឿងនេះគឺជាវណ្ណកម្ម ជាលក្ខណៈប្រវត្តិសាស្ត្រដែលរំឭកពីអនុស្សាវរីយ៍ដ៏ជូរចត់មួយបានបន្សល់ទុកពីសម័យអាណានិគមនិយមបារាំង។

ព្រឹត្តិការណ៍១៨ ខែមេសា ឆ្នាំ១៩២៥ គឺជាព្រឹត្តិការណ៍ពិតជាព្រឹត្តិការណ៍ដែលប្រជាជនខ្មែរហ៊ានបូជាសាច់ស្រស់ ឈាមស្រស់ដើម្បីវាយបំបាក់ដៃជើង របស់បរទេសដែលមានមហិច្ឆតាគាបសង្កត់ពស្ត្រខ្មែរ ពិសេសគឺនឹមដែករបស់ពួកគេ ត្រូវបានពស្ត្រខ្មែរវាយបំបាក់ប្រកបដោយឧត្តមគតិជាតិ។

ជាការពិតរឿងនេះ គឺអត្ថបទដែលបានវែកមុខពួកចោរប្លន់ទឹកដីប្លន់សិទ្ធសេរីភាពប្រជាជន ហើយក៏បានបកអាក្រាតពីមុខមាត់របស់ពួកមន្ត្រីខ្មែរ មួយចំនួនដែលបិទភ្នែកជាមួយម្ចាស់អាណានិគមរួចមកធ្វើបាបប្រទេសឯង ប្រជាជនឯងដោយមិនខ្លាចព្រលឹងបុព្វបុរសដាក់បណ្តាសា។

ដើម្បីឲ្យបានជ្រាបច្បាស់ សូមមិត្តអ្នកអាន អញ្ជើញអាននូវសម្រង់អត្ថបទនេះជាមួយនឹងយើងខ្ញុំដូចតទៅះ

"...ក្រោយដែលបានទទួលដំណឹងថា ប្ដីរបស់ខ្លួនជាប់ខ្នោះបារាំងទៅហើយ នាងនីក្ដី នាងប៊ីក្ដីមានការរំភើបចិត្តជាពន្លឹក។ នាងទាំងពីរនេះ

បានទូលបាយរៀងៗខ្លួនទៅសាលាឃុំដើម្បីយកទៅឲ្យប្ដីបរិភោគ។ ប៉ុន្តែនៅពេលដែលនាងទាំងពីរនេះទៅដល់មាត់ជណ្ដើរសាលាឃុំ ក៏ត្រូវកងរក្សា ស្រុកដែលកាន់កាំភ្លើងមួយដើមឈរយាមនៅទីនោះហាមឃាត់មិនឲ្យឡើងជាហេតុនាំឲ្យនាងនីក្ដៅស្ទើកត្រចៀកមួយរំពេច ទើបសួរដោយភាពទន់ភ្លន់៖

-ហេតុអ្វីបានជាខ្ញុំសុំឡើងមួយភ្លែតមិនបានលោកជី?

-ព្រោះមានបញ្ជាពីលោកធំ!

ស្រីម្នាក់ទៀតដែលប្រុងឡើងយកបាយទៅឲ្យប្ដីដែរ (គឺនាងប៊ី) ក៏សួរបន្ថែម៖

-លោកបង្គាប់ដូចនេះមែនឬ?

-បាទ!

លុះជជែកចុះជជែកឡើងតឹងសរសៃករៀងខ្លួន ក៏ឮដល់លោករ៉េស៊ីដង់ៗ សាកសួរចៅស្មៀនៗក៏បកប្រែឲ្យលោកស្ដាប់ដឹងរឿងភ្លាមមួយរំពេច ទើបលោករ៉េស៊ីដង់ស្រែកសួរឡូលេៗ ស្ទើរលៀនអណ្ដាតជាភាសាបារាំង ដែលចៅស្មៀនប្រែមកបានសេចក្ដីថា៖

-នាងឯងមានជាប់ប្រាក់មកផងទេ? បើមានប្រាក់យកមកបង់ពន្ធ ទើបយើងអនុញ្ញាតឲ្យជួបប្ដីនាងបាន!

ពេលនោះនាងនី និងនាងប៊ីឆ្លើយតបទៅវិញយ៉ាងសមរម្យរាបសារថា៖

-លោកជីអើយ បើយើងខ្ញុំបានប្រាក់យើងខ្ញុំពុំមែនបណ្ដោយឲ្យប្ដីនៅជាប់ខ្នោះមួយកំណាត់ថ្ងៃដូចនេះទេ។ ឥឡូវយើងខ្ញុំពុំមែនសុំឲ្យលោកដោះលែងប្ដីយើងខ្ញុំទេ គឺយើងខ្ញុំគ្រាន់តែខ្ញុំអនុញ្ញាតយកបាយឲ្យប្ដីទទួលទានទេតើ ម្ដេចក៏លោកតឹងតែងដាច់មេត្តាខ្លាំងម្ល៉េះ!

លោកប៉េស៊ីដង់ធ្វើក្បាលងឺងើៗ សម្លក់សម្លឹងចុះឡើង លុះចីសួនប្រែជាភាសាបារាំងឲ្យស្ដាប់ ក៏ស្រាប់តែក្ដីឈ្លួលចុងច្រមុះ ខឹងច្រឡោតតោតតូងមួយរំពេច ទើបបញ្ជាឲ្យចាប់ស្ត្រីមាត់រឹងទាំងពីរនាក់ទៅដាក់ខ្នោះជាបន្ទាន់ ប៉ុន្តែនាងទាំងពីរពុំព្រមឲ្យចាប់ រួចពោលសងទៅបារាំងវិញ៖

-នៃលោកធំ! លោកប្រើអំណាចមកលើខ្ញុំ និងជាតិខ្ញុំជ្រុលហួសហើយៗ លោកដាក់ខ្នោះប្ដីខ្ញុំ មិនទាន់ស្កប់ចិត្ត ឥឡូវលោកគិតដាក់ខ្នោះប្រពន្ធទៀត...ៗ

ពេលនេះ ក្រុមអ្នកក្លាហានកាន់តែសរសៀរមកកៀកនាងនីនិងនាងប៊ីៗ ឯអ្នកដទៃទៀត ក៏ចេះតែចូលមកជិតយ៉ាងពពាក់ពពូនហើយម្នាក់ៗហាក់ដូចជាកាន់តែកាន់ជើងនាងទាំងពីរនេះៗ

ទើបនាងនីបន្តទៅទៀតថា៖

-លោកធ្វើចៅហ្វាយលើខ្មែរ លោកមើលឃើញត្រឹមតែប្រាក់មួយមុខប៉ុណ្ណោះ ចង់ខ្មែរធ្វើស្រែមិនបាន ចង់ខ្មែរដាច់ពោះស្លាប់ លោកឥតឈឺក្បាលអ្វីទេ លោកគិតតែពីសង្កើញទារពន្ធអោយខាងតែបានៗ នេះ រឺដែលហៅអ្នកអាណាព្យាបាល?

នៅពេលនោះលោកប៉េស៊ីដង់ក៏បញ្ជាក់ថា បើនរណាមានលុយយកមកបង់ពន្ធនឹងលែងប្ដីភ្លាមៗ

នាងប៊ីពេលនោះមានលុយ តែមិនទាន់បង់ភ្លាមទេ ព្រោះនាងនីមិនមានលុយៗ បើបង់ទៅក្រែងបានតែប្ដីមក មិនបានប្ដីនាងនី ម្ល៉ោះហើយបានជាខំអង្វរបារាំងៗ ដល់អង្វរមិនបានការហើយត្អូញបារាំងថា ដូចនោះទើបសំរេចចិត្តយកលុយបង់មុននាងនីៗ នាងប៊ីបង់លុយហើយ មិនឃើញគេដោះលែងប្ដីនាង នាងក៏សួរថា

ម៉េចលោកថា បើមានលុយបង់ពន្ធលោកឲ្យរួចពីការឃុំឃាំង។ ឥឡូវខ្ញុំបង់លុយម៉េចបានជាលោកមិនលែងប្តីខ្ញុំមក?

លែងមិនបានទេ ទាល់តែអ្នកដទៃទៀតយកលុយមកបង់គ្រប់សិន ទើបដោះលែងជាមួយគ្នាតែម្តង។

ពួកអ្នកស្តាប់ទាំងប៉ុន្មាននៅដី ដែលឃ្វានបាយឡើងមុខស្លូតរៀងខ្លួន លុះដល់ឮនាងប៊ីនិយាយបែបត្រូវចិត្ត ក៏តាំងញញឹមញញែមតែមិនហ៊ានសើចហ៊ោទេ ព្រោះនៅញញើតលោករ៉េសីដង់នៅឡើយ។ បន្ទាប់មកនាងប៊ីនិយាយសឹកអោយបារាំងម្តងវិញ

យើសលោកបារាំង! លោកអែងអាងសាសន៍លោកត្រួតលើក្បាលខ្មែរ លោកចង់ជាន់លើខ្មែរស្មើរម៉ាន បានស្មើណោះឬ? តើលោកទុកខ្មែរជាមនុស្សម្នាដូចលោកដែរ រឺមួយជាសំរាមសំរោចមិនស្មើនឹងបាតជើងលោកទេ?

ពេលនោះ លោករេសីដង់ប្រឹងជំទែងស្រែកសួរថៅបកឈ្មោះសួនដែលនៅជិតបង្កើយនិងលោកសោះ ឮសួរសំលេងឡូលៗយ៉ាងគ្រលរនិងញាប់រន្ថើន ព្រោះចង់ដឹងអំពីសំដីនៃស្ត្រីទាំងពីរនាក់នោះខ្លាំងពេក។ លុះថៅសួនប្រែឲ្យ ស្តាប់យល់អត្ថន័យហើយគាត់ក្តៅក្រហាយចំពោះនាងមាត់រឹងទាំងពីរនាក់ឥតឧបមា ទើបបញ្ជាឲ្យចាប់យកទៅដាក់ខ្នោះជាប្រញាប់។

ប៉ុន្តែនាងនីក្តី នាងប៊ីក្តីហាក់ដូចជាមានគំនិតត្រូវគ្នា គឺមិនបណ្តោយឲ្យនរណា ចូលមកចាប់បានដោយងាយៗឡើយ។ដោយពិនិត្យឃើញថា ស្ត្រីទាំងពីរនាក់នេះសែនមហារឹងរូស រកអ្នកណាប្រដូចពុំបានគ្មានញញើតកោតខ្លាចអំណាចលោកសោះ ទើបលោករ៉េសីដង់បង្គាប់ទៅកងរក្សាស្រុកឲ្យបាញ់នាងនី និងនាងប៊ីជាបន្ទាន់ ដើម្បីផ្តាច់

ជីវិត ក្នុងពេលនោះតែម្តងទៅសោះនឹងនៅតវ៉ាប្រឆាំងប្រជែងនាំអំពល់គេឯង...។

## ៧ លោកគុយ ធុត

លោកប្រសូតនៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៤០ នៅសង្កាត់ស្វាយ-គង់ ស្រុកកងមាស ខេត្តកំពង់ចាម។ បិតាលោកនាម គុយ ទូនមាតានាម អ៊ូ ទូច។

លោកក៏ជាអ្នកដែលមាននិស្ស័យ ស្រឡាញ់វិស័យអក្សរសាស្ត្រមួយរូបដែរ ដោយគេបានរកឃើញស្នាដៃរបស់លោកមួយចំនួនដែលបានបោះពុម្ពផ្សាយមានដូចជា៖

-រឿងសែនកំសត់ ជាប់លើកទឹកចិត្តរង្វាន់ឥន្ទ្រទេវីលើកទី១

-រឿងដែនដួងចិត្ត ឆ្នាំ១៩៦៣

-រឿងពេជ្រមួយត្រួយពីរ ឆ្នាំ១៩៦៧

-រឿងព្រះបាទពញ្ញាយ៉ាត ឆ្នាំ១៩៦៦

ជាបន្តទៅទៀត ខ្ញុំសូមនាំអារម្មណ៍មិត្តអ្នកអានមកមើលទឹកដៃរបស់លោកអ្នកនិពន្ធមួយរូបនេះ ក្នុង**រឿងព្រះបាទពញ្ញាយ៉ាត** ដែលជាប្រលោមលោកលំនាំប្រវត្តិសាស្ត្រជាលក្ខណៈសម្រង់ដូចតទៅ៖

...ស្តេចសៀម និងព្រះរាជបុត្រចាត់ទ័ពឲ្យវាយលុកសម្រុកចូលប្រទេសនេះ ដោយឥតប្រកាសរាស្ត្រទាសក័យឡើនឡង់បោះបង់លំនៅឋាន ផ្ញើប្រាណនឹងព្រៃ ខ្លះរត់រួចរហូតក៏ស្រូតមកកាន់មហានគរ ឲ្យព័ត៌មានដល់មន្ត្រីកងទ័ព។ សម្តេចជហ្វាទឡ្ហៈសួសបានដំណឹង មិនបង្អង់ក៏

ចូលក្រាបទូលព្រះបរមពិត្រ។ ព្រះបរមសោករាជព្រះចៅក្រុងកម្ពុជា កាលបើទ្រង់ជ្រាបថា សៀមចូលមកពាធាស្តេចក៏បញ្ជាឲ្យមេទ័ព ធំ តូច ទាំងឡាយ ប្រញាប់ចាត់ការចេញកម្ចាត់បច្ចាមិត្ត។ រាល់គ្នាក្រាបហ្មប ហ្មាយ ថ្វាយជីវិតជួយយកអសាផែនដីចាប់អាវុធគ្រប់គ្នាចេញការពារ ប្រទេសយ៉ាងក្លាហាន។ ប៉ុន្តែខាងសៀមមានគ្នាសម្រាំងៗជាច្រើន ក៏វាយ ផ្ចាញទ័ពយើង ជ្រុលបន្តិចម្តងៗមកជិតដល់ព្រះរាជធានី។ ទ័ពខ្មែរកាប់ សម្លាប់តទល់យ៉ាងណាបច្ចាមិត្តនៅតែរំកិលចូលមកបានជាលំដាប់ វាប្រ ថុយស្លាប់ឲ្យតែបានឈ្នះខ្មែរ។

នោះទើបសម្តេច ព្រះបរមសោកទ្រង់ប្រោរព្ធរក្សាទិសរាជធានី ទ្រង់ចាត់ពញាកែវបុត្រច្បងឲ្យថែទិសខាងលិច ចាត់ពញានៃបុត្រពៅឲ្យ កាន់ទ័ពខាងជើង ព្រះពញាយ៉ាតជាអនុជទៅទិសខាងត្បូង សម្តេចជហ្វា ទឡ្ហៈសួស នៅទិសខាងកើត។ ទ្រង់បញ្ជាឲ្យយកកាំភ្លើង ធំដាក់គ្រប់ជ្រុង កំពែងនគរទាំងអស់។ ទ័ពសៀមមិនស្មៀមបានមកជិត កាំភ្លើងខ្មែរក៏ផ្ទុះ ឡើងបំបើុងជីវិតវាឲ្យថយទៅវិញបានយ៉ាងជោគជ័យ។ ព្រះចៅបរមរា ជាស្តេចសៀម ទ្រង់វាយទម្លាយមហានគរពុំបែក ស្តេចមានទោមនស្ស ណាស់ ទើបទ្រង់ថយទៅវិញ ប៉ុន្តែឲ្យកងទ័ពព័ទ្ធមហាធានីនេះឲ្យជាប់ រួចទ្រង់បញ្ជាឲ្យលើកដីជុំវិញ មហានគរឲ្យមានកម្ពស់ស្មើនឹងកំពែង មហានគរដែរ។ ស្តេចឲ្យយកកាំភ្លើងធំៗមកដាក់លើដី លើកនោះទល់ មុខមករកកាំភ្លើងខ្មែរ។ ការបាញ់គ្នាដោយកាំភ្លើង ក៏ផ្តើមឡើងលាន់ ទ្រហឹង ផ្សែងក៏ខ្ពុរឡើង បីដូចគេបាចសាចពពកមកលើផែនដី។ ជាមួយ ស្នូរកាំភ្លើង ផ្ទៃព្រួញបានហើរទៅវិញទៅមក។

ការច្បាំងគ្នារវាងសៀមនិងខ្មែរនេះ បានប្រព្រឹត្តទៅអស់រយៈ ពេល៧ខែ។ សៀមស្លាប់ដូចគេហាល ស្រាលសេចក្តីក្លាហានជាលំដាប់

ប្រញាប់ថយខ្លួនពួនរកឧបាយកលជាថ្មីវិញ។...

កាលដែលដឹងថា សៀមវាយមហានគរនោះ គាត់ក៏បានប្រមូលទ័ពបានចំនួន៣០០នាក់ ហើយថ្ងៃនេះ គាត់ប្រារព្ធលើកទ័ពទៅមហានគរដើម្បីរួមកម្លាំងនឹងព្រះមហាក្សត្រកម្ចាត់សៀម។

ដោយខ្យល់រលកពុំទាន់ស្ងប់ កងទ័ពក៏ពុំទាន់ឆ្លងទៅត្រើយម្ខាងដែរ គេនៅកុះកុំផ្តុំគ្នាលើគោកមីរដេរដាស។

ឥឡូវនេះមេឃស្ងប់ខ្យល់ ទន្លេស្ងប់រលកបន្តិចហើយ កងទ័ពអាចឆ្លងទៅត្រើយម្ខាងបានដោយឥតគ្រោះថ្នាក់ ក៏នាំគ្នាចុះទូកចាប់ចែវចាប់ច្រវ៉ានឹងអុំឆ្លង។

ពេលនោះនៅកណ្តាលទន្លេ មានទូកក្តោងតូចមួយកំពុងសម្តៅមក លោកអភិបាលខេត្តសង្កេតដោយឆ្ងល់ ទូកនរណាអេះ?គេប្រុងមករកអញឬ? ឬទូកចោរខ្មាំងទេ? លោកផ្អាកដំណើរចាំមើល។

ភ្លាមនោះ ទូកក្តោងដែលត្រូវខ្យល់បក់បន្ទំមកផង ក៏នាំមនុស្សចំនួន៥នាក់ចូលមកដល់ ហើយទល់នឹងទូកក្តោងអភិបាលខេត្ត។ ទាំងប្រាំនាក់នោះ យើងក៏បានស្គាល់ បីនាក់គឺសម្តេចជហ្វាទឡ្ហសួស ព្រះអង្គម្ចាស់ពញាយ៉ាត នាយជំនិត ឯពីរនាក់ទៀតគឺជាម្ចាស់ទូក។

ម្តៃថ្ងៃក្រោយមក លោកឧកញ៉ាកែបិតានាងកល្យាណបាននាំទ័ពត្រលប់ចូលមកទីក្រុងវិញ ដោយនាំទាំងសេនាសៀម៥នាក់ចូលមកផង។

ព្រះអង្គម្ចាស់និងមេទ័ពទាំងអស់គ្នា ស្មានតែមានការប្រកាសចម្បាំងនិងសៀមទៀតហើយ ក៏ប៉ុន្តែតាមការពិត ឧកញ៉ាកែទូលថា ព្រះបរមជាព្រះចៅសៀម បានចាត់សារមកថ្វាយព្រះអង្គម្ចាស់សុំសពព្រះឥន្ទរាជាទៅវិញ។

លោកឧកញ៉ាកែអានចុតហ្មាយនោះមានសេចក្ដីថា៖

"យើងព្រះបរមរាជាព្រះចៅសៀម សោយរាជនៅអយុធ្យាមហាធានី សូមចម្រើនមេត្រីចំពោះព្រះអង្គម្ចាស់ខ្មែរដ៏មានជ័យជម្នះ។

យើងបានដឹងថាទ័ពរបស់យើងដែលនៅមហានគរ បានទទួលបរាជ័យទៅហើយ ឯព្រះរាជបុត្របណ្ដូលបណ្ដាច់របស់យើងក៏ត្រូវសុគតទៅទៀត គួរឲ្យយើងឈឺចាប់ណាស់ ! ក៏ប៉ុន្តែយើងពុំមានប្រាថ្នានឹងបន្តកលិយុគតទៅទៀតទេ យើងជឿជាក់លើកម្លាំងអានុភាពរបស់ព្រះអង្គម្ចាស់ហើយ!

ដូច្នេះខណៈនេះ យើងសូមព្រះអង្គម្ចាស់មេត្តាអនុញ្ញាតឲ្យសេនាមាត្រយើងទាំង៥នាក់នេះ នាំសពព្រះឥន្ទរាជាបុត្រាយើងត្រលប់ទៅអយុធ្យាវិញគ្រាន់នឹងបានធ្វើបុណ្យទានតាមគន្លង។

យើងសង្ឃឹមថា ព្រះអង្គម្ចាស់មុខជានឹងទទួលយល់ព្រមតាមសេចក្ដីសុំនេះពុំខាន។

ជាទីបញ្ចប់ យើងសូមគោរពបូរណភាព និងឥស្សរភាពនៃប្រទេសកម្ពុជារបស់ព្រះអង្គម្ចាស់ហើយ។

ព្រះហស្តលេខា

ព្រះបរមរាជាព្រះចៅសៀម

ក្រៅពីបណ្ដាអ្នកនិពន្ធ ដែលមានស្នាដៃបានមកចុះបង្ហាញនៅទំព័រសៀវភៅខ្ញុំនេះ មិនមែនមានន័យថា លោកមិនមានថ្វីដៃដ៏ឆើតនោះទេ។ លោកដែលបានបោះពុម្ពផ្សាយកាលនោះ គឺសុទ្ធតែជាអ្នកនិពន្ធដ៏ល្អព្រោះតែមានការត្រួតពិនិត្យបានត្រឹមត្រូវ ហើយស្នាដៃរបស់លោក

សុទ្ធតែទទួលបាននូវការគាំទ្រពីសំណាក់មិត្តអ្នកអានដូចៗគ្នា។ អ្នកនិពន្ធទាំងអស់នោះរួមមាន[១]៖

-លោកគឹម សឿន រឿងផ្កាក្រអូប ឆ្នាំ១៩៥៤

-លោកគឹម សែត រឿងស្នេហ៍កាំភ្លើងនៅក្រោមភ្លៀងធ្លាក់ ឆ្នាំ១៩៥៥

-រឿងនារីពត្រី ឆ្នាំ១៩៥៥

-លោកគឹម សំអុន រឿងបុរសពីរនារីមួយ ឆ្នាំ១៩៥៤

-លោកលី ធាមតេង រឿងរំដួលភ្នំគូលេន ឆ្នាំ១៩៥៤

-លោកប៊ីវ ឆៃលាង រឿងព្រះចន្ទរាជា ឆ្នាំ១៩៥៥

-រឿងបក្សីចាំក្រុង ឆ្នាំ១៩៥៥

-រឿងព្រះខ័នរាជ ឆ្នាំ១៩៥៥

-អ្នកស្រីរស់ សារ៉េត រឿងកើតពីខ្ញុំស្លាប់ព្រោះខ្ញុំ ឆ្នាំ១៩៥៥

-លោកកឹម ដា រឿងចេញពីក្ដារមឈូស ឆ្នាំ១៩៥៦

-លោកគន្ធ ប៊ុនឈឿន រឿងនាងរំសាយសក់ ឆ្នាំ១៩៦០

-រឿងពេជ្ឈឃាតក្រមុំ ឆ្នាំ១៩៦០

-លោកមិត្ត សាខុន រឿងទង់មរណៈ ឆ្នាំ១៩៧០

-រឿងព្រួញពិសអាថ៌កំបាំង ឆ្នាំ១៩៧០

-រឿងវីរជនក្មេកមួយ ឆ្នាំ១៩៧០

រួមសេចក្ដីមកឃើញថា អ្នកនិពន្ធនៅសម័យសង្គមរាស្ត្រនិយម គេអាចចែកចំណាត់ថ្នាក់ជា៦និន្នាការប្លែកៗពីគ្នា ដូចជា៖

-អ្នកនិពន្ធ ដែលប្រារព្ធស្នាដៃរបស់ខ្លួនវិលទៅរកអតីតកាល មានន័យថាអ្នកនិពន្ធមួយជំពូកនេះ បានចងក្រងស្នាដៃខ្លួនជាលក្ខណៈរឿងនិទាន បុរាណដោយគាត់បានប្រើប្រាស់លក្ខណ្ឌបុរាណនៃស្ថាន

---

[១] ឃួន សុខម្ភ អ្នកនិពន្ធខ្មែរតាមលំដាប់ឆ្នាំ

ភាពប្រវត្តិសាស្ត្រ មកចងក្រងជាដំណើររឿងឡើងៗក្នុងករណីនេះ អត្ថបទខ្លះ ត្រូវបានសរសេរជាពាក្យកាព្យដូចជាបណ្ដារឿងរ៉ាវទាំងឡាយដែលបានសរសេរជាសាស្ត្រាល្បែង និងសាស្ត្រាល្បើកដែលធ្លាប់បានអ្នកនិពន្ធ សម័យបុរាណចងក្រងឡើងក្នុងអំឡុងសតវត្សទី១៨ឬទី១៩ដែរ។ អ្នកនិពន្ធដែលមានទំនោរគំនិត បែបនេះ មានដូចជាលោក ឌឹក គាមសរសេររឿងព្រះនាងឥន្ទ្រទេវី លោកគង្គ ប៊ុនឈឿន សរសេររឿងនាងរំសាយសក់ លោកសាំង ហ៊ែលសរសេររឿង រាជនីគោកធ្លក និងលោកគុយ ឡុតសសេររឿងព្រះបាទត្រសក់ផ្អែមជាដើម។

-អ្នកនិពន្ធ ដែលបានសរសេរទាក់ទងទៅនិងតថភាពសង្គមក្នុងន័យនេះ គឺអ្នកនិពន្ធខ្មែរបានសរសេរក្រើនរំឭកដល់មិត្តអ្នកអានខ្លួន ឲ្យចេះប្រកាន់គំនិតឯករាជ្យ ម្ចាស់ការខ្លួន ពិសេសគឺត្រូវរំដោះខ្លួនឲ្យរួចផុតពីសកម្មភាពក្ដាប់សេដ្ឋកិច្ចរបស់ពាណិជ្ជករអាណិកជនចិនដែលបានប្រើរបៀបកេងប្រវញ្ចមកលើការរស់នៅរបស់ប្រជាជនខ្មែរ។

-អ្នកនិពន្ធ ដែលបានសរសេរលើកសរសើរសមិទ្ធផលនានាក្នុងរបបសង្គមរាស្ត្រនិយម និន្នាការបែបនេះ គឺត្រូវបានបង្កើតឡើងដោយមានការប្រកួតប្រឡងប្រជែងពានរង្វាន់ផ្សេងៗ ឬក៏ជាការសរសេរដោយផ្ដេកទៅតាម នយោបាយនៅក្នុងសង្គមសម័យកាលនោះដើម្បីជាផលប្រយោជន៍របស់អ្នកដឹកនាំប្រទេស។ ស្នាដៃដែលបានស្គាល់ទាំងនោះមានដូចជា រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ របស់អ្នកនិពន្ធសួន សុរិន្ទ ពានរង្វាន់ឥន្ទ្រទេវីលេខ១ ឆ្នាំ១៩៦០ រឿង ជួន ជា កំណាព្យជ័យលាភីចំណាត់ថ្នាក់លេខ២ ពានរង្វាន់ឥន្ទ្រទេវី របស់អ្នកនិពន្ធ ផល ទិត រឿងនាងវ៉ែន ណែត ជាប់ពានរង្វាន់ឥន្ទ្រទេវីលើកទី១ដែរ របស់អ្នកនិពន្ធ អ៊ឹម ធុំ ជាដើម។

-អ្នកនិពន្ធ ដែលបានសរសេរបំផុសប្រជាជនពីការជិះជាន់កេងប្រវ័ញ្ច និន្នាការរបស់អ្នកនិពន្ធនេះ គឺបានបំផុសនូវកំហឹងឈឺចាប់ជាមួយអ្នកកាន់អំណាច ជាពិសេសជាមួយពួកអាណានិគមចាស់ថ្មីដោយមានទំនោរបម្រើសង្គមជាតិទាំងមូល។ វាជារឿងបង្ហាញពីការតស៊ូក្នុងវណ្ណៈ ដូចជារឿង គ្រូបង្រៀនស្រុកស្រែ រឿងស៊ឹមអ្នកបរឡាន រឿងគូលីកំណែន របស់អ្នកនិពន្ធអ៊ឹម ថុក។

-អ្នកនិពន្ធដែលបានសរសេរស្នាដៃជាលក្ខណៈទស្សនវិជ្ជា ស្នាដៃទាំងនេះ បានបង្កប់នូវការពិចារណាជាច្រើននៅក្នុងនោះសម្រាប់ជាការត្រិះរិះ ពិចារណារកពីមូលហេតុពិតប្រាកដណាមួយដែលអ្នកនិពន្ធចង់បង្ហាញប្រាប់អ្នកអាន។ អត្ថបទដែលបានសង្កេតឃើញមានលក្ខណៈដូចនេះមានដូចជារឿង ជីវិតឥតន័យ រឿងអ្នកផ្សងព្រេងអាពត់អាពាយរបស់អ្នកនិពន្ធសុទ្ធ ប៉ូលីន។

-អ្នកនិពន្ធ ដែលសរសេរគ្រាន់តែយកករម្រែមកបំពេញជីវិត អត្ថបទប្រភេទនេះក៏មានច្រើនណាស់ដែរ តែទោះបីជាយ៉ាងណាក៏ដោយ ក៏ឧត្តមគតិរបស់លោក នៅតែមានជានិច្ចក្នុងការសរសេរអប់រំកូនចៅឲ្យទទួលបាននូវគំនិតថ្លៃថ្នាក្នុងសង្គមរស់នៅ។ ស្នាដៃប្រភេទនេះ មិនមែនមានន័យថា គាត់រស់ក្នុងជីវភាពមួយដែលមានភាពលំបាកខ្វះមុខខ្វះក្រោយនោះទេ តែស្នាដៃគាត់ត្រូវបានគេចាត់បញ្ចូលយ៉ាងនេះ ក៏ព្រោះតែស្នាដៃទាំងនោះមិនមានលក្ខណៈពិសេសដោយឡែកណាមួយដែលនាំឲ្យអ្នកកត់ត្រា អាចកត់ត្រាវាយតម្លៃចូលជាប្រភេទដទៃបាន ។ ស្នាដៃទាំងនោះមានដូចជា រឿងបុរសពីរនារីមួយ របស់អ្នកនិពន្ធគីម សំអុន រឿងរំដួលភ្នំគូលេនរបស់អ្នកនិពន្ធ លី ធាមតេង រឿងថ្ងៃរះថ្ងៃលិច របស់អ្នកនិពន្ធអ៊ុំ សុខរសេជាដើម។

ដូចនេះយើងអាចសន្និដ្ឋានបានថា អក្សរសិល្ប៍សម័យនេះគឺជាវណ្ណកម្មមួយដែលបានកើតឡើងពី ការច្នៃប្រឌិតចេញពីសង្គមបរិយាកាសពិតប្រាកដ នៅលើផែនដី មិនមែនជាការសរសេរប្រាសចាកពីគោលគំនិតពិតឡើយ។ ទោះបីជាមានអ្នកនិពន្ធមួយចំនួនដែលលោកបានសរសេរវិលទៅរកលក្ខណៈបុរាណក្តី ក៏ប៉ុន្តែស្នាដៃទាំងនោះ គឺជាស្នាដៃមួយដែលមានលក្ខណៈប្រវត្តិសាស្ត្រ មានការគួបផ្សំជាមួយព្រឹត្តិការណ៍ពិតដែលបានកើតមាននៅក្នុងសង្គមដែរ។

ជារួម សង្គមជាតិទទួលបានឯករាជ្យពិតប្រាកដ ក៏នាំឲ្យអ្នកនិពន្ធមានលទ្ធភាពសរសេរ នូវគុណប្រយោជន៍មួយចំនួនដើម្បីបានជាគន្លឹះសម្រាប់ ការអប់រំតាមផ្លូវគំនិតបន្ថែមពីលើអ្វីដែលប្រមុខដឹកនាំបានផ្តល់ជាឱវាទសម្រាប់ពស្ត្រ។

ក្រោមកិច្ចប្រឹងប្រែង របស់អ្នកដឹកនាំដែលមានអង្គសម្តេចឪជាប្រមុខដ៏ឆ្លាតវៃនោះ សក្តានុពលខាងសេដ្ឋកិច្ច ក៏មានការរីកចម្រើន តែដោយឡែក វិស័យតែងនិពន្ធក៏រិតតែមានសន្ទុះយ៉ាងលឿនគួរឲ្យកត់សម្គាល់ដែរ ដោយអ្នកនិពន្ធមានការកើនឡើងគួរជាទីមោទនភាពសម្រាប់វិស័យនេះ។ ចំណែកនៅផ្នែកសិល្បៈភាពយន្តវិញ ប្រទេសខ្មែរយើងក៏មានការរីកចម្រើនណាស់ដែរ ដោយនៅឆ្នាំ១៩៦០ លោកសោម សំអាល់ ដែលជាលោកបានទៅហាត់រៀនថតខ្សែភាពយន្តនៅប្រទេសបារាំងឯសាលាInstitut des Hau-tes Etudes Cinématographiquea បានផលិតខ្សែភាពយន្តមួយមានឈ្មោះថា **ផ្ការីកផ្ការោយ** របស់អ្នកនិពន្ធអៀង សាយ។ រឿងនេះត្រូវបានដាក់បញ្ចាំងជាលើកតំបូងនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ ១៩៦០នៅរោង**កាពីតូល** ដែលនេះគឺជាកុនខ្នាតធំលើកតំបូងហើយដែលមានលក្ខណៈជាខ្នាតធំ។ ក្នុងឱកាសនោះ ប្រជាជនខ្មែរ

បានឲ្យតម្លៃថា វាកុនខ្នាតធំមួយដែលល្អមើលមិនចាញ់ខ្សែភាពយន្តពីបរទេសឡើយ ។

# អក្សរសិល្ប៍សម័យសាធារណរដ្ឋខ្មែរ
# ឆ្នាំ១៩៧០-១៩៧៤

## ទិដ្ឋភាពទូទៅអក្សរសិល្ប៍សម័យសាធារណរដ្ឋខ្មែរ

អក្សរសិល្ប៍សម័យសាធារណខ្មែរ គឺជាបណ្ដាវណ្ណកម្មទាំងឡាយណាដែលបានប្រសូតឡើងបន្តពីសម័យសង្គមរាស្ត្រនិយម។ មកដល់សម័យនេះ អ្នកនិពន្ធគ្រប់រូបហាក់ដូចជាមានសិទ្ធិសេរីភាពច្រើនយ៉ាងក្នុងការតាក់តែងស្នាដៃរបស់ខ្លួន ខុសប្លែកពីសម័យមុនៗក្នុងប្រវត្តិសាស្ត្រអក្សរសិល្ប៍។ ការដែលមានសិទ្ធិសេរីភាពបែបនេះ ក៏ព្រោះតែសង្គមខ្មែរសម័យនោះមានទំនោរងាកមកប្រកាន់ខាងសេរីវិញ ពិសេសសការសរសេរមានលក្ខណៈជាប្រជាធិបតេយ្យ។

អ្នកនិពន្ធភាគច្រើន បានសរសេរវណ្ណកម្មរបស់ខ្លួនដោយមានបញ្ចូលបញ្ហាស្នេហា ឬបញ្ហាចារកម្មមកជាមួយជាដើម។ មួយវិញទៀតគឺថា បញ្ហាសេរីខាងការសរសេរនេះ ក៏បានជំរុញឲ្យអ្នកនិពន្ធខ្មែរមួយចំនួនបានងាកមក ការសរសេរដួលទៅតាមចរន្តអក្សរសិល្ប៍បរទេសទៅវិញ ដែលចរន្តមួយនេះគឺមានលក្ខណៈទស្សនវិជ្ជាសុទ្ធសាធ។ បញ្ហានេះក៏បណ្ដាល ឲ្យមានភាពសម្បូរបែបនៅក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរដែរ។

ចរន្តអក្សរសិល្ប៍ដែលមានលក្ខណៈទស្សនៈវិជ្ជា ហើយបានផ្សាយចូលមកដល់ស្រុកខ្មែរ គឺតាមរយៈការផ្សព្វផ្សាយ និងមកពីអ្នកនិពន្ធមួយចំនួនធំបានទៅបន្តការសិក្សាពីបរទេស រួចគាត់ក៏ បាននាំលក្ខណៈអក្សរសិល្ប៍នេះមកស្រុកខ្មែរ ដែលមានខ្លះត្រូវបានបកប្រែជាភាសាជាតិ និងស្នាដៃមួយចំនួនទៀតត្រូវបាននិពន្ធឡើងដោយមានលំនាំប្រហាក់ប្រហែលគ្នា តែគ្រាន់ប្រើកាលអាកាសនៃសាច់រឿងខុសគ្នាពិសេស គឺសកម្មភាពតួអង្គមានលក្ខណៈជាខ្មែរពិតប្រាកដមិនដូចជាសាច់រឿងដើមពេក។ ស្នាដៃប្រភេទនេះ ក៏ទទួលបានការពេញនិយមពីសំណាក់មិត្តអ្នកអានដែរ ហើយក៏បានផ្សព្វផ្សាយជាលក្ខណៈទូលំទូលាយដែរ។ គួរកត់សម្គាល់ថា អក្សរសិល្ប៍បែបនេះ គឺមានការរីកចម្រើនយ៉ាងឆាប់រហ័ស គឺនៅទសវត្សរ៍ទី៦០ប៉ុណ្ណោះ។

អក្សរសិល្ប៍ស្ថិតនៅក្នុងចរន្តទស្សនវិជ្ជា ភាគច្រើន គឺច្រើនតែមានទំនោរជាលក្ខណៈបរទេស ហើយអ្នកនិពន្ធក៏បានលាក់កុសលរសខ្លួននៅក្នុងផ្ទៃរឿង។ ការសរសេរបង្កប់កុសលរសនៅក្នុងផ្ទៃរឿងបែបនេះគឺមានលក្ខណៈស៊ីជម្រៅ ជាស្នាដៃមួយដែលបានចងក្រងឡើងសម្រាប់តួអង្គដែលមានចំណេះដឹងជ្រៅជ្រះ ជាបញ្ញាវន្ត ជាអ្នកដែលបានរៀនសូត្រជ្រៅជ្រះ ចំណែកប្រធានបទដែលបានសរសេរគឺច្រើនតែជាប្រធានបទជាក់លាក់ និងមានលក្ខណៈទស្សនវិជ្ជាបង្កប់នៅក្នុងនោះ។

អ្នកនិពន្ធនៅសម័យនេះ គឺជាអ្នកនិពន្ធដែលបានរៀនសូត្រមានចំណេះដឹងជ្រៅជ្រះ ជាបញ្ញាវន្ត ជាអ្នកទស្សនវិជ្ជា ហើយបានប្រកាន់ទស្សនៈនិយមទៅតាមការយល់ឃើញរៀងៗខ្លួន។

របបសាធារណរដ្ឋខ្មែរ ដែលដឹកនាំដោយលោក លន់ នល់បរិយាកាសសង្គមគ្រានោះ គឺមានលក្ខណៈបើកចំហរដល់បណ្តាអ្នកនិពន្ធ អ្នក

កាសែតនៅក្នុងការបញ្ចេញទស្សនៈរបស់ខ្លួនជុំវិញការរស់នៅ ក៏ដូចជាជុំវិញការដឹកនាំ របស់ថ្នាក់ដឹកនាំប្រទេសតាំងពីសម័យមុនៗរហូតដល់អ្នកកាន់អំណាចនៅសម័យនោះទៀតផង។ អាស្រ័យដោយសិទ្ធសេរីភាពយ៉ាងដូចនេះហើយ បានជាបណ្ណាវណ្ណកម្មដែលបានសរសេរឡើងត្រូវបានជាទីពេញចិត្តសម្រាប់ការ អាន នឹងបានជ្រួតជ្រាបដល់ស្រទាប់មហាជនយ៉ាងឆាប់រហ័ស ពិសេសគឺស្រទាប់បញ្ញាវន្ត សាស្ត្រចារ្យដែលបង្រៀននៅតាមសាលានានា ក្នុងប្រទេសដែលមានឯកទេសខាងមុខវិជ្ជាអក្សរសាស្ត្រ អក្សរសិល្ប៍។ ការគាំទ្រនេះ ក៏ជាកម្លាំងចិត្តដ៏មហិមាមួយជួយជំរុញការសរសេររបស់អ្នកនិពន្ធឲ្យរិតតែសម្បូរបែបបន្ថែមទៀត ។

សមាគមអ្នកនិពន្ធខ្មែរ ដែលមានកំណើតតាំងពីសម័យសង្គមរាស្ត្រនិយមនោះ ក៏ជាកន្លែងដែលប្រមូលផ្តុំអ្នកនិពន្ធល្បីៗនោះ នៅពេលនេះក៏នៅតែជាកន្លែងទទួលការកិច្ចរបស់ខ្លួនដដែល ដោយគ្រាន់តែមានការផ្លាស់ប្តូរឈ្មោះពានរង្វាន់របស់ខ្លួនមួយចំនួន។ ដូចជា ពានរង្វាន់ឥន្ទ្រទេវី មកជាពានរង្វាន់ក្រមង៉ុយ ជាដើម។ សមាគម នេះមានតួនាទីសំខាន់ណាស់ នៅក្នុងសង្គមអ្នកនិពន្ធដូចជាអ្នកនិពន្ធណាដែលមានស្នាដៃល្បីៗចាប់ពីពីរឡើងទៅ អ្នកនិពន្ធនោះនឹងត្រូវបានចុះឈ្មោះជាសមាជិកសមាគមនេះ ដោយស្វ័យប្រវត្តិកាលណាអ្នកនិពន្ធបានចូលជាសមាជិកពេញសិទ្ធិរបស់សមាគមហើយ អ្នកនិពន្ធនោះក៏រិតតែល្បីឈ្មោះបន្ថែមទៀតនៅក្នុងវណ្ណកម្មរបស់ខ្លួន បានន័យថាអ្នកអានក៏នឹងរិតតែចូលចិត្តអានស្នាដៃគាត់។

ចំពោះការផ្សាយវិញ គឺមានការចុះផ្សាយតាមរយៈសារព័ត៌មានក្នុងស្រុកដែរ ដូចជាសារព័ត៌មាន **នគរធំ** ដែលមានលោក**សុខ្ញប៉ូលីន** ជានាយកការផ្សាយ កាសែត**មាតុភូមិ**របស់លោក**សឹង ភៀក**កាសែត**កោះ**

**សន្តិភាព** របស់លោក **ជូ ថានី** ចំណែកអស់លោកខ្លះទៀត គឺត្រូវបានបោះពុម្ពផ្សាយជាសៀវភៅដោយខ្លួនឯង ឬមួយលក់សិទ្ធទៅឲ្យម្ចាស់បណ្ណាគារជាដើម។ ពួកគាត់មានសេចក្ដីសប្បាយរីករាយនៅក្នុងការគាក់តែងស្នាដៃរបស់គាត់ណាស់ ចំណែក អ្នកអានក៏ទទួលបាននូវការពេញចិត្តណាស់ដែរ ដោយសារតែប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស ត្រូវបានបិទ ដូចនេះពួកគាត់ត្រូវតែបង្វែសេចក្ដីអផ្សុកដែលមាននៅក្នុងអារម្មណ៍មកជាការអានកម្សាន្តប្រលោមលោកវិញ។ ស្នាដៃប្រលោមលោកដែលបានផ្សាយនៅលើទីផ្សារ មានច្រើនប្រភេទ ដូចជាប្រលោមលោកអាសអាភាស ប្រលោមលោកដែលបំផុសសេចក្ដីស្នេហាជាតិ ប្រលោមលោកមនោសញ្ចេតនាស្នេហាធម្មតា ប្រលោមលោកដែលការសរសេរមានលក្ខណៈជាទស្សនវិជ្ជា ជាដើម។ ក្នុងចំណោមបណ្ដាវណ្ណកម្មទាំងនេះ ប្រលោមដែលទទួលបានការពេញនិយមជាងគេ គឺជាប្រលោមលោកដែលសរសេរជាលក្ខណៈ អាសអាភាស។

ទោះបីជាបញ្ហាអក្សរសិល្ប៍ ត្រូវបានទទួលការវាយលុកពីបណ្ដាវណ្ណកម្មដែលមានលក្ខណៈអាសអាភាស ដែលធ្វើឲ្យថមថយសីលធម៌នៅក្នុងសង្គមក៏ដោយ ក៏ប៉ុន្តែបើនិយាយពីបញ្ហាអក្សរសិល្ប៍ គឺមានលក្ខណៈខុសគ្នាណាស់ ព្រោះកត្តានេះ ជារឿងមួយដែលអក្សរសិល្ប៍ត្រូវបានដកមកមានការចាប់អារម្មណ៍ពីស្រទាប់ អ្នកអាន តែក៏មានទស្សនៈរិះគន់ទៅលើបណ្ដាវណ្ណកម្ម ដែលសរសេរប្រាសចាកសីលធម៌នេះដែរ។

ប្រសិនណាជាដកមកសិក្សា ពីកម្រិតជីវភាពអ្នកនិពន្ធនៅក្នុងដំណាក់កាលនេះ គឺថាជីវភាពរបស់គាត់មានការរីកចម្រើនធូរធារជាងមុន ដោយសារតែបណ្ដាស្នាដៃត្រូវបានអ្នកអានពេញនិយម ក៏បណ្ដាល

ឲ្យគាត់មានកម្លាំងចិត្តក្នុងការសរសេរ រហូតដល់ពេញមួយសម័យសាធារណរដ្ឋខ្មែរ គឺការសរសេរបែបនេះ រហូតរបបសាធារណរដ្ឋខ្មែរត្រូវបានផ្តួលរំលំដោយរដ្ឋប្រហារ របស់ពួកទ័ពខ្មែរក្រហមថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ទើបបណ្តារណ្ណកម្មនានាត្រូវបានបញ្ចប់។

អ្នកនិពន្ធសំខាន់ៗនៅក្នុងសម័យនេះ រួមមាន៖

## ១ លោក គយ សារុន

លោកប្រសូតឆ្នាំ១៩២០ នៅសង្កាត់លិចធំ ស្រុកសំរោង ខេត្តតាកែវ។ លោកគឺជាអ្នកដែលមានប្រវត្តិការសិក្សាបានវែងឆ្ងាយណាស់ដែរ។ ឆ្នាំ១៩២៩ លោកបានរៀនសូត្រនៅសាលាចាក់អង្រែ រួចបន្តមកសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្នុងក្រុងភ្នំពេញនៅឆ្នាំ១៩៥៥ក្រោយមកនៅឆ្នាំ១៩៦៥ លោកក៏បានធ្វើជាសាស្ត្រាចារ្យបង្រៀននៅវិទ្យាល័យតាកែវ។ បង្រៀននៅទីរួមខេត្តបានតែ៣ឆ្នាំ លោកក៏បានផ្លាស់មកបង្រៀននៅអនុវិទ្យាល័យកំពង់កន្ទួត។

នៅឆ្នាំ១៩៧១ លោកគយ សារុនក៏បានជាប់ឈ្មោះជាអធិការរងនៅខេត្តឧត្តរមានជ័យ។ បទពិសោធរបស់លោកកាលនៅជាមន្ត្រីការស៊ីវិល គឺលោកគឺជាសាស្ត្រាចារ្យបង្រៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ហើយក៏ធ្លាប់បានធ្វើជាអ្នកសិក្សាភិរក្សដែរ។

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ លោកបានបន្សល់ស្នាដៃសំខាន់ៗចំនួន៤ ដូចជា៖

-ជីវិតនិស្សិត អត្ថបទកំណាព្យ ចំណាត់ថ្នាក់លេខ៣ ពានរង្វាន់ព្រះកុសុមៈ ផ្នែកអក្សរសាស្ត្រឆ្នាំ១៩៥៩

-បុប្ផាខ្មៅ អត្ថបទកំណាព្យ ចំណាត់ថ្នាក់លេខ២ ពាន

វង្វាន់ឥន្ទ្រទេវី ផ្នែកអក្សរសាស្ត្រឆ្នាំ១៩៦៧

-កើតជាមនុស្សនេះ អត្ថបទកំណាព្យ ចំណាត់ថ្នាក់លេខ ៣ ពានរង្វាន់ក្រមង៉ុយ ផ្នែកអក្សរសាស្ត្រឆ្នាំ១៩៧១

-បេះដូងសម្រាប់ស្រឡាញ់ ?

ខាងក្រោមនេះ ខ្ញុំដកស្រង់អត្ថបទបុប្ផាខ្មៅ ដែលជាស្នាដៃរបស់លោកជាប់ពានរង្វាន់អក្សរសាស្ត្រឆ្នាំ១៩៦៧ ដែលអត្ថបទរបស់លោកសរសេរជាកំណាព្យខ្លីៗមានច្រើនបទ ច្រើនវគ្គប្រកបទៅដោយខ្លឹមសារយ៉ាងជ្រាលជ្រៅ។ ដើម្បីរឹតតែច្បាស់ សូមមិត្តអ្នកអានធ្វើការអាន នឹងសិក្សាជាមួយខ្ញុំដូចតទៅៈ

## ខ្វះដើមអំពិលទឹក

| | | |
|---|---|---|
| គេកាត់គេច្រិបគេរក្សា | ស្អិតស្អាងកាយាឲ្យឥតហ្មង | |
| ពីខាង ពីលើធ្វើរបង | អ្នកផងសរសើរអំពិលទឹក | ។ |
| ថាជារុក្ខជាតិមានវាសនា | គេរាប់ប្រើការបានសន្ទឹក | |
| មានដើមមានមែកបន្ទាញឹក | សន្ទឹកក៏ស្រស់សៅយូរយារ | ។ |
| តែស្រស់តែស្អាតតែត្រឹមត្រង់ | រូបខ្វង់នេះសម្រាប់នរណា? | |
| សម្រាប់អំពិលទឹករុក្ខា? | ឬថាសម្រាប់មនុស្សវិញទេ | ។ |
| ដើមណាដែលរស់តាមធម្មជាតិ | លូតលាស់តាមមាឌមែកទន់ទេរ | |
| សារិកាច្រៀវព្រៃច្រៀងបំពេ | ផ្កាផ្លែរាំរេតាមសូរខ្យល់ | ។ |
| ឯដើមឈរត្រៀបតម្រៀបជួរ | សមគួរល្អគន់ពន់ពេកសល់ | |
| តែកម្រើកដែកខ្វែងដល់ | បានផលដាច់កត្រូវរស់ ។ | |
| រស់រាប់ខែឆ្នាំចាំជីវិត | ក្រិនក្រៀមក្រំពិតឥតកម្ពស់ | |
| យាមផ្ទះឲ្យគេទទេសោះ | មានឈ្មោះតែត្រង់គេថាល្អ | ។ |

លុះថ្ងៃដែលប្រាក់កាសគេដល់ គេកាប់គ្មានសល់ពូជទុកត
គេគាស់ទាំងឫសចាក់គ្រឹះថ្ម គេសរសើរល្អរបងដែក ។

## ប្រតិទូក្សត់ពូជ

អ្នកក្រត្រដឲ្យកូនរៀន ខំប្រឹងស្មើរលៀនក្មេកគ្រប់គ្នា
លក់គោក្របីជ្រូកមាន់ទា ដីស្រែចម្ការសឹងគ្មានសល់ ។
កូនខ្លះផ្គេសផ្គាសមិនខំរៀន ថែមហ៊ានយកលុយម៉ែឪផ្តល់
ចាយវាយហ៊ឺកហ៊ាក់ហាក់តាមខ្យល់ មិនមានគិតដល់ញើសឪម៉ែ។
កូនខ្លះគ្រាន់បើខាងរៀនសូត្រ ស្ទុះលូតរបូតផុតដីស្រែ
ធ្វើការរាជការបានប្រាក់ខែ ប៉ុន្តែភ្លេចអស់រឿងក្រីក្រ ។
ភ្លេចពូជពណ៌ពង្សវង្សអធន ដែលរងទុក្ខធ្ងន់មកច្រើនត
ត្រូវគេពួតគ្នាប្រូបាច់ក ត្រដររកខ្យល់ចាំតែស្លាប់ ។
អ្នកក្របញ្ជូនឲ្យកូនរៀន ឲ្យមានតម្រិះចេះប្រញាប់
ក្មែកភ្លឺឃើញច្បាស់ឲ្យដាស់ប្រាប់ ម្តេចឡើយក្រឡាប់ភ្លេចពូជឯង។
បែរជាព្រួតដៃនឹងអ្នកខ្ពស់ ត្រគោះប្រឆាំងច្បាំងកំហែង
ថាក្រព្រោះខ្ជិលមិនប្រឹងប្រែង ថាកម្មតាក់តែងពីព្រេងនាយ ។
បើតែម៉្លឹងៗអ្នកខ្សោយខ្សត់ ប្រាកដជាគ្មានផ្លូវដោះស្រាយ
គេក្សត់ខ្លួនអស់ព្រោះជិនណាយ ព្រោះគេសប្បាយភ្លេចពូជពណ៌។

## អាសូរដើមដូង

យូរហើយដូងដុះក្នុងភូមិក្ម ដើមជាងលូតល្អមានផ្លែផ្កា
ស្រាប់គេផ្គាច់ឫសផ្គាច់អាហារ គេថាគាស់ដឹកយកទៅដាំ។
ល្ងាចនេះដូងដុះក្បែរសាលា លោកអ្នករាជការខំថែទាំ

តុបតែងស្រោចទឹកយ៉ាងដោតដាំ ផ្កាក់ថ្មមុតមាំខ្ចាចដូងដួល។
ព្រឹកឡើងបុណ្យសម្ពោធសាលា មនុស្សមូលខ្សៀវខ្សាមីខ្មៅញុំខ្នល
ញញឹមប្រិមប្រិយចាំទទួល ស្រុះស្រួលចោមជុំសម្តេចឪ ។
ដើមដូងដាច់ឫសសប្បាយដែរ រេរាំហូរហែនៅក្បែរផ្លូវ
ញញឹមស្វាគមសម្តេចឪ មើលអស់លោកត្រូវបានមេដៃ។
ព្រឹកដ៏រីករាយកន្ទង់ទៅ ដូងនៅម្នាក់ឯងកណ្តាលថ្ងៃ
សូរ្យសែងក្តៅដុតគ្មានសំចៃ ដូងក្សយចោលរូបកណ្តាលក្រុង។

## ស្តាយដូងចន្ទ្រា

ខ្ញុំស្រឡាញ់ ដូងចន្ទ្រា ពេញបូរមី
រឿងរង្សី ភ្លឺស្រលះ ច្បាស់មេឃា
ស្អាតបរិសុទ្ធ មូលក្រឡង់ ក្នុងនភា
ខ្ញុំនិទ្រា មិនលក់ឡើយ ពេលរាត្រី។
ខ្ញុំស្រឡាញ់ ដូចន្ទ្រា ភ្លឺត្រជាក់
ពន្លឺប្រាក់ ស្រោបដួងចិត្ត ជនប្រុសស្រី
ឲ្យសប្បាយ ភ្លើតភ្លើនចិត្ត ឥតខ្វល់អ្វី
ភ្លេចក្រក្រី ក្តីសោកសៅ ក្នុងជីវិត។
ខ្ញុំស្រឡាញ់ ដូងចន្ទ្រា មូលក្រឡង់
ហាក់ដូចវង្ស កត្រ្តកល្យាណ គូស្នេហ៍ស្និទ្ធ
នាងញញឹម ខ្ញុំសង្ឃឹម សប្បាយចិត្ត
ហាក់បានជិត វិតរួមរក្ស ស្ម័គ្រកនិដ្ឋា ។
ខ្ញុំស្រឡាញ់ ដូងចន្ទ្រា ជាសាក្សី
នៃសេចក្តី ស្មោះស្ម័គ្រចិត្ត ស្និទ្ធស្នេហា

នៃគ្រមុំ និងកម្លោះ គួសង្ហារ
ដែលប្រាថ្នា បានជាគូ រូបរួមកាយ ។
ខ្ញុំស្រឡាញ់ ដួងចន្ទ្រា ជាល្បែងក្មេង
ម្ដាយពោលលេង ឲ្យកូនតូច ពនសុំបាយ
សុំសម្ល ទឹកបំពង់ ចេក ដូង ស្វាយ
កូនសប្បាយ ញុាំចិបៗ សើចក្អឹកៗ ។
ខ្ញុំស្រឡាញ់ ដួងចន្ទ្រា មានពោធិធំ
ជីដូនខ្ញុំ ប្រាប់មកច្នេះ មកជាញឹក
មើលទៅឃើញ មានឫសគល់ ដើមមែកស្លឹក
ក្រោមពោធិព្រឹក្ស ដូនចាស់រ- វៃអំបោះ ។
ខ្ញុំស្រឡាញ់ ដួងចន្ទ្រា ហៅសសាង
ព្រះឥន្ទ្រស្ពាង រូបទន្សាយ ទុកនៅនោះ
រំឭកកាល ពោធិសត្វ គិតសង្គ្រោះ
ព្រាហ្មណ៍ដោយស្មុះ លោតចូលភ្លើង ជាអាហារ ។
ខ្ញុំស្រឡាញ់ ដួងចន្ទ្រា ហៅលោកខែ
នៅស្រុកខ្មែរ រាជពិធី ដ៏ថ្លៃថ្លា
អកអំបុក ដើយមើលចំ ដួងចន្ទ្រា
បន់ទេពតា សូមខេមរា បានចម្រើនថ្កាន ។
ខ្ញុំស្រឡាញ់ ដួងចន្ទ្រា នៃកវី
ក្នុងរាត្រី នាំអារម្មណ៍ ឲ្យក្សេមក្សាន្ត
ខួនរំភើប ហាក់អណ្តែត ទៅឆ្ងាយបាន
ភ្លេចខ្លួនប្រាណ សប្បាយតាម កាំរស្មី ។
ខ្ញុំតូចចិត្ត នឹងពួកអ្នក វិទ្យាសាស្ត្រ

| | | | |
|---|---|---|---|
| ម្ដេចក៏ផ្កាស | ធ្វើកាំជ្រួច | បាញ់ពីដី | |
| ចង់ទៅយក | ដួងព្រះចន្ទ្រ | ពិភពថ្មី | |
| ហេតុចង់ល្បី | ខ្វាយកេរ្តិ៍ឈ្មោះ | បោះនាមា | ។ |
| ខ្ញុំមិនចង់ | ឲ្យមនុស្សលោក | សុទ្ធហ្មង់សៅ | |
| ដូចធ្យូងខ្មៅ | ទៅប្រឡាក់ | ដួងចន្ទ្រា | |
| ដែលបរិសុទ្ធ | ផុតមន្ទិល | ផង់នានា | |
| គួរបូជា | ស្រឡាញ់ស្មោះ | ពីហឫទ័យ | ។ |
| ឱសែនស្ដាយ | ដួងចន្ទ្រា | ជាសាកល | |
| ដែលតែងផ្ដល់ | គ្រប់បំណង | ដោយប្រពៃ | |
| ម្ដេចឡើយអ្នក | វិទ្យាសាស្ត្រ | គិតបំភ្លៃ | |
| យកចន្ទ្រថ្លៃ | ជាកម្មសិទ្ធិ | ឲ្យសៅហ្មង | ។ |

## ២ លោកកេង វ៉ាន់សាក់

លោកប្រសូតនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩២៤ នៅភូមិកំពង់បឹង សង្កាត់កំពង់បឹង ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។ បិតារបស់លោកមាននាម "កេង ស៊ីផាន់" និងមាតានាម "ជៀស-ហាន"។

បន្ទាប់ពីបានប្រឡងជាប់មធ្យមសិក្សាប័ត្រភាគ២ ផ្នែកទស្សនវិជ្ជា នៅឆ្នាំ១៩៤៦ លោកបានទៅបន្តការសិក្សានៅប្រទេសបារាំង ទន្ទឹមនឹងការសិក្សា លោកបានធ្វើការជាសាស្ត្រាចារ្យជំនួយភាសាខ្មែរនៅសាលាជាតិជីវភាសាបូព៌ាប្រទេស នៅទីក្រុងប៉ារីសនៅឆ្នាំ១៩៤៧-១៩៤៨ និង ១៩៥១-១៩៥២ នៅចន្លោះពេលនោះលោកបង្រៀនភាសាខ្មែរនៅសាលាសិក្សាផ្នែកបូព៌ា និងអាហ្វ្រិកនៃសាកលវិទ្យាល័យក្រុងឡុងដុង (School of Oriental and Afican Studias. London University) ក្នុងឆ្នាំ

១៩៤៨-១៩៥០ នៅឆ្នាំ១៩៥១ លោកបានប្រឡងជាប់បរិញ្ញាប័ត្រអក្សរ-សាស្ត្រ ផ្នែកទស្សនវិជ្ជា នៅមហាវិទ្យាល័យ អក្សរសាស្ត្រនិងមនុស្សសាស្ត្រក្រុងប៉ារីស។

ភរិយារបស់លោកមាននាមស៊ុយស្កាន កុលលើវីល (Zuzane COLLEVILLE) ។ នៅឆ្នាំ១៩៥២លោកបានបង្កើតអង្គុលីលេខជាអក្សរខ្មែរដើម្បីសម្រួលដល់ការវាយអត្ថបទ។ លុះមកដល់ឆ្នាំ១៩៥២-១៩៥៨ លោកកេង វ៉ាន់សាក់បានត្រលប់មកប្រទេសកម្ពុជាវិញហើយបានទទួលមុខនាទី ជាសាស្ត្រាចារ្យនៅវិទ្យាល័យស៊ីសុវត្ថិនៅក្រុងភ្នំពេញ។

នៅឆ្នាំ១៩៥៥ ប្រទេសកម្ពុជាសម័យនោះ មានការបោះឆ្នោតជាសកល លោកក៏បានក្លាយជាមេ "គណៈបក្សប្រជាធិបតេយ្យ" សម្រាប់ការបោះឆ្នោតនាពេលនោះ។ លោកកេងវ៉ាន់សាក់ បានចេញមុខប្រឆាំងដោយផ្ទាល់ជាមួយនឹងរាជបល្ល័ង្ក ជាពិសេសគឺប្រឆាំងផ្ទាល់នឹងសម្តេចនរោត្តមសីហនុ ជាស្ថាបនិកនៃ "គណៈបក្សសង្គមរាស្ត្រនិយម"។ បន្ទាប់ត្រូវបរាជ័យនៃគណៈបក្សប្រជាធិបតេយ្យ នៅថ្ងៃទី១៣ ខែកញ្ញា ដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៥៥លោកត្រូវបានរដ្ឋាភិបាលសម័យនោះចាប់លោកដាក់គុក។ នៅពេលចេញពីពន្ធនាគារ លោកបានបោះពុម្ពផ្សាយកម្រងកំណាព្យដែលលោកបាននិពន្ធក្នុងគុក ហើយកម្រងកំណាព្យនេះបានទទួលឥទ្ធិពលដ៏ខ្លាំងក្លាទៅលើកវីនិពន្ធខ្មែរនៅជំនាន់នោះ។ នៅឆ្នាំ១៩៥៨ លោកមានតួនាទីជាប្រធានគណៈកម្មការពិនិត្យសៀវភៅអក្សរសាស្ត្រខ្មែរនៅមធ្យមសិក្សា។ឆ្នាំ១៩៥៨-១៩៦២ លោកទទួលតំណែងជាព្រឹទ្ធបុរសមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ និងជាចាងហ្វាងវិទ្យាស្ថានជាតិគរុកោសល្យ ហើយក្នុងឱកាស នោះលោកបានទៅបង្រៀនអក្សរសាស្ត្រ វប្បធម៌ អរិយធម៌ខ្មែរនៅមហាវិទ្យាល័យអក្សរ

សាស្ត្រ និងមនុស្សសាស្ត្រ និងពុទ្ធិកសាកលវិទ្យាល័យភ្នំពេញ រហូតដល់ឆ្នាំ១៩៦៨ នៅពាក់កណ្ដាលឆ្នាំ១៩៦៨ រដ្ឋាភិបាលក៏បានបញ្ឈប់លោកឲ្យលែងបង្រៀន ហើយឲ្យភ្នាក់ងារឃ្លាំមើលគេហដ្ឋានលោកទៀត ដោយលោកជាប់ចោទថាជាអ្នកបំបះបំបោរនិស្សិត និងសិស្សនានាឲ្យធ្វើសកម្មប្រឆាំងនឹងរដ្ឋាភិបាលជំនាន់នោះ។គ្រានោះដែរ អាជ្ញាធរបានចុះឆែករុករក នៅផ្ទះលោកសាស្ត្រាចារ្យរូបនេះ បានរកឃើញមានសៀវភៅ "ម៉ាក់, ម៉ៅ" និងទស្សនាវដ្ដីប្រទេសចិន។ល។ នៅបណ្ណាល័យរបស់លោក ជាហេតុនាំឲ្យអាជ្ញាធរក្រសួងសន្តិសុខចាប់លោកឃុំនៅ "រាជបណ្ឌិតសភានគរបាល" ជាមួយលោក សូ នៃមនិងលោកភួង តុនដោយទទួលការចោទប្រកាន់ថា ជាពួកកុម្មុយនិស្តនិយមបានបំបះបំបោរនិស្សិត និងប្រជាជនឲ្យប្រឆាំងនិងរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម។

បន្ទាប់ពីសភាពការណ៍នយោបាយនៅឆ្នាំ១៩៧០ ដែលធ្វើឡើងដោយឧត្តមសេនីយ៍ លន់ នល់ ប្រទេសកម្ពុជាបានក្លាយជាសាធារណរដ្ឋខ្មែរ រដ្ឋាភិបាលថ្មីបានផ្ដល់និតិសម្បទាឲ្យលោកវិញហើយបានបង្កើត "វិទ្យាស្ថានខ្មែរ-មន" ដោយបានតែងតាំងលោកជាមេដឹកនាំក្នុងគោលបំណងលើកតម្កើងវប្បធម៌ខ្មែរ-មនឲ្យបានខ្ពង់ខ្ពស់ ដើម្បីឲ្យជនជាតិខ្មែរមានមោទនភាពជាខ្មែរ និងបង្រួបបង្រួមខ្មែរជាទូទៅនៅជុំវិញគេរមរតកវប្បធម៌នេះជាអាវុធប្រឆាំងនិងចក្រពត្តិយៀកណាមកុម្មុយនិស្ត។ លោកបានធ្វើនិក្ខេបបទមួយ ដែលបានការពារនៅសាកលវិទ្យាល័យស្តុកហោមកាលពីឆ្នាំ១៩៧១ដែលមានចំណងជើងថា "ការស្រាវជ្រាវរកឫសគល់មួយនៃវប្បធម៌ខ្មែរ"។ លោកសាស្ត្រាចារ្យ ជាបញ្ញាជនមួយរូបដ៏កម្រដែលមានចក្ខុវិស័យសាកលវែងឆ្ងាយស្ដីអំពីវប្បធម៌ អរិយធម៌ខ្មែរ។ នៅឆ្នាំ១៩៧១ លោកបានធ្វើជាគូឈ្លួយប្រតិភូអចិន្ត្រៃយ៍ នៅអង្គការអុយ-

នេស្តស្ទូនៅទីក្រុងប៉ារីស។ បន្ទាប់មកនៅខែតុលា ឆ្នាំ១៩៧៤ ដល់ឆ្នាំ ១៩៧៥ លោកក៏មានតួនាទីជាការធារីនៃរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ប្រចាំប្រទេសបារាំងទៀតផង។

ស្នាដៃរបស់លោក មាននៅក្នុងវណ្ណកម្មអក្សរសិល្ប៍គឺជាប្រភេទ ស្នាដៃមួយដែលមានគំនិតជឿនលឿន និងមានអត្ថ័យអប់រំបង្កប់ដែល អ្នកអានត្រូវប្រើគំនិតជ្រៅក្នុងការវិភាគ។ ស្នាដៃរបស់លោកក្នុងផ្នែកវណ្ណ កម្មអក្សរសិល្ប៍រួមមានៈ

-កម្រងកំណាព្យ ចិត្តក្រមុំ ១៩៥៤

-កម្រងកំណាព្យ គុកកាមកិលេស ១៩៥៦

-កម្រងកំណាព្យ ក្រពះ

-រឿង ចម្រៀងតាប៉ី

- រឿងសាច់ពុំបានស៊ីយកឆ្អឹងព្យួរក មាន៥ឈុត សរសេរជាល្ខោន សម្តែងនៅឆ្នាំ១៩៤៥

- រឿងអន្ទិតគោលោត មាន៥ឈុត សរសេរជាល្ខោន ឆ្នាំ ១៩៤៥ នៅក្នុងរឿងនេះលោកបានពណ៌នាអំពីបញ្ហាទំនៀមនិយមនិង ទំនើបនិយម។

-កន្ទ្រែង។ក្រលិតក្តងង ១៩៧២

-ឱយតែខ្មែររស់ ១៩៧២

-ដើទៅអាថា ១៩៧៨

-អាទូអាទា ១៩៧៩

-ខ្មែរស្ងាប់ខ្មែររស់ ១៩៨១

-ចិនទេសង់អង្គរ ១៩៨៦

ក្រៅពីបណ្តាស្នាដៃរបស់លោកទាំងនេះ យើងក៏នៅឃើញស្នាដៃ

របស់លោកជាច្រើនទៀត ដែលបានចងក្រងឡើងក្នុងន័យសម្រាប់បម្រើការសិក្សាអក្សរសាស្ត្រជាតិខ្មែរ។

ជាបន្តទៅទៀត ខ្ញុំនឹងដកស្រង់អត្ថបទកំណាព្យមួយចំនួននៅក្នុងស្នាដៃកំណាព្យគុកកាមកិលេស មកបង្ហាញជូនមិត្តអ្នកអានឲ្យបានជ្រាបដូចតទៅៈ

## ភ្ជុំបិណ្ឌក្នុងគុក

យប់នេះផ្គរលាន់សូររងំ បុណ្យភ្ជុំប្រមូលញាតិសន្តាន
សួគ្រធម៌ ឬសើចលេងកម្សាន្ត ឱកែវកល្យាន្តបងជាប់គុក ។
បងភ្ជុំជាមួយនឹងជញ្ជាំង ប្អូនផ្ទាំងឆ្វេងស្តាំក្រោយនិងមុខ
ខាងលើខាងក្រោមឃើញតែទុក្ខ ក្នុងគុកបុណ្យភ្ជុំនឹងខ្លួនឯង ។
យប់នេះម្ទេះសមកែវវរមិត្រ នាងគិតរកបងវែងចម្បែង
ថែមខ្មើយក្ឃួយមុងមិនប្រលែង អូនគេងម្នាក់ឯងយប់បុណ្យភ្ជុំ ។
ក្នុងគុកគង់បងនៅមានគ្នា កម្មព្រាត់កំព្រាថ្ងូររងំ
អ្នកទោសដូចបងដេកទ្រូញយំ នឹកដល់បុណ្យភ្ជុំជុំវេទនា ។
អ្នកខ្លះនឹកទៅម្តាយឪពុក ខ្លះចង់ជួបមុខបុត្រភរិយា
ខ្លះចង់បានសិទ្ធិជាអ្នកជា គ្រប់គ្នាប្រជុំភ្ជុំទុក្ខព្រួយ ។
ខ្លះដេកគងថ្ងាសពព្រិចភ្នែក ខ្លះដេកយំយែកឲ្យព្រះជួយ
ខ្លះដកដង្ហើមសូរមួយៗ ខ្លះព្រួយនៅស្ងៀមឥតស្រាកស្រាន្ត។
ចាំបាច់ថាអីត្រឹមបងព្រួយ អ្នកទោសរង្វើយយំគ្រប់ប្រាណ
សូម្បីអ្នកជាទាំងប៉ុន្មាន បងស្មានថាភ្ជុំទុក្ខព្រួយដែរ ។
អូនស្តាប់មើលចុះសូររងំ គឺព្រួយប្រជុំធ្វើបុណ្យខ្មែរ
កើតស្លាប់ព្រាត់ប្រាសមានហូរហែរ អូនអើយមានតែក្តីស្នេហា ។

ទើបជួយស្រោចស្រង់សត្វលោកបាន ឲ្យមានកម្សាន្តដោយប្រាថ្នា
សង្ឃឹមអាណិត ចិត្តមេត្តា កើតពីស្នេហាមនុស្សគ្រប់គ្នា ។

## គុកតាមតណ្ហា

ព្រលឹងមាសអើយ ជាប់គុកមែនហើយ
តែហាក់ស្រមៃ បងស្មានទៅជិត
នៃបនិត្យថ្ងើមថ្ងៃ ស្រាប់តែយប់ថ្ងៃ
នៅមួយកន្លែង ។
ព្រលឹងមាសអើយ ចិត្តហោះទៅហើយ
កាយនៅតឹងតែង រឹងធុញរែងថប់
គ្រប់សព្វចម្បែង ឆ្ងាយពីប្រលែង
ប្រលោមក្នុងក្រៅ។
ឆ្ងាយលួងលោមស្រី ថ្នាក់ថ្នមបមបី
មិនឲ្យហ្មងសៅ ចង់អ៊ីបន្តិច
បងហិចហោះទៅ រត់រកថៅរៅ
ផ្គាប់ចិត្តពុំងា ។
ព្រាត់ត្រេកត្រអាល ព្រាត់ស្និទ្ធស្នេហ៍ស្នាល
ត្រអាល រក គ្នា ព្រាត់ពាក្យសម្តី
ស្រស់ស្រី មាយា ធ្វើ ឫក ធ្វើ ពា
ឲ្យបងស្រឡាញ់ ។
ឃ្លាតពេល ង៉រ ង៉ក់ ខឹងហើយ តប់ គក់
ក្តិចខាំ គ្នាន់ខ្នាញ់ អូនបាត់ ខឹង ហើយ
លោកអើយស្រឡាញ់ ឱប រិត ខ្នួលខ្នាញ់

ស្រងេះស្រងោល ។

ឥឡូវព្រាត់ហើយ ម្ទេះសមត្រាណាត្រើយ
កំព្រា តេលតាល បង់ គង់មានគុក
មាន ទុក្ខ អុជអាល ស្នេហ៍ ស្និទ្ធដុតរាល

**គុក** គប់ **តណ្ហា** ។

ចំណីណាល្អ មួយ ម៉ាត់ មួយ ក
យើងធ្លាប់ភោគ្គា បញ្ចុកគ្នាលេង
ប្រលែងចរចា ចើបដៃ ចើបស្មា

សួរសើចក្អាកក្អាយ ។

ធ្លាប់បង់បំពេរ ព្រលឹងមាសមេ
ដោះសក់រំសាយ គេង លើទ្រូងបង់
ត្រកង់កៀកកាយ កៀកកើយសប្បាយ

ស្រាប់តែព្រាត់ប្រាស ។

ឥឡូវកៀកកើយ ព្រួយកលជាខ្នើយ
គង់ដៃលើថ្ងាស ដកធំ ដង្ហើម
រៀងដើមដេរដាស ភរ់រកអាកាស

ក្នុងគុកស្នេហ៍ស្នង ។

នឹកដល់ពេលយប់ ដូចផ្កា យីហ៊ុប
ពិដោរន្ទួនល្អង ក្រអូបជាប់ជិត
ឈ្មុយឈ្ងិតជាប់ចង ក្លិនជាចំណង

ចង់គុកតណ្ហា ។

ស្តាយស្តាប់សំឡេង ពីពេះដូចភ្លេង
សួរស័ព្ទកាមា បំពេរសាច់ឈាម

អ្នកយាមនោះណា　　　　គឺកាមតណ្ហា
យាមមិនឈប់សោះ　　ៗ
ព្រលឹងមាសអើយ　　　　យប់ចុះមកហើយ
ឱ! សែនស្រណោះ　　　　រូបរៀវពង់ក្ងំ
មើលសមឥតខ្ចោះ　　　　ទ្រូងស្រួចមាត់ស្រស់
ស្រៀវស្រើបគុកបង　　ៗ
អង្កែលត្រង់ណា　　　　រំភើបមំសា
ព្រឺព្រួចឆ្លើយឆ្លង　　　　ទន់ភ្លន់ស្រឡូន
ឱអូនមាសបង　　　　ធំណាស់ចំណង
កិលេសគុកកម្ម　　ៗ...

## ៣　លោកហាក់ ឆៃហុក

លោកប្រសូតនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៤៤ នៅសង្កាត់គារ ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ គួរឲ្យសោកស្តាយណាស់ ដែលប្រវត្តិរូបអ្នកនិពន្ធនេះ ខ្ញុំពុំអាចស្រាវជ្រាវឲ្យអស់សេចក្តីបាន ក៏សូមប្រិយមិត្តអ្នកសិក្សាជួយបំពេញបន្ថែមចំណុចនេះឲ្យបានល្អប្រសើរទៅចុះ។

លោកហាក់ ឆៃហុក បានបន្សល់ស្នាដៃអក្សរសិល្ប៍ចំនួនពីរ ដែលយើងបានជួបប្រទះឃើញ ហើយសុទ្ធតែជារឿងដែលមានន័យខ្លឹមសារល្អសម្រាប់ជាគតិ អប់រំជីវិតមនុស្សសម័យទំនើបដែលឈ្ងក់ជាមួយវិទ្យាសាស្ត្រនោះ។

វណ្ណកម្មអក្សរសិល្ប៍ទាំងពីររបស់លោកមានដូចជា៖

- រឿងប្រុសអប្រិយស្រីរងកម្ម
-រឿងឱផ្សែងមរណ:

ជាបន្ត ដើម្បីឲ្យរិតតែស៊ីជម្រៅស្នាដៃរបស់លោកទៅទៀត ខ្ញុំដក

ស្រង់ស្នាដៃរបស់លោកមួយមកបង្ហាញជូនមិត្តអ្នកអាន គឺរឿង**ប្រុសអប្រិយស្រីរងកម្ម** ដែលមានខ្លឹមសាដូចតទៅះ

...ក្រោយពីលោករ៉ៃត្រេតបានបីឆ្នាំ កិរិយារបស់លោកក៏ទទួលអនិច្ចកម្មទៅទៀត ទុកឲ្យលោករស់នៅ ជាមួយកូនប្រុសឈ្មោះធីដេត។ សព្វថ្ងៃលោកគ្មានរបរជំនួញជួញប្រែអ្វីទេ ទុកភារៈរកស៊ីនេះ លើកូនប្រុសលោកទាំងអស់។ មួយថ្ងៃៗលោកយកចិត្តទុកដាក់តែលើធម៌អាថ៌គម្ពីរក្រាំងក្បួនខ្នាតបុរាណ។ ចំណែកធីដេតវិញ ក៏គ្មានមុខងារអ្វីក្នុងក្របខ័ណ្ឌរាជការដែរ នះគ្រាន់តែជាលេខាធិការនៅក្នុងហាងជំនួញមួយប៉ុណ្ណោះ។ បៀវត្សក្នុងមួយខែៗ ល្មមគ្រប់គ្រាន់ចាយវាយក្នុងគ្រួសារដោយមិនខ្វះមុខខ្វះក្រោយ។គួរកោតសរសើរ នូវឧត្តមគតិរបស់លោកចំរើនណាស់ ដែលលោកបានហាមប្រាមចំពោះកូន មិនចូលធ្វើការក្នុងក្រុមរាជការជាដាច់ខាត។ ផ្ទុយពីគំនិតរបស់ឪពុកម្តាយខ្លះ ខិតខំគ្រប់យ៉ាងឲ្យតែកូនរបស់ខ្លួន បានចូលធ្វើការអង្គុយកៅអី ក្នុងក្របខណ្ឌរាជការ ។ បើទោះជាកូនឯង ចំណេះវិជ្ជាមិនដល់ ក៏រត់ដើងបីដើងបួន ទៅគិតលោកនេះសូកលោកនោះ ធ្វើម៉េចឲ្យតែកូនខ្លួនមានបុណ្យសក្តិ។ ដើម្បីឲ្យគេហៅលោក ហៅព្រះតេជគុណ ហៅថៅ ដែលជាការផ្ទុយស្រឡះ ពីព្រះរាជឱវាទរបស់សម្តេចឪយើងដែលព្រះអង្គខំដឹកនាំកូនចៅឲ្យស្រឡាញ់របរកសិកម្ម ឧស្សាហកម្ម និងមុខជំនួញគ្រប់ប្រភេទ។...

ការពិតវិចិត្រអ្នកហត់ណាស់ទៅហើយ ដង្ហើមដកស្ទើរនឹងផុតខ្យល់ម្តងៗ ណាពោះក៏កាន់តែកួរទាររកអាហារ តែជាការហួសនិស្ស័យចំពោះអ្នក តើនឹងទៅរកអាហារឯណា បើអ្នកគ្មានប្រាក់ ជាពិសេសអ្នកមិនទាំងដឹងខ្លួនថា ខណៈនេះអ្នកកំពុងនៅទីណាផង។

ដើរទៅដើរទៅ ពីព្រឹករហូតដល់ថ្ងៃត្រង់ ហើយពីថ្ងៃត្រង់រហូតដល់រសៀល ជនពិការក៏មកឈប់នៅមុខភោជនីយដ្ឋានមួយ ក្ងិន

អាហារឈ្មុយឈ្ងប់ ហើរប្រដេញគ្នាមកប៉ះនឹងច្រមុះ ធ្វើឲ្យអ្នកស្រក់ទឹកមាត់ហើយលេបក្អឿកចូលទៅក្នុងពោះ ដែលកំពុងរមួលខ្លាំងៗ។ ឃ្លានណាស់......!តែធ្វើម្ដេចទៅ នឹងបានស្គាល់រសជាតិអាហារដ៏មានឱជារសនេះ បើទ្រាំឈរលេបទឹកមាត់ត្រឹមដប់នាទីទៀត អ្នកដឹងខ្លួនថា មុខជាខ្យល់គរដួលដោយអំណាចខ្វានមិនខាន។

ហួសនិស្ស័យនឹងទ្រាំតទៅទៀតកើត ជនខ្វាក់ក៏ដាច់ចិត្តប្រថុយគ្រវាសឈើច្រត់ ស្ទាបដើរចូលទៅខាងក្នុង បម្រុងនឹងលើកដៃសំពះសុំបាយបានមួយចានតូចគ្រាន់តែចម្អែតផ្ទៃមួយគ្រាប៉ុណ្ណោះ។ ប៉ុន្តែជនពិការមិនទាន់ទាំងបានចូលស៊ប់ផង បោយបម្រើភោជនីយដ្ឋាន ក៏បានបេញមកដេញច្រានអ្នកមកក្រៅវិញ យ៉ាងគ្មានប្រណី។ ជនពិការភ្នែក ខំស្ទុះរត់បេញមកបុកប៉ះនឹងតុកៅអី បណ្ដាលឲ្យជ្រមុជដួលបីបួនត្រឡប់

ក្រោកលែងរួចចុកចាប់សព្វមំសា ណាឃ្លាន ណាហត់អស់កម្លាំង។ វិចិត្រទៅជាអន្ទ័យយំដកដង្ហើមចង់ផុត។ ដូចសុនខដែលរត់ហាលថ្ងៃ ក្ដៅមកពីព្រៃ ហើយមិនទាន់បានផឹកទឹក។

មើលចុះ! តាប៉ិម្ចាស់ភោជនីយដ្ឋានគ្មានចិត្តមេត្តា ឬអើពើអ្វីបន្តិចបន្តួចទេ វាបែរមកមើលបុរសខ្វាក់បន្តិច រួចហើយក៏ទៅនិយាយជាមួយគ្នាវាពីរបីនាក់ជាភាសាចិន ហើយវាទាំងអស់គ្នាក៏សើចគិលឡើង។ ពុទ្ធោ!... ពុទ្ធោ! ឃើញគ្នាដង្ហក់ជិតស្លាប់ទៅហើយ មិនគិតជួយយកបុណ្យ បែរជានាំគ្នាមើលសើច ដូចជាតុក្កតាកំប្លែងអ្វីទៅវិញ។ ...

## ៣ លោកកែវ សូវ៉ាត

លោកអ្នកនិពន្ធម្នាក់នេះ ខ្ញុំមិនបានស្រាវជ្រាវឃើញប្រវត្តិរូបពិតរបស់លោកឃើញទេ។ តែខ្ញុំក៏បានរកឃើញស្នាដៃរបស់លោកមួយ

គឺរឿង **ចៅហ្វាយគុយ** ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ខ្ញុំបានដឹងថា លោកគឺជាអនុសេនិយឯកនៃកងយុទ្ធពលខេមរជាតិ បម្រើការនៅក្នុងសង្គមខ្មែរសម័យឆ្នាំ១៩៧១ដែរ។

ខាងក្រោមនេះ គឺជាអត្ថបទដែលខ្ញុំស្រង់ចេញពីរឿងចៅហ្វាយគុយ សូមប្រិយមិត្តអ្នកសិក្សាសិក្សាជាមួយគ្នាដូចតទៅ៖

-សម្រាប់រូបខ្ញុំគឺគ្មានចង់បានអ្វី ក្រៅពីសុំឲ្យលោកលុបបំបាត់បញ្ហាដាច់ណាត់របស់ព្រះចៅមិញម៉ាង ដើម្បីទុកទំនៀមទម្លាប់ប្រពៃណី និងព្រះពុទ្ធសាសនាខ្មែរឲ្យគង់វង្សដូចដើមវិញនោះឡើយ។ ម្យ៉ាងទៀត នៅមុនពេលដែលខ្ញុំស្លាប់ ខ្ញុំសុំឲ្យលោកអនុញ្ញាតច្បាប់ឲ្យខ្ញុំពីរយ៉ាងដូចតទៅនេះ ៖

១- សូមលោកចេញប្រកាសជាធរមាន ប្រាប់ទៅបងប្អូនខ្មែរគ្រប់ភូមិស្រុក ដែលរស់នៅលើដីកម្ពុជាក្រោមនេះ ឲ្យបានជ្រាបគ្រប់ៗគ្នាថា ព្រះពជាបញ្ញាព្រះចៅក្រុងវេ ទុកជាមោឃៈ បងប្អូនខ្មែរត្រូវតែមានសិទ្ធសេរីភាព ក្នុងការកាន់ទំនៀមទម្លាប់ប្រពៃណី និងគោរពព្រះពុទ្ធសាសនាខ្មែរឡើងវិញទាំងអស់។

២- ក្នុងខណៈដែលលោកបណ្ដើរខ្ញុំយកទៅសម្លាប់ ទោះបីកន្លែងណា ឬដោយវិធីណាក៏ដោយ សូមលោកអនុញ្ញាតឲ្យខ្ញុំបានជួបមុខប្រជាជាតិ ចំនួនកន្លះម៉ោងជាមុនសិន ដើម្បីសំណេះសំណាលគ្នាឲ្យអស់ចិត្តមុនពេលដែលត្រូវស្លាប់។

មេទ័ពយួនអុងឡូវស្ដាប់ពួហើយ ក៏ងក់ក្បាលញាប់ស្មេក បញ្ជាក់នូវការយល់ព្រមដោយមិនបាច់ព្រាងទុក៖

-ការសម្រេចចិត្តរបស់លោកនេះប្រសើរមែន! ខ្ញុំជឿជាក់ថា ព្រះ

ចៅក្រុវមិនជំទាស់នឹងបំណងនេះទេ។

... ... ...

-ខ្ញុំរីករាយចិត្តខ្លាំងណាស់ ដែលបានជួបមុខបងប្អូនរួមលោហិតទាំងអស់ នៅមុនពេលខ្ញុំផុតជីវិតនេះ។ ខ្ញុំសូមអភ័យទោស ពីសំណាក់បងប្អូនជាទីស្នេហា និងព្រះសង្ឃទាំងអស់ ដោយខ្ញុំព្រះករុណាខ្ញុំបាទពុំមានសមត្ថភាពគ្រប់គ្រាន់នឹងបម្រើជាតិមាតុភូមិ។ ដូច្នេះខ្ញុំត្រូវតែបញ្ចប់ជីវិតជូនជាតិដោយពុំស្តាយស្រណោះសោះឡើយ។

ឥឡូវនេះ ទំនៀមទម្លាប់ព្រះពុទ្ធសាសនា និងប្រពៃណីខ្មែរយើងត្រូវទាមទារបានមកវិញហើយ។ ហេតុនេះ សូមបងប្អូនរួមជាតិខ្មែរទាំងអស់នាំគ្នាថែរក្សាឲ្យបានគង់វង្សរៀងរហូតទៅ កុំឲ្យមានថ្ងៃផុតរលត់ឡើយ។

សូមបងប្អូនចាំនិងយល់ឲ្យច្បាស់ថា ពូជខ្មែរយើងជាពូជអ្នកចម្បាំង ធ្លាប់មានកេរ្តិ៍ឈ្មោះល្បីសុះសាយពេញសកលលោក។ ហេតុនេះយើងត្រូវតែមានស្មារតីរឹងប៉ឹង រួមសាមគ្គីគ្នាជានិច្ច កុំជឿពាក្យចាក់រុកបោកប្រាសបំបែកបំបាក់របស់សត្រូវ ឬលក់ក្បាលបម្រើនយោបាយដ៏ខ្មៅងងឹតរបស់វា ដោយគិតតែពីប្រយោជន៍បុណ្យសក្តិ មាសប្រាក់ផ្ទាល់ខ្លួនឲ្យសោះ។

នៅទីបញ្ចប់នេះ ខ្ញុំជឿជាក់ថា ខ្ញុំម្នាក់ស្លាប់ទៅ នៅមានបងប្អូនកូនខ្មែរជំនាន់ក្រោយជាច្រើនលាននាក់ទៀត ដែលមានឧត្តមគតិខ្ពង់ខ្ពស់ហ៊ានប្តូរជីវិត ដើម្បីការពារបូរណភាពទឹកដី សេរីភាព និងព្រះពុទ្ធសាសនាខ្មែរឲ្យគង់វង្សពុំខាន។

សូមបងប្អូនរស់នៅឲ្យបានសុខសប្បាយគ្រប់ៗគ្នាទាំងអស់ចុះ...

## ៤ លោកគគ្គ ប៊ុនឈឿន

លោកប្រសូតនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៣៩ នៅភូមិបឹងព្រីងឃុំថ្មគោល ស្រុកបាត់ដំបង ខេត្តបាត់ដំបង ប៉ុន្តែក្រោយមក ស្រុកកើតកលយុគ សំបុត្រកំណើតដើមក៏ត្រូវបាត់អស់ ទើបលោកត្រូវចុះទីកន្លែងកំណើតថ្មីនៅភូមិចំការសំរោង ឃុំចំការសំរោង ស្រុកសង្កែ ខេត្តបាត់ដំបងវិញ។

ឪពុកលោកឈ្មោះ គគ្គ ឈិន មានទីកន្លែងកំណើតនៅឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ឪពុកលោកមិនមែនជាអ្នកនិពន្ធ ឬ អ្នកអក្សរសាស្ត្រទេ ប៉ុន្តែគាត់ចេះភាសាបារាំងយ៉ាងស្ទាត់ហើយអាចបង្រៀន ភាសានេះបានទៀតផង ប៉ុន្តែគាត់បែរជាធ្វើកាប៉ូរ៉ាល់គ្រប់គ្រងសម្ភារៈឧស្សាហកម្មប្រចាំឃ្លាំងស្រែបារាំង និងតំបន់បឹងព្រីង។

ម្ដាយរបស់លោកនាម ម៉ ភីង ជាអ្នកស្រុកព្រៃកហ្លួង ស្រុកសង្កែ ខេត្តបាត់ដំបង។

លោកមានបងប្អូនទាំងអស់ពីរនាក់ គឺគគ្គ ប៊ុនធោម និងលោកគគ្គ ប៊ុនឈឿន។

លោកអាយុបាន៨ឆ្នាំ ឪពុកលោកក៏បាននាំទៅសិក្សាថ្នាក់កុមារដ្ឋាន និងបរិវេចដ្ឋាននៅសាលាវត្តពោធិវាល។ បន្តមកទៀត លោកក៏បានប្រឡងចូលរៀននៅវិទ្យាល័យព្រះមុនីវង្ស រហូតប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សា (ឌីប្លូម) នឹងត្រូវបង្ខំចិត្តឈប់រៀនត្រឹមតែប៉ុណ្ណោះព្រោះតែមានជីវភាពក្រីក្រលំបាកពេក។

នៅឆ្នាំ១៩៥៣ ឪពុករបស់លោកក៏ត្រូវទទួលសមរណភាពទៅ ខណៈនោះលោកមានអាយុទើបតែ១៤ឆ្នាំប៉ុណ្ណោះ។ កេរមរតកដែល

បានបន្សល់ទុក គឺមានតែកាសែតជាភាសាបារាំងពីរហើប ព្រោះឪពុកលោកចូលចិត្តអានកាសែតបារាំងណាស់ ក្រៅពីនេះ នៅមានសៀវភៅកំណត់ហេតុ នៃព្រឹត្តិការណ៍ផ្សេងៗជាច្រើនក្បាលដែលកាលនោះលោកមិនអាចយល់សេចក្ដីដែលបានចារនៅក្នុងនោះបាន។ ចុងក្រោយគឺសៀវភៅកំណាព្យខ្លីៗ លាយជាមួយធម៌អាថ៌មួយកូនសៀវភៅតូចៗ។ ចំណុចពិសេសដែលនាំឲ្យលោកក្លាយជាអ្នកនិពន្ធ គឺបណ្ដាលមកពីសេចក្ដីឈឺចាប់ កម្សត់ទុរគតនេះឯងដែលបណ្ដាលឲ្យលោកចេះពិចារណា ទៅតាមគំនិតរបស់ខ្លួន រួមផ្សំជាមួយនិស្ស័យដែលបានផ្ដល់ពីកំណើត ផងដែរ។

តាមការស្រាវជ្រាវ លោកគង្គ ប៊ុនឈឿន គឺជាកំពូលអ្នកនិពន្ធម្នាក់ដែលបានបន្សល់ទុកស្នាដៃជាច្រើន បម្រើវិស័យអក្សរសិល្ប៍ខ្មែរ។ លោកគឺជាអ្នកនិពន្ធតែម្នាក់ នឹងបានឆ្លងកាត់របបសង្គមរស់នៅជាច្រើនជាងគេ។ បទពិសោធជីវិតរបស់លោកមានច្រើនរាប់មិនអស់។ ទោះបីជាសព្វថ្ងៃ ក៏លោកនៅតែបន្តអាជីពជាអ្នកនិពន្ធដដែលទោះបីជាត្រូវនិរទេសខ្លួនទៅរស់នៅប្រទេសន័រវ៉េ ព្រោះតែស្នាដៃខ្លួនក៏ដោយ។

ស្នាដៃអក្សរសិល្ប៍សំខាន់ដែលខ្ញុំទទួលបានមានដូចជា៖

**ស្នាដៃមិនទាន់បោះពុម្ព**

| | | |
|---|---|---|
| ១ | រឿង ស្រុកសត្វ | ឆ្នាំ ១៩៥៥ |
| ២ | រឿងរាជនីដួងចិត្ត | ឆ្នាំ ១៩៥៥ |
| ៣ | រឿងកែវកល្យា | ឆ្នាំ ១៩៥៥ |
| ៤ | រឿងឆ្នេសមុទ្រវេក | ឆ្នាំ ១៩៥៦ |
| ៥ | ខ្សែទឹកភ្លូច | ឆ្នាំ ១៩៥៦ |
| ៦ | រឿងអ្នកលេងវាលអន្ទក់ | ឆ្នាំ ១៩៥៦ |

៧ រឿងកូនស្រីអ្នកនេសាទ ឆ្នាំ ១៩៥៦

៨ រឿងស្នេហាលុះអវសាន្ត ឆ្នាំ ១៩៥៦

៩ រឿងនាងរំសាយសក់ ឆ្នាំ ១៩៥៦

១០ រឿងផ្កាយដូចដើងមេឃ ឆ្នាំ១៩៧១

១១ រឿងបឹងទឹកស្នេហ៍ ឆ្នាំ១៩៧១

១២ រឿងឆ្នាំមុន ឆ្នាំ១៩៧១

១៣ រឿងអណ្តើកស៊ីត្រកួន ឆ្នាំ១៩៧១

១៤ រឿងព្រហ្មលិខិតឥតប្រណី ឆ្នាំ១៩៧១

១៥ រឿងផ្កាយប្រដាប់ចិត្ត ឆ្នាំ១៩៧១

## ស្នាដៃបានបោះពុម្ពរួច

១ រឿងតំណក់ទឹកភ្នែកនារី បោះពុម្ពឆ្នាំ ១៩៥៧

២ រឿងលោហិតនារី បោះពុម្ពឆ្នាំ ១៩៥៨

៣ រឿងពេជ្ឈឃាតក្រមុំ បោះពុម្ពឆ្នាំ ១៩៥៨

៤ រឿងក្រឡាហោមផល បោះពុម្ពឆ្នាំ ១៩៥៨

៥ រឿងកូលាបពោយ បោះពុម្ពឆ្នាំ ១៩៦០

៦ រឿងស្នេហាចិត្តមួយ បោះពុម្ពឆ្នាំ ១៩៦១

៧ រឿងលីដែកលក់ជីវិត បោះពុម្ពឆ្នាំ ១៩៦២

៨ រឿងវិមាននរក បោះពុម្ពឆ្នាំ ១៩៦៣

៩ រឿងនេះគឺកម្មបង បោះពុម្ពឆ្នាំ ១៩៦៣

១០ រឿងភ្លើងជីវិត បោះពុម្ពឆ្នាំ ១៩៦៣

១១ រឿងទឹកភ្នែកឪពុក បោះពុម្ពឆ្នាំ ១៩៦៤

១២ រឿងចានហោះ បោះពុម្ពឆ្នាំ ១៩៦៥

១៣ រឿងតិច! ក្បាលមួយកន្ត្រងប្រហុក បោះពុម្ពឆ្នាំ ១៩៦៥

១៤ **រឿងមានលុយស៊ីបាយផ្សារ អត់លុយស៊ីបាយផ្ទះ** បោះពុម្ពឆ្នាំ ១៩៦៥

១៥ រឿងកន្ទង់បាក់ស្លាប កូឡាបបាក់ទង បោះពុម្ពឆ្នាំ ១៩៦៥

១៦ រឿងសីលធម៌និងដុំបាយ បោះពុម្ពឆ្នាំ ១៩៦៦

១៧ រឿងមួយរៀលពីររៀលកុំនាំភ្លើង បោះពុម្ពឆ្នាំ ១៩៦៦

១៧ រឿងអាសាច់ជូនម្តាយ បោះពុម្ពឆ្នាំ ១៩៦៦

១៨ រឿងទឹកភ្នែកពេលព្រលប់ បោះពុម្ពឆ្នាំ ១៩៦៦

១៩ រឿងព្រះរាជសម្ភារ បោះពុម្ពឆ្នាំ ១៩៦៦

២០ រឿងព្រះបាទជ័យវរ្ម័នទី៧ បោះពុម្ពឆ្នាំ ១៩៦៧

២១ រឿងកលិយុគនៅលង្វែក បោះពុម្ពឆ្នាំ ១៩៦៧

២២ រឿងម្រាមប្រាំបួន បោះពុម្ពឆ្នាំ ១៩៦៧

២៣ រឿងព្យុះដាវយុត្តិធម៌ បោះពុម្ពឆ្នាំ ១៩៦៧

២៤ រឿងដាវសែងសូរិយា បោះពុម្ពឆ្នាំ ១៩៦៨

២៥ រឿងកំណាប់រាជ បោះពុម្ពឆ្នាំ ១៩៦៨

២៦ រឿងពណ្ណរាយក្នុងដែនមច្ចា បោះពុម្ពឆ្នាំ ១៩៦៨

២៧ រឿងបុប្ផាពស់វែក បោះពុម្ពឆ្នាំ ១៩៦៩

២៨ រឿងឥន្ទ្រីកុមារ បោះពុម្ពឆ្នាំ ១៩៦៩

២៩ រឿងស៊ីបាយបោកឆ្នាំង បោះពុម្ពឆ្នាំ ១៩៧០

៣០ **រឿងម៉ែអើយៗម៉ែ មិនចង់ធ្វើស្រែចង់ធ្វើលោកស្រី** បោះពុម្ពឆ្នាំ ១៩៧០

៣១ រឿងឯណាអនាគតវា ? បោះពុម្ពឆ្នាំ ១៩៧០

៣២ រឿងបេះដូងជូនស្នេហា សង្ខារជូនជាតិ បោះពុម្ពឆ្នាំ ១៩៧០

៣៣ រឿងអន្ទាក់នាងឆ្មាព្រៃ បោះពុម្ពឆ្នាំ ១៩៧០

៣៤ **រឿងបុរសស្ដឹងមាស ប្រយុទ្ធនឹងស្តេចទន្ទះខ្មៅ** បោះពុម្ពឆ្នាំ ១៩៧០

៣៥ រឿងកាមាសូត្រា បោះពុម្ពឆ្នាំ ១៩៧១
៣៦ រឿងខ្ទមកាមទេព បោះពុម្ពឆ្នាំ ១៩៧១
៣៧ រឿងលោហិតខ្មែរអង្គរ បោះពុម្ពឆ្នាំ ១៩៧២
៣៨ **រឿងសាច់មាន់ទៅនៅទគរ រងទឹក រងខ្យល់** បោះពុម្ពឆ្នាំ ១៩៧២
៣៩ រឿងខ្លាដំរី បោះពុម្ពឆ្នាំ ១៩៧២
៤០ រឿងពលទោអភ័ព្វ បោះពុម្ពឆ្នាំ ១៩៧២
៤១ រឿងពលទោគន្ធា បោះពុម្ពឆ្នាំ ១៩៧២
៤២ រឿងម្ចាស់ក្បួនអប្រិយ បោះពុម្ពឆ្នាំ ១៩៧២
៤៣ រឿងក្មេងការក្មេងកម្ម បោះពុម្ពឆ្នាំ ១៩៧២
៤៤ រឿងចំប៉ាបន្ទាយដែក បោះពុម្ពឆ្នាំ ១៩៧២
៤៥ រឿងកំពង់ចាមដែនសោកា បោះពុម្ពឆ្នាំ ១៩៧៣
៤៦ រឿងទឹកភ្នែកកូលាបបាត់ដំបង បោះពុម្ពឆ្នាំ ១៩៧៣
៤៧ រឿងជំនោរប៉ៃលិន បោះពុម្ពឆ្នាំ ១៩៧៣
៤៨ រឿងសែនស្តាយថ្ពាល់ស្តាំ បោះពុម្ពឆ្នាំ ១៩៧៣
៤៩ រឿងជ្រោះនាងខ្មៅ បោះពុម្ពឆ្នាំ ១៩៧៣
៥០ រឿងពស់វែកព្រៃ បោះពុម្ពឆ្នាំ ១៩៧៣
៥១ រឿងល្អាងគ្រុឌមាស បោះពុម្ពឆ្នាំ ១៩៧៣
៥២ រឿងរាហ៊ូចាប់ច័ន្ទ បោះពុម្ពឆ្នាំ ១៩៧៣
៥៣ រឿងកញ្ចក់មរណៈ បោះពុម្ពឆ្នាំ ១៩៧៣
៥៤ រឿងបញ្ជីលោហិត បោះពុម្ពឆ្នាំ ១៩៧៣
៥៥ រឿងស្លៀកខ្យល់ដណ្តប់មេឃ បោះពុម្ពឆ្នាំ ១៩៧៣
៥៦ រឿងទារុណកម្មក្នុងជំរុំខ្មាំង បោះពុម្ពឆ្នាំ ១៩៧៣
៥៧ រឿងបានត្រឹមសោកា បោះពុម្ពឆ្នាំ ១៩៧៤

៥៨ រឿងនេះគឺរឿងខ្ញុំ បោះពុម្ពឆ្នាំ ១៩៧៤
៥៩ រឿងកាត់កន្ទុយលាបកំបោរ បោះពុម្ពឆ្នាំ ១៩៧៤
៦០ រឿងដៃដែក៣២ បោះពុម្ពឆ្នាំ ១៩៧៤
៦១ រឿងមុំមាសស្នេហ៍ បោះពុម្ពឆ្នាំ ១៩៧៤
៦២ រឿងស្បៃអក្ខពចំប៉ាបាណន់ បោះពុម្ពឆ្នាំ ១៩៧៤
៦៣ រឿងផ្សូងភ្លើងចាស់ បោះពុម្ពឆ្នាំ ១៩៧៤
៦៤ រឿងរាត្រីកាលដ៏យូរលង់ បោះពុម្ពឆ្នាំ ១៩៧៤
៦៥ រឿងសល់តែទឹកភ្នែក បោះពុម្ពឆ្នាំ ១៩៧៤
៦៦ រឿងស្នឹមក្រអូប បោះពុម្ពឆ្នាំ ១៩៧៤
៦៧ រឿងស្នេហាព្រៃផ្សៃ បោះពុម្ពឆ្នាំ ១៩៧៤
៦៨ រឿងសាមកុក បោះពុម្ពឆ្នាំ ១៩៧៥
៦៩ រឿងមុខមួយភ្នែកបួន បោះពុម្ពឆ្នាំ ១៩៧៥
៧០ រឿងផ្លូវដើរមានមួយ បោះពុម្ពឆ្នាំ ១៩៧៩
៧១ រឿងអង្គរអើយនិយាយទៅ បោះពុម្ពឆ្នាំ ១៩៨០
៧២ រឿងល្ខោនក្រៅឆាក បោះពុម្ពឆ្នាំ ១៩៨១
៧៣ រឿងចោរកំសត់ បោះពុម្ពឆ្នាំ ១៩៨១
៧៤ រឿងអណ្តាតភ្លើងក្នុងដួងព្រលឹង បោះពុម្ពឆ្នាំ ១៩៨២
៧៥ រឿងស្លឹកឈើចាកមែក បោះពុម្ពឆ្នាំ ១៩៨៥
៧៦ រឿងអ្នកដើរកាត់ព្យុះ បោះពុម្ពឆ្នាំ ១៩៨៧
៧៧ រឿងផ្លូវសេត្វា បោះពុម្ពឆ្នាំ ១៩៩៥
៧៨ រឿងរន្ទះដាវពញាយ៉ាត បោះពុម្ពឆ្នាំ ១៩៩៥
៧៩ រឿងរំដួលឯកក្នុំ បោះពុម្ពឆ្នាំ ១៩៩៥
៨០ រឿងអំពិលអំពែក បោះពុម្ពឆ្នាំ ១៩៩៦

៨១ រឿងព្រាយក្លាមស្រងែ បោះពុម្ពឆ្នាំ ១៩៩៧

៨២ រឿងបេះដូងក្រៅទ្រូង បោះពុម្ពឆ្នាំ ២០០០

៨៣ រឿងវាសនានាងម៉ារីណា បោះពុម្ពឆ្នាំ ២០០០

៨៤ កំណាព្យស្នេហ៍មាស បោះពុម្ពឆ្នាំ ២០០១

៨៥ រឿងកម្ពុជាខ្វង់ខែក ?

៨៦ រឿងឥន្ទ្រីខ្មៅលើភ្លៅកាមទេព ?

៨៧ បណ្ដាំកវី (កំណាព្យ) ?

៨៨ ទំនួញស្វាបប៉ាកាមាស ?

## ស្នាដៃដែលមានសេសសល់ក្នុងរោងពុម្ពអំឡុងឆ្នាំ១៩៧៥

១ រឿងមេឃាភ្នំពេញ តាកបាត់ដំបង

២ រឿងដានជើងក្របី

៣ រឿងរំដួលដងស្ទឹងសង្កែ

៤ រឿងស្ពានយោលដាច់ខ្សែ

៥ រឿងពន្លឺក្នុងភ្នែកខ្វាក់

៦ រឿងអាក្រក់បំផុតគឺមនុស្ស

៧ រឿងលាហើយសោភានី

៨ រឿងប្រទីបនៃធម៌

៩ រឿងផ្សែងទៀននៃជីវិត

១០ ព្រះអាទិត្យទី៧

## ស្នាដៃដែលបានថតជាខ្សែភាពយន្ត

១ រឿងយំមួយពាន់ដង ថតឆ្នាំ១៩៨៨

២ រឿងសែនទារុណ ថតឆ្នាំ១៩៨៩

៣ រឿងអូនឈឺចិត្តណាស់ ថតឆ្នាំ១៩៨៩

៤ រឿងកាត់ចិត្តទាំងអាល័យ ថតឆ្នាំ១៩៨៩

៥ រឿងត្រកូនក្មេចបឹង ថតឆ្នាំ១៩៨៩

៦ រឿងព្រះគុណម៉ែ ថតឆ្នាំ១៩៨៩

៧ រឿងជំនោរប៉ៃលិន ថតឆ្នាំ១៩៩០

៨ រឿងទុកស្នេហ៍ជូនបង ថតឆ្នាំ១៩៩០

៩ រឿងស្លៀកខ្យល់ដណ្តប់មេឃ ថតឆ្នាំ១៩៩១

១០ រឿងកូលាបបាត់ដំបង ថតឆ្នាំ១៩៩១

១១ រឿងនាងរំសាយសក់ ថតឆ្នាំ១៩៩២

១២ រឿងឥន្ទ្រីកុមារ ថតឆ្នាំ១៩៩៣

១៣ រឿងចៅស្រទបចេក ថតឆ្នាំ១៩៩៣

១៤ រឿងយក្សច្រលំសតវត្ស ថតឆ្នាំ១៩៩៣

១៥ រឿងបុប្ផាពស់វែក ថតឆ្នាំ១៩៩៣

ក្រៅពីស្នាដៃដែលបានរៀបរាប់ខាងលើ លោកនៅមាននិពន្ធស្នាដៃជាច្រើនទៀតដែលខ្ញុំស្រាវជ្រាវមិនបានដឹង។ ការរៀបខាងលើ គឺគ្រាន់ជាវណ្ណកម្មដែលលោកប្រារព្ធឡើងនៅត្រឹមអំឡុងឆ្នាំ២០០០ប៉ុណ្ណោះ។

ខាងក្រោមនេះ គឺជាទំនុកបទចម្រៀងដែលជាស្នាដៃរបស់លោក គង្គ ប៊ុនឈឿនដែលបានតែងឡើងនៅក្នុងអំឡុងឆ្នាំ១៩៧០ ហើយដែលដែលពេលនេះ ខ្ញុំនឹងលើកយកមួយបទមកបង្ហាញជូនមិត្តអ្នកសិក្សាដូចខាងក្រោមនេះ

## ស្អាតឈើអនិច្ច

I ភូមិវត្តកំផែង រៀមសូមថ្លែងទុក្ខ ស្នេហ៍ខានជួបមុខវាយជាទំនុកគុកកម្ម ស្នេហ៍ខ្ញុំ ស្អាតកម្សត់ក្សត់ស្នេហ៍ឧត្តម ក្សត់រាត្រីចន្ទ្រាទឹកឃ្មុំតោយំសុំក្តីមេត្តា។

II ឱ!វាលបែកចានបែកចិត្តទៅហើយ ស្នេហ៍គ្មានកោះត្រើយ ស្ទឹងសង្កែអើយម្តេចឡើយឬស្សា ក្បួចស្នេហ៍ខ្ញុំឲ្យលង់មរណា ក្បួចទាំងចិត្តឲ្យស្វិតដូចផ្កា ខ្លោចផ្សារឱព៉ាមួហ្មង។

R គ្រាប់ខ្សាច់បាតស្ទឹងរៀមប្រឹងរក្សា ទុកពោយធ្វើជាផ្កាស្លា រៀបការអូនហើយនិងបង ស្អាតឈើរៀមទុកឲ្យអូនឆ្លង តែកម្មកាចកំណាចកន្ទង់ នួនល្អងឆ្លងស្អាតគេវិញ។

III បងឈឺកកណាមដូចអ៊ុក សារ៉ែន ឈឺហួសព្រះដែន ស្រីចិត្តម៉ឺនសែននឹកសែនទោម្នេញ បេះដូងមួយឲ្យគេដូរទិញ ដូចទឹកស្ទឹងហូរមិនវិលវិញ ទោម្និញព្រោះស្រីចិត្តស្រស់។

ក្រោពីនេះ នៅមានអ្នកនិពន្ធជាច្រើនទៀតដែលលោកបានផ្សព្វផ្សាយស្នាដៃខ្លួន ដែលបានទ្រទ្រង់រស្មីអក្សរសិល្ប៍ឲ្យរឹតតែមានភាពភ្លឺថ្លាថែមទៀត។ អស់លោកទាំងនោះរួមមានដូចជា៖

**១ លោករស់ ចន្ទ្រាបុត្រ** សរសេររឿងដូចជា៖

-រឿងម្ចាស់ប្តីដួងចិត្តអូន ១៩៦៦

-រឿងអាម៉ុក ឬជនវិកលចរិតនៅម៉ាឡេស៊ី បកប្រែ ១៧១

**២ លោក ឃុន ស្រ៊ុន** សរសេររឿងដូចជា៖

-កម្រងកំណាព្យ គំហើញទី១ ១៩៧០

-កម្រងកំណាព្យ គំហើញទី២ ១៩៧០

-កម្រងកំណាព្យ គំហើញទី៣ ១៩៧០

-សម្រស់ជីវិត ការផ្សាយរបស់ស្នេ ១៩៧១

-កម្រងរឿង លំនៅចុងក្រោយ ១៩៧២

-សិក្សាកថា ជនជាប់ក្រោយ ១៩៧៣

៣ លោក **ឡាំង ប៉េងសៀក** សរសេររឿងដូចជា៖

-រឿងព្រលឹងម៉ែ ១៩៧០

-រឿង ទោសពានរាំង ១៩៧១

-រឿង តាករៀងរះ ១៩៧១

-រឿង មេចោរកំបុតក ១៩៧១

-រឿង ខ្មោចចិត្តនៅឡាបានសៀក ១៩៧១

-រឿង មហាចោរនៅក្នុងដងវែក ១៩៧១

-រឿង ស្រងេះស្រងោច ១៩៧១

-រឿង ខ្យល់កំបុតត្បូង ១៩៧៣

៣ លោក **ស៊ូ ចំរើន** សរសេររឿងដូចជា៖

-រឿង វីរជនសង្គ្រាមជ័យ ១៩៧០

-រឿង អាចារ្យស្វា ១៩៧១

-រឿង អាម៉ៅក្ដៅខ្មែរ ១៩៧១

-រឿង ពោធិកំបោរ ១៩៧១

# អក្សរសិល្ប៍សម័យកម្ពុជាប្រជាធិបតេយ្យ
# ១៩៧៥-១៩៧៩

## **សង្ខេបប្រវត្តិ**

### **ចិត្តភាពចូលទៅអក្សរសិល្ប៍សម័យកម្ពុជាប្រជាធិបតេយ្យ**

*មតិរបស់អ្នកសិក្សាតែចាត់ទុកថា នៅសម័យកម្ពុជាប្រជាធិបតេយ្យ គឺជាសម័យយុគសៅងងឹតដែលចរន្តអក្សរសិល្ប៍ខ្មែរត្រូវបានជាប់គាំងមិនបានធ្វើសកម្មភាព ផ្សព្វផ្សាយចូលដល់បណ្ដាជនទៅនៅក្នុងប្រទេស។ តាមការពិតនៅសម័យកម្ពុជាប្រជាធិបតេយ្យ ចរន្តអក្សរសិល្ប៍ខ្មែរ មិនបានក្រាបឱនដូចអ្វីដែលបានសិក្សានាពេលកន្លងមកទេ។ អក្សរសិល្ប៍ខ្មែរសម័យនេះ គ្រាន់តែជាផ្នែកមួយនៃសង្គមដែលបម្រើដល់ការគ្រប់គ្រងអំណាចរបស់មេដឹកនាំប៉ុណ្ណោះ។ ប្រជាជនដែលបានរស់នៅនិងឆ្លងកាត់តែងតែចេះចាំបទចម្រៀង និងរឿងរបស់បដិវត្តន៍ជានិច្ច។*

*នៅសម័យកម្ពុជាប្រជាធិបតេយ្យ អក្សរសិល្ប៍ដែលលេចជារូបរាងឡើង គឺជារូបភាពរឿងបដិវត្តន៍ ជាអត្ថបទកំណាព្យតែងជាទំនុកច្រៀង ពាក្យស្លោក និងមានភ្ជាប់នូវអត្ថន័យផ្សេងៗដែលបម្រើដល់ការគ្រប់គ្រងប្រទេសឲ្យមានស្ថេរភាព។*

*មកដល់សម័យកម្ពុជាប្រជាធិបតេយ្យ ចរន្តអក្សរសិល្ប៍ខ្មែរគឺពុំមែនជាស្នាដៃប្រលោមលោក ទំនើបបែបមនោសញ្ចេតនាស្នេហានោះទេ*

តែវាគឺជារឿងបដិវត្តន៍ខ្លីដែលអ្នកនិពន្ធបានសរសេរឡើង ក្រោមប្រធានបទ **តស៊ូវណ្ណៈរំដោះប្រទេសជាតិ ការរួបរួមគ្នាធ្វើជាសហករណ៍**។

ការផ្សព្វផ្សាយវណ្ណកម្មដែលបាននិពន្ធឡើង គឺត្រូវបានធ្វើតាមរយៈការចុះផ្សាយតាមទស្សនាវដ្តី**យុវជនយុវនារីបដិវត្តន៍ ទស្សនាវដ្តីកង់ទ័ព**ជាដើម។ ចំណែកចម្រៀងបដិវត្តន៍វិញ គឺគេបានច្រៀងមិនឈប់ឈរក្នុងគោលបំណងបម្រើគោលនយោបាយ និងមាត់បដិវត្តន៍របស់អ្នកដឹកនាំនៅសម័យនោះ។

បើយោងតាមលោក**សោម សុមុនី** ក្នុងបទសម្ភាសអំពី**ចម្រៀងសម័យកម្ពុជាប្រជាធិបតេយ្យ**បានឲ្យដឹងថា ចម្រៀងបដិវត្តន៍សម័យកម្ពុជាប្រជាធិបតេយ្យមានពីរដំណាក់កាលធំៗគឺ៖

**ដំណាក់កាលទី១** សម័យរណសិរ្ស ជាដំណាក់កាលសង្គ្រាមបង្ហាញ ពីការតស៊ូរបស់ខ្មែរក្រហមប្រឆាំងនឹងពួកចក្រពត្តិអាមេរិកនិងលន់ នល់ បទចម្រៀងនេះបានលើកឡើងពីការប្រយុទ្ធ និងកំហឹងគំនុំវណ្ណៈ។

**ដំណាក់កាលទី២** ក្រោយទទួលជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ អត្ថន័យបទចម្រៀងច្រើនលើកយកពីការរំឭកអនុស្សាវរីយ៍ នៃការតស៊ូបដិវត្តន៍ជាងប្រាំឆ្នាំកន្លងមក។ ក្នុងដំណាក់កាលនេះ បទចម្រៀងបដិវត្តន៍បានលើកយកវិន័យអង្គការ វិន័យកុមារ វិន័យយុវជនយុវនារី វិន័យកម្មាភិបាលដើម្បីពង្រឹងបដិវត្តន៍។ នៅដំណាក់កាលនេះខ្លឹមសារនៃបទចម្រៀងទាក់ទងទៅនឹងការបង្កបង្កើនផល រៀបរាប់ពីទេសភាពសម្រស់មាតុភូមិ សោភ័ណភាពវាលស្រែ គឺនាំឲ្យយើងមានគំនិតជាតិនិយមតាមរយៈធម្មជាតិផងដែរ។ បទចម្រៀងច្រើនលើកយកពីអំនួតបេតិកភ័ណ្ឌ មកនិយាយដើម្បីបង្ហាញអំពីអំណាចខ្លាំងពូកែរបស់

ខ្មែរកាលពីអតីតកាល និយាយអំពីសម្រស់ធម្មជាតិដើម្បីធ្វើឲ្យប្រជាជនមានអារម្មណ៍ធូរស្រាល មិនគិតពីគំនុំ កំហឹង មិនដូចដំណាក់កាលទីមួយដែលច្រើនតែលើកយកពីប្រវត្តិក្នុងការតស៊ូឡើយ។

គោលនយោបាយដ៏ភ្លឺថ្លារបស់របបកម្ពុជាប្រជាធិបតេយ្យ គឺអ្នកដឹកនាំដែលបានតាំងខ្លួនជាអង្គការនោះ បានខិតខំបង្កបង្កើតគំនិត វប្បធម៌ថ្មីរបស់ខ្មែរខុសពីទម្លាប់ចាស់ តែប្រកាន់គោលការណ៍ចាស់ៗមួយចំនួនមកជាតឹកតាងក្នុងការបង្កើតថ្មីនេះ។ មានន័យថា អ្វីដែលចាស់គឺគេបានយកមកធ្វើជាទ្រឹស្តីបទ រួចក៏បង្កើតអ្វីដែលថ្មី ដែលគេយល់ថាល្អសម្រាប់បម្រើគោលនយោបាយដ៏ឆើតរបស់គេ។ ក្នុងន័យនេះដែរ ទំនៀមទម្លាប់ សាសនា ប្រពៃណី រួមទាំងទំនុកបទចម្រៀង សិល្បៈភាពយន្ត វប្បធម៌នៃការប្រាស្រ័យទាក់ទងក្នុងជីវភាពប្រចាំថ្ងៃត្រូវបានបំបាត់ចោល នឹងត្រូវបានហាមឃាត់ដាច់ខាត ព្រមទាំងព្រមានសម្លាប់ចោលក្នុងករណីណាមាន ប្រជាជនរឹងរូសនៅតែគោរពប្រតិបត្តិតាមឱវាទចាស់

តែបើទោះបីជាមានការហាមប្រាម យ៉ាងដាច់អហំការក៏ដោយក៏ប្រជាជននៅតែរក្សាទំនៀមទម្លាប់ក្នុងផ្លូវចិត្តជាប្រចាំ ពិសេសគឺការគោរពបូជាសាសនា ក៏នៅតែមានក្នុងសន្តានចិត្តដដែល។ ប្រហែលជាអ្នកដឹកនាំយល់ពីស្ថានភាពនេះហើយ បានជាគេបានរៀបចំរចនាអ្វីដែលមានថ្មី ដែលគេបានបង្កើតនោះដោយបានយកទម្រង់ចាស់មកបញ្ចូលជាមួយទម្រង់ថ្មី បើមើលតែសម្បកក្រៅនឹងឃើញថា មានការកែប្រែទាំងស្រុង តែរូបភាពពិត អ្វីដែលមានចាស់ គឺត្រូវបានដូរតែរូបរាងខាងក្រៅ តែអ្វីដែលជាស្នូលពិតគឺនៅរក្សាដដែល ដូចជាបទចម្រៀងដែលបាននិពន្ធឡើងគឺគោរពតាមចង្វាក់រាំវង់ រាំក្បាច់ សារ៉ាវ៉ាន់ ឡាំលាវជាដើម។ មួយវិញទៀត សិល្បៈក្នុងការសរសេរកំណាព្យគឺនៅរក្សាបទ

ចំណាប់ចួនដើមដូចជា បទពាក្យ៧ បទពាក្យ៨ នឹងមានការគោរព ចំណាប់ចួនបានត្រឹមត្រូវ។

ចំពោះពាក្យពេចន៍ក៏មានការ ប្រើបានល្អល្អងល្អាយណាស់ដែរ ដោយគោរពតាមក្បួននិយាមអក្សរសាស្ត្រជាតិ ដូចជាមានការប្រើពាក្យ ជាលក្ខណៈវប្បធម៌ ជ្រៅជ្រះតាមលក្ខណៈមនោគមវិជ្ជា ពាក្យបម្រើដល់ ការគ្រប់គ្រងប្រទេស បម្រើបដិវត្តនៅសម័យនោះ។

ទោះបីជាវិស័យតែងនិពន្ធ ត្រូវបានបំបិទមិនឲ្យសេរីដូចសម័យ មុនៗក្តី តែអ្វីដែលពួកបដិវត្តបានកសាងឡើង គឺជាព្រឹត្តិការណ៍ពិត ជា សាច់រឿងជាក់ស្តែង ដែលបង្កការឈឺចាប់ដល់មនុស្សរស់ក្នុងសង្គមឲ្យ មានសេចក្តីឈឺចាប់។ ស្នាដៃដែលអ្នកនិពន្ធបានផលិតឡើង ត្រូវបានធ្វើ ការផ្សព្វផ្សាយតាមរយៈទស្សនាវដ្តី ឬក៏មានការសម្តែងសិល្បៈតំបន់ឲ្យ ប្រជាជនបានទស្សនានៅពេលរាត្រីបានម្តងម្កាល។ ក្នុងន័យនេះ ចង់ និយាយថា គេបានរៀបចំក្រុមសិល្បៈគ្រប់តំបន់សម្រាប់ការសម្តែងនៅ ឱកាសពេលធ្វើមីទិញធំៗម្តងម្កាល ដែលមានការចូលរួមពីគណៈភូមិ ភាគ តំបន់ ស្រុក ឃុំ។

ការសម្តែងសិល្បៈ ដែលជារូបភាពនៃការផ្សព្វផ្សាយអក្សរសិល្ប៍ នៅសម័យនោះ គឺគេចែកចេញជាបួនធំៗគឺ៖

១ **សិល្បៈស្រុក:** គឺគេបានរើសចេញពីមូលដ្ឋានចាស់ដែលរស់នៅ សម្រាប់យកមកសម្តែងនៅក្នុងស្រុកខ្លួន។ អ្នកសម្តែង គឺគេចែកជាអ្នក សម្តែងចម្រៀង ល្ខោន អាយ៉ៃ ដែលអ្វីទាំងនេះ គឺសុទ្ធតែមានការពង្រឹង អំណាចកុម្មុយនិស្ត។ អ្នកសិល្បៈនៅស្រុកក៏អាចទៅសម្តែងនៅស្រុកដទៃ បានអាស្រ័យដោយការស្នើពីមូលដ្ឋាននោះ។

២ **សិល្បៈតំបន់:** ពាក្យតំបន់នេះ គឺមានទំហំប្រហាក់ប្រហែលនឹង

ខេត្តដែរ។ ការសម្តែងសិល្បៈនេះ គឺមានរូបភាពប្រហាក់ទីងការសម្តែងនៅស្រុកដែរ តែទាស់ត្រង់ថា សិល្បៈតំបន់នេះមានឧបករណ៍ភ្លេងទំនើបជាងនៅស្រុក ហើយរឿងដែលបានសម្តែងភាគច្រើនជារឿងល្បីប្រចាំតំបន់ដែលមានការបម្រើឲ្យនយោបាយបក្សទាំងស្រុង។ តួអង្គសំខាន់ៗនៅក្នុងរឿងគឺត្រូវបានជ្រើសមកពីអ្នកសិល្បៈនៅស្រុក បានន័យថា អ្នកដែលសម្តែងសិល្បៈនៅស្រុកបានល្អគឺត្រូវជ្រើសរើសបន្តទៅតំបន់ទៀត។

៣ **សិល្បៈភូមិភាគ:** ភូមិភាគនៅសម័យកម្ពុជាប្រជាធិបតេយ្យ ត្រូវបានបែងចែកចេញជា៦ភូមិភាគ មានដូចជាភូមិភាគបូព៌ា ភូមិភាគនីរតី ភូមិភាគបស្ចិម ភូមិភាគពាយ័ព្យ ភូមិភាគឧត្តរ និងភូមិភាគឦសាន។ សិល្បៈភូមិភាគ គឺជាសិល្បៈប្រចាំភូមិភាគនីមួយៗដែលមានទីតាំងនៅក្នុងប្រទេស។ សិល្បៈភូមិភាគនេះ មិនមានការខុសគ្នាពីសិល្បៈស្រុក សិល្បៈតំបន់ទេ តែខុសត្រង់ថា សិល្បៈភូមិភាគគឺមានឧបករណ៍រិតតែទំនើប នៅពេលសម្តែង មានពន្លឺភ្លើងអគ្គិសនីតែការសម្តែងនេះ គឺសម្រាប់តែជួរកម្មាភិបាលជំនាន់នោះទស្សនាប៉ុណ្ណោះ។ ជួរកម្មាភិបាលដែលបានទស្សនាល្ខោនប្រភេទនេះ គឺនៅបន្ទាប់ពីពួកគេបានបញ្ចប់សិក្ខាសាលាពង្រឹងនយោបាយបក្ស ដែលមានរយៈពេលមិនតិចជាងពីរខែទេ។

៤ **សិល្បៈមជ្ឈិម:** ជាសិល្បៈថ្នាក់ជាតិដែលមាននៅតែទីក្រុង។ការសម្តែងគឺសម្រាប់ឥស្សរជនជាន់ខ្ពស់ទស្សនាប៉ុណ្ណោះ។

ប្រជាជនដែលបានទៅចូលរួមទស្សនាសិល្បៈ គឺសុទ្ធតែមានការស្នើពីប្រធានមូលដ្ឋានឲ្យទៅចូលរួមទស្សនា។ គេត្រូវហូបអាហារពេលល្ងាចឲ្យរួចរាល់នៅវេលាភ្លឺ រួចប្រជាជនដែលរស់នៅតាមភូមិនាំគ្នាទៅទស្សនាមិនមាននរណាខកខានឡើយ។ ពេលចូលទៅដល់កន្លែង

សម្រាប់ទស្សនាសិល្បៈ គឺមានមេក្រុមដើរសម្ញឹងមុខយកវត្តមានអ្នកដែលមិនបានចូលរួមទស្សនាល្ខោនៗ ការសម្តែងល្ខោនម្តងៗគឺមានការចូលរួមទស្សនាពីសំណាក់ប្រជាជនច្រើនណាស់ៗ មួយវិញទៀតប្រជា-ជនដែលបានចូលទស្សនានេះ គឺត្រូវអង្គុយទៅតាមភូមិ និងមានជួរបន្ទាត់យ៉ាងច្បាស់លាស់ៗ នរណាដែលអង្គុយខុសជួរត្រូវមានទោស ឬមានតិទៀនមិនខានៗ

ប្រជាជនដែលទៅទស្សនាល្ខោន គឺមិនត្រូវឲ្យដេកឡើយ ប្រសិនមាននរណាដេកនៅពេលល្ខោនកំពុងសម្តែង មេក្រុមដែលដើរពិនិត្យនោះ នឹងទាត់ ឈូសនឹងជើងឲ្យភ្ញាក់វិញៗ ម្យ៉ាងទៀតអ្នកដែលទៅទស្សនា គឺអាចអនុញ្ញាតបានតែការជក់បារី ហូបទឹកបត់ជើងតូច-ធំ តែត្រូវត្រលប់មកកន្លែងដើមវិញៗ

ក្រៅពីផ្សព្វផ្សាយអក្សរសិល្ប៍ជាលក្ខណៈសិល្បៈ ក៏នៅមានការផ្សព្វផ្សាយតាមប្រព័ន្ធវលកជាតុអាកាសដែរ ដោយនៅសម័យនោះមានវិទ្យុបក្សៗ អ្នកដែលបានស្តាប់មានតែជួរកម្មាភិបាលប៉ុណ្ណោះៗ ចំណែកការផ្សាយតាមរយៈទស្សនាវដ្តីក៏មានសកម្មភាពណាស់ដែរ ដោយអត្ថ-ន័យនិយាយតែពីកំហឹងឈឺចាប់ជាមួយពួកចក្រពត្តិ និយាយពីរឿងតស៊ូក្នុងន័យបដិវត្តប៉ុណ្ណោះៗ

ចំណែកខាងសៀវភៅវិញ នៅសម័យកម្ពុជាប្រជាធិបតេយ្យក៏មានការផ្សព្វផ្សាយណាស់ដែរ ដែលសៀវភៅទាំងអស់នោះគឺត្រូវបានបោះពុម្ពផ្សាយដោយអង្គការមានដូចជា៖

-សៀវភៅទស្សនាវដ្តីកម្ពុជា ចេញផ្សាយជារៀងរល់ខែ

-សៀវភៅទស្សនាវដ្តីយុវជននិងយុវនារីបដិវត្តន៍ ចេញផ្សាយជារៀងរាល់ខែដែលជាទស្សនាវដ្តីអប់រំរបស់សម្ព័ន្ធយុវជនកុម្មុយនិស្ត

កម្ពុជា។

-សៀវភៅវីរភាពរបស់ប្រជាជននិងកងទ័ពកម្ពុជា ភាគ១

១ រឿងពលីកម្មរបស់ម៉ែៗយើង

២ រឿងបេះដូងក្រហមរបស់យុវជនដាំផេង

៣ រឿងគំនុំវណ្ណៈ

៤ រឿងបណ្តាំឪពុក

៥រឿងស្នារតីឈ្លាសវៃរបស់កុមារឃ្លាលក្របីក្នុងការចាប់ខ្មាំង

-សៀវភៅវីរភាពរបស់ប្រជាជននិងកងទ័ពកម្ពុជា ភាគ២

១ រឿងកសិករក្រីក្រដាច់ខាតឈរនៅខាងបដិវត្តន៍

២ រឿងរស់ដើម្បីតស៊ូរំដោះប្រទេសជាតិរំដោះប្រជាជននិងរំដោះវណ្ណៈក្រីក្រ

៣ រឿងខ្ញុំវាយខ្មាំងទាល់តែវារលំរលាយអស់ពីកម្ពុជា

-សៀវភៅវីរភាពរបស់ប្រជាជននិងកងទ័ពកម្ពុជា ភាគ៣

១ រឿងសូមមិត្តប្រគលភារកិច្ចដ៏ឧត្តមនេះមកឲ្យខ្ញុំចុះ

២រឿងជីវិតរបស់យុទ្ធមិត្តសាយជាជីវិតអមតៈស្ថិតស្ថេរជានិច្ចនៅក្នុងព្រលឹងជាតិយើង

៣ រឿងស្មារតីវៃឈ្លាសរបស់ប្រជាជនចាប់គិញ

ចំណែករឿងខ្លីនានា ដែលបានចុះផ្សាយតាមទស្សនាវដ្តីមានដូចជារឿង៖

-**រឿង ពលីកម្មរបស់យុទ្ធមិត្តយើង** ចុះផ្សាយតាម

- ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តន៍ លេខ២ ខែកុម្ភៈ ឆ្នាំ១៩៧៦

- ទស្សនាវដ្តីយុវជននិងយុវនារីបដិវត្តន៍ លេខ៣ ខែមីនា ឆ្នាំ១៩៧៦

*-រឿងយុវនារីជនធ្វើពលីកម្មគ្រប់បែបយ៉ាងដោយឥតគិតល័ក្ខខ័ណ្ឌ* **ដើម្បីបដិវត្តន៍និងប្រជាជន** ចុះផ្សាយតាម

*-ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តន៍ លេខ៤ ខែមេសា ឆ្នាំ ១៩៧៦*

*-ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តន៍លេខ៧ ខែកក្កដា ឆ្នាំ ១៩៧៦*

*នៅខាងក្រោមនេះ ខ្ញុំនឹងដកស្រង់សាច់រឿង ក៏ដូចជាចម្រៀងកំណាព្យ ដែលបានកើតឡើងនៅសម័យកម្ពុជាប្រជាធិបតេយ្យមកបង្ហាញជូនមិត្តអ្នកអានដូចតទៅៈ*

## ស្នាដៃអត្ថបទកំណាព្យ

**យុវជន យុវនារីកម្ពុជាសូមប្រសិទ្ធពរជ័យមហាប្រសើរជូនចំពោះបក្សកុម្មុយនីស្តកម្ពុជាដ៏រុងរឿង**[១]

*បក្សកុម្មុយនិស្តកម្ពុជា ប្រសូត្រនៅនាថ្ងៃ៣០*
*កញ្ញា១៩៦០ ប្រជាចាំជាប់គ្រប់ៗគ្នា ។*
*បក្សយើងកកើតពេញលក្ខណៈ មានលក្ខន្តិកៈមានមាគ៌ា*
*មានជំហរឯករាជម្ចាស់ការ ជាប្រទីបថ្ងៃថ្លាប្រាប់ទិសដៅ។*
*គ្រាន់តែបក្សកកើតឡើងភ្លាម បក្សមិននៅស្ងៀមសំងំនៅ*
*បក្សចុះប្រឡូកចូលយ៉ាងជ្រៅ ក្នុងចលនាក្តៅសាងកំឡាំង។*
*ប្រជាជនក្រីក្រគ្រប់ជនបទ ស្គាល់ច្បាស់ប្រាកដមិត្តនិងខ្មាំង*
*កំហឹងពុះពារឈឺចាប់ខ្លាំង ស្ទុះក្រោកប្រឆាំងខ្លាំងចង្រៃ ។*

---

[១] **ខ្ញុំយកអក្ខរាវិរុទ្ធតាមច្បាប់ដើមដែលបានបោះពុម្ពនៅសម័យនោះ**

មីទិញបាតុកម្ម កុប្បកម្ម សស្រាក់ស្រាំជាប់ពល់ថ្ងៃ
អាមេរិកនិងបរិវាដើងដៃ ត្រូវបរាជ័យបន្តបន្ទាប់ ។
បក្សកុម្មុយនិស្តកម្ពុជា ប្រយុទ្ធពុះពារយ៉ាងស្វាហាប់
ដើរមុខប្រជាក្រក្រីជាប់ ក្តោបក្តាប់វាសនាជាតិផ្ទាល់ដៃ ។
កំឡាំងបដិវត្តន៍តិចតួចទេ ហើយសុទ្ធសឹងតែអ្នកក្រក្រី
ស្បៀងខ្វះ អាវុធខ្វះ ឥតមានអ្វី មានតែស្មារតីនិងមាគ៌ា ។
តែដោយស្មារតីបក្សដាច់ខាត ឈ្លាសវៃឆ្លៀវឆ្លាតជាតុម្ចាស់ការ
គិតគូរខ្លួនឯងគ្រប់បញ្ហា ឈរលើសភាពការណ៍ពិតជាក់ស្តែង ។
តែដោយមាគ៌ាបក្សត្រឹមត្រូវ លេចចេញជាផ្លូវភ្លឺច្បាស់ទៃង
លេចជាកម្លាំងខ្លាំងក្រៃលែង មិនចេះហួតហែងរីងស្រកចុះ ។
៦១-៦២-៦៣ រហូត៦៨អាវុធផ្ទុះ
ពួកក្មាំក្នុងក្រៅនៅពេលនោះ ប៉ងស្ទុះក្រញឹមកម្ទេចយើង ។
កំហឹងប្រជាជនពុះពារ សន្ធោសន្ធៅដូចភ្លំភ្លើង
ទៅមុខប្រយុទ្ធខ្លាំងទ្វេរឡើង បុកគាស់រំលើងខ្មាំងយកជ័យ ។
បក្សកុម្មុយនិស្តកម្ពុជា ឈរលើសភាពការណ៍ឆ្នាំ៦៨
ឃើញច្បាស់កម្លាំងយើងខ្លាំងក្រៃ កំណត់ទិសថ្មីវាយបន្ត ។
៧០-៧១-៧២ ខ្មាំងគ្រប់ទិសទីភ័យរីករវរ
ស្ថានការណ៍លិចលង់ផុងធ្ងន់ធ្ងរ គ្មានអីទប់ទ្រជាប់នៅបាន ។
ឆ្នាំ៧៣ខ្មាំងស្ទន់ស្ទោខ្លាំង អាមេរិកកាំងចោរសាមាន្យ
ប្រមូលយន្តហោះដែលវាមាន ពីគ្រប់ទីឋានវាយកម្ពុជា ។
វាប៉ងវាយយើងឲ្យខ្ទេចខ្ទី ឲ្យស្ទុតស្មារតីសារភាពវា
ឲ្យយើងដាក់អាវុធទៅចរចា ដើម្បីវាស្តារស្ថានការណ៍ថ្មី ។
តែបក្សកុម្មុយនិស្តកម្ពុជា អង់អាចក្លៀវក្លាឆ្លាតវៀងវៃ

ការពារដាច់ខាតជាតិទឹកដី ប្រជាជនប្រុសស្រីនិងបដិវត្តន៍។
បក្សយើងដាច់ខាតមិនចរចា ដាច់ខាតមិនសារភាពចក្រពត្តិ
ដាច់ខាតមិនចាញ់សត្យានុមតិ អត្តនោមតិត្រូវឈ្នះជ្រោកជ។
១៧មេសា៧៥ សង្គ្រាមវិនាសកម្មត្រូវរលត់
ប្រទេសជាតិវណ្ណៈក្រខ្សត់ រំដោះរួចផុតជាស្ថាពរ ។
ប្រជាជនកម្ពុជាក្រុងជនបទ ជាម្ចាស់បដិវត្តន៍ម្ចាស់នគរ
ម្ចាស់ស្រែចំការម្ចាស់ភូមិករ ម្ចាស់លើរបស់របរគ្មានសល់អ្វី ។
១៥ឆ្នាំបក្សសម្រេចបានយ៉ាងស្អាត បដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យ
ហើយបានបន្តជ្រោងត្រើ ទង់បដិវត្តន៍ថ្មីសង្គមនិយម ។
បក្សបន្តដឹកនាំបោសសំណល់ ចំហាយឥទ្ធិពលនៃសង្គម
ចក្រពត្តិ-អាណានិគមនិយម នាយទុនសក្តិភូមិឲ្យរលាយ ។
បក្សបន្តអប់រំយើងខ្ញុំ ជ្រួតជ្រាបរឹងមាំជំហរថ្មី
ធ្វើបដិវត្តន៍សង្គមនិយមការពារទឹកដី សាងកម្ពុជាថ្មីល្បីថ្កើងថ្កាន។
បក្សបានលើកស្ទួយជីវភាពប្រជា កើនឡើងធូរធារគ្រប់ៗប្រាណ
មានស៊ីមានចុកស្លៀកពាក់បាន សមរម្យថ្កើងថ្កានកើនរាល់ឆ្នាំ ។
បក្សបានប្រែក្លាយកម្ពុជាយើង ដែលខ្ទេចដោយភ្លើងសង្គ្រាមវិនាសកម្ម
មកជាសួនស្រូវសួនដំណាំ រោងចក្រតូចធំ រោងចក្រថ្មី ។
បើសិនគ្មានបក្សម្ទេះទឹកដី ប្រជាប្រុសស្រីគ្រប់ទិសទី
ព្រមទាំងយើងខ្ញុំយុវជន-យុវនារី រលាយរលត់ផុតពីពិភពលោក។
ដោយសារមានបក្សទើបយើងខ្ញុំ ផុតក្តីក្រៀមក្រំផុតទុក្ខសោក
ផុតការជិះជាន់ផុតទាបថោក ហើយបានឡើងមកជាម្ចាស់ប្រទេស។
គុណបក្សកុម្មុយនិស្តកម្ពុជា ចំពោះប្រជាជនក្មេងចាស់
ជាតិនិងទឹកដីធ្ងន់ធ្ងណាស់ ពិតប្បាស់គ្មានអ្វីប្រៀបបានទេ ។

យើងខ្ញុំសូមស្ដេជ្ញារៀនសូត្រ ស្ដេជ្ញាប្រយុទ្ធឲ្យខ្លាំងទ្វេ
ប្រយុទ្ធការពារបក្សនិងមាគ៌ា ទឹកដីប្រជាយ៉ាងមោះមុត។
មិនឲ្យខ្មាំងណាទោះជិតឆ្ងាយ ខ្មាំងលេបទឹកដីនិងពួកក្បត់
ប៉ះពាល់ឈ្លានពានជាដាច់ខាត វាយឲ្យខ្ទេចខ្ទាតក្ស័យមរណា។
យើងខ្ញុំយុវជន-យុវនារី សូមប្រសិទ្ធិពរថ្លៃថ្លា
ជូនបក្សកុម្មុយនិស្តកម្ពុជា ដោយមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅ។
សូមបក្សមានសុខភាពល្អ មានគោលជំហរក្រហមឆ្អិនឆ្អៅ
ដឹកនាំយើងខ្ញុំតរៀងទៅ តាមមាគ៌ាត្រឹមត្រូវគ្មានវៀត ។
សំរេចនូវមហាជោគជយា ក្នុងកិច្ចការពារ-កសាងជាតិ
ក្នុងការបន្តធ្វើបដិវត្តន៍ សង្គមនិយមទៀតរៀងរហូត ។

## ស្នាដៃអត្ថបទចម្រៀង

### សូមកូនៗចងចាំប្រពៃណីរស់នៅរបស់បដិវត្តន៍រៀងរហូត

ស្រី: ឱ!កូនពន្លកកូនមកជិតម្ដាយ ពុកម៉ែបរិយាយប្រាប់
ដល់មាសថ្លៃ
ចូរកូនចងចាំៗមួយជីវី
រក្សាប្រពៃណីបដិវត្តន៍ផងយើង ។
ប្រុស: កូនអើយទំពាំបាយដូចសព្វថ្ងៃ
សង្គមជាតិថ្មីយុត្តិធម៌រុងរឿង
ប្រជាជនយុទ្ធជនកម្មាភិបាលយើង
ពលីក្នុងភ្លើងច្រើនឥតគណនា។
ស្រី មិត្តយើងបានឆ្លងឧបសគ្គច្រើនក្លាត់

រស់ក្នុងសម្ងាត់តឹងតែងវេទនា
អាខ្មាំងតាមដានគ្មានលុះពេលណា
ព្រាត់ប្រាស់គ្រួសារពុំដែលជួបមុខ។

ប្រុស ពេលថ្ងៃពួននឹងស្ដាកខ្ចមកសិករ
ពេលយប់ចុះមកដឹកនាំសត្វមុខ
ហូបពុំដែលឆ្អែត ដេកពុំដែលលក់
រាប់ឆ្នាំញ៉ាំញ៉ក់សុខភាពខ្ចាំខ្ចេច ។

ស្រី នៅពេលចេញដើរៗដើងទទេ
ឡើងភ្នំរាប់ខែ កាត់ថ្មព្រៃព្រិច
ដេកផ្ទាល់នឹងដី កៅស៊ូរហែក
ភ្លៀងសាចភ្លៀងលិច អង្គុយញ័រញាក់ ។

ប្រុស ក្រោយមកទើបបានដេកក្នុងអង្រឹង
យកព្រៃស្វាត់ឈឹងធ្វើផ្ទះសំណាក់
ពន្លឺថ្ងៃចូលមិនដល់ ងងិតមូសទាក
គ្រុនចាញ់គ្រុនញាក់តែដាច់ខាតតស៊ូ ។

ស្រី ខោអាវផាឱបតែមួយចង្កេះ
ពុកផុយរលេះរហែករយ៉ង
ពេលបោកម្ដងៗអង្គុយចាំញ័រ
ស្ងួតហើយស្លៀកតចូលភូមិធ្វើការ។

ប្រុស ពេលខ្មាំងឡោមព័ទ្ធនីរសាត្រូវដាច់
ហូបក្លួចគល់ចេកជំនួសបបរ
បាត់ហេវគ្រុនចាញ់ ហូបឫសឈើវល្លិ៍
ស្គាំងស្គមស្លាំងសតែចិត្តក្រហមឆ្អៅ ។

ស្រី	កូនអើយនេះហើយជីវភាពបង៉ៗ
	រាប់សិបឆ្នាំកន្លង បានត្រួសត្រាយផ្លូវ
	ជីវភាពបដិវត្តន៍ក្រហមឆ្អិនឆ្អៅ
	ដែលនាំមកនូវសព្វថ្ងៃមនោរម្យ ។

ប្រុស	ហេតុនេះសព្វថ្ងៃកូនរស់ស្រួលដូចចិត្ត
	កូនត្រូវប្រយ័ត្នៗជំហរទ្រោម
	កូនត្រូវរក្សាប្រពៃណីបដិវត្តឲ្យក្រហម
	កម្មសិទ្ធសមរម្យគឺស្បោងមួយតូច ។

ស្រី	កូនចាំឲ្យច្បាស់ឱណាមាសម្ដាយ
	ពេលកូនហូបបាយកូននឹកដល់ក្អួច
	ពេលកូនស្លៀកល្អ នឹកដល់ឈាមស្រោច
	ពេលណាកូនសើច នឹកដល់មិត្តៗកំព្រា ។

រួមគ្នា	សូមកូនសំលៀងជំហរបដិវត្តន៍
	ឲ្យស្រួចរហូតក្រហមថ្ងៃថ្លា
	សីលធម៌រស់នៅទៅតាមមាគ៌ា
	លុះទើបជានាបដិវត្តន៍អវសាន្ត ។

រួមគ្នា	ឱ! កូនមាសថ្លៃកូនសំឡាញ់អើយ
	កូនកុំធ្វើអ្វីនាំឲ្យរំខាន
	ផុះខាត់ប្រពៃណីជាអ្នកបន្តវេន
	ទុកកេរថ្កើងថ្កានអមតៈណាកូនអើយ ។

រួមគ្នា	ឱ! កូនមាសថ្លៃកូនសំឡាញ់អើយ
	កូនកុំធ្វើអ្វីនាំឲ្យរំខាន
	ផុះខាត់ប្រពៃណីជាអ្នកបន្តវេន

ទុកគេរថ្កើងថ្កានអមតៈណាកូនអើយ ។

## ចម្រៀងបក្ស

### សង្គមអនាគត

ក្រោកឡើងអស់អ្នកខ្ញុំគេទាំងប៉ុន្មាន
ក្រោកឡើងអស់អ្នកតោកយ៉ាកពាល់ប្រាណ
ក្តៅណាស់ចុកណែនស្ទើរប្រេះដើមទ្រូងធ្លាយ
គ្រាម្តងនេះស្លាប់រស់មិនស្តាយ ។
របបចាស់យើងបំផ្លាញឲ្យអស់ឆាប់
អស់អ្នកខ្ញុំគេក្រោកឡើងទៅ
ថ្ងៃស្អែករបបថ្មីផងយើងបានវិញ
ប្រយោជន៍ទាំងប៉ុន្មានធ្លាក់បានដៃយើង ។
បន្ទរ តស៊ូនេះគ្រាចុងបំផុតរួមគ្នាមកដល់ថ្ងៃមុខ
L'Internationale គឺជាសង្គមអនាគត
តស៊ូនេះគ្រាចុងបំផុតរួមគ្នាមកដល់ថ្ងៃមុខ
L'Internationale គឺជាសង្គមអនាគត ។

## ភ្លេងជាតិកម្ពុជាប្រជាធិបតេយ្យ

### ១៧ មេសា មហាជោគជ័យ

១ ឈាមក្រហមច្រាល ស្រោចស្រព ក្រុងវាល
កម្ពុជា មាតុភូមិឈាមកម្មករ កសិករដ៏ឧត្តម
ឈាមយុទ្ធជន យុទ្ធនារីបដិវត្តន៍ ។
២ ឈាមប្រែក្លាយជា កំហឹងខ្លាំងក្លា តស៊ូមោះមុត

១៧មេសា ក្រោមទង់បដិវត្តន៍ ឈាមរំដោះផុត
ពីភាពខ្ញុំគេ។

**បន្ទរ** ជយោ ជយោ ១៧ មេសា
ជោគជ័យមហាអស្ចារ្យ មានន័យធំធេង លើស
សម័យអង្គរ!

៣ យើងរួមរួមគ្នា កសាងកម្ពុជា និងសង្គមថ្មីបវរ
ប្រជាធិបតេយ្យ សមភាព និងយុត្តិធម៌
តាម មាគ៌ា ម្ចាស់ការ ឯករាជ រឹងមាំ។
ដីឧត្តម បដិវត្តន៍ដ៏រុងរឿង!

**បន្ទរ**
ជយោជយោ ជយោ កម្ពុជាថ្មីប្រជាធិបតេយ្យ
សម្បូរថ្កុំថ្កើង! ស្តេជ្វា ជ្រោងគ្រវី ទង់បដិវត្តន៍ក្រហម
ខ្ពស់ឡើង សាងមាតុភូមិយើង ឲ្យចំរើនលោតផ្លោះ
មហារុងរឿង មហាអស្ចារ្យ។

ក្រៅពីបទចម្រៀង កំណាព្យទាំងនេះ នៅសម័យកម្ពុជាប្រជាធិប-តេយ្យក៏នៅមានស្នាដៃរឿងខ្លីៗជាច្រើនទៀត ដែលស្នាដៃទាំងនេះ សុទ្ធសឹងតែបម្រើដល់បដិវត្តន៍បក្ស បំផុសសេចក្តីឈឺចាប់ដល់ប្រជាជនជាមួយរបបចាស់ទាំងអស់។ នៅមានចំណុចមួយទៀតនោះគឺថា កុសលរសដែលបង្កប់យ៉ាងល្អនៅក្នុងវណ្ណកម្មនេះ គឺចង់ប្រាប់ដល់អ្នកទស្សនាថា គ្មានរបបណាដែលល្អជាងរបបកម្ពុជាប្រជាធិបតេយ្យទេ មានតែរបបនេះមួយគត់ ដែលការរស់នៅរបស់ប្រជាជនមិនមានការបែងចែកវណ្ណៈ។

រឿងភាគច្រើនត្រូវបានផ្សាយតាមរយៈការសម្តែងសិល្បៈ។ ការនិយាយបែបនេះមិត្តអ្នកអានអាចមានចម្ងល់ថា នៅសម័យនោះមានសិល្បៈដែរ? ជាការពិតណាស់ សម័យកម្ពុជាប្រជាធិបតេយ្យក្រុមសិល្បៈគឺគេបង្កើតតាំងពីថ្នាក់ស្រុក រហូតថ្នាក់ខេត្ត សម្រាប់តែការសម្តែងបម្រើដល់នយោបាយដ៏ឆ្កួតលីលារបស់ពួកវាប៉ុណ្ណោះ ពោលសាច់រឿងគឺមានតែការឈឺចាប់ ខ្លោចផ្សារ និងការតស៊ូរបស់ក្រុមពួកវាមុនពេលបានកាន់អំណាចប្រយុទ្ធផ្តួលរំលំជាមួយរបបចាស់។

តាមរយៈឪពុកម្តាយខ្ញុំ អ៊ុំខ្ញុំដែលបានរស់នៅឆ្លងកាត់ក្នុងសម័យកាលនោះគាត់បានឲ្យដឹងថា ពេលមានការសម្តែងសិល្បៈម្តងៗ គឺប្រជាជនក្អកទឹកក្អកដីទៅទស្សនាយ៉ាងច្រើនកកកុញ។ ការសម្តែងគឺគេសម្តែងចែកជូនប្រជាជនមិនមានការគិតលុយទេ។ ការសម្តែងគឺប្រព្រឹត្តតែរវាងអំឡុងឆ្នាំ១៩៧៥ -១៩៧៦ប៉ុណ្ណោះ។ នៅតាមតំបន់នីមួយៗតែងមានរឿងប្រចាំតំបន់នោះ តែអ្វីដែលបានល្បីនៅតំបន់ខេត្តព្រៃវែងគឺមានរឿងមួយដែលអស្ចារ្យបំផុត គឺរឿង**បេះដូងក្រហមរបស់យុវជនដាំផេង** ដែលរឿងមួយនេះ ប្រជាជនខាងតំបន់មួយចំនួនធំបានចេះចាំរហូតមកដល់សព្វថ្ងៃនេះដែរ។ គាត់និយាយថា រឿងនេះកម្សត់ ហើយល្អមើលណាស់។

ការសម្តែង ក្នុងក្រុមល្ខោននោះគឺគេប្រព្រឹត្តតែពេលរាត្រី ហើយការសម្តែងនេះ គឺដើម្បីអបអរសាទរថ្ងៃបុណ្យមីទិញកាលពីថ្ងៃដែលគណៈដឹកនាំបានចុះមកសំណេះសំណាល ពង្រឹងអំណាចថ្នាក់ក្រោម។ ចំពោះការរៀបចំឆាកសម្តែងវិញ លោកឪពុក អ្នកម្តាយក៏បានឲ្យដឹងថា គេរៀបឆាកដូចជារោងល្ខោនសព្វថ្ងៃនេះដែរ តែថា ភ្លើងគឺគេប្រើភ្លើងចង្កៀងម៉ាំងសុងតែពីរបីប៉ុណ្ណោះ។ ការសម្តែង គឺប្រព្រឹត្តឡើងដោយមាន

អ្នកយាមកាមតឹងរ៉ឹងណាស់ ដូចជាមានអ្នកឲ្យការណ៍ដែលមានចម្ងាយឆ្ងាយប្រមាណជា១០០ម៉ែត្រ សម្រាប់ផ្ទុកព្នៃកាលណាមានយន្តហោះស៊ើបការណ៍របស់អាមេរិកមកដល់។ អ្នកចាំគ្រប់ពន្លឺភ្លើងម៉ាំងសុងសម្រាប់គ្រប់ពន្លឺភ្លើងម៉ាំងសុង ឲ្យរហ័សបំផុតខណៈដែលទទួលដំណឹងបានថាមានយន្តហោះខ្មាំងបានមកដល់។ បន្ទាប់មក មានអ្នកប្រកាសរំសាយប្រជាជនវិញ គឺមិនមានការសម្ដែងជាលើកទី២ទៀតទេខណៈដែលមានការប្រកាសអាសន្នម្ដងហើយ។ ឪពុកខ្ញុំថា មានម្ដងនោះ អ្នកយកការណ៍មិនទាន់ ត្រូវបានយន្តហោះអាមេរិកមកបាញ់រះខណៈដែលអ្នកគ្រប់ចង្កៀងកំពុងបំពេញការងាររខ្លួន បណ្ដាលឲ្យមានរងរបួសខ្លះស្លាប់ខ្លះ ចំណែកប្រជាជន រត់ប្រសេចប្រសាចភ័យលោះព្រលឹងគ្រប់គ្នា។

ដូច្នេះ ការផ្សាយលក្ខណៈអក្សរសិល្ប៍ឲ្យដល់មនុស្សជាតិជាជនរួមជាតិរបស់សម័យកម្ពុជាប្រជាប្រជាធិបតេយ្យ គឺប្រព្រឹត្តតាមការសម្ដែងសិល្បៈជាកត្តាចម្បង។ ក្រៅពីនេះ គឺនៅមានការបោះពុម្ពសៀវភៅដែរ តែមិនទូលំទូលាយទេ ព្រោះគ្មានអ្នកអានមានតែអ្នកធ្វើការពីព្រឹករហូតយប់ហូបតែបបរពរមួយវែក ឬពីរវែកជាមួយសម្លគល់ចេកបង់តែអំបិល ជាមួយប្រហុក ត្រីពីបីប៉ុណ្ណោះ។ អ្នកដែលមានចំណេះ ត្រូវបានអង្គការបោសសម្អាត ដូចនេះ ការផ្សាយតាមរយៈទស្សនាវដ្ដីគឺគ្រាន់តែជាការបំពេញលក្ខខណ្ឌអក្សរសាស្ត្រសម័យនោះប៉ុណ្ណោះ។ អ្នកដែលបានអាន គឺមានតែបណ្ដាឥស្សរជនរបស់វាប៉ុណ្ណោះ។ ទស្សនាវដ្ដីមានតែមួយ គឺទស្សនាវដ្ដីកង់ទ័ពដែលជាទស្សនាវដ្ដីល្បីជាងគេ បម្រើគោលនយោបាយបក្សដ៏ត្រឹមត្រូវ។

ចំពោះការប្រើពាក្យខ្មែរនៅក្នុងសម័យនោះវិញឃើញថា មាន

លក្ខណៈត្រឹមត្រូវទៅតាមអក្ខរាវិរុទ្ធដែរ។ ត្រង់ចំណុចនេះ បញ្ជាក់ថា សម័យកម្ពុជាប្រជាធិបតេយ្យ មានអ្នកដែលមានចំណេះដឹងខាងអក្សរ-សាស្ត្រជាតិជ្រៅជ្រះ តែសម្រាប់បម្រើគោលនយោបាយបក្សតែប៉ុណ្ណោះ អ្នកក្រៅពីនេះ ទោះបីជានៅកន្លែងណាត្រូវបានអ្នកដឹកនាំដែលយក ឈ្មោះជា អង្គការ រុករកឲ្យឃើញរួចយកទៅសម្លាប់ចោល ឬយកទៅរៀនសូត្រ។

ខ្ញុំសូមធ្វើការកត់សម្គាល់ថា សម័យកម្ពុជាប្រជាធិបតេយ្យ គឺជាសម័យដែលស៊ីវិល័យខាងអក្សរសាស្ត្រជាតិដែរ ព្រោះថា ពាក្យសម្ដីដែលពួកវាបានប្រើគឺមានការលាក់កំបាំងអត្ថន័យយ៉ាងជ្រាលជ្រៅ ដូចជាពេលដែលពួកវា ចង់សម្លាប់នរណាម្នាក់ ពួកវាបានប្រើពាក្យថា **យកមិត្តទៅរៀនសូត្រ** ឬថាបើចង់សម្លាប់មនុស្សជាលក្ខណៈធំដុំ គឺវាបានប្រើពាក្យថា **យកមិត្តទៅរស់នៅកន្លែងថ្មី** ឬក៏**យកមិត្តទៅរស់នៅកន្លែងខ្វាញ់** ក្រៅពីនេះ ពាក្យសម្ដីដែលប្រើក្នុងកាដឹកនាំ ជាពាក្យបដិវត្តន៍ទាំងស្រុង ដែលធ្វើឲ្យអ្នកនៅក្រោមអំណាច បាក់ស្បាតរហូតដល់សព្វថ្ងៃក៏មានដែរ។

ដើម្បីឲ្យរឹតតែច្បាស់បន្ថែមទៀត សូមមិត្តអ្នកអាន អញ្ជើញអានរឿងបេះដូងក្រហមរបស់យុវជនដាំផេង ដែលជាស្នាដៃអក្សរសិល្ប៍ដ៏ឯកមួយ នឹងល្បីល្បាញនៅខេត្តព្រៃវែងដូចតទៅ៖

## រឿងបេះដូងក្រហមរបស់យុវជនដាំផេង[១]

យុវជនដាំផេង កើតនៅស្រុកបាភ្នំ ខេត្តព្រៃវែងក្នុងត្រកូលកសិករក្រមួយ។ ឪពុកម្ដាយដាំផេង ក៏ដូចកសិករក្រដទៃទៀតនៅទូទាំងប្រទេស

[១] អក្ខរាវិរុទ្ធនេះ ខ្ញុំមិនបានកែប្រែពីអត្ថបទច្បាប់ដើមទេ ខ្ញុំរក្សាឲ្យនៅដដែល

កម្ពុជាដែរ ម្យ៉ាងត្រូវអាណានិគមបារាំងជិះជាន់សង្កត់សង្កិន ខាងសិទ្ធសេរីភាព នយោបាយ ទាំងខាងជីវភាពស្មារតី នឹងសំភារៈ។ ហើយម្យ៉ាងទៀត ត្រូវពួកសក្តិភូមិ នាយទុននៅក្នុងប្រទេស ជិះជាន់ ឆក់ប្លន់ នឹងកេងប្រវ័ញ្ច ជារៀងរាល់ថ្ងៃ ថែមពីលើនេះមួយជាន់ទៀត។ ម្លោះហើយ គ្រួសារដាំផេង នឹងគ្រួសារកសិករក្រឯទៀតទាំងអស់ ត្រូវរស់នៅក្នុងរណ្តៅទុក្ខវេទនា ក្រខ្សត់អត់ឃ្លាន ខ្វះមុខខ្វះក្រោយ យ៉ាងសែនឈឺចាប់ខ្លោចផ្សា ជាអាចិន្ត្រៃយ៍ គ្មានពេលណាល្ហែឡើយ។ តាំងពីកើតឃើញពន្លឺព្រះអាទិត្យកាលណាមក ដាំផេង បានដឹង បានឃើញ នឹងបានស្គាល់តែរសជាតិ នៃជីវភពតោកយ៉ាកខ្លោចផ្សានេះ។ ដោយជីវភាពលំបាកវេទនាខ្លាំងពេក ម្ហូបអាហារក៏មិនគ្រប់គ្រាន់ សំលៀកបំពាក់ក៏ខ្វះខាត ក្មេងៗស្រាតខ្លួនទទេ រាល់ព្រឹករាល់ល្ងាច ហើយថ្នាំសង្កូវក៏គ្មានសោះតែម្តង បងប្អូនប្រុសស្រីរបស់ដាំផេង ក៏ឈឺស្លាប់ឲ្យរពុយជាបន្តបន្ទាប់។ បន្ទាប់មក ឪពុកម្តាយដាំផេងក៏ឈឺស្លាប់ ជាបន្តបន្ទាប់ទៀត។ ទីបុងបំផុត គ្រួសារនេះនៅសល់តែមនុស្សពីរនាក់ គឺបងស្រីម្នាក់ នឹងដាំផេងខ្លួនឯងម្នាក់។ ពេលនោះដាំ ផេង មានអាយុប្រហែល៧ឆ្នាំ ឬ៨ឆ្នាំប៉ុណ្ណោះ។ ឯបងស្រី ក៏ទើបតែធំទង់ដែរ។ ដូច្នោះទាំងពីរនាក់បងប្អូន ត្រូវធ្លាក់ខ្លួនទៅជាក្មេងកំព្រា មួយជាន់ទៀត គ្មានទីពំនឹង ពឹងពាក់អ្វីសោះ។ បងស្រី ត្រូវបានប្រជាជនក្នុងភូមិរើសយកទៅចិញ្ចឹម។ ចំណែកកុមារដាំផេង ត្រូវបានព្រះសង្ឃរើសយកទៅចិញ្ចឹមនៅវត្ត ហើយក៏បានរៀនអក្សរ រៀនលេខជាមួយព្រះសង្ឃតែម្តងទៅ។

ក្នុងការរៀនសូត្រ ក៏ដូចក្នុងគ្រប់កិច្ចការបំរើព្រះសង្ឃ កុមារដាំផេង ពិតមែនតែនៅតូចក្មេងខ្ចី តែមានបញ្ញាវាងវៃ ហើយឧស្សាហ៍ព្យាយាម ម៉ត់ចត់ ទៀងទាត់ជានិច្ច ធ្វើឲ្យព្រះសង្ឃក្នុងវត្ត អាណិត

ស្រឡាញ់ពេញហឫទ័យគ្រប់អង្គ។ ក្រោយមកពេលរៀនចប់សាលាបឋមសិក្សាហើយ ដោយឃើញថាកុមារដាំ ផេង់រៀនពូកែផង ព្រះសង្ឃដែលទទួលខុសត្រូវចិញ្ចឹមកុមារនេះ ក៏បាននាំយកកុមារដាំ ផេង់ មកផ្ញើនឹងព្រះសង្ឃ នៅវត្តសារាវ័ន្តដើម្បីឲ្យបន្តវិជ្ជា នៅភ្នំពេញទៀត។ ពេលនោះ កុមារដាំ ផេង់ធំពេញជំទង់ហើយ។កុមារបានប្រឡងចូលរៀនថ្នាក់ទី៦នៅវិទ្យាល័យយុគន្ធរ។

ពេលរស់នៅក្នុងវត្តសារាវ័ន្ត ដើម្បីបន្តការសិក្សានៅមធ្យមសិក្សាទៀត យុវជនដាំ ផេង់ ត្រូវគិតគូរដោះស្រាយជីវភាពសិក្សាដោយខ្លួនឯងទាំងអស់។ ព្រោះក្នុងសង្គមអាណានិគមសក្តិភូមិ នាយទុន រដ្ឋវាគ្មានគិតគូរជួយឧបត្ថម្ភអ្វី ដល់យុវជនសិក្សាបន្តិចសោះឡើយ។ ពួកវាមានតែពង្វក់បំពុលយុវជនឲ្យភ្លើតភ្លើន ទៅតាមមនោគមវិជ្ជាជិះជាន់របស់វា ឲ្យជក់ចិត្តជក់គំនិត លង់ខ្លួនទៅតាមវប្បធម៌ពុករលួយ រវើរវាយ លទ្ធិលន្ទោចតែប៉ុណ្ណោះ។ ហើយម្យ៉ាងទៀត វាធ្វើច្បាប់តឹងតែង កៀបគៀតយុវជន ដែលជាកូនចៅប្រជាជនក្រីក្រ កុំឲ្យរៀនសូត្របានវែងឆ្ងាយ ដូចកូនចៅពួកវា។ ម្នោះហើយ យុវជនដាំ ផេង់ ក៏ដូចជាយុវជនក្រីក្រផ្សេងទៀត ដែលចង់បន្តការសិក្សាទៅទៀត ត្រូវបង្ខំចិត្តលក់កម្លាំងឲ្យពួកសក្តិភូមិ នាយទុន ពេលសំរាកពីការរៀនសូត្រ ដើម្បីបានប្រាក់បន្តិចបន្តួចគ្រាន់ទិញសៀវភៅរៀន ទិញខោអាវស្លៀកពាក់ នឹងទិញម្ហូបចំណីខ្វះៗ។ យុវជនដាំ ផេង់ ពេលថ្ងៃទៅរៀននៅសាលា ពេលយប់ឆ្លៀតលក់នំប៉័ងឬជួលស៊ីក្លូគេរត់ គ្រាន់បានកំរៃខ្វះ ផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ។ ពេលបុណ្យទាន ឬវិស្សមកាលដែលឈប់សំរាកយូរថ្ងៃ យុវជនដាំ ផេង់ទៅស៊ីឈ្នួលរែកកំបោរ រែកឥដ្ឋ នៅការដ្ឋានសំណង់ផ្សេងៗ ជាមួយកម្មករឯទៀត។ ណាខំរៀនឲ្យទាន់គេនៅសាលា ណាខំរកស៊ីចិញ្ចឹមជីវិត។

ម្នោះហើយយុវជនយើងត្រូវហត់នឿយទាំងផ្លូវកាយផ្លូវចិត្ត   នឹងបញ្ញា ទាំងយប់ទាំងថ្ងៃគ្មានដែលបានសំរាកឡើយ។ ម្យ៉ាង ដោយហត់នឿយហួសកម្លាំង ម្យ៉ាងទៀតដោយការស៊ីចុកក៏ខ្វះខាត ហើយដេកក៏មិនគ្រប់គ្រាន់ទៀត ម្នាក់ៗទំរាំបានសញ្ញាប័ត្រឱប្តូម ឬបាសូវាមួយសន្ធឹកៗ ខូចខ្លួនខូចប្រាណអស់។ ខ្វះរបេងស៊ីស្ងួត ខ្វះទៀតទៅជាឆ្កួតឡប់សតិ ខ្វះទៀត សុខភាពចុះខ្សោយរហូត។ឆ្នាំ១៩៦០ អង្គការយុវជនបដិវត្ត ដែលនៅពេលនោះ មានឈ្មោះថា "សម្ព័ន្ធយុវជនកម្ពុជាប្រជាធិបតេយ្យ" បានចាប់បដិសន្ធិឡើង។ ក្រោមការដឹកនាំរបស់អង្គការបដិវត្តកម្ពុជា ចលនាយុវជនសិក្សា នៅទីក្រុងភ្នំពេញ ក៏ចាប់ផ្តើមផុលផុស កក្រើករំពើកឡើងដែរ។ យុវជនដាំ ផេងបានចូលក្នុងអង្គការយុវជនបដិវត្តនេះ នៅឆ្នាំ ១៩៦១។ ហើយចាប់ពីនោះមក យុវជនដាំ ផេង បានទទួលការអប់រំ ថែបំប៉ន ទាំងនយោបាយ សតិអារម្មណ៍ នឹងចាត់តាំងបដិវត្ត អំពីអង្គការបដិវត្តជាប់រហូតមក ។ យុវជនដាំ ផេង បានរីកចំរើនធំធាត់យ៉ាងឆាប់រហ័ស ទាំងរូបរាងកាយ ទាំងគំនិតបញ្ញា ទាំងទស្សនៈ ទាំងគោលជំហរនយោបាយ សតិអារម្មណ៍ នឹងចាត់តាំងបដិវត្ត ក្រោមការជួយណែនាំអប់រំ នឹងការជួយឧបត្ថម្ភសព្វបែបយ៉ាងអំពីអង្គការបដិវត្ត ។ យុវជនយើងចាប់មានភ្នែកភ្លឺ ហើយមើលឃើញវែងឆ្ងាយ ច្បាស់លាស់ ជាងកែវយិតទៅទៀត ។ គេឃើញទុក្ខវេទនាមួយរយមួយពាន់ជំពូក របស់ប្រជាជន ក្រោមការជិះជាន់ ដ៏សែនធ្ងន់ធ្ងរ របស់ចក្រពត្តិ សក្តិភូមិ នាយទុន ។ តាមរយៈនេះ គេក៏យល់ច្បាស់ នូវមូលហេតុ នៃទុក្ខវេទនា របស់គ្រួសារម៉ែឪ បងប្អូនគេ កាលពីមុន រហូតស្លាប់បាត់បង់ជីវិតនិរាសព្រាត់ប្រាសគ្នាអស់ នឹងយល់ការលំបាកវេទនា របស់គេសព្វថ្ងៃ ។ ម្យ៉ាងទៀត គេឃើញច្បាស់ នូវគ្រោះអាសន្នដែលប្រទេសជាតិគេ កំពុងឋិតនៅក្រោម

ការគំរាមកំហែង ការជ្រៀតជ្រែកឈ្លានពាន របស់ចក្រពត្តិអាមេរិក ជារៀងរាល់ថ្ងៃ ។ នៅតាមព្រំដែន ឈាមប្រជាជនកម្ពុជា ស្រី ប្រុស ចាស់ក្មេង ត្រូវហូររាល់ថ្ងៃ ដោយសារអំពើឈ្លានពាន របស់ចក្រពត្តិអាមេរិក នឹងបរិវារព្រៃនគរ បាងកក ទាំងតាមជើងគោក នឹងជើងអាកាស ។ សំរែកមាតុភូមិជាទីស្នេហា ដែលដង្ហោយហៅកុលបុត្រ កុលធីតាឲ្យក្រោកឈរឡើងការពារទឹកដី បានលាន់ឮកងរំពង ដល់បេះដូងដ៏ក្មេងខ្ចី នឹងបរិសុទ្ធ របស់យុវជនដាំ ផេង នឹងយុវជន យុវនារីកម្ពុជាឯទៀតទាំងអស់ ។ យុវជនដាំ ផេង ក៏ចាប់ផ្ដើមត្រួតពិនិត្យមើលអាត្មាខ្លួនឡើងវិញ ហើយក៏បានឃើញ នឹងបានយល់ច្បាស់ថាអាត្មាខ្លួនដែលបានខិតខំចំណាយពេលវេលា ចំណាយកម្លាំងកាយ ចិត្តគំនិត នឹងបញ្ញា នឹងចំនាយយុវវ័យរបស់ខ្លួន យ៉ាងពេញទំហឹងសព្វថ្ងៃនេះ ដើម្បីបានសញ្ញា-ប័ត្រ បានបុណ្យសក្តិ លាភសក្ការៈផ្ទាល់ខ្លួន ទៅថ្ងៃក្រោយទៀតនោះ គឺជាការឥតប្រយោជន៍។ ព្រោះគ្មាន បំរើប្រទេសជាតិគ្មានផលប្រយោជន៍អី ដល់ប្រជាជនបន្តិចសោះ ។ ហើយផ្ទុយទៅវិញតំរេះវិជ្ជា នឹងការយល់ដឹងរបស់ខ្លួននេះវាបំរើតែចក្រពត្តិសក្តិភូមិ នាយទុនក្នុងការជិះជាន់ ឆក់ប្លន់កាប់សំម្លាប់ប្រជាជនឯងប៉ុណ្ណោះ។

ដោយបានអង្គការបដិវត្តឃោសនាអប់រំ ពន្យល់ណែនាំយុវជនដាំ ផេង ក៏ដូចយុវជន យុវនារីផ្សេងទៀត បានភ្ញាក់ខ្លួនទាន់ពេលវេលា នឹងចំនាយពេលដែលប្រទេសជាតិមាតិភូមិ កំពុងស្រែកដង្ហោយហៅគេទាំងឡាយផង។ យុវជនដាំ ផេង បានបង្វែរសកម្មភាព របស់ខ្លួនទាំងអស់ ការខំប្រឹងប្រែងមានះព្យាយាមស្វិតស្វាញ របស់ខ្លួនទាំងអស់ ក្នុងការបំរើប្រទេសជាតិ បំរើប្រជាជននឹងបំរើវណ្ណះក្រីក្រវិញ។ ដោយមានចរិតស្លូតបូត សុភាពរាបសាផង ដោយមានស្មារតីស្នេហាជាតិ ស្នេហាប្រជាជន

ខ្ពស់ ពិសេសប្រជាក្រីក្រ ហ៊ានលះបង់ផលប្រយោជន៍ផ្ទាល់ខ្លួនទាំងអស់ ដើម្បីបុព្វហេតុឧត្តុង្គឧត្តមនេះ នឹងដោយមានគោលជំហរប្រយុទ្ធដាច់ខាត ជាមួយចក្រពត្តិ នឹងពួកវណ្ណៈជិះជាន់ទាំងអស់ក៏ដូចជាមួយឧបសគ្គតូច ធំ ក្នុងការបំពេញភារៈកិច្ចផង យុវជនដាំ ផេង បានទៅជាគំរូលះបង់ នឹងគំរូសាមគ្គីភាព ឯកភាព ក្នុងផ្ទៃអង្គការយុវជនបដិវត្ត នៅក្នុងទីក្រុងភ្នំពេញទាំងមូលៗ នៅក្នុងវិទ្យាល័យយុគន្ធរ ក៏ដូចនៅវិទ្យាល័យ នឹងអនុវិទ្យាល័យផ្សេងទៀត ក្នុងទីក្រុងភ្នំពេញ យុវជនដាំ ផេង មានការប្រាស្រ័យទាក់ទងជិតស្និទ្ធល្អ ជាមួយយុវជន នឹងយុវនារីឯទៀតទាំងអស់ៗ ដោយមានអាកប្បកិរិយាស្លូតបូត នឹងសុភាពរាបសា ហើយយល់ដឹងសុខទុក្ខ យល់អធ្យាស្រ័យ នឹងចេះជួយយកអាសាយុវជនដទៃក្នុងការរៀនសូត្រ ក៏ដូចជាក្នុងជីវភាពរស់នៅរបស់គេ ដែលមានការលំបាក យុវជនដាំ ផេង ត្រូវបានយុវជនយុវនារីជាច្រើនស្រឡាញ់រាប់អាន នឹងកោតសរសើរៗ

ចុងឆ្នាំ១៩៦៣ នឹងដើមឆ្នាំ១៩៦៤ចក្រពត្តិអាមេរិក នឹងបរិវារព្រៃនគរ បាងកក ធ្វើការគំរាមកំហែង នឹងកៀបសង្កត់យ៉ាងខ្លាំង មកលើឯករាជភាព សន្តិភាព អព្យាក្រឹតភាព នឹងបូរណភាពដែនដីកម្ពុជាៗ ប្រទេសកម្ពុជា ឋិតនៅចំពោះមុខគ្រោះអាសន្ន នៃរដ្ឋប្រហារ យោធារបស់ខ្ញុំចក្រពត្តិអាមេរិក ដែលមានលន់ ណុល នឹងបក្សពួកជាមេ ជាអចិន្ត្រៃយ៍ៗ តែពួកវណ្ណៈកាន់អំណាចជំនាន់នោះបែរជាចង់សារភាពខ្លាំង សំរុះសំរួលជាមួយចក្រពត្តិអាមេរិក-បរិវារ ដើម្បីសុំសេចក្តីសុខសាន្តអំពីវាទៅវិញ តែទោះបីជាតិ ធ្លាក់ទៅជាខ្ញុំគេ ក៏មិនខ្វល់ដែរៗ ដូច្នោះ អង្គការបដិវត្តកម្ពុជា ក្នុងឋានៈជាអ្នកតំណាង នឹងការពារផលប្រយោជន៍ប្រទេសជាតិ នឹងប្រជាជនកម្ពុជាទាំងមូល បានដឹកនាំ ប្រជាជន យុវជន-

យុវនារីកម្ពុជានៅទូទាំងប្រទេស ឲ្យក្រោកឡើងធ្វើការតស៊ូតាមគ្រប់រូបភាព ប្រឆាំងចក្រពត្តិអាមេរិក នឹងបរិវាព្រៃនគរ បាងកក ហើយកៀបសង្កត់នឹងអូសទាញពួកវណ្ណៈកាន់អំណាចជំនាន់នោះ កុំឲ្យសារភាពខ្លាំងៗ យុវជនដាំ ផេង ក្រោមការដឹកនាំដ៏ភ្លឺស្វាងរបស់អង្គការបដិវត្ត បានចុះប្រឡូកជាប់ជិតស្និទ្ធនឹងមជ្ឈដ្ឋាន យុវជន-យុវនារីសិក្សាក្នុងទីក្រុងភ្នំពេញ ធ្វើការឃោសនាអប់រំ បកអាក្រាត នឹងវែកញែក នូវឧបាយកលនឹងបទឧក្រិដ្ឋ របស់ចក្រពត្តិអាមេរិក នឹងបរិវាព្រៃនគរ បាងកក ដែលប៉ុនប៉ងសម្លាប់ ឯករាជ សន្តិភាព អព្យាក្រិត នៃកម្ពុជា យើងៗ យុវជនដាំផេង បានបំផុសបំផុលចលនាយុវជនសិក្សា យ៉ាងសកម្មក្លៀវក្លាបំផុត ហើយបានចូលរួមដឹកនាំចលនាយុវជន-យុវនារី តស៊ូប្រឆាំងចក្រពត្តិអាមេរិក បរិវា យ៉ាងអង់អាចក្លៀវក្លា នឹងគគ្រឹកគគ្រេងបំផុតៗ មានចលនាបាចខិតប័ណ្ណ ចលនាបាតុកម្ម កូដកម្ម មីទិញជាដើមៗ

ដោយយុវជន-យុវនារីកម្ពុជា ក្រោមការដឹកនាំ ដ៏ឈ្លាសវៃ នៃអង្គការបដិវត្តកម្ពុជា បានធ្វើការតស៊ូខ្លាំងក្លា គគ្រឹកគគ្រេង នៅទូទាំងប្រទេស ទាមទារនឹងកៀបសង្កត់ខ្លាំង ពួកវណ្ណៈកាន់អំណាចពេលនោះក៏ត្រូវបង្ខំចិត្ត ទាត់ជំនួយ ដ៏មានពិសពុល របស់ចក្រពត្តិអាមេរិក ទាំងក្តីសោកស្តាយ នៅខែ១១ ឆ្នាំ១៩៦៣ៗ នេះជាជ័យជំនះ ដ៏ត្រចះត្រចង់មួយ របស់ប្រជាជន យុវជន-យុវនារីកម្ពុជា ក្រោមការដឹកនាំដ៏ភ្លឺស្វាង នៃអង្គការបដិវត្តកម្ពុជាៗ ហើយក៏ជាបរា ជ័យយ៉ាងអាម៉ាសមួយរបស់ចក្រពត្តិអាមេរិក និងបរិវាក្នុង-ក្រៅវា នៅកម្ពុជាៗ ដោយហេតុឃោរឃៅហ្វាស៊ីស នឹងចចែសក្បាលរឹងរបស់វា ចក្រពត្តិអាមេរិក នឹងបរិវា ខំរិះរកឧបាយកលខ្មៅងងឹត លើកផែនការឧក្រិដ្ឋមួយហើយមួយទៀត ប៉ងសម្លាប់កម្ពុជាឯករាជ សន្តិភាព អព្យាក្រិតយ៉ាងមមាញឹកទៀតៗ តាម

ការណែនាំរបស់អង្គការបដិវត្ត នៅខែ១-១៩៦៤ យុវជនដាំ ផេង បាន ចូលរួមបំផុសនីងដឹកនាំចលនាយុវជនសិក្សា ធ្វើកូដកម្ម ធ្វើបាតុកម្ម ធ្វើ មីទិញនៅវាលមេរុ នៅមុខវាំង នៅមុខរដ្ឋសភា ដើម្បីវែកញែក បក អាក្រាត នូវផែនការ និងសកម្មភាពឧក្រិដ្ឋ របស់ចក្រពត្តិអាមេរិក-បរិវារ ដែលប៉ុនប៉ងសម្លាប់ឯករាជ សន្តិភាព អព្យាក្រិត នៃកម្ពុជា ប្រកាស ថ្កោលទោស នូវអំពើជ្រៀតជ្រែក ឈ្លានពាន របស់វា ដែលបាញ់រះ ទំលាក់គ្រាប់បែក ទៅលើភូមិករ ទ្រព្យសម្បត្តិ ផលដំណាំប្រជាជន នៅ តាមព្រំដែន នឹងសម្លាប់ប្រជាជនស្លូតត្រង់ ទាំងស្រីប្រុស ចាស់ក្មេង នៅ តាមព្រំដែន ជារៀងរាល់ថ្ងៃៗ [...]

ដូច្នេះមិត្ត ត្រូវតែស្លាប់ក្នុងឋានៈជាជនបដិវត្ត ជាយុវជនស្នេហាជាតិ។ ពោលគឺស្លាប់ក្នុងកិត្តិយសរុងរឿង ឧត្តុង្គឧត្តមៗដាច់ខាត មិត្តមិន ស្លាប់ក្នុងឋានៈជាជនក្បត់ជាតិ ជាជនកំសាកសារភាព ខ្មាំង ក្បត់បងប្អូនរួមវណ្ណៈឯងឡើយ...។ មិត្តប្តេជ្ញាថា នឹងប្រយុទ្ធជាមួយ ខ្មាំង រហូតដល់ដង្ហើមចុងក្រោយបំផុត។ គិតដូច្នេះហើយ មិត្តរក្សាជំហរ នឹងអាកប្បកិរិយានឹងនរ តែមោះមុត ក្នុងឋានៈ ជាអ្នកវាយសំរុកខ្មាំងវិញ លើគ្រប់បញ្ហា។ ហើយមិត្តពើងទ្រូងដើរចូលទៅក្នុងកន្លែងធ្វើទារុណកម្ម យ៉ាងអង់អាចក្លាហាន។ ក្នែកទាំងគូរបស់មិត្ត សំឡក់សំឡឹងពួកអាពេជ្ឈឃាត ដែលនៅរង់ចាំក្នុងទីនោះស្ទើរធ្លុះដល់ឆ្អឹង ដោយសេចក្តីស្អប់ខ្ពើម ជាទីបំផុត។ ពេលខ្មាំងចាប់ផ្តើមសួរចំឡើយ ជាលើកដំបូង មិត្តឆ្លើយតប ទៅវិញដោយភ្លើងកំហឹងពុះពោរពេញឱវាទថា "ពួកអាឯង ជាជនក្បត់ ជាតិ ជាខ្ញុំបំរើដាច់ថ្លៃ របស់ចក្រពត្តិអាមេរិក ពួកអញជាអ្នកស្នេហាជាតិ ជាអ្នកការពារប្រទេសជាតិ ជាអ្នកសង្គ្រោះជាតិ នឹងរំដោះប្រជាជន ឲ្យ រួចផុតពីអំពើការជិះជាន់សង្កត់សង្កិន របស់ចក្រពត្តិអាមេរិក-បរិវា នឹង

ឲ្យរួចផុតអំពីការជិះជាន់សង្កត់សង្កិន របស់ពួកអាវណ្ណៈកាន់អំ ណាច ប្រតិកិរិយា ក្បត់ជាតិឯងរាល់គ្នា! នេះជាព្រំដែនយ៉ាងច្បាស់លាស់រវាងពួកអាឯង នឹងពួកអញ! ដូច្នេះអញគ្មានពាក្យអី និយាយជាមួយពួកអាឯងរាល់គ្នាទេ! ចង់ធ្វើអីធ្វើទៅ មិនបាច់សួរអញទេ!” ថាហើយ មិត្តស្តោះទឹកមាត់ រួចងាកមុខចេញធ្វើហី លែងនិយាយឆ្លើយឆ្លងនឹងវារហូត។ ខ្មាំងចាប់ផ្តើមធ្វើទារុណកម្ម យ៉ាងព្រៃផ្សៃ លើរូបកាយមិត្តទាំងយប់ទាំងថ្ងៃ ជាប់បីយប់បីថ្ងៃ។ មិត្តខាំមាត់អត់គ្មានស្រែកថ្ងូរមួយអ៊ឹសទេ។ ក្នុងមួយថ្ងៃៗ មិត្តត្រូវវាវាយដំច្រំធាក់ បញ្ច្រាកទឹកសាប៊ូ ទឹកត្រី វែកញែក សន្លប់បាត់ស្មារតីរាប់មិនអស់ទេ។ ឲ្យតែដឹងខ្លួនពេលណា មិត្តតែងតែបកអាក្រាត នឹងប្រកាសកាត់ទោសឧក្រិដ្ឋទៅលើឧបាយកល នឹងសកម្មភាពជ្រៀតជ្រែកឈ្លានពាន បំផ្លិចបំផ្លាញប៉ុនប៉ងសម្លាប់កម្ពុជាឯករាជសន្តិភាព អព្យាក្រិត របស់ចក្រពត្តិអាមេរិក-បរិវា នឹងប្រកាសទោសពួកអាក្បត់ លន់ណុល-សិរិមតៈ-សឺងង៉ុកថាញ់-អ៊ិន តាំដែលបំរើចក្រពត្តិអាមេរិក ក្នុងការបំផ្លិចបំផ្លាញ និងសម្លាប់ប្រទេសជាតិនឹងប្រជាជនឯងជានិច្ចៗ មិត្តស្ងាត់មាត់តែពេលសន្លប់បាត់ស្មារតីប៉ុណ្ណោះ។

ខ្មាំងទាល់ចំណេះ ព្រោះវាទារុណកម្មសព្វបែបយ៉ាងអស់ហើយនៅតែយកការណ៍អ្វីពីមិត្តមិនបានសោះ។ ដូច្នេះវាដូរវិធីត្រជាក់ម្តងវិញ។ វាលួងលោម បញ្ចុកបន្ស៊ីគ្រប់បែបយ៉ាង វាយកស្រីញីមកទាក់ទាញទឹកចិត្ត វាសន្យាឲ្យបុណ្យសក្តិ សន្យាឲ្យបន្តវិជ្ជានៅបរទេសទៀត មានប្រទេសបារាំង នឹងសហរដ្ឋអាមេរិកជាដើមឲ្យតែមិត្តសុខចិត្តប្រាប់ឈ្មោះប្រាប់កន្លែង នឹងប្រាប់ខ្សែអ្នកដឹកនាំដល់វា។ តែនៅចំពោះមុខឧបាយ-កល ដ៏ផ្អែមល្ហែមរបស់ខ្មាំងទាំងអស់ មិត្តបានវែកញែក បកអាក្រាត នឹងវាយសំរុកទៅខ្មាំងវិញ យ៉ាងអង់អាចនឹងឈ្លាសវៃបំផុត ធ្វើឲ្យខ្មាំងទាល់

ប្រាជ្ញសុញគំនិតជាញើកញាប់ៗ

ខ្ញុំធ្លាប់ប្រើល្បិចគលក្ដៅ-ត្រជាក់ សព្វគ្រប់អស់ហើយ នៅតែមិនបានការទៀត វាក៏ចាប់ប្រើធម៌ក្ដៅ ផ្ដាច់ព្រ័តែម្ដងៗ តាំងពីចាប់យកទៅខ្ញុំមិនហ៊ានដាក់មិត្តដាំ ផេងជុំជាមួយគេឯងទេ វាដាក់ឃុំឃាំងមិត្ត នៅក្នុងបន្ទប់ងងឹតតូចមួយ ដាច់ឆ្ងាយពីគេឯងជានិច្ចៗ ក្នុងប៉ុន្មានថ្ងៃនេះ ខ្លួនប្រាណមិត្ត ត្រូវបាក់បែកខ្ទេចខ្ទាំអស់ហើយតែធន្ទះប្រយុទ្ធរបស់មិត្ត នៅតែរឹងចែសដាងដែកថែបទៅទៀតៗ ពេលខ្មាំងបញ្ចេញមិត្តពីបន្ទប់ងងឹតយកទៅកន្លែងធ្វើទារុណកម្មសួរចំឡើយពល់ដង មិត្តត្រូវបានដើរកាត់មុខ បន្ទប់ឃុំឃាំងដទៃផ្សេងទៀតៗ យុទ្ធមិត្តឯទៀត ដែលបានដឹងព្រឿងរ៉ាវមិត្ត ហើយមានការព្រួយបារម្ភ ចំពោះអាយុជីវិតរបស់មិត្ត បាននាំគ្នារត់ស្រមកអើតមើលមិត្តៗ មិត្តដាំ ផេងទុរនទុរាណាស់ទៅហើយ ស្ទើរលើកជើងដើរមិនរួច ណាហាត់ហេវឈឺចុកចាប់ពេញទាំងខ្លួនប្រាណណាវាធ្ងន់នឹងច្រវាក់ដែក ដែលខ្មាំងចងជាប់នៅជើង នឹងដៃទាំងពីរតែនៅពេលដែលមិត្តក្រឡេកឃើញមុខ នឹងភ្នែកច្រើនគូរបស់យុទ្ធមិត្តដទៃដែលខ្មាំងចាប់មកពីតំបន់នានា ទូទាំងប្រទេស សំឡឹងមើលមិត្ត ដោយក្ដីព្រួយបារម្ភ នឹងមនោសញ្ចេតនាបដិវត្តកក់ក្ដៅបំផុត មិត្តមានកម្លាំងព្រឹសឡើងវិញ ភ្លេចអស់នូវការឈឺចុកចាប់ក្នុងខ្លួនៗ មិត្តលើកដៃទាំងគូរដែលជាប់ច្រវាក់ឡើងលើ...ហើយស្រែយ៉ាងខ្លាំងៗថា "**ជយោ បដិវត្តកម្ពុជា ដ៏រុងរឿង! ជយោប្រជាជនកម្ពុជា ដ៏អង់អាចក្លាហាន! បដិវត្តកម្ពុជាពិតជាឈ្នះ! បរាជ័យ ចក្រពត្តិអាមេរិក-បរិវានឹងពួកអាក្ដេបំរើវា!**" ពេលនោះសំរែកជ័យឃោសន៍ នឹងសំរែកបដិសេធចក្រពត្តិអាមេរិក-បរិវា បានលាន់ឮកងរំពង ចេញពីគ្រប់បន្ទប់ទាំងអស់ៗ រួចហើយមិត្តខំងាកញញឹមដាក់យុទ្ធមិត្តឯទៀត ដើម្បីលើកទឹកចិត្តកុំឲ្យព្រួយបារម្ភអីចំពោះរូបមិត្ត

ហើយឲ្យបន្តការប្រយុទ្ធដាច់ខាតជាមួយខ្មាំងទៀត។

យប់មួយ បន្ទាប់ពីខ្មាំងធ្វើទារុណកម្មយ៉ាងសាហាវគ្រប់បែបយ៉ាងមក មិត្តដាំ ផេង សន្លប់បាត់ស្មារតី។ ខ្មាំងវាអូសមិត្តមកបោះចោល នៅក្នុងបន្ទប់ងងឹតវិញ។ ពេលភ្ញាក់ខ្លួនពីសន្លប់ មិត្តក្អួតធ្លាក់ឈាមទាំងដុំៗ ។ មិត្តដឹងខ្លួនថាមិនរស់ទេ មិត្តខំប្រឹងប្រែប្រាប្រតោងជញ្ជាំង សរសេរចារឹកលើថ្ម ដោយឈាមស្រស់របស់មិត្ត នូវកំណាព្យមួយ ដែលមានន័យដូចតទៅ៖

| | | |
|---|---|---|
| ^បេះដូងក្រហម | ខ្ញុំថ្នាក់ខ្ញុំថ្នម | លត់ដំរាល់ថ្ងៃ |
| ទុកជូនបដិវត្ត | ដ៏មានតម្លៃ | ជូនអ្នកក្រក្រី |
| | វណ្ណៈអធន ។ | |
| ពេលនេះហើយណា | ជនកម្ពុជា | ត្រូវការទាន់ហាន់ |
| យកបេះដូងខ្ញុំ | ទៅដោះទុក្ខធ្ងន់ | មិត្រប្រជាជន |
| | រីករាយបូជា ។ | |

ដើម្បីសំដែង នូវមនោសញ្ចេតនា ដ៏ល្អបរិសុទ្ធ នឹងជ្រាលជ្រៅរបស់មិត្តចំពោះអង្គការបដិវត្ត ប្រជាជន នឹងវណ្ណៈក្រីក្រដែលមិត្តគោរព បំរើ ស្មោះត្រង់ នឹងស្រឡាញ់ លើសអាយុជីវិត របស់មិត្តតទៅទៀត។

ព្រឹកស្អែកឡើង មិត្តដាំ ផេង បានពលីជីវិតដ៏ក្មេងខ្ចីនៅក្នុងបន្ទប់ងងឹតយ៉ាងរុងរឿង ឧត្តុង្គឧត្តមអស្ចារ្យ ដើម្បីបុព្វហេតុការពារប្រទេសជាតិ នឹងរំដោះប្រជាជន ពិសេសប្រជាជនក្រីក្រ ឲ្យចាកផុតពីទុក្ខវេទនាសព្វបែបយ៉ាង។

ខ្មាំងអាចវាយដំច្រំជាក់ លើរូបរាងកាយមិត្តបាន អាចវាយបែកសាច់ ហូរឈាម បាក់ឆ្អឹងឆ្អែងខ្ទេចខ្ទាំអស់ រហូតដល់ផ្តាច់ផ្តិលអាយុជីវិត

មិត្តទៀតបាន។ តែខ្មាំងពុំអាចវាយបំបាក់ឬធ្វើឲ្យរង្គោះរង្គើ នូវឆន្ទៈប្រយុទ្ធដាច់ខាត របស់មិត្ត ដាំ ផេង បានឡើយ។ នៅចំពោះមុខគោលជំហរប្រយុទ្ធដាច់ខាតរបស់មិត្តយ៉ាងនេះ ខ្មាំងទោះមានគ្រឿងសាស្ត្រវែងទំនើប មានមធ្យោបាយ នឹងឧបករណ៍ឃោរឃៅហ្វាស៊ីសច្រើនយ៉ាងណា ក៏នៅតែចាញ់។ រីឯមិត្តដាំ ផេងគឺឈ្នះ! មិត្តស្លាប់ក្នុងឋានៈជាអ្នកវាយសំរុក ជាអ្នកឈ្នះ ហើយឈ្នះរៀងរហូតទៅយុទ្ធមិត្តឯទៀត រាប់ម៉ឺនរាប់សែននាក់ ដែលនៅឯក្រោយ បានប្តេជ្ញា លើកជ្រោងគ្រវីទង់ប្រយុទ្ធនេះ តាមគន្លងដ៏ល្អប្រពៃ របស់មិត្ត ប្រយុទ្ធវាយសំរុកកំទេចខ្មាំង រហូតបានដល់រំដោះទឹកដីកម្ពុជាជាទីស្នេហា ទាំងស្រុងនឹងជាស្ថាពរ។ ជាមហាជ័យជំនះ របស់វិញ្ញាណក្ខ័ន្ធមិត្តដាំ ផេង នឹងយុទ្ធជនកម្មាភិបាលយើងឯទៀតទាំងអស់ ដែលបានពលីជីវិត នៅលើសមរភូមិប្រយុទ្ធនឹងខ្មាំងនៅគ្រប់ទិសទី។

ជីវិតរបស់មិត្តដាំ ផេង គឺជាជីវិតតស៊ូ តស៊ូរហូតដល់ដង្ហើមចុងក្រោយបំផុត ដោយឈរលើគោលជំហរដាច់ខាតប្រយុទ្ធគ្មានខ្លាចលំបាក គ្មានខ្លាចស្លាប់ នឹងជំហរវាយសំរុកខ្មាំងជាប់ជានិច្ច ទោះត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃខ្មាំងហើយក៏ដោយ។ ជាគោលជំហររបស់ជនបដិវត្តដែលរស់នៅថ្លៃថ្លា ហើយស្លាប់ទៅក៏អស្ចារ្យ រុងរឿង ឧត្តុង្គឧត្តមបំផុត។

ក្រៅពីបណ្តាស្នាដៃទាំងនេះ ក៏នៅមានអ្នកនិពន្ធមួយចំនួនតូចបានលួចសរសេរស្នាដៃរបស់ខ្លួន បង្ហាញប្រាប់មិត្តអ្នកអានអំពីទុក្ខលំបាកវេទនា របស់ប្រជាជនខ្មែរនៅសម័យកម្ពុជាប្រជាធិបតេយ្យ ដែរទោះ បីជាដឹងថា ប្រសិនណាជាគេដឹង គេឃើញនឹងត្រូវមានទោសរហូតដល់ស្លាប់ក៏ដោយ។ អ្នកនិពន្ធបែបនេះ គាត់បានលួចសរសេរស្នាដៃតែពេលដែលស្ងាត់ប៉ុណ្ណោះ ស្នាដៃដែលបានសរសេរហើយ ត្រូវមានការ

លាក់កំបាំងយ៉ាងស្ងាត់បន្ថែមទៀត។ អ្នកនិពន្ធដែលបានរកឃើញស្នាដៃនិពន្ធក្នុងអំឡុងប៉ុល ពតនៅកាន់អំណាចមានដូចជា៖

-លោកជួន ម៉ែន សរសេរកំណាព្យ**មើលផែនដីខ្មែរ** សរសេរនៅឆ្នាំ១៩៧៦-១៩៧៧

-អ្នកស្រីអ៊ុង ស៊ីណន សរសេរកំណាព្យ**សោកនាដកម្មស្រុកមោងឫស្សី** ឆ្នាំ១៩៧៨

-លោកកែវ ចិន្តា សរសេរកំណាព្យ**ចុកណែនឱក** សរសេរនៅឆ្នាំ១៩៧៦ ជាបន្តទៅទៀត ខ្ញុំសូមលើកយកអត្ថបទកំណាព្យរបស់លោកជួន ម៉ែន និងប្រវត្តិនៃការតាក់តែងស្នាដៃអត្ថបទនេះមកបង្ហាញជូនមិត្តអ្នកអានដូចតទៅ៖

លោកជួន ម៉ែននិពន្ធស្នាដៃមួយនេះឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងឆ្នាំ១៩៧៦-១៩៧៧ដែលការនិពន្ធស្នាដៃនេះលោកបានលួចនិពន្ធមួយថ្ងៃតែមួយឬពីរឃ្លាតែប៉ុណ្ណោះ។ គោលបំណងនៃការនិពន្ធស្នាដៃនេះ គឺដើម្បីបង្ហាញដល់កូនចៅជំនាន់ក្រោយឲ្យបានដឹងពីសេចក្តីលំបាកវេទនារបស់ប្រជាជននៅក្នុងរបបវាលពិឃាត។ លោកលួចសរសេរកំណាព្យនេះឡើង ដោយចារនៅលើក្រដាសស៊ីម៉ង់ត៍ជាមួយដីសរួចក៏ទន្ទិញ ឲ្យចាំមាត់ជានិច្ចរហូតដល់ចប់អត្ថបទនេះក្នុងរយៈពេលមួយឆ្នាំ។ ក្រោយថ្ងៃរំដោះគឺនៅឆ្នាំ១៩៨០ទើបអត្ថបទនេះត្រូវបានបោះពុម្ពផ្សាយ ដែលមានចំនួន១៤២ឃ្លានឹងមានចំនួន៤៩ទំព័រ។

មេឃភ្លឺខ្មៅជិត ផ្គរលាន់ក្នុងចិត្ត រងំឥតសូរ
ស្ទឹងជន់ស្នួតចែស ភ្នំប្រេះជាអូរ ទឹកភ្នែកជន់ជោរ
ហូរលិចភូមិឋាន ។

| | | |
|---|---|---|
| បក្សីប្រែដើរ | ម្រឹគប្រែហោះហើរ | ត្រីលង់ស្លាប់ប្រាណ |
| ខ្ទមក្លាយជាផ្ទះ | វិនាសវិមាន | យំសោកស្រែកឃ្លាន |
| | ទួញថ្ងូរក្នុងចិត្ត | ។ |
| ផ្កាកែខុសកាល | ទឹកសាចពេញវាល | ស្មៅស្រពោនស្វិត |
| ក្រួសថ្មក្រៀមក្រំ | យំសោកអាណិត | ត្រកួនព្រលិត |
| | លេងឫទ្ធិឡើងទ្រើង | ។ |
| វេស្សវ័ណអង់អាច | អាងឫទ្ធិអំណាច | ប្រឹងលើកតម្កើង |
| ហ៊ីងនិងគីង្គក់ | ពីកក់ចំបើង | ឲ្យរុងរឿងថ្កើង |
| | ឡើងស្មើចន្ទ្រា | ។ |
| ហ៊ីងអរភ្លេចគិត | ភ្ញាក់ទាំងងងិត | ឥតគិតពិចារ |
| លោតលលេងភ្លើង | ក្រហមភ្លឺថ្លា | ព្រាត់ប្រាសខ្មោចផ្សា |
| | ទើបនឹកស្តាយក្រោយ | ។ |
| ស្រណោះផ្ទះលោន់ | ផ្ទះស្រែកន្ទាន់ | ប្រាប់ជាអំណោយ |
| ហ៊ីងក្អាត់មិនស្តាប់ | លុះស្លាប់ថ្ងោះថ្ងោយ | បែរងាកមើលក្រោយ |
| | កោះត្រើយហួសឆ្ងាយ | ។... |

សរុបសេចក្តីមក ទោះបីជាអក្សរសិល្ប៍នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈតឹងរ៉ឹង យ៉ាងណាក៏ដោយក៏អក្សរសិល្ប៍នៅតែមាននិរន្តភាពដែរ គ្រាន់តែអក្សរសិល្ប៍នេះបានប្តូររូបរាងពីលក្ខណៈបម្រើអារម្មណ៍ប្រជាជនក្នុងផ្លូវអប់រំជាលក្ខណៈសង្គម មកជាការអប់រំនៅក្នុងផ្លូវបម្រើគោលនយោបាយបដិវត្តន៍ទៅវិញ។ ការផ្សព្វផ្សាយវិញមានលក្ខណៈចង្អៀតណាស់ ព្រោះគេផ្សាយតែនៅក្នុងឱកាសមានពិធីធំៗនៅក្នុងរដ្ឋ ក្រៅពីនេះ ចម្រៀងត្រូវបានចាក់ផ្សាយនៅក្នុងការដ្ឋានតែប៉ុណ្ណោះ ចំណែកសិល្បៈដែលមានមនោសញ្ចេតនាសង្គមត្រូវបានបិទ។

អាស្រ័យដោយបញ្ហានេះហើយ បានជាអ្នកនិពន្ធដែលមាននិន្នាការរិះគន់សង្គម ឬបង្ហាញតថភាពសង្គមរស់នៅត្រូវបានសរសេរដោយលួចលាក់មិនចំហរទេព្រោះនឹងមានគ្រោះថ្នាក់ដល់អាយុជីវិត និងសន្តិសុខគ្រួសារ ទាំងមូលដែរ។

# អក្សរសិល្ប៍សម័យក្រោយថ្ងៃរំដោះ

## ទិដ្ឋភាពទូទៅអក្សរសិល្ប៍សម័យក្រោយរំដោះ

ដែលហៅថាអក្សរសិល្ប៍សម័យក្រោយរំដោះ នៅទីនេះគឺសំដៅទៅដល់បណ្ដាវណ្ណកម្មទាំងឡាយណាដែលអ្នកនិពន្ធ អ្នកកវីបានសរសេរនៅសម័យដែលប្រទេសកម្ពុជារួចផុតពីការកាប់សម្លាប់ យ៉ាងរង្គាល នៃពួកក្បត់ប្រល័យពូជសាសន៍ប៉ុល ពត រហូតដល់អំឡុងឆ្នាំ ១៩៩៣ជាសម័យកាល ដែលប្រទេសកម្ពុជាបានបោះឆ្នោតគោរពតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ។

បន្ទាប់ពីប្រទេសមានសន្តិភាព ក្រោមការជួយរំដោះពីរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ក្រោមការដឹកនាំរបស់គណបក្សប្រជាជនបដិវត្តន៍កម្ពុជាមក ឃើញថាគ្រប់ហេដ្ឋារចនាសម្ព័ន្ធនៅទូទាំងប្រទេសត្រូវបានងើបជាបណ្ដើរៗ បម្រើដល់ការរស់នៅរបស់ប្រជាជនទាំងនៅទីក្រុង ក៏ដូចជានៅទីជនបទដែរ។ ប្រជាជនមានសេចក្ដីសប្បាយរីករាយនឹងជីវិតថ្មីរបស់គាត់ណាស់ ព្រោះពួកគាត់ម្នាក់ៗមិននឹកស្មានសោះថានឹងអាចមានថ្ងៃនេះទេ ព្រោះគ្រប់គ្នាមិនមានសង្ឃឹមថានឹងបានរួចរស់ជីវិតពីការកាប់សម្លាប់របស់ពួកឧក្រិដ្ឋប៉ុល ពតឡើយ។ បន្ទាប់ពីបាន

សន្តិភាព ប្រជាជននៅទូទាំងប្រទេសរួមជាមួយថ្នាក់ដឹកនាំនៅសម័យនោះ បានរៀបចំកសាងប្រទេសដែលបាក់បែកដោយសារសង្គ្រាមឡើងវិញ ពីអ្វីដែលខ្លួនមាននៅដៃសម័យកាលនោះ រហូតដល់អភិវឌ្ឍន៍ជាតិមួយទាំងមូល ឲ្យមានដំណើរការបានល្អរហូតដល់មានការរៀបចំបោះឆ្នោតជាលើកទី១ដែលបានរៀបចំឡើងដោយអង្គការសហប្រជាជាតិ។

មិនថាតែ បណ្ដាហេដ្ឋារចនាសម្ព័ន្ធនានា នៅក្នុងប្រទេសទេដែលទទួលបានការរីកចម្រើនហួសពីការស្មានទេ សូម្បីតែបណ្ដាវណ្ណកម្មដែលជាព្រលឹងដ៏បរិសុទ្ធ របស់សង្គមក៏បានកើតឡើងវិញប្រកបដោយសក្ដានុពលដែរ។

ទោះបីជាមានចំណុចសកម្មជាច្រើនក៏ដោយ ក៏ប៉ុន្តែប្រសិនណាជាក្រលេកមើល ឲ្យស៊ីជម្រៅទៅលើបណ្ដាវណ្ណកម្មដែលបានផ្សាយនោះគេនឹងឃើញថា មានលក្ខណៈតូចចង្អៀត ព្រោះតែស្នាដៃទាំងនោះត្រូវតែលើកសរសើរ តែពីការកសាងប្រទេសឡើងវិញ និយាយតែពីការកសាងជាតិដែលខិតខំដោយសារសង្គ្រាមផ្ទៃក្នុង មួយវិញទៀត ស្នាដៃក៏ត្រូវបង្ហាញពីកម្លាំងពិតរបស់បដិវត្តន៍ ហើយត្រូវតែបញ្ចូលការអូសទាញពួកវង្វេងផ្លូវប៉ុល ពតឲ្យត្រលប់មករួមរស់នៅក្នុងសង្គមជាតិក្រោមការគ្រប់គ្រងនៃមេដឹកនាំតែមួយ ពិសេសស្នាដៃដែលបានអួតសរសើរពីសាមគ្គីភាពរវាងកម្ពុជា និងវៀតណាមត្រូវបានលើកកម្ពស់នឹងលើកទឹកចិត្តជាខ្លាំង។ យោលទៅតាមបញ្ហានេះហើយ បានជាគេសង្កេតឃើញបណ្ដាវណ្ណកម្ម នៅជំនាន់នោះផ្ដេកផ្ដួលទៅលើនិន្នាការនយោបាយសង្គមច្រើន។ ចំពោះស្នាដៃដែលសរសេរប្រាសចាកពីនេះ ពុំត្រូវបានលើកទឹកចិត្ត ថែមទាំងមិនជាទីពេញនិយមពីសំណាក់មនុស្សទូទៅនៅក្នុងមជ្ឈដ្ឋានរស់នៅថែមទៀតផង។ តើនេះបណ្ដាលមកពីអ្វី?

នៅរយៈកាលក្រោយមក អំឡុងឆ្នាំ១៩៨៧ ស្នាដៃរបស់អ្នកនិពន្ធក៏បានងាកមកសរសេរជាលក្ខណៈមនោសញ្ចេតនាវិញ ដោយអ្នកនិពន្ធមានការចាប់អារម្មណ៍ទៅលើបញ្ហានេះម្ដង តែទោះបីជាយ៉ាងណាក៏ដោយ ក៏បញ្ហាសង្គមរស់នៅមានអំណោយផលល្អសម្រាប់ការសរសេរប្រលោមលោកមនោសញ្ចេតនាដែរ។ អ្នកនិពន្ធក៏រិតតែមានកម្លាំងចិត្តនៅក្នុងការសរសេរស្នាដៃ ដើម្បីបានជាចំណីអារម្មណ៍របស់មនុស្សទូទៅ។ មកដល់ពេលនេះ ប្រលោមលោកខ្លីៗត្រូវបានចុះផ្សាយនៅតាមទំព័រកាសែតជាតិជាច្រើន ព្រមជាមួយទស្សនាវដ្ដីក្នុងស្រុកផងដែរ។

នៅអំឡុងឆ្នាំ១៩៩១ ការសរសេរក៏បានងាកជាការសរសេរបង្ហាញពីមនោសញ្ចេតនាសុទ្ធសាធវិញទៀត ពោលគឺអ្នកនិពន្ធលែងសរសេរចំណោទបញ្ហារឿង ទាក់ទងទៅនឹងមាគ៌ានយោបាយបដិវត្តន៍ទៀតហើយ ស្នាដៃនីមួយៗដែលបានប្រារព្ធឡើង គឺនិយាយតែពីបញ្ហាមនោសញ្ចេនាសុទ្ធសាធ ជាប្រលោមលោកដែលទទួលការពេញចិត្តជាខ្លាំងពីសំណាក់មិត្តអ្នកអាន។

គេលែងមានទុក្ខកង្វល់ទៀតហើយ ដោយប្រទេសក៏ទទួលបានឯករាជ្យពិតប្រាកដ ដូចនេះពួកគេគ្រប់គ្នាត្រូវតែងាកសម្ញឹងការសប្បាយវិញម្ដង។ សិល្បៈភាពយន្តក៏បានកើតឡើងដែរ ឃើញថាមធ្យោបាយផ្សព្វផ្សាយអក្សរសិល្ប៍ក៏កាន់តែសម្បូរណាស់ដែរ តែសម្រាប់ការអានក៏នៅតែទទួលការចាប់អារម្មណ៍ ដដែលនៅក្នុងស្រទាប់សង្គមមនុស្ស។

ចំពោះអ្នកនិពន្ធ ដែលបានប្រារព្ធស្នាដៃនៅក្នុងសម័យនេះមានច្រើនណាស់ដែរ តែពេលនេះខ្ញុំស្រង់អ្នកនិពន្ធមួយចំនួនព្រមទាំងស្នាដៃជាសម្រង់មកបង្ហាញជូនមិត្តអ្នកអានដូចតទៅ៖

## ១ លោកតាជី ជីហ្វូត

លោកប្រសូតនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៥២ នៅសង្កាត់លេខ៤ ក្រុងភ្នំពេញ។ បិតារបស់លោកនាមទី ពត មានមុខរបរជាជាងកាត់សក់ កាលពីសម័យសង្គមរាស្ត្រនិយម លុះមកដល់សម័យប៉ុល ពតត្រូវបាន ពួកវាយកទៅសម្លាប់ចោល។ មាតានាម ថោង អាំសព្វថ្ងៃបានស្លាប់ទៅ ហើយ។

កាលពីវ័យកុមារ មាតាបិតាបានបញ្ជូនលោកមកទទួលលើការ សិក្សានៅសាលាបឋមសិក្សាព្រះកែវមរកត លុះមកដល់ឆ្នាំ១៩៦៥ លោកក៏បានប្រឡងជាប់ចូលរៀនថ្នាក់ទី៦ទំនើបជាតិ គឺវិទ្យាល័យអនុវត្ត ក្រុងភ្នំពេញ។ លោកទី ជីហ្វូតបានបន្តការសិក្សារហូតដល់ថ្នាក់ទី៣ ទំនើបតែពុំបានប្រឡងយកសញ្ញាបត្រអ្វីទេ ព្រោះតែបញ្ហាជីវភាពខ្វះ ខាតពេក។

កាលពីនៅសិក្សា លោកឆ្លៀតពេលទំនេរបានដើរយកព័ត៌មានឲ្យ កាសែតកោះសន្តិភាព ដើម្បីបានប្រាក់កម្រៃខ្លះមកចិញ្ចឹមជីវិតក្នុងគ្រួ - សារនិងបានបន្តការសិក្សា។

ឆ្លៀតពេលទំនេរពីការងារ រលោយប់ស្ងាតលោកបានសរសេរ កំណាព្យមួយដែលកំណាព្យនោះនិយាយអំពីទុក្ខវេទនា របស់កូនអ្នកក្រី ក្ររស់ក្នុងសង្គម នឹងនិយាយពីការបែងចែកវណ្ណៈក្នុងសង្គម។ អត្ថបទ កំណាព្យ សរសេរចប់លោកក៏បានយកអត្ថបទនេះទៅចុះផ្សាយនៅ សាព័ត៌មាន។ អត្ថបទទូលការចាប់អារម្មណ៍ជាខ្លាំងរហូតបណ្តាលឲ្យ មានភ្នាក់ងារសម្ងាត់បានចុះតាមដានលោកទៀតផង។ ដោយភ័យនិង សន្តិសុខផ្ទាល់ខ្លួន លោកបានភៀសខ្លួនទៅរស់នៅខេត្តរតៈគិរីមួយរយៈ

ដែលបញ្ហានេះហើយ ជាបច្ច័យនាំឲ្យលោកត្រូវបោះបង់ចោលការសិក្សាទាំងស្ដាយស្រណោះ។

បន្ទាប់ពីរដ្ឋប្រហាររបស់លោកលន់ នល់នៅថ្ងៃទី១៨ ខែមីនាឆ្នាំ១៩៧០មក លោកទី ជីហួតក៏បានវិលត្រលប់មករួមរស់ជាមួយឪពុកម្ដាយបងប្អូនវិញ រួចក៏បន្តការនិពន្ធស្នាដៃប្រលោមលោកបានជាច្រើនដែលបានចុះផ្សាយ ។បន្ទាប់ពីនោះមក លោកក៏បានក្លាយខ្លួនទៅជាអ្នកនិពន្ធម្នាក់ និងបានក្លាយជាសមាជិកអ្នកនិពន្ធដែរ។ នៅសម័យប៉ុល ពតលោកត្រូវបានអង្គការជម្លៀសឲ្យទៅរស់នៅភូមិត្រពាំងថ្ម ឃុំប៉ោយចារស្រុកភ្នំស្រុក ខេត្តបាត់ដំបង។ នៅទីនោះលោកត្រូវបានអង្គការចាត់លោកឲ្យធ្វើជាជីលាមក។

ក្រោយថ្ងៃរំដោះ៧ មករា ឆ្នាំ១៩៧៩ លោកទីជីហួតត្រូវបានចាត់តាំងលោកបម្រើការងារ នៅក្រសួងឃោសនាការវប្បធម៌និងព័ត៌មាន។ លុះមកដល់ខែមករា ឆ្នាំ១៩៨១ លោកក៏ត្រូវបានតែងតាំងឲ្យទទួលបន្ទុកជាប្រធានការិយាល័យនិពន្ធនៃនាយកដ្ឋានសិល្បៈ។

ឆន្ទៈការងាររបស់លោកក្នុងវិស័យតែងនិពន្ធមានសកម្មភាពខ្លាំងក្លាណាស់ ដូច្នេះ លោកគឺជាអ្នកដែលប្រើខួក្បាលជាងមនុស្សធម្មតាដែលរស់ក្នុងសង្គមជាមួយគ្នា។ លោកមានចរិតស្លូតបូតណាស់ ដូច្នេះហើយបានជាលោក ត្រូវបានក្លាយខ្លួនជាមនុស្សជាទីស្រឡាញ់រាប់អានពីសំណាក់មនុស្សនានានៅក្នុងសង្គម។

ជាអកុសល្យ ដោយសារតែការប្រើខួរក្បាលខ្លាំងពេក ក៏បណ្ដាលឲ្យលោកកើតជំងឺរលាកខួរក្បាលជាទម្ងន់ កាលនោះត្រូវបានបក្សនិងរដ្ឋបញ្ជូនលោកទៅ សម្រាកព្យាបាលនៅប្រទេសអាល្លឺម៉ង់ខាងកើតអស់រយៈពេល៧ខែ។ ឡៀតពេលដែលកំពុងសម្រាកព្យាបាលជំងឺ លោកក៏

នៅតែធ្មៀតសរសេរប្រលោមលោកមួយមានចំណងជើងថា **មេឃបាត់ដួងចន្ទ** បានចប់ដោយបរិបូរណ៍។ ខណៈដែលជំងឺបានជាសះស្បើយហើយ លោកក៏បានវិលត្រលប់មកមាតុភូមិវិញ រួចបន្តអាជីពជាអ្នកនិពន្ធបន្តទៀត។

នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៨៧ អាស្រ័យដោយលោកព្យាយាមក្នុងការសរសេរពេក ក៏បានបណ្ដាលឲ្យជំងឺរបស់លោករើឡើងវិញនិងត្រូវបានស្លាប់នៅក្នុងមន្ទីរពេទ្យកាល់ម៉ែត្រ។

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ លោកបានបន្សល់ស្នាដៃជាច្រើនទាំងបទចម្រៀង ក៏ដូចជាល្ខោន អាយ៉ៃ ប្រលោមលោកដែលអាចឲ្យយើងកត់ត្រាបានជាដំណាក់ៗដូចតទៅ៖

**ផ្នែកប្រលោមលោក**

- -រឿង អញមកវិញហើយ ឆ្នាំ១៩៧១
- -រឿង អ្នកលេងជាយសមុទ្រ ឆ្នាំ១៩៧១
- -រឿង គុហារថ្មលឿង ឆ្នាំ១៩៧២
- -រឿង អ្នកតាត្បូងខ្មៅ ឆ្នាំ១៩៧២
- -រឿង ឃាតករអោវ៉ាសែ ឆ្នាំ១៩៧២
- -រឿង ម្រេញគង្វាល ឆ្នាំ១៩៧៤
- -រឿង ម្រាមភ្លើង ឆ្នាំ១៩៧៤
- -រឿង យមរាជប្រមឹក ឆ្នាំ១៩៧៤
- -រឿង ជ្រោះខ្មោចល្អាងព្រាយ ឆ្នាំ១៩៧៤
- -រឿង វិលរកទ្រនំ ឆ្នាំ១៩៨៣
- -រឿង មេឃបាត់ដួងចន្ទ ឆ្នាំ១៩៨៥
- -រឿង ជីវិតអាថ៌កំបាំង ឆ្នាំ១៩៨៧

### ស្នាដៃល្ខោនបាសាក់

- រឿង ព្រះឥន្ទ្រខ្វាក់ភ្នែក ឆ្នាំ១៩៨២
- រឿង តេជោយ៉ត ឆ្នាំ១៩៨២
- រឿង នាងបដាចា ឆ្នាំ១៩៨៤
- រឿង អរុណរះនៅទិសបូព៌ា ឆ្នាំ១៩៨៤
- រឿង គូព្រេងចំលែក ឆ្នាំ១៩៨៤
- រឿង ព្រលឹងបន្ទាយស្រី ឆ្នាំ១៩៨៤

### ស្នាដៃល្ខោននិយាយ

- រឿង ជួបគ្នាពេលចូលឆ្នាំថ្មី ឆ្នាំ១៩៨០
- រឿង ចិត្តប្រណី ឆ្នាំ១៩៨៣
- រឿង វិលរកទ្រទំ ឆ្នាំ១៩៨៣

### ស្នាដៃយីកេរឿង

- រឿង មាយើង ឆ្នាំ១៩៨០
- រឿង ម៉ាក់ថើង ឆ្នាំ១៩៨១
- រឿង ឃុនឆាងឃុនផែន ឆ្នាំ១៩៨៣
- រឿង សំឡេងនៃក្តីសង្ឃឹម ឆ្នាំ១៩៨៣
- រឿង ឈាមពលករ ឆ្នាំ១៩៨៣
- រឿង បុរសបេះដូងមាស ឆ្នាំ១៩៨៤
- រឿង ជនឥស្សរៈ ឆ្នាំ១៩៨៥
- រឿង កុំភ្លេចរឿងចាស់ ឆ្នាំ១៩៨៦
- រឿង ស្នងស្នូរ មនោកែវ ឆ្នាំ១៩៨៦
- រឿង ក្បួនជីវិត ឆ្នាំ១៩៨៧

### ស្នាដៃអាយ៉ៃរឿង

-រឿង ៧មករាថ្ងៃជោគជ័យនៃសង្គមនិយមបរិសុទ្ធ ឆ្នាំ ១៩៨០

-រឿង ទំនាស់ទោសបនប៉ុល ពត អៀង សារី ខៀវ សំផនក្នុងនរកអវចី ឆ្នាំ១៩៨០

-រឿង ជីវិតថ្មីក្រោយថ្ងៃ៧មករា ឆ្នាំ១៩៨១

-រឿង ៧មករាមហាជោគជ័យ ឆ្នាំ១៩៨១

-រឿង មាគ៌ាសន្តោសប្រណី ឆ្នាំ១៩៨២

-រឿង ប្រាំឆ្នាំក្នុងជីវិតថ្មី ឆ្នាំ១៩៨៣

-រឿង កងទ័ពគំរូ ឆ្នាំ១៩៨៦

## ស្នាដៃចម្រៀងអាយ៉ៃ

-បទអបអរសាទរថ្នាក់ដឹកនាំរដ្ឋមន្ត្រីការបរទេស ប្រទេសឥណ្ឌូចិនទាំងបីលើកទី៧នៅទីក្រុងវៀងច័ន្ទ ឆ្នាំ១៩៨១

-បទអបអរសាទរមហាសន្និបាតទូទាំងប្រទេសនៃរណសិរ្សកសាងមាតុភូមិកម្ពុជា ឆ្នាំ១៩៨១

-បទល្បែងផ្តិនក្អែកថ្មីរបស់ប៉េកាំង និងអាមេរិក ឆ្នាំ១៩៨១

-បទសេចក្តីសំរេចចិត្តរបស់សម័យប្រជុំលើកទី២ នីតិកាលទី១ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ១៩៨២

-បទកិច្ចប្រឹងប្រែងរបស់តំណាងអាស៊ានត្រូវបរាជ័យឆ្នាំ១៩៨២

-បទកងទ័ពរបស់ប្រជាជនត្រូវបំរើប្រជាជន ឆ្នាំ១៩៨២

-បទអត្តចរិតរបស់ស្តេចសីហនុក្នុងពេលកាន់អំណាច ឆ្នាំ១៩៨២

-បទតើអង្គការសហប្រជាជាតិរក្សាកិត្យានុភាពរបស់ខ្លួនឬទេ? ឆ្នាំ១៩៨២

-បទសិទ្ធិនិងតួនាទីនៃបដិវត្តន៍កម្ពុជា ឆ្នាំ១៩៨២

-បទយើងពួតដៃគ្នាកំចាត់សត្វកណ្ដុរ ឆ្នាំ១៩៨៣

-បទចំណងសាមគ្គីភាពវណ្ណៈអធន ឆ្នាំ១៩៨៣

-បទអបអរសាទរថ្ងៃអនុស្សាវរីយ៍កំណើតកងទ័ពឥស្សរៈ ឆ្នាំ១៩៨៣

-បទប្រពៃណីតស៊ូនៃបក្សប្រជាជនបដិវត្តន៍កម្ពុជាឆ្នាំ១៩៨៣

-បទអបអរសាទរសន្និសីទថ្នាក់រដ្ឋមន្ត្រីការបរទេស ប្រទេសឥណ្ឌូចិនលើកទី៧ ឆ្នាំ១៩៨៣

-បទអបិយជំនឿនាំឲ្យមនុស្សដើរថយក្រោយ ឆ្នាំ១៩៨៣

-បទអបអរសាទរសម័យប្រជុំលើកទី៤ នីតិកាលទី១ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ១៩៨៣

-បទយុទ្ធជនដើមឆ្នាំ១៩៨៤ ឆ្នាំ១៩៨៤

-បទការយកចិត្តទុកដាក់របស់បក្ស និងរដ្ឋអំណាចចំពោះបងប្អូនជនជាតិចាម ឆ្នាំ១៩៨៤

-បទកត្តាថ្មីបីនៃជ័យជំនះ ឆ្នាំ១៩៨៥

ខាងក្រោមនេះ គឺអត្ថបទសង្ខេបនៅក្នុងរឿងតេជោយ៉ត ដែលជាស្នាដៃបែបល្ខោនបាសាក់ របស់លោកទីជីហួតសរសេរឡើងនៅក្នុងឆ្នាំ១៩៨២ដែលមានខ្លឹមសារដូចតទៅៈ

នៅដែនកំពង់ស្វាយមានបុរសម្នាក់ឈ្មោះមាស មានងារជាឧកញ៉ាតេជោបរមរាជ ដែលគេហៅថាតេជោមាស។ លោកមានភរិយាម្នាក់ឈ្មោះស្រែន្យ មានងារជាជំទាវ ព្រមទាំងមានសិស្សម្នាក់ឈ្មោះយ៉តដែលតែងតែទៅសមរភូមិប្រយុទ្ធជាមួយនឹងលោកគ្រប់ទីកន្លែង។ ស្វាមីភរិយាទាំងពីរនេះ មានទឹកចិត្តស្រឡាញ់រាប់ អានយ៉តជាពន់ពេក

ណាស់។ ស្ដេចសំរែបានតាំងខ្លួនឯងថា ស្ដេចសំរែរាជាធិរាជ បានតាំងកងទ័ពនៅកំពង់ហៅ (កំពង់ឆ្នាំង) ដោយបានរៀបចំនគរមួយឈ្មោះថាបន្ទាយនគរ។ ស្ដេចសំរែ ជាមេបះបោរ ប្រឆាំងនឹងព្រះជ័យចេស្ដា ដើម្បីដណ្ដើមអំណាចគ្រប់គ្រងផែនដី។ តេជោមាសនិងយ៉តបានព្យាយាមលើកទ័ពទៅបង្ក្រាបក្រុមបះបោរនេះខ្លាំងដែរតែត្រូវបរាជ័យ។ ជំទាវស្រែន បានរៀបចំល្បិចបញ្ឆោតឲ្យស្ដេចសំរែធ្លាក់ក្នុងអន្ទង់ស្នេហ៍ ហើយបង្អកស្រាររហូតដល់ស្រវឹង។ ស្ដេចសំរែនិងបក្សពួកត្រូវតេជោមាស យ៉តនិងកងទ័ពចាប់ទីថ្វាយព្រះចៅចេស្ដាកាត់ទោសតាមច្បាប់នគរ។

បន្ទាប់ពីតេជោមាសស្លាប់ដោយសារ ត្រូវបាតដៃមហាទម្ងន់មកតេជោមាសក៏ទទួលមរណៈកាលទៅ តេជោយ៉តក៏ទទួលភារកិច្ចដឹកនាំស្រុកកំពង់ស្វាយបន្ត ហើយក៏ទទួលបន្ទុកទៅបង្ក្រាបឈ្វើយសៀមបះបោរនៅពោធិសត្វ។ នៅក្នុងបេសកកម្មប្រមូលកំណែនទ័ពធ្វើបន្ទាយតេជោយ៉ត បានប្រើល្បិចចាប់សត្រូវផ្ទៃក្នុងដោយការអួសឫស្សីបញ្ច្រាស់ចុង។ ក្នុងរឿងនេះ តេជោយ៉តបានសម្លាប់ម៉ឺនចៃចុងរ៉ាក់ជាប្អូនអ្នកម្នាងនូដែលគេជាសត្រូវផ្ទៃក្នុង ព្រមទាំងបានសម្លាប់អ្នកម្នាងនូដែរដោយអាងថា អ្នកម្នាងនេះហើយជាអ្នកឈរនៅពីក្រោយម៉ឺនចៃចុងរ៉ាក់។

បន្ទាប់ពីបានជ័យជម្នះលើសត្រូវមក តេជោយ៉តបានឲ្យគេធ្វើឃ្នាងដាក់ខ្នោះខ្លួនមកទទួលទោសនៅវាំង ដែលបានធ្វើគតអ្នកម្នាងនូ។ ព្រះរាជាមិនបានយកទោសទេ ហើយបានបញ្ជាគេឲ្យដោះលែងតេជោយ៉តទៅកាន់តំណែងនៅកំពង់ស្វាយវិញ។

ក្រោយមក តេជោយ៉តក៏បានទទួលជំទាវស្រែនឲ្យធ្វើជាភរិយាហើយបានរួមរស់នៅក្នុងអាណាខេត្តខ្លួនបានសុខតទៅ។

ជាបន្តទៅទៀត ខ្ញុំសូមដកស្រង់អត្ថបទរឿងនេះដែលជាស្នាដៃជំ

*វិសេសមួយរបស់លោក មកបង្ហាញជូនមិត្តអ្នកអានបន្ថែមដើម្បីស្វែងយល់ពីភាពប៉ិនប្រសប់ របស់លោកការតែងនិពន្ធដែលមានលក្ខណៈរស់រវើកផ្នែកវិស័យសិល្បៈមួយនេះ ៖*

...**ស្ដេចសំរែះ:** *អាំ! ជំទាវស្រែន្យ! ជំទាវស្រែន្យលែងប្ដី! យី! ជំទាវស្រែន្យស្អាតណាស់ៗ ឱយើងចង់បានណាស់ៗ*
*(ច្រៀង) ព្ទឈ្មោះនាងស្រែន្យ ចាប់ផ្ដើមស្នេហា ចង់បានកន្និដ្ឋា រួមក្សេមេត្រីៗ អស់អញជាស្ដេច ត្រូវមានមហេសី (ពីរដង) រូបស្អាតប្រិមប្រិយដូចទេពកញ្ញាៗ អាំ! បើតាមស្ដាប់ការៀបរាប់របស់ពួកអាមាត្រ ជំទាវស្រែន្យប្រាកដជាមានក្ដួចចិត្តមកលើយើងមិនខានហាស! ហាស! ហា*
**ឧកញ៉ាពិភា:** *សូមក្រាបថ្វាយបង្គំព្រះករុណា(ឧកញ៉ាពិភាចូលមកដល់)*
**ស្ដេចសំរែះ:** *អើ!*
**ឧកញ៉ាពិភា:** *តើព្រះអង្គទ្រង់ត្រាស ហៅទូលបង្គំចូលគាល់នេះ មានកិច្ចការអ្វីទៅក្រាបទូល?*
**ស្ដេចសំរែះ:** *អើ! មានការមួយសំខាន់ណាស់ លោកឧកញ៉ាពិភាៗ*
**ឧកញ៉ាពិភា:** *ព្រះករុណាថ្លៃវិសេសៗ*
**ស្ដេចសំរែះ:** *មហាតលិករបស់យើងបានមកទូលថា ជំទាវស្រែន្យឈ្លោះទាស់ទែងនិងតេជោមាសជាស្វាមីរហូតលែងលះគ្នា ហើយចែកទ្រព្យសម្បត្តិគ្នារៀងខ្លួនៗ ហាស! ហាស! ហា! ឥឡូវនេះ នារីស្រែន្យមកបើកផ្ទះ លក់ត្រីធ្មើត និងលក់គ្រឿងអាវុធនៅផ្សារកំពង់ហាវមែនទេ?*
**ឧកញ៉ាពិភា:** *ករុណាថ្លៃវិសេស រឿងនេះពិតដូចបន្ទូលព្រះអង្គមែនក្រាបទូលៗ*
**ស្ដេចសំរែះ:** *អូមែន! អេះៗ*

***ឧកញ៉ាពិភា:*** ឯផ្ទះលក់អាវុធនោះ គឺមានសុទ្ធតែកាំបិតផ្គាក់ ហើយនិង ដាវល្អៗណ៎ាព្រះអង្គ។

***ស្តេចសំរែ:*** អើ! មិនតែប៉ុណ្ណោះ មហាតលិកវាបានទូលថា ពួកអ្នកបម្រើ របស់ជំទាវស្រែន្យ ដែលកាន់កាប់ផ្ទះលក់ត្រីងៀត និងផ្ទះលក់អាវុធនោះ បើឃើញពលទាហាន របស់គេដោមាសទៅទិញត្រីងៀតគេលក់ថ្លៃ ណាស់។ ប៉ុន្តែ...ហេះហេ! បើពលទាហានយើងទៅទិញគេលក់ថោកជា ទីបំផុត។ ដូច្នេះជំទាវស្រែន្យ ច្បាស់ជានាងក្ងួចចិត្តស្រឡាញ់យើងហើយ ។ លើសពីនេះទៅទៀត ឮថានាងស្អាតដូចទេព អប្សរអីចឹង ហឺះ..... ហ៊ឹ.........។

***ឧកញ៉ាពិភា:*** ព្រះករុណាជាអម្ចាស់ ពិតដូចជាពាក្យមហាតលិកពិត ប្រាកដណាស់។

***ស្តេចសំរែ:*** ប្រាកដមែន?

***ឧកញ៉ាពិភា:*** ជំទាវស្រែន្យទើបតែមានអាយុ២៨ឆ្នាំប៉ុណ្ណោះ។

***ស្តេចសំរែ:*** ២៨ឆ្នាំ? អូ!

***ឧកញ៉ាពិភា:*** ព្រះករុណាថ្លៃវិសេស ក៏ប៉ុន្តែមិនទាន់មានកូនមួយសោះ។ ចំណែករូបសោតទៀត នែ៎ សាច់ក៏ស្អាត លើសក្រមុំព្រហ្មចារីយ៍ ដែល ទើបចេញពីម្លប់ទៀតណ៎ា ព្រះអង្គ។ [...]

## ២ លោកស្រីចាំល់ វណ្ណារីរក្សា

ខាងក្រោមនេះខ្ញុំដកស្រង់រឿងមួយមានចំនងជើងថា "បំភ្លេចមិន បាន" ដែលជាស្នាដៃដ៏ពិសិដ្ឋរបស់អ្នកស្រីដើម្បីមកបង្ហាញជូនមិត្តអ្នក អាន។ វណ្ណកម្មអក្សរសិល្ប៍នេះ ត្រូវបានជាប់ចំណាត់ថ្នាក់លេខមួយស្នូ ពានរង្វាន់ព្រះសីហនុរាជឆ្នាំ១៩៩៥ គឺជាស្នាដៃដ៏ល្អមួយដែលមាន

សកម្មភាព រស់រវើកផ្អែកអារម្មណ៍។ វណ្ណកម្មអក្សរសិល្ប៍រឿងនេះត្រូវបានបោះពុម្ពចំនួនពីរដងមកហើយ។

[...] អតីតកាលផុសឡើងភ្លែតៗក្នុងខួរក្បាល ដូចខ្សែភាពយន្ត កាលពីឆ្នាំ ១៩៧៩ រីយ៉ាមានឈ្មោះដើមថា ចរិយា នាងជាក្មេងកំព្រា កាលណោះនាងមានអាយុ៦ឆ្នាំ ឪពុកម្តាយក្មេងស្លាប់ដោយសារបេបប៉ុល ពត។

លើផែនដីដ៏ធំធេង រីយ៉ា រស់ក្បាលមួយ តែលតោលសោត អណ្តែតអត់ទីពឹង គ្មានជម្រក របបចិញ្ចឹមជីវិតរបស់ក្មេង គឺដើរសុំទានគេគ្រប់ច្រកល្ហក។ ទ្រព្យសម្បត្តិពិសិដ្ឋរបស់ចរិយា មានតែសំពត់ខ្មៅកញ្ចាស់ រហែករយ៉ៃ អាវខ្មៅពក្ងក់រហែកច្រៀតផ្សៀក ពណ៌ឡើងប្រផេះសខ្មង មើលស្ទើរមិនស្គាល់ជាពណ៌អ្វីឲ្យចំ។

ព្រះអាទិត្យរះថ្មើរណា ជើងចរិយាឈានតត្រុក ជាមួយដៃកាន់ផ្តិលរយេះមាត់ ដើរចច្រប់តាមផ្ទះតាមផ្លូវ...កាកសំណល់ជាទាន ក្មេងទទួល ដោយរងនូវពាក្យស្តីបន្ទោស គម្រោះគំរើយ រម៉ាំងរម៉ោក។ ដៃលើកបាយពមជាមួយទឹកភ្នែក ប្រដេញកាត់ផែនថ្ពាល់ខ្វង...កម្សត់ខ្លួនពន់ពេក តែចរិយាគ្មានពំនឹងច្រកកោន...

យប់ត្រង់ណា ត្រង់ហ្នឹងជាជម្រក ព្រះធរណីជាគ្រែពូកវិចិត្រផ្ទៃមេឃអមដោយតារា ឬដួងច័ន្ទជាចង្កៀង លម្ហអាកាសជុំវិញខ្លួនជាស្បៃមុង។ ជីវិតកំព្រា កំញើញក្មេងឲ្យរស់ក្នុងភាពរន្ធត់ ដោតជាំជាមួយការភ័យខ្លាច...រាត្រីដ៏ខ្មៅងងឹត ក្មេងខ្លាចញាក់សាច់ ដេកមិនលក់ អង្គុយឱបដៃកំប្រោនៗ បើកភ្នែកម៉ក់ៗ សម្ងឹងជើងមេឃបន់ឲ្យថ្ងៃឆាប់រះ...ជំនោររាត្រីបក់មក ក្មេងកំព្រារងារញ័រតត្រុនរណ្តំថ្គាម បើសិនជាមានព្រះពិរុណបង្អុរផង នោះភាពវេទនាពិតជារៀបរាប់មិនអស់។ ជួនកាលសត្វ

កណ្ដុរតូចសោះ យំឆ្លងឆ្លើយគ្នា វិរិយាភ័យស្ញើត ដេកមិនលក់ អង្គុយយំគគ្រូកៗ មានយប់មួយនោះ ខ្លាដេញព្រួសដណ្ដើមកន្ទែងនាងដេក នាងតូចរត់សស្ញើត ក្អែកនៅកញ្ចឹងក យំសសឹករត់កាត់ភាពអន្ធការសូន្យសុង មិនដឹងស្រែកហៅឲ្យនរណាជួយ បើគ្មានម៉ែ គ្មានឪ គ្មានញាតិសណ្ដាន...ក្មេងរត់...រត់ទៅបុក យុទ្ធមិត្តកងទ័ពម្នាក់គំពុងដើរល្បាត...គឺពេលនោះហើយដែលទំព័រជីវិត វិរិយាប្រាសចាកភាពតៃលតោល ត្រម៉ង់ត្រមោច មករស់ក្នុងមជ្ឈមណ្ឌលកូឡាបដែលមាតុភូមិបានបង្កើតក្នុងគោលបំណងស្រោចស្រង់វាសនាលិចលង់របស់កុមារកំព្រា រាប់ម៉ឺនសែននាក់ៗ ... ...

-នាងតូច... នាងមិនខុសពីរូបមីងកាលពីអតីតកាលទេ...ជាងដប់ប្លាយឆ្នាំមុន ជីវិតមីងមានការផ្លាស់ប្ដូរ ព្រោះតែ...តែ...តែ...សត្វខ្លាដេញខាំដូចជានាងដែរ។ កាលណោះមីងជាក្មេងក្ងើ ល្ងើនិវគុណពូម្នាក់ ដែលជាអ្នកមានគុណ។ មីងមិនបានសួរនាំពីឈ្មោះរបស់គាត់...មីងមិនស្គាល់ពីអស័យដ្ឋានគាត់...លុះដល់ពេលមីងមានអ្វីៗសព្វបែបយ៉ាង តែមីងគ្មានឱកាសតបស្នងដល់អ្នកមានគុណ ដែលសង្គ្រោះមីងពីចង្កូមសត្វខ្លា... នាងតូចនាងមិនត្រូវដើរតាមគន្លងចាស់របស់មីងទេ...នាងប្រញាប់សួរឈ្មោះលោកដ៏មានគុណនេះណ៎ា។

-ចា៎ស លោកស្រី "ក្មេងសុំទានឆ្លើយទាំងងាកមើលទៅពូនោះស្ដីបន្ត" លោកតាឈ្មោះអី សុំប្រាប់ចៅផង។

ពូនោះឥតបានឆ្លើយតបទៅក្មេងទេ គាត់ឈរកាំងក្ងឹកក្ងាំងភ្នែកផ្ដោតភ្ជាប់រង្វង់មុខវិរិយា ទឹកមុខគាត់ប្រែប្រួលយ៉ាងចម្លែក...ភាពរំភើបដោយក្ដីអំណរ លេចជាមួយស្នាមញញឹម រួចវាចាញ័រៗលាន់ឡើងពីបបូរមាត់បុរសចំណាស់៖

- លោកស្រី...លោកស្រី...គឺ...គឺចរិយារបស់ពូឬ?

-ពូ...ពូ...ថាម៉េច...ពូស្គាល់ឈ្មោះកំណើតខ្ញុំ?

- បានន័យថា គឺពិត... ពិតជាចរិយាដ៏កម្សត់របស់ពូមែនហើយ។ ចរិយាដែលត្រូវខ្មែរក្រហមដេញខាំ ពីដប់ប្លាយឆ្នាំមុន...ចរិយាក្មួយសម្លាញ់...ពូដាប់រវល់ការកិច្ច ពូភ្លេចឯងសូន្យឈឹង។ [...]

ក្រៅពីបណ្ដាអ្នកនិពន្ធដែលបានរៀបរាប់ខាងលើនេះ នៅមានអ្នកនិពន្ធជាច្រើនទៀត ដែលសុទ្ធតែមានស្នាដៃបានចុះផ្សាយនៅលើទំព័រសៀវភៅ ហើយបានបំពេរអារម្មណ៍អ្នកអានប្រកបដោយទេពកោសល្យអប់រំក្នុងន័យតម្លៃជាតិយ៉ាងធំធេង។ លោកទាំងនោះគឺពិតជាវិស្វករព្រលឹងយ៉ាងពិតប្រាកដ ព្រោះមានតែលោកទាំងនេះហើយ ដែលអាចបំពេរអារម្មណ៍ និងអប់រំមនុស្សសម័យថ្មីឲ្យយល់ថាអ្វីដែលហៅថាតម្លៃជាតិពិតប្រាកដ។ បណ្ដាអ្នកនិពន្ធទាំងនោះមានដូចជា៖

| | | |
|---|---|---|
| លោកស្រីម៉ៅ សំណាង | រឿងបំណុលចុងក្រោយ | ១៩៨៦ |
| | រឿងទន្សាយស្ដាយចន្ទ | ១៩៨២ |
| | រឿងកោះផ្កាច់និស្ស័យ | ១៩៨២ |
| លោកយក់ គុណ | រឿងជីវិតជូរចត់ក្នុងរបបប៉ុល ពត | ១៩៨៣ |
| | រឿងថ្ងៃរះនៅភូមិថ្មី | ១៩៨៧ |
| | រឿងកុកញីឈ្មោល | ១៩៨៨ |
| លោកនន្ទ ចន្ទ | រឿងចម្រៀងលើសមរភូមិចុងក្រោយ | ១៩៨៣ |
| | រឿងព្រលឹង | ១៩៨៦ |
| | រឿងផ្ការីកពេលអរុណរះ | ១៩៨៦ |
| | រឿងជួបគ្នាកន្លែងភ្លើងឆេះ | ១៩៨៨ |

| | | |
|---|---|---|
| លោកយ៉ូវ សំផុន | រឿងម្រាមបួន | ១៩៨៦ |
| | រឿងចិត្តម្ដាយ | ១៩៨៧ |
| | រឿងទំនួញខ្ទើងឯក | ១៩៨៧ |
| | រឿងឈប់យំទៅអូន | ១៩៨៨ |

មកដល់សម័យនេះ ចំនួនអ្នកនិពន្ធមានចំនួនច្រើនណាស់ដែរ ដែលបញ្ហាទាំងនេះហើយ បានជំរុញឲ្យអក្សរសិល្ប៍ខ្មែររឹតតែមានការរីកចម្រើនធំធាត់យ៉ាងឆាប់រហ័សបំផុត កត្តាទាំងនេះក៏ព្រោះតែសន្តិសុខជាតិរឹតតែមានអំណោយផលល្អ សម្រាប់ការសរសេរព្រោះជនវង្វេងផ្លូវរបស់ក្រុមប៉ុល ពតចេះតែមកសារភាពជាបណ្ដើរៗ ពោលគឺគេយល់ពីគោលនយោបាយអ្នកដឹកនាំដែលស្រឡាញ់សន្តិភាព ស្រឡាញ់ការអភិវឌ្ឍន៍ជាតិជាធំ រហូតដល់បានសម្រេចផលជាផ្លែផ្កាបន្តបន្ទាប់ៗ

មិនថាតែអក្សរសិល្ប៍តែងនិពន្ធប៉ុណ្ណោះទេ ដែលទទួលការរីកចម្រើនស្គុះស្គាយនោះ សូម្បីតែវិស័យសិល្បៈចម្រៀង អាយ៉ៃ ល្ខោន ភាពយន្ត... ក៏មានការរីកចម្រើនណាស់ដែរដោយសង្កេតឃើញកាលនោះមានផលិតកម្មក្នុងស្រុកថតជាកាសែ្សតលក់ ថតជាភាពយន្តសម្រាប់ការដាក់បញ្ចាំងជូនមិត្តទស្សនិកជនបានទស្សនា ក្នុងស្រុក និងមានផលិតកម្មខ្លះនាំចេញទៅបញ្ចាំងនៅបរទេសផងដែរ ដែលនេះជាកិត្តិយសមួយសម្រាប់ជាតិដែលទើបងើបពីសង្គ្រាមៗ អ្នកចម្រៀង អ្នកសិល្បៈ ក៏កាន់តែមានការកើតឡើងដែរ ចំណែកការស្លៀកពាក់ដែលជាធាតុចាំបាច់មួយក្នុងការផ្សព្វផ្សាយអក្សរសិល្ប៍ក៏រឹតតែមានកែប្រែជាបន្តបន្ទាប់ៗ

អាស្រ័យដោយការរីកចម្រើននេះហើយ ចរន្តអក្សរសិល្ប៍ខ្មែរក៏បានឈានមកដល់សម័យកាលមួយ ជាសម័យកាលស៊ីវិល័យខាបច្ចេកវិទ្យាបន្ទាប់ពីមានព្រឹត្តិការណ៍ថ្ងៃទី១៥-១៦ខែកក្កដា ឆ្នាំ១៩៩៧មក

នឹងជាពិសេស គឺចាប់តាំងពីរបបពួកបះបោរប៉ុល ពតចូលមករួមរស់ជាមួយថ្នាក់ដឹកនាំជាតិមក ហើយសន្តិសុខជាតិក៏ត្រូវបានធានានោះ សន្ទុះអក្សរសិល្ប៍រឹតតែមានការរីកចម្រើន យ៉ាងមហិមា។ នេះជាកិត្តិយសមួយសម្រាប់អ្នកសិក្សាអក្សរសិល្ប៍ខ្មែរ ពិសេសសម្រាប់អ្នកដែលស្រឡាញ់អក្សរសាស្ត្រជាតិពិតប្រាកដ។

# អក្សរសិល្ប៍សម័យទំនើប ឬអក្សរសិល្ប៍សម័យបច្ចុប្បន្ន
## ឆ្នាំ១៩៩៣...

### ចរិតលក្ខណៈទូទៅនៃអក្សរសិល្ប៍សម័យទំនើប

*ដែលហៅថាអក្សរសិល្ប៍សម័យទំនើប នៅទីនេះសំដៅដល់បណ្ដាស្នាដៃទាំងឡាយណា ដែលបានប្រសូតក្រោយការបោះឆ្នោតឆ្នាំ ១៩៩៣ជាដរាបរៀងមក។ អក្សរសិល្ប៍ប្រភេទទាំងនេះមានលក្ខណៈទំនោរទៅរកបែបផែនថ្មី បម្រើអារម្មណ៍ថ្មីដែលមានគ្រប់រសជាតិ ហើយឈរលើនិន្នាការ នៃទម្រង់ថ្មីមួយបម្រើដល់គំនិតមនុស្សសម័យថ្មីដែលមានលក្ខណៈល្អខាងសំនួន ក៏ដូចជាការប្រើពាក្យពេចន៍លែងសូវមានការព្រួយបារម្ភពីសុវត្ថិភាពស្នាដៃដែរ។ អាស្រ័យដោយប្រទេសកម្ពុជាបានងាកមកការគ្រប់គ្រងប្រទេស តាមបែបលទ្ធិប្រជាធិបតេយ្យ ដូច្នេះបណ្ដាស្នាដៃក៏មានការរីកចម្រើន ទៅតាមបរិបទនៃសង្គមដ៏ជឿនលឿននេះដែរ។ គេតែងឲ្យតម្លៃថា មកដល់សម័យនេះ វណ្ណកម្មអក្សរសិល្ប៍សម័យទំនើប មាននិន្នាការប្លែកៗពីគ្នាមានដូចជា៖*

*-ស្នាដៃអក្សរសិល្ប៍មានទំនោរទៅរកទៅរកស្វាកស្វាម អតីតកាលសម័យកម្ពុជាប្រជាធិបតេយ្យវិញ។ ស្នាដៃប្រភេទនេះអ្នកនិពន្ធនៅមានកំហឹងឈឺចាប់ជាពន់ប្រមាណចំពោះរបបវាលពិឃាត។ ទោះបីជា*

រយៈកាលនោះកន្លងទៅយូរហើយ តែកំហឹងឈឺចាប់ហាក់ដូចជាមិនទាន់រលាយសោះតែម្តង ឬយ៉ាងហោចណាស់ក៏អ្នកនិពន្ធនៅតែសរសេរក្នុងអារម្មណ៍កថារំឭកពីការឈឺចាប់នោះដែរ បណ្តាអ្នកនិពន្ធដែលបានសរសេរស្នាដៃមានជាប់ទាក់ទង ជាមួយព្រឹត្តិការណ៍ពីសម័យកម្ពុជាប្រជាធិបតេយ្យមានដូចជារឿង **ក្មេងការអេកំព្វ** របស់លោក**គឹម ពេជ្រពីរនន់** រឿង**ក្រលេកមើលភ្លើងឆេះស្រុកខ្មែរពីត្រើយម្ខាង** របស់លោក**ជៀប គឹមហៀង** ជាដើម។

-ស្នាដៃអក្សរសិល្ប៍ ដែលមានទំនោរបង្ហាញពីមនោសញ្ចេតនារបស់យុវវ័យឬបង្ហាញពីភាពក្តៅក្រហាយរបស់យុវវ័យ តែពោរពេញទៅដោយការអប់រំនៅក្នុងនោះមានដូចជា រឿង**មមាចមិនស្គាល់ភ្លើង** របស់អ្នកស្រី**ពាន់ ភួងបុប្ផា** រឿង**ឈាមយុវវ័យ** របស់លោក**អៀង ពិសី** រឿង**សំណោកអនុស្សាវរីយ៍** របស់លោក**សំ សុភារិទ្ធ** ជាដើម។

-ស្នាដៃអក្សរសិល្ប៍ ដែលមានទំនោរបង្ហាញពីភាពលំបាកនៅក្នុងជីវិតរស់នៅក្នុងសង្គមមនុស្ស និងបង្ហាញពីក្តីតស៊ូដើម្បីសម្រេចគោលដៅអប់រំជីវិតតទៅអនាគតឲ្យបានរុងរឿង។ បណ្តាស្នាដៃទាំងនោះមានដូចជា រឿង**សង្សារគ្រូបង្រៀន** របស់លោក**ស៊ុយ វ៉ាន់សាក់** រឿង**ប្រពន្ធគ្រូស្រុកស្រែ** រឿង**ជីវិតថ្មី** រឿង**គំនិតអភិវឌ្ឍ** របស់លោក**អៀង ពិសី**ជាដើម

ខាងក្រោមនេះ ខ្ញុំនឹងដកស្រង់អ្នកនិពន្ធនិងស្នាដៃមួយចំនួនមកបង្ហាញប្រាប់អ្នកអានដើម្បីឲ្យដឹងពីទឹកដៃ របស់អ្នកនិពន្ធយើងដែលប្រសូតនៅសម័យបច្ចុប្បន្ន ដើម្បីឲ្យដឹងថា ទឹកដៃរបស់គាត់តើអាចស្នងរៀមច្បងសម័យមុនបានដែរឬទេ។

សូមប្រិយមិត្តអញ្ជើញអាន នឹងសិក្សាវិភាគជាដូចតទៅៈ

## ១ លោកគីម ពេជ្រពីរនង់

លោកប្រសូតនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៦១ នៅភូមិបន្ទាយ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល។ បិតារបស់លោកមាននាម គីម សេង និងម្តាយមាននាម បាវ ហៀម។ លោកគឺជាមនុស្សម្នាក់ដែលរៀនបានចំណេះដឹងជ្រៅជ្រះ រហូតបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសិល្បៈ(Master of Arts) ។ បន្ទាប់ពីបានបញ្ចប់ការសិក្សា លោកក៏បានទទួលតំណែងជាព្រឹទ្ធបុរសរង មហាវិទ្យាល័យសិល្បៈនាដសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

លោកគឺជាមនុស្សម្នាក់ដែលមានចិត្ត ស្រឡាញ់វិស័យអក្សរសាស្ត្រ ពិសេសគឺវិជ្ជានិពន្ធរបស់លោកតែម្តង ហេតុដូច្នេះហើយបានជាគេឃើញលោកបានបន្សល់ស្នាដៃជាច្រើនផ្នែកអក្សរសិល្ប៍ ដូចជា៖

-រឿងទឹកចិត្តបង(ល្ខោននិយាយ) សរសេរឆ្នាំ១៩៨៣

-រឿងពូគុណកសិករ(ល្ខោននិយាយ) សរសេរឆ្នាំ១៩៨៤

-រឿងកូនកើតមុនឪ(ល្ខោននិយាយ) សរសេរឆ្នាំ១៩៨៥

-រឿងឈើដប់ប្រសប់ដឹងមួយ(ល្ខោន) សរសេរឆ្នាំ១៩៨៦

-រឿងផ្កាក្រហម(ល្ខោនមហោរី) សរសេរឆ្នាំ១៩៨៤

-ពុកយើងនិទានរឿង (រឿងខ្លីៗសរសេរផ្ញើមកពីប៊ុលហ្គារី) ត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៨៧

-សំណើច (រឿងកម្សាន្តខ្លីៗ) សរសេរឆ្នាំ១៩៩៤

-គតិបណ្ឌិតបួនទិស(គំនិតគួរពិចារណា)សរសេរឆ្នាំ១៩៩៥

-ជីវិតនិងមរណៈ(គំនិតគួរពិចារណា) សរសេរឆ្នាំ១៩៩៦

-ប្រវត្តិស្នេហារបស់មហាបុរសក្នុងលោក ភាគ១

-ជីវិតស្នេហារបស់មហាបុរស-ស្ត្រីក្នុងលោក ភាគ១ ភាគ២

-ស្រុកខ្មែរជីវិតខ្ញុំ (កម្រងកំណាព្យ ទទួលរង្វាន់លេខ២) ប្រឡង
ពានរង្វាន់អក្សរសិល្ប៍ព្រះសីហនុរាជ ឆ្នាំ១៩៩៥

-ជំងឺ និងឱសថ អត្ថបទសរសេរជាពាក្យកាព្យ

-អត្ថបទស្រាវជ្រាវអំពីលក្ខណៈទេវៈក្នុងសិល្បៈល្ខោនយីកេ ឆ្នាំ
១៩៩៦ ទទួលបានបណ្ណសរសើរពីមជ្ឈមណ្ឌលវប្បធម៌ និងវប្បស្សនា

-មហាជនក (ល្ខោននិយាយ-សម្រួលចេញពីទសជាតក)

-អំពើល្អ និងអំពើអាក្រក់

-សម្ភីមាសក្នុងវិស័យសិល្បៈ

-ក្មេងការអភ័ព្វ (ប្រលោមលោក) ចំណាត់ថ្នាក់លេខ២ ពាន
រង្វាន់អក្សរសិល្ប៍ **៧ មករា**

-សម្ភីមាសក្នុងវិស័យអក្សរសិល្ប៍

-ប្រវត្តិអ្នកនិពន្ធរឿងល្ខោនដែលមានឈ្មោះល្បីក្នុងលោក

-ប្រវត្តិសង្ខេបរបស់អ្នកនិពន្ធរឿងល្ខោនក្នុងលោក

-ស្វែងយល់អំពីល្ខោន

ជាបន្ត ខ្ញុំស្រង់ស្នាដៃរបស់លោកមួយរឿងគឺរឿង **ក្មេងការអភ័ព្វ** ដែលជារឿងទទួលបានពានរង្វាន់អក្សរសិល្ប៍៧ មករាចំណាត់ថ្នាក់លេខ២មកធ្វើការបង្ហាញដូចតទៅៈ

"...ក្រោយមកទៀត នៅពេលដែលចប់ពិធីចាប់ដៃផ្សំផ្គុំនោះ លោកអាចារ្យក៏បង្គាប់ឲ្យគេរៀបចំធ្វើពិធីបើកបាយស្រី ឬរាំបើកទៀនៗ ក្នុងពិធីនេះ ខ្ញុំឃើញអ្នកក្មេងប្រុសម្នាក់ចូលមកច្រៀងរាំដាវដៃម្ខាងកាន់ជង ដៃម្ខាងទៀតកាន់ស្រោម ហើយហូតដាវនិងច្រៀងបញ្ជាក់ពីមហិទ្ធិឫទ្ធិនៃដាវដែលលោកអាចារ្យប្រគល់ឲ្យសម្រាប់ការពារសត្រូវៗ បន្ទាប់

មកអ្នកច្រៀងជដែលនេះ ក៏យកសំពត់ស្បៃ៥ហត្ថមកក្រវាត់ និងច្រៀងបញ្ជាក់ពីទឹកចិត្តក្លាហានរបស់បុរសដែលមានដើមទ្រូង៥ហត្ថ ហើយចុងក្រោយនៃពិធីនេះ គាត់ចាប់រាំបើកទៀបមួយគូ ដោយច្រៀងបញ្ជាក់ពីគុណភាពទៀបមួយគូនោះថា ជាទៀបដ៏មានតម្លៃថ្លៃថ្លាគ្មាននរណាម្នាក់ក្រៅពីលោកមេបាបញ្ជាឲ្យបើកបានទេ។ លុះចប់ពិធីនេះហើយ ក៏ចូលដល់ពិធីចងដៃកូនប្រុសកូនស្រី។

ពេលនោះម៉ោងប្រមាណជា៧ យប់ទៅហើយ ភ្លេង "**បាយខុនចងដៃ**" បានប្រគំឡើងគួរឲ្យរំភើបចិត្ត។ ខ្ញុំបានលួចជៀងភ្នែកក្រឡេកញញឹមទៅរកធីតា ដែលពេលនោះនាងក៏លួចញញឹមយ៉ាងប៉ប្រិមមករកខ្ញុំវិញពោរពេញទៅដោយក្ដីរំភើបរីករាយឥតព្រំដែន។ ញាតិមិត្តជិតឆ្ងាយ លោកមេបាតូចធំ ក្រមុំកំលោះ ក៏ចាប់អំបោះពណ៌សដែលនៅគងលើមាត់ផ្ដិលយកមកចងដៃឲ្យខ្ញុំ និងធីតាជាការប្រសិទ្ធពរជ័យសិរីមង្គល និងទទួលស្គាល់ថា យើងទាំងពីរគឺពិតជាបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរពិតប្រាកដមែន។ មួយរំពេចនោះ ទន្ទឹមនឹងក្ដីរំភើបរីករាយ ខ្ញុំហាក់ដូចជាបានទទួលអារម្មណ៍មិនល្អមួយដែលនាំឲ្យព្រួយ និងឈឺផ្សាក្នុងចិត្តឥតឧបមា ព្រោះថា ពេលនោះខ្ញុំបានឃើញអាលីន!...តែចុះឯណាប្អូនលក្ខណា? តើពេលនេះនាងកំពុងស្ថិតនៅទីណាដែរ? តើនាងបានដឹងទេថា ថ្ងៃនេះលក្ខណ៍បងប្រុសបង្កើតរបស់នាងកំពុងរៀបការ? រយៈពេល២ឆ្នាំកន្លងទៅនេះ តើនាងធំប៉ុណ្ណាហើយ? ទេ! ក្រែងនាងស្លាប់បាត់ហើយទេដឹង? ទេ! មិនអាចទៅជាអញ្ចឹងទេ! ឱលក្ខណាអើយ...តើអូនស្លាប់មែនឬយ៉ាងណា? ម្ដេចក៏បាត់ដំណឹងសូន្យឈឹងយ៉ាងនេះ? បើអូននៅ ម្ល៉េះសមអូនចូលមករកខ្ញុំសុំអំបោះចងដៃមុនគេហើយមើលទៅ! ឱ អារម្មណ៍ខ្ញុំ...

ក្នុងពេលដែលកំពុងរាយមាយពីរឿងសោកស្រណោះអាឡោះអាល័យប្អូនលក្ខណានេះ ស្រាប់តែក្រុមអ្នកភ្លេងដែលកំពុងលេងបទ "បាយខុនចងដៃ" បញ្ឈប់ការប្រគំរបស់ខ្លួនយ៉ាងសោះកក្រោះ...!

-មានរឿងអ្វីហ្នឹង?

-មានដំណឹងមិនល្អ!

-ត្រូវផ្អាកពិធីនេះជាបន្ទាន់!

ពេលនោះសភាពជ្រួលច្របល់ បានចូលមកកាត់ពិធីចងដៃកូនប្រុសកូនស្រី ធ្វើឲ្យភ្ញៀវគ្រប់គ្នាមីម្នាចាកចេញពីផ្ទះការជាបន្តបន្ទាប់រាប់ដោយទាំងអ្នកភ្លេង អ្នកកំដរ លោកមហា តាអាចារ្យ ព្រមទាំងញាតិមិត្តជិតឆ្ងាយ ក៏រំសាយខ្លួនយ៉ាងរហ័សសម្តៅគេហដ្ឋានរៀងៗខ្លួន។ ក្នុងពេលជាមួយគ្នានេះ ខ្ញុំឃើញស្វាយត្រាណដែលមានកាំភ្លើងនៅដៃ បានចូលមកជួបនិយាយការអ្វីជាមួយនឹងឪពុកម្តាយខ្ញុំ និងឪពុកម្តាយរបស់ធីតាទាំងទឹកមុខភ័យព្រួយ និងស្ងន់ស្ញោ។បន្តិចក្រោយមក ម្តាយខ្ញុំដែលមានទឹកមុខស្លេកស្លាំងក៏តាំងប្រញាប់ចូលមកប្រាប់ខ្ញុំទាំងត្រហេបត្រហបថា៖

-ឆាប់ផ្លាស់ខោអាវចេញទៅ! មានគេឲ្យដំណឹងមកថា ទ័ពព្រៃប្រុងចូលមកវ៉ៃភូមិយើងឥឡូវនេះហើយ!

-កងស្វ័យត្រាណបានប្រាប់យើងថា បន្តិចទៀតនឹងមានផ្ទុះអាវុធ! (ពុកខ្ញុំបានបន្ថែមព្រមទាំងដេញអាលីន និងអាលួតឲ្យទៅផ្ទះរៀបចំបង្វិច)។ ខ្ញុំមិនបានសួរទៅឪពុកម្តាយខ្ញុំអ្វីទៀតទេ។ ខ្ញុំក៏ប្រញាប់ដោះសម្លៀកបំពាក់អាពាហ៍ពិពាហ៍ ចេញទាំងអារម្មណ៍ញាប់ញ័រពន់ប្រមាណ។ ក្នុងពេលជាមួយគ្នានេះដែរ ស្រាប់តែឃើញធីតាដើរចេញមកពីក្នុងបន្ទប់ក្នុងសម្លៀកបំពាក់ធម្មតា ហើយវាចារមកកាន់ខ្ញុំទាំងក្រៀមក្រំបំផុតថា៖

-បងលក្ខណ៍ បងនៅទីនេះហើយ!

ខ្ញុំមិនបានឆ្លើយទៅធីតាវិញទេ តែពេលនោះខ្ញុំបានងក់ក្បាល ហើយសម្លឹងមើលចំទៅកែវភ្នែករបស់នាង ដែលកំពុងតែរលីងរលោង ទាំងក្ដីអាណិត និងហួសចិត្តចំពោះព្រឹត្តិការណ៍ដ៏មហាចង្រៃឧបទ្រព នាពេលយប់អាពាហ៍ពិពាហ៍នោះ។

ខ្ញុំមិនទាន់ទាំងបានប្ដូរអាវរួចស្រួលបួលផង ភ្លើងអគ្គិសនីដែល ឆេះបំភ្លឺពិធីមង្គលការក៏រលត់ រីឯសំឡេងម៉ាស៊ីនភ្លើងក៏លែងឮសូរហើយ ក៏ប្ដូរទៅជាងងឹតឈឹងស្ងាត់ នៅសល់តែកូនពន្លឺទៀននិងសំឡេងផ្គរព្រុស ជាជំនួស។ តែមួយស្របក់តូចប៉ុណ្ណោះ សភាពស្ងាត់ជ្រងំបានព័ទ្ធរុំភូមិ អរិយក្សត្រទាំងមូលឲ្យលុះទៅ ក្នុងអំណាចនៃសភាពតានតឹងនិងភាព បរាជ័យអស់ន័យស្ងួនស្ងាត់ឈឹង។ បរិយាកាសនេះបានប្រព្រឹត្តទៅក្នុង សភាពស្ងប់ស្ងៀម និងគួរឲ្យព្រឺក្បាលអស់រយៈពេល៣ម៉ោងថ្វាយ។

ដោយមិនអាចទុកចោលអាលីន និងអាល្ងួតឲ្យនៅផ្ទះតែពីរនាក់ បាន ឪពុកម្ដាយខ្ញុំ និងខ្ញុំក៏សុំលាគ្រួសារធីតាវិលទៅសម្រាកនៅផ្ទះឯភូមិ បន្ទាយវិញ។ ខ្ញុំបានកាត់ចិត្តលាធីតាមួយរយៈទាំងអស់អែក ព្រោះមិន គួរបែកនាងពេលនេះសោះ។

ពីផ្ទះធីតាមកផ្ទះខ្ញុំមានចម្ងាយ ៦០០ម៉ែត្រ។ នៅតាមផ្លូវ កង ស្វ័យត្រាណ បានមកបញ្ជាក់ទៀតថា យប់នេះឲ្យប្រុងប្រយ័ត្នរៀបចំ ឥវ៉ាន់ឲ្យហើយ និងកុំអាលចេញដើរទៅណាមកណាក្រៅពីផ្ទះឲ្យសោះ ព្រោះខ្មាំងកងការពារគ្នាច្រឡំ។ ឮដូចនេះ ម្ដាយខ្ញុំកាន់តែភ័យខ្លាំងឡើង ហើយគាត់បានតឿនឲ្យខ្ញុំស្រូត ដំណើរឲ្យលឿននឹងអាលបានមកដល់ ផ្ទះ។ ... ...

ក្រោយមកមិនយូរប៉ុន្មាន ថ្ងៃអាពាហ៍ពិពាហ៍រវាងខ្ញុំ ជួប កុសល

និងកញ្ញា ហឿង ចន្ទីក៏ចូលមកដល់នោះគឺថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៨១ ថ្ងៃនេះ មិត្តភក្តិជិតឆ្ងាយកំពុងតែខ្វល់ខ្វាយជួយជ្រោមជ្រែងដោយអស់សមត្ថភាពៗ ចាស់ទុំ លោកយាយ លោកតា គ្រូអាចារ្យ ដែលបានអញ្ជើញមកជាតំណាងខាងកូនប្រុស កូនស្រីក៏កំពុងតែមមាញឹកជួយចាត់ចែងពិធីរៀបការ មូលមីរ អ៊ូអរ កំដរទៅដោយបទភ្លេងការលាន់រងំ...

និមិត្តឮតែពាក្យនេះភ្លាម ចន្ទី និងខ្ញុំក៏ងាកមើលមុខគ្នាដោយសការៈ...ម៉េចក៏យើងទាំងពីរនាក់ស្គាល់មីងសាន?

ក្នុងពេលជាមួយគ្នានេះ ស្រាប់តែមីងសាន ពូប៊ិន និងសំបូរ ដែលបានមកដល់ហៀបតែចងដៃហើយនោះ ក៏បានឧទានឡើងទាំងភ្ញាក់ផ្អើល និងឆ្ងើងឆ្ងល់ ខ្វល់ខ្វាក់ ល្អក់គំនិត ព្រោះនឹកមិនដល់៖

-លក្ខណ៍ និងលក្ខណា ?

- ក្មួយលក្ខណ៍!

- បងស្រីលក្ខណា!

ក្នុងខណៈដ៏ខ្លីនេះ រូបខ្ញុំហាក់គ្មានព្រលឹង និងច្របល់ក្នុងគំនិតគិតមិនយល់៖

-ចន្ទី គឺលក្ខណា!

-មែនហើយលក្ខណ៍ នេះគឺលក្ខណាប្អូនស្រីពៅរបស់ក្មួយហើយ ៗ លក្ខណាក្មួយស្រី នេះគឺលក្ខណ៍ បងប្រុសបង្កើតរបស់ក្មួយហើយ!

ពេលនេះ លក្ខណា និងខ្ញុំបានក្រោកអង្គុយទាំងស្រឡាំងកាំង... តាអាចារ្យ តំណាងមេបា គ្រូអាចារ្យ ជំនាញការរៀបការតាមព្រមទាំងភ្ញៀវកិត្តិយសទាំងអស់ក៏ទៅជាស្រឡាំងកាំង ហើយក្រុមអ្នកភ្លេងក៏ភ្ញាក់នឹករកបទមិនទាន់ក៏គាំងគាំង និងបញ្ឈប់ការប្រគំនៅកណ្ដាលទី...

-រៀបការចំបងប្អូនឯងបង្កើត!

ខ្ញុំបានសម្លឹងចំមុខលក្ខណាសារជាថ្មី...មែន! នៅលើស្មាខាងស្តាំរបស់នាងមានស្នាមរបួសតូច ដូចកាលពី១១ឆ្នាំមុន ។ខ្ញុំបានយកដៃទៅកាន់ស្មានាងថ្នមៗ រួចហើយនិយាយទាំងរំភើបញាប់ញ័រហួសប្រមាណថា៖

-លក្ខណា! កាលពី១១ឆ្នាំមុន អូនត្រូវរបួសត្រង់ក្បាល និងស្មានេះ ហើយជាពិសេស អូនមានប្រជ្រុយពណ៌ក្រហមមួយនៅក្រោមទ្រូងខាងឆ្វេងមែនទេ? បើដូច្នេះមែន អូនគឺជាលក្ខណា ប្អូនស្រីពៅរបស់បងមែនហើយ! ឈ្មោះកុសល មិនមែនជាឈ្មោះពិតរបស់បងទេ ឈ្មោះពិតរបស់បង គឺលក្ខណ៍...គឺលក្ខណ៍គឺជាបងបង្កើតរបស់លក្ខណា! ...

## ២ លោក ជៀប គឹមហៀង

លោកប្រសូតនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៤៥ មានទីលំនៅភូមិស្លូង ឃុំស្លូង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។ បិតាលោកនាមជៀប ជិន-ឡេង និងមាតានាម តាំង អេង។

លោកបានទទួលការសិក្សាដំបូង នៅសាលាបឋមសិក្សាស្លូង រួចបន្តមកសិក្សានៅអនុវិទ្យាល័យស្លូង និងមកបន្តការសិក្សាបន្តនៅវិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាមរហូតដល់បញ្ចប់មធ្យមសិក្សាប័ត្រភាគទី២ទៀតផង។

បន្ទាប់ពីបញ្ចប់ការសិក្សាចំណេះទូទៅរួចមក លោកក៏បានបន្តការសិក្សានៅមហាវិទ្យាល័យកេរ្យត្រសាស្ត្រចម្ការដូង ជំនាន់ទី១ផ្នែកបសុ-ពេទ្យ។ បន្ទាប់មក លោកក៏បានបន្តការសិក្សានៅទីក្រុងប៉ារីសក្នុងអំឡុងឆ្នាំ១៩៧០ ដោយកាលណោះលោកទទួលបានអាហារូបករណ៍បារាំង។ លោកក៏បានទៅសិក្សានៅវិទ្យាស្ថានផ្នែកខាងជំនួញអន្តរជាតិ

នាទីក្រុងប៉ារីស។

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ ខ្ញុំរកឃើញស្នាដៃរបស់លោកចំនួនពីរគឺ៖

-រឿង ក្រលេកមើលភ្លើងឆេះស្រុកខ្មែរពីត្រើយម្ខាង ពានរង្វាន់អក្សរសិល្ប៍សន្តិភាពឆ្នាំ១៩៩៧ ចំណាត់ថ្នាក់លេខ១ ផ្សាយចេញពីសមាគមអ្នកនិពន្ធខ្មែរនៅបរទេស។

-រឿងពន្លឺផ្កាយ ពានរង្វាន់អក្សរសិល្ប៍សមាគមនូ ហាចឆ្នាំ ២០០៩

ខាងក្រោមនេះ ខ្ញុំដកស្រង់រឿង ក្រលេកមើលភ្លើងឆេះស្រុកខ្មែរពីត្រើយម្ខាង ជាអត្ថបទសង្ខេបមកបង្ហាញជូនមិត្តអ្នកអានដូចតទៅ៖

លោកសម្បត្តិ មានឈ្មោះតាបសបានប្រើបានដើរកម្សាន្តតាមមាត់ទន្លេ ដែលពោរពេញទៅដោយសេចក្តីនឹករឭកទៅនារីម្នាក់ ដែលនាងធ្លាប់ស្បថសច្ចាជាមួយគ្នា នៅមុខព្រះអង្គ**ជង់កើ**ថាសូមព្រះអង្គជួយឲ្យពួកគេជួបគ្នានៅថ្ងៃខាងមុខ។ ក្រោយពីភ្លេងពិណពាទ្យត្រូវបានបញ្ចប់ លោកសម្បត្តិក៏បានជួបនារីម្នាក់ដែលលោកទន្ទឹងរង់ចាំពល់ថ្ងៃ។ នាងបានមកពី ទីក្រុងឡុងប៊ិចរដ្ឋកាលីហ្វ័រនី សហរដ្ឋអាមេរិក ហើយដែលបានបែកគ្នាក្នុងសម័យស្រុកទេសមានសង្គ្រាមផ្ទៃក្នុង។ នាងម្នាក់នេះហើយ ដែលលោកសម្បត្តិមានសេចក្តីនឹករឭកគ្មានភ្លេច។ នាងមានឈ្មោះដានី តែលោកសម្បត្តិចូលចិត្តហៅនាងថា អប្សរ។ ឈ្មោះលោកថា តាបស់ក៏នាងបានដាក់ឲ្យដែរ។បន្ទាប់ពីបានសំណេះសំណាលគ្នាយ៉ាងយូរ ពួកគេក៏បានណាត់ជួបគ្នានៅថ្ងៃស្អែក។

ម៉ោងប្រាំពីរព្រឹកនាងដានីហៅអប្សរ បានទូរស័ព្ទមកតាបស

ហើយគាត់បានយករថយន្តម៉ែរសេដែស មកទទួលនាងដល់ផ្ទះនៅម៉ុំទួលគោក ហើយថានឹងនាំគ្នាទៅញ៉ាំគុយទាវ។ តាមផ្លូវអ្នកទាំងពីរបាននិយាយ រំឭកអនុស្សាវរីយ៍នៅពីមុខព្រះអង្គដងកើដែលជាអនុស្សាវរីយ៍ស្នេហាដ៏បរិសុទ្ធមួយ បានកើតឡើងក្នុងវ័យដែលអ្នកទាំងពីរនៅកម្មោះក្រមុំ។

លោកសម្បត្តិពុំទាន់នាំនាងដានីទៅញ៉ាំគុយទាវភ្លាមទេ តែគាត់បាននាំនាងទៅអតីតផ្ទះលោកឧត្តមសេនី "រាហ៊ូ"ដែលត្រូវជាឪពុកមារបស់នាងដានី។ ផ្ទះមួយនេះ ត្រូវបានសាងសង់ឡើងដោយការកេងបន្ទំលុយទាហាន។ លោកបាននិយាយរឿងកាលនៅសម័យបារាំង លោកសម្បត្តិធ្លាប់បាន សរសេរអត្ថបទចុះផ្សាយក្នុងកាសែតខ្មែរប្រឆាំងនាយទាហាន និងឧត្តមសេនី ហើយកាលនោះត្រូវបានគេមកចាប់ខ្លួនលោក ព្រមទាំងបានព្រមានដល់ម៉ែឪលោកទៀតផង។

នៅផ្ទះលោករាហ៊ូ នាងដានីឬទេពអប្សរបានមើលឃើញសៀវភៅចាស់ៗជាច្រើន ដែលលោកសម្បត្តិបានប្រមូលយកទុក ពិសេសគឺនាងបានមើលឃើញរូបថតកូនប្រុសធំ និងភរិយារបស់គាត់ជនជាតិបារាំងថតនៅពីមុខសំណង់TourEiffel។ ប្រពន្ធជាតិបារាំងរបស់តាបស់គឺមីសែល ជាវិជ្ជបណ្ឌិតវះកាត់យ៉ាងជំនាញ ហើយកូនធំរបស់គាត់ឈ្មោះធានីក៏ជាវិជ្ជបណ្ឌិតដែរ។ អ្នកទាំងអស់គ្នា បានស្ម័គ្រចិត្តមកធ្វើជា "ក្រុមគ្រូពេទ្យឥតព្រំដែន" នៅព្រំប្រទល់ខ្មែរថៃក្នុងឱកាសដែលស្រុកខ្មែរកើតសង្គ្រាម។ អ្នកទាំងអស់គ្នាត្រូវបាត់ខ្លួននៅពេលនោះដែរ ទោះបីជាយ៉ាងណាក៏ពួកគាត់បានបំពេញបេសកកម្ម ជួយអ្នករបួសដោយសង្គ្រាមដែរ។

លោកសម្បត្តិហៅតាបស់ បាននិយាយរៀបរាប់រឿងហេតុតាំងពី

ដើមរហូតដល់ចប់ប្រាប់ទៅអប្សរ រហូតដល់រឿងដែលអប្សរបានទៅរៀបការជាមួយសំអឿនបងជីដូនមួយនាង។ បន្ទាប់ពីនោះនាងក៏និយាយរឿងដែលនាងបានរៀបការជាមួយសំអឿនប្រាប់ទៅតាបស់វិញ។ អ្នកទាំងពីរនាក់ក៏បានរំឭកអនុស្សាវរីយ៍ កាលពីពួកគេកំពុងសិក្សានៅប្រទេសបារាំង ដែលកាលនោះនិស្សិតខ្មែរ ត្រូវបានបែងចែកបក្សគ្នាម្ខាងក្រហមម្ខាងខៀវ។ បក្សខាងក្រហម ត្រូវបានគេដឹងថា ដឹកនាំដោយហ៊ូ យន់ ,ហ៊ូ នឹម , ខៀវ សំផន, និងសម្តេចឪតែមិនសាហាវដូចប៉ុល ពតទេ។ ចំណែកខាងបក្សខៀវ ត្រូវបានដឹកនាំដោយលោកឧត្តមសេនីលន់ នល់, ចេង ហេង, សិរីមតៈ ។ បក្សទាំងពីរបានបង្កទំនាស់យ៉ាងខ្លាំង រហូតដល់ត្រូវប៉ូលីសបារាំង ចាប់ដាក់ខ្នោះដេកគុកមួយបន្ទប់៣នាក់។

បន្ទាប់ពីរំឭកអនុស្សាវរីយ៍ អ្នកទាំងពីរ បានទៅទស្សនាប្រទេសខ្មែរជាលើកតំបូង គឺពួកគេបានទៅទស្សនាប្រាសាទអង្គរវត្ត ដែលជាអច្ឆរិយវត្ថុរបស់ពិភពលោក។

បន្ទាប់មកពីលេងនៅសៀមរាប តាបសបានធ្វើពិធីជប់លៀងមួយដើម្បីអបអរអប្សរ ត្រលប់ទៅសហរដ្ឋអាមេរិកវិញ។ ខណៈនោះនាងអប្សរ បានច្រៀងចម្រៀងមួយបទមានចំណងជើងថា "ស្នេកអូនលាបង" បណ្តាលឲ្យអ្នកស្តាប់ សរសើរគ្រប់គ្នាថា ច្រៀងបានពីរោះ។ លុះពេលបញ្ចប់ចម្រៀង ក៏មានស្ត្រីម្នាក់ឈ្មោះស៊ីថា ជាមិត្តចាស់ ហើយនាងបានប្រាប់ពីរឿងហេតុ ដែលសំអឿនស្លាប់ក្នុងឱកាសដែលសង្គ្រាមត្រូវបានបញ្ចប់។

លុះព្រឹកឡើង មុនពេលឡើងយន្តហោះ នាងបានមកហូបបាយនៅផ្ទះម្តាយមីងនាងនៅទួលគោក នឹងបានផ្តាំផ្ញើតាបស់ថា "កុំឲ្យឡើងជំបូលផ្ទះលត់ភ្លើងតែម្នាក់ឯងទៀត" គឺទុកឲ្យគេជួយលត់ខ្លះផង ព្រោះ

ថាបើលត់តែម្នាក់ឯង នោះនាំឲ្យគេឈរក្រពាត់ដៃមើល ឬក៏មកឈរជញ្ជាក់មាត់សរសើរឡានមែសីដែសទៅវិញ។

នាងអប្សរ ត្រលប់ទៅដល់សហរដ្ឋអាមេរិក តាបស់នៅស្រុកខ្មែរបានសម្រេចចិត្តបួសរកសន្តិភាពឲ្យខ្មែរ តែរបបនយោបាយផ្លាស់ប្តូរត្រូវបានតាបស់ផ្អាកសកម្មភាពនេះ ហើយបានទូរសព្ទមកអប្សរ ដើម្បីសុំរស់ជាមួយនាងជាគូស្នេហ៍លុះអវសានជីវិត។

## ៣ លោក ហ៊ី យ៉ាត

លោកប្រសូតនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៥០ នៅភូមិខ្ទរឃុំព្រែកលៀប ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ លោកជាកូនជាទីពីរក្នុងចំណោមបងប្អូនបីនាក់ ក្នុងនោះប្រុសពីរស្រីមួយ។

បិតាលោកនាម ហ៊ី យន់មានមុខរបរជាកសិករ ម្តាយមាននាមខៀវ សយ មានមុខរបរជាកសិករ។

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ លោកបានបន្សល់ស្នាដៃជាច្រើនទុកសម្រាប់ការសិក្សាជំនាន់ក្រោយ ដូចជាៈ

-រឿងវិចិត្រករដៃឯក ជ័យលាភីលេខ២ មហោស្រពអក្សរសិល្ប៍ខេត្តកណ្តាល លើកទី២ ឆ្នាំ១៩៨៦

-រឿងភូមិចំណុច ជ័យលាភីលេខ២ មហោស្រពអក្សរសិល្ប៍ខេត្តកណ្តាលលើកទី៣ ឆ្នាំ១៩៨៧

-រឿងតំណក់ឈាមនៅទល់ដែន ជ័យលាភីលេខ១មហោស្រពអក្សរសិល្ប៍ខេត្តកណ្តាលលើកទី៥ ឆ្នាំ១៩៨៩

-រឿងអ្នកមានគុណ មហោស្រពអក្សរសិល្ប៍ ពានរង្វាន់៧មករា លើកទី១ ឆ្នាំ១៩៩៧

-បេះដូងអប្បលក្ខណ៍ ជ័យលាភីលេខ៣ ពានរង្វាន់អក្សរ-សិល្ប៍ "៧ មករា ឆ្នាំ១៩៩៩" រៀបចំឡើងដោយសមាគមអ្នកនិពន្ធខ្មែរ លើកទី២

-រឿងពពកខ្មៅ ជ័យលាភីលេខ១ ពានរង្វាន់មហោស្រពអក្សរសិល្ប៍ព្រះសីហនុរាជលើកទី៣ ឆ្នាំ១៩៩៩ រៀបចំឡើងដោយសមាគមអ្នកនិពន្ធខ្មែរ

-រឿងស្ពានសួគ៌នៅឯណា? ជ័យលាភីលេខ២ មហោស្រពអង្គរ ឆ្នាំ២០០០

ជាបន្តទៅទៀត ខ្ញុំនឹងដកស្រង់អត្ថបទរឿង**ពពកខ្មៅ**របស់លោកមកបង្ហាញជូនមិត្តអ្នកអានដូចមានសេចក្ដីតទៅ៖

...រថយន្តម៉ាកនីសាន់ ពណ៌ក្រហមរលើបរលោងដូចផ្លែម្ទេសទុំ ស៊េរីថ្មីលូនទៅមុខលាន់ខ្សៀក ក្រោមបញ្ជាម្ចាស់វាលើមហាវិថី"ព្រះសុរាម្រិត"ឆ្ពោះទៅទិសខាងលិច។

នៅក្នុងរថយន្តដ៏ស្អាតត្រដាក់ស្រីបនិងប្រកបដោយក្លិនក្រអូបទ្រង់ទេពគង់នៅកៅអីមុខទន្ទឹមនឹងកញ្ញាចារវៃ។ ចំណែកនាងម៉ាហ្គារ៉េតអង្គុយគងអន្ទាក់ខ្លានៅកៅអីពូកក្រោយ។ នាពេលស្ងៀមស្ងាត់តែរៀងៗខ្លួន បានរសាត់ទៅអស់មួយខណៈទើបម្ចាស់រថយន្តបង្ហើបសំណួរស្នើទ្រង់៖

-ទ្រង់ត្រូវចូលទៅផ្ទះដោះសម្លៀកបំពាក់នេះចេញសិន ហើយស្លៀកខោពាក់អាវធំចង់ក្រវ៉ាត់ក ជាជនជាតិអឺរ៉ុបដ៏មានអារ្យធម៌ខ្ពស់ ដើម្បីចូលបាសប្បាយជាមួយខ្ញុំម្ចាស់ សូមកុំប្រកែកណា ។

ទ្រង់មានបន្ទូលសួរវិញ៖

-ហេតុអ្វី...ក៏ខ្ញុំត្រូវដោះសម្លៀកបំពាក់នេះចេញ? ថ្ងៃនេះជាថ្ងៃ

បុណ្យប្រពៃណីជាតិខ្មែរ ខ្ញុំស្លៀកខោឡាញ់ខ្មៅថ្មៗប្រាំ ពាក់អាវសដៃវែង ដែលខ្មែរទូទាំងប្រទេសធ្លាប់ប្រើ មានអីដែលមិនសមនោះយើងជាខ្មែរ... យើងមិនភ្លេចទំនៀមទម្លាប់ពីដូនតាឡើយៗ ផ្ទុយទៅវិញ យើងគួរខ្មាស់ ជនជាតិចាម វៀតណាម ជប៉ុន ឥណ្ឌា សាំងហ្គាពួ ដែលមកចូលរួម កម្សាន្តសប្បាយក្នុងពិធីអុំទូករបស់ខ្មែរ ដែលគេស្លៀកពាក់តាមបែប ប្រពៃណីជនជាតិគេ...ចុះយើងជាខ្មែរ ក្នុងពិធីបុណ្យជាតិខ្មែរ!!

កញ្ញាចារវៃ ពោលពេបជ្រាយឲ្យទ្រង់៖

-តែទ្រង់ជាជនជាតិអឺរ៉ុបទេតើ ! ស្លៀកពាក់បែប ខោកុងម៉ូវអាវ ស វាលកសាមញ្ញពេក នាំឲ្យអ្នកឯទៀត...គេសើចយំៗ ម្យ៉ាងទៀត...អ្នក ស្លៀកពាក់បែបនេះ...ប្រហែល...ជា... មានតែទ្រង់មួយអង្គឯងប៉ុណ្ណោះ ។ ... ...

មិនដឹងជាអស់ពេលវេលាប៉ុន្មាន ដែលសន្លប់បាត់ស្មារតីនៅក្នុង ឧម្មត្តមរណៈនោះ ពលបានដឹងខ្លួនឡើងវិញ កត្តីស្ថិតនៅក្នុងទី ឃុំឃាំង មួយដែលដៃទាំងពីរ ជាប់ខ្នោះបន្តដោយច្រវ៉ាក់យ៉ាងមាំភ្ជាប់នឹងជញ្ជាំង ថ្មៗ សត្រូវស្រាតសម្លៀកបំពាក់នាយ នៅសល់តែខោខ្លីប៉ុណ្ណោះៗ គេដឹង ថា ក្បាលរបស់ខ្លួនឈឺខ្មោកៗដោយជាតិម្សៅពុល ហើយកម្លាំងក្នុងខ្លួនក៏ ត្រូវចុះខ្សោយយ៉ាងខ្លាំងៗ ក្នុងបន្ទប់តូចសត្រូវឃុំតែខ្លួនគេម្នាក់ ឯ ចំណែកសង្ការិញ នាយពុំដឹងនៅឯណាទេៗ ស្នូរទឹកបោកបក់ដោយ ខ្យល់គ្រាំគ្រេងៗធ្វើឲ្យគេដឹងថា ទីនេះនៅក្បែរមាត់ទន្លេ ឬមាត់សមុទ្រៗ នាយប៉ូលីសមានវិប្បដិសារីយ៉ាងខ្លាំង បណ្ដោយអាត្មាធ្លាក់ខ្លួនចាញ់កល ត្រូវក្លាយជាចំណាប់ខ្មាំងៗ ខ្នោះដែលធ្វើឡើងសម្រាប់ដាក់ដៃ ឬជើងអ្នក មានទោស ឥឡូវបែរជាអ្នកមានទោស យកដៃប៉ូលីសពុលស្រា ឆ្កួតនឹង សម្រស់ស្រីដាក់ខ្នោះទៅវិញៗ គេស្ដាយកេរ្តិ៍ឈ្មោះ និងស្នាដៃនៅក្នុងអង្គ

កាព ដែលកន្ទង់មកធ្វើឲ្យជនល្មើសមានការខ្លាចរអែងញាក់សាច់។ គេនឹកឃើញពាក្យសម្តីរបស់ដារីដែលពោលថា ប្រុសៗស្លាប់ក្រោមកន្ទុយក្បិនរបស់ស្រីៗ ដែលមាណពធ្លាប់ឮជាពាក្យសាមញ្ញធម្មតា ដែលគេតែងយកមកនិយាយលេងសើច នោះក្លាយមកជាពាក្យមានន័យប្រកបដោយគ្រោះថ្នាក់សម្រាប់ខ្លួន។ នាយគិតថាខ្លួនជាប៉ូលីស ដែលមានទេពកោសល្យខ្ពស់ក្នុងការបង្ក្រាបជនល្មើស ដឹងអីថា ពពួកជនពាលក៏មានល្បិចកលប្លែកៗចាប់ប៉ូលីស ឬសម្លាប់ក្រុមសមត្ថកិច្ចវិញនៅពេលណាដែលមានការធ្វេសប្រហែសយ៉ាងដូច្នេះសោះ។...

## ៤ អ្នកស្រី អ៊ុំ សុផានី

បិតាអ្នកស្រីមាននាម លោក អ៊ុំ សាមឿន និងមាតានាមធូ សំបូរ អ្នកស្រីមានបងប្អូនទាំងអស់ចំនួន៦នាក់ ហើយឪពុកម្តាយរបស់អ្នកស្រីរួមជាមួយបងប្អូនចំនួន៤នាក់ទៀតត្រូវស្លាប់កាលពីជំនាន់ប៉ុល ពត។

នៅឆ្នាំ១៩៧៥ អ្នកស្រីបានរៀបការជាមួយលោកស៊ូ ណាន ហើយមានកូនចំនួន២នាក់ គឺ

- -ស៊ូ បុទុម ស្រី កើតនៅឆ្នាំ១៩៧៧
- -ស៊ូ អម្រិត ប្រុស កើតឆ្នាំ១៩៨៥

### អំពីការសិក្សា និងការងារ

- -ឆ្នាំ១៩៥៨ ដល់ឆ្នាំ១៩៦០អ្នកស្រីបានសិក្សានៅសាលាម៉ាលីកា
- -ឆ្នាំ១៩៦០ដល់ឆ្នាំ១៩៧០បន្តការសិក្សានៅវិទ្យាល័យព្រះយុគន្ធរ
- -ឆ្នាំ១៩៧០ ដល់១៩៧៥ សិក្សានៅមហាវិទ្យាល័យបុរាណវិទ្យា
- -ឆ្នាំ១៩៧៥ ដល់១៩៧៩ ជាកសិករនៅឃុំត្រពាំងធំ ស្រុកត្រាំកក់
- -ឆ្នាំ១៩៨៩ ដល់១៩៩៣ អនុប្រធានសារមន្ទីរអតីតរាំង

-ថ្ងៃទី០៦ ខែមីនា ឆ្នាំ១៩៩៦ រហូតដល់បច្ចុប្បន្ន ជាប្រធានការិយាល័យមគ្គុទេសក៍ចាត់តាំងដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រីព្រះបរមរាជវាំង គង់ សំអុល

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍វិញ អ្នកស្រីគឺជាអ្នកនិពន្ធដ៏ឆ្នើមម្នាក់ ដែលវណ្ណកម្មរបស់លោកស្រីភាគច្រើនត្រូវបានជាប់ជាពានរង្វាន់អក្សរសិល្ប៍ទៀតផង។ ក្នុងគំនិតជាអ្នកនិពន្ធម្នាក់ អ្នកស្រីបានបញ្ចូលនូវសេជាតិពិសេសតាមលក្ខណៈសិល្ប៍រូបារម្មណ៍ដើម្បីជាប្រទីបពិសេសអប់រំអ្នកអាន អ្នកសិក្សា ឲ្យចេះគិតពិចារណា រើសយកឧត្តមគតិមកទូន្មានខ្លួនស្របទៅតាមអ្វីដែលជាគោលដៅរបស់អ្នកស្រី។

វណ្ណកម្មអក្សរសិល្ប៍សំខាន់ៗដែលខ្ញុំទទួលបាននោះមានដូចជាៈ

-សៀវភៅ "កិច្ចត្រួតពិនិត្យប្រាសាទបុរាណ" ជាភាសាខ្មែរ នៅឆ្នាំ១៩៨០

-រឿង **ក្រោមតំណក់ទឹកភ្លៀង** ពានរង្វាន់លេខ៣ មេដាយសំរិទ្ធ ។ ស្នាដៃនេះ អ្នកស្រីបានសរសេរដើម្បីអបអរសាទរថ្ងៃបុណ្យជាតិ ០៧ មករា ខួបលើកទី១០ដែលបានប្រារព្ធធ្វើនៅថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៨៩នៅសាលមហោស្រពចតុមុខ។

-នៅឆ្នាំ១៩៨៩ បានគូរគំនូរផ្សាយ Pour la Vie et la Paix Contre le Nucléaire ដើម្បីអបអរសាទរមហោស្រពពិភពលោករបស់យុវជន និងនិស្សិតលើកទី៣ ពុងយ៉ាង១៩៨៩

គំនូរនេះត្រូវទទួលបានចំណាត់ថ្នាក់លេខ១ នៅក្នុងប្រទេសព្រមទាំងបានយកទៅចូលរួមប្រកួតនៅទីក្រុងពុងយ៉ាង ប្រទេសកូរ៉េខាងជើងដើម្បីជ្រើសរើសជើងឯកពិភពលោក។

-ឆ្នាំ១៩៩០ បានសរសេរសៀវភៅប្រលោមលោករឿង **ផ្ទៃមេឃតែមួយ** ដើម្បីអបអរសាទរពិធីប្រកាសលទ្ធផលមហោស្រពតែងនិពន្ធមហាជនទូទាំងប្រទេសលើកទី៣ ហើយត្រូវទទួលបានពានរង្វាន់លេខ២មេដាយប្រាក់។

-១៩៩១ បានសរសេរនិក្ខេបទ ស្ដីពីក្អំតាម៉ៅ ជំនឿ និងកិច្ចប្រតិបត្តិផ្សេងៗ សម្រាប់សញ្ញាបត្របុរាណវិទ្យា។

- ឆ្នាំ១៩៩៣ បានសរសេរសៀវភៅនិក្ខេបទ Conservation of wall painting reference in Cambodia បញ្ចប់ការសិក្សាការពារថែរក្សាវត្ថុសិល្បៈ នៅប្រទេសឥណ្ឌា ជាភាសាអង់គ្លេស។

-អ្នកស្រីបានសរសេររឿងមួយមានចំណងជើងថា លោហិតតែមួយ ហើយស្នាដៃនេះត្រូវបានទទួលចំណាត់ថ្នាក់លេខ២ នៅប្រទេសកម្ពុជា ហើយក៏ទទួលបានរង្វាន់កិត្តិយសនៅប្រទេសបារាំងផងដែរ។

ជាបន្តទៅទៀត ខ្ញុំនឹងលើកយកស្នាដៃរបស់លោកស្រីមួយដែលមានចំណងជើងថា **អ្នកណាជាម្ដាយខ្ញុំ** ដែលជាស្នាដៃរបស់លោកស្រីបានទទួលចំណាត់ថ្នាក់លេខមួយ ពានរង្វាន់អក្សរសិល្ប៍សន្តិភាព ឆ្នាំ ២០០០ មកបង្ហាញជូនមិត្តអ្នកអានដូចខាងក្រោម៖

នៅមុខព្រះបរមរាជវាំង តាមដងទន្លេមេគង្គ គេបានរៀបចំសួនច្បារដ៏ស្រស់បំព្រងដោយផ្ការចម្រុះពណ៌ ព្រមទាំងមានដាំដើមដូងជុះជាជួរៗ នៅចន្លោះដើមដូង គេបានរៀបដាក់កៅអីស៊ីម៉ង់មានបង្អែក ទុកសម្រាប់ភ្ញៀវទេសចរមកអង្គុយលេង សម្រាកលម្ហែកែអផ្សុកបានមួយគ្រាៗដែរ។ ចាប់តាំងពីរសៀលម៉ោង៤ទៅ គឺពេលដែលព្រះសុរិយាបន្ទាបអង្គ ប៉ាំងនឹងកំពូលប្រាសាទចន្ទ្រឆាយាដែលបិតនៅទិសខាងលិចទន្លេ

មេឃគ្គ ជាតុអាកាសក៏ចាប់ផ្តើមត្រជាក់បន្តិចម្តងៗ ខណៈនោះគឺមានភ្ញៀវទេសចរដើរត្រេចចរហូរហែកែកម្សាន្តជាបណ្តើរៗ លាយឡំជាមួយអ្នកលក់ដូរ និងអ្នកសុំទានបង្កើតឲ្យឆ្នេរទន្លេមានសកម្មភាពរស់រវើកឡើង។

ទឹកទន្លេនៅតែហូរខ្ចួលខ្ចាញ់ដដែល។ ជារៀងរាល់ឆ្នាំនៅរដូវវស្សាព្រមទាំងហូរនាំដីល្បប់ដ៏មានជីវជាតិ ទៅចាក់បំពេញបឹងទន្លេសាប ដ៏ធំល្វឹងល្វើយ ស្ទឹងបឹងបួរ និងត្រពាំងទាំងឡាយជាច្រើនទៀតដូចសរសៃឈាមហូរជ្រាបពាសពេញក្នុងផ្ទៃប្រទេស។

ខ្យល់បក់ស្ទឹកដូងឮខ្សាក។ លាយនឹងសម្រែកស្ត្រីលក់ដូរក្នុងវ័យចំណាស់ម្នាក់ ហៅឈ្មោះក្មេងស្រី ដែលកំពុងឈរសម្លឹងទៅត្រើយជ្រោយចង្វា:

-សុខាអើយសុខា...រវល់នៅឈរមើលទឹកទន្លេអី...ហ្នុះភ្ញៀវមកដល់ហើយ...ប្រញាប់ទៅក្មួយ...ឆាប់ឡើង។... ......

ដល់ទីក្រុងព្រះសីហនុហើយ លោករដ្ឋាបើករថយន្តមកឈប់នៅឆ្នេរត្រង់សណ្ឋាគារសុខា។ ពេលដែលលោកបើកទ្វាររថយន្តខ្យល់ចាស់ដែលបានដឹងរឿងរ៉ាវ នាងតូចកម្សត់ ពិន សុខា ក៏នាំគ្នាហោះហើរប៉ើងរសាត់ទៅឆ្ងាយ ដោយទុកឲ្យខ្យល់សមុទ្រចូលមកជំនួសនាទីនោះម្តង។

សុខាស្រូបយកខ្យល់សមុទ្រថ្មីនៃក្តីសង្ឃឹម ឲ្យចូលទៅទ្រទ្រង់រាងកាយដើម្បីឲ្យរាងកាយនេះ ក្លាយជាវត្ថុសំខាន់ហើយចាំបាច់សម្រាប់បម្រើសង្គម ឲ្យស្គាល់តែការជឿនលឿនព្រមទាំងថ្លៃថ្នូរដូចមហាប្រទេសលើសកលលោក។

សុខារត់រកមីងលាំ និងកេត នាងយកដៃម្ខាងកាន់ដៃមីងលាំ ឯដៃម្ខាងទៀតកាន់ដៃកេត រយចនាងយកដៃអ្នកទាំងពីរមកផ្ទឹប និងដើមទ្រូងរបស់នាង ព្រមទាំងថ្លែងវាចា ដោយក្តីឃ្នាក់ខ្នាញ់ស្រឡាញ់ពេញចិត្ត។...

## ៤ លោក សំ សុភារិទ្ធ

លោកប្រសូតនៅថ្ងៃព្រហស្បតិ៍ ទី៦ ខែកក្កដា ឆ្នាំ១៩៧៨ នៅភូមិស្រែខ្វាវ ឃុំដាំងទង់ ស្រុកត្រាំកក់ ខេត្តតាកែវ។

លោកគឺជាកុលបុត្រខ្មែរដ៏ឆ្នើមមួយរូប ដែលបានច្រារព្ធស្នាដៃអក្សរសិល្ប៍ជាច្រើន ហើយសុទ្ធតែមានខ្លឹមសារល្អបម្រើដល់ការរស់នៅផ្នែកអារម្មណ៍បានមួយភាគធំ។ ស្នាដៃសំខាន់របស់លោកដែលបានចងក្រងឡើង ភាគច្រើនជាស្នាដៃដែលត្រូវបានជាប់ជាជ័យលាភីពានរង្វាន់អក្សរសិល្ប៍។ វណ្ណកម្មទាំងនោះរួមមាន៖

- រឿងលំហជីវិត ជាវណ្ណកម្មដំបូងរបស់លោកដែលបានសរសេរកាលពីនៅសិក្សាឯវិទ្យាល័យ១ឧសភា ក្នុងស្រុកត្រាំកក់ ខេត្តតាកែវកាលពីឆ្នាំ១៩៩៥

- ទំនុកច្រៀងចំនួន៥បទ ក្នុងកម្រងបទចម្រៀងអនុស្សាវរីយ៍របស់សម្ដេច ហ៊ុន សែន នៅខែសីហា ឆ្នាំ១៩៩៧

- រឿងទឹកមន្តមករា ជ័យលាភីចំណាត់ថ្នាក់លេខ១ ពានរង្វាន់អក្សរសិល្ប៍៧ មករា លើកទី២ ឆ្នាំ១៩៩៨ពីសមាគមអ្នកនិពន្ធខ្មែរ។

- ជីវិតអ្នកប្រយុទ្ធ រឿងខ្លីជ័យលាភីចំណាត់ថ្នាក់លេខ១ ពីអង្គការទស្សនៈពិភពលោកអន្តរជាតិ-កម្ពុជាឆ្នាំ១៩៩៨

- រឿងសំណោកអនុស្សាវរីយ៍ ប្រលោមលោកចេញផ្សាយឆ្នាំ២០០០ ហើយស្នាដៃនេះបានទទួលបណ្ណសរសើរពីសមាគមអ្នកនិពន្ធខ្មែរនៅបរទេស។

- រឿងពេលថ្ងៃរះ ប្រលោមលោកជ័យលាភីចំណាត់ថ្នាក់លេខ២ ពានរង្វាន់អក្សរសិល្ប៍ព្រះបាទសុរាម្រិត ពីក្រសួងវប្បធម៌ និងវិចិត្រ

សិល្បៈឆ្នាំ២០០០ ហើយនៅឆ្នាំ២០០២រឿងនេះត្រូវទទួលការបោះពុម្ពផ្សាយ។ នៅអំឡុងឆ្នាំ២០០១ ស្នាដៃអក្សរសិល្ប៍មួយនេះ ក៏ត្រូវបានសម្រួលជាភាគនិទានចាក់ផ្សាយតាមវិទ្យុផងដែរ។

-រឿងសែនធូន់ សរសេរជាកំណាព្យ និងត្រូវបានជាប់ជ័យលាភីចំណាត់ថ្នាក់លេខ២ ពីមហោស្រពពានរង្វាន់អក្សរសិល្ប៍ព្រះសីហនុរាជ ឆ្នាំ២០០១ រៀបចំឡើងដោយសមាគមអ្នកនិពន្ធខ្មែរ និងនៅឆ្នាំ២០០៣ អត្ថបទរឿងនេះត្រូវបានបោះពុម្ពផ្សាយ។

- រឿងពេលគ្មានម៉ែ ប្រលោមលោកខ្នាតខ្លី ជ័យលាភីចំណាត់ថ្នាក់លេខ១ ឆ្នាំ២០០៣ ពីវិទ្យាស្ថានសិល្បៈរៃយំ។

- រឿងស្រែករហែកមេឃ ប្រលោមលោកជ័យលាភីចំណាត់ថ្នាក់លេខ៣ ពានរង្វាន់ព្រះរាជសម្ភារ ឆ្នាំ២០០៥ ពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

- រឿងអាសូរស្នេហ៍ ប្រលោមលោក បោះពុម្ពផ្សាយឆ្នាំ២០០៧

- កម្រងប្រលោមលោកខ្នាតខ្លី ចន្ទ្រជីវី ប្រលោមលោកបោះពុម្ពផ្សាយឆ្នាំ២០០៧

ក្រៅពីនេះ លោកក៏នៅមានសរសេរអត្ថបទជាច្រើនទៀត ដែលទាក់ទងនិងសារព័ត៌មាន ក៏ដូចជាផ្នែកអប់រំចំណេះទូទៅដែរ។

ជាបន្តទៅទៀត ខ្ញុំនឹងដកស្រង់រឿង**សែនធូន់** ដែលជាស្នាដៃរបស់លោកសំ សុភារិទ្ធ ដែលវណ្ណកម្មមួយនេះបានទទួលចំណាត់ថ្នាក់លេខ២ ពានរង្វាន់អក្សរសិល្ប៍ព្រះសីហនុរាជឆ្នាំ២០០១ ហើយអត្ថបទរឿងទាំងស្រុងសរសេរជាកំណាព្យដូចតទៅ៖

## បទពាក្យ៧

បើកភ្នែកយល់ទុក្ខគុកជីវិត ទ្វីបលោកងងឹតជិតឥតថ្លា
អាសូររាត្រីស្រីសោកា មិនដឹងថ្ងៃណារួចចំណង ។
ឆ្នាំថ្មីមកដល់រិតខ្វល់ខ្វាយ ខ្លួនរស់ព្រោះម្ដាយៗស្នេហ៍ស្នង
ទើបនាងសម្រេចស្រេចចិត្តម្ដង កាត់ខ្មាស់អ្នកផងទាំងអាម៉ាស ។
ស៊ូទ្រាំខាំមាត់សង្កត់ចិត្ត ដ្បិតព្រហ្មលិខិតឥតប្ដូរផ្លាស់
ចូលរាំលក់ផ្កាជូនម្ដាយចាស់ ចង់ឲ្យគាត់សះជ្រះរោគា ។
បទមួយបទពីរនារីព្រួយ គិតដល់ម្ដាយមួយនៅត្រាំត្រា
ម្លេះបើលោកយល់កូនពុំងា សមដួងទយាឈឺយ៉ាងណា ។
កណ្ដាលចំណោមគេរីករាយ នាងគិតរាយមាយគ្រប់បញ្ហា
លាក់លួចជូតផ្ដិតទឹកនេត្រា ស្រណោះកាយាពន់ប្រមាណ ។
ពិតយប់រាំចំឆ្នាំថ្មី គេរាំនិងស្រីបានគ្រប់ប្រាណ
សមនាងរូបល្អក្រនឹងបាន អ្នកណាខកខានប្រាណសោកស្ដាយ។
គ្រានោះនាងជួនជាជួបជាក់ ស្គាល់បុរសម្នាក់វ័យសាមព្វាយ
សៀកពាក់សង្ហាមុខស្រស់ស្រាយ ប្លែកមុខប្លែកកាយទើបយល់ម្ដង។
ដួងចិត្តបុរសសែនត្រេកអរ បានយល់ស្រីល្អលើសអ្នកផង
ប្រឹងរាំកៀងកិតឥតសៅហ្មង ទាំងស្ដីសាសងនឹងធីតា ។
យប់នេះខ្ញុំហាក់មាននិស្ស័យ បានជួបស្រស់ថ្ងៃក្រៃរាបសា
រូបរាងស្រស់តូចដូចបុប្ផា នេះខ្ញុំវាចាមិនប្រឌិត ។

... ... ...

## ៦ លោក អៀង ពិសី

លោកប្រសូតនៅថ្ងៃទី៣ខែកក្កដាឆ្នាំ១៩៨០ នៅភូមិចំបក់ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ លោកមានបិតានាម អៀង ស៊ីម មានមុខរបរជាគ្រូបង្រៀន ម្ដាយនាម យិន ចន្ទា មានមុខរបរជាកសិករ។

លុះអាយុគម្រប់ល្មមចូលរៀន លោកក៏ត្រូវឪពុកនាំលោកទៅចូលរៀននៅសាលាបឋមសិក្សាប្រាសាទ។ នៅឆ្នាំ២០០០ លោកក៏បានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ រួចក៏បន្តទៅសិក្សានៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ហ៊ុន សែនព្រៃវែង ឯកទេសអក្សរសាស្ត្រខ្មែរ ។ នៅឆ្នាំ២០០២ លោកក៏ចេញបម្រើការងារនៅសាលាអនុវិទ្យាល័យ មេស ប្រចណ្ឌ ស្រុកពាមរ៍ង ខេត្តព្រៃវែង។ នៅឆ្នាំ២០០៤ លោកក៏បានរៀបអាពាហ៍ពិពាហ៍ជាមួយនាង ហាក់ វណ្ណា មានមុខរបរជាគ្រូបង្រៀន និងបានផ្ទេរមកបម្រើការងារនៅសាលាអនុវិទ្យាល័យព្រៃស្មៀតស្ថិតនៅឃុំព្រៃស្មៀត ស្រុកពារាំង។

នៅឆ្នាំ២០០៦ លោកក៏បានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រ នៅរាជធានីភ្នំពេញ រួចក៏បន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ (អនុបណ្ឌិត) ជំនាញអក្សរសាស្ត្រខ្មែរទៀត។

នៅឆ្នាំ២០០៩ លោកក៏បានផ្ទេរកន្លែងបម្រើការងារមកវិទ្យាល័យកំពង់ត្របែក ស្ថិតក្នុងស្រុកកំពង់ត្របែក ជាស្រុកកំណើតវិញ។

នៅផ្នែកវណ្ណកម្មអក្សរសិល្ប៍ លោកបានសរសេរស្នាដៃជាច្រើនក្នុងន័យរួមចំណែកលើកកម្ពស់ការសិក្សាអក្សរសាស្ត្រខ្មែរ ក្នុងនោះស្នាដៃរបស់លោកដែលបានចងក្រងឡើងរួមមាន៖

-រឿង លំពែងមានវិញ្ញាណ សរសេរនៅឆ្នាំ១៩៩៨ ជាវណ្ណកម្មអក្សរសិល្ប៍ដំបូងរបស់លោកក្នុងវិស័យតែងនិពន្ធ។

-រឿងជីវិតនាងកែវ សរសេរនៅឆ្នាំ១៩៩៩ និងត្រូវបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានអន្តរជាតិនៃកម្ពុជា (IIC)

-ឆ្នាំ២០០០ សរសេររឿង ស្បែវិប្បដិសារី

-ឆ្នាំ២០០១ សរសេររឿងស្រមោលស្នេហ៍

-ឆ្នាំ២០០២ សរសេររឿងស្នេហ៍មាននិស្ស័យ (បោះពុម្ពហើយ)

-ឆ្នាំ២០០២ សរសេររឿងកុលាបកោះស្តេច (បោះពុម្ពហើយ)

-ឆ្នាំ២០០២ សរសេររឿង ប្រពន្ធគ្រូស្រុកស្រែ (បោះពុម្ពហើយ)

-ឆ្នាំ ២០០៣ សរសេររឿង ឈាមយុវវ័យ (បោះពុម្ពហើយ)

-ឆ្នាំ២០០៣ សរសេររឿង នៅតែទឹក នៅតែស្រណោះ(បោះពុម្ព)

-ឆ្នាំ២០០៣ សរសេររឿងជីវិតថ្មី (បោះពុម្ពហើយ)

-ឆ្នាំ២០០៣សរសេររឿង ទម្ងន់ជីវិត (ចុះផ្សាយតាមទស្សនាវដ្តីប្រជាប្រិយ)

-ឆ្នាំ២០០៣ សរសេររឿង ជំនោរខែបុស្ស (បោះពុម្ពហើយ)

-២០០៤ សរសេររឿងរំដួលទងពេជ្រ (ចុះផ្សាយតាមទស្សនាវដ្តីប្រជាប្រិយ)

-ឆ្នាំ២០០៦ សរសេររឿងព្រះអាទិត្យត្រជាក់ (បោះពុម្ពហើយ)

-ឆ្នាំ២០០៨ សរសេររឿង អប្បលក្សណ៍

-ឆ្នាំ២០០៨ សរសេររឿង បង្គងជីវិត

-ឆ្នាំ២០០៩ សរសេររឿងព្រាយដើមព្រីង

ក្រៅពីនេះ នៅមានសរសេរអត្ថបទស្រាវជ្រាវមួយចំនួន និងរឿងខ្លី កំណាព្យជាច្រើនទៀតដែលមួយចំនួនធំមិនទាន់បានបោះពុម្ពទេ។

ខាងក្រោមនេះ ជាសម្រង់អត្ថបទរឿងមួយរបស់លោកដែលមានចំណងជើងថា **ជីវិតថ្មី** សូមមិត្តអ្នកអាន សិក្សាជាមួយគ្នាដូចតទៅៈ

...នៅថ្ងៃសម្រាកពីការសិក្សា សំណាងបានមកជួយធ្វើការនៅផ្ទះជាមួយឪពុកម្ដាយវា ។ សំណាងជាក្មេងមួយដែលមិនចេះនៅទំនេរទោះបីឪពុកវា មិនឲ្យធ្វើការធ្ងន់ៗតែសំណាង បែរជាទៅជួយទូលនំម្ដាយវាយកទៅលក់។ នៅផ្ទះសំណាង ជួយមើលថែដំណាំ និងជួយថែទាំសត្វទៀត។ នៅរសៀលថ្ងៃអាទិត្យនេះ សុខនិងប្រពន្ធរបស់គេ ព្រមទាំងកូននាំគ្នាបុកស្រូវដោយត្បាល់ជាន់យ៉ាងសកម្ម ស្រាប់តែពេលនោះ អ៊ុំឈុនជាអ្នកជិតខាងរបស់សុខបានដើរមកលេង។ ពេលគាត់ចូលដល់មុខផ្ទះស្រាប់តែគាត់ឃើញឆ្កែគ្រហឹមដាក់គាត់ អ៊ុំឈុនក៏ស្រែកហៅសុខៈ

-សុខអើយ! ទៅណាហើយ មើលឆ្កែឲ្យផង។

សុខតបពីក្រោយផ្ទះជាពាក្យកំប្លែងកំប្លុកៈ

-មិនអីទេអ៊ុំឈុន! អញ្ជើញចូលមក ឆ្កែខ្ញុំវាមិនខាំអ្នកក្រដូចគ្នាទេ ព្រុសក៏វាមិនព្រុសដែរ ព្រោះអ៊ុំមិនមែនជាមនុស្សក្បត់ជាតិ

អ៊ុំឈុនដើរចូលមក ហើយនិយាយទៅកាន់សុខៈ

-ហើយក្មួយឯងប្រឹងបុកស្រូវយកអង្ករទៅណាច្រើនម្ល៉េះ។

សុខតបដោយពាក្យសម្ដីគួរសមៈ

-មិនយកទៅណាអ៊ុំអើយទុកគ្រាន់តែស៊ីហ្នឹង ! ហើយអ៊ុំអញ្ជើញទៅណាមកណា បានជាមកដល់ផ្ទះខ្ញុំថ្ងៃនេះ?

អ៊ុំឈុនអង្គុយចុះជិតចាន់នីដែលកំពុងអុំអង្ករ គាត់ចាប់អង្ករមួយដៃមកមើលរួចនិយាយៈ

-អ៊ុំមកលេងឯង។ សុខឯងឥឡូវខំប្រឹងដល់ហើយ ខ្វាចតែក្រ។

សុខសើចតិចៗ រួចនិយាយតបៈ

-ត្រូវតែប្រឹងអីចឹងហើយព្រោះត្រូវផ្ដល់ប្រាក់ឲ្យកូនរៀន។ លុយចង

ការគេឲ្យកូនរៀន ទើបតែសងគេអស់ៗ ហ៊ុយ... ពិបាកណាស់អ៊ុំអើយ រកមួយថ្ងៃសម្រាប់ស៊ីតែមួយថ្ងៃស្ទើរតែមិនគ្រប់គ្រាន់ មិនដឹងកាលណាបានដូចគេទេៗ

អ៊ុំឈុនឲ្យយោបល់៖

-ក្មួយឯង មិនដឹងជាឲ្យកូនរៀនធ្វើស្អីទេ បើឧកញ៉ា សម្ដេច ឯកឧត្តម គេមានតំណែងអស់ហើយនោះៗ

សុខឈប់ដាន់ស្រូវ ហើយមកអង្គុយបារអង្កែរពីក្នុងត្បាល់ដាក់ល្អី ហើយឆៀតងាកមកនិយាយជាមួយអ៊ុំឈុន៖... ......

ក្រៅពីអស់លោកអ្នកនិពន្ធដែលបានរៀបរាប់ខាងលើ គឺនៅមានអ្នកនិពន្ធច្រើនណាស់ ដែលលោកសុទ្ធតែបានបន្សល់ស្នាដៃរបស់លោកនៅក្នុងទំព័រវណ្ណកម្មអក្សរសិល្ប៍ខ្មែរជាច្រើនស្អេកស្កះ នៅតាមបណ្ណាគារ និងមួយចំនួនទៀតនៅលើទីផ្សារយ៉ាងព្រោងព្រាតៗសមិទ្ធផលទាំងនេះ កើតឡើងដោយសារតែការខំប្រឹងប្រែង របស់ប្រមុខរដ្ឋាភិបាលដែលបានបើកឱកាសឲ្យអ្នកស្រទាប់អ្នកនិពន្ធ បង្ហាញស្នាដៃខ្លួននៅលើទីផ្សារៗ មួយចំនួនធំទៀត គឺជាអ្នកនិពន្ធជើងចាស់ដែលលោកបានឆ្លងកាត់សម័យកាលតែងនិពន្ធជាច្រើនជំនាន់ហើយ ហើយក៏កំពុងតែបន្តអាជីពលោកទៅទៀតៗ

ការងារជាស្នូលរបស់អ្នកនិពន្ធ គឺដើម្បីរួមចំណែកថែរក្សាអក្សរសិល្ប៍ខ្លួនឲ្យរិតតែមានរស្មីថែមទៀតៗ

ខ្ញុំសូមកោតសរសើរយ៉ាងស្មោះអស់អំពីចិត្តចំពោះ ស្មារតីខិតខំប្រឹងប្រែងរបស់អស់លោកអ្នកនិពន្ធ អ្នកករីគ្រប់ស្រទាប់ជាន់ ថ្នាក់ដែលជានិច្ចកាល អស់លោកតែងតម្កល់ប្រយោជន៍ជាតិជាធំ ហើយបានបូជា

កម្លាំងប្រាជ្ញាមិនខ្វាចនឿយហត់ ប្រឹងចងក្រងវណ្ណកម្មខ្លួនសម្រាប់បានជាគតិដល់កូនខ្មែរគ្រប់រូប។

ទោះបីជាការសរសេរតែងនិពន្ធបានទទួលប្រាក់កម្រៃទាប ពីតម្លៃញើសឈាមនេះក្តី ក៏ទឹកចិត្តដ៏ស្មោះស្ម័គ្ររបស់អ្នកនិពន្ធខ្មែរនៅតែមានជានិច្ច ហើយខ្ញុំសង្ឃឹមថា អាជីពជាអ្នកនិពន្ធ ដែលត្រូវបានមជ្ឈដ្ឋានអ្នកសិក្សាចាត់ទុកថា ជាវិស្វករព្រលឹង នឹងទទួលបាននូវការឲ្យតម្លៃយ៉ាងខ្ពស់សមនឹងការលះបង់របស់អស់លោក នៅថ្ងៃណាមួយជាប្រាកដ។

សូមកូនខ្មែរត្រូវងាកមកចាប់អារម្មណ៍ចំពោះ វិស័យតំណែងនិពន្ធរបស់ខ្មែរវិញ ដើម្បីបានជាកិត្តិយសជាតិផង ក៏ដូចជាបន្សល់កេរសម្រាប់ការអប់រំដួងវិញ្ញាណទៅថ្ងៃខាងមុខផង។

ជាបន្ត មុននឹងបញ្ចប់នូវកម្រងឯកសា ស្តីពីចរន្តអក្សរសិល្ប៍ខ្មែរ ខ្ញុំសូមធ្វើការបង្ហាញជូនមិត្តអ្នកអាន អំពីស្នាដៃកំណាព្យរបស់លោកកវីមួយរូបដែលលោកមិនមានឱកាសនឹងផ្សាយស្នាដៃខ្លួន តែនៅក្នុងចិត្តពោរពេញដោយការព្យាយាមសរសេរជានិច្ច។ ខាងក្រោមនេះ គឺជាស្នាដៃ និងប្រវត្តិរូបដែលលោកសរសេរជាកាព្យដែលមានការរៀបជាចង្វាក់ចំណាប់ចួនយ៉ាងល្អងល្អាយះ

## លោកជូ កោត

| | | |
|---|---|---|
| នាមដើមឈ្មោះកោត | អ្នកស្រុកថាឆោត | ដាក់ឈ្មោះអីចឹង |
| ខ្វះអ្វីឈ្មោះល្អ | ដូចក្រដល់មឹង | ជួនកាលគេខឹង |
| | សើចចំអកភ័យ ។ | |
| លោកអាចារ្យណឹម | ថាអ្នកម្តាយរ៉ឹម | ឈ្មោះនេះមានន័យ |
| អ្នកខ្វះមិនយល់ | និមលប្រពៃ | តែកុំនិយាយ |

ពិតជាល្អហើយ ។

សរសេរបីបែប  រៀបរាប់សង្ខេប  ជម្រាបថ្ងៃក្រោយ
ភ័ន្តសូរស្អប់ភ័យ  តែន័យត្រូវហើយ  ខ្ពង់ខ្ពស់ដល់ត្រើយ
ជីវិតថ្ងៃមុខ ។

កោតនេះសរសើរ  កោដិច្រើនគ្រាន់បើ  កោដិជាជង្រុក
តែអនិច្ចា  ខ្លោចផ្សារដ៏ទុក្ខ  ស្រុកកលិយុគ
សង្គ្រាមអប្រិយ ។

ឪពុកឈ្មោះគង់  វ័យមិនវែង  ស្លាប់ឆ្នាំចិតបី
ដោយខ្យល់វិលមុខ  ក្នុងគុកលោកីយ៍  គ្រួសារក្រក្រី
ទើបជួបអន្តរាយ ។

រស់សែនលំបាក  វេទនាតោកយ៉ាក  ក្រោមគុណអ្នកម្តាយ
មិនកបសុខី  ជាស្រីមេម៉ាយ  ពិការអង្គកាយ
អភ័ព្វសោកា ។

ធ្វើស្រែតត្រុក  ជាមួយអ្នកស្រុក  ភូមិផងគេហា
គេស្រែកគេកេះ  មិនចេះស្តីថា  មេម៉ាយពិការ
ដោយសារលង់ទឹក ។

អាសូរម្តាយខ្ញុំ  កម្មមិនសុខុម  ហត់នឿយសន្ធឹក
ចង់ឃើញកូនល្អ  ត្រេកអរពន្លឹក  ផ្គត់ផ្គង់ល្ងាចព្រឹក
ប្រដៅសំភី ។

កើតប្រាំកក្កដា  មួយពាន់នោះណា  ឆ្នាំចិតសិបពីរ
ខែឆ្នាំរាជការ  រក្សាជីវី  ការងាររកស៊ី
មិនងាយរ៉ីត្រែត ។

នៅភូមិប្រស្តេច  ឃុំចាមស្រុកស្រេច  នៅព្រៃវែងខេត្ត

កំពង់ត្របែក　　មិនប្លែកតាមហេតុ　　តាំងពីកូនង៉ែត
ដូចកម្មកាក់កាត់ ។
សាលាថ្នាខាន់　　បឋមខ្ញុំបាន　　សិក្សាប្រតិបត្តិ
ចំណេះផ្ទៃផ្កា　　បញ្ញាដុសខាត់　　គុណគ្រូមធ្យ័ត
ផលគាប់ពិសិដ្ឋ ។
វត្តបេងព្រះសង្ឃ　　លោកជួយតម្រង់　　ឃើញក្រអាណិត
កំព្រាឪពុក　　គ្រោះទុក្ខបាំងបិទ　　ញាតិសាលោហិត
អាណិតហួសហេតុ ។
ឆ្នាំប៉ែតសិបបួន　　ដូរត្រកូលខ្លួន　　ជួបជុំត្រដែត
សាច់ជីដូនមួយ　　រួមជួយជាហេតុ　　រួមឃុំស្រុកខេត្ត
រួមតុប្រឡង ។
ពីហេងមកផ្ទូ　　ខាងម្តាយខ្ញុំប្តូរ　　ចិញ្ចឹមខ្ញុំផង
ទំនុកបម្រុង　　ផ្តើមផ្តុំបំណង　　ល្អល្អះហ្មត់ហ្មង
នាអនាគត ។
ឆ្នាំប៉ែតសិបបួន　　ឡើងថ្នាក់ផ្ទួនៗ　　តែចិត្តរន្ធត់
ព្រៃពោនកូលែស　　ចង់បេះអត់ធ្មត់　　ជីវិតទុរគត
ទុក្ខសោកក្រំចិត្ត ។
ឆ្នាំប៉ែតប្រាំពីរ　　ខំប្រឹងសំកី　　ខ្លួនជានិស្សិត
គរុកោសល្យ　　បានផ្តល់ក្រមក្រឹត្យ　　ជាគ្រូកម្រិត
បឋមភូមិស្មោះ ។
នៅឆ្នាំកៅសិប　　រសល់រសិប　　ខ្លួនពេញកំលោះ
តើព្រេងឯណា?　　ប្រាថ្នាស្នេហ៍ស្មោះ　　ជីដូនមួយសោះ
គូពីជាតិមុន ។

ការឆ្នាំនោះណា មន្ត្រីកាន់ត្រា លោកព្រំសុគុន
ឃុំចាមតាមច្បាប់ ចាស់ប្រាប់ពីមុន ប្រពន្ធជាទុន
ឈ្មោះនាងថារ៉ូ ។

ពួតដៃការងារ សុខទុក្ខឈឺជា ខំប្រឹងមិនថូរ
មានកូនប្រុសស្រី ប្រុសបីខំបួរ ស្រីមួយអាសូរ
ស្មើរអស់ជីវី ។

ឆ្នាំកៅសិបប្រាំ រដ្ឋប្តូរប្រែប្រ្ហាម តាមកម្មវិធី
បំពេញបង្គ្រប់ បាក់ឧបបូកពីរ ខំប្រឹងសំកី
លះបង់ហានក្លា ។

ដល់ថ្នាក់ឧត្តម សញ្ញាបត្រផ្សំ ខ្មែរបរិញ្ញា
ពីរពាន់ប្រាំពីរ ស្វាយរៀងនោះណា ចប់សារណា
ពីរពាន់ដប់មួយ ។

ចប់បរិញ្ញា ខ្សត់ថវិកា គ្រួសារសែនព្រួយ
ប្រឹងរស់ផ្តាច់ប្តូរ លក់ដូរជំនួយ សង់ផ្ទះបានមួយ
គ្រាន់ជាទ្រនំ ។

ប្រវត្តិការងារ ប្រកាសបញ្ជា ក្រសួងអប់រំ
គរុនិស្សិត កម្រិតមធ្យម បង្រៀនក្នុងឃុំ
នៅតាមស្រុកខណ្ឌ ។

ឆ្នាំប៉ែតប្រាំបួន សន្យាស្ម័គ្រខ្លួន បម្រើស្ថាប័ន
បង្រៀនពេលនោះ អនុ ថ្នាខាន់ បួនឆ្នាំទើបបាន
ប្តូរកន្លែងប្លែក ។

ចុងឆ្នាំកៅបី វិទ្យាល័យថ្មី កំពង់ត្របែក
ខំធ្វើការងារ ពុះពារគ្រប់ផ្នែក បានរួមចំណែក

អប់រំថ្ងៃថ្វា ។

ស្នាដៃសំខាន់ៗរបស់លោកដែលបានចងក្រងឡើង មានដូចជា៖

-រឿង សុជាតិ ប្រលោមលោកដែលមិនទាន់បានបោះពុម្ព

-កម្រងកំណាព្យកេរខ្មែរ មិនទាន់បានបោះពុម្ព

-វិភាគស្នាដៃអក្សរសិល្ប៍រឿង តេជោយ៉ត សារណាថ្នាក់បរិញ្ញាបត្រ ឆ្នាំ២០១០

-កម្រងវិញ្ញាសា សីលធម៌ ពលរដ្ឋវិជ្ជា

-កម្រងវិញ្ញាសាវប្បធម៌ទូទៅ

ខាងក្រោមនេះ ខ្ញុំដកស្រង់អត្ថបទកំណាព្យរបស់លោក មួយចំនួនមកបង្ហាញជូនមិត្តអ្នកអានដូចតទៅ៖

## អ្នករៀនសម័យទំនើប

កូនគេកូនខ្ញុំផ្គុំចិត្តគំនិត ថាជីវិតស្រុកវិតស៊ីវិល័យ
សម្ភារៈគ្រប់ភាពទាន់សម័យ ទំនើបក្រៃពល់ថ្ងៃចង់ក្មេងរៀន ។
ស្លៀកសំពត់ខ្លីត្រឹមក្បាលជង្គង់ ស្បែកជើងជង់ស្រួចទៅរួចមិនអៀន
លេងសើចចំអន់មិនស្រន់អន់ប្រៀន ដល់ពេលរៀនផាកប្រៀនព្រោកមិត្តភក្តិ។
ខោជើងកំប៉ុងដូចស្បែកកង្កែប ហោប៉ៅអែបថ្នេរគូចជូរយារធ្លាក់
សក់ដូចអំបោសលាបពណ៌ពញាក់ រាំបទញាក់ស្ទាត់វគ្គមិនបាច់ប្រាប់ ។
អាងឡានទំនើបទើបទិញពីផ្សារ ឬកហឺហាអស្ចារ្យទាំងទូរស័ព្ទ
ម៉ោងរៀនក្នុងថ្នាក់កេះផាកមិនស្តាប់ ឈឺក្បាលយ៉ាប់សុំច្បាប់ករចេញក្រៅ ។
ការពិតម៉ូយឡូយរាងស្រស់សង្ហារ ចុចផ្ញើសារស៊ុញ៉ូទ្វាហួចហៅ
លង់ពាក្យពីរោះព្រោះតែតោមឡៅ ចិត្តសំដៅជ្រួលក្តៅពេញវិញ្ញាណ ។
ហ៊ីណ្ឌាម៉ូតូថ្មីដេញស៊េរី ស្តិបស្កុបពី មីអូ អាយខុនមាន

ឃ្វីក ស្មាស់ រីវ៉ូ ហេប្រ៊ូទើបហ៊ាន  សង់ក៏មានអ៊ែប្លៃដ គុបហ្វ្រេសទា ៗ
មករៀនមានលុយស្អុយលឿនប្រញាប់ មានទូរស័ព្ទអាយហ្វូន ចំណូគា
ស៊ីមពីរ បីឡាញទំនើបសន្ទនា  ជាប់លេខគ្នាជាជាងខំសិក្សា ៗ
ពេលជាប់បាក់ឌុបឈប់វិទ្យាល័យ  ជ្រួលរញ៉េជ្រើមជ្រើសរើសសាលា
សកលភូមិន្ទភ្នំពេញអស្ចារ្យ  យកមហាវិទ្យាល័យផ្នែកច្បាប់ ៗ
ខ្លះថាយកអក្សរសាស្ត្រអង់គ្លេស  មិនយកទេក្រមបែបទ្រង់រៀនយ៉ាប់
ព័ត៌មានវិទ្យាកុំព្យូទ័រស្រាប់  សេដ្ឋកិច្ចហាប់ហំហិរញ្ញវត្ថុ ៗ
ចង់ច្រើនគឺពេទ្យស្រួលចាក់ថ្នាំលក់  កសិកម្មផ្នែកពេទ្យសត្វបសុ
ពេទ្យសើស្បែកធ្មេញក្រពះចក្ខុ  ហិរញ្ញវត្ថុ និងផ្នែកទីផ្សារ ៗ
នាសម័យនេះគេពេញនិយម  ប្រាក់ដូចភ្នំខ្ទាំងហ៉ាមពលសក្កា
គឺរបរពេទ្យក្លែតមានដូឡា  មាននរណាឈឺព្វហ៊ានតថ្លៃ ៗ
កូនអ្នកក្រត្រដររៀនដើម្បីរស់  ជាប់លក់ឈ្មោះបានលោះយកកម្រៃ
ស៊ូទ្រាំអត់ឃ្លានគ្មានត្រូវសំបៃ  ប្រឹងយប់ថ្ងៃគិតថ្ងៃក្រេងបានធូរ ៗ
អ្នកមានរៀនពេទ្យខ្វែតឡូយខ្លាំងណាស់ ក្រកម្មក្រាស់គឺច្បាស់ប្រឡងគ្រូ
រស់អត់ឃ្លានពិតជីវិតមិនធូរ  មិនគិតគូក្រេងយូរទៅអត់លិទ្ធ ៗ
បើជាប់ជាគ្រូបានធូរកន្ទល់  កុំទាត់ខ្យល់ដើរលេងណាអន្ទិត
គ្រូក្រប្រាក់តិចគ្មានគេគិត  មានគំនិតចាស់ព្រឹទ្ធតែងសរសើរ ៗ
ជីវិតត្រូវតែខំអភិវឌ្ឍ  ការងាររដ្ឋវិវត្តពិតគ្រាន់បើ
មនសិការស្តារជាតិទេតើ  ស្ម័គ្របម្រើប្រសើរឈ្មោះយូរយារ ៗ

## ក្មេងទំនើង

-ក្មេងទំនើង  តើងមិនខ្លាច  កាចខុសបទ
បានសន្មត់  កត់ត្រាចាំ  ឆ្នាំពីរពាន់
ប្រាំបួនមក  ភ្នកបំណាំ  ផ្តាំរួសរាន់
កុំកពភ័ន្ត  ទាន់នៅក្មេង  ឆ្វេងកុំធ្លាក់ ៗ
-ក្មេងទំនើង  ដើងវាយតប់  សព្វភូមិឋាន

មនុស្សគ្រប់ប្រាណ បានស្អប់ជ្រេញ ពេញគ្រោះថ្នាក់
ឆ្កែតអំពើ ល្ងើឥតត្រាប់ ច្បាប់ចាប់ដាក់
គុកច្រវាក់ បាក់មុខមាត់ ព្រាត់គ្រួសារ ។
-ផឹកតែស្រា ក្អាតតបី ស្តីមិនសម
មិនប្រឡុំ សមដូចគេ ជេរតវ៉ា
ខ្ជិលធ្វើការ ជាខឹងចិត្ត ផ្សិតទោសា
ឲ្យគ្រួសារ ប៉ានិងម៉ាក់ បាក់ទុក្ខធំ ។
-ចាយតែប្រាក់ ដាក់របស់ ថ្លោះទាំងខ្លួន
ពេលខ្វះពួន ជូនគេដេញ ស្មេញញ៉ើមញ៉ុម
ទ័លលួចឆក់ ធ្លាក់ទូរស័ព្ទ កាប់ជាក្រុម
មិនសុខុម ផ្តុំមានះ ផ្ទះមិននៅ ។
-ប្រើថ្នាំញៀន រៀនមិនខំ ចំទុក្ខធំ
ស្រានិយម ជុំជានិច្ច ភ្លេចសៀវភៅ
បោកប៉ោឡៃ ញ៉ែសង្វាត ស្អាតពងរៅ
សេពគប់ទៅ នៅទុក្ខា ជាមិនឈឺ ។

... ... ... ...

# ឯកសារយោង


១ កេង វ៉ាន់សាក់ គុកកាមកិលេស

២ កេង វ៉ាន់សាក់ មូលដ្ឋាននៃការបង្កើតពាក្យថ្មី ភ្នំពេញ ១៩៦៤

៣ កែវ សុវត្ថិ ចៅហ្វាយគុយ សារព័ត៌មានអង្គរបុរី ២០០៦

៤ ក្រសួងអប់រំ អក្សរសិល្ប៍ថ្នាក់ទី៧

៥ គីម សែត ប្រវត្តិអក្សរសាស្ត្រខ្មែរ ភ្នំពេញ ១៩៦៨

៦ គីម ពេជ្រពីរនន់ ភ្លេងការអភ័ព្វ សមាគមអ្នកនិពន្ធខ្មែរ ១៩៩៨

៧ គីម ហាក់ ទឹកទន្លេសាប ១៩៣៩

៨ គុយ ឡូត ព្រះបាទពញាយ៉ាត ១៩៦៦

៩ ឃីង ហុកឌី មាលីបទនៃអក្សរសាស្ត្រខ្មែរសតវត្សទី១៩ ២០០០

១០ ឃីង ហុកឌី មាលីបទនៃអក្សរសាស្ត្រខ្មែរសតវត្សទី២០ ២០០០

១១ ឃីង ហុកឌី សម្ពហកម្មអក្សរសាស្ត្រខ្មែរ ភ្នំពេញ
បណ្ណាគាអង្គរ ២០០៦

១២ ឃីង ហុកឌី បណ្តាំតាមាស បណ្ណាគារអង្គរ ២០០៧

១៣ ង៉ួន សោម អត្ថបទរឿងទុំទាវ ពុទ្ធសាសនបណ្ឌិត្យ ព.ស២៥១៤

១៤ ជា វណ្ណី ទុយ យូ ឃីម អក្សរសិល្ប៍ខ្មែរក្រោយអង្គរ ឯកសារប្រើប្រាស់ផ្ទៃក្នុង
ឆ្នាំ២០០៧

១៥ ជួន ណាត វចនានុក្រមខ្មែរភាគ១ ភាគ២ ភ្នំពេញ
វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ១៩៦៧

១៦ ជ័យ ចាប ជីវប្រវត្តិអ្នកនិពន្ធខ្មែរ ឯកសារប្រើប្រាស់ផ្ទៃក្នុង
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឆ្នាំ១៩៨៨

១៧ ញ៉ុក ថែម បញ្ញាសជាតក មហាវិទ្យាល័យអក្សរសាស្ត្រ និង
មនុស្សសាស្ត្រ ឆ្នាំ១៩៦៣

១៨ ញ៉ុក ថែម កុលាបប៉ៃលិន ឆ្នាំ១៩៦០

១៩ ណុន សុខា មូលដ្ឋានទ្រឹស្តីអក្សរសិល្ប៍ ភ្នំពេញ ២០០៧

២០ ណុន សុខា ចំណោទសម្រាយក្នុងអក្សរសិល្ប៍ខ្មែរ ភ្នំពេញ២០០៩

២១ ណុន សុខា លន់ ស៊ីនន់ ការវិវត្តន៍នៃអក្សរសិល្ប៍ខ្មែរ ឯកសារប្រើប្រាស់ផ្ទៃក្នុង
ឆ្នាំ២០០៩

២២ ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ១៩៧៣

២៣ ត្រឹង ងា អរិយធម៌ខ្មែរ ឆ្នាំ១៩៧៥

២៤ ថាច់ ត្វាន់ ប្រវត្តិសាស្ត្រប្រជាជាតិខ្មែរ បណ្ណាគារអង្គរ ២០០៧

២៥ ធ សោ អក្សរសិល្ប៍ពុទ្ធនិយម ភ្នំពេញ ១៩៩៤

២៦ ធ សោ អក្សរសិល្ប៍ខ្មែរព្រហ្មណ៍និយម ភ្នំពេញ ១៩៩៣

២៧ ប៊ី សុខគង់ ប្រភេទពាក្យក្នុងភាសាទំនើប ឆ្នាំ២០០២

២៨ ពុយ គា រដ្ឋាភិបាលកម្ពុជាពីឆ្នាំ១៩៤៥ ដល់ឆ្នាំ២០១០ រាហ៊ុ ឆ្នាំ ២០១០

២៩ ពុទ្ធសាសនបណ្ឌិត្យ ច្បាប់ក្រមង៉ុយ ឆ្នាំ១៩៧២

៣០ ពៅ សាមី លក្ខណៈទំនោរនៃអក្សរសិល្ប៍ និងសិល្បៈ ភ្នំពេញ១៩៨៧

៣១ ព្រះឃ្លាំង នង ភោគកុលកុមារ បណ្ណាគារអង្គរ ២០០៤

៣២ ព្រះអង្គឌួង កាកី ពុទ្ធសាសនបណ្ឌិត្យ ព ស ២៥៤១

៣៣ មជ្ឈមណ្ឌលនិពន្ធកម្មវិធី និងសៀវភៅសិក្សា កម្រងអត្ថបទអក្សរសិល្ប៍ថ្នាក់ទី៧ ឆ្នាំ៩៨២

៣៤ រឹម គីន មាលាដួងចិត្ត ឆ្នាំ១៩៧២

៣៥ រឹម គីន សូផាត ក្រសួងអប់រំយុវជន និងកីឡា ២០០២

៣៦ លន់ ស៊ីនន់ អក្សរសិល្ប៍ខ្មែរក្រោយសម័យអង្គរ ភ្នំពេញ២០០៧

៣៧ លាង ហាប់អាន ប្រវត្តិអក្សរសាស្ត្រខ្មែរ បណ្ណាគារតិម អេង ១៩៦៧

៣៨ លីតារាវុធ និង អ៊ីនគ្រីដ ប៉ូអាន់ កំណើតកុនខ្មែរ វ៉ៃយ៉ ឆ្នាំ២០០៩

៣៩ លី ធាមតេង អក្សរសាស្ត្រខ្មែរ ភ្នំពេញ ១៩៦៧

៤០ លី ធាមតេង អ្នកនិពន្ធខ្មែរដែលល្បីៗឈ្មោះ ១៩៧២

៤១ ស៊ីសុវត្ថិ ប៉ូរក្ខស៊ី បរិវាស័ព្ទក្នុងភាសាខ្មែរ សមាគមសម្តេចសង្ឃ ជួន ណាត ឆ្នាំ១៩៧៣

៤២ សុត្តន្តប្រីជា ឥន្ទ គតិលោកភាគទី៣ ពុទ្ធសាសនបណ្ឌិត្យ ព ស ២៥៣៩

៤៣ ស៊ុយ ហៀង វាសនានៃនាងណាត្រី មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ ឆ្នាំ១៩៩៩

៤៤ ស៊ុយ ហៀង ផ្ការីកផ្គពេយ ឆ្នាំ១៩៥២

៤៥ សួន សុរិន្ទ ព្រះអាទិត្យថ្មីរះលើផែនដីចាស់ ឆ្នាំ១៩៦១

៤៦ សំ សុភារិន្ទ សែនធូន់ ឆ្នាំ២០០៣

៤៧ សេង តារា មាសស្រោបនគរ ភាគ៤ បណ្ណាគារអង្គរធំ ២០០៧

៤៨ ហាក់ ឆៃហុក ប្រុសអប្រិយស្រីរងកម្ម បោះពុម្ពឡើងវិញឆ្នាំ២០០៤

៤៩ ហ៊ុ យ៉ាត ពពកខ្មៅ សមាគមអ្នកនិពន្ធខ្មែរ ឆ្នាំ១៩៩៩

៥០ អ៊ឹម ប៊ុក គ្រូបង្រៀនស្រុកស្រែ ក្រសួងអប់រំយុវជន និងកីឡា២០០២

| | | | |
|---|---|---|---|
| ៥១ | អ៊ុំ សុផានី | អ្នកណាជាម្ដាយខ្ញុំ? សមាគមអ្នកនិពន្ធខ្មែរនៅបរទេស ឆ្នាំ២០០០ | |
| ៥២ | អៀង ពិសី | វិធីសាស្ត្រក្នុងការសរសេរតែងសេចក្តី | IIC ២០០៨ |
| ៥៣ | អៀង ពិសី | ជីវិតថ្មី | IIC ២០០៨ |

៥៤ ឧកញ៉ាកោសាធិបតី កៅ ក្រុងសុកមិត្រ ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៩៨

៥៥ ឯកសារទស្សនាវដ្ដី វីរភាពរបស់ប្រជាជន និងកងទ័ពបដិវត្តន៍កម្ពុជា សម័យកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៦

៥៦ ការចុះសិក្សាមួយចំនួននៅតាមភូមិភាគដែលមានជាប់ទាក់ទងជាមួយប្រធានបទ